៩

# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៤១ ខែ កញ្ញា

ព.ស. ២៥១៣ គ.ស. ១៩៦៩

– ភ្នំពេញ –



សម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ

ជួន-ណាត ព្រះសង្ឃរាជថ្នាក់ទី១

ទ្រង់បានយាងចូលទីវង្គតពីថ្ងៃ ព្រហស្បតិ៍ ទី ២៥ កញ្ញា ១៩៦៩ វេលាម៉ោង ២០ និង ២០ នាទី នៅព្រះមហាកុដិ វត្តឧណ្ណាលោម ។

ទស្សនាវដ្ដីកម្ពុជសុរិយា និង វិជ្ជាប៉ានពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងបុគ្គលិកទាំងអស់ សូមឱនកាយសម្តែងសេចក្តីសោកវិយោគដ៏ក្រៀមក្រំបំផុត ចំពោះព្រះរាជទីវង្គតនេះ ។

៩

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ — ផ្នែកសាសនា — ទំព័រ


១— ទស្សនវិជ្ជាក្នុងសាសនា ព្រះមហាវីរិយបណ្ឌិតោ ហួត-តាត រៀបរៀង ៩០៣
២ [illegible] ភិក្ខុ [illegible] រៀបរៀង . . . ៩១៦


## ផ្នែកអក្សរសាស្ត្រ


៣— [illegible] រៀបរៀង . . . . ៩២៦
៤— [illegible] ហួត តាត . . . . ៩៣៣
៥— [illegible] (៥) [illegible] ប្រែរៀបរៀង . . . . ៩៣៧
៦— [illegible] ប្រែរៀបរៀង ៩៤៥
៧— ទំនុកបុរាណខ្មែរ [illegible] ប្រមូលក្រង . . . . ៩៦៣
៨— [illegible] ស្រាវជ្រាវ . . . . ៩៧១
៩— [illegible] ព្រះមហាវីរិយបណ្ឌិតោ ហួត-តាត រៀបរៀង. . ៩៨៧
១០— [illegible] . . ១០០២


## ផ្នែកកំណត់-ប្រវត្តិការណ៍


១១— [illegible]
[illegible] . . . ១០[illegible]

ក្រុមទាំងមាន ១២ សៀវភៅ តម្លៃជា ២៣០៛០០ ។

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ,
ឲ្យជុំសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ។

ប ព

# ទស្សនវិជ្ជាពុទ្ធសាសនា

ព្រះមហាវីរិយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង

## (តពីលេខមុន)

---

ថ្ងៃមួយ ព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចព្រះឥរិយាបថ អស់រាត្រីមួយ ក្នុងរោងកុម្ភការ ទ្រង់បានជួបប្រុសក្មេងម្នាក់ ដែលចូលមកនៅក្នុងរោងនោះមុនព្រះអង្គ ។ ព្រះអង្គក្តី ប្រុសក្មេងក្តី ទាំងពីរនាក់នេះ មិនបានស្គាល់គ្នាទេ ។ លុះទតព្រះនេត្រឃើញប្រុសក្មេងនោះហើយ ព្រះសម្ពុទ្ធទ្រង់ព្រះតម្រិះថា : "ចរិយាប្រុសនេះ ស្រគត់ស្រគំសមរម្យល្អណាស់ មើលទៅមុខគួរឲ្យជ្រះថ្លា គួរនឹងបានផលល្អ ប្រសិនបើតថាគតសាកសួរមើល" ។ ទ្រង់ព្រះតម្រិះហើយទ្រង់ត្រាស់ក្បាន់សួរថា :

„ម្នែប្រុស ! អ្នកចេញចាកផ្ទះហើយមកបួសនេះ តើអ្នកបួសចំពោះលោកណា? លោកណាជាសាស្តារបស់អ្នក? តើធម៌លោកនោះដូចម្តេច?

បានឮពុទ្ធដីកាហើយ ឫសីក្មេងនោះ ឆ្លើយតបពុទ្ធដីកាដោយអាការ ជា គ្នាធម្មតា ថា :

"នុសម្លាញ់អើយ ! មានឫសីមួយអង្គនាមថា គោតម ជាសាក្យ ដោយជាតិ ព្រះអង្គចេញចាកសាក្យត្រកូល ហើយមកបួសកាន់យក ភេទជាឫសី ព្រះអង្គមានកិត្តិនាមល្បីខ្ចរខ្ចាយខ្ទរទៅថា ជាព្រះអរហន្ត បានត្រាស់ដឹងធម៌ ជាសម្មាសម្ពុទ្ធ ខ្ញុំឮហើយជ្រះថ្លា ខ្ញុំចេញចាកផ្ទះ មកបួសកាន់យកភេទជាឫសីចំពោះព្រះអង្គ ព្រះអង្គជាសាស្តាខ្ញុំ ខ្ញុំពេញចិត្តចំពោះភេទៈរបស់ព្រះអង្គនោះ" ។

"ចុះព្រះអង្គ, ទ្រង់ត្រាស់សួរទៀត, ជាអរហន្ត ជាសម្មា-សម្ពុទ្ធ ដែលអ្នកយកធ្វើជាសាស្តាខ្លួនអ្នកនោះ ឥឡូវនេះទ្រង់គង់នៅ ទីណា ?

"នុសម្លាញ់អើយ !, ឫសីក្មេងឆ្លើយតបវិញ, បានឮថាមានអា-រាមមួយនៅឯឧត្តរប្រទេស ជិតក្រុង សាវត្ថី ព្រះអង្គជា អរហន្ត ជាសម្មាសម្ពុទ្ធ ជាសាស្តារបស់ខ្ញុំ ព្រះអង្គប្រថាប់នៅទីនោះ ។

"នែឫសីក្មេង !, ទ្រង់ត្រាស់បញ្ជាក់, ចុះអ្នកដែលបានឃើញ សាស្តារបស់អ្នកនោះដែរឬទេ ?

"ទេសម្លាញ់ !, ឫសីក្មេងបញ្ជាក់ទូល ខ្ញុំមិនដែលបានឃើញ ឬបាន

ជួបព្រះអង្គទេ កុំថាឡើយឃើញ គ្រាន់តែស្គាល់ព្រះអង្គ ខ្ញុំក៏មិនដែលតាំងបានស្គាល់ព្រះអង្គផង ” ។

ពេលនោះ ព្រះសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថា បុសីក្មេងនេះ បួសកាន់យកភេទជាតាបសចំពោះធម្មវិន័យព្រះអង្គ ទើបទ្រង់ត្រាស់ថា ៖

“ ឱភិក្ខុ ! តថាគតនឹងទេសនា អ្នកប្រុងស្តាប់ចុះ ! ” ។ តទៅទ្រង់សំដែង អរិយសច្ច ព្រោះប្រទាន ចប់ ធម្មកថា ហើយ បុសីក្មេងនោះបានលុះអរហត្តផល ។ ទីបំផុត តាំងអស់គ្នាបានស្គាល់ថា បុសីក្មេងនោះគឺ បុក្កុសាតិភិក្ខុ អ្នកប្រទានធម្មទេសនានោះ គឺអង្គព្រះសម្ពុទ្ធ ។ ពេលនោះ បុក្កុសាតិភិក្ខុ នទក្រាបទៀបបាទាអង្គព្រះសម្ពុទ្ធ ហើយលើកកម្ពង់អញ្ជលីក្រាបទូលសូមខមាទោស ដោយខ្ញុំពុំបានដឹងថាជាអង្គព្រះសម្ពុទ្ធ បានក្ងាត់ពោលពាក្យហៅព្រះអង្គថា “ សម្លាញ់ ” ។ តទៅ បុក្កុសាតិ ក្រាបទូលអង្គព្រះសម្ពុទ្ធ សុំបព្វជ្ជាជាភិក្ខុកង់សំណាក់ពុទ្ធសាសនា តែពេលនោះ បុក្កុសាតិ មិនមានត្រៃចីវរ មិនមានបាត្រ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់បង្គាប់ឲ្យរកត្រៃចីវររកបាត្រ តាមប្រពៃណីពុទ្ធសាសនា ។ បុក្កុសាតិ ក្រាបថ្វាយបង្គំលាព្រះសម្ពុទ្ធ ហើយដើរទៅស្វែងរកត្រៃចីវរនិងបាត្រ កំពុងតែដើរស្វែងរក មានគោញីមួយអកដល់លោក ហើយលោកធ្វើមរណកាលទៅ ។

តមកថ្ងៃក្រោយទៀត ព្រះសម្ពុទ្ធទ្រង់បានជ្រាបថា បុក្កុសាតិភិក្ខុ នោះគាញីដល់ហើយ ផ្ទើមរណកាលទៅហើយ ទើបទ្រង់ត្រាស់ថា: " បុក្កុសាតិភិក្ខុ នេះជាអ្នកប្រាជ្ញ បានឃើញអរិយសច្ចធម៌ហើយ បានដល់ឈានថ្នាក់ខ្ពស់ផុត ដែលត្រូវសម្រេចនិព្វានជាអរហន្ត និព្វានហើយមិនត្រឡប់មកកាន់ភពនេះទៀតទេ " ។

និទាននេះ បញ្ជាក់សេចក្ដីច្បាស់លាស់អស់ដើងហើយថា បុក្កុសាតិភិក្ខុ បានស្ដាប់ធម៌អង្គព្រះសម្ពុទ្ធ ហើយបានត្រាស់ដឹងធម៌ព្រះអង្គហើយ ។ ភិក្ខុ បុក្កុសាតិ នេះ មិនបានស្គាល់ថាអ្នកណាជាអ្នកសម្ដែងធម៌ដល់ខ្លួនទេ តែលោកស្ដាប់ហើយមានក្នុក ឃើញសច្ចធម៌ពិតប្រាកដ ។ បុក្កុសាតិភិក្ខុ បានឃើញធម៌ ហើយបានលុះអរហត្តផល ចូលនិព្វានទៀតតើបានដោយមានស្មាក ឬ យ៉ះហោ ? បើថ្នាំសក្តិសិទ្ធិហើយ ដម្មុខតែជាសះស្បើយពិតប្រាកដពុំខាន មិនបាច់ដឹងថាពេទ្យណាជាអ្នកផ្សំថ្នាំ ឬ ថ្នាំនោះបានមកពីលោកណាទេ ។ ដូច្នេះសច្ចធម៌ មិនពឹងផ្អែកទៅលើស្មាក ឬ យ៉ះហោឡើង ។

លទ្ធិសាសនាស្ទើរតែទាំងអស់ សុទ្ធតែកើតឡើងដោយជំនឿ-(Foi, croyance) យកជំនឿ ឬ "ជំនឿភ្លាក់" ទុកជាបានលទ្ធិសាសនា ហើយពឹងផ្អែកទៅលើព្រះអាទិទេព ព្រមទាំងលាក់ព្រះអាទិទេពនៅឯឋានសួគ៌ ហើយផ្សាយជំនឿឲ្យគេជឿតាម ។ ជំនឿបែបនេះ ជាជំនឿ

ឥតហេតុផល ជាជំនឿឥតបើគិត ។ ឯជំនឿក្នុងពុទ្ធសាសនា ផ្ទុយគ្នាស្រឡះ ជាជំនឿប្រកបដោយហេតុផល (Cause et effet) ជាជំនឿប្រកបទៅដោយវិចារណញ្ញាណ (Raisonnement) ពោលគឺសទ្ធា =ជំនឿដែលប្រកបដោយបញ្ញា Confiance= Confidence et sagesse = winsdom) ។ ជំនឿពុទ្ធសាសនានេះ សំដៅយក ៈ ការឃើញច្បាស់ ការដឹងច្បាស់, ការយល់ជាក់ច្បាស់ "មិនមែនសំដៅយកជំនឿបែប "Foi, Croyance; Faith, Belief" ដូចពាហិរសាសនាទាំងអស់នោះទេ ។ សព្វថ្ងៃនេះ យើងប្រើពាក្យត្រឡប់ច្របល់គ្នាណាស់ ដូចពាក្យថា "Religion" យើងប្រែថា "សាសនា" ឬពាក្យថា „ Foi, Croyance ជាបារាំង, Faith, Belief ជាអង់គ្លេស យើងប្រែថា „ជំនឿ ពោលគឺ សទ្ធា" តែសេចក្ដីពិត ពាក្យថា "សទ្ធា= ជំនឿ" ក្នុងពុទ្ធសាសនា មិនមែនមានអត្ថន័យដូចពាក្យ "Foi, Croyance; Faith, Belief" ក្នុងសទ្ធិសាសនាគ្រិស្ត ឥស្លាម ព្រាហ្មណ៍ នោះទេ ។ សទ្ធា = ជំនឿក្នុងពុទ្ធសាសនា ជាជំនឿបែប „ Confiance, Confidence" = ជំនឿដែលកើតចេញពីការជឿជាក់ (Conviction) ការជ្រះថ្លា (Joi ou sereine) ទុកជាសរណៈ ការទីពឹងប្រសើរ (Refuge) ដូចសទ្ធា ជឿជាក់ ជ្រះថ្លាចំពោះគុណព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាដើម ។ ការជឿជាក់ច្បាស់មិនកម្រើក, សេចក្ដីជ្រះ

ថ្វាចំពោះកុសលធម៌, ការទុកចិត្តដោយយល់ច្បាស់ថានឹងបានសម្រេចដូចបំណង ក៏លោកទុកថាជា សទ្ធា=ជំនឿដែរ ។ ធម៌ ២ ប្រការ គឺ សទ្ធា នឹង បញ្ញា ជាធម៌គូគ្នា គឺបើមានសទ្ធា ត្រូវមានបញ្ញា ។ អ្នកជឿ មិនមានបញ្ញានឹងដើរវង្វេងផ្លូវ ។ អ្នកមានសទ្ធា មិនប្រើបញ្ញាពិចារណារកខុសត្រូវ គិតតែពីជឿ នឹងធ្លាក់ទៅជាមនុស្សល្ងង់ ។ រីអ្នកមិនមានសទ្ធា មិនមានជំនឿទេ ធ្វើអ្វី ។ អាងបញ្ញាគិតពិចារណា បើបញ្ញាខ្លួនគិតចាក់មិនធ្លុះ នឹងធ្លាក់ខ្លួនទៅជាអ្នកយល់ខុស គឺទៅជាអ្នកមិច្ឆាទិដ្ឋិ ។ អ្នកដើរក្នុងលោកងងឹតនេះ ត្រូវប្រើធម៌ ២ ប្រការគឺ សទ្ធា នឹង បញ្ញានេះ នឹងខានពុំបានឡើយ ទើបដើរទៅមិនវង្វេងកណ្តាលអទ្ធា ។

សទ្ធា = ជំនឿ ដែលប្រកបដោយបញ្ញា ពិចារណាឃើញពិតដឹងពិត យល់ពិត នូវកិច្ចការអ្វីមួយដែលបុគ្គលត្រូវការធ្វើ ជាពលៈ = មានសទ្ធាពល មានកម្លាំងខ្លាំងបំផុត ជាហេតុនាំឲ្យសម្រេចសេចក្តីប្រាថ្នាពិតប្រាកដ ។ បុគ្គលដែលធ្វើកិច្ចការអ្វីមួយ ហើយមិនបានសម្រេចសមតាមក្តីប្រាថ្នា មិនមែនដោយខ្វះអ្វីទេ គឺខ្វះធម៌ ២ ប្រការនេះឯង ។

ព្រះបរមពោធិសត្វ ដែលបានសម្រេចភាវៈជាព្រះសម្ពុទ្ធ ក៏ដោយសទ្ធា ដែលប្រកបដោយបញ្ញា ចាប់ដើមតាំងពីទ្រង់តាំងព្រះទ័យកសាងបារមីធម៌ ឲ្យបានសម្រេចសម្មាសម្ពោធិញាណ ។ សទ្ធានេះហៅថា

អាគមសទ្ធា ។

ព្រះអរហន្តគ្រប់អង្គ ក៏មានសទ្ធាដែលប្រកបដោយបញ្ញា ទើបបានលុះធម៌ដែលព្រះសម្ពុទ្ធទ្រង់សម្តែងទុកមក ។ សទ្ធានេះ ហៅថា អធិគមសទ្ធា ។

ឯការជឿជាក់ច្បាស់ មិនកម្រើកចំពោះគុណព្រះរត្នត្រ័យ ក៏ដោយសទ្ធាដែលប្រកបដោយបញ្ញាដែរ ។ សទ្ធានេះ ហៅថា ឱកប្បនសទ្ធា ។

ចិត្តដែលជ្រះថ្លាចំពោះអំពើជាកុសល ដោយបានយកបញ្ញាពិចារណាឃើញពិត ដឹងពិត យល់ពិត ថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ នេះហៅថា បសាទសទ្ធា ។

សទ្ធាដែលប្រកបដោយបញ្ញានេះ ជាទ្រព្យដ៏ប្រសើររបស់មនុស្សក្នុងលោក សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ ជំនឿនេះ មានតម្លៃណាស់ ស្មើជីវិត មិនគួរនឹងជឿអ្វីៗ ឥតប៉ិះគិតទេ ។ បុគ្គលជឿឥតប៉ិះគិតនេះ មានទោសដល់ស្លាប់ ។ ដូច្នេះ ជំនឿផ្សេងៗ បែប Foi, Croyance; Faith, Belief តែងកើតឡើងតែក្នុងពេលណា ដែលគេមិនទាន់ឃើញពិត ដឹងពិត យល់ពិត, ក្នុងពេលណាដែលគេបានឃើញពិតបានដឹងពិតបានយល់ពិតហើយ ប្រស្នាជំនឿនេះនឹងលែងបាត់ទៅឯង ឧបមាថា មានមនុស្សម្នាក់មកនិយាយប្រាប់ថា "ខ្ញុំមានពេជ្រមួយគ្រាប់នៅក្នុងកាប់

ដៃខ្ញុំនេះក្នុងពេលដែលឮពាក្យនេះ” ប្រស្នាជំនឿទើបកើតឡើង ព្រោះមិនទាន់បានឃើញពេជ្រនោះ ដោយភ្នែកខ្លួនឯងនៅឡើយ គ្រាន់តែឮគេនិយាយប្រាប់ ។ កាលបើអ្នកនិយាយនោះលាក្តាប់ដៃបង្ហាញពេជ្រនោះហើយ យើងឃើញពេជ្រនោះដោយភ្នែក នឹងថាជាពេជ្រពិតមែនយល់ច្បាស់ថាជាពេជ្រពិតមែន ពេលនោះប្រស្នាជំនឿបែប Foi, Croyance; Faith, Belief រលត់បាត់ឯងលែងកើតមានទៀតហើយ ។ សេចក្តីនេះដូចជារឿងដែលយើងធ្លាប់បានឮមកថា ” បានសម្រេច ដូចជាគេបានឃើញពេជ្រនៅលើបាតដៃ ,, ។ ដូច្នេះ គួរគប្បីយល់ថា ជំនឿដែលកើតមានឡើង កើតមានតែក្នុងពេលណា ដែលយើងមិនទាន់ឃើញ មិនទាន់ដឹង មិនទាន់យល់ បើឃើញហើយដឹងហើយ យល់ច្បាស់ហើយ ប្រស្នាជំនឿនេះនឹងបាត់ទៅឯងវិញ មិនមានជាប្រស្នាចោទឡើងទៀតទេ ក្នុងគម្ពីរបាលីពុទ្ធសាសនា មាននិទានជាឧទាហរណ៍ច្រើនអន្លើណាស់ សម្រាប់បញ្ជាក់សេចក្តីខាងលើនេះ ដូចនិទានតទៅនេះ (១) ។

សម័យមួយ ព្រះ មុសិលត្ថេរ គង់នៅវត្ត ឃោសិតារាម ជិតក្រុង កោសម្ពី មានថេរដីកាចំពោះព្រះបវិដ្ឋត្ថេរ ថា :

“ អាវុសោ បវិដ្ឋ ! បើបុគ្គលណាមួយមិនមានធម៌ ៥ ប្រការ:

-សទ្ធា = ជំនឿ គឺជំនឿទៅតាមធម្មតា តាមអត្តានុរូបរបស់

១- សំយុត្តនិកាយ និទានវគ្គ សៀវភៅទី ៣១ ទំព័រ ២៥៧ ។

សព្ទថា "សទ្ធា,, មានអត្ថន័យដូច Dévotion, Foi, Croyance; Faith, Belief

- រុចិ = ការពេញចិត្ត (Penchant ou inclination= Liking or inclination)

- អនុស្សវ = ការឮតៗគ្នា (Oui-dire ou tradition= Hearsay or tradition)

- អាការបរិវិតក្កា = ការត្រិះរិះដោយអាការ (Considérer les raisons apparentes= Considering apparent reason)

- ទិដ្ឋិនិជ្ឈានក្ខន្តិ = ការពេញចិត្តតាមការយល់ឃើញ (Se complaire dans les spéculations des opinions= Delight in the speculations of opinions)

ខ្ញុំដឹងថា ខ្ញុំឃើញថា ជរា ព្យាធិ មរណៈ រលត់ព្រោះជាតិរលត់, ជាតិរលត់ ព្រោះភពរលត់, ភព រលត់ ព្រោះ ឧបាទាន រលត់, ឧបាទាន រលត់ ព្រោះ តណ្ហា រលត់, តណ្ហា រលត់ ព្រោះ វេទនា រលត់, វេទនា រលត់ ព្រោះ ផស្ស រលត់, ផស្ស រលត់ ព្រោះសឡាយតនរលត់, សឡាយតនរលត់ ព្រោះ នាមរូបរលត់, នាមរូបរលត់ ព្រោះ វិញ្ញាណរលត់, វិញ្ញាណ រលត់, ព្រោះ សង្ខារ រលត់, សង្ខារ រលត់ ព្រោះ អវិជ្ជា រលត់ ។

"អាវុសោ មុសិល! ព្រះបវិដ្ឋត្រូវសួរបញ្ជាក់, បើមិនមានធម៌ ៥ ប្រការខាងលើនេះ តើ មុសិលមានអាយុ មានញាណឃើញច្បាស់ក្នុងខ្លួនថា ភពរលត់ ភវនិរោធ គឺនិព្វាន ដូច្នេះឬ ?

"អាវុសោ បវិដ្ឋ, ព្រះមុសិលត្រូវតប, បើមិនមានធម៌ ៥ ប្រការនេះទេខ្ញុំដឹង ខ្ញុំឃើញថា "ការរលត់ ជានិព្វាន = ភវនិរោធោនិព្វានំ,, ។

" អាយស្មា មុសិល! ព្រះ បវិដ្ឋត្ថេរ បញ្ជាក់ថែមទៀត, បើដូច្នោះមានតែ មុសិល ដ៏មានអាយុ ជាព្រះអរហន្តខីណាស្រពឬ?

កាលព្រះ បវិដ្ឋត្ថេរ សួរបញ្ជាក់ថែមទៀតយ៉ាងនេះហើយ ព្រះមុសិលត្ថេរ គង់នៅស្ងៀម មិនទាំតតទៅទៀត ។

សទ្ធានេះ មិនមាននៅសន្ដានចិត្តព្រះអរហន្តទេ ដូចសេចក្ដីតទៅនេះ (១) ។

សម័យមួយ ព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចឥរិយាបថ នៅវត្តជេត-វនារាម ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ជិតក្រុងសាវត្ថី ។ កាលនោះ ព្រះសម្ពុទ្ធមិលមើលឃើញឧបនិស្ស័យភិក្ខុ ៣០ រូប ទ្រង់ប្រារព្ធបញ្ចិន្ទ្រិយ ហើយត្រាស់ចំពោះព្រះ សារីបុត្ត ថា :

" សារីបុត្ត! អ្នកមាន សទ្ធា = ជំនឿចំពោះសទ្ធិន្ទ្រិយ ដែល

---

១- [illegible] ។

តថាគតបានការនោះហើយ ចុះសិប់ក្ខ អមតនិញ្វាណ មានអមតនិញ្វាណ ជាបរិយោសានដែរឬទេ ? ។

"សូមទ្រង់ព្រះមេត្តាប្រោស! ព្រះសារីបុត្តត្ថេរ ទូលតបព្រះពុទ្ធដីកា ខ្ញុំព្រះអង្គមិនលុះដោយសទ្ធាអង្គព្រះមានព្រះភាគថា "សទ្ធិន្ទ្រិយ ។ល។ មាន អមតនិញ្វាណ ជាបរិយោសាន,, ដូច្នេះទេ ។

"សូមទ្រង់ព្រះមេត្តាប្រោសបុគ្គលណា មិនបានដឹង មិនបានសិក្សា មិនបានឃើញ មិនបានត្រាស់ដឹង មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានប៉ះពាល់សេចក្តីនេះដោយបញ្ញាខ្លួនឯងទេ បុគ្គលនោះតែងលុះដោយសទ្ធានៃបុគ្គលដទៃថា សទ្ធិន្ទ្រិយ ដែលបុគ្គលដទៃបានការនោះហើយ ។ល។ មាន អមតនិញ្វាណ,, ជាបរិយោសាន ដូច្នោះឯង ។

កាលនោះ ភិក្ខុទាំងឡាយបប្តូលគ្នានិយាយអឺងកងឡើងថា ព្រះសារីបុត្តត្ថេរ ក្រាបទូលតបស្នងព្រះពុទ្ធដីកាអំបាញ់មិញនេះ ដោយការយល់ឃើញខុសទេ ។ ថ្ងៃនេះ ព្រះសារីបុត្តត្ថេរ មិនមានសទ្ធាជឿអង្គព្រះសម្ពុទ្ធឡើយ ។ សេចក្តីនេះបានជ្រាបដល់ព្រះកាណ៌អង្គព្រះមានបុណ្យទើបទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា :

"ភិក្ខុទាំងឡាយ ! តថាគតសួរ សារីបុត្ត ថាបុគ្គលដែលមិនបានការនាបញ្ចិន្ទ្រិយ មិនបានចម្រើន សមថវិបស្សនា តើអាចធ្វើឲ្យជាក់ច្បាស់នូវមគ្គផលបានឬទេ ដូច្នេះទេតើ ។ ពេលនោះព្រះសារី-

បុត្ត ឆ្លើយតប មកតថាគតវិញថា :

“សូមទ្រង់ព្រះមេត្តាប្រោស ! ខ្ញុំព្រះអង្គមិនមានសទ្ធាជឿថា ''បុគ្គលនេះអាចធ្វើឲ្យជាក់ច្បាស់បាន, សារីបុត្ត មិនមានសទ្ធាជឿផលវិបាកដែលគេឲ្យ ឬ ផលវិបាកដែលគេធ្វើ, មិនមានសទ្ធាជឿគុណព្រះអរិយបុគ្គល មានអង្គព្រះសម្ពុទ្ធជាដើមដូច្នេះទេ ,, ។ សារីបុត្ត មិនមានសទ្ធាយ៉ាងនេះព្រោះ សារីបុត្ត បានឈាន វិបស្សនា មគ្គផលខ្លួនឯងហើយ មិនលុះដោយសទ្ធានៃអ្នកដទៃទៀតទេ ។ ដូច្នេះអ្នកទាំងឡាយ មិនគួរលើកទោស សារីបុត្តឡើយ មានពុទ្ធដីកាហើយទ្រង់ត្រាស់ថា :

អស្សទ្ធោ អកតញ្ញូ ច សន្ធិច្ឆេទោ ច យោ នរោ
ហតាវកាសោ វន្តាសោ ស វេ ឧត្តមបោរិសោ ។

លោកណាអស់សទ្ធា បានលុះនិព្វាន អស់កំណើត អស់ពូជបុណ្យបាប
មានករណីយកិច្ចធ្វើហើយ លោកនោះ ជាឧត្តមបុរស

សេចក្តីនេះ បញ្ជាក់យ៉ាងច្បាស់លាស់ថា: ''ព្រះអរហន្ត មិនមានសទ្ធាទេ ព្រះអរហន្តលះបង់ចោលសទ្ធាអស់ហើយ” ។ មួយទៀត សេចក្តីនេះ បញ្ជាក់ច្បាស់លាស់ថា: “ព្រះសម្ពុទ្ធមានព្រះទ័យទូលំទូលាយណាស់ ទ្រង់ប្រទានសេរីភាពដ៏បរិបូណ៌ដល់សាវកព្រះអង្គ សាវកព្រះអង្គអាចពោល

ដោយសេរីចំពោះព្រះភក្ត្រព្រះសាស្តារបស់ខ្លួន តាមសេចក្តីពិតដែមាខ្លួនបានឃើញពិត ,, ។ ព្រះសម្ពុទ្ធតែងទ្រង់ត្រាស់ថា(១) :

ភិក្ខុទាំងឡាយ ! បុគ្គលណាបានកំចាត់បង់នូវឆន្ទរាគ និង ឧបកិលេសអស់លើងហើយ បុគ្គលនោះ បានឃើញ មិនបានដឹង មិនបានយល់ច្បាស់ នោះឥតអត្ថិមានឡើយ ។

ប្រស្នាសទ្ធា=ដំនឿ នេះ និយាយចំពោះតែការឃើញច្បាស់ដឹងច្បាស់តែប៉ុណ្ណោះទេ មិនមែននិយាយពីដំនឿតាមធម្មតានោះទេ ។ សេចក្តីនេះ ព្រះសម្ពុទ្ធបានថ្លែងបញ្ជាក់ដោយពុទ្ធវចនៈថា "ឯហិ បស្សិកោ បានសេចក្តីថា ចូរអ្នកចូលមក ! ហើយមើលដោយខ្លួនឯងចុះ" មិនមែនហៅឲ្យចូលមក ហើយឲ្យជឿដូចពាហិរសាសនាទាំងឡាយទេ ។

(នៅមានត)

---

១-សំយុត្តនិកាយ កិលេសសំយុត្ត សៀវភៅទី ៣៤, ទំព័រ ១៧៥ ។

# អដ្ឋង្គិកមគ្គកថា

ភិក្ខុ លាម - សារុន ហៅ ហាន និស្សិតពុទ្ធិកសកល-
វិទ្យាល័យព្រះសីហនុរាជ រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ពេលនេះ សូមសម្ដែងអំពី អដ្ឋង្គិកមគ្គ ដោយសង្ខិត-ន័យ ដូចតទៅនេះ ៖

ពាក្យថា អដ្ឋង្គិកមគ្គ ប្រែថា មគ្គប្រកបដោយអង្គប្រាំបី បានសេចក្ដីថា ធម៌ ៨ យ៉ាង សម្រាប់ពួកសត្វប្រតិបត្តិ ដើម្បីឆ្ពោះទៅរកព្រះនិព្វាន ។

មគ្គ ៨ យ៉ាងនោះគឺ ៖

| | |
|---|---|
| ១- សម្មាទិដ្ឋិ | ការយល់ឃើញត្រូវ |
| ២- សម្មាសង្កប្បៈ | សេចក្ដីត្រិះរិះត្រូវ |
| ៣- សម្មាវាចា | វាចាត្រូវ |
| ៤- សម្មាកម្មន្តៈ | ការងារត្រូវ |
| ៥- សម្មាអាជីវៈ | ការចិញ្ចឹមជីវិតត្រូវ |
| ៦- សម្មាវាយាមៈ | ការព្យាយាមត្រូវ |
| ៧- សម្មាសតិ | សេចក្ដីរលឹកត្រូវ |
| ៨- សម្មាសមាធិ | ការតម្កល់ចិត្តត្រូវ |

បណ្ដាមគ្គទាំង ៨ នេះ, មគ្គ ទី ១ គឺ, សម្មាទិដ្ឋិ ជាប្រធានលើ មគ្គ ទាំងអស់ ព្រោះថា បើបុគ្គលមាន សម្មាទិដ្ឋិហើយ, មគ្គ ដទៃទៀតទើបកើតឡើងជាលំដាប់លំដោយ, សមដូចព្រះពុទ្ធដីកាថា តត្រ ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ម្នាលភិក្ខុទាំងឡាយ បណ្ដាមគ្គទាំង ៨ នោះ សម្មាទិដ្ឋិ ជាធម្មជាតិដល់មុន (ជាប្រធាន) ។

តើសម្មាទិដ្ឋិជាប្រធានដូចម្ដេច ?

មុនដំបូង ត្រូវស្គាល់ឲ្យច្បាស់នូវពាក្យថា សម្មាទិដ្ឋិសិន សម្មាទិដ្ឋិ ប្រែថា ទិដ្ឋិត្រូវ, ការយល់ឃើញត្រូវ

គម្ពីរមហាចត្តារីសកសូត្រ លោកសម្ដែងថា មិច្ឆាទិដ្ឋិ មិច្ឆាទិដ្ឋីតិ បជានាតិ សម្មាទិដ្ឋិ សម្មាទិដ្ឋីតិ បជានាតិ អយំ សម្មាទិដ្ឋិ ហោតិ ។ ប្រែថា បុគ្គលដឹងច្បាស់នូវមិច្ឆាទិដ្ឋិថាជា មិច្ឆាទិដ្ឋិ, ដឹងច្បាស់នូវសម្មាទិដ្ឋិថាជាសម្មាទិដ្ឋិ, ការដឹងនេះ ឈ្មោះថាសម្មាទិដ្ឋិ ។ ន័យនេះ សមនឹងពាក្យខ្មែរថា ដឹងខុស ថាខុស ដឹងត្រូវថាត្រូវ, ការដឹងបែបនេះ ឈ្មោះថាយល់ត្រូវ ។

តើដឹងនូវមិច្ឆាទិដ្ឋិ ថាជាមិច្ឆាទិដ្ឋិដូចម្ដេច ?

មិច្ឆាទិដ្ឋិ គឺទិដ្ឋិខុស គឺការយល់ឃើញខុស សំដៅយក នត្ថិកទិដ្ឋិ ឬ មិច្ឆត្តនិយតិ

១- នត្ថិ ទិន្នំ ទានដែលបុគ្គលឲ្យហើយមិនមានផល

២- នត្ថិ យិដ្ឋំ ការបូជាតូច មិនមានផល

៣- នត្ថិ ហុតំ ការបូជាធំ មិនមានផល

៤- នត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ មិនមានផលវិបាករបស់កម្មដែលសត្វធ្វើហើយល្អ និង អាក្រក់ទេ

៥ នត្ថិ អយំ លោកោ លោកនេះ មិនមាន

៦- នត្ថិ បរោ លោកោ លោកដទៃ មិនមាន

៧- នត្ថិ មាតា មាតា មិនមានគុណ

៨ នត្ថិ បិតា បិតា មិនមានគុណ

៩- នត្ថិ សត្តា ឱបបាតិកា សត្វជាឱបបាតិកៈ កំណើត មិនមាន

១០- នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ មិនមានពួកសមណព្រាហ្មណ៍ក្នុងលោក ដែលព្រមព្រៀងប្រតិបត្តិ ត្រូវដឹងយ៉ាងចម្លែកហើយ ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយខ្លួនឯង ហើយត្រាស់ដឹងនូវលោកនេះ និងលោកដទៃទេ ។

ការដឹងច្បាស់ថា ការយល់បែបនេះ ជាការយល់ឃើញខុស

ហៅថា ការដឹងនូវមិច្ឆាទិដ្ឋិ ថាជា មិច្ឆាទិដ្ឋិ ។

ការដឹងនូវសម្មាទិដ្ឋិ ថាជា សម្មាទិដ្ឋិ តើដូចម្តេច ?

សម្មាទិដ្ឋិ មាន ២ យ៉ាងគឺ លោកិយសម្មាទិដ្ឋិ ១ លោកុត្តរសម្មាទិដ្ឋិ ១

១– លោកិយសម្មាទិដ្ឋិ គឺការយល់ឃើញរបស់បុថុជ្ជនទិងសេខបុគ្គល សំដៅយកសម្មាទិដ្ឋិប្រកបដោយអាសវៈ ជាចំណែកបុណ្យ ឲ្យផលជាឧបធិកិលេស គឺយល់ច្បាស់ក្នុងរឿង ១០ យ៉ាង គឺ

១– អត្ថិ ទិន្នំ ទានដែលបុគ្គលឲ្យហើយ មានផល

២– អត្ថិ យិដ្ឋំ ការបូជាតូច មានផល

៣– អត្ថិ ហុតំ ការបូជាធំ មានផល

៤– អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ ផលវិបាករបស់កម្ម ដែលសត្វធ្វើហើយ ល្អនិងអាក្រក់មាន

៥– អត្ថិ អយំ លោកោ លោកនេះ មាន

៦– អត្ថិ បរោ លោកោ លោកដទៃ មាន

៧– អត្ថិ មាតា មាតាមានគុណ

៨– អត្ថិ បិតា បិតាមានគុណ

៩– អត្ថិ សត្តា ឱបបាតិកា សត្វជាឧបបាតិកៈ កំណើតមាន

១០ អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលព្រមព្រៀងប្រតិបត្តិត្រូវ ដឹងយ៉ាងចម្លែកហើយ ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដោយខ្លួនឯង ហើយត្រាស់ដឹងនូវលោកនេះនិងលោកដទៃមាន ។ ការដឹងច្បាស់ថា ការយល់បែបនេះ ជាការយល់ឃើញត្រូវ ហៅថា ដឹងនូវសម្មាទិដ្ឋិ ថាជាសម្មាទិដ្ឋិ ។

២– លោកុត្តរសម្មាទិដ្ឋិ សំដៅយកទិដ្ឋិរបស់ព្រះអរិយបុគ្គល ដែលមិនមានអាសវៈ, ជាលោកុត្តរៈ មានពុទ្ធដីកាក្នុងមហាចត្តារីសកសូត្រថា យោ ខោ ភិក្ខវេ អរិយចិត្តស្ស អនាសវចិត្តស្ស អរិយមគ្គង្គិនោ អរិយមគ្គំ ភាវយតោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ សម្មាទិដ្ឋិ មគ្គង្គំ អយំ ភិក្ខវេ សម្មាទិដ្ឋិ អរិយា អនាសវា លោកុត្តរា មគ្គង្គា ម្នាលភិក្ខុទាំងឡាយ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ធម្មវិចយសម្ពោជ្ឈង្គ សម្មាទិដ្ឋិ អង្គនៃមគ្គរបស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តមិនមានអាសវៈ, អ្នកបរិបូណ៌ដោយអរិយមគ្គ, ម្នាលភិក្ខុទាំងឡាយ នេះ ឈ្មោះថា សម្មាទិដ្ឋិដ៏ប្រសើរមិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គ ។

កាលដែលបុគ្គលមានសម្មាទិដ្ឋិហើយ រមែងមានចិត្តជាកុសល ជឿបុណ្យ បាប គុណ ទោស ល្អ អាក្រក់ ហេតុផល របស់ខ្លួនឲ្យតាំងនៅក្នុងសុចរិត មានទានសីលភាវនាជាដើម ហើយប្រឹងលះបង់អកុសលកម្ម ៗ សម្មាទិដ្ឋិនេះហើយដែលអាចបំភ្លឺសត្វលោក ឲ្យឃើញពន្លឺអរិយសច្ច ៤ គឺ

១– ទុក្ខៈ សេចក្ដីទុក្ខលំបាក គឺអត់ទ្រាំទីងក្នុងទុក្ខ ក្នុងកិលេស មានជាតិ ជរា មរណៈ ជាដើម

២– ទុក្ខសមុទយៈ តណ្ហាជាមេបណ្ដាលឲ្យកើតទុក្ខ

៣– ទុក្ខនិរោធៈ សេចក្ដីរលត់ទុក្ខ គឺព្រះនិព្វាន

៤– ទុក្ខនិរោធគាមិនីបដិបទា មជ្ឈិមបដិបទា (ផ្លូវកណ្ដាល) នាំឲ្យទៅកាន់រលត់ទុក្ខ ៗ

បើមានសម្មាទិដ្ឋិហើយ សម្មាទិដ្ឋិអាចបំភ្លឺក្នុងសម្មាសង្កប្បៈ គឺការត្រិះរិះត្រូវ មាន ៣ យ៉ាងគឺ ៖

១– នេក្ខម្មសង្កប្បៈ សេចក្ដីត្រិះរិះក្នុងការចេញចាកកាម គឺការចេញបួស

២– អព្យាបាទសង្កប្បៈ សេចក្ដីត្រិះរិះក្នុងការមិនព្យាបាទ គំគុំគំគួន

៣– អវិហឹសាសង្កប្បៈ សេចក្ដីត្រិះរិះក្នុងការមិនបៀតបៀនគេ

សម្មាសង្កប្បៈ ជាពន្លកនៃ សម្មាវាចា គឺ ការពោលពាក្យត្រូវ មាន ៤ យ៉ាងគឺ

១- មុសាវាទា វេរមណី ការវៀរចាកពាក្យកុហក

២- បិសុណាយ វាចាយ វេរមណី ការវៀរចាកពាក្យញុះញង់

៣- ផរុសាយ វាចាយ វេរមណី ការវៀរចាកពាក្យទ្រគោះបោះបោកគម្រោះគម្រើយ

៤- សម្ផប្បលាបា វេរមណី ការវៀរចាកពាក្យពេលរាយឥតប្រយោជន៍ ។

សម្មាវាចា ជាពន្លកនៃសម្មាកម្មន្តៈ គឺការងារត្រូវ មាន ៣ យ៉ាង គឺ

១- បាណាតិបាតា វេរមណី ការវៀរចាកការសម្លាប់សត្វ

២- អទិន្នាទានា វេរមណី ការវៀរចាកការកាន់យកវត្ថុដែលគេមិនបានឲ្យ

៣- កាមេសុ មិច្ឆាចារា វេរមណី ការវៀរចាក ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

សម្មាកម្មន្តៈ ជាពន្លកនៃសម្មាអាជីវៈ គឺការចិញ្ចឹមជីវិតត្រូវ បើជាគ្រហស្ថ បានខានការៈវៀរចាកជំនួញខុស ៥ យ៉ាង ការកែបំបាត់,

ការលំអៀងអគតិ, ហើយចិញ្ចឹមជីវិតដោយសុចរិត យុត្តិធម៌, បើជាបព្វជិតបានខានការលះបង់ មិច្ឆាជីវៈ គឺការចិញ្ចឹមជីវិតខុស ដោយអនេសនបាបធម៌ មានទូតកម្ម វេជ្ជកម្មជាដើម ហើយចិញ្ចឹមជីវិត ដោយបច្ច័យដែលកើតដោយធម៌ ។

សម្មាអាជីវៈ ជាពន្លឺដល់ សម្មាវាយាមៈ គឺការព្យាយាមត្រូវ មាន ៤ យ៉ាងគឺ

១– សំវរប្បធាន ព្យាយាមរាំង មិនឲ្យអកុសលធម៌កើតឡើងបាន

២– បហានប្បធាន ព្យាយាមលះអកុសលធម៌ដែលមាននៅក្នុងខ្លួនសន្តានហើយ ឲ្យសាបសូន្យទៅ

៣– ភាវនាប្បធាន ព្យាយាមបំពេញកុសលធម៌ ឲ្យចម្រើនរឹងប៉ឹងក្នុងខ្លួនសន្តាន

៤– អនុរក្ខនាប្បធាន ព្យាយាមរក្សាឃុំគ្រង កុសលធម៌ដែលបានធ្វើហើយ ឲ្យបានគង់វង់ ។

សម្មាវាយាមៈ ជាពន្លឺក្នុង សម្មាសតិ គឺការរលឹកត្រូវ មាន ៤ យ៉ាងគឺ

១– កាយានុបស្សនាសតិប្បដ្ឋាន ការតាំងស្មារតីពិចារណារឿយៗ ក្នុងកាយ

២- វេទនានុបស្សនា សតិប្បដ្ឋាន ការតាំងស្មារតីពិចារណារឿយ ៗ ក្នុងវេទនា

៣- ចិត្តានុបស្សនាសតិប្បដ្ឋាន ការតាំងស្មារតីពិចារណារឿយ ៗ ក្នុងចិត្ត

៤- ធម្មានុបស្សនាសតិប្បដ្ឋាន ការតាំងស្មារតីពិចារណារឿយ ៗ ក្នុងធម៌ ។

សម្មាសតិ ជាពន្លឺក្នុង សម្មាសមាធិ គឺ ការតម្កល់ចិត្តត្រូវ ក្នុងឈាន ៤ ដែលស្ងប់ស្ងាត់ចាកកាមតាំងឡាយ, ចាកអកុសលធម៌ ហើយលះនូវអង្គ តាមលំដាប់លំដោយគឺ

១- បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតពីវិវេក ។

២- ទុតិយជ្ឈាន រម្ងាប់វិតក្កៈ វិចារៈថ្លាល្អ មានបីតិនិងសុខ ដែលកើតពីវិវេក ។

៣- តតិយជ្ឈាន ប្រាសចាក បីតិ ប្រកបដោយសុខៈនិងឧបេក្ខា ។

៤ ចតុត្ថជ្ឈាន លះបង់សុខទុក្ខ មិនមានសោមនស្សទោមនស្ស មានសតិប្រកបដោយឧបេក្ខាដ៏បរិសុទ្ធ ។

សម្មាសមាធិ ជាពន្លឺ ដល់សម្មាញាណៈ គឺការដឹងត្រូវ ៗ

សម្មាញាណៈ ជាពន្លឺដល់សម្មាវិមុត្តិ ការរួចស្រឡះគឺព្រះនិព្វាន ។

ការសម្ដែងអំពី អដ្ឋង្គិកមគ្គ ដោយសង្ខេបចប់ត្រឹមតែប៉ុណ្ណេះ ។

(ស្រង់ពីសៀវភៅធម្មទាន បោះពុម្ពចែក ក្នុងឱកាសសំលាយសព
ព្រះសុមេធាវង្ស ច្រាជ ប៉ុល វត្តឧណ្ណាលោម )

# វិចារណកថា

## រឿងអាប៉ូឡូទី ១១ របស់អាមេរិកាំង

សតវត្សទី ២០នេះ ពិសេសគឺផ្នែកអឌ្ឍសតវត្សទី ២ បានត្រូវគេកំណត់ទុកជាសតវត្សប្រកបដោយវឌ្ឍនភាព ខាងវិទ្យាសាស្ត្រនិងខាងបច្ចេកទេសថ្នាក់កម្រិតកំពូល ដែលមនុស្សលោកមិនធ្លាប់បានស្គាល់ម្តងណាសោះចាប់តាំងពីសម័យមុនមានប្រវត្តិសាស្ត្រ និងមានប្រវត្តិសាស្ត្រមកម៉្លេះ ដោយតែវឌ្ឍនភាពខាងវិទ្យាសាស្ត្រនិងខាងបច្ចេកទេសផ្សេងៗ មានអវកាសយានប្រកបដោយល្បឿនលឿនជាងសម្លេង វិទ្យុ ទូរទស្សន៍ គ្រាប់បែកបរមាណូ ។ល។ ចេញ មានសមិទ្ធិមួយដ៏អស្ចារ្យបំផុតនៃមនុស្សលោក គឺយានអវកាសដែលអាចបង្ហោះឲ្យទៅចុះចតនៅលើឋានព្រះចន្ទបាន ជាឋានដែលមនុស្សលោកមិនដែលយល់សប្ត មិនដែលនឹកស្មានថានឹងមានមនុស្សអាចនឹងបានទៅដល់ម្តងណាសោះឡើយ ។ យានអវកាសនេះជារបស់ជនជាតិអាមេរិកាំង ឈ្មោះអាប៉ូឡូទី ១១ ដែលមានមនុស្សបីនាក់ជិះក្នុងនោះគឺឈ្មោះអាំស្ត្រុង ១ អេដវិនអាល់ឌ្រិន ១ មីកាអែលខុលីន ១ ។

ជនក្លាហានទាំងបីរូបនេះ បានជិះអាប៉ូឡូទី ១១ ដែលមានអ្នកប្រាជ្ញម្នាក់ជាជនជាតិអល្លឺម៉ង់ ហើយដែលត្រូវអាមេរិកាំងចាប់យកមកឲ្យនៅក្នុងប្រទេសរបស់ខ្លួន ខាងក្រោយសង្គ្រាមលោកលើកទី ២ ជាអ្នកធ្វើ

ហោះទៅកាន់ឋានព្រះចន្ទនៅថ្ងៃទី ១៦ កក្កដា ១៩៦៩ ហើយបានទៅចុះចតលើឋានព្រះចន្ទមុនគេបង្អស់នៅថ្ងៃចន្ទទី ២១-៧-៦៩ ពេលម៉ោង ៣ព្រឹកទៀបភ្លឺ ។ ចម្ងាយពីផែនដីទៅព្រះចន្ទ មានចំនួន ៣៨៤.៤០០ គីឡូម៉ែត្រ សូមបញ្ជាក់ថា អ្នកទាំងបីនាក់នេះពុំបានចុះទាំងអស់គ្នាទៅលើព្រះចន្ទទេ គឺមានតែពីរនាក់ប៉ុណ្ណោះដែលបានចុះទៅលើព្រះចន្ទ គឺអាំស្ត្រុង និង អេដវិនអាល់ឌ្រិន តាមបន្ទប់យានអវកាសមួយឈ្មោះ "ឡេម" ផ្ដាច់ចេញពីយានអវកាសធំចំណែកឯមិកាអែលខុលិន នៅហោះរង់ចាំពីខាងលើជាមួយយានអវកាស ។ ឯជនទាំងពីរនាក់នោះចុះនៅលើឋានព្រះចន្ទក្នុងរយៈពេលតែជាងពីរម៉ោងប៉ុណ្ណោះដោយការប្រុងប្រយ័ត្នជាទីបំផុត រួចនាំគ្នាប្រមូលយកវត្ថុផ្សេងៗ ពីឋានព្រះចន្ទបានចំនួន ៥០០ មុខ មានទម្ងន់ទាំងអស់ ៣១ គីឡូក្រាម ហើយក៏ប្រញាប់រត់ឡើងជិះយានពិសេសឈ្មោះ "ឡេម" ក៏ហោះត្រឡប់ទៅរកយានអវកាសធំ ដែលមានឈ្មោះខុល៊ីន កំពុងបង្ហោះរង់ចាំនៅពីខាងលើនោះ ។ លុះនាំគ្នាឡើងទៅជិះក្នុងយានអវកាសធំអស់ហើយ គេក៏ផ្ដាច់ម្ចាក់បន្ទប់ឡេមនៅលើឋានព្រះចន្ទទុកចោលនៅទីនោះ មិនតែប៉ុណ្ណោះ មុននឹងថយចេញពីព្រះចន្ទ គេបានទាំងដោតទុកនៅទីនោះ នូវទង់ជាតិអាមេរិកាំង ១ នូវប្រដាប់ផ្សេងដទៃទៀតពីរគ្រឿង (ប្រដាប់ថតសំឡេង ប្រដាប់ឆ្លុះឡូរទេសរង្ស៊ី) ជានិមិត្ត-រូបនៃជោគជ័យមនុស្សជាតិជាលើកដំបូងបំផុត (ក្នុងកក្កដានេះ) ។ រួច

គេនាំគ្នាបង្ហោះយានអវកាសវិលត្រឡប់មកវិញ បានមកចុះក្នុងមហាសា-
គរប៉ាស៊ីហ្វិក ក្បែរកោះមួយឈ្មោះហាវ៉ៃ នៅថ្ងៃព្រហស្បតិ៍ ២៤-៧-៦៩
ពេលម៉ោង១១ ប្លាយ តាមរយៈវេលាដែលគេបានកំណត់ទុកពីមុននោះៗ

រឿងនេះ មានការសង្កេតពិនិត្យ ឃើញថាមានពិតប្រាកដអ៊ីចឹងមែន
ព្រោះមុនបង្ហោះអាប៉ូឡូ ១១ ឲ្យទៅកាន់ឋានព្រះច័ន្ទ គេបានបង្កើតស្ថា-
នីយ ៧ កន្លែងសម្រាប់ចុះពិនិត្យតាមមើលថាទៅដល់មែន ឬមិនមែន ។
ឯស្ថានីយទាំងប្រាំពីរនោះ គឺ ពីរនៅប្រទេសអាមេរិក ពីរនៅប្រទេស
ជប៉ុន ពីរនៅប្រទេសអូស្ត្រាលី និងមួយនៅក្នុងទ្វីបអឺរ៉ុប ។ ដូច្នេះមិន
គប្បីសង្ស័យចំពោះរឿងនេះឡើយ ។ បានជាថាមិនគប្បីឲ្យសង្ស័យ
ព្រោះសហភាពសូវៀតក៏ត្រូវការប្រជែងប្រណាំង ក្នុងដំណើរទៅកាន់ឋាន
ព្រះច័ន្ទនេះដែរ ធ្វើម្ដេចនឹងបណ្ដោយឲ្យសហរដ្ឋអាមេរិកលេងល្បែងបួន
សន្ធឹកជាមួយខ្លួនបាន ។ ឥឡូវសហភាពសូវៀតក៏បានទទួលស្គាល់ថា
អ៊ីចឹងមែន ព្រមទាំងបានថ្លែងសេចក្ដីសរសើរ ចំពោះសហរដ្ឋអាមេរិកផង
ដែរទៀត ។

ចំពោះវឌ្ឍនភាពខាងវិទ្យាសាស្ត្រ និងខាងបច្ចេកទេស ត្រូវតែសរ-
សើរទទួលស្គាល់ថាយ៉ាងដូច្នេះមែន តែចំពោះសីលធម៌ សន្តិភាព
និងសង្គមកិច្ចវិញ មិនគួរសរសើរទាល់តែសោះ ។ ពួកអាមេរិកាំងពូកែ
ខាងវិទ្យាសាស្ត្រ និងខាងបច្ចេកទេសពិតប្រាកដមែនតែបែរជាទ្រាយ

ខាងសីលធម៌ ខាងសន្តិភាព និងខាងសង្គមកិច្ច ណាស់ដែរ ។ ព្រោះថា ការរៀបចំធ្វើយានអវកាស សម្រាប់បង្ហោះឲ្យទៅកាន់ឋានព្រះច័ន្ទនេះ ត្រូវចាយប្រាក់អស់ចំនួន២០ ពាន់លានដុល្លារ បើគិតមកជាប្រាក់យើងត្រូវជា ៧០០ ពាន់លានរៀល ។ បើតាមការសង្កេតទៅ ឃើញថាចំណាយប្រាក់អស់ដ៏យ៉ាងសម្បើមប៉ុណ្ណោះ នេះបានតែត្រឹមទៅដល់ឋានព្រះច័ន្ទប៉ុណ្ណោះ ក្រៅពីនេះគឺសូន្យ ។ ដូច្នេះ សីលធម៌នៃជនជាតិអាមេរិកាំងចំពោះមនុស្សជាតិ ពិសេសចំពោះជនជាតិអាមេរិកាំងស្បែកខ្មៅ ដែលអាស្រ័យនៅក្នុងប្រទេសជាមួយ គឺផ្ទុយទេស្អាត បានសេចក្ដីថា អាមេ-រិកាំងស្បែកសនៅតែនិយមប្រមាថមើលងាយ បណ្ដោយទុកឲ្យគ្នារងទុកវេទនា ជារៀងរាល់ថ្ងៃ ទោះបីគ្នាខ្វះខាតខាងសម្ភារៈដូចម្ដេចក្ដី ខ្លួនគិតតែពីចាយប្រាក់ពាន់លាន ៗ សម្រាប់ស្វែងរកកិត្យានុភាព ស្វែងរកការកោតសរសើរ ស្វែងរកមហិទ្ធិឫទ្ធិ ដើម្បីតាំងខ្លួនជាម្ចាស់ពិភពលោក ។ សព្វថ្ងៃមានតែប្រទេសដែលមានសីលធម៌ ខ្សោយបំផុតដូចជាខ្លួនទេ ដែលនិយមសរសើរជោគជ័យ ប្រាសចាកហេតុផលត្រូវនៃ អាមេ-រិកាំងនេះ ដ្បិតថាប្រសិនបើគេយកប្រាក់ចំនួនដ៏សម្បើមនេះ មកចាយប្រើប្រាស់ សម្រាប់កសាងមន្ទីរពេទ្យ សម្រាប់ជួយដោះទុក្ខ នៃជនក្រីក្រសម្រាប់ស្ថាបនាសាលារៀន ។ល។ មិនដឹងជាបានប៉ុន្មានឡើយ ។ ដូច្នេះយើងអាចជឿបានថាជនជាតិអាមេរិកាំង ជាមនុស្សខ្លាំងពូកែបានដែរឬទេ?

ខ្លាំងពូកែមែន ខ្លាំងពូកែចំពោះតែទៅលើអំពើទុច្ចរិត ទៅលើអំពើកាម សាហាវទៅលើអំពើឈ្លានពាននិងជិះជាន់អ្នកដទៃ ។ ប្រសិនបើយើង សរសើរអាមេរិកាំង គប្បីតែសរសើរមនុស្សប្រព្រឹត្តចោរកម្មផងទើបត្រូវ គប្បីតែគប់រកមនុស្សកំណាចឃោរឃៅផងទើបសម ។

ព្រះពុទ្ធបរមគ្រូទ្រង់សំដែងថា អ្នកមានបញ្ញាគឺសំដៅទៅលើបុគ្គល ណាដែលចេះធ្វើខ្លួនឯងឲ្យបានសុខផង និងធ្វើអ្នកដទៃឲ្យបានសុខផង ។ រីឯអ្នកដែលចេះតែធ្វើខ្លួនឲ្យបានសុខ ហើយដែលធ្វើអ្នកដទៃឲ្យបានទុក្ខ នោះពុំមែនមានឈ្មោះថា អ្នកមានបញ្ញាឡើយ ។ បើដូច្នេះ ចំពោះអាមេ-រិកាំងតើត្រូវថាដូចម្តេចទៅវិញ ? ត្រូវហៅថា អ្នកទុប្បញ្ញា ប្រែថាអ្នក មានបញ្ញាអាក្រក់ គឺថាអ្នកខ្វះបញ្ញាតែម្តង ។ សត្វតិរច្ឆានដែលខាងកាម សាហាវមានខ្លា ពស់ក្រពើជាដើម តើយើងនិយមទុកពួកវាថាជាសត្វមាន បញ្ញាដែរឬទេ ? ឆ្លើយថា ជាសត្វឥតមានបញ្ញាទាល់តែសោះ ព្រោះបើ វានៅទីណា វាតែងសាបព្រោះមហន្តភយគ្រប់បែបយ៉ាងនៅទីនោះ ។ ហេតុអ្វីបានជាវាគិតតែពីសាបព្រោះនូវសេចក្តីទុក្ខព្រួយ នៅលើអ្នកដទៃ? ថាព្រោះវាមិនដឹង វាគ្មានបញ្ញាសម្រាប់ជាគ្រឿងត្រិះរិះ បានជាវាធ្វើ ដូច្នេះទៅកើត ដោយអាងតែទៅលើពលានុភាព របស់វាប៉ុណ្ណោះ ។ សេចក្តីនេះឧបមាយ៉ាងណា រឿងអាមេរិកាំងក៏មានឧបមេយ្យដូច្នោះ ។

ស្មៅដុះច្រុលគ្របនៅក្បែរដើមសសរផ្ទះរបស់ខ្លួន មិនគិតជម្រះឲ្យ

ស្អាត ប៉ែរជាទៅគិតសំអាតស្មៅឯឋានព្រះចន្ទទៅវិញ ។ តើមនុស្សប្រភេទនេះត្រូវគេចាត់ទុកជាពពួកមនុស្សបែបណា?

ឥឡូវឮដំណឹងថាមិនទាន់អស់ចិត្តទេ ដែលគ្រាន់តែទៅដល់ឋានព្រះចន្ទប៉ុណ្ណោះ ពួកអាមេរិកាំងបំរុងធ្វើយានអវកាសឲ្យហោះចូលទៅភពផ្កាយទាំងឡាយផងទៀត មានផ្កាយព្រះអង្គារ ផ្កាយព្រះសុក្រជាដើម ព្រោះតាមការពិនិត្យរបស់គេទៅ ឃើញថាផ្កាយប្រហែលអាចឲ្យមនុស្សរស់នៅបានមិនដូចជាឋានព្រះចន្ទដែលមានសុទ្ធតែថ្មនោះទេ ។

សូមអ្នកអានជាទីមេត្រីទាំងឡាយ មេត្តាពិចារណាឲ្យហ្មត់ចត់បន្តិចល្បងមើលថា តើពួកចក្រពត្តិនិយម ដែលអួតអាងព្រមទាំងតាំងខ្លួនជាមេលទ្ធិប្រជាធិបតេយ្យជាមេលទ្ធិសេរីភាពនោះ និយមប្រកាន់យកនូវគំនិតអ្វីនិយមប្រាថ្នាអ្វី និយមប្រកាន់យកយ៉ាងជាប់ខាត នូវចំណូលអ្វី?

បើតាមយោបល់ខ្ញុំ គ្មានអ្វីក្រៅពីមហិច្ឆតា របស់គេតែប៉ុណ្ណោះ ។ ដទៃពីនេះ គេគ្មានគិតរវីរវល់ គ្មានឈឺក្បាលនឹងអ្នកណាឡើយ ទោះបីខ្លួនរងទុក្ខវេទនា លំបាកគោកយ៉ាក ទោះបីខ្លួនស្លាប់ព្រាត់ប្រាសគ្រួសារដូចម្តេចក្តី គេធ្វើយ៉ាងណាឲ្យតែមហិច្ឆតារបស់គេ បានសម្រេច ។

រួមសេចក្តីទៅ យើងមិនត្រូវអើពើនឹងសមិទ្ធិដ៏ចម្លែកនៃចក្រពត្តិនិយមទេ ជាសមិទ្ធិដែលគ្មានផ្តល់លទ្ធផលដ៏ប្រសើរដល់មនុស្សលោកនោះ ។ សូមឲ្យចក្រពត្តិនិយមបន្តពង្រីកសមិទ្ធិចម្លែកនេះតទៅទៀតចុះ យើងជាជន

ជាតិអាស៊ី ពិសេសជនជាតិខ្មែរ ត្រូវតែខំប្រឹងស្ថាបនាជាតិខ្លួន តាមព្រះមាគ៌ានយោបាយនៃសម្ដេចឪយើងតទៅទៀត ទើបបានប្រសើរ ទើបបានសេចក្ដីសុខសេចក្ដីចំរើន ។ ព្រោះនៅឯផែនដីយើង ក៏មិនខ្វះកិច្ចការប្រកបដោយប្រយោជន៍ទឹងបំពេញឡើយ ។

ជេង-ជ្រីវ

## ផ្នែកអក្សរសាស្ត្រ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ឆាំង-ខាត់ រៀបរៀង*

អភិគោរី ក្រ.វិ. ដោយប្រឆាំងចំពោះព្រះក្រូស្ណា ។

អភិគ្រិ ធាតុ តឹងពាក់ ។

អភិគ្រុ ធាតុ ស្តាប់ក្រៃលែង ស្តាប់ដោយយកចិត្តទុកដាក់។

អភិគូស៍ ធាតុ ហួត ថ្ងូរឈឺចាប់ ។

អភិមង្គ បុំ. កិរិយាលំអៀង, អភ័ព្វ ។ មង្គិន៑ គុ. ដែលធ្វើឲ្យអាមាសមុខ ។

អភិញ្ញា (សញ្ញា) ធាតុ ពោលពាក្យអសុរោះ ។

អភិមេរ បុំ. មេរិណា នបុំ. កិរិយាមុចទឹក ។

អភិមហ៊ា ធាតុ បៀតបៀន ប្រទូស្ត ។

អភិមិប៑ ធាតុ ស្រោចទឹក អភិសេក ។ បិក្ត គុ. ដែលស្រោះព្រំ ។

អភិមិញ្ចន — នប៉ុ. កិរិយាប្រោះព្រំ ។

អភិមិមេណាយិមុ — គុ. ដែលរៀបចំតទល់ ។

អភិមុ (សុ) — ធាតុ គាបក្រៃលែង សង្កត់ ។

អភិមូទ (សូទ) — ធាតុ សម្លាប់ ។

អភិមេក — ប៉ុ. អភិសេក ។

អភិមេចន — នប៉ុ. កិរិយាស្រោច កិរិយាប្រោះព្រំ ។

អភិមេចនីយ — គុ. ដែលគប្បីអភិសេក ។

អភិម្ដវ — ប៉ុ. អភិស្ដុប កិរិយាសរសើរ កិរិយាបញ្ជោរ ។

អភិម្ដុ (ស្ដុ) — ធាតុ សរសើរ ពោលពាក្យសរសើរ ។

អភិម្ឋា (ស្ឋា) — ធាតុ ឈរ តាំងនៅ រស់នៅ ។

អភិម្យន្ទ (ស្យន្ទ) — ធាតុ រត់តម្រង់ ភ្លៀង ដោរ ។

អភិម្យន្ទ — ប៉ុ. ភាពហួសប្រមាណ ភាពសម្បូណ៌ហូរហៀរ ។

អភិម្វង្គ — ប៉ុ. កិរិយាជាប់ជំពាក់ក្រៃលែង ។

អភិម្វញ្ជ ស្វញ្ជ — ធាតុ ព័ទ្ធ,ឱប ។

អភិសំយុត្ត — គុ. ដែលទាំដោយ (ស៊េះ)ដែលនាំដោយ ។

អភិសំយា — ធាតុ វិចាលុកធំ, ដែលធ្វើអុកឡុក ។

អសំយុត្ត — គុ. ដែលប្រកប ។

អភិសំរត្ត — គុ. ដែលជាប់ដោយ ។

អភិសំរព្ធ — គុ. ដែលនាំឲ្យកើត, បោករយៅ ។

អភិសំរភ (សំរភ) — គុ. កំពេល ។ ចុំ. មនុស្សកំរោល។

អភិសំរាធន — នបុំ. កិរិយាធ្វើឲ្យពេញចិត្ត ឬ ធ្វើឲ្យត្រេកស្រហល ។

អភិសំរុធ — ធាតុ បញ្ឈប់ ។ រុទ្ធ គុ.ដែលបិទបាំង។

អភិសំភិញ្ញ — ធាតុ ប៉ង, ប្រាថ្នា ។

អភិសំរីគ៍ — ធ.តុ រំលាយផ្សំ ។ រួបរួម ។

អភិសំវិក្ស — ធាតុ ក្រឡេកមើល ។

អភិសំវ្រឹ — ធាតុ បំបាំង។ វ្រិត គុ. ដែលបំបាំង ដែលលាក់ ។

អភិសំវ្រឹត្ត — គុ. ដែលទទួលធ្វើ។

អភិសំវ្រឹទ្ធ — គុ. ចាស់ទ្រុល ចាស់ណាស់ ។

អភិសំស្រយ — បុំ. អភិសំស្រ័យ, ជម្រក កិរិយាទាក់ទងចំពោះ

អភិសំស្រិ — ធាតុ អភិដ្ឋានខ្លួន ពឹងពាក់ ។ ស្រិត គុ. ដែលរត់ទៅជ្រក ដែលទៅជួប ។

| | | |
|---|---|---|
| អភិសំគ្រ | ធាតុ | ស្តាប់និយាយ ។ |
| អភិសំគ្លិប៊ | ធាតុ | ផ្អោប ចងផ្អោបគ្នា ។ |
| អភិសំស្ប | ធាតុ | លោតស្ទុះទៅ។ ស្បត៌ គុ. ដែលមកជិត។ |
| អភិសំស្បុត | គុ. | ដែលលំអក្រៃលែង ។ |
| អភិសំស្តម្ភ៊ | ធាតុ | ធ្វើឲ្យជួបសសរ ពង្រឹង ។ |
| អភិសំស្តំណ៍ | គុ. | ដែលពាសពេញសព្វ ដែលដើរដាស ។ |

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

## ឆូ-កាង

ប្រែ-រៀបរៀង

(ក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ុន

ជូឡុងក៏និយាយនឹងស៊ុយអៀនថា តាំងពីយើងធ្លាប់ធ្វើសង្គ្រាមរៀងមក ក៏មិនដែលបានឃើញក្បួនទ័ពជាចំឡែកយ៉ាងនេះសោះ, ឥឡូវ យើងគិតយ៉ាងម្តេចទើបនឹងមានជ័យជម្នះ, ទទួលឮសំឡេងគោង, ក្រឡេកទៅឃើញបុកឡុកតែអងកយមន្តលើខ្នងដំរី ១ ស្របក់ ក៏កើតជាព្យុះខ្យល់បក់បោកអណ្តែតដុំថ្មធ្លាក់ចុះមក បីដូចគ្រាប់ភ្លៀង ហើយបានឮសំឡេងបុកឡុកតែអងផ្លុំត្រែស្នែងក្របី, សត្វសាហាវក៏រត់ចេញពីក្នុងព្រៃជាច្រើន សម្តែងឫទ្ធិគេជះបោលចូលមកក្នុងកងទ័ពជូឡុង ៗ ឃើញដូច្នោះ ក៏ថយទ័ពត្រឡប់ចូលបន្ទាយ និយាយរឿងរ៉ាវជម្រាបខុងបេងគ្រប់ប្រការ ហើយក៏អង្វរសុំទោសដែលទៅធ្វើការបរាជ័យនឹងខ្មាំងសត្រូវ ៗ

ខុងបេងបានស្តាប់ក៏អស់សំណើច ហើយថា អ្នកកុំព្រួយជាទុក្ខឡើយ

ព្រោះសត្រូវនោះ វាមានសិល្បវិជ្ជាលើសប្រាជ្ញអ្នក ។ មិនមានទោសទេ, ដែលបុគ្គលតែឯងមានវិជ្ជាយ៉ាងនេះ យើងក៏អាចទឹងជឹងដល់ តាំងបានបម្រុងទឹងធ្វើកលខល់ប្រាជ្ញាសព្វគ្រប់ហើយ, ខុនបេងក៏ឲ្យទាហានទៅយករទេះដែលត្រៀមទុកតាំង១១រទេះនោះមកបើកគម្របដែលគ្របចេញ, ក្នុងរទេះនោះមិញ មានសឹងរូបសត្វការាផ្សេង ៗ ចំនួន ១០០ ធ្វើដោយឈើលាបថ្នាំធ្វើឲ្យដូចរូបសត្វ ហើយលុងខាងក្នុងពោះរូបនោះ ដាក់រំសេវទិងគ្រាប់, មានយន្តសម្រាប់ទាញវង្វិលឲ្យរើរបានគ្រប់រូប; ខុនបេងក៏ជ្រើសរើសទាហានដែលមានកម្លាំងចំនួន ១,០០០ នាក់ សម្រាប់អមនាំរូបសត្វ ១ មនុស្ស ១០ នាក់, លុះដល់ពេលព្រឹក ក៏ឲ្យលើកទាហានតម្រង់ចូលទៅក្នុងស្រុកងិនទៃ, ឯខ្លួនខុនបេង ក៏លើកពលតាមទៅជាក្រោយ ។

ឯបុគ្គលតែឯងបានជ័យជម្នះហើយ ក៏លើកទ័ពត្រឡប់ចូលស្រុក, បេងហេក ក៏តែងតុលៀងភោជនាហារ, ខ្លួលមានបម្រើចូលទៅប្រាប់ថា ខុនបេងលើកទ័ពមកច្បាំង; បុគ្គលតែឯង បានឮដូច្នោះ ក៏ថា ខុនបេងនៅមិនទាន់ញញើតថ្ងៃយើងទេឬ បានជាហ៊ានលើកទ័ពចូលមកទៀត ? ហើយក៏ចាត់ចែងទាហានទិងបេងហេកចេញចាកស្រុក, ខ្លួលខុនបេងលើកទ័ពមកដល់, បេងហេកក៏លើកដៃឡើងចង្អុលបង្ហាញបុគ្គលតែឯងថា ដែលពាក់មួកក្រហម តែងខ្លួនជាមហាឧបរាជ កាន់ផ្ចិតអង្គុយលើរទេះតូចនោះ គឺខុនបេង, បើប្រសិនយើងចាប់ខ្លួនបានហើយ ដែនដីរបស់

ឡើង ក៏ទឹងបានសេចក្ដីសម្រាន្តសុខ; បុកខ្យុកកៃតអង បានឮដូច្នោះ ក៏គោះគាំងកយមន្ត ហៅឲ្យកើតខ្យល់ព្យុះបក់បោកអណ្ដែតដុំថ្មធ្លាក់ចុះមក បីដូចគ្រាប់ភ្លៀង ហើយផ្ទុំត្រៃហៅសត្វកាចឲ្យចេញមកច្រើនណាស់ ។

ខុនបេងឃើញដូច្នោះ ក៏កយមន្ត បោកផ្លិតឲ្យខ្យល់បក់ត្រឡប់ទៅវិញ, សត្វកាចទាំងប៉ុន្មានក៏ឈប់នៅភាំងអស់, រួចខុនបេងក៏ឲ្យយកភ្លើងក្រុដលម្ពនសត្វ ដែលធ្វើកលនោះ ឲ្យបោលចូលទៅក្នុងកងទ័ពបេងហោក, ហើយឲ្យកាយៈឃោះគោះគងខុងកេរលើកពលហានទ័ពចូលទៅ, បណ្ដាសត្វកាចដែលបុកខ្យុកកៃតអងហៅមកនោះ សឹងតែត្រូវគ្រាប់ និងរបួសពិការជាសាហ៊ស ក៏បោលប្រាសរត់ត្រឡប់ប្រទាក់ប្រទូន, ពលហានទាំងពួង ក៏បែកបាក់ទ័ពត្រឡប់រត់ចេញទៅ; ខុនបេងក៏បរពលចូលប្រកាប់ សម្លាប់បុកខ្យុកកៃតអងស្លាប់ក្នុងទីចម្បាំង, បេងហោកលើកទ័ពលេះលាំងចូលទៅក្នុងស្រុកវិញ ហើយនាំការបោទិងស្ល័គ្រប័ក្ខពួកគេដោះខ្លួន, ខុនបេងក៏លើកទ័ពទាំងក្បួន ចូលទៅតាំងក្នុងស្រុកមិនរើ ហើយឲ្យបំណាច់ផ្គាន់ពលហានតាមសមគួរ រួចហើយចាត់ពលហានឲ្យលើកស្រូតទៅតាមចាប់ខ្លួនបេងហោកទៀត ។

ឯបេងហោករត់ទៅនោះ គួរឲ្យជាប្អូនប្រពន្ធ ក៏និយាយថា ឡើងទឹងរត់ទៅគ្រានេះ ក៏ឃើញថាមិនផុតពីដៃខុនបេងទេ, ខ្ញុំនឹងគិតកលឧបាយឲ្យ

ទាហាន១០០នៃកងខ្លួនចង្កប់អាវុធលាក់ក្នុងអាវ ហើយធ្វើជាចាប់ខ្លួនលោកទាំង២នាក់និងបងស្រីខ្ញុំចងនាំទៅឲ្យខុងបេង ។ គង់នឹងពេញចិត្ត ហៅខ្លួនខ្ញុំនិងទាហាន១០០ ដែលមានសេចក្ដីគាប់ប្រសើរ ឲ្យចូលទៅក្នុងបន្ទាយ, ខ្ញុំនិងចាប់ខុងបេងសម្លាប់ចេញ, បេងហេក បានឮដូច្នោះ ក៏យល់ឃើញត្រូវនឹងចិត្ត, តួឡៃក៏ចាប់ខ្លួនបេងហេក-បេងហ៊ី និងនាងចុកយ៉ុង ហើយឲ្យទាហាន១០០នាក់ឃុំនាំទៅជាមួយនឹងខ្លួន លុះទៅដល់បន្ទាយខុងបេងក៏ប្រទះនឹងពួកល្បាត, តួឡៃក៏និយាយប្រាប់ពួកល្បាតថា ខ្ញុំបាននិយាយហាមប្រាមបេងហេកថា ឲ្យមកសុំចំណុះចុះចូលមហាឧបរាជចុះ ក៏វាមានះពុំព្រមស្ដាប់ រឹតតែចចេសមកធ្វើចម្បាំងតនឹងមហាឧបរាជ ទាល់តែពលទាហានបានសេចក្ដីក្ដៅក្រហាយជាច្រើន, ខ្ញុំនឹកខឹងក៏ចាប់ខ្លួនបេងហេក-បេងហ៊ីនិងគរិយាមកជូនមហាឧបរាជ, ពួកល្បាត ក៏ចូលទៅជម្រាបខុង-បេង ។ បានឮដូច្នោះ ក៏បង្គាប់ទៀវហ៊ីនិងម៉ាតង់ថា អ្នកឯង ទាំងពីរនាក់ចូរចាត់ទាហានម្នាក់១.០០០ ឲ្យឈរតម្រៀបគ្នាតាមសង្កាត់ទ្វារបន្ទាយ បើឃើញតួឡៃនាំបេងហេក-បេងហ៊ីចូលមក ឲ្យនាំគ្នាព្រួតចាប់ខ្លួនតួឡៃចងព្រមទាំងទាហានដែលមកជាមួយ នាំមកឲ្យយើង ។

ទៀវហ៊ីនិងម៉ាតង់ ក៏ចេញទៅចាត់ការជាស្រេចតាមខុងបេងបង្គាប់; តួ-ឡៃក៏នាំខ្លួនបេងហេក-បេងហ៊ីនិងបងស្រី ចូលទៅដល់ទ្វារបន្ទាយ; ខណៈនោះ ម៉ាតង់និងទៀវហ៊ី ក៏នាំទាហានព្រួតចាប់ខ្លួនតួឡៃ និងទាហាន

១០០ នាក់បាន នាំចូលទៅ, ខុនបេនកែងឲ្យទាហានចេញទៅបង្គាប់ថា ដែលគូឡៃនិងអស់ទាហាន បានចាប់ខ្ញុនបេងហោកមកនោះ ឲ្យនាំចូលទៅចុះ, ទៀវឆី និង ម៉ាតង កំនាំខ្ញុនបេងហោក បេងហ៊ាំ គូឡៃ នាង ប៊ុកយ៉ុង និងទាហាន ១០០ នាក់ ចូលទៅគំនាប់ខុនបេង ៗ ក្រឡេកឃើញគូឡៃ និងទាហានចូលទៅគំនាប់ ក៏អស់សំណើចហើយថា ដែលបេង-ហោកបានប្រព្រឹត្តល្មើសនឹងយើង ៗ ចាប់បានខ្ញុំហើយលែង ៗ ហើយចាប់បានខ្ញុនទៀត, គងជាទមុខនេះ អៀវហងជាកៀនសំឡាញ់ខ្ញុន ឃើញថាខ្ញុនធ្វើខុស ក៏ចាប់ខ្ញុនមកឲ្យយើង, យើងក៏បានទុកអាយុជីវិត បើកលែងទៅវិញមិនសម្លាប់, ឥឡូវនេះ គូឡៃជាប្អូនថ្លៃខ្ញុនចាប់ខ្ញុនមកឲ្យយើងប្រាថ្នានឹងកែងឧបាយធ្វើអន្តរាយយើង ៗ ក៏អាចដឹងដល់, ហើយខុនបេងក៏ឲ្យទាហានរើមើលក្នុងខ្លួនគូឡៃ នូវអស់ទាហាន ក៏បានឃើញកាំបិតដែលសៀតបង្កប់នៅក្នុងអាវ ១ ម្នាក់ គ្រប់ៗគ្នា ៗ

ខុនបេង ក៏ចអកបញ្ឈឺចិត្តឲ្យបេងហោកថា ឯកលឧបាយដែលខ្ញុនគិតធ្វើនេះ សូម្បីគ្រាន់តែយើងគិតលេង ហើយបំភ្លេចទៅវិញ ក៏ល្អជាជាង, គ្រានេះ យើងមើលទៅឃើញថា ខ្ញុនទាល់ផុតអស់គំនិតគិតហើយតើខ្ញុននឹងជាដូចម្តេចទៅទៀត ៗ

បេងហោកឆ្លើយថា យើងមិនបានចាញ់ដោយកម្លាំងថ្លៃដៃលោកសោះ, ចាញ់នេះ ព្រោះគំនិតគិតខុសចូលមកគេទស្លាប់ឯង ៗ បានជា

លោកចាប់យើងបាន, បើលោកនឹងសម្លាប់យើងមិនបង្អង់ខាន, យើងក៏មិនត្រូវការនឹងអង្វរករទេ តាមចិត្តចុះ ។

ខុងបេងថា យើងចាប់អ្នកឯងបានដល់ ៦ គ្រាហើយ អ្នកឯងនៅតែនិយាយកោងព្រហើនដដែល តើគំនិតអ្នកឯងនឹងចង់ឲ្យយើងទៅតាមចាប់ប៉ុន្មានដងទៀត ទើបអ្នកឯងទទួលខ្លាចយើងជាប្រាកដ ? ។

បេងហេកឆ្លើយថា បើលោកបើកលែងយើងទៅម្តងទៀតឲ្យយើងបានធ្វើការត្រាតែអស់គំនិតគិតទិសអស់ថ្វីដៃហើយ ទើបបានយើងព្រមចំ-ណុះចុះចាញ់លោក, បើលោកមិនជឿ យើងនឹងធ្វើសត្យសញ្ញាទុកជូនលោក, ហើយបេងហេកក៏ធ្វើសញ្ញា នៅចំពោះមុខខុងបេង ។ បានស្តាប់ទើបគិតថា បេងហេកនេះ វាចាញ់ប្រៀបយើងណាស់ទៅហើយ, ពលទាហាន ក៏កាន់តែនៅស្តើងស្តួច មុខជានឹងធ្វើការធំទៅទៀតពុំបាន, យើងនឹងលែងវាទៅទៀតចុះ, តែម្តងនេះ វាក៏អស់តម្រិះប្រាជ្ញាហើយ, ខុងបេងឲ្យទាហានស្រាយចំណងបេងហេក-បេងហ័វ តួឡៃ និងនាងចុក-យ៉ុងនូវអស់ពលទាំង ១០០ នាក់ ចេញទៅ, ហើយថា យើងឲ្យអាយុជីវិតអ្នកឯងម្តងនេះទៀត បើគ្រាក្រោយយើងចាប់បានហើយ អ្នកឯង នៅតែនិយាយកោងដូចមុនៗទៀត, យើងនឹងសម្លាប់ឲ្យអស់មួយដួរគោត្រ ។

បេងហេកទទួលពាក្យខុងបេងហើយ, ក៏ឱនជាក់មុខដើរទាំងទុក្ខចេញទៅពីទីនោះ លុះទៅដល់ទីកន្លែង ក៏ចាត់ចែងបញ្ចុះបញ្ចូលទាហាន

បានប្រមាណ ៨០០ នាក់, បេងហេកក៏និយាយនឹងតួឡៃថា វេលានេះខុងបេងក៏ចូលទៅតាំងនៅក្នុងស្រុកយើងហើយ, យើងក៏គ្មានទីអាស្រ័យសោះ; បើដូច្នោះយើងនឹងគិតប្រការម្តេចទើបនឹងបានតាំងខ្លួនធ្វើការតទៅ? តួឡៃថា លុតតក់តកុត ដែលជាចៅហ្វាយស្រុក អក្កុក ខាងទិសឯកើត ចម្ងាយពីនេះទៅ ៧.១០០ សិន (២៨០ គីឡូម៉ែត្រ) មានទាហានច្រើនណាស់, បើប្រសិនយើងរិះគិតនឹងទៅពឹងប្រាស្រ័យ ឲ្យលុតតក់តកុតលើកទ័ពមកជួយ មុខជាយើងនឹងធ្វើការបានជ័យជម្នះជាប្រាកដ ព្រោះលុត-តក់តកុតនោះមានកម្លាំងពលច្រើនណាស់ ខ្ពស់១ព្យាម ៣ ហត្ថ ស៊ីតែសាច់សត្វរស់ និងផ្លែឈើជាអាហារ ហើយក៏មានវិជ្ជាគង់អាវុធកាប់មិនមុត, ពលដែលចូលតយុទ្ធគង់ណាផ្ទង់សង្គ្រាម ក៏ស្លៀកគ្រាប់ធ្ងន់ពាក់ យកផ្តៅត្រាំប្រេង ៦ ខែមកចាក់ធ្វើជាក្រោះ ទោះទៅដល់ផ្លូវដាច់ស្រយាលនឹងឆ្លងទឹក ក៏អណ្តែតខ្លួនស្រាលឡើងហែលឆ្លងទៅត្រើយម្ខាងបាន, បើត្រូវអាវុធព្រួញ ក៏មិនបានមុតចូលទៅក្នុងសាច់, ទើបហៅពលទាំងអស់នោះឈ្មោះថា ទ័ពក្រោះប្រេង, សូមឲ្យលោកទៅអង្វរលន់តួលុតតក់តកុតឲ្យលើកទាហានមកជួយធ្វើការសងសឹកនឹងខុងបេង ។ បេងហេកបានស្តាប់មានសេចក្តីត្រេកអរណាស់, តួឡៃក៏នាំបេងហេកទៅគាល់លុតតក់តកុត ឯស្រុកអក្កុក គំនាប់គោរពតាមទំនៀមហើយ បេងហេក ក៏ពណ៌នាសេចក្តីឲ្យស្តាប់គ្រប់ប្រការ, លុតតក់តកុតថា ដែលខុងបេងលើកកងទ័ពរុកពាន

ទន្ទ្រានចូលមកញាំញីក្នុងដែនយើង ឲ្យអ្នកបានសេចក្តីក្តៅក្រហាយនោះ អ្នកកុំព្រួយចិត្តគិតពេកឡើយ, យើងនឹងទទួលរ៉ាប់រងជាធុរៈឯង ដើម្បីឲ្យខុងបេងដឹងសំណាក់ដៃឲ្យបាន, លុតត័តកុត ក៏បង្គាប់ខៅអ៊ុន និងគេហ៊ី ឲ្យលើកទាហានទីនកៈប៉េង ៣០.០០០ ជាកងមុខ ទៅតាំងចាំទទួលកងទ័ពខុងបេង នៅក្បែរស៊ឹងផោហួយស៊ុយ ក្រៅស្រុកអក្កុក ខាងទិសឯកើតជាមុន ហើយលុតត័តកុត ក៏នាំបេងហេកនិងស័គ្របក្ខពួកទាំងពួង ចេញទៅប្រចាំជូនជាក្រោយ ។

(នៅមានត)

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក រ៉ាប៊ិន្ទ្រណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ២៧

កាលនាងដឹងខ្លួនឡើង ហើយស្ទុះរកមើលជុំវិញខ្លួននាង ទើបនាងដឹងថា នាងគេងតែឯងទេនោះ រាត្រីកាលមិនទាន់សើយផុតនៅឡើយទេ នាងនឹកមួយសន្ទុះ ទើបនាងដឹងថានាងគេងនៅទីណា , នាងចុះពីលើគ្រែ ហើយស្ទុះទៅបើកទ្វារ នៅលើផ្ទៃទឹកនឹងថ្កល់នោះ មានអ័ព្ទពណ៌សប្រផេះអណ្ដែតខ្ទប់ នៅលើមាត់ច្រាំង ឯនាយដើមឈើដុះច្រូងច្រាងដូចរនាំងសំពត់, រស្មីព្រះអាទិត្យពេលព្រហាម មានពណ៌ក្រហមព្រឿងបញ្ចេញរង្វង់កាន់តែធំបន្តិចម្ដង ៗ នៅលើផ្ទៃទឹកទន្លេ, ក្ដោងទូកអ្នកនេសាទចេញបន្ត ៗ គ្នា បីដូចគេបន្តក់ផ្កាសលើផ្ទៃសំពត់ពណ៌ស្រគាំ ។

ទេសភាពវេលាព្រឹកនោះ មិនដឹងដូចម្ដេចទេ ក៏ទៅជាគួរអាប់បណ្ដាលឲ្យនាងកមលាតប់ប្រមល់ក្នុងចិត្ត នឹកអាណិតខ្លួនតាំងពីធំដឹងក្ដីមកស្គាល់តែវេទនា ទឹកដល់រឿងនេះ នាងអួលដើមក ៗ ទើបតែពីល្ងាចម្សិលមិញនោះសោះ នាងក្លួចខ្លួនថានាងជាកូនកំព្រា ហើយមានតែប្ដី

មួយជាបង្គោលប៉ុណ្ណោះ  ចុះហេតុម្តេចបានជានាងត្រឡប់ជាទឹកឃើញថានាងកំព្រាទៀតហើយ ។ ភាមេស្ហគ្រប់គ្រងនាងមិនបានគ្រប់គ្រាន់ទេឬ ? អ្វីអេះដែលបណ្តាលឲ្យនាងទឹកឃើញតាំងក្រៀមក្រំអំពីអមិត្តភាពរវាងរូបនាងនិងទីកន្លែងដែលនាងរស់នៅ ។

ពេលដែលនាងកំពុងតែបណ្តែតអារម្មណ៍នោះ រស្មីព្រះអាទិត្យបាំងនៅលើផ្ទៃទឹក ភ្លឺប្រាលប៉ីដូចទឹកមាសរលាយកំពុងហូរក្រាលពាសលើផ្ទៃទន្លេ ។ ពួកកម្មករ នាំគ្នាចាប់ការងាររៀង ៗ ខ្លួន ម៉ាស៊ីនកប៉ាល់ចាប់ធ្វើចលនាគគ្រឹក សូរគ្រឿងចក្រអូសរបស់ធ្ងន់ រួសប្រពាក់ ធ្វើឲ្យក្មេងតូច ៗ ក្នុងភូមិភ្ញាក់មុនពេលធម្មតា ហើយនាំគ្នាមកលោតលេងពេញលើមាត់ប្រាំង ។

ពេលនោះ, ភាមេស្ហក៏ងើប ក្រោកដើរចេញមកមាត់ទ្វារអ៊ែតរកមើលនាងកាមាលា ឃើញហើយនិយាយថា ៖

- នាងលុបមុខលុបមាត់ហើយឬនៅ ? គេក្រោកគ្រប់គ្នាហើយណា៎

ពាក្យនិយាយជាសំនៀងប៉ុណ្ណោះមិនសូវខ្លឹមខ្លីសោះ តែនាងកាមាលាអោជាអន់ចិត្ត ព្រោះនាងនឹកឃើញថា ភាមេស្ហដែលក្រោកពីព្រលឹម ហើយតឿននាងឲ្យលុបមុខមាត់មិនមែនគ្រាន់តែជាការគ្មានអត្ថប្រយោជន៍ប៉ុណ្ណោះទេ ថែមទាំងមិនសមរម្យទៀតផង ។ នារីយល់ទៀតថា បុរសបានដាក់សម្រេះជាត្រាដែនជាស្រេច ក្នុងការទាក់ទងរវាងខ្លួននាងនិងគេ

ហើយគេនឹងមិនទន្ទ្រានមកកាន់កេរ្តិ៍ភាពបុគ្គលវិញទេ ។ ចុះបើឃើញគេប្រកាន់សរិយាបថបែបនោះហើយ ហេតុម្ដេចបានជានារីនៅតែមានការទើសទាស់ កាលណានាងនៅចំពោះមុខគេ ?

កាលបើតូឃ្យុវជនប្រើនាងឲ្យទៅលុបលាងកាយ នារីមិនឆ្លើយតបទេ នាងកើចយកសំពត់អាវ រួចដើរតម្រង់ទៅបន្ទប់ទឹក ។ ចេញពីផ្ងូតទឹកមកវិញ នាងដើរចូលទៅក្នុងបន្ទប់ ហើយទាញសោពីចង្កេះចាក់បើកហិបសំពត់អាវ, បើកភ្លាមក៏ឃើញប្រអប់ប្រាក់ ដែលកមេសូប្រគល់ឲ្យនាងពីថ្ងៃមុន ៗ កាលដែលនារីយករបស់នេះមកទុកក្នុងហិប នាងមានសេចក្ដីកក្រើកគួរឱ្យគ្មាន តែឥឡូវនេះ សេចក្ដីបង្ហៀម ការសប្បាយទាំងប៉ុន្មាន រលាយអស់លើង . . . . ព្រោះរបស់នេះ មិនមែនជារបស់នាងទេ គឺជាសម្បត្តិរបស់កមេសូ, នាងមិនអាចយកប្រើការបានដោយមិនប្រាប់ស្ងួម្ចាស់គេទេ, នាងគ្រាន់តែជាអ្នកកេក្រឹត្យទ្រព្យឲ្យគេប៉ុណ្ណោះ

— នាងនៅធ្វើអីបងអូនម៉ែះ ឃើញអ្នកដាក់ក្នុងហិបនោះ ខ្មោចលងឬ ? (កមេសូដើរចូលមកបណ្ដើរនិយាយបណ្ដើរ )

— ចា៎ះ! បង ខ្ញុំឃើញប្រអប់នេះដែលជារបស់បង (នាងហុចប្រអប់ឲ្យទៅកមេសូ )

— ឲ្យបងយកទៅធ្វើអ្វី ?

— អូនឹង បើកាលណាបងត្រូវការ, សូមបងប្រាប់ខ្ញុំមក សុំ

ខ្ញុំប្រើក្មេងទៅទិញជូន ។

— ចុះកាមាលាឯង មិនត្រូវការជួបបងដែរទេឬ ?

— ខ្ញុំឥតត្រូវការប្រាក់ទេ (នាងឆ្លើយយ៉ាងខ្លី )

ភរមេស្ហព្ទុះហើយញញឹម ។

— គិតមានមនុស្សណានិយាយដូចកាមាលាឯងណាស់ ។

នារីមិនឆ្លើយតបថែមទៀតទេ តែនាងដាក់ប្រអប់ប្រាក់នោះទៅលើក្តារ ។

— នាងខឹងនឹងបង ព្រោះបងមិនបញ្ចប់រឿងឲ្យ ឬ អី ?

— ខ្ញុំគ្មានខឹងអ្វីនឹងបងទេ (នាងប្រកែក) តែនាងមិនលើកភ្នែកពីក្តារក្រាលសោះ ។

— ខ្ញុំមិនជឿទេ ដរាបណានាងមិនព្រមទទួលយកប្រអប់នេះ ។

— ខ្ញុំមិនយល់សោះ ប្រអប់នេះជារបស់បង បងត្រូវតែរក្សា ។

— វាមានជារបស់បងឯណា កូនដឹងទេលោកថា តែអ្នកណាឲ្យអ្វីគេហើយយកមកវិញ ស្លាប់ទៅជាខ្មោចហើយ ក៏នៅតែវិលមករក្សារបស់នោះដែរណា៎ ហើយនាងស្ងួនថា ខ្ញុំចង់ដូចអីចឹងឬ ? ។

— ពុកមេស្ហ និយាយលេងបែបនេះ នាងទ្រាំសើចមិនបាន ផ្ទុះសំណើចហើយឆ្លើយតប ៖

— មែនហើយ ប៉ុន្តែពាក្យដែលបងនិយាយអម្បាញមិញនេះ ជាការ

ពិតឬកុហក ? ខ្ញុំមិនដែលឮអ្នកណានិយាយដូច្នេះសោះ . . .

បន្ទាប់ពីនោះមក ភាពតានតឹងរវាងនារី និងបុរសក៏ធូរស្រាលទៅវិញ ។

—មានផ្លូវតែម្យ៉ាងទេ បើអូនចង់ដឹងថាពាក្យនោះ ពិតឬមិនពិត គឺថា បើកាលណាអូនឃើញខ្មោចលង អូនសួរវាទៅ ។

នាងកាមាលា មានវ័យក្មេង តែឮគេនិយាយអ្វី ចូលចិត្តជឿណាស់ នារីខំសួរបុរសថា :

—បងនិយាយឲ្យត្រឹមត្រូវទៅមើល បងដែលឃើញខ្មោចលងឬទេ ?

—ខ្មោចមែនទែន បងមិនដែលឃើញទេ ឃើញតែគេធ្វើ ។

—ចុះ កុយមេស្ហាថា . . .

នៅពេលនោះ ពួកនាវិកបានចំរៀលកកប៉ាល់រួចពីជាប់គៀង ក៏បើកចេញទៅ ចេញទើបនឹងផុតពីច្រាំង ស្រាប់តែគេក្រឡេកឃើញក្មេងម្នាក់ចូលអីវ៉ាន់ពេញកញ្ច្រែង រត់បណ្ដើរស្រែកបណ្ដើរ ឲ្យកប៉ាល់ឈប់, លុះវាមើលឃើញកមេស្ហាឈរនៅក្នាក់ដៃ វាស្រែកថា :

— ប៉ាប៊ូ ! ប៉ាប៊ូ !

នាយកប៉ាល់ គ្មានវេលាយកចិត្តទុកដាក់នឹងសម្រែកក្មេងបន្តិចសោះ :

— យី ! អាក្មេងនេះ វាធ្វើមើលតែខ្ញុំជាអ្នកដឹកសំបុត្រកប៉ាល់

( ភមេស្ហដៃតបទៅវិញ ) តែនាងកាមាលាមិនព្រម

— អុយមេស្ហទេតើ បង, បោលគ្នាម្ដេចកើត ?

— ឲ្យបងធ្វើម្ដេច គេមិនមែនឈប់ឲ្យយើងទេណា៎

— ទេបង ! . . . បងត្រូវតែធ្វើម្ដេចឲ្យគេឈប់ទៅយើងនៅជិតប្រាំងនៅឡើយទេតើ . . . .

នាងលំអុកខ្លាំងពេក ភមេស្ហកំទៅនិយាយនឹងនាយកប៉ាល់ ៗ មុនដំបូងគេមិនព្រមទេ ទាល់តែឲ្យប្រាក់ខ្លះទៅ ទើបគេព្រមឈប់ឲ្យ ៗ កប៉ាល់ឈប់ហើយ នាវិកជួយគូសកុមារឲ្យឡើងផុតមក ៗ ឡើងរួចមក កាលណា កុមារដាក់ទំនួលនៅក្បែរជើងម្ចាស់ស្រីក ហើយសើចកាច់កដូចជាគ្មានភ័យនឹងកប៉ាល់ចេញបោលសោះ . . . .

— ន ! ប៉ុណ្ណឹងហើយ នៅសើចទៀត ? (នាងនិយាយដោយធ្វើមុខស្មើ ) កុះបើកប៉ាល់ចេញបោល ឯងធ្វើម្ដេចទៅ ?

កុមារមិនឆ្លើយតបទេ វាបោលភ្នែក ទៅលើកព្រួង បន្ទូនាងដាក់ភ្នែកតាមឃើញ មានខ្សែក ថ្មី រនោង ៗ ល ៗ

— ឯងបានរបស់ទាំងនេះមកពីណា ?

— ម៉ែ ពីថ្ងៃមុន ពេលដែលកប៉ាល់ចៀង ខ្ញុំដើរទៅក្បែរមាត់ប្រាំង ឃើញបន្ទូទាំងនេះ របស់អ្នកស្រុក តែខ្ញុំមានលួចគេឯណា

ខ្ញុំគ្រាន់តែបេះនេះបន្តិចនោះបន្តិច មិនបានសុំម្ចាស់គេទេតើ ...

– ឯងគិតយ៉ាងម៉េចហ្នឹង ! បន្តិច ៗ ហ្នឹង មិនហៅថាលួចទេឬ? (កាមេស្ហូនិយាយបែបខឹង) ទៅ ! យកចេញពីមុខអញឲ្យឆាប់ ឯងយកទៅណាទៅ ៗ ។

អ៊ុយមេស្ហូ ខំសំឡឹងមុខនាងកាមាលា ហាក់ដូចជាខំអង្វរឲ្យនាង ជួយពាំងកំហឹងកាមេស្ហូ ក៏ខំនិយាយបន្ទន់ឲ្យនាងបាត់ខឹង

– នែម៉ែ ! អាផ្លែនេះ ស្រុកខ្ញុំគេយកទៅធ្វើម្ហូបឆ្ងាញ់ណាស់ ឯរនាងនោះ ....

– យកចេញឲ្យឆាប់ (កាមេស្ហូគំហក បែបខឹងសម្បើម )គេមិនចេញអញគ្រវាត់ក្នុងទឹកទាំងអស់ ទាំងអាឯងផងឥឡូវ ....

អ៊ុយមេស្ហូ ខំងើបមើលមុខនាងកាមាលាម្តងទៀតដូចជាចង់ឲ្យនាង ជួយ តែនាងធ្វើកាយវិការ បញ្ជាឲ្យចេញឆាប់ទៅ កុំទទឹង ។ កុមារប្រមូលគីវ៉ាន់ដាក់កន្ត្រកហើយ រត់ចុះទៅក្រោម តែវាយល់ទឹកមុខនាងថា នាងនៅអាណិតគាត់ដែរ ។

កាមេស្ហូដើរចូលបន្ទប់ទាំងមុខក្រញូវ ទៅសម្ងំសរសេរសំបុត្រមួយបន្តិច ... នាងកាមាលា [illegible] ឃើញវានៅអង្គុយលើគែមកប៉ាល់ ក្បែរបន្ទប់ធ្វើម្ហូប ។ នាងយកក្រមាខ្ទប់ក្បាល រួចដើរចូលទៅជិតក្មេង ... ។

— ឯងគ្រវាត់ចោលអស់ទៅហើយឬ ?

— ទេម៉ែ ? ខ្ញុំលាក់នៅក្រោមនោះទេ ?

— អំពើដែលឯងបានធ្វើហ្នឹង មិនល្អទេណា : ?

— (នាងធ្វើជាបន្ទោស) កុំធ្វើដូច្នេះទៀតឮទេ ? ចុះបើលោកប្រុសឯង ចោលឯងនៅទីនោះ គេយាងម៉េចទៅ ត្បិតឯងត្រូវទៅរកកាំបិតឲ្យម៉ែមួយមក ។

កុមារកំព្រាតែពេញចិត្ត នាំរើសយកបន្ទះបំពង់ ដើម្បីឲ្យធ្វើអាហារ ។ ឱ ! គួរឲ្យស្តាយ ទោះជាក្មេងកំព្រាបានធ្វើកំហុសប៉ុណ្ណេះក៏ដោយ នាងក៏នៅតែខំគ្រប់គ្រងបានដែរ ព្រោះគ្នាគ្មានទីពឹង ហើយបើធៀបរឿងលួចនឹងរឿងដែលគ្នាកំព្រាគ្មានទីពឹងវិញនោះ ឃើញថារឿងកំព្រាឯការនេះរាប់ធ្ងន់ជាង ។ ម្យ៉ាងទៀត កុមារដែលបានទៅលួចបន្ទះបន្ទុកគេនោះ ក៏ពីព្រោះតែគួរឲ្យគេយកចិត្តទុកដាក់ ក៏ទៅជាយល់ខុស ។

— ទេ! នៅសល់បំពង់គ្នាខ្លះដែរ ឯងយកទៅដាក់ទៅ ហើយកុំទៅដើរចប្រចប់អាប៉ែងណាំអ្នកស្រុកដូចមុនទៀត ។

— ម៉ែ ពីសាទេ ? (កុមារមស្ហទំនួរយកចិត្តនាង) ។

— គិតតែមាត់ឯងឲ្យឆ្អែតទៅ ម៉ែមិនឃ្លានដូចឯងទេ ។ ឯងគិតធ្វើម្តេចបានត្រី ដើម្បីធ្វើម្ហូបឲ្យលោកប្រុសឯង ?

— ខ្ញុំរកបាននៃម៉ែ ! តែទៅលើតែទិញគេ ។

— មិនដែលឃើញក្មេងណាឆ្គួតដូចឯងសោះ, អ្នកណាគេឲ្យឯងទៅយកអីវ៉ាន់គេហើយ មិនឲ្យលុយ ។

តែនឹកដល់រឿងលុយ កុមារកំព្រានឹកឃើញដល់ការមេស្រុកគ្រាម ពីព្រោះនាងកាមាលាមិនមែនយកលុយពីកមេស្រុកបានងាយទេ ហេតុនេះទើបអ៊ុយមេស្រុកនឹកស្អប់ចៅហ្វាយប្រុសក់ ដែលចេះតែត្រូវការឃ្លានហើយ ទុកម្ចាស់ស្រីទីផង្គួនក់ ឲ្យចាំគេមធ្យោភាយតែពីរនាក់ ឯគាត់នៅព្រៃឆើយ គ្មានខ្វល់គិតគូរអាំងអស់ ។ បើបន្ទិចបន្តួចមិនថ្វីទេ សុំគេបាន ចុះបើត្រីសាច់ តើបុំអ្នកណាបាន ដើម្បីនឹងយកមកធ្វើអាហារផ្គាប់ចិត្តគេ?

— ម៉ែ! បើបានលុយតែ ៥ អាណា(១)មក ខ្ញុំនឹងទៅរកទិញឲ្យបានត្រីមួយយ៉ាងគួរសម ។

— ទេ ម៉ែ! មិនឲ្យឯងចុះពីកប៉ាល់នេះជាដាច់ខាត តែឯងចុះហើយមកមិនទាន់ កប៉ាល់ចេញចោលដូចមុន មុខជាគេទៅចោលឯងហើយ!

— ទេ, ម៉ែ! ខ្ញុំទិញនៅខាងក្រោមទេតើ ខ្ញុំមិនចុះពីកប៉ាល់ទេ ។ ពីព្រឹកមិញខ្ញុំឃើញពួកកម្មករបង់បានត្រីធំ ៗ បើខ្ញុំសុំចែក ច្បាស់ជាគេលក់មិនខាន ។

នាងកាមាលា ចូលទៅយកលុយមកហុចឲ្យកុមារ : ។

— នែ! យកទៅទិញទៅ សល់លុយយកមកវិញ ។

---

១- ប្រាក់នៅប្រទេសឥណ្ឌា ។

បន្តិចក្រោយមក អ៊ុយមេស្ហត្រឡប់មកវិញ កាន់ត្រីមួយយ៉ាងធាត់ល្អមកផង ។

– ម៉ែអើយ ? គេឥតថែមលុយឲ្យទេ, គេយកទាំងអស់ទៅហើយ !

(នាងកាមាលាញញឹម នាងដឹងថាវាកុហកហើយ ។ )

– បើមិនសល់លុយក៏ចឹង ដល់តំណាក់ត្រូវតែរកលុយទៀត .

– បាទ ! មែនហើយម៉ែ ! បើមិនរកបានទេវិញអីក៏មិនពិសារ .

យូរក្រោយមកទៀតដល់ពេលបរិភោគអាហារ :

– អ៊ីយ៉ា ! ឆ្ងាញ់ណាស់ទេតើ ( កាមេស្ហលាន់មាត់សរសើរ ទាំងចាប់លើកក្បាលត្រីនោះផង ) នាងបានត្រីនេះពីណាមក ?

លុះកាមេស្ហបរិភោគរួច ដើរចេញទៅ ត្រូវដល់វេនអ៊ុយមេស្ហ, កុមារសប្បាយចិត្តនឹងបានអាហារឆ្ងាញ់ បរិភោគទាល់តែនាងកាមាលាឃាត់.

– ប៉ុណ្ណឹងបានហើយ ចាំល្ងាចសឹមស៊ីទៀត ម៉ែទុកឲ្យ .

រាត្រីកាលសន្សឹមចុះមក នារីក៏ចូលផ្ទះឈប់សម្រាកដូចកាលសព្វដងរៀងមក ។ នាងកាមាលារៀបចំទឹងចំអិនម្ហូបទៀតហើយស្រាប់តែកាមេស្ហដើរចូលមក .

– កាមាលាអូន ! កុំធ្វើអីទៀត បងឆ្អែតណាយពីព្រឹកមិញពេក ឥឡូវនេះគ្មានឃ្លានសោះ .

នាងកាមាលា ក៏រៀបបំរុងតែអ៊ុយមេស្ហទៅ ។ រាត្រីនោះព្រះចន្ទ

រះឡើងក្តៅត្រចះ ពោលស្ទើរទៅលើផ្ទៃស្រែធំធេងស្ងាត់ ៗ នាងកាមាលា ចេញមកឈរនៅក្អាក់ដែកប៉ាល់ ក្បែរកៅអីកមេស្ហ នាងលបគន់មើលទឹកមុខបុរស ក្រោមរស្មីព្រះចន្ទ, បុរសគ្មានចាប់អារម្មណ៍ដល់នាងបន្តិចសោះ គ្រាន់តែឃើញទឹកមុខបុរស នាងយល់ភ្លាមថា បុរសពុំមានជំពាក់អារម្មណ៍លើរូបនាងបន្តិចសោះទេ, នាងនឹកអាណិតខ្លួនកំព្រាស្រងូតចិត្ត ហើយទំថយលប ៗ ចូលទៅក្នុងបន្ទប់ងងឹត ដែលនាងមើលទៅហាក់ដូចជាមាត់សត្វអ្វីមួយគួរខ្លាច នាងព្រឺក្បាលខ្លាក ប៉ុន្តែបើមិនទៅទីនេះទេ តើមានកន្លែងដទៃឯណាទៀត ដែលគួរឱ្យនាងជ្រកបានដោយសុខុម .

នាងដើរចូលទៅ ប៉ះនឹងគ្រែកមេស្ហដែលព្យួរនៅក្បែរមាត់ទ្វារ ធ្លាក់ទៅលើហិបដែកត្រុកក៏ ធ្វើឱ្យគ្រែកមេស្ហដែលកំពុងតែស្ងប់គំនិត ភ្ញាក់ស្ទុះដើរមករកនាង ៖

– កាមាលាឬ ? បងស្មានថាអូនគេងទៅហើយតើ អូនខ្លាចឬ ? បងមិនទៅវាងក្រៅយូរទេ ហើយដល់បងចូលចាំបង់ទុកទ្វារចូលទៅបន្ទប់ចំហរ កុំឱ្យអូនខ្លាច .

– ខ្ញុំគ្មានខ្លាចអ្វីទេ

ថាតែប៉ុណ្ណោះ នាងទាញទ្វារបន្ទប់បិទគ្រឹប ហើយផ្តួលខ្លួនទៅលើគ្រែយកក្រមាខ្ទប់មុខយំ ព្រោះនាងនឹកឃើញកំព្រាពេក , គ្មានបុរសជាទីសង្ឃឹម . . . គ្មានគ្រួសារ គ្មានផ្ទះសំបែង នៅតែឯងបែបនេះ តើ

នាងនឹងអាចតស៊ូម្ដេចបាន . . . .

មនុស្សម្នាក់ទៀតបាំលច់ចូលទន្ទ្រាស្លាក់ឈើនាងគេងមិនលក់ ដោយវិតក្កកពេក ក៏ដើរចេញពីបន្ទប់ទៅអង្គុយខាងក្រៅ សំឡឹងមើលទៅលើប្រាំងឆ្ងាយ, យប់ជ្រៅណាស់ហើយ គ្មានមនុស្សម្នាណាដើរម្នាក់សោះ ព្រះចន្ទក៏សន្សឹមចុះបំបាំងខ្លួនទីងទោំងព្រៃ ផ្លូវដើងដែលញែកតាមគុម្ពស្រូវក៏មើលមិនឃើញដោយអន្ធការ នាងទឹកសម័យឃើញស្រី ៗ ទូលក្អមទឹកដើរដង្ហែគ្នាទៅកាន់ផ្ទះសម្បែងគេរៀង ៗ ខ្លួន ទឹកដល់ត្រង់នេះនាងស្អួលដើរមកចង់ស្រក់ទឹកភ្នែក " ចុះកំព្រាអ៊ីតែរូបខ្ញុំ រកគ្រួសារគផ្ទះសម្បែងនឹងគេគ្មាន ! "

នាងឮសូរជើងមនុស្សដើរស្រិប ៗ នាងភ្ញាក់ព្រើត " យី នាងមិនមែននៅតែឯងទេ " នាងងាកមើលក្រោយ

— ខ្ញុំតើម៉ែ, ( អ៊ុយមេស្រនិយាយ )

— ម្ដេចក៏ឯងមិនដេក ( និយាយបានតែប៉ុណ្ណោះ ទឹកភ្នែកនាងហូរស្រក់ទប់ពុំបាន វិស័យដូចពពកទឹកដែលរសាត់តាមផ្ទៃអាកាសទៅប៉ះលើខ្យល់ត្រជាក់ ក៏ធ្លាក់ចុះជាភ្លៀងដោយទប់ទល់នឹងទម្ងន់អម្រែកខ្លួនពុំបាន យ៉ាងណាមិញ, ពាក្យអ៊ុយមេស្រតែមួយម៉ាត់ក៏អាចធ្វើទឹកភ្នែកនាងកាមាលាឲ្យហូរបានដូចោះដែរ . . . .

កុមារកំព្រាឃើញម្ចាស់ស្រីរាយំ មិនដឹងរកពាក្យអ្វីនិយាយនឹង

នាង ចេះតែស្ងៀមមួយសន្ទុះ ទើបថា :

– ម៉ែ ! ប្រាក់ពីថ្ងៃមុននោះ នៅសល់ ៧ កាក់ទៀត ...

នាងបាត់យំទៅជាញញឹមទៅកាន់ក្មេង ..

– ទុកឲ្យស្រួលបួលទៅ រួចទៅដេកទៅ យប់ណាស់ហើយ .. នារីក៏ដើរចូលបន្ទប់វិញដែរ ។

## វគ្គទី ២៨

ព្រលឹមឡើង នាងចំធ្វើការទាំងព្រាន់ក្នុងចិត្ត មើលទៅព្រះអាទិត្យ ក៏ដូចជាឥតរស្មី មើលទៅទឹកទន្លេហូរ ក៏ដូចជាខ្ជិលច្រអូស មើលទៅដើមឈើដែលទោរទន់មកលើទន្លេ ក៏ដូចជាអ្នកដំណើរនឿយណាយ រកកម្លាំងទឹងឈរឲ្យត្រង់ខ្លួនពុំបាន លុះនាងឃើញអ៊ុយមេស្វាដើរទៅជិត ប្រុងនឹងជួយធ្វើការនាង នាងទៅជាមួរម៉ៅស្រែកថា :

– ទៅឲ្យឆ្ងាយ ! កុំមករេងគាង ?

– ខ្ញុំមានធ្វើអីម៉ែ ខ្ញុំមកជួយកិនគ្រឿងទេតើ ?

មិនយូរប៉ុន្មាន ទឹកមុខស្លេកស្រពោនរបស់នាង ទាញសតិអារម្មណ៍មេស្វាម អ្នកចំសួរយ៉ាងរួសរាន់ ក្រែងនាងឈឺ តែនាងគ្រវីក្បាលបដិសេធ ។

យុវជនយើងយល់ដល់ជម្រៅបញ្ហារវាងនារីនឹងអ្នក ដែលកាន់តែ

តឹងទៀង ៗ រាល់តែថ្ងៃ ,អ្នកពិបាកចិត្តពេក ក៏នឹកថា "បើសិនជាខ្ញុំថ្លែងទុក្ខរបស់ខ្ញុំតាំងពីមុនប្រាប់នាងហិមណាល័នឲ្យអស់សេចក្ដី ប្រហែលជានាងជួយដោះស្រាយរួច" គិតសព្វគ្រប់ហើយក៏ទាញក្រដាសមកសរសេរសំបុត្រ : កំពុងតែសរសេរ អ្នកព្រំទៀងមនុស្សប្រុកនិយាយមកកាន់អ្នក អ្នកធាប់ហែកសំបុត្រចោលភ្លាម ងាករកមើលម្ចាស់សំទៀងតាំងធ្លល់ ៗ តាចាស់ម្នាក់ក្បាលតក ពុកមាត់ស្កូវមួយៗ សួរភ្លាកថា :

សុំទោសលោក ? លោកឈ្មោះអ្វី ? លោកជាពូជព្រាហ្មណ៍មែនឬទេ ហើយលោកនេះហើយឬ ដែលឈ្មោះកាមេស្វាហប្អូ? ខ្ញុំសុំដកបសួរ សុំលោកកុំអន់ចិត្ត កុំលាក់ឈ្មោះលោកម្ដេអ្វី បើសិនជាលោកចង់ដឹងឈ្មោះខ្ញុំ , ឈ្មោះឪពុកម្ដាយ , ដីដូនជីតាខ្ញុំ ខ្ញុំអាចដំកបលោកបានតាំងអស់ ៗ

កាមេស្វាហស្ងើច ហើយឆ្លើយទៅវិញ :

— ខ្ញុំគ្មានអន់ចិត្តអ្វី គ្រាន់តែឆ្ងល់ប៉ុណ្ណឹងទេ លោកប្រាប់ឈ្មោះលោកឲ្យខ្ញុំស្គាល់ផងមើល លោកឈ្មោះអ្វី ?

— ត្រៃលក្សា ចក្របត្តិ តែអ្នកស្រុកនៅតាមដងទន្លេនេះ ហៅខ្ញុំតែ " លោកមាំ "ទេ , លោកប្រាំបាទ , តាកេតាស្ដេចអតិពជនៅតណ្ហាស្ដូននេះ ហើយខ្ញុំជាមារបស់ព្រះអង្គ ៗ ខ្ញុំចង់សួរថា តើលោកអញ្ជើញទៅណាដែរហ្នឹង ?

— ខ្ញុំមិនទាន់សម្រេចថា ចុះនៅឯណា នៅឡើយទេ លោកមា ?

— រឿងចុះពីកប៉ាល់នោះ យើងមិនបាច់ប្រញាប់ក៏បានដែរ បើគេឡើង ទើបត្រូវរត់ឲ្យទាន់គេ ។

— បាទមែនហើយ , តែកាលដែលខ្ញុំចុះពីរថភ្លើង នៅគ្រាលុនដ្យូ ខ្ញុំឮស៊ីប្លេកប៉ាល់ បន្លឺរន្ទើនៗ ខ្ញុំក៏រត់ឡើងភ្លាមមក រកគិតថាទៅណា មិនទាន់ ។

— ខ្ញុំកោតលោកដែរ ដែលធ្វើដូច្នេះកើត ព្រោះថាបើខ្ញុំវិញ ធ្វើដូច្នេះ មិនកើតទាល់តែសោះ ។ ព្រោះថាមុននឹងឡើងកប៉ាល់ ខ្ញុំត្រូវតែដឹងថា តើខ្ញុំទៅកន្លែងណាជាមុនសិន ទើបទៅកើត ។ ប្រពន្ធលោកមកតាមលោកដែរ ឬលោកអញ្ជើញមកតែឯងទេ ?

ប៉ុន្តែ លុះគាត់ឃើញកាមេស្ហឹមអៀមបែបមិនចង់ឆ្លើយ គាត់ក៏និយាយបន្ថែម . . . .

— ខ្ញុំដឹងហើយ សុំទោស ខ្ញុំឃើញនាងរៀបចំបាយទឹកជូនលោក ខ្ញុំឃ្លានដែរ - ខ្ញុំបានតាំងប្រាប់នាងថា កុំឲ្យនាងញញើតខ្ញុំផង ។ យី ! នាងនេះ ពិជាស្រីមេផ្ទះចំណាប់ល្អណាស់លោក ម្យ៉ាងទៀត ដោយខ្ញុំគ្មានគ្នាមកជាមួយសោះ ខ្ញុំបាននិយាយលេងនឹងនាងថា : "ខ្ញុំចង់សំបរិ-ភោគអាហារជាមួយនាងណាស់ មើលទៅម្ហូបនាងគួរឲ្យស្រក់ទឹកមាត់ នាងសើច , លោកអើយតាំងពីកាលណាមក ខ្ញុំមិនដែលបានជួបជោគ

វាសនាល្អ ដូចជនេះសោះ , ទ ! លោករវល់ឬ ? ខ្ញុំមិនចង់ឲ្យរំខាន លោកទេ , ហើយបើលោកមិនយល់ទាស់ទេ ខ្ញុំសុំទៅជួយធ្វើការប្រពន្ធលោកឯណោះ ដរាបណាខ្ញុំនៅទីនេះ ខ្ញុំមិនចង់ឲ្យប្រពន្ធលោករចដៃរចជើងទេ, កុំអញ្ចើញក្រោកធ្វើអីលោក ខ្ញុំទៅខ្លួនខ្ញុំបានហើយ . . . ។

ថាហើយលោកមាក៏ដើរចូលទៅកន្លែងនាងកាមាលាធ្វើម្ហូប . . . ។

– យីឈ្ងុយអីក៏ឈ្ងុយម្ល៉េះ! គ្រាន់តែធុំក្លិនឆ្ងាញ់មុនទៅហើយ មិនបាច់ចាំភ្លក់ទេ ទៅលាងដៃទៅនាង ដល់ពេលបាយហើយ ចាំខ្ញុំបង្ហើយកិច្ចការឲ្យ កុំព្រួយរឿងម្ហូប ខ្ញុំចេះ ព្រោះខ្ញុំធ្លាប់ធ្វើជាមួយប្រពន្ធខ្ញុំ, នាងសើច នាងមិនជឿខ្ញុំ ខ្ញុំមិនមែននិយាយលេងទេ ខ្ញុំចេះប្រាកដមែនណា៎ ?

– បើពូចេះ បង្រៀនខ្ញុំផង ។

– បង្រៀនម្ដេចបាន បើខ្ញុំទើបនឹងស្គាល់នាងសោះ ទាល់តែនាងយកចិត្តខ្ញុំណាស់ ទើបខ្ញុំប្រាប់ , ប៉ុន្តែមិនអីទេ , ដូចនាងមិនចាំបាច់យកចិត្តខ្ញុំច្រើនទេ , ព្រោះខ្ញុំដូចជាចូលចិត្តនឹងនាងទៅហើយ អ្នកណាឈរនៅនោះនាង ? កេងហ៊ង មានទឹកមុខស្រស់ស្រាយគ្រាន់បើ ។

អ៊ុយមេស្ហឈរបែខ្នង ពីចម្ងាយតែវាមិនសូវសប្បាយចិត្តនឹងអ្នកបំណូលថ្មីនេះប៉ុន្មានទេ, ព្រោះវាខ្លាចនាងកាមាលាស្រឡាញ់អ្នកថ្មីជាងវា ។

មាយើងចូលមកកាលណា ធ្វើឲ្យនាងកាមាលាមិនស្ងប់ហេងហាង កាមេស្វាក៏កង្វល់ស្រាលខ្លួនបន្តិចដែរ ៗ កាមេស្វាដែលពីដំបូងឡើងធ្លាប់តែស្ងួតស្ងាត់ទីងនាង ហើយទៅជាប្រែចិត្តផុយអំពីមុនស្រឡះយ៉ាងនេះ ធ្វើឲ្យនាងកាមាលាពីបាកចិត្តក្រៃលែង ម្ល៉ោះហើយនាងចំរកមធ្យោបាយនឹងទាញអ្នកឲ្យត្រឡប់ដូចដើមវិញ ៗ

ថ្ងៃមួយ នៅពេលដែលកាមេស្វាកំពុងតែគិតដោះស្រាយបញ្ហាបេះដូងរបស់គេ នាងកាមាលាទៅអើតនៅមាត់ទ្វារ ដើម្បីហៅលោកមាចក្របត្តិ ព្រោះសៀវភៅនោះនាងចំនេរ នាងរកគ្នានិយាយលេង ៗ គ្រាន់តែក្រឡេកឃើញនាងភ្លាម លោកមាលាន់មាត់ ៖

– យី ? មិនល្អទេណានាង !

នាងកាមាលាមិនយល់, លោកមានចង់ថាដូចម្ដេច ក៏មើលមុខគាត់ ធ្វើភ្នែកឡង់ឡង់

– មាចង់និយាយពីស្បែកជើងនាងណ៎ា ? នៃកាមេស្វា ! ក្មួយឯងនេះហើយ ជាអ្នកដើមគំនិត ក្មួយជីងជាផុយនឹងវិន័យសាសនារបស់យើងទេ ច្បាប់សាសនាបានចែងថា ជនណាដាក់ទ្រនាប់នៅបាតជើងខ្លួនដើម្បីដើរលើជីជននោះមើលងាយស្រុកទេសរបស់ខ្លួន ៗ ក្មួយជឿទេតថាប្រសិនជាកាលណោះ ព្រះរាមលោកមិនបង្ខំឲ្យព្រះនាងសីតាពាក់ស្បែកជើងទេ ប្រហែលជាព្រះលក្ខណ៍មិនព្រាត់ប្រាសអំពីព្រះអង្គទេ

ក្នុងរយៈពេល ១៤ ឆ្នាំ ដែលព្រះអង្គត្រេចរង្គត់ក្នុងព្រៃភ្នំក្រំថ្ម ឬ ! នាងសើច នាងមិនជឿក៏ហាទៅ, ខ្ញុំមិនឆ្ងល់ទេ ព្រោះថាចំពោះមនុស្សដែលរត់ទៀងកប៉ាល់ ហើយមិនដឹងថា : តើខ្ញុំត្រូវចុះទៅចំណតណានោះ យ៉ាងម្ដេចក៏បានដែរ -

— បើអ៊ីចឹងលោកមា ជួយសម្រេចតែម្ដងទៅ, តើយើងត្រូវចុះត្រង់ណា ( កាមេស្ហឆ្លើយ )

— ចុះនៅក្ហាស៊ីបូរីទៅ ឬ យ៉ាងម្ដេចនាង ស្រុកនេះជាស្រុករបស់ខ្ញុំស្រាប ហើយសម្បូណ៌ផ្កាកូឡាបល្អៗណាស់ ។

កាមេស្ហងាកមើលមុខនាងកាមាលា នារីងក់ក្បាលស្របយោបល់ . .

លោកពូចក្របត្តិនាំអ៊ុយមេស្ហទៅអង្គុយលេង ក្នុងបន្ទប់ជាមួយនឹងនាងកាមាលា ឯទាក៏ចេះតែបន្ដដំណើរជាធម្មតាទៅ យូរ ៗ សំណើចស្រួយរបស់នាងកាមាលាហើរមកប៉ះត្រចៀកកាមេស្ហម្ដង ៗ

(នៅមានត)

# ប្រមូលចំនុកបុរាណខ្មែរ

យើងដឹងហើយថា ប្រជាជាតិខ្មែរ ធ្លាប់មានអារ្យធម៌តាំងពីព្រេងនាយ វែងឆ្ងាយណាស់មកហើយ គឺតាំងពីសតវត្សដំបូង នៃគ្រិស្តសករាជ ។ ក្នុងអារ្យធម៌នោះ សិល្បៈជាមែកធាងមួយធំណាស់ ហើយមានប្រសិទ្ធភាពជាងគេក្នុងសន្តានចិត្តអ្នកស្រុក ។ ដូច្នេះ សិល្បៈ បានបែកចេញជាផ្នែកច្រើនណាស់ទៅទៀត ដូចជាភ្លេង, បទចម្រៀង, ចំនុកច្រៀង, ក្បាច់រាំ, អលង្ការ ។ ល ។

វេលានេះ យើងសូមល្បងធ្វើការប្រមូលក្រង "ចំនុកបុរាណ" របស់ខ្មែរយើងយកមកផ្សាយជាទិដ្ឋានុគត សម្រាប់យុវជនកុលបុត្រខ្មែរទាំងអស់ បានឃើញជាក់ថា ចំណេះវិជ្ជា សន្តានចិត្ត ការវាងវៃ សម្ពស្សវោហារ របស់បុព្វបុរសខ្មែរ មានដល់កម្រិតណា បើយើងពិនិត្យនៅក្នុងពាក្យកាព្យជាចំនុកច្រៀងទាំងនេះ ។ ចំនុកៈដែលចុះផ្សាយតទៅនេះ យើងប្រមូលបានមកពីនិគមជនបទនានាក្នុងព្រះរាជាណាចក្រ ។

ហេតុនេះ យើងសូមអំពាវនាវចំពោះអ្នកអានទូទៅ សូមមេត្តាជួយផ្ញើចំនុកច្រៀងបុរាណខ្មែរយើង ដែលអស់លោក-អ្នកបានចេះចាំ ទោះច្រើនក្តី តិចក្តី សូម្បីតែ ២-៣ បន្ទាត់ក៏ដោយ ឲ្យតែផ្ញើមកយើងនឹងចុះផ្សាយបន្ត ៗទៅ ដោយចុះនាមអ្នកផ្តល់ឯកសារនេះទុកជាតាងផង ។

មិនតែប៉ុណ្ណោះ យើងនឹងយកឯកសារនេះតម្កល់ទុកក្នុងការិយាល័យទំនៀមទម្លាប់សម្រាប់ជាឯកសាររបស់ជាតិ ទុកជាកេរ្តិ៍វែងឆ្ងាយ ។

ជាបឋមនេះ យើងចុះផ្សាយទំនុកខ្លះ ដែលប្រមូលបានពីអ្នកដែលធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ និងស្រង់ចេញពីសៀវភៅចាស់ ៗ ដែលមានតម្កល់នៅពុទ្ធសាសនបណ្ឌិត្យ ដែលបោះពុម្ពតាំងពី គ.ស. ១៩២៩ មកដល់ ១៩៤៩ ។ នៅលេខក្រោយ ៗ ទៀត យើងនឹងចុះផ្សាយត ៗ គ្នា នូវទំនុកដែលយើងបានទទួលពីអ្នកអានខ្លះ ពីឯកសារទំនៀមទម្លាប់ខ្លះ ត ៗ ទៅ ៖

## ទំនុកផ្តោះផ្តងស្រី - ប្រុស

ប. ឱម្លប់ដួងអើយ ដែលបងអង្គុយ
បងអត់ងងុយ ចាំស្រីរៃ ។
ចិត្តបងតែងចាំ ក្តុកបងរំពៃ
ចាំស្រីរៃ ចុះមកជួបបង ។
ស. មួយយប់មួយថ្ងៃ បានបីកម្រង
រៃចាំបង ទម្រាំខែលិច ។
ស្រមោចវាទាំ សង្ហារវាចិច

| | | |
|---|---|---|
| ខម្រាំខែលិច | ដាច់ខ្យល់បងហើយ | ។ |
| ប. ថ្ងៃអើយអ្នកថ្លៃ | ថ្ងៃអើយអ្នកថ្លៃ | |
| ខែភ្លឺដូចថ្ងៃ | នរណាឲ្យថ្លៃមក | ។ |
| ស. កាំភ្លើងចាំបែង | ដាវវែងចាំប្រក | |
| នរណាឲ្យថ្លៃមក | មិនដឹងខ្លួនស្លាប់ | ។ |

នេះសម្រាប់ប្រុសប្រៀងផ្ដើម បើស្រីផ្ដើមវិញ ថាដូច្នេះ:

| | | |
|---|---|---|
| ស. ឧម្ចប់ដូងអើយ | ដែលប្អូនធ្លាប់ជ្រក | |
| ចាំប្រុសពន្លក | ព្រលឹងថ្មើមថ្លៃ | ។ |
| ចិត្តប្អូនតែងចាំ | ភ្នែកប្អូនរំពៃ | |
| ចាំអ្នកប្រុសថ្លៃ | ថាមកជួបប្អូន | ។ |
| ប. បងបិតបន្ទោះ | មិនទាន់គ្រប់ខ្លួន | |
| បងបិតចាំអូន | ខម្រាំខែលិច | ។ |
| ស. ស្រមោចរាំទាំ | សង្ហាររង់ចិច | |
| ខម្រាំខែលិច | ដាច់ខ្យល់ប្អូនហើយ | ។ |
| ប. ថ្ងៃអើយស្រីថ្លៃ | ថ្ងៃអើយស្រីថ្លៃ | |
| ខែភ្លឺដូចថ្ងៃ | នរណាឲ្យថ្លៃមក | ។ |
| ផចាំផ្លូវវែង | ម៉ែចាំស្លាក់ប្រេក | |

ម៉េចក៏ថ្ងៃមក　　នៅពេលថ្ងៃនេះ ៗ

(ទំនុកនេះបានមកពី សហ. ព្រួច - ភុម)

ប. ស្មើរអើយស្រីស្មើរ　　ស្មើរអើយស្រីស្មើរ
បងរៀបដំណើរ　　បានអ្វីឲ្យបង ៗ
បានស្លាមួយមាត់　　កន្ទេលមួយផង
បានអ្វីឲ្យបង　　បងទៅទន្លេ ៗ

ស. អ្នកទៅទូកអ្នក　　ឬទៅទូកគេ
អ្នកទៅទន្លេ　　ប្រយ័ត្នជើងដៃ ៗ
មុសកាំខាំយប់　　សុចកាំខាំថ្ងៃ
ប្រយ័ត្នជើងដៃ　　ក្រែងខ្យល់លេក ៗ
ព្រោះខ្យល់លេក　　ហោកបែកផ្កាក្រែង
អ្នកប្រុសកំប្លែង　　ស្តាប់ពាក្យប្អូនផ្តាំ ៗ
ប្អូនផ្តាំទៅអ្នក　　អ្នកថាមិនទើង
ត្រឡាចមានជើង　　ប្អូនមិនទើងយកប្តី ៗ

ស. អ្នកជិះដំរី　　ប្អូនស្រីជិះទូក
ចូងពាមមាត់ជ្រូក　　ធ្លាងបាយមួយគ្នា ៗ
អង្ករមួយកញ្ចប់　　ដុតជាក្រឡាន

| | | |
|---|---|---|
| ខ្លាចស៊ីមិនបាន | កៀកកន្ទាយំ | ៗ |
| ប. ចន្ទអើយស្រីចន្ទ | ចន្ទអើយស្រីចន្ទ | |
| រំកាយប្រាំជាន់ | ហៅចន្ទស៊ីស្លា | ៗ |
| កំពោរអប់ស្ងួន | ក្រមួនអប់ផ្កា | |
| ហៅចន្ទស៊ីស្លា | ចន្ទអើយកុំខ្លាច | ៗ |
| ដំរីបង់មួយ | ជញ្ជាបចិញ្ចាច | |
| ចន្ទអើយកុំខ្លាច | ដំរីបង់ទេ | ៗ |
| ក្រសាំងតាបអើយ | តាបអ៊ីម្ល៉េះទេ | |
| បង់នៅស្រុកគេ | រកស្លាស៊ីគ្មាន | ៗ |
| កាលនៅស្រុកបង់ | ស៊ីស្ងួនជើងពាន | |
| រកស្លាស៊ីគ្មាន | ហៅស្រុកកំសត់ | ៗ |

(ស្រង់ពីប្រក្រតិទិនកម្ពុជា ឆ្នាំ ១៩៤៥)

| | | |
|---|---|---|
| សរើយសស្អាត | សអើយសស្អាត | |
| លាងដៃកប់បាត្រ | នាងប្រាថ្នាអ្វី | ៗ |
| ចង់បានកូនប្រុស | តាមក្បាលដំរី | |
| បើបានកូនស្រី | ស៊ីជើងដាំមុខ | ៗ |

ផ្គរលាន់ឯត្បូង ត្រយូងចេកក្ដឹប
លើកគ្នាសាមសិប ដណ្ដើមកូនគេ
ឪពុកថាឲ្យ ម្ដាយថាទេ
លើកកូនឲ្យគេ ចង់ស៊ីក្បាលជ្រូក ។

ដំរីធ្ងន់ក្លុក ក្របុកធ្ងន់ផ្ទៃ
យកគេធ្វើម៉ែ មិនដូចម៉ែខ្លួន ។

មុំអើយស្រីមុំ ស្រីលេងបាយខុំ
ស្រីមុំឃ្លាងបង ឃ្លាងអស់តាំងគេ
គេឃ្លាងម្ដងៗ ស្រីមុំឃ្លាងបង
ឃ្លាងហើយឃ្លាងទៀត ។

ស្រីតូចទ្រទាប់ ធំឡើងឲ្យឆាប់
ឲ្យទាន់ឆ្នាំបង ស៊ីបាយជឹកទឹក
មួយថ្ងៃប្រាំដង ឲ្យទាន់ឆ្នាំបង
ពិសាខឆ្នាំក្រោយ ។

កាំអើយស្រីកាំ ព្រះពុទ្ធលោកផ្ដាំ

ថាអាំដោយបង　　　　　បងដាំពោធិមួយ

មិនទាន់បានចូន　　　　　បើអាំដោយបង

ចូនពោធិពីរនាក់ ៗ

(ស្រង់ពីប្រតិទិនកម្ពុជា ឆ្នាំ ១៩៤៦)

# ល្បើកអក

[ក]

( ចម្លងពីសាស្ត្រាស្លឹករឹត )

ពាក្យ ៧

ត្រាចត្រៀករលៀករលាយលោត  កែវកោតកោងកាងមាក់ប្រាងជាប់
មាក់ប្រេងដុះជិតដើមទម្លាប់  ទន្ទាលូតប្រសព្វសន្ទឹកគ្នា  ៗ
ថ្មថ្ងាន់លំពាន់ទំពូងពោន  ស្វាស្វាបត្រទុនសោកសែងព្រា
ព្រីងព្រំខ្ទឹងខ្មួតឪជ្រឹងល្វា  ពុទ្រាខ្នុរណាំងក្រសាំងខ្វិត  ៗ
ស្រគំស្រកាក្តាមក្តុលក្តួច  ទ្រមូចទ្រមូងដូចស្រឡៀត
ស្រឡៅតាត្រាវប្រេបប្រេកិត  គគិតគគីរស្ពីលាយ  ៗ
ស្តីស្តៅស្តុកស្តុរត្រមុលមៀន  ទូរេនគូលែនប៉ែនដក់ពាយ
ជកពពង្រពេគពងពយ  វល្លិ៍ពយវល្លិ៍រើកត្រើកត្រដិត  ៗ
វល្លិ៍ពាសផាសដោយដើមក្នុំក្នែង  ប្រទាក់ខ្វាត់ខ្វែងប្រក់ប្រកិត
សន្ទឹកលូតលាស់ស្រស់គ្មានស្វិត  ធោមស្និទ្ធមិត្តមូលទឹងឫខក៏  ៗ
ទីនេះសុសសាយសប្បាយគ្រាន់  ទឹងជិះទឹងជាន់ស្និទ្ធស្នេហា
បម្រើនកម្លាំងខ្លាំងក្លៀវក្លា  ដោយសារព្រៃព្រឹកស្លឹកត្រជាក់  ៗ
ផុះផុបព្រាបម្យ៉ាក  ប្អូនត្រេកស្រវៃដូចក្ងិនអក

កាលថ្ងៃអាស្រ័យនៅរូមរែក្ស    មិត្តកក្តិទីឯខ្ញុំពុំមិនបាត់ ៗ
អកទំយំគិតអាណិតខ្លួន    ព្រួយប្រួនស៊ើរប្រេះថ្លើមប្រមាត់
សញ្ញាប់សុបសៅនៅស្ងប់ស្ងាត់    មើលទីដទៃទៅរកស៊ី ៗ
ត្រយង់គេងកងកុកគ្រោងគ្រែង    ក្អែកក្អាតតាតខ្ទឹងក្ងាជាន់ញី
ទុងទោមប្រើកគតឹកយ៉រ    ពីរៗសន្ទឹមទទឹមគ្នា ៗ
ចៀបចាបលលកលលេលេង    ទន្ទេងទន្ទឹមទឹងគួប
នោះនៃប្រទ្បេទោមទា    ក្រសាស-កស្ទាំងប្រដៀវ ៗ
ក្ងានក្ងាកប៉ោលតាកទុង    សំកុងសំកុកលើឈើគៀវ
សេកសត្វសារិកាហាហើរខៀវ    កញ្ជ្រៀវប្រចឹកប្រឡែងគ្នា ៗ
ទន្ទេបស្វិតចៅតាវើសត្វ    ហើរគាត់ទាំមករកគួប
កាកព្រួប្រសព្វស្អប់ស្អល់ស្អ    រោរកស៊ីទាំងពីរនាក់ ៗ
មេអកមើលយល់ខ្វល់កង់ចិត្ត    ឆ្អែតឆ្អិតច្រូងត្រូតតែរង់អាក់
រលឹកនឹកប្តីបង់រូមរែក្ស    មិត្តកក្តិភាកព្រួប្រសព្វគ្នា ៗ
ទួញយំសង្រេងកន្ទេងនឹក    សរង្រៃគ្រួចក្តឹកធ្ងួសអង្គា
ភ្នាត់ដើងកើចចាប់មែកព្រា    ដូលផ្ការជង្រាងស្រទាងខ្ទោក ៗ
ក្ងាក់ព្រោណពានប្រឹងជឹងខ្លួនជាក់    ជាផ្ងាក់ដួលប្ញោះគ្រេះស្ទុះក្រោក
ហើរទៀងឈើធំទីយោគ    សោយសោកសល់សែនណែនឱក ៗ
ខ្សែតខ្សែតឱ្យកខ្សួលវគេះឱស    ទុញតុះទៀងរញ្ញទំនួញថា

នាំថ្ងៃថ្នមចិត្តមិត្តសង្សារ ទៅឯណាបាត់ពេកចម្លែកម្ល៉េះ ៗ
បួនតែងតាមអ្នកស្រាក់ស្រូតរក អ្នកប្រុសពន្លកល្អចំណេះ
ប្រឹងហើយប្រឹងហត់មាត់ប៉ផ្ទះ តឹងទ្រូងស្ទើរប្រេះរលេះថ្លើម ៗ
ប្រុសអើយសត្វគេដទៃទៀត ទំទីមចង្អៀតឈើមួយដើម
ផ្ទុំកូនស្រុះស្រួលផ្ទួលជ្រៀវជ្រើម ប្រឡែងដណ្ដើមចំណីគ្នា ៗ
ខ្លះបៀតបៃរបានប្រាណប្របជិត ស្នាលស្និទ្ធដោយបែបសេពគប់
បួនយល់ខ្វល់ចិត្តគិតប្រុសក្លា អង្គាព្រួញត្រីស្ទើរដាច់ខ្យល់ ៗ
មិនដឹងថ្ងៃណាទីងបានស្បើយ កម្មអើយកម្មអ្វីតាមមកផ្តល់
មកឃាតខ្លួនប្រុសឲ្យឆ្ងាយធ្ងល់ ឲ្យឆ្ងាយកាយគលកើតទុក្ខា ៗ
អកទំបន្តិចលេចឃើញទុង ហើរស្ទុងមកទំទៀបអាត្មា
អកក្រាបទន្ទាបកបសរសោ សួរថាលោកមាកណិតកយ ៗ
កយមានទុក្ខធ្ងន់ពន់ពេកក្រៃ ស្ទើរក្សយជីវិតពីព្រោះព្រួយ
ព្រោះប្រាណកំព្រាតែក្បាលមួយ ត្បិតកយលោកមាលាទៅបាត់ ៗ
សខ្យាថាទៅតែបីថ្ងៃ ប្រាស្រ័យស្វរកូនកំព្រាក្ដាត់
និត្យនៅព្រៃក្នុងទ្រទំស្ងាត់ ខ្ញុំធ្ងល់ទីងបាត់មិនជួកាល ៗ
ខ្ញុំមកតាមរកគ្រប់កន្លែង បឹងស្ទឹងខ្វាត់ខ្វែងព្រៃព្រឹក្សសាល
ស្ទើបសួរសុសសព្វគ្រប់អម្បាល ដែលស្គាល់ស្និទ្ធស្នាលគ្មានប្រទះ ៗ
ឥឡូវលោកមាសូមប្រោសប្រាណ ប្រោសប្រាប់ឲ្យបានដឹងការខ្លះ

លោកមាមេត្តាថាឲ្យច្បាស់ ខ្ញុំនឹងរូតរះទៅតាមដាន ៗ
ទុងឆ្លើយក្មួយអើយមាសព្ធថ្លៃ អាស្រ័យទីនេះនៅនាឋាន
ហាក់ជាចន្ទោះសោះមិនបាន ឃើញប្រាណអកលោហារហើរមក ៗ
ឬក្រែងឯងអាត់តែមុជទឹក ចិត្តទឹកសិនសមខំតែរក
ត្រីសាច់ឲ្យបានមិនហ៊ានជ្រក ជូនមកចន្ទោះនឹងក្អែកមា ៗ
អកស្តាប់ទុងប្រាប់ថាមិនយល់ រឹងតាល់ទុក្ខធ្ងន់អស់អង្គា
ដាក់ក្បាលរេញ្ចកបក្រាបលុតលា ទុងហើរមម្មាតាមទៀតទៅ ៗ
សង្វាតសង្វេតឯកកាយា ចូលក្នុងព្រឹក្សាព្រឹក្សាន្តជ្រៅ
ខ្ញុញថានុណាអ្នកប្រុសពៅ អ្នកនៅទីណាអ្នកថ្លៃអើយ ៗ
ប្អូនគេជ្រកគ្មានចន្លោះ គៀនគោះគុម្ពោតពុំយល់ស្បើយ
បឹងព្រៃស៊ីងសព្វគ្រប់ទិសហើយ ប្រុសអើយថ្លៃណាទីងជួបជួន ៗ
អកយំសង្រេងសង្វេងស្អា អនិច្ចាអកខំទ្រាំទ្រមខ្លួន
ទ្រមទ្រាំងកាំងខ្វាចឃ្លាតប្រុសសួន ទុក្ខធ្ងន់ថែមថប់ចំប្រួប់ប្រាណ ៗ
កាងស្ទាបដាបស្អុតរន្ធត់ធ្លាក់ ដូចគេទម្លាក់ដល់ដែនដាន
ដល់ដីអស់ស្រីសែនរំខាន ទណាក់ធរណីត្រវីក្បាល ៗ
ទន់គោះជ្រោជ្រប់សន្ទប់ស្មុន្យ លង់លុះដឹងខ្លួនក្រោកដោះដាល
ទំះហើរទំលើព្រឹក្សាសាល កើតការលំកំសត់សោកកើតចិ ៗ
គ្រោះនោះមែនមានសក្តានដក់ ហិចហាក់ហើរបករកបាប់ត្រី

បានដល់យល់យល់សត្វអកស្រី    សោកប្ដីរហែបពេបឥតស្បើយ ៗ
តាជក់ហក់ចុះមោះមកទំ    សួរថាក្រមុំមាសតាអើយ
មានហេតុភេទអ្វីណាស្រីអើយ    ចៅអើយប្រាប់តាឲ្យដឹងជាន ៗ
គ្រានោះបក្សីអកស្រីសត្វ    ប្រណិបតន៍ថ្លាស់ឆ្លើយស័ព្ទសង្សារ
ថាឱលោកតាសូមប្រោសប្រាណ    សូមទានស្ដាប់ខ្ញុំជម្រាបតា ៗ
សង្សារតែមួយជាត្រួយចិត្ត    ធ្លាប់ស្និទ្ធស្នេហស្នាលជាធម្មតា
ប្រែព្រាត់ប្រាសព្រាកចាកឧក    ប្រាប់ថាទៅរកស្រូវកូនចៅ ៗ
សន្យាថាឆាប់មកទេត្រូវ    ឥឡូវបាត់យូរគួរឲ្យក្ដៅ
ក្ដុកក្ដួលរំជួលចិត្តមួម៉ៅ    ទ្រូងចៅស្ទើរធ្លាយខ្លាយស្ទើរធ្លាក់ ៗ
លោកតាជាចាស់ច្បាស់សេចក្ដី    ជាស្រីភល់កាយកាមរាគកក់
ដូចជាតណ្ហាឡើងគ្មានអាក់    សស្រាក់ហៀរហូរពោរពាសថ្ពាល់ ៗ
ដូចខ្ញុំក្រមុំយ៉ាងប៉ុណ្ណោះ    មិនចេះហៅឲ្យបានផ្អែកផ្អល់
ចំណីបាយត្រីផ្ទឹមមិនដល់    ស្ទើសល់ចោលនៅចៅមិនថា ៗ
សង្សារសង្ស័យជាន់ជីវិត    មិនគិតស្ទើស្លាប់តាមវាសនា
គេកាប់គេដោតដូចម្ដេចម្ដា    ទោះខ្ញារមាសមិនមានក្រែង ៗ
បាត់អស់របស់ទ្រព្យគ្រប់ប្រការ    ចិន្ដាកាកាត់មិនស្ដាយស្ដែង
ឯបាត់សង្សារដូចខ្ញុំឯង    រមែងមានទុក្ខពុំសុខឡើយ ៗ
តាជក់បានស្ដាប់គ្រប់ប្រការ    ឆ្លើយថាចៅស្រីស្ដីត្រូវហើយ

វិស័យសង្ក្រាមាសតាអើយ     ទៅអើយទៅជាតាពូលចិត្ត ៗ
ដូចជារូបតាដកដល់     កាយកល់ស្គមពេកស្បែកជ្រីវស្វិត
ជើងដៃសរសៃរួញរួបរឹត     ល្ហេវល្ហិតកម្លាំងកាំងស្ការតើ ៗ
ដូចប្រេះម៉េះម្តេចគង់មានចិត្ត     ស្នេហាស្និទ្ធអាល័យរូបពងស្រី
ល្អល្អះត្រយង់ចង់បេតី     មេត្រីត្រេកត្រង់ការគាមគុណ ៗ
ស្រដីឡ្យកលយឲ្យផ្តើសផ្តាស     ប្រឡ្យះប្រឡ្យើសលើសលៀនស៊ុន
វង្វេងដោយនាមនាំខុសទុខ     ខ្លួនចាស់កម្រុនកម្រើកចិត្ត ៗ
រសាប់រសល់ខ្វល់ខ្វាំងណាស់     ខ្លួនចាស់កំព្រឹងក្ដីងក្លេចគិត
នឹកស្មានថាប្រាណនៅមានបុទ្ធិ     ដល់បានជិតលោរួញគង្ហួញថយ ៗ
អេះអុះអាបឡ្យប ស្ទាបតែដៃ     ម៉ៃងាយថាអារ៉េតេធ្វើប៉យ
គេស្តោះមកធ្វើយហើយក្រោកក្តួយ     ឯងអៀនស្រមយស្រមេះមុខ ៗ
គេគេចបាត់ទៅនៅទីកស្តាយ     កងកាយផ្អេតផ្អល់ខ្វល់កើតទុក្ខ
ជ្រងោចប្ដូរនៅប្រងឹក     រិតក្តាំខានមិនក្សាន្តចិត្ត ៗ
ខ្លួនប្រាណមិនបានកំឥតថា     ប្រាថ្នាឲ្យបានតែដៃជិត
ដៃដល់ប៉ះពាល់ប្រកៀកកិត     ទើបបានស្បើយស្បៀតឥតទុក្ខា ៗ
ខ្លួនតាចាស់ព្រឹទ្ធិគិតពេកបង់     បំណង់បើនាងនៅរួបា
ក្មេងសោះទាន់អស់ពីកាលណា     កំពុងខ្លាំងក្លារបាស់ក្លែត ៗ
កម្រៃតពាល់ដល់ដោយដៃ     វិស័យខ្លួនក្មេងគ្មានទោសហេតុ

ឈាមនៅកវរង៍ថ្លាអណ្ដែត ទឹកឲ្យឆ្អល់ឆ្អែតម្ដេចមាសគា ៗ

នុះប៉ៅសម្លាញ់អញអាណិត ព្រោះត្បិតនាងឯងក្មេងណាសា

កំពុងពេញពាលស្របាលក្វា តណ្ហាកម្លាំងបន្តិចផង ៗ

តានៅទីនេះជាយូរហើយ ប៉ៅអើយគ្មានឃើញសល់ជាម្ដង

មិនដែលអកណាទើងហើរធ្វេង តែសង់សាមយំពុំមានឡើយ ៗ

ប៉ៅទៅសួរគេដទៃសួន ក្រែងជួនគេឃើញណានាងអើយ

អាណិតប៉ៅតាអីម៉្លេះហើយ ប៉ៅអើយទៅចុះដូចបណ្ដេញ ៗ

បក្សីស្រីអកស្ដាប់តាជក់ លោហាក់ហៀរហើរលេលើចេញ

ទទះបក្សាលឿនស្ទុះស្ទេញ ទ្រូងម្ញេញពេញទុក្ខពុំសុខចិត្ត ៗ

ខំហើរបានដល់យល់ទីទួល ព្រៃស្រួលស្រោងស្រស់លាស់ប្រកិត

ប្រគងទងទាក់ហាក់ប្របជិត អកគិតថាទព្រៃនេះហើយ ៗ

ល្អពេកបម្រែកទឹងព្រៃបឹង ព្រលឹងប្រុសនៅនេះដឹងអើយ

ប្អូនហៅធោម ធ្លាមិនឮឆ្លើយ ប្ដួមួយខឹងហើយប្ដីហ៊ាអ្នក ៗ

បើខឹងម្ដេចម្ដាមេត្តាឆ្លើយ ប្រុសអើយអាណិតចិត្តប្អូនស្ត្រី

ប្អូនស្មានថាបាននៅរួមរ័ក្ស រួមរូបរវល់ក្ខណ៍ដល់អស់ជន្ម ៗ

មិនដឹងមកប្រាសនិរាសគ្នា ប្អូនមហាចំបែងតែងទុក្ខធ្ងន់

ទុក្ខយើងព្រាត់ប្រាសប្ដីប្រពន្ធ ខ្លាំងលន់លើសទុក្ខគ្រប់ប្រការ ៗ

ទុក្ខមួយព្រួយចិត្តត្បិតអត់ឃ្លាន ទុក្ខពីរទឹងគ្មានស្បៀងអាហា

ទុក្ខបីនឹងគេធ្វើទោសា ទុក្ខបួនកាយាកើតព្យាធិ ។
ទុក្ខប្រាំនឹងប្រាសទ្រព្យសម្បត្តិ ទុក្ខប្រាំមួយនឹងសត្តុបង់ហោយើ
ទុក្ខប្រាំពីរនឹងលង់ក្នុងវារី ទុក្ខប្រាំបីអគ្គីឆេះពេលពល ។
ទុក្ខប្រាំបួននឹងខ្លួនធ្វើឲ្យក្តី មិនមានប្រណីដោយពុតពាល
ទុក្ខដប់គេស្អប់ធ្វើផ្គាល ផ្ចាញ់ផ្ចាលគិតកាល់សម្លាប់កាយ ។
ទុក្ខតពីនេះច្រើនសណ្ឋាន ពុំបានទុក្ខស្មើព្រាសសហាយ
ព្រាសឪពុកទុក្ខតិចជាងព្រាសម្តាយ ព្រាសកូនមិនស្តាយដូចព្រាសប្តី ។
រីទុក្ខនឹងព្រាសប្តីប្រពន្ធ ធំលន់ធ្ងន់លើសទុក្ខអ្វីៗ
អត់ឃ្លានគ្មានបាយដូចម្តេចក្តី ប្អូនស្រីគ្មានថប់គ្រប់ប្រការ ។
ថប់តែប្រុសព្រាសទិពសប្រាណ ពុំបានមូលមិត្តសិទ្ធស្នេហា
មិនដឹងប្រុសទៅទីឋានណា កនិដ្ឋានថប់ធ្ងនមួនមិនះស្បើយ ។
អកយំបណ្តើរហើរបណ្តែត ស្តាប់ហេតុក្រែងបីយំធ្ងង់ធ្ងើយ
ព្រះពាយបក់បោកមករំភើយ រហើយកាកាយខ្ចាយក្លិនផ្កា ។
ក្រអូបឈ្ងុយឈ្ងប់ត្រឡប់ហួង ផាត់ត្រង់ផាត់ចូលចំនាសា
មេអករំជួលអួលឧរា ថ្ងូញថាឱប្រុសសំឡាញ់ប្អូន ។
ព្រះពាយផាត់ផើយរំភើយផាយ គ្រសាយពពកមកពពូន
ធធុំក្លិនផ្កាភាគាដូន ផាត់ជាប់អង្គប្អូនក្រអូបសាយ ។
ប្អូនផ្អកលើកទឹកលែក ត្បិតបែកពីប្រុសព្រាសទៅឆ្ងាយ

កាលនៅនែបនិត្យផ្តិតផ្តកកាយ ក្លិនក្លាយជាប់ខ្លួនប្អូនមិនបាត់ ៗ
ក្លិនអ្នកប្រៀបហាក់ដូចក្លិនផ្កា រាគាបក់បោកពពួនសាត់
ប្រៀបដូចអ្នកប្រុសអ្នកប្រាសបាត់ ដូចខ្យល់ផាត់ពពកជ្រកព្រៃផ្សៃ ៗ
សុរិយ៍ទន់ទេរបែរបស្ចិម សន្ទឹមលិចបាត់ស្មើថ្ងៃ
បក្សីសេក្ខអកជ្រកអាស្រ័យ នៅព្នរដើមស្រល់ខ្វល់ក្នុងកាយ ៗ
រៀបកប់ទំនួញទួញថៃថា នុណាអ្នកប្រុសអ្នកប្រាសឆ្ងាយ
ប្អូននៅកំព្រាជាមេម៉ាយ កាខអើយប៉ៃណៃម៉ៃហ៊ិនហ្នាំ ៗ
អព្រាត្រស្រណាត់សត្វអកយំ ទូរគមឯកោគួរអេនិច្ចា
ជួនថប់ទឹងចិត្តគិតបង្ក្រ ស្អកស្អាសម្ទេងរងស្គមខ្លួន ៗ
ជាសទុំអកយំស្នូរគ្រលួច ព្រឺព្រួចរងារងាប់ជួន
ជាទុក្ខចំប្រចប់ថប់ព្រួយព្រួន ព្រួយប្រាណមាំមួនមិះល្ហែល្ហើយ ៗ
ទួញយំ ៗ យប់មិនឈប់ដេក ទឹកភ្នែកតកក់ស្រក់ឥតស្បើយ
ថ្ងៃងថាកុំងាប្រុសប្អូនអើយ ប្តីអើយរងាពន់ពេកណាស់ ៗ
ប្អូនធ្លាប់កៀតកិតជិតអង្គា រងាស្រោកស្រន់អន់បាត់ខ្លះ
បានស្តាប់អ្នកប្រុសឱសព្រៃលក្រាស់ ត្រាស្ទុះពកពំងរបាំងខ្យល់ ៗ
តទូវអ្នកទៅបាត់សុងសូន្យ ចោលប្អូនម្នាក់ឯងតែងកន្ទល់
ហោលហា ះតេងតាងគុញតប់ប្រមល់ សេនធ្ងល់សលឆ្ងាយកាយទោមស្ងួត ៗ
អកយំយ្មេរលង់លុះព្រឹកព្រាង ភ្ញីស្មាងស្រឡះរះរឿងឬទ្ធិ

សព្វសត្វប្រវាត់ហើរប្រកិត ប្រកិនដោយបនកនគូវ
អកយល់ទល់ទុក្ខមុខក្រៀមផ្អស់ ទុក្ខម្នោទោមនស្សស្រឹងកំព្រា
កំព្រានម្នាក់ឯងវែងវេទនា អង្គារន្ទត់ស្ងុតស្វាតើ ។
ខះខំតម្រង់អង្គកាយកល គិតដល់បក្សាជាស្វាមី
ប្រឹងហោះហើរផ្ទោះខ្ពស់ឡើងខ្ពី បក្សាសត្វសឹងវឹងវេក ។
គន់គយដោយសព្វព្រៃព្រឹក្សា បក្សាទ្រះនៅជ្រៀតជ្រក
ចំប្រេបសព្វដោយជ្រោយឈ្លូងញក ដេកដឹករករក៏វិវរចិត្ត ។
អកហើរពីព្រឹកព្រះសុរិយា លុះគ្រាព្រលប់យប់ងងឹត
បានដល់ព្រៃភ្នំទំនៅនិត្យ ទៀបជិតទ្រនំនៃអកប្ដី ។
អកទំសំកុកក្ដឹកក្បាលជ្រប់ សញ្ចាប់នៅលើដើមស្រឡី
ទឹកភ្នែកតតក់ស្រក់ដល់ដី អកស្រីរយោគសោកគ្មានឈប់ ។
គ្រានោះមានសត្វសារិកា នៅដើមបង្គៅជាទីម្លប់
យល់អកចម្លែកស្រែកយំយប់ សញ្ចាប់សញ្ចឹងនឹកសង្ស័យ ។
ព្រួសព្រូរៀបរាប់រឿងរកប្ដី បក្សីសារិកាអាណិតក្រៃ
និយាយប្រាប់ប្ដីសីថាហៃ អកថ្ងៃអកស្លាប់ស័ព្ទអកយំ ។
រាប់រៀបទំនួញម្ញួញរកប្ដី ចិត្តស្រីរូបគេហើយរូបខ្ញុំ
អកខេះប្រាកដរូបអកភ្នំ ដែលទំនៅទីគីរខ្ពស់ ។

បានជាហានថាគូអកកំ ត្បិតខ្ញុំដឹងរឿងកាលគាត់រស់
ពីកាលដែលខ្ញុំមានផ្ទៃពោះ អ្នកប្រុសមិនទៅទៅរកស៊ី ៗ
អ្នកឲ្យខ្ញុំនៅចាំសំបុក ផ្ញើទុកនៅនៃព្រៃគីរ
គ្រានោះអកកំទាំងឈ្មោលញី កូនពីរនៅតូចៈទីបដុះក្រាស ៗ
អកពីរអត់ឃ្លានគ្មានអាហារ ដោយសាររបឹងរឹងខ្លាំងណាស់
ទឹកបឹងត្រពាំងគោករីងខះ ទឹកស្រះទឹកស្រែតែដូចគ្នា ៗ
អកអត់ចំណីប្ដីប្រពន្ធ ស្គមលន់ណាស់ពេកពីរអង្គា
អកប្ដីស្រីដឹងទឹករិយា ឲ្យគ្នានៅក្រាបចាំសំបុក ៗ
រក្សាកូនតូចទាំងពីរមិញ ខ្លួនចេញទៅរកត្រីស៊ីចុក
អកញីគ្នាអវេតវិតក្ក រីកមុខញញឹមសង្ឃឹមប្ដី ៗ
គ្នាផ្ដាំថាទៅកុំនៅយូរ គិតគូរឲ្យខំរកតែត្រី
សន្យាថាទៅតែថ្ងៃបី អកស្រីផ្ដាំសព្វគ្រប់ប្រការ ៗ
អកប្រុសស្ទុះហើរលើទៅ មិនដឹងគេចទៅទិសឋានណា
អកស្រីយំក្រៃស្រែកច្រេច្រា ហើរហោះចោលកូនគិតតាមប្ដី ៗ
ទៅចោលកូនបាត់មានសត្វក្អាត សង្វាតៈហើរហោះផ្លោះមកខ្ញី
ចិកស៊ីកូនអកជាចំណី ចោលផ្ទឹងមកដីហើយហើរទៅ ៗ
ល្មុះយូរបន្តិចលេចមេអក ហើរមកដល់ទំលើលំនៅ

ជាទុក្ខមើលមុខជាំជាំខ្មៅ ទៅទៅរកកូនស្ងួនពុំយល់ ។
ឮតែទំនួញទួញពីប្តី មានស្រីអកបឹងរួមមណ្ឌល
ពោលកូនប្រពន្ធពុំវិល អំពល់អំពីទីលំនៅ ។
ហើយទួញរកកូនទាំងពីរបាត់ ក្តៅក្តាត់ពោកខ្លួនធ្លាក់ចុះទៅ
ដល់ដីសន្លប់ស្ងុបស្ងួនស្ងៅ ដោយក្តៅទឹងប្តីមានស្រីទៀត ។
មួយក្តៅទឹងកូនស្ងួនបង់បាត់ អកសត្វផ្តាច់ជន្មស្លាប់បង្បៀត
តំណាថ្ងៃតពីនោះទៀត ឃើញឈ្មោលបោលបៀតហើរមកដល់ ។
ទំលើសំបុកមុខមិនរេក ធ្វើក្អកក្អឹះៗគិតខ្វាយខ្វល់
សម្បុរស្មេកស្មាំងទាំងកាយកល់ ទំនងខ្វល់កង្វល់ចិត្តត្បិតមានពីរ ។
ឮទួញរៀបរាប់គ្រប់ប្រការ យំថាអកស្ងួនអកញី
ទឹងម្តេចចាំកូនស្ងួនដល់ពោលទី មាសមេកាត់ចិត្តបោលបោះបង់ ។
អកឈ្មោលរំពោតឈ្មោកមើលដី ឃើញស្រីអកស្លាប់ក្រៀមក្រញង់
ឃើញកូនទាំងពីរក៏ស្លាប់បង់ ហើរត្រង់ចុះទៅដល់ដែនដី ។
កាងស្លាបក្រសោបឱបខ្មោចកូន សន្លប់ស្ងឹងស្ងួនទៅទៀតខ្ញី
ដំណាលកាលលាទៅរកត្រី ពុំបានក្ដួបស្រុកសំបុកនៅ ។
រៀបរាប់សព្វស្មុសស្មុះឡើងហើរ លលើទម្លាក់ខ្លួនស្លាប់ទៅ

ប្រពន្ធចុងហោលទុកឲ្យព្រៅ | នោមនៅល្មមចាំយកជាយ៉ាង ៗ

សារិកាឈ្មោលញីប្រពន្ធថា | ផ្សៀងទុនកាមាកែកេបផាង

វេលាសាសព្វបក្សាកាង | ក្អែងក្អាងបរេចាថានាងអើយ ៗ

នាងឯងកំប្លែងថាដូច្នោះ | ខ្លោចប្រុសគម្រក់អង់ឥតត្រើយ

ស្ទះស្នែងថាឯងគ្រាន់បើហើយ | ដើមឡើយអ្នកឯងទៅកេត្រ ៗ

យកមកចិញ្ចឹមប្រពន្ធកូន | បាត់សូន្យមិនឃើញបានមានអ្វី

ទៅផ្ទួបចម្រប់តែទីងស្រី | សេចក្ដីវេលេគ្នាផាំកករ ៗ

ក្លែបអស់សំដីខ្ទីក្រឡះ | បានចំហោលបាស់មិនទឹកនា

ចិត្តជាសប្ដទ់ពន់វេលា | ហាទធ្វើឲ្យគ្នាបែរបង្ខាត ៗ

ខ្លោចអាគម្រក់អ្នកទួន | មិនគួរឲ្យយកជាក្បួនខ្នាត

សមតែសម្ពលដីចំណាំគ្នាត | ទើបសមមារយាទបុករូបរ៉ា ៗ

មេណារ៉ាដោយអាថែងនោះ | ចំពោះមេនោះស្រីសាធារណ៍

ស្ដាប់ធ្វើសំពីងវិញក៏ជា | បានប្រាក់ដួលស្ដាប់ឲ្យមើល ៗ

នាងឯងកុំឲ្យអញយកយ៉ាង | រឿងរ៉ាវទោសអញ្ជាមិនត្រើល

ហើរហោលក្បួនទៅទៅដដើល | ដួបបែរងើលងីង៉ុមក ៗ

មួយអតិមួយឃ្មាទព័ន្ធលើគ្នា | ក៏កក្លេចការងើរងើបក្បាលជ្រក

មិនមានគិតគួរស្រស្រើបរក | ជាល្មមយកជាគតាប់ ៗ

បេះឃើញតែប្រុសនោះមិនថា ប្ដីសីនណាក្ដក់ប៉ោះជាប់
ស្រីនោះដូច្នោះគេមិនពប់ អញស្អប់ស្មាលាដល់ទិញ្ញូខ ៗ
កុំឲ្យឃើញយល់យ៉ាងដូច្នោះ ជាតិនេះជាតិក្រោយកុំឲ្យមាន
ឃើញយល់អំពល់ចិត្តវិញ្ញាណ បើគ្មានស្ងួតព្រៅនៅទទេ ៗ
នាងឯងយកអញទៅប្រដូច មេខ្វូចនេះហើយតិចអញដេរ
យ៉ាងអញមិនបេះវេះវៀចវេរ រិះរេរកគល់តែដូច្នោះ ៗ
អ្នកណាក្សេចិត្តហ៊ាងអញ នេះពេញជាក់ជាតិជាហៅប្រុស
ស្រអាំស្រអុកទុក្ខចិត្តពុះ មិនខុសខ្វួចទេកុំថៃថប់ ៗ
គ្រានោះបក្សស្រីអកស្ដាប់ ព្រួសត្វសារិកាផ្កាសត្វស្ព
ឈឺចិត្តផិតផ្អល់ខ្វល់ហ្វឹមឡប់ ចំប្រាប់ប្រាណប្រឹងរំពឹងគិត ៗ
ថាដើសារិកាថាអម្បាញ ដៀលអញឯងស្មោះចំពោះពិត
ទុះហេតុតែកម្មទាំគំនិត ប្រព្រឹត្តឲ្យខុសប្រុសមើលងាយ ៗ
ដើគេប្រាកដប្រកាន់ចិត្ត ស្នេហ៍ស្និទ្ធគិតក្រែងលែងព្រាត់ព្រាយ
ស្មានតែទំនេរដូចនិយាយ បង់កាយទទេគេខ្វូចសោះ ៗ
បើបានដឹងជាន់ដូចសារិកា កាលណាទីងក្ដោយដោយដល់ម៉្វោះ
ប្រាកដស្ងួតអត់ឲ្យក្រៀមក្រោះ ស្រះណោះទឹកពោះដេកឲ្យងាប់ ៗ
បើត្រាំពុំបានមានមែកឈើ សសុលក្រកើកុំឲ្យធ្លាប់

កុំឲ្យខ្ចោយដោយគេឥតគំនាប់ ឥតគំនិតគិតគាប់ឲ្យគេថា ៗ
មេអកអន់ចិត្តឥតទុកដាក់ អៀនអាក់កុកក្ដុលអួលឧរា
ទឹកខ្មាសសំដីនៃសារិកា ឈឺផ្សាផ្សាយផ្សព្វចំប្រប់ប្រាណ ៗ
ព្រះចន្ទរៀងរះស្រឡះមក ពពកព្រះពាយផាយផាត់ប្រាន
មេអកតានតឹងរឹងរំខាន ពុំបានឈប់ដេកក្អែករំពៃ ៗ
រកមើលគិរីទីអកកុំ តែងទំសំណាក់នៅនាព្រៃ
ដោយពាក្យសារិកាថានោះនៃ អកស្រីឃើញពិតឥតបង្អា ៗ
គិតថាសារិកាស្ដីប្រាកដ ទឹងរត់រិះរះព្រះសុរិយា
ពុំចិត្តខ្មាសអស់សត្វសារិកា គេថាមុខគួរឲ្យឈឺណាស់ ៗ
ចង់ទៅឥឡូវទាន់យប់ស្ងាត់ ហើយកាត់ទៅឲ្យបានឃើញច្បាស់
បើពិតដូចពាក្យទឹងប្រែប្រាស ក្រឡាស់កែដកគំនិតថ្មី ៗ
អកគិតដូច្នោះស្មោះហើរទៅ សំដៅគិរីតាមសម្ដី
សារិកានិយាយប្រាយប្រាប់ប្ដី អកស្រីដល់ដួចក្ដួចចិន្ដា ៗ
ចូលចំទ្រនំនៃអកប្ដី បក្សីយល់ជាក់ជាក់កាយា
ចំពោកឈ្មោកមើលសព្វប្រការ ដោយសារពន្លឺព្រះចន្ទថែង ៗ
យង់យល់សម្បុកទុកទើរកូន ស្ងាត់ស្ងួនឲ្យគ្មានយល់ចៅកន្ទេង
គិតថាគិរីទីនេះឯង ពុំប្លែងប្លែកពីពាក្យសារិកា ៗ

យល់ពិតប្រាកដថាទ្រង់ អកត្តំជាសាច់សង្សាក
ពុំមែនជាទីអកឯណា គិតថាដូច្នោះស្អុះហើរទៅ ៗ
ចរចុះលុះដល់គល់គគីរ អកញីបានយល់ខ្មោចប្ដីនៅ
ស្ទាប់គរលើគ្នាក្នុងស្មៅព្រៅ ទឹកក្ដៅក្ដាត់ក្លួលអួលក្នុងចិត្ត ៗ
ស្ដីថាប្រាជ្ញាអ្នកឯងនេះ ដឹងយ៉ាងម៉្លេះៗអញមិនស្មិត
រលំអំពល់ឲ្យបង់ចិត្ត ដើស្ដាយគំនិតគិតឲ្យខុស ៗ
អញគិតថាចិត្តជាដូចមាត់ ថាអីប្រាកដដូចអស់ប្រុស
បើដឹងពុតពាលពីកាលនោះ មិនឲ្យចូលចុះទេអាពី ៗ
ណ្ហើយចុះស៊ុញោបានជាធ្លោយ ចូស់ធ្លាក់ខ្លួនដោយឥតប្រាជ្ញា
ធុរធោតលលោតដោយតណ្ហា បក្ខារបក្ខអស់ទៅហើយ ៗ
នឹងកែយកល្អក៏មិនបាន គ្រប់ប្រាណគេស្គាល់មិនសល់ឡើយ
ចង់ស្លាប់ឥឡូវទៅជាត្រើយ ថាហើយស្អុះហើរលើវេហាស៍ ៗ
ទៀងធាបទន្ទាបទំដើមបេង សង្រេងសង្រែងក្រែមហិមា
អកស្រីស្រដីខ្ញុំសូមលា ប្ដឹងអស់ទេវានៅសព្វស្ថាន ៗ
ថានុទេវាជាទិព្វចក្ខុ សូមអ្នកអាសូរសូមប្រោសប្រាណ
ជួយចាំជាតិខ្ញុំជាតិរង្វាន ប៉ុកប្រាណដោយប្រុសខុសយះហា ៗ
ចង់កើតព្រោះគេមានប្រាជ្ញា ចង់ការគេទុកជាស្រីពោរ
ស្រះប៊ីកទុកដូចជាចេញរះចាល់ មិនះហាដូចចិនថាមិនល្អ ៗ

សុខអីប៉ុណ្ណោះខុសទៅហើយ លោកអើយឱលោកទេពនិករ
មេត្តាប្រោះព្រំដោយស្មោះសរ ស្តាប់ខ្ញុំអង្វរសូមសច្ចា ៗ
ខ្ញុំកើតជាតិនេះប្លោះទៅហើយ ម្ចាស់ហើយនឹងរស់ក៏ឥតការ
សូមស្លាប់ចាប់ជាតិដោយសញ្ញា ប្រាថ្នាកុំឲ្យជួបឥឡូវ ៗ
កើតជាតិនានាជារូបអ្វី សេចក្តីដែលទឹកកើតអាស្រូវ
កុំឲ្យឃើញយល់អម្ពល់ត្រូវ រៀងទៅដកបងល់និព្វាន ៗ
ឲ្យរស់បក្សីជាប្រិសត្វ ចូរប្រុងប្រយ័ត្នស្តាប់ពាក្យមាង
ចាំទុកទៅមុខកុំពារពាន ស្តោកស្តានគំនិតគិតយ៉ាងខ្ញុំ ៗ

(នៅមានត)

# វប្បធម៌សំស្ក្រឹតអំពីបុរាណ

ព្រះមហាវីរិយបណ្ឌិតោ ចា៉ង - ខាត់ រៀបរៀង

(ស្រង់ចេញពីទស្សនាវដ្តីពុទ្ធិកសិក្សាឆ្នាំ ១៩៥៨)

ក្នុងអត្ថបទមុន ខ្ញុំបានទាញយកប្រវត្តិសាស្ត្រខ្មែរពីបុរាណជាបទសន្និទ្ទទ័យ តាមសេចក្តីសិលាចារឹកទាំងឡាយដែលអ្នកប្រាជ្ញបានរកឃើញមក ពោលខ្លះសម្រាប់ប្រដាប់ប្រាជ្ញា លោកអ្នកអានទុកជាការផ្តើមសកករាជមួយទៀត ដើម្បីជាជំនួយជួយឲ្យយល់វប្បធម៌សំស្ក្រឹតក្នុងចក្រអក្សរសាស្ត្រនីមួយៗ ៗ ក្នុងសម័យវេលានេះ អត្ថបទក្នុងសិលាចារឹកទាំងឡាយខ្លះ យើងអាចទុកជាការផ្តើមចក្រអក្សរសាស្ត្រមួយបាន ហើយសិលាចារឹកដែលយើងគួរយកជាវត្ថុធាតុសម្រាប់ពិចារណាមាន ៥ គឺ សិលាចារឹកវត្តលួងកៅ ១ សិលាចារឹកហាន់ជ័យ ១ សិលាចារឹកអង្គជំនិក ១ សិលាចារឹកវត្តព្រៃវៀរ ១ សិលាចារឹកក្រុមសម្បូណ៌ព្រៃគុក ១ ។

យើងមើលសិលាចារឹកវត្តលួងកៅហើយ សឹមមើលសិលាចារឹកដទៃៗ តាមលំដាប់សកករាជទៀត ។ សិលាចារឹកវត្តលួងកៅជាសាសនាព្រាហ្មណ៍ នៅទីវត្តលួងកៅជាទីបរិវេណចម្បាសក្តិ ជាសិលាចារឹកចាស់មួយជំនាន់សម័យនគរភ្នំ តែមានបែបបទផ្សេងពីគ្នា មិនមានកាលបរិច្ឆេទទេ ហើយលក្ខណៈអក្សរនាំឲ្យយល់ថានៅក្នុងគ្រិស្តសតវត្សទី ៥ ទំនងជារបស់ខ្មែរ តែអ្នកប្រាជ្ញខ្លះយល់ថា ជារបស់ចាមពីបុរាណ, និយាយពីព្រះរាជាមួយព្រះ

អង្គ ព្រះនាមទេវានីកៈ សោយរាជ្យនៅក្រុងជាទីបរិវេណចម្បាសក្តិ នៅគ្រិស្តសតវត្សទី ៥ ជាទ្រង់មកពីប្រទេសឆ្ងាយតាមសេចក្តីត្រូវការទេវតានៅលិង្គបព៌តជាលិង-គៀ-ប៉ូ-ប៉ូ របស់ចិន ដើម្បីប្រសិទ្ធិកំពង់បុណ្យធំ (មហាគជ:) ក្នុងទីនេះ ។ ដើម្បីពិចារណាព្រះនាមថា "ទេវានីកៈ" ដែលជាប្រធានសព្វក្នុងអត្ថបទសិលាចារឹកនេះ មានការចាំបាច់ត្រូវនិយាយពីមូលហេតុផ្សេង ៗ ដែលទាក់ទងនឹងរឿងនេះធនធំខានពុំបាន ព្រោះនឹងបានជាពន្លឺក្រោលបំភ្លឺមើល ព្រឹត្តិការណ៍ដែលនាំឲ្យកើតជាព្រះរាជអាណាចក្រខ្មែរឡើងក្នុងកាលនោះគឺ ៖

១– តាមសន្ទស្សន៍នៃអ្នកប្រាជ្ញខ្លះយល់ថា ក្នុងគ្រិស្តសតវត្សទី ៤ ទីទំនាបទន្លេមេគង្គត្រង់ខាងលើជួរខាន គួរទុកជាទីបានឋិតនៅក្រោមអំណាចនៃប្រទេសចម្ប៉ា ឯទីវាលខាងត្បូងក្នុងដែនវែកទឹងទីទំនាបទន្លេមេគង្គត្រង់ខាងក្រោមជួរខាន ឋិតនៅក្រោមអំណាចក្សត្រវង្សកម្ពុជ: ហើយកាលនោះទំនងជានៅក្នុងចំណោះប្រទេសនគរភ្នំផង លុះដល់មកចុងគ្រិស្តសតវត្សទី៥ ក្នុងរជ្ជកាលព្រះបាទទេវានីកៈ (ហ្វាន់-ចេង-ចេង នៃប្រទេសចម្ប៉ា?) (តាមសេចក្តីក្នុងសិលាចារឹកល្អងកៅ) ឬក៏ព្រះរាជាជាលំដាប់តមក ព្រះរាជាវង្សកម្ពុជ: គឺព្រះបាទស្រុតវម៌ននិងស្រេស្ឋវម៌ន បានពង្រីកអាណាចក្រព្រះអង្គទៅដល់តំបន់ខាងជើងក្នុងដែនវែកៈ មានគម្រលើលិង្គបព៌តនូវគិរលិង្គនាមគេស្រ្រគុរ: ជាអាទិទេពនៃជាតិប្រទេសចម្ប៉ា សំគាល់ឲ្យឃើញថាទំនងជាទ្រង់

មានជ័យជំនះឈ្នះចាម ហើយត្រួតត្រាប្រទេសចម្ប៉ាសក្តិ ។ សេចក្តីត្រង់នេះ មានទំនងដូចជាយើងបានដឹងតាមពង្សាវតារយើងថា "ព្រះថោងជាបឋមក្សត្រ បានធ្វើសង្គ្រាមនឹងព្រះបាទអស្សរេចយ្យរាជជាស្តេចចាមហើយមានជ័យជំនះរឿងនេះទេដឹង?។ ចំណេរកាលមក ទើបព្រះរាជានៃរាជវង្សកម្ពុជៈទី ៤ និងទី ៦ គឺ ព្រះបាទភវវរ្ម័ន និងចិត្រសេនាមហេន្ទ្រវរ្ម័នជាព្រះរាជាមានអាគតដ្ឋានមកពីប្រទេសនគរភ្នំ បានពង្រីកអាណាចក្រឲ្យធំទូលាយទៅទៀតគឺវាយយកភូមិភាគខាងត្បូងខ្ពង់រាបនគររាជ (នគររាជសីមា ប្រទេសសៀមសព្វថ្ងៃនេះ) ព្រមទាំងទីទំនាបភាគកណ្តាលនៃទន្លេមេគង្គរហូតទៅដល់ស្ទឹងព្រៃមូល (សៀមថា ណាំមូន) ស្រេចហើយទ្រង់ត្រឡប់មកវាយយកប្រទេសនគរភ្នំវិញ ។ កាលនោះ ព្រះរាជានគរភ្នំព្រមទាំងរាជបរិពារស្តេចថយចេញពីក្រុងវ្យាធបុរៈ (បាភ្នំ) ទៅគង់នៅនរវរនគរ (ចិនថា ណាហ្វូ-ណា) គឺអង្គរបូរីសព្វថ្ងៃនេះ ។ ព្រះបាទភវវរ្ម័នវាយដណ្តើមយកប្រទេសនគរភ្នំក្នុងគ្រានេះ ពុំទាន់បានសម្រេចដូចព្រះរាជបំណងព្រះអង្គទេ មកដល់រាជ្យព្រះបាទឦសានវរ្ម័ន ជាព្រះរាជបុត្រនៃព្រះបាទចិត្រ-សេនាមហេន្ទ្រវរ្ម័ន ទើបសម្រេច ។ ព្រះបាទឦសានវរ្ម័នស្តេចគង់នៅក្រុងភវបុរៈ (នៅជិតស្រុកអម្ពិលរលំ ចំនួន ៣០ គ.ម. ខាងទិសពាយ័ព្យក្រុងកំពង់ធំ) ជារាជធានីនៃព្រះអតីតរាជានោះ ហើយតមក ទើបស្តេច

មកតាំងរាជធានីថ្មី នៅឦសានបុរៈ (សម្បូណ៌ព្រៃគុក ចម្ងាយចំនួនជា ៤០ គ.ម. ទៅខាងកើតក្រុងកវបុរៈ) ។

២ - រឿង "ចេនឡា" គួនិពន្ធចិន ។ រឿងនេះអ្នកប្រាជ្ញខាងបុរាណវិទ្យា កើតក្ដីងឿងឆ្ងល់ហើយបានរកមូលហេតុរឿងនេះមកយូរហើយឆ្លល់ថា ចេនឡាជាពាក្យខ្មែរចិនគ្រាប់តាមមិនច្បាស់ ឬមួយជាពាក្យចិន លុះមកដល់ឥឡូវនេះនៅតែមិនទាន់បានលទ្ធផលប្រពៃឡើយ បើពាក្យនេះជាពាក្យខ្មែរ ចិនគ្រាប់តាមមិនច្បាស់ តើចិនចង់គ្រាប់ពាក្យខ្មែរថាម៉េច ? ទំនងជាថាគ្រាប់តាមពាក្យខ្មែរ តែយើងរកមិនទាន់ឃើញ ដូចជាពាក្យថាកម្ពុជានេះក៏អាចនឹងក្លាយទៅជាចេនឡាបានដែរ ទំនងដូចពាក្យហ្វូណន (Fou-nan) ជាពាក្យខ្មែរ ចិនគ្រាប់ពាក្យខ្មែរថា "ភ្នំ" មិនច្បាស់ ត្រឡប់ជាថាហ្វូណនវិញ ព្រោះមានសិលាចារឹកខ្មែរបុរាណបញ្ជាក់ថាក្រុងភ្នំ ឬក្រុងភ្នំ ជាសំស្ក្រឹតបរិគតូបាល "ស្ដេចភ្នំ" ។ ការរកពាក្យចេនឡា ថាជាពាក្យដើមខ្មែរឬថាជាពាក្យដើមចិន នៅមិនទាន់ជ្រះស្រឡះ តែលោកបានរកឃើញទីក្រុងដែលឈ្មោះថាចេនឡា ។ អ្នកប្រាជ្ញបុរាណវិទ្យារកឃើញហើយឆ្លើយថាទីបរិវេណក្រុងចម្បាសក្តិ នឹងប្រាសាទបុរាណវត្តភូ (ប្រទេសលាវភាគក្រោម) នៅជើងភ្នំមួយដ៏មានកំពូលទ្រមួយដុំធំកាងទៅដូចគិរលិង្គ ដែលមានសិលាចារឹកហៅកន្លែងនោះទុកថា "លិង្គបវ៌ត" និពន្ធថា លិង-គៀប៉ូ-ប៉ូ (Lin-Kia po-po) នៅលើលិង្គបវ៌តនេះ មានប្រាសាទមួយ

តម្កល់សិវលិង្គនាមថា "ភទ្រេស្វរៈ,, និពន្ធចិនថាប៉ូ-តូ-លិ (Po-to-li) ហើយ ដែលសិលាចារឹកនៃខេត្តបុរាណសម័យនគរឲ្យនាមាភិធេយ្យថាកម្ពុជទេសៈ "ប្រទេសនៃព្រះរាជបុត្រនៃវង្សស្រីកម្ពុ ,, នេះហើយជាមជ្ឈមណ្ឌលបុរាណនៃប្រទេសដែលនិពន្ធចិនហៅថា "ចេនឡា ,, ។

៣– ក្នុងការពិចារណាសិលាចារឹកវត្តលួងកៅ លោកសឺដេសសរសេរថា "ទីបរិវេណចម្បាសក្តិនេះហើយដែលចប់មក្សត្រនៃកម្ពុជៈ មានព្រះបាទស្រុតវម៌នទឹងព្រះបាទស្រេស្ឋវម៌នជាដើម (ខាងសូរ្យវង្ស) សោយរាជ្យក្រោមអធិរាជភាពនៃប្រទេសនគរភ្នំ នៅក្នុងកំឡុងគ្រិស្តសតវត្សទី ៦ មានព្រះរាជធីតាមួយព្រះអង្គក្នុងវង្ស នេះ ( វង្សស្រីកម្ពុ ឬ ខាងសូរ្យវង្ស) នាមស្រីកម្ពុរាជលក្ស្មី បានទៅជាទេពីនៃព្រះរាជកុមារមួយអង្គ ត្រូវជាព្រះរាជនត្តានៃព្រះបាទរុទ្រវម៌ន ( ខាងសោមវង្ស ) ដែលជាអវសានរាជាក្នុងមហាប្រទេសនគរភ្នំ ។ អាស្រ័យដោយការសម្ពន្ធព្រះរាជវង្សទាំងពីរដូចពោលមកនេះ ព្រះរាជកុមារ ដែលមានអាគតដ្ឋានមកពីប្រទេសនគរភ្នំ (ខាងសោមវង្ស) បានឡើងសោយរាជ្យជាព្រះនរបតីជាធំលើវង្សស្រីកម្ពុ(ខាងសូរ្យវង្ស)ឡើង ព្រះនាមថា ភវវម៌ន ។ ក្នុងកាលតមកព្រះបាទភវវម៌ន មានព្រះអនុជព្រះនាមចិត្រសេនា (មហេន្ទ្រ-វម៌ន ) ជាសេនាបតីជំនាញខាងយុទ្ធវិធី លើកវេហ៍ពលទៅវាយ យកប្រទេសនគរភ្នំដូចបានពោលមកហើយខាងលើ ។ មូលហេតុដូចម្តេច

បានជាទ្រង់ទៅវាយយកនគរភ្នំ ? ឯកសារផ្សេង ៗ (និពន្ធបិននិងសិលា-ចារឹក ) បានឲ្យយើងដឹងថាព្រះបាទកៅណ្ឌិន្យជ័យវរ្មន ប្រហែលជាទ្រង់មានព្រះរាជបុត្រ ២ ព្រះអង្គ មួយអង្គព្រះនាមគុណវរ្មន ជាមកុដរាជកុមារ ព្រោះជាព្រះរាជបុត្រព្រះអគ្គមហេសីព្រះនាមមកុលប្រភាវតី (សិលាចារឹក-ដំបងដែក, ខេត្តតាកែវ) មួយព្រះអង្គទៀតព្រះនាមរុទ្រវរ្ម័ន ជាព្រះរាជបុត្រព្រះស្នំ កាលព្រះវររាជបិតាទីវង្គត គ.ស ៥១៤ ព្រះរាជកុមាររុទ្រវរ្ម័ន ទំនងជាធ្វើគតព្រះរាជកុមារគុណវរ្ម័នដែលជាព្រះរាជបុត្រធម្មានុរូប ហើយឡើងសោយរាជ្យ ទ្រង់ព្រះនាមរុទ្រវរ្ម័ន (សិលាចារឹកទន្លេបាទី) ក្នុងខណៈដែលព្រះបាទរុទ្រវរ្ម័នទីវង្គត (ឬមានការធ្វើគត) ទំនងជាព្រះវង្ស ខាងព្រះគុណវរ្ម័ន កាន់ព្រះពុទ្ធសាសនាមុតមាំដែងរាជ្យតសន្តតិវង្ស បានជាខណៈនោះព្រះបាទគវវរ្ម័ន កាន់សាសនាព្រាហ្មណ៍និកាយព្រះឥស្សូរ មុតមាំដែលជាព្រះរាជបុត្រព្រះវីរវរ្ម័ន ហើយត្រូវជាព្រះរាជនត្តា ព្រះបាទរុទ្រវរ្ម័នផងយកឱកាសនេះលើកទ័ពមកវាយដណ្តើមសោយរាជ្យវិញ ។

សិលាចារឹកវត្តលួងកៅនេះ ជាថ្មមួយដុំបួនជ្រុងជាភាសាសំស្រ្កឹត គ្រប់ទាំងបួន អក្សរជំនាន់មុនរាជ្យព្រះបាទគវវរ្ម័ន ។ លក្ខណៈអក្សរមានទំនងដូចសិលាចារឹកព្រះរាជកុមារគុណវរ្ម័ន នៅប្រាសាទ ៥ ល្វែង ស្រុកទឹកថ្លា (វៀតណាមខាងត្បូង) ហើយរាប់បញ្ចូលទៅក្រុម អក្សរសម័យ

បល្លវៈប្រទេសឥណ្ឌាទក្ខិណាបថគ្រិស្តសតវត្សទី ៩ មិនមែនក្រោយកាលបរិច្ឆេទនេះទេ ។

ប្រធានសព្ទក្នុងសិលាចារឹក គឺព្រះបាទទេវានីកៈ (ទេវ ទេពតា ឬ ទិព្វ+អានីកៈ សេនាឬសេនី សេនាទេពតាឬទិព្វ) ជាមហារាជាធិរាជ គេរកឃើញក្នុងទីឋាននេះ ។ ដូច្នេះ កើតជាប្រស្នាឡើងថា ព្រះរាជាអង្គនេះជាវង្សណា ? នាមថា ទេវានីកៈនេះ មាននៅតែក្នុងគម្ពីរបុរាណៈ ជាបុព្វបុរសព្រះរាមនៅប្រទេសឥណ្ឌា មិនដែលឃើញមាននៅក្នុងវង្សណាមួយក្នុងសុវណ្ណភូមិនេះទេ ។ កាលដើមអ្នកប្រាជ្ញទុកដាក់ថា ព្រះរាជាអង្គនេះជាវង្សកម្ពុជៈ គឺវង្សកម្ពុជៈដែលមានព្រះបាទស្រុតវរ្ម័ន និងស្រេស្ឋវរ្ម័នជាមូល ដោយហេតុថា សិលាចារឹកនេះនៅក្នុងបរិវេណជាមជ្ឈមណ្ឌលចេនឡា ។ ហើយគំនិតដែលខុសហុចមកមុនដំបូងនាំឲ្យយល់ថា ក្សត្រកម្ពុជៈដូច្នេះឯង តែសេចក្តីនៅក្នុងផ្ទៃសិលាចារឹកនាំឲ្យឃ្លាតចេញពីសម្មតិកម្មដើមទៅ ហើយនាំឲ្យយល់ថាជាក្សត្រប្រទេសចម្បាវិញ តែកិច្ចការទាំងនេះស្ថិតនៅក្នុងសម្មតិកម្មទាំងអស់ យើងទុកជូនឲ្យអ្នកប្រាជ្ញប្រវត្តិសាស្ត្រពិចារណាសេចក្តីពិតទៅអនាគតចុះ ចំណែកយើង យើងត្រូវមើលចំពោះតែវប្បធម៌សំស្ក្រឹត ព្រោះសិលាចារឹកនេះ ជារបស់បុរាណចាស់មួយ ជាវប្បធម៌សំស្ក្រឹតសហកាលក្នុងប្រទេសនគរភ្នំ តែមានរបៀបផ្សេងពីគ្នាស្រឡះ ។ សិលាចារឹកនេះមិនឃើញមានឈ្មោះគរ-

និពន្ធទេ មុខគួរឲ្យស្តាយណាស់ ។

អត្ថបទសិលាចារឹកមួយបន្ទាត់ដើមក្នុងភាគទីមួយ កវីនិពន្ធតែងជាគាថាស្រគ្ធរា សេចក្តីដូចជាមិនមែនជាបទស្តុតិសុទ្ធទេ គ្រាន់តែជាសេចក្តីប្រកាស ពីកុសលវិធីតាមទំនៀមសាសនាព្រាហ្មណ៍ចំពោះត្រៃទេពត្រិមូតិ ដូចមានពាក្យថា " ទ្រង់បានបំពេញកុសលវិធីចំពោះព្រះព្រហ្ម ព្រះឧបេន្ទ្រ (វិស្ណុ) ព្រះត្រៀគួរ (ព្រះឥសូរ) ដោយខ្សែកៗផ្សេងគ្នា ទាំង ៣ ព្រះអគ្គិទេះទាំផ្ទៃក្រោមឲ្យបម្រើន កើតបានទៅជាមាយាមួយពាន់ ឬនាំផ្ទៃក្រោមនេះឲ្យលាញទៅវិញ ព្រមទាំងចម្ងង់សត្វនិករដែលលិចលង់ក្នុងសមុទ្រសាគរ ឲ្យធ្ងន់ផុតទៅដល់ត្រើយនាយពោលគឺទីបំផុតទុក្ខ " ។

បន្ទាត់ទី ៩ ក្នុងភាគទីមួយដដែលជាពាក្យពយជាប់សេចក្តីការហូតដល់បន្ទាត់ទី ១០ នៃភាគទីពីរ កវីនិពន្ធថ្លែងពីព្រះបាទទេវានិកៈរីកពយព្រះទ័យចំពោះព្រះអាទិទេពដែលបានប្រោសប្រោណព្រះអង្គ ដែលមកពីប្រទេសឆ្ងាយថាបានតម្កល់ព្រះអង្គនៅក្នុងព្រះរាជានុភាព ដោយបារមីទេពតានៅលិង្គបតិតដូចសេចក្តីថា "ព្រះរាជាជាព្រះមហារាជាធិរាជមានសិរី ព្រះនាមព្រះបាទទេវានិកៈ ទ្រង់រីកើបព្រះទ័យចំពោះសេចក្តីអនុគ្រោះនៃព្រះអាទិទេព គឺបិតាមហា (ព្រះព្រហ្ម) នារាយណៈ (ព្រះវិស្ណុ) គន្ធ័រ (ព្រះឥសូរ) ទ្រង់ប្រកបដោយមេត្តាធម៌ និងកុសលធម៌ដ៏ច្រើន ដែលកើតចេញមកពី

កុសលក្នុងអតីតជាតិទ្រង់តាំងនៅក្នុងធម៌ ប្រាជ្ញដូចជាព្រះបាទយុធិស្ឋិរៈ[១] ទ្រង់ជាទីពឹងនាក់ប្រជាជន ប្រាកដដូចជាព្រះឥន្ទ្រាធិរាជ ទ្រង់មានជ័យឈ្នះមារសត្រូវ ប្រាកដដូចជាព្រះបាទធនញ្ជ័យ (អជ៌ុន) ទ្រង់ធ្វើពិធីយជ្ញៈច្រើនប្រាកដដូចជាព្រះបាទឥន្ទ្រទ្យុម្ន[២] ទ្រង់បំពេញទាននឹងមហាទានប្រាកដដូចព្រះបាទសិពិ[៣] ទ្រង់បានបំពេញភាគព្រះអង្គជាព្រាហ្មណ៍ ប្រាកដដូចព្រះភគីរថមហាបុរស[៤] ទ្រង់រក្សានូវខ្សាយ ប្រាកដដូចជាព្រះកនកបាណ្ឌ្យ[៥] ទ្រង់មានព្រះប្រាជ្ញាជ្រាលជ្រៅដូចមហាសមុទ្រ ទ្រង់មានព្រះទ័យនឹងធឹងដូចភ្នំព្រះសុមេរុ ទ្រង់ស្ដេចមកពីប្រទេសឆ្ងាយ ហើយតាំងនៅលើលិង្គបពិត្រដ៏មានបុណ្យដែលជនគោរពតាំងពីបុរាណកាល ទ្រង់មានព្រះបរមនាមប្រកបដោយព្យាង្គបួន ទេ-វា-នី-កៈ ទ្រង់មានជ័យច្រើនគ្រា ប្រាកដដូចព្រះវិជ័យ (អជ៌ុន) ទ្រង់បានចម្លងសត្វនិករឲ្យផុតពីមហាសាគរឥតត្រើយគឺសង្សារ ដោយការបូជាព្រះអគ្គិដ៏ប្រសើរ និងដោយការព្រះរាជទានគោច្រើនពាន់ជាទាន ។

បន្ទាត់ទី ១១ ក្នុងភាគទីពីរហូតដល់បន្ទាត់ទី ១៣ នៃភាគទីបួន ជា

---

១- ស្ដេចប្រកបដោយធម៌ ជាអធិបតីលើក្សត្របាណ្ឌវៈ ក្នុងរឿងមហាភារត ។ ២- ព្រះរាជាច្រើនព្រះអង្គក្នុងរឿងព្រេង ។ ៣- ព្រះរាជាល្បីព្រះនាមជាមានមេត្តា តែងមានព្រះរាជាអគ្គណាស្មើបាន ជាព្រះរាជបុត្រព្រះបាទឧសិនរ និងព្រះនាងមាធវី ក្នុងរឿងមហាភារតៈ និងជាតក ។ ៤- ព្រះនាមព្រះរាជា ព្រះមហាមុនីច្រើនអង្គក្នុងអតីតកាល ។ ៥- ព្រះនាមនេះ អក្សរក្នុងសិលាចារឹកមើលមិនច្បាស់ ។

បទ ២១ស្លោក កវីនិពន្ធជាស្លោករៀបរាប់ពីកិច្ចការកុសល ខាងដើមរលុបរលាយអក្សរអស់ច្រើន ខាងចុងនៅសល់ខ្លះ ថ្លែងពីទ្រង់បានសាងកំពង់បុណ្យធំ (មហាតីថិ:) បានធ្វើពិធីស្នាន: (ពិធីមុជទឹក-ស្រោចទឹក) សំរាប់លាងបាបឲ្យបានចំរុងចំរើន ទីឋាននេះ តាំងឲ្យឈ្មោះថាកុរុក្សេត្រ: សម្រាប់បង្ហោះបុណ្យដល់ជនណា ដែលបានចូលទៅដល់ឲ្យប្រាកដ ដូចជាបានចូលទៅដល់កុរុក្សេត្រៈនៅប្រទេសឥណ្ឌា ដូចសេចក្ដីតទៅនេះ "ជននៅក្នុងមហាតីថិ: (កំពង់បុណ្យធំ) ដែលត្រូវតែស្លាប់ហើយបានធ្វើពិធីស្នាន: សូមឲ្យបានសម្រេចផល - សូមឲ្យបានសម្រេចផលប្រាកដដូចបានធ្វើនាប្រភាសតីថិ:(១) ទេវតាទាំងឡាយមានព្រះព្រហ្មព្រះឧបេន្ទ្រ (ព្រះវិស្ណុ) ព្រះឦគ្វរ (ព្រះឥសូរ) ជាដើម ដែលបានទទួលយកយជ្ញ: នេះ សូមបំណាំឈ្មោះអ្នកបូជាកុំខាន - សូមអធិដ្ឋានទីនេះឲ្យឈ្មោះថាកុរុក្សេត្រ:(២) ប្រាកដដូចប្រទេសឥណ្ឌា—សូមសម្រេចផលក្នុងកុរុក្សេត្រ: នេះឲ្យដូចជាបានសម្រេចផលទិព្វនៅកុរុក្សេត្រ:ពីបុរាណ - ឬសីនាមកុរុពីបុរាណ បានបង្កើតឋានបណ្ដុះពូជសម្រាប់ជនសប្បុរស ដូច្នេះមហាតីថិ:ថ្មីនេះ អាចឲ្យបានផលច្រើន ហេតុនេះហើយឋានជាឋាននេះ ហោ

១- ឈ្មោះទីឋានស្ស៊ីមួយនៅជិត គុជរាត ប្រទេសឥណ្ឌា ។ ២- កុរុក្សេត្រនេះ លោកទុកជាឋានបណ្ដុះពូជ ព្រោះលោកថា ពូជនឹងអាចមិ (ចម្បាំងមហាភារតៈ) កើតនៅកុរុក្សេត្រនេះ ទីបំផុតពូជឈ្មោះអាចមិយុទ្ធដែលគួរកត់សំគាល់ថា បុរាណលោកចង់ឲ្យប្រទេសខ្មែរដូចប្រទេសឥណ្ឌា ឬដូចម្ដេច ? ។

ថាកុរុក្ខេត្រៈ — សូមព្រះកាសុ ហៅៈឈ្មោះអ្នកដែលគាត់ធ្វើអំពើអាក្រក់ក្នុងកុរុក្ខេត្រៈនេះ ហើយប្រទានឲ្យបានគតិប្រសើរ — សូមឲ្យខ្ញុំបានទៅកាន់កុរុក្ខេត្រៈ ហើយឲ្យបានទៅក្នុងកុរុក្ខេត្រៈ ព្រោះអ្នកណាទៅក្នុងកុរុក្ខេត្រៈ អ្នកនោះបានទៅកាន់ឋានសួគ៌ — ព្រៃនៃមិគ (ព្រៃមួយនៅជិតស្ទឹងគោមតី ឥណ្ឌា) ជាឋានបុណ្យមួយនៅលើផែនដីឯឋានបុស្ករៈ (បឹងមួយនៅ អជ្មេរ ឥណ្ឌា) ទុកជាឋានបុណ្យនៅឋានសួគ៌ កុរុក្ខេត្រនេះជាឋានបុណ្យប្រសើរ សម្រាប់ជនទិងក្សត្រគ្រាន់តែពុទ្ធគិត្តនាម ម្ដេចបានអាទិសន៍ដល់ទៅប្រាំភីដ្ឋក្រុងហៅ ហើយចាំបាច់និយាយថ្វីដល់ជនដែលបានទៅកាន់ទីនេះដោយការពេះពឹងព្រះធម៌?—ជនដែលធ្វើអត្តមេធៈ (បូជាសេះ) រាជសុយ (ឈ្មោះពិធីបុណ្យ)មួយរយ និងការឲ្យគោមួយពាន់ជាទានក្នុងទីឋាននេះដោយប្រពៃ មិនមែនឈ្មោះថាជាហេតុនៃផលទេ បើជនណាបានធ្វើពិស្នានៈនៅក្នុងកុរុក្ខេត្រៈនេះ ជននោះទើបឈ្មោះថាបានផលដ៏ទៀងទាត់មែន — សូមជនទាំងឡាយនៅក្នុងកុរុក្ខេត្រៈនេះបានសម្រេចផល ដូចព្រះសុកមិទាំងឡាយបានពោលហើយពីអតីតកាល — សូមផលដែលកើតពីពិធីៈមួយពាន់នៅក្នុងកុរុក្ខេត្រៈនេះ បានសម្រេចដល់ជនទាំងឡាយដោយប្រពៃកុំខាន — ជនអ្នកមានបាប គ្រាន់តែបានចូលទៅកាន់មហាតីថ៌ៈនេះគាពន់រួចបាបបាន ចាំបាច់និយាយថ្វីដល់ទៅជនដែលត្រេកអរបំពោះធម៌? ។

បីបន្ទាត់ចុងបំផុតនៃភាគទីបួនជាគាថាមាលិនី កវីថ្លែងស្តុតិចំពោះព្រះបាទទេវានីកៈ ថាទ្រង់ជាអ្នកបង្កើតកំពង់បុណ្យធំមួយនៅលើផែនដីនេះដូចតទៅនេះ "ព្រះមហារាជាធិរាជ មានព្រះសព្វាង្គកាយស្រោចស្រប់ហើយដោយភាពក្ខុផ្ទុកពោលគឺកុសល មានព្រះពលយសកើតចេញពីព្រះហស្ត មានព្រះឧត្តមាង្គដ៏ប្រសើរប្រដាប់ដោយកម្រងផ្កា មានព្រះសុគន្ធពោលគឺមហាគ្រីដៃបរកបាទដោយកម្ម មានព្រះនាមាភិធេយ្យថាទេវានីកៈ បានបង្កើតកំពង់បុណ្យប្រសើរដ៏លើសមួយនៅផែនដីនេះ" ។

យើងបានមើលតាំងពីដើមដល់ចប់ហើយបានដឹងថា ព្រះបាទទេវានីកៈជាប្រធានសព្ទក្នុងសិលាចារឹកនេះ ទ្រង់ជាមាមកៈសាសនាព្រាហ្មណ៍និកាយព្រះក្រឹស្ណ ដែលជាអវតារព្រះវិស្ណុក្នុងរឿងមហាភារតៈ ព្រោះទ្រង់បានបង្កើតកំពង់បុណ្យធំ (មហាតីថ៌ៈ) ឲ្យនាមថាកុរុក្សេត្រៈ នៅប្រទេសយើងពីបុរាណកាល ។ កវីអ្នកនិពន្ធកាព្យនេះក៏កាន់សាសនាព្រាហ្មណ៍ម៉ឺតចត់ មានការចេះដឹងសាសនាព្រាហ្មណ៍យ៉ាងទូលាយ ចេះតែងកាព្យបំពេញព្រះរាជហឫទ័យឲ្យសមតាមពាក្យបំភាន់ឥតខ្ចោះ សម្តែងឲ្យឃើញថាកវីនេះមានស្នាដៃប្រសើរជាអ្នកដ៏ឯកមួយក្នុងកាលនោះ មានទឹកប៉ាកកាមិនចាញ់ប្រៀបសិលាចារឹកទន្ទេបាទដែលជាសហកាលិកខ្លួនទេ ថ្វីត្បិតតែសិលាចារឹកទន្ទេបាទជាពុទ្ធសាសនា មួយខាងទៀតក៏ជាពុទ្ធសាសនា មួយខាងទៀតជាសាសនាព្រាហ្មណ៍ ។ កវីនេះ ចេះតែងពាក្យ

ជាស្រគួក ជាពាក្យកយ ជាស្មោះ ៗ ជាអាលិទី បញ្ជាក់ឲ្យឃើញច្បាស់ ថា លោកជាអ្នកប្រាជ្ញមានការចេះដឹងសំស្ក្រឹត ធម៌អាថ៌កាព្យ ជាន់ខ្ពស់មួយរូប តែយើងស្តាយណាស់ ព្រោះមិនបានស្គាល់នាមលោក ។

ទីបំផុត ខ្ញុំនឹកថា យើងធ្លាប់តែក្រេបរសជាតិធម៌អាថ៌នឹងពាក្យពេចន៍ខាងពុទ្ធសាសនា ពេលនេះ យើងភ្លក់រសជាតិភាសាព្រាហ្មណ៍ ទំនងជាប្រឆាំមមាត់អស់លោកទេដឹង ? មិនអីទេ យើងខំពិនិត្យពិចារណាមើលទៅចុះ ព្រោះធម៌អាថ៌ក្នុងសាសនាព្រាហ្មណ៍ជាពន្លឺមួយដ៏សំខាន់ដល់យើងជាអ្នកកាន់ពុទ្ធសាសនាដែរ តែយើងមិនត្រូវក្រួបនាទីយើងថា យើងមើលតែរឿងធម៌សំស្ក្រឹត ” ទេ ។

## អត្ថបទសិលាចារឹកវត្តល្វេងដំរៃ

វ្រាសំ មាឃោសហស្រកញ្ចតទិទយទិលំ យៃស្រ្តិកិន្នៃកការលេ
គុច្ឆត្យន្តិ ទិមត្ថំ ភាសេលិលចិហៅ ការយន្តិ ស្ត យេ ប
ព្រហ្មបេវេន្ទ្រគុកណាំ សទិទិលមន្ទុធំ សត្វភាពញ្ញា តេហមាធន ឬប៊ិ
ខន្រ្ទៈ កុះសណវិធិមំ យត្តគាក - ហេតុ: ॥

ងវត្យាយ៉ំ គ្រឹតគ្គរនោពយណាប់តាងហោចិសរិទៅប្រុសាគាតិបក្តិ:

បរិវេនាធិគតគុណកុសលទិដ្ឋិសម្មាវិតស្សំកម្មាតិមានុបគម្មា យុធិដ្ឋិរ ឥវ-
សទ្ធម្មិស្សិតោ [វិរុ] ធនរាគិរិវ ប្រជាបាលនេ ធនញ្ជយ ឥវ វិបុ-
គណវិជយេ ឥន្ទ្រទ្យុម្ន ឥវ កុវេរដ្ឋវិធានេ ពលិរិវ ទានេ មហាយនេ
ភគវាន្ទហាបុរេ ព្រាហ្មណ្យតាទុចារេ ព្រាហ្មណ្យការេ ភវភបាណ្យ
ឥវ ទ្យាយវក្យរណេ មហោទធិរិវ គាម្ភីរ្យេ មេរុរិវ ស្ថៃរ្យេ
បូរិមតេន ភគវតា ត្រិលិង្គបរិគេនាសិទ្ធរនេគាទនីគាធិម្ឋតោ មហា
ធិកវៃជ្យគ្គុយេ វិតិឫវិស្យប្តាប្តាទ្ធិក្យរមង្គលនាមធេយោ ទ្វិបទនេក-
ទីការប្តុវិជយោ វិជយ ឥវ មហាកជាធិកជត្រុមាត្រោនេកនីកៈ អបារ-
សំសារសាគរត្តរណាយ សវិសត្វានុទ្វិត្យ មហាតីមខបុរេកមំ សារទ-
កនោសហស្រ ॥

យេ សន្តិ មហាតីតេ  តត្រ ច យេ មូតា ទក:
ស្ថាវិទំ យេ ច កុវន្ទិ  តត្លេំ ប្រាប្រវន្តុ តេ ॥
ឥនេក្យវមាទិប្រណីធិ-  រាជគិន្ទយតស្ថទ!
នាមតគំ កុរ្រកេត្រ  . . . . ប្រផលៃសន្ទេម ॥
តត្រៃត្រភប៊ កុរ្រកេត្រេ  រាសុទា សមុទីរតា:
មហាទុស្តគម្ភាណំ  នយន្តិ បរមាំ គតិម ॥
កុរ្រកេត្រទ្ធមិសប្រាមិ  កុរ្រកេត្រេ វសាម្យហម

យេ វសន្តិ កុរុក្ខេត្តេ    តេ វសន្តិ ត្រិវិដ្ឋបេ ||
តន្នាមកីត្តិទេវាបិ    តេន ហ្យា សប្តមំ កុលម៑
កិម្បុនយេ្យ តុ សេវន្តេ    មនុជា ធម្មពុទ្ធយះ ||
អស្សមេធសហស្សស្ស    វាជបេយ្យសតស្ស ច
គវំ សតសហស្សស្ស    សម្បុគ្គតស្ស យត្ផលម៑ ||
ឥត្ថលំ តុ កុរុក្ខេត្តេ    កុរុន្តិ សុវន្នាទិ ច
តត្រាប្យហេតុ ទុប្រាបំ    លភន្តេ តេ ធ្រុវំ ផលម៑ ||

កុសលចបលផាពនោតសហ្វ៊ន្គទេគសិ៑
សុកុផពលទាគស្រស្សគ្គាមបាវត្តមាន្គះ
ទុរធិគតមហាគ្រឹគន្ធកស្តិ្ថមគ្រេ្យម៑
ផឱយតិ កុរុំ ទេវាទីក ឥត្យាប្តនាមា ||

# សប្បុរិសធម៌ពាក្យកាព្យ

ពាក្យកាព្យនេះ កម្មវិធីសិក្សាមធ្យមភូមិ បានជ្រើសរើសយកសម្រាប់ សិស្សថ្នាក់ទី ៤ ទំនើប ថ្មីៗនេះហើយបានជាយើងសូមស្រង់ មកបោះផ្សាយក្នុងទីនេះ ។

## អារម្ភកថា

រឿងសប្បុរិសធម៌នេះ ខ្ញុំបាទមានមនោគតិគិត ផ្ដើមឡើងដោយ ឃើញថា ជាឧបការគុណដ៏ឧត្ដម សម្រាប់ពុទ្ធបរិស័ទដែលត្រូវការ ។

ប៉ុន្តែធម៌នេះ ចំពួកប្រាជ្ញជាន់ខ្ពស់ លោកបាន ប្រែពីបាលីធ្វើជា សេចក្ដីអធិប្បាយ ជាធម្មតាក៏មាន តែនៅជាពាក្យសម្រាប់ចុះសៀវភៅ សម្រាប់ឲ្យមើលផ្ទាល់ក៏មាន នោះពុទ្ធបរិស័ទទាំងឡាយសឹងបានជ្រាបខ្លះ ហើយ ។

ឥឡូវនេះ ខ្ញុំបាទតែងជាពាក្យកាព្យវិញដើម្បីជាការស្រួលសម្រាប់ ពុទ្ធបរិស័ទពួកខ្លះ ដែលត្រូវការស្ដាប់ពាក្យកាព្យ អាចឲ្យបំបាត់នូវ សេចក្ដីធុញទ្រាន់ក្នុងការមើល ការស្ដាប់បរិយាយពុទ្ធភាសិតនេះផង ។

អវសានវាទនេះ ខ្ញុំបាទសូមប្រណិប័តន៍ថា សប្បុរិសធម៌ ដែលខ្ញុំបាទ តែងនេះ ប្រហែលជាខាតខ្វះលើសលោះក្នុងបទឯណានីមួយខ្លះ ។ ប៉ុន្តែខ្ញុំជឿថា មុខជាបានទទួលសេចក្ដីអភ័យអំពីពុទ្ធបរិស័ទទាំង ឡាយពុំខាន ។

សោ ហា ភិក្ខុ ណាម

**ជាន-គេច**

# សប្បុរិសធម៌ពាក្យកាព្យ

សូមពោលសូត្រពុទ្ធទាំងទេ ប្រាសទេមាន

គុណបករណ៍អង្គុតរជាប្រធាន កែពាក្យអត្ថបដិភានវោហារ ។

នាមព្រះសូត្រសប្បុរិសធម្មោ គឺជាទាំងពុទ្ធវិចារណ៍ ប្រទានជា

ប្រយោជន៍យ៉ាងពិស្ដារ បរិហារសព្វសត្វឲ្យបានសុខ ។

មានចំនួនសត្តបទកំណត់ប្រាប់ បានសាសព្ទអធិប្បាយជា បែប

ទុក ឲ្យមនុស្សភ្ញាក់កំណើតធើតទៅមុខ ស្គាល់វិថីផ្លូវសុខសប្បុរស ។

និងសាធកលើករឿងឡើងជាអាថ៌ សូមផ្ទៀងសោតប្រសាទស្ដាប់

ឲ្យអស់ ផ្ចង់សតិន្ទ្រិយ៍តាំងសោមនស្ស ទំលាស់ទោះចិត្តចាកកង្វល់ ។

១– ធម្មញ្ញូគឺដឹងកំណើតហេតុ គ្រប់ប្រភេទគឺហេតុបង្កើតផល

ទាំងផែនភពសព្វសត្វសេពឥតសល់ ដឹងមិនដល់ដោយខ្លៅដៅតែស្មាន ។

ហេតុនោះឬគឺកម្មដែលកសាង មានពីរយ៉ាងគួរយល់សម្ដាន កម្មអាក្រក់

និងល្អប្រចាំប្រាណ ធ្វើប៉ុន្មានបានប៉ុណ្ណឹងកុំប្រឹងឆ្ងល់ ។ ចិត្តខិលខូចផ្ដួច

ផ្ដើមធ្វើមធ្វើសកាច យ៉ាងនេះប្រាជ្ញប្រាប់ថាអកុសល អ្នកណាសាងអ្នក

នោះឯងសោយផល ជាប់សកលកាយសែងដូចសែកាន់ ។ ប្រព្រឹត្ត

ត្រឹមត្រង់ត្រូវផ្លូវសុចរិត នោះបណ្ឌិតហៅថាកុសលខន្ធ ត្រូវត្រង់ត្រាប់ត្រិះ

គិតឲ្យកើតធន្ធ គង់ជួបសន្តិសុខសាគរ ។ យើងជាអ្នកស្វែងមគ្គឲ្យជាក់

ហេតុ និងប្រភេទក្តីមិនផលកុំខ្វល់វ៉រ ឥឡូវនេះលើកកម្មឡើងឧទូរណ៍ ផ្តើម
សន្ទរកថាតទៅសំណោក ។ សូមករីប្រើជាបេះចំណាន ជួយប្រោសប្រាណ
ពន្យល់ដល់ផងទៀត កុំឈប្បញ្ញាតាមសំណោក ប្រោសប្រទៅដុសខាត់
អញ្ញាស្រ័យ ។

២- កុងអត្តញ្ញាណថាជីងផល គួរសំគាល់កាទីវិទិច្ច័យ ព្រោះតួហេតុ
ប្រភេទដើមនិស្ស័យ ជាបច្ច័យជួបឧសទិងអគ្គី ។ ប្រៀបដូចធ្វើអំពើ
កម្មអាក្រក់ ផលខ្វល់ល្អកំដក់កុងឥន្ទ្រិយ អំពលចិត្តតតសុខទុក្ខពោរទី
គ្មានវិធីណាថយឲ្យស្រាកស្រាន្ត ។ បើធ្វើល្អផលល្អកំដរកាយ ឲ្យ
សប្បាយសមបែបសេពសុខសាន្ត ក្រកីខ្វាត់ខ្សត់កីខ្វាយធ្លាយចាកប្រាណ
សុខសម្រាន្តកល់ចិនមិនស្រាកស្រន់ ។ កាលសុខទុក្ខមកដល់ចូលប្រុង
ចិត្ត រំលឹកគិតរំពឹងដឹងឲ្យទាន់ តាំងគេយើងកុងកតពាបម៉ុនពាន់ ទុក្ខតែង
ជាន់សុខតាមជួយតែកល់គ្នា ។ ត្រូវពិនិត្យសមុទ័យទោសទុច្ចរិត ដែល
បាំងបិទឥតក្តី គឺអវិជ្ជា បើជម្រះឲ្យជ្រះពីអគ្គា រៀងនាគង់ស្ងប់ម្ងាប់កាយ ។
កាលចិត្តកាចកើតឡើងយើងលះចេញ ត្រូវបំពេញមេត្តាករុណាផ្សាយ
ទើបបានសេពសន្តិសុខសប្បាយ អផ្ទៃងធ្លាយគគោហៅផលល្អ ។ ស្គាល់
ធម៌ពីរនេះទេញជាស្គាល់ត្រូវ ព្រោះដងផ្លូវត្រូវកើតទ្រព្យកេក្រ ធម្មញ្ញូរជីង
ជាដើមទ អត្តញ្ញូលោកសព្រុះបំថាចុង ។ ឯស្គាល់ដើមគឺស្គាល់ប្រធាន

ហេតុ កំណត់ខេត្តខណ្ឌគ្នាជាក្រៅក្នុង ការស្គាល់ផលត្រូវយល់ដល់
ស្គាល់ចុង គតិក្នុងតួហេតុប្រភេទចាស់ ៗ

៣. ក្នុងអត្តញ្ញុតាជាស្គាល់ខ្លួន ត្រូវបេះស្នួនស្ងប់ស្ងៀមចៀមកើតខ្មាស
ប្រុងប្រយ័ត្នមារយាទជាតិពុទ្ធសាសន៍ មើលឲ្យច្បាស់ច្បាប់ធម៌ប្រដៅ
កាយ ៗ ឲ្យដឹងខ្លួនដោយជាតិត្រកូលកើត ពូជកំណើតក្រុងស្រែសែស្រ-
ឡាយ សម្បូណ៌ទ្រព្យសម្បត្តិឬខ្សត់ខាយ កំណត់កាយឲ្យជាក់ជាចម្ងាៗ
លុះកំណត់ដឹងជាតិដឹងកំណើត ដែលរៈយើងកើតនៅក្នុងពូជពង្សណា
ហើយដាក់ទុកខ្លួនប្រមាណប្រើកិរិយា ឲ្យសមតាមអត្តាជាការគួរ ៗ
កុំធ្វើបែបឲ្យកមាឌបង្អៀតព្រែក រាក់ខ្ពង់កប្ពក់ចេះមិនត្រូវជួរ មួយគប្បី
កំណត់ជាគួរ ឲ្យស្គាល់ខ្លួនក្បាលខ្លួនជាល្ងង់ខ្លាត ៗ បើដឹងខ្លួនថាខ្លួនជា
មនុស្សល្ងង់ កុំទ្រនង់ទ្រទើសទ្រើសហួសខ្នាត លើផែនដីក្រក្បីប្រាជ្ញឈ្លៀវ
ឆ្លាត ត្រូវសង្កាត់យកជាគ្រូអាចារ្យ ៗ តែបន្ទំចិត្តខ្លួនខ្លាំងរាវខ្លៅ
អាចហ៊ានសៅស្មូនស្ញូទ្រព្យខ្ពើមសារ បើសម្បូណ៌សម្បត្តិយសបរិវារ
កុំឲ្យរិកត្រើលមើលងាយគេ ៗ បុកណារោលថាបើឈើរលំ ដើរ
កន្លងតាំងគម្ពុំអើវេ បើមនុស្សដួលកុំអាលកន្លងគេ ត្រូវគ្នាន់គោរមនុស្ស
ដូចគ្នាដែរ ៗ បើយខ្លួនមិនទាន់បរិបូណ៌ច្រើន កុំព្រះហើនហួសមាឌជាតិ
ក្នុងខ្មែរ ចំណែកអ្នកអាយុច្រើនក៏ដែរ ត្រូវបន្ទ្រុសន្តានស្ងានមើលមាឌ ៗ
ឲ្យសមក្ខុមិតាមការស្ដាប់ស្លូនវ័យ ចេះប្រព្រឹត្តតាមពូជពង្សជាតិ មាន

ចំណេះត្រូវចេះប្រើមារយាទ កុំឃ្វេងឃ្វាតក្លាយទិនស្រវឹងខ្លាំង ។
គួរចម្រើនសីលធានទៀនអត្ថៈ ជាសារៈឧត្តមដល់រូបំ តែអត្តញាតាតាម
អត្ថ ចប់ឯវណ្ណយដ៏ស្ទះប៉ុណ្ណេះចុះ ។

សរុបធម៌ជាសុភាសិត ប្រដៅចិត្តជនាទុជនៈនោះគង់ទប្បមាន
បទអត្ថសង្គ្រោះ លោកតាំងឈ្មោះហៅមត្តញ្ញុតា ។ បានដល់ស្គាល់
ប្រាកដបទសេចក្ដី គិតអ្វីៗឲ្យស្គាល់ប្រមាណថា ដូចការកេចញ៉ឹមជីពភគា
ការបេតនាធ្វើឲ្យមានកិច្ចឲ្យគួរ ។ ស្វែងរកតាមបណ្ដាអាជីវៈ មិនលោភលោ
មោហហិនជាតិជួរ ឲ្យដឹងថាគួរបានឬមិនគួរ កុំសាញសួរនេះបាកដោយ
ទុច្ចរិត ។ ជាតិមនុស្សលោកលោភលាកជញ្ជាបមាត់ ក្រតែភ្លាត់ចូលក្នុង
រកហេតុស្មគ្គ យកតែខាងបានទ្រព្យទើបគាប់ចិត្ត ទេះបណ្ដិតបន្ទះជាទុស
ធម៌ ។ របស់ដែលបានដោយផ្លូវអស័ត្យ គង់វិបត្តិកើតទុក្ខលំអក់ពណ៌
ដល់ជីវិតជិតក្ស័យទើបភ័យញ៉ើរ នឹកដល់ធម៌មិនចាំកម្ពក់ក្រាស់ ។ មួយ
គួរចេះប្រមាណមាត់បរិភោគ កុំកញ្ជ្រោកស៊ីជ្រុលពាល់ចាក់ប្រាស ល្វីង
ជាថ្នាំផ្អែមផ្អមហើមពោះណាស់ ប្រាជ្ញប្រាប់ប្រកាសផ្លូវត្រូវប្រយ័ត្ន ។ គួរ
ជ្រើសរើសចំណីកុំខុស នូវជាសេពសាកឈើថ្នាំ យ៉ាងផ្អូកផ្អូរខូរ
ខ្ទោះទាសបញ្ញត្តិ ក្នុងមួយមាត់ភ្លាត់ខុសពាក្យពុះផ្ទៃ ។ មួយឲ្យចេះប្រយ័ត្ន
សម្បត្តិទ្រព្យ កុំចម្ចាប់ចាយធំពុំប្រពៃ ប្រាក់កប់សែនមែនបើមិនថៃ គង់

មានភ័យដល់កាយស្តាយកម្លាំង ៗ ឯការរកទ្រព្យធនជូនគំនិត ត្រូវព្រួយគិតប្រើកាយនឿយហត់ខ្លាំង ឃ្លាតប្រពន្ធឃ្លាតកូនខ្លួនស្គមស្គាំង សែងស្បៀងតាំងក្បាលហាលតាំងកាយ ៗ មានស្រីខ្លះប្រុសខំរកគគ្រេង ខ្លួនល្អបលេងតែល្បែងតាមសប្បាយ គ្មានអាណិតគិតប្តីនឿយព្រួយកាយ តែប្រុសខ្លះជះចាយទ្រព្យដូចគ្នា ៗ កាលបើមានឱកាសគួរល្មមទៅ ដើរសំដៅរកបនមិនរួញរា ចំពូកខ្លះស្រុះស្រួលបបួលគ្នា ព្រមទាំងបុត្រករិយាចរចូលវង់ ៗ គួរសង្វេគពេកណាស់ទឹកឡើងហើយ មិនសមឡើយពួកយើងវង្វេងល្ងង់ ប្រឹងបង្ហិនធនធានគ្មានឲ្យគង់ ហក់បម្រុងចង់តែឲ្យអស់ទៅ ៗ ឈ្មោះថាទ្រព្យទ្រនាប់ដៃអ្នកចាយ ចិញ្ចឹមកាយកាលឃ្លានគ្មានខុសត្រូវ បើអ្នកមានគំនិតគិតពក់ជ្រៅ រើសតែផ្លូវឲ្យគុណចាយធនធាន ៗ ដូចបញ្ចេញទុនបួលហ៊ុនដួញលក់ដូរ គួរបង្ហូរចាយចុះព្រោះចង់មាន ប្អូនយ៉ាងនេះហៅថាប្រើធនធាន បើសល់មានទៀតទុកបង្ការកោយ មួយឯស្រាអាកៀនញៀនបង្ហៀរ គួរលះវៀរចំរៀសជៀសឲ្យឆ្ងាយ ទំងវិនាសសម្បត្តិទ្រព្យខ្ចាត់ខ្ចាយ ផ្លូវអបាយមុខទុក្ខអាត្មា ៗ ទោះមានច្រើនបើក្អឹនក្អេចលែលក ទ្រព្យដែលរកមកនោះគង់កាលណា ទ្រព្យមានតិចប្រើចាយហួសមាត្រា មិនប៉ុន្មានអាត្មាផ្សារប្រេងាង ៗ សូមដាស់តឿនសតិជនប្រុសស្រី ដោយសេចក្តីសុចរិតឥតអួតអាង ពន្យល់ផ្លូវប៉ុណ្ណោះជាបែបយ៉ាង ទឹងសូមអាងខ្ញុំតាមបរិយាយ ៗ ខ្ញុំប្រាប់ថាកាល.

ញាតា ក្នុងអត្ថថាឲ្យស្គាល់កាលទាំងឡាយ មានសេចក្ដីរៀនកាយទូលាយ

ធ្លាយ អធិប្បាយពីកាលយូរនិងឆាប់ ៗ បើកាលមានអាសន្នបន្ទាន់ចង់

កុំបង្អង់ឲ្យយូរគួរប្រញាប់ ទើបទាន់ចិត្តឥតទាស់ថ្ងស់ចំណាប់ បុកណាព្រុប

ស្ដាប់ចុះពីពេះពិត ៗ ត្រូវលៃកាលមុនក្រោយឲ្យជាក់ច្បាស់ កាលហើស

គួរហាទឲ្យទាន់គិត បើកាលយូរគួរយូរជួរគំនិត ចូរប្រព្រឹត្តឲ្យត្រូវផ្លូវ

ប្រើការ ៗ មានកាមិតប្រក្រិដ្ឋជាអដ្ឋ ថាកាលហាន់រូបជាខ្ចីមសារ អ្នក

ហាត់ចិត្តគួរគិតរិះរិចារណ៍ ស្ងាទមើលការក្រូតើងដឹងឲ្យទាន់ ៗ ឯកិរិយា

កាលនោះភាឧពីរយ៉ាង ជាតិកតាងតាំងខ្លួនតាមលក្ខណ គឺកាលថេរកាល

ប្រចាំចំរុងកាន់ ជាកំណាន់គ្រប់ទិសមិនខុសទេ ៗ កាលប្រចាំចាត់ជា

កាលរំលឹក គឺៈពេលព្រឹកថ្ងៃត្រង់សាយណ្ហ ក្នុងរវាងចនោះនោះគឺវេ-

លាចរិញដេញពេរផ្លួសម័យ ៗ កិច្ចណាគួរត្រូវធ្វើប្រចាំកាល ដូចចំអិន

អាហារយើងអាស្រ័យ ត្រូវកេរៀបរូសពនឲ្យទាន់ថ្ងៃ ចាត់សំរៃកោក្ដាតាម

ការគួរ ៗ លុះថ្ងៃត្រូលស្គល់ស្គប់គិតកុំភ្លេច ត្រូវចាប់កិច្ចការធ្វើកុំខោះខ្វ

បើហាត់ពេកសំរាប់ឲ្យតែគួរ កុំផ្ដាក់ផ្អែកភាក់សន្សំម្រង់ខ្លួន ៗ លង់លុះទាល់

ដល់កាលពេលថ្ងៃត្រង់ សំបង្អង់បង្អន់កិច្ចការផង រកអាហារបរិភោគ

តាមបំណង បំបាត់ស្រេកឃ្លានផងផែលទៀយហាត់ ៗ ដល់បរិភោគ

ស្រេចស្រាប់ចាប់ការធ្វើ ចូរខំរើល្បើល្បងប្រឹងរំណត់ យកកម្លាំង

ច្បាំងការកុំគិតហាត់ ស្វ្រាំរត់ដល់បច្ចុសសម័យ ៗ ហើយរំលឹកជួស

កាយដែលស្មោគគ្រោក រូបរំភោគភោជនតាមវិស័យ យ៉ាងនេះហៅកិច្ចការប្រចាំថ្ងៃ ក្រៅពីនោះកែរៃជាការបេះ ៗ ដូចជាផ្ទះផ្ទុកតែគ្រឿងកខ្វក់ សម្រាមដក់កកក្តាំងតាំងគំនរ គួរបោសព្រោសជុំសខាត់កុំទុកគរ ប្រើមិនប្រើកែវរវល់រក ៗ ទ្រព្យមាសប្រាក់ទុកដាក់មានវត្ថុស្មើ ត្រូវការប្រើមានព្រមតាមចិត្តភក្ក ណាមិនប្រើទើរតាំងដោយៈកៀនញក គន់មិនចាស់ខ្ទះយើងរកយកបានងាយ ៗ ហើយមើលកាលហាត់កូនតាមក្បួនខ្នាត ឲ្យធ្មៀរធ្មាតកពងវៃមិនរ.យអ.យ ពន្យល់ផ្លូវត្រូវខុសឲ្យដុះធ្លាយ ការវិនាសនិយាយឲ្យចូលចិត្ត ៗ ធម្មតាពត់ព្រឹក្សាលតាវល្លិ៍ ត្រូវពត់ពាល់ពីខ្ចីទើបទន់ស្និទ្ធ ការហ្វឹកហាត់កូនៈចៅឲ្យត្រូវចិត្ត គួរប្រៀនប្រិតពីតូចទើបស្ទាត់ច្បាស់ ៗ ទំនងបន្ទាយវែងទៅហួសផ្លូវកាព្យ នាំឲ្យសាបពេហារសាញខ្លាំងណាស់ បានលើកកាលចាំងពីរឡើងប្រកាស ឲ្យឃើញច្បាស់ប៉ុណ្ណោះស្ទុះនិពន្ធ ៗ

សូមតែតទប្រាំមួយដោយពាក្យថាបរិសុញ្ញតាអនុសន្ធិ៍ ប្រែតាមយល់ចាស្គាល់ប្រជុំជន គប្បីគន់គិតមើលឲ្យម៉ាំមួន ៗ មនុស្សល្អមែនគង់មានអធ្យាស្រ័យ ក្នុងហឫទ័យវត្ថុទុកជាក្បួន ចូលត្រង់ណាចូលចុះចេះបៀមខ្លួន មិនឲ្យស្លូនស្លាក់ហួសជ្រុលសកាល ៗ ធម្មតាបង្កើតកំណើតមនុស្ស មានជាន់ខ្ពស់ជាន់ទាបជាន់កណ្ដាល មានតាំងប្រាជ្ញតាំងព្រាលតាំងខ្ជះស្រោល តាំងស្រួលចុះលទ្ធភាពញាណ ៗ មនុស្សគ្រប់ជាន់គួរ

សម្ពន្ធមេត្រីចិត្ត ចងជាមិត្តជាភក្តិសាមគ្គី តែឲ្យស្គាល់កិរិយាប្រពៃណី រើស
វិធីណាល្អប្រព្រឹត្តតាម ៗ មារយាទអធ្យាស្រ័យកាយវាចា ពោលកនិយម
យ៉ាងណាក្នុងទីស្នាម ត្រូវសម្រួលផ្លូលដោយកុំឲ្យជាម ទើបសមតាមឋានៈ
ទុកជាក់អង្គ ៗ ទោះជាទាបក៏មិនទាបពីកំណើត ប្រើកិរិយាឲ្យឆើតកុំបេះ
បង ត្រូវស្គាល់សព្ទបញ្ញើរបុរសត្រង់ កណ្តាលវង្សចំណោមប្រជុំជន ៗ
សរម្ងង់ប្រាប់សំរែកដូចក្អែកបួល មារយាទប្រាប់គ្រកូលចូលប្រឹងគន់ អធ្យា
ស្រ័យសមគួរបុរសជន ធ្លាយចេញឯងឲ្យគន់ឃើញសង្ហៅ ៗ ទោះរូប
ឆោមលោមពណ៌ល្អស្អាងស្អាត តែមារយាទខុសខ្នាតគេថាខ្មៅ ស្រឡាញ់
ខ្លួនស្ងួនកាយកុំឲ្យសៅ អាក្រក់ល្អក៏នៅតែលើខ្លួន ៗ ខ ប្រាំពីលក្បៀលខ្ចប់
បញ្ចប់ផ្តាច់ ព្រះសពេជ្រត្រាស់ទុកតាមចំនួន ប្រាសាទសុខារម្មណ៍ឲ្យ
មាំមួន កាលបើខ្លួនសេវនាសមាគម ៗ បទដើមគឺបុគ្គលញាតា មានអត្ថា-
ធិប្បាយដោយនិយម ប្រែថាស្គាល់ចរិតជនតូចធំ គួរសមាគមឬគេចមិន
សេពគប់ ៗ ឯមនុស្សនៅក្នុងក្រុងកម្ពុជខេត្ត មានប្រភេទពីរយ៉ាងអាង
ប្រាជ្ញ គឺពាលកាចទឹងប្រាជ្ញប្រាប់ឲ្យគ្រប់ មិនទាន់គប់គាស់កាយផ្សាយ
ចេញឯង ៗ ឯសញ្ញាតិជនពាលចណ្ឌាសទាប គ្មានសភាពរៀបរយគួរ
ឲ្យក្រែង មានវិស័យចិត្តសម័យជាអ្នកល្បែង ប្រើទសំដែងអាការកាច
គក់ម៉ក់ ៗ ផ្លូវវិនាសរូបកាយអបាយមុខ ទទួលផ្ទុកគ្រប់យ៉ាងខាងអា
ក្រក់ កណ្តាគផ្តាត់បត់ករករកុហក វៀចក្រង់កមុខង៉ប់គ្រប់ប្រការ ៗ តែ

នៅស្ងៀមផ្ចិតអង្គុយរង់ចាំយានទៅចាកជ័យជាតិពូជពង្សវង្សាក្សត្រា គួរតែជៀស
ជៀសកាយឆ្ងាយឱកចារ ហើយជាឧបការគុណដល់កាយ ។ ឯបណ្ឌិត
គ្រាន់គិតមិនថេះខុស ជនស្រីប្រុសគ្រាន់គ្រាប់គង់សប្បាយ ទឹងជុំប្រឹងកេរ្តិ៍
ឈ្មោះខ្ពស់ផែងឆ្ងាយ បានសុខចិត្តសុខកាយគ្រប់ប្រការ ។ តោលគំល្អ
ថ្មើគំល្អិតគិតគំគ្រប់ សំដៅផ្លូវសន្តិសុខសង្ខារ ភង់វិប័ត្តកាចង្រៀមិច្ឆាចារ សាង
តែការបុណ្យបានគានទោះខារ ។ ត្រឹមប៉ុណ្ណោះណែនាំឲ្យឃើញហេតុ
គ្រឿងសង្កេតជាតិមនុស្សជាប្តី ក្នុងលោកនេះទឹកគប់គប្បីស្ងួរ ឃើញ-
សមគួរល្អពិតសមផ្ចិតអង្គ ។ ធម៌ខនេះជាច្បាប់សម្រាប់ប្រើ ឲ្យសប្បុរស-
ស្រីសើរកផ្លូវគ្រាន់ ក្នុងរឿងសន្តរម៉ិត្តចិត្តចំណាន់ ឲ្យផ្លូវផង់យើនយូរអង្វែង
គប្បី ។ បុគ្គលឹងគប់គប្បីមើលមុខចិត្ត ឲ្យឃើញពិតតាមពុទ្ធដីកាប្រាប់
អាក្រក់ល្អសខ្លៅឡៅបានឆាប់ មិនខុសច្បាប់បណ្ឌិតដូចសម្តែង ។ ប៉ុ-
មនុស្សពាលតែពោលយល់ប្រកេច ឲ្យឃើញហេតុឧបាយដែលក្លាយក្លែង
គ្រប្រជាបអត្តសព្រះពុទ្ធថ្លែង កុំផែងសង្ស័យកាល័យឆ្ងល់ ។ គប់ជនល្អ
គង់ល្អប្រសើរផែត រាបឲ្យកើតសុភអត្តពិតទទួល គប់ជនអាក្រក់ចិត្តល្អក់
កន្ទក់ខ្វល់ ខ្ទុតវាបដល់សកលកាយកល់គ្នា ។ មនុស្សយើងនេះឧត្តម-
ដោយគំកើត មិនមែនកើតមកក្លាយគំខុចរា ហុះប្រែបល់ចូលជាប់ជាតិ-
ការវា រូចទឹងជាតាង់ស្តិតចិត្តពស់ស្មាត ។ បុគ្គលាចិត្តានយានទុងអង្គ
ផ្ទាតកៅត្តុខសុភសេកជាការ ការប្រាស់ផែងផប្បធិអនេខនិទាក ចិត្ត-

កំសួាតបរិសុទ្ធឥតហោរហៅ ។ លុះខ្យល់បក់ឆក់បាត់សាត់តាកទី កំព្រាត់ពីសម្បុកបែកគ្នាទៅ សេកមួយនោះជ្រុះធ្លាក់លើលំនៅ ព្រះតាបសរើសទៅថែរក្សា ។ សេកមួយទៀតក៏តផាត់សាត់ទៅដល់ ទីមណ្ឌលសំណាក់ពួកចោរ ចោររើសទៅចិញ្ចឹមដោយមេត្តា ប្អូនរក្សាឥតល្ហែថែទាំទុក ។ សេកដែលនៅសំណាក់ព្រះតាបស ចិត្តសប្បុរសរកផលខ្វល់ចង់សុខ សាងសន្សំសុចរិតបំពេញវត្ត ដោះតាំងមុខតាមមគ្គលោកអ្នកប្រាជ្ញ ។ សេកដែលនៅទីធំចោរចិត្តអាក្រក់ រៀនតែឆក់និងលួចប្លស្រាកាច ចេះតែលួចឲ្យថ្ងៃបារកំណាច ក្អាត់តត្រូវចត់តក់តិតជីវិតក្ស័យ ។ ចូរមើលចុះតែជាតិសត្វតិរច្ឆាន តែបើតាលបំនានខ្វចនិស្ស័យ បើអប់ប្រាជ្ញ ។ រៀនព្រះធម៌ថ្លៃ អង្គស្រស័យប្រែតាមស្ពាមនោះហោង ។

---

សៀវភៅ សប្បុរិសធម៌ ពាក្យកាព្យ នេះ

មានផ្សាយនៅពុទ្ធសាសនបណ្ឌិត្យ ផ្សាភ្ជាប់នឹងសៀវភៅមួយផ្សេងទៀត

## ផ្នែកកំណត់-ប្រវត្តិការណ៍

# ចុតហ្មាយសហជីវិនរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ

នៅពេលដែលចូលកាន់ដំណែងថ្មី សហជីវិន ឌី-ទូច រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ បានធ្វើចុតហ្មាយមួយ ថ្វាយសម្ដេចព្រះសង្ឃរាជ សម្ដេចព្រះសង្ឃនាយក សម្ដេចព្រះពោធិវង្ស និង សម្ដេចព្រះធម្មវង្សា ព្រមទាំងព្រះសង្ឃ រាជាគណៈ ឋានានុក្រម និង ព្រះសង្ឃ-ពុទ្ធបរិស័ទទាំងអស់ក្នុងព្រះរាជាណាចក្រ មានសេចក្ដីដូចតទៅ ៖

ទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ
លេខ ៧០៩ កធ

ព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ នៅថ្ងៃទី ២០ ខែ សីហា ១៩៦៩

សូមព្រះតេជៈ គុណលើត្បូង !

សូមព្រះរាជទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទ

សម្ដេចព្រះសង្ឃរាជ ថ្នាក់ទី ១

សូមទ្រង់ជ្រាប ។

សូមនមស្ការចំពោះសម្តេចព្រះសង្ឃនាយក

សូមនមស្ការសម្តេចព្រះពោធិវង្ស សម្តេចព្រះធម្មវង្សាធិបតី

សូមទានប្រាប ។

សូមនមស្ការ ព្រះតេជព្រះគុណ ព្រះសង្ឃ កជាគណៈ ហំនាទុក្រម មេគណ អនុគណ លេខាធិការ ព្រមទាំងព្រះសង្ឃទាំងពីរគណៈ ក្នុងព្រះរាជាណាចក្រ ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ទើបនឹងមានភ័ព្វវាសនា បានទទួល តំណែងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ និង សាសនសិក្សាធិការ ក្នុងរាជរដ្ឋាភិបាលថ្មី ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា មានបីតិរីករាយណាស់ ដោយបាន គាល់បម្រើសម្តេចជាម្ចាស់ និងព្រះតេជព្រះគុណផ្ទាល់ ជាភ័ព្វសំណាង ឲ្យបានបម្រើព្រះពុទ្ធសាសនា ដ៏ជាសាសនារបស់រដ្ឋផង និងជាគោល នយោបាយជាតិដ៏ប្រសើរ ដែលសម្តេចឪជាម្ចាស់ជាទីគោរពៈ និងស្នេហា ព្រះអង្គទ្រង់ត្រួសត្រាយឡើង ហៅថា "សង្គមនិយមព្រះពុទ្ធសាសនា" ផង ។ មិនតែប៉ុណ្ណោះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា បានទទួលព្រះ រាជតម្រាស់ផ្តាំផ្ញើអំពីសម្តេច ព្រះប្រមុខរដ្ឋ អំពីឯកឧត្តមនាយករដ្ឋមន្ត្រី និង ព្រះបញ្ញាវៃនៃអង្គម្ចាស់ ឧបនាយករដ្ឋមន្ត្រីទី ១ ទទួលបន្ទុកក្រសួង មហាផ្ទៃ និងការសម្របសម្រួលនៃកិច្ចការសាសនា ទ្រង់បានផ្ទុកផ្តាក់ឲ្យ

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខិតខំបម្រើល្អងធូលី អង្គសម្ដេចជាអម្ចាស់ និងព្រះតេជព្រះគុណគ្រប់ព្រះអង្គ ។ ព្រះរាជបន្ទូលបណ្ដាំនេះស្របនឹងគំនិតផ្ទាល់ដែលទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា តាំងចិត្តយ៉ាងមាំថា នឹងខិតខំបំពេញភារកិច្ចបម្រើកិច្ចការព្រះពុទ្ធសាសនា ឲ្យបានពេញសមត្ថភាពគ្រប់ពេលវេលា ដើម្បីជាប្រយោជន៍ដល់ប្រទេសជាតិ ឯករាជ្យ និង អព្យាក្រឹតផង ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ជឿជាក់ថាភារៈដ៏ធំធេងទាំងនេះ នឹងប្រព្រឹត្តទៅបានល្អប្រសើរនោះ អាស្រ័យដោយព្រះរាជូបត្ថម្ភ ដ៏ថ្លៃថ្លា សេចក្ដីឧបត្ថម្ភ ពីសំណាក់ល្អងធូលី សម្ដេចជាម្ចាស់ និង ព្រះតេជព្រះគុណគ្រប់ព្រះអង្គជានិច្ចផង ។ ហេតុនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា សូមបួលមកលំនុនកាយថ្វាយខ្លួន ចំពោះល្អងធូលីសម្ដេចជាម្ចាស់ និងព្រះតេជព្រះគុណគ្រប់ព្រះអង្គ ទ្រង់មេត្តា- សូមទានមេត្តាប្រោសប្រទានទូន្មាន និងសេចក្ដីណែនាំផ្សេងៗ សម្រាប់យកមកប្រតិបត្តិឲ្យបានល្អប្រសើរ គង់មុខការបម្រើព្រះពុទ្ធសាសនា នៅគ្រប់ពេលវេលាដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ សព្វព្រះទ័យ ។

ជាអវសាន ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា សូមលំអុតលំទុនកាយបង្គំសួងចំពោះតេជានុភាពនៃព្រះត្រៃរតន៍ សូមមេត្តាជួយជ្រោមជ្រែងរក្សាកិបាលសម្ដេចជាអម្ចាស់ និងព្រះតេជព្រះគុណគ្រប់ព្រះអង្គ សូមទ្រង់

បាន និង បានប្រកបដោយសេចក្តីសុខចម្រើន និងព្រះជន្មាយុវែងឆ្ងាយ ដើម្បីជាពំនាក់អាស្រ័យនៃពុទ្ធមាមកជនជាតិខ្មែរតរៀងទៅ ។

មួយទៀត សូមថ្លែងសេចក្តីគោរព និង ប្រគេន-ជូនពរសព្ទសាធុ-ការចំពោះព្រះភិក្ខុ សាមណេរ-ឧបាសក-ឧបាសិកា ជាពុទ្ធបរិស័ទទាំងអស់ក្នុងព្រះរាជាណាចក្រ ។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ

និង សាសនសិក្សាធិការ

ហត្ថលេខា : ជី-ឡុង

ចម្លងជូន :

– ខុទ្ទកាល័យសម្តេចព្រះប្រមុខរដ្ឋ
– ទីស្តីការនាយករដ្ឋមន្ត្រី
– ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
– គ្រប់សាលាក្រុង-សាលាខេត្ត-អនុខេត្ត

១០

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤១ ខែ តុលា

ព.ស. ២៥១៣ គ.ស. ១៩៦៩

– ភ្នំពេញ –

១០

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ — ផ្នែកសាសនា — ទំព័រ

១— ទស្សនវិជ្ជាពុទ្ធសាសនា ព្រះមហាវីរិយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង ១០១៧

២— រឿងបណ្ឌិតសាមណេរ លោក ប៊ូ-ប៊ូ ប្រែរៀបរៀង . . . ១០៣០

## ផ្នែកអក្សរសាស្ត្រ

៣— វិចារណកថា : ការផ្លាស់ប្តូរប្រពៃណីក្នុងរឿងរកគូស្រករ លោក ផេង-ផ្ដើរ រៀបរៀង . . . . . . . . ១០៥៨

៤— ចម្រៀង បញ្ចសិខគន្ធព្វទេវបុត្រ លោក ញូង-សឿង រៀបរៀង . . ១០៦៥

៥— វចនានុក្រមសំស្ក្រឹតខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ១០៧៤

៦— រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ១០៧៨

៧— រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ អ្នកស្រីពេជ-សល់ ប្រែរៀបរៀង . . ១១០១

៨— កម្រងទំនុកបុរាណខ្មែរ សហ. លី-ធាមតេង ប្រមូលរៀង . . . ១១២០

## ផ្នែកកំណាត់-ប្រវត្តិការណ៍

៩— ព្រះរាជជីវប្រវត្តិ នៃសម្តេចព្រះមហាសុមេធាធិបតី (ជួន-ណាត) ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ . . . ១១២៧

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជា៛ ២៣០៛០០ ។

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ,
ឲ្យជុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ·

ប ព

# ទស្សនវិជ្ជាពុទ្ធសាសនា

ព្រះមហាវីរិយបណ្ឌិតោ ទាំង - ទាស់ រៀបរៀង

(តពីលេខមុន)

គោលធំបំផុត ក្នុងពុទ្ធសាសនា ដោយពិត និយាយចំពោះតែការត្រាស់ដឹងអរិយសច្ច ដែលព្រះសម្ពុទ្ធប្រើពាក្យថា: "ធម្មចក្ខុ=ភ្នែកធម៌ ឬមានភ្នែកឃើញធម៌" កើតឡើង, បានសេចក្តីថា "ភ្នែកមានធូលីគឺរាគៈទៅប្រាសហើយ បានឃើញសច្ចធម៌ បានលុះសច្ចធម៌ បានត្រាស់ដឹងសច្ចធម៌ បានចាក់ធ្លុះសច្ចធម៌ មានក្តីសង្ស័យកន្លងផុតហើយ ឃើញអ្វីៗឃើញដោយបញ្ញាចក្ខុ ដោយពិត តាមពិត = យថាភូតំ ញាណទស្សនំ, យថាភូតញាណទស្សនញាណ ។ បើតាមសេចក្តីដែលយើងបានសិក្សាគម្ពីរដីកាពុទ្ធសាសនា យើងបានឃើញថា ព្រះសម្ពុទ្ធទ្រង់

ត្រាស់ទុកក្នុងបឋមទេសនាថា (១) "ភ្នែក កើតហើយ ញាណ កើតហើយ បញ្ញា កើតហើយ វិជ្ជា កើតហើយ ពន្លឺកើតហើយ = ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ" ៗ ដូច្នេះ ពុទ្ធសាសនា និយាយតែពីការឃើញច្បាស់ដោយ ញាណទស្សនៈ មិនមែននិយាយជំនឿ ដូចជំនឿ = Croyance, Foi; Faith, Belief នោះទេ ៗ

ប្រស្នាជំនឿនេះ មានច្រើនអន្លើណាស់ ៗ ក្នុងសម័យពុទ្ធកាល មានព្រាហ្មណ៍ច្រើននាក់ សុទ្ធតែជាអ្នកគន្ធប្បដិបត្តិតឹងរ៉ឹង (Orthodox) ជាប់ប្រកែកជជែកគ្នាតឹងក ក្នុងការប្រើជំនឿទៅតាមប្រពៃណី ដែលខ្លួនធ្លាប់តែប្រកាន់ជឿតៗមក ហើយដែលខ្លួនចុះចិត្តស៊ប់ជឿថា ជាសច្ចៈឯក មិនមានប្រស្នាទៅទៀតឡើយ ៗ ថ្ងៃមួយ មានពួកព្រាហ្មណ៍អ្នកប្រាជ្ញច្រើននាក់ សុទ្ធតែបានដល់ត្រើយនៃត្រៃវេទ(២) ជជែកគ្នាពីប្រស្នាជំនឿនេះមិនដាច់ស្រេច បានចូលទៅគាល់ព្រះមានបុណ្យ ហើយលើកប្រស្នាជំនឿមកសាកសួរដេញដោល ៗ បណ្ដាព្រាហ្មណ៍ទាំងនោះ មានព្រាហ្មណ៍ម្នាក់នៅក្មេងជាងគេ អាយុទើបតែបាន ១៦ ឆ្នាំ ឈ្មោះ កាបដិកៈ ជាព្រាហ្មណ៍មានការចេះដឹងប្រសើរជាងគេ គេទុកជាព្រាហ្មណ៍

---

១. ធម្មចក្កប្បវត្តនសូត្រ ៗ ២. ព្រាហ្មណ៍អ្នកប្រាជ្ញសុទ្ធតែចេះវិជ្ជាព្រាហ្មណ៍ ព្រាហ្មណ៍ គម្ពីរ ៤ ជាដើម គឺគម្ពីរនិឃណ្ឌុ, អក្ខរប្បភេទ, កេដុភ, សិក្ខា និង និរុត្តិ, [illegible] ៗ

ឯក មានប្រាជ្ញាក្ដីថ្លៃ បានទៅទដណ្ដឹងព្រះមានបុណ្យថា: (១) ។

បពិត្រព្រះមានបុណ្យ ! មានគម្ពីរព្រាហ្មណ៍ គឺគម្ពីរ វេទ គេបានកេក្រទុកតៗមកដោយប្រពៃ តាមមុខបាឋតាមប្រពៃណី ។ គម្ពីរវេទ នេះ ព្រាហ្មណ៍គ្រប់គ្នាបានយល់គ្រប់គ្នាជាឯកច្ឆន្ទថា: “មន្ត្រវេទនេះ ជាសច្ចឯក មិនមានពីរទេ = ឯកំសច្ចំ អាទ្ទិតីយម ដទៃពីនេះសុទ្ធតែជាធម៌ខុស មិនមែនជាសច្ចៈទេ” ។ សេចក្ដីនេះតើព្រះសមណគោតម មានសេចក្ដីយល់ឃើញជាដូចម្ដេច ?

ព្រះសម្ពុទ្ធទ្រង់ព្រះសណ្ដាប់ហើយ ត្រាស់ក្ខាន់ តបទៅវិញថា: ។

“ភារទ្វាជ: ! បណ្ដាព្រាហ្មណ៍ទាំងអស់ មានព្រាហ្មណ៍ណាម្នាក់ ដែលអួតការថាខ្លួនបានដឹងច្បាស់ បានឃើញច្បាស់ដោយខ្លួនឯងថា មន្ត្រៈវេទ នេះជាសច្ចឯកមិនមានពីរទេ ដទៃពីនេះសុទ្ធតែជាធម៌ខុសដែរឬទេ ?

“មិនមានទេ ពានប្រោស ! កាបទិកព្រាហ្មណ៍នេះ ជាគេង ស្មោះត្រង់ឆ្លើយតបពុទ្ធដីកាថា, ឥតមានព្រាហ្មណ៍ណាម្នាក់បានដឹង បានឮ បានឃើញដោយខ្លួនឯងទេ ” ។

“ភារទ្វាជ: ! ព្រះសម្ពុទ្ធត្រាស់សួរតទៅទៀត, ចុះមាន អាចារ្យណាម្នាក់ ឬ អាចារ្យតពីអាចារ្យដើម ដែលជាព្រាហ្មណ៍មានអាយុ

---

១- មជ្ឈិមនិកាយ ចង្កីសូត្រ មជ្ឈិមបណ្ណាសក សៀវភៅ ទី ២៥ ទំព័រ ១៨ ។

វែងរហូតដល់ប្រាំពីរជួរគោត្រ ឬក៏ឫសីដើម (១) ដែលបានចងក្រងគម្ពីរ វេទ ទុកមក ហើយអ្នកអាងថាខ្លួនបានដឹងច្បាស់ បានឮច្បាស់ បានឃើញច្បាស់ដោយខ្លួនឯងថា មន្ត្រៈ វេទ ជាសច្ចឯកមិនមានពីរទេ ដទៃពីនេះសុទ្ធតែជាធម៌ខុសដែរឬទេ " ?

" ទេ ! ទេ ! ទានប្រោស ! កាបទិកព្រាហ្មណ៍ក្មេងក្រាបទូលតបពុទ្ធដីកា , មិនមានអ្នកណា បានដឹង បានឮ បានឃើញដោយខ្លួនឯងទេ " ។

ភារទ្វាជៈ ! ព្រះសម្ពុទ្ធត្រាស់តទៅ , ចម្លើយរបស់អ្នកនេះ មើលទៅឃើញថា ព្រាហ្មណ៍ទាំងអស់សុទ្ធតែជាជួរគោត្រមនុស្សខ្វាក់ ៗ ព្រាហ្មណ៍ខ្វាក់ម្នាក់ ដៀពឹងផ្អែកទៅលើព្រាហ្មណ៍ខ្វាក់ម្នាក់ទៀត ដៀខ្វាក់តៗគ្នារហូតមកឫសីជំនាន់ដើម ដែលជាអ្នកចងក្រង វេទ ក៏មិនបានឃើញឫសីជំនាន់កណ្ដាល ក៏មិនបានឃើញដែរ ឫសីជំនាន់ក្រោយតៗមកទៀត ក៏រតែមិនបានឃើញសោះទៅទៀត ។ ដូច្នេះតថាគត យល់ឃើញថា ចម្លើយរបស់អ្នកនេះ ប្រាប់តថាគតច្បាស់ថាស្ថានភាពព្រាហ្មណ៍ទាំងអស់ បើគន់គិតមើលឲ្យបព្វគ្រប់ ជាជួរគោត្រព្រាហ្មណ៍ខ្វា៎ ដូចជាជួរគោត្រមនុស្សខ្វាក់រហូតទាំងគោត្រ យកជា

---

១- ឫសីពីបូរាណសុទ្ធតែអ្នកជំនាញ គឺឫសីអដ្ឋកៈ, វាមកៈ, វាមទេវៈ, វេស្សាមិត្តៈ, យមតគ្គិ, អង្គីរសៈ, ភារទ្វាជៈ, វាសេដ្ឋ, កស្សបៈ, ភគុ ។

ការមិនបាន ។ តទៅព្រះសម្ពុទ្ធត្រាស់ទេសនាទូន្មានព្រាហ្មណ៍ទាំងនោះថា សេចក្តីនេះមិនសមបើបុគ្គលជាអ្នកប្រាជ្ញប្រាកដដូចអ្នកគ្រប់គ្នាដែលជាអ្នកចេះដឹងប្រសើរ នៅតែទទួលប្រកាន់ជឿថា " មន្ត្រ:វេទជាសច្ចឯកមិនមានពីរ ដទៃពីនេះសុទ្ធតែជាធម៌ខុស " ដូច្នេះឡើយ ។

" ភារទ្វាជ:! ព្រះសម្ពុទ្ធត្រាស់ដណ្តឹងតទៅទៀត, ចុះអ្នកគ្រប់គ្នាយល់ឃើញសេចក្តីនេះ ថាដូចម្តេច ? បើមិនដូច្នោះទេ មានតែជំនឿព្រាហ្មណ៍ដែលអ្នកអួតអាងមកនេះ ជាអមូលិកា: = មិនមានឫសគល់ពិតប្រាកដ មែនឬទេ ?

" សូមទ្រង់ព្រះមេត្តាប្រោស ! ការបទិកព្រាហ្មណ៍ក្រាបបង្គំទូល, ជំនឿព្រាហ្មណ៍នេះ មិនមែនជាឥតហេតុផលទេ ពួកព្រាហ្មណ៍បានចូលទៅអង្គុយជិត បានសិក្សា រៀនសូត្រ បានឮត ៗ គ្នាមក ហើយទើបប្រកាន់ជឿដូច្នេះឯង " ។

" ភារទ្វាជ: ! ព្រះសម្ពុទ្ធត្រាស់តទៅ, កាលពីមុន អ្នកបាននិយាយថា "មានជំនឿ" ឥឡូវនេះ អ្នកនិយាយថា "បានឮត ៗ គ្នាមក បានជាមានជំនឿ „ ។

ភារទ្វាជ: ! ធម៌ ៥ ប្រការគឺ ១–ជំនឿ = សទ្ធា, ២ ការគាប់ចិត្ត = រុចិ, ៣–ការឮត ៗ តាមគ្នា = អនុស្សវ, ៤–ការត្រិះរិះនូវអាការ = អាការបរិវិតក្ក, ៥– ការចូលចិត្តតាមការ

យល់ឃើញ ការចូលចិត្តសិប់ = ទិដ្ឋិនិជ្ឈានក្ខន្តិ ទាំង ៥ ប្រការនេះ តែងមានវិបាក ២ ប្រការគឺៈ

ក– ហេតុណា ដែលបុគ្គលសិប់, ដែលបុគ្គលគាប់ចិត្ត, ដែលបុគ្គលពុត ៗ តាមគ្នា, ដែលបុគ្គលត្រិះរិះនូវអាការ, ដែលបុគ្គលចូលចិត្តសិប់ តែហេតុនោះមិនមែនជាការពិត ក៏តែងមានដែរ

ខ– ហេតុណា ដែលបុគ្គលមិនជឿសិប់, ដែលបុគ្គលមិនគាប់ចិត្ត ដែលបុគ្គលមិនពុត ៗ តាមគ្នា, ដែលមិនត្រិះរិះនូវអាការ, ដែលមិនចូលចិត្តសិប់ តែហេតុនោះ ជាការពិត ក៏តែងមានដែរ ។

ដូច្នេះ ធម៌ ៥ ប្រការនេះគឺ សទ្ធា រុចិ អនុស្សវ អាការបរិវិតក្កា ទិដ្ឋិនិជ្ឈានក្ខន្តិ មិនមែនជាពុទ្ធសាសនាទេ ។ ពុទ្ធសាសនិកជន ត្រូវវៀរបង់នូវធម៌៥ប្រការនេះ ដែលជាធម៌ពាំងមិនឲ្យយល់សេចក្តីពិតបាន មិនត្រូវឲ្យធម៌នេះ បិតនៅកង្សន្តានចិត្តឡើយ ។

លំដាប់នោះ ព្រះសម្ពុទ្ធត្រាស់ទេសនាទូន្មានថាៈ "ការស្វែងរកសច្ចធម៌មិនត្រូវសម្រេចសេចក្តីអ្វីមួយដោយដាច់ខាតថា មានតែធម៌មួយនេះ វេទ ជាសច្ចឯក អ្វីដទៃទៀតសុទ្ធតែខុសទាំងអស់ ដូច្នេះឡើយ ។

"សូមទ្រង់ព្រះមេត្តាប្រោស! កាបទិកព្រាហ្មណ៍ក្រាបទូលសួរ, ដើម្បីស្វែងរកសច្ចធម៌ ឬការពារសច្ចធម៌ តើត្រូវប្រើឧត្តមគតិដូចម្តេច ?

ភារទ្វាជៈ! ព្រះសម្ពុទ្ធត្រាស់ពន្យល់, មនុស្សម្នាក់ៗ តែងមានជំនឿ = សទ្ធា (Croyance, Foi) ។ បើនិយាយ គេអាចនិយាយបានថា នេះជាជំនឿ = សទ្ធា របស់ខ្ញុំ ទៅទល់ពេលណាដែលគេរកសច្ចធម៌ឃើញ ។ ប៉ុន្តែជំនឿនេះគេមិនត្រូវជំរុញទៅដល់ការសម្រេចចិត្តដាច់ខាតថា នេះជាសច្ចឯក ឯធម៌ដទៃទៀតសុទ្ធតែខុសទាំងអស់ ដូច្នេះឡើយ " ។ និយាយមួយបែបទៀតថា: "មនុស្សម្នាក់ៗអាចជឿអ្វីបានតាមដែលខ្លួនយល់ឃើញ ហើយអាចនិយាយបានថា ខ្ញុំជឿដូច្នេះទៅដល់ពេលណា ដែលខ្លួនរកសច្ចធម៌ឃើញ តែដោយជំនឿ (Croyance, Foi) នេះ គេមិនគប្បីសម្រេចដាច់ខាតថា អ្វីដែលខ្លួនជឿនោះជាសច្ចធម៌តែមួយ ឯធម៌ដទៃពីនេះ សុទ្ធតែខុសទាំងអស់ ដូច្នេះទេ " ។

ព្រះសម្ពុទ្ធតែងត្រាស់ទេសនាទូន្មានថា : (១)

« មនុស្សតែងដេកត្រាំនៅក្នុង ទិដ្ឋិ ថា ធម៌នេះ ប្រសើរបំផុត ហើយគោរពសាស្ដានោះ ទុកជាសាស្ដាវិសេសបំផុត សាស្ដាដទៃពីរបស់ខ្លួន សុទ្ធតែថោកទាប ទាំងអស់ ។ ដោយហេតុនេះបានជាមនុស្សចេះតែមានវិវាទមិនចេះចប់ ។

« មនុស្សបានឃើញការនិស្ស័យក្នុងខ្លួន ចំពោះអារម្មណ៍ដែលខ្លួន

១- ខុទ្ទកនិកាយ សុត្តនិបាត មហាព្យូហសូត្រ សៀវភៅទី ៥៤ ទំព័រ ២៧៣ ។

បានឃើញ បានឮ បានពាល់ត្រូវ ឬ ចំពោះសីលព្វត ក៏ប្រកាន់ខ្ជាប់នូវអានិសង្សនោះ ទុកជា សក្កាយទិដ្ឋិ = ឃើញថាជារបស់ខ្លួនប្រសើរ ហើយទុកគ្រូដទៃ ៗ ថាសុទ្ធតែថោកទាបទាំងអស់ ” ។

“ អ្នកដែលនៅក្នុងសំណាក់គ្រូណា ហើយដេកត្រាំនៅក្នុង ទិដ្ឋិ គ្រូនោះតែងតែយល់ថា ធម៌គ្រូរបស់ខ្លួនប្រសើរបំផុត ធម៌គ្រូដទៃ ៗ សុទ្ធតែជាធម៌ថោកទាបទាំងអស់ ។ អ្នកប្រាជ្ញឈ្លាសវៃប្រដៅទុកថា: “ការជាប់ក្នុង ទិដ្ឋិ នេះ ជាប្រក់បង្ក ” ។

ភិក្ខុទាំងឡាយ មិនគួរគប្បីជាប់ជំពាក់ចំពោះ ទិដ្ឋិ និងសីលព្វត នេះឡើយ ” ។

មួយទៀត ព្រះសម្ពុទ្ធត្រាស់ទេសនាបដិច្ចសមុប្បាទធម៌[1] ចំពោះភិក្ខុទាំងឡាយ ។ លុះបានស្តាប់ព្រះធម្មវិសេសទេសនា ហើយ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលព្រះសម្ពុទ្ធថា :

“ សូមទ្រង់ព្រះមេត្តាប្រោស ! ខ្ញុំព្រះអង្គបានឃើញធម៌នោះហើយ ,, ។

“ ភិក្ខុទាំងឡាយ ! ព្រះសម្ពុទ្ធត្រាស់បញ្ជាក់. បើអ្នកពល់គ្នាជាប់ជំពាក់ វែកកាយ ក្តួចកាន់ រាប់អានចំពោះទិដ្ឋិនេះថា: បរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ដោយតណ្ហា និង ទិដ្ឋិ នោះឡើយទេ ម្តេចឡើយអ្នកនឹង

---

១- មជ្ឈិមនិកាយ មូលបណ្ណាសក មហាតណ្ហាសង្ខយសូត្រ សៀវភៅទី២២ ទំព័រ ១៦៣ ។

បានយល់ច្បាស់នូវធម៌ដែលមានឧបមាដូចជា សំពៅគេគ្រាដែលតថា-គតសម្ដែងហើយ ដើម្បីប្រយោជន៍រើខ្លួនឲ្យចាក ឱឃៈ ទាំង ៤ មិនមែនដើម្បីប្រយោជន៍ឲ្យប្រកាន់នូវខន្ធបញ្ចកៈនោះទេ មិនដូច្នោះឬ ។

ក្នុងពុទ្ធសាសនា ព្រះសម្ពុទ្ធទ្រង់តែងតែត្រាស់ទេសនា ប្រៀបធៀបធម៌ព្រះអង្គថា ដូចជាសំពៅគេគ្រា សម្រាប់ជិះឆ្លងទៅកាន់ត្រើយនាយ មិនមែនសម្រាប់ប្រកាន់ខ្ជាប់ ហើយលីសែងយកទៅតាមទេ ទ្រង់ត្រាស់ថា :

" ភិក្ខុទាំងឡាយ ? មនុស្សម្នាក់ ជាអ្នកធ្វើដំណើរ ដើរទៅដល់ត្រើយសមុទ្រត្រើយអាយ ប្រកបដោយភ័យច្រើន ត្រើយនាយជាត្រើយនិរភ័យ ប្រកបដោយក្ដីក្សេមក្សាន្ត តែមិនមានអ្វីនឹងឆ្លងទៅ ។ មនុស្សនេះគិតថា សមុទ្រនេះធំធេងណាស់ ត្រើយអាយនេះមានភ័យច្រើនណាស់ ត្រើយនាយឥតភ័យ មានតែក្ដីក្សេមក្សាន្ត តែមិនមានយានឆ្លងទៅ ទូកក៏មិនមាន ! ជាការគាប់ប្រសើរណាស់ ប្រសិនបើអាត្មាអញយកស្មៅ ឈើ មែកឈើ ឬ សន្លឹកឈើ មកធ្វើជាក្បូន ហើយអាស្រ័យដោយក្បូននេះ អាត្មាអញនឹងឆ្លងទៅត្រើយនាយ ដោយប្រើដៃនិងជើងអុំទូកចែវទៅ ។

ភិក្ខុទាំងឡាយ ? មនុស្សអ្នកធ្វើដំណើរនេះ ដើររកស្មៅ ឈើ មែកឈើ សន្លឹកឈើ រកបានហើយ ធ្វើជាក្បូននេះ អាស្រ័យដោយ

ក្បូននេះគេធ្លងទៅត្រើយខាយ ដោយប្រើដៃនិងជើងអុំទូកថែវទៅ ។ ធ្លងទៅដល់ត្រើយនាយហើយមានប្រស្នាមួយទៀត អ្នកធ្វើដំណើរនេះគិតថា អាត្មាអញធ្វើដូចម្ដេចអេះ ? ក្បូននេះ ជួនអាត្មាអញបានសម្រេចដូចបំណង ហើយអាស្រ័យដោយក្បូនជាពំនឹងនេះ អាត្មាអញបានដល់ត្រើយ ប្រកបដោយក្ដីក្សេមក្សាន្ត ដើម្បីតបឧបការៈ គួរតែអាត្មាអញលើកក្បូនជាពំនឹងដ៏ប្រសើរនេះដាក់លើក្បាលហើយទូល ឬ អាត្មាអញលើកក្បូននេះ ដាក់លើស្មាហើយលីយកទៅ ទើបសម ។

ភិក្ខុទាំងឡាយ សេចក្ដីនេះ អ្នកទាំងឡាយគិតដូចម្ដេច ? អ្នកដំណើរយើងនេះ ត្រូវធ្វើតាមគំនិតដែលខ្លួនគិតឃើញនេះ ឬ ទើបឈ្មោះថាធ្វើការគួរសមចំពោះក្បូននោះ ?

សូមទ្រង់ព្រះមេត្តាប្រោស ! ពុំគួរសមទេ

ព្រះសម្ពុទ្ធទ្រង់បន្តព្រះពុទ្ធដីកាតទៅទៀតថា :

" ភិក្ខុទាំងឡាយ ! ឥឡូវនេះ អ្នកធ្វើដំណើរយើងបានធ្លងមកដល់ត្រើយនាយដោយក្ដីក្សេមក្សាន្តហើយ ឧបមាថា អ្នកធ្វើដំណើរនេះគិតថា " ក្បូននេះមានគុណបំណាច់នឹងអាត្មាអញណាស់ អាស្រ័យដោយក្បូននេះអាត្មាអញបានធ្លងមកដល់ត្រើយ ប្រកបដោយក្ដីក្សេមក្សាន្តហើយគួរណាស់តែអាត្មាអញលើកក្បូននេះ ដាក់ទៅលើត្រើយ ឬចងទុក ឬក៏ពន្លិចចោលទៅ ហើយធ្វើដំណើរចរចេញទៅតាមក្ដីប្រាថ្នា ។ ធ្វើដូច្នេះ

ទើបឈ្មោះថាអ្នកធ្វើដំណើរនេះ ចេះធ្វើការគួរសមចំពោះក្បូននោះ ។

ភិក្ខុទាំងឡាយ ! ធម្មវិន័យដែលតថាគតបានសម្តែងហើយ ប្រៀបដូចក្បូនដូច្នោះដែរធម្មវិន័យនេះ គ្រាន់តែជាសំពៅកេត្រាសម្រាប់ជិះឆ្លងតែប៉ុណ្ណោះទេ មិនមែននាំឲ្យកើតមានឧបាទាន សម្រាប់ប្រកាន់ខ្ជាប់ទេ ។

ភិក្ខុទាំងឡាយ ! បុគ្គលណាមួយយល់ឃើញធម្មវិន័យនេះ ថាទុកដូចជាសំពៅកេត្រា បុគ្គលនោះឈ្មោះថាបានប្រតិបត្តិធម្មវិន័យ ដែលតថាគតសម្តែងហើយនេះសមគួរទៅតាមធម៌ហើយ ព្រោះបានលះបង់ធម៌ ធម៌ (១) ទាំងអស់ចោលបង់អស់ហើយ ។

ដំណើរនិទាននេះ ធ្វើឲ្យយើងបានយល់ច្បាស់ថា ពុទ្ធវចនៈ មានអត្ថន័យថានាំសត្វទៅកាន់ សិរីឋានសន្តិវរបទ បរមសុខ. ខេមឋាន ត្រើយត្រានអមតនិព្វានពិតប្រាកដ ។ ពុទ្ធវចនៈនេះ ជាស្វាក្ខាតធម៌ដឹកនាំសត្វទៅកាន់ទីបំផុតទុក្ខបានពិត ។ ពុទ្ធវចន. នេះ ជានិយ្យានិកធម៌ គឺជាសំពៅកេត្រាដឹកនាំសត្វទៅកាន់ត្រើយត្រានអមតនិព្វានពិតប្រាកដ ។ ព្រះសម្ពុទ្ធទ្រង់មិនសម្តែងធម៌ទុកគ្រាន់តែសម្រាប់បន្អឹតសត្វលោក ឬទុកគ្រាន់តែបង្ហាញបុគ្គលបញ្ញវន្តឲ្យចង់មើលចង់ដឹងនោះទេ ។ ធម្មវិន័យព្រះអង្គ ពិតជាធម៌នាំសន្តិភាព នាំ

---

១- ក្នុងអដ្ឋកថាសូត្រនេះពន្យល់ថា កុសលធម៌ក្តី អកុសលធម៌ក្តី ព្រមទាំងឈានសមាបត្តិ ត្រូវលះបង់ចោលទាំងអស់ ព្រោះធម៌ទាំងអស់នេះ មិននាំឲ្យទៅដល់ទីបំផុតទុក្ខទេ ។

សេចក្ដីសុខ មកប្រគល់ឲ្យសត្វលោក ដែលកំពុងក្ដៅពេលពលដោយភ្លើងទុក្ខ ភ្លើងកិលេសបានយ៉ាងសក្តិសិទ្ធិបំផុត ។ ធម្មវិន័យព្រះអង្គនេះជាទឹកអម្រឹត គួរសាធុជនក្រេបផឹកបំបាត់ក្ដៅស្រេកឃ្លានបានយ៉ាងប្រសើរបំផុត ។

អ្នកមិនបានសិក្សាពុទ្ធសាសនា ដោយម៉ត់ចត់តែងនិយាយថា ពុទ្ធ-សាសនាមិនមានលក្ខណៈដោយបរិបូណ៌ទៅតាមផ្លូវលោក គឺគេចង់និយាយថា ព្រះសម្ពុទ្ធមិនចេះវិជ្ជាផ្លូវលោក សម្រាប់បង្កើតសារពើភ័ណ្ឌជាផាសុក = Confort សម្រាប់មនុស្សលោកឡើយ ។ ព្រះសម្ពុទ្ធទ្រង់ជាសព្វញ្ញុពុទ្ធ ទ្រង់មិនមានអ្វីនៅសល់ទើសទាក់នឹងព្រះបញ្ញាញាណព្រះអង្គទេ ធម៌ណាជាកុសលជាធម៌ដឹកនាំសត្វលោកទៅកាន់ សន្តិវរបទ ទ្រង់តែងតែសម្ដែងធម៌នោះអស់ចិរៈវេលា ៤៥ វស្សា ដើម្បីជាប្រយោជន៍ដល់មនុស្សលោក ទេវលោកព្រហ្មលោក ។ ធម្មវិន័យព្រះអង្គនេះជាកញ្ចក់សម្រាប់ឆ្លុះមើលអ្វីក៏បាន មើលល្អក៏បានមើលអាក្រក់ក៏បាន ស្រេចហើយតែអ្នកឆ្លុះត្រូវការ ។

សម័យមួយ ព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចព្រះឥរិយាបថនៅសីសបាវន ជិតក្រុងកោសម្ពី ។ ពេលនោះ ទ្រង់លោងព្រះហស្តទៅចាប់សន្ទឹកឈើមួយក្តាប់មកទុកក្នុងព្រះហស្ត ហើយទ្រង់ត្រាស់សួរទៅ

កាន់ភិក្ខុទាំងឡាយថា :(១)

" ភិក្ខុទាំងឡាយ ! អ្នកទាំងឡាយយល់ឃើញដូចម្តេច ? សន្លឹកឈើមួយក្តាប់ ដែលនៅក្នុងដៃតថាគតនេះ និងសន្លឹកឈើដែលមាននៅព្រៃដើមឈើឯណោះ ឯណាច្រើនជាងឯណា ?

សូមទ្រង់ព្រះមេត្តាប្រោស ! ភិក្ខុទាំងឡាយទូលព្យាករ ហើយក្រាបទូលថា សន្លឹកឈើដែលនៅក្នុងក្តាប់ព្រះហស្តនេះ មានចំនួនតិចណាស់ ឯសន្លឹកដែលមាននៅព្រៃដើមឈើក្នុងសីសបាវននេះ មានចំនួនច្រើនណាស់ និងគណនរាប់ពុំបានឡើយ ។

ភិក្ខុទាំងឡាយ ធម្មវិន័យដែលតថាគតបានត្រាស់ដឹង ហើយដែលតថាគតយកមកសម្តែងប្រាប់ដល់អ្នកទាំងឡាយ មានចំនួនតិចណាស់ ឯធម៌ដែលតថាគត បានត្រាស់ដឹងហើយមិនបានយកមកសម្តែងប្រាប់ដល់អ្នកទាំងឡាយ មានច្រើនណាស់ ដូចសន្លឹកឈើដែលមាននៅក្នុងសីសបាវននេះឯង ។ ចុះហេតុអ្វី ក៏តថាគតមិនយកធម៌ទាំងអស់នោះមកសម្តែងប្រាប់អ្នកទាំងឡាយ ? ព្រោះថាធម៌ទាំងអស់នោះ មិនមានប្រយោជន៍ មិននាំសត្វលោកទៅនិព្វាន ។

(នៅមានត)

១- សំយុត្តនិកាយ មហាវគ្គ សីសបាវនវគ្គ សៀវភៅទី ៣៩ ទំព័រ ២៥៣ ។

# រឿងបណ្ឌិតសាមណេរ

អដ្ឋកថាធម្មបទ បណ្ឌិតវគ្គទី ៦ ភាគទី ៤

លោក ប៊ូ - ប៊ុ រៀបរៀង

កាលព្រះបរមសាស្ដាគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនឹង បណ្ឌិតសាមណេរ ( ឲ្យជាហេតុ ) ហើយទ្រង់សម្ដែងធម៌ដោយបទគាថាថា ឧទកំ ហិ នយន្តិ ដូច្នេះជាដើម ។

មានសេចក្ដីពិស្ដារថា = កាលកន្លងរំលងទៅជាច្រើនហើយ ព្រះកស្សបសម្មាសម្ពុទ្ធ មានព្រះវិហារស្រពតំរឹនអន្តរាបរិការ បាននេះស្ដេច យាងទៅឯនគរពារាណសី ៗ មនុស្សទាំងឡាយកំណត់ដីកម្លាំងរបស់ខ្លួន ហើយប្រជុំគ្នា ៨ នាក់ខ្លះ ១០ នាក់ខ្លះ បានថ្វាយអាគន្តុកទាន ៗ

ថ្ងៃមួយ ក្នុងវេលាភត្តកិច្ច ព្រះបរមគ្រូបានទ្រង់ធ្វើអនុមោទនាយ៉ាងនេះថា ម្នាលឧបាសកនិងឧបាសិកាទាំងឡាយ! មនុស្សខ្លះក្នុងលោកនេះ គិតថា គាត់ឲ្យទ្រព្យសម្បត្តិរបស់ខ្លួនជាទាន តែម្នាក់ឯងប៉ុណ្ណោះ ក៏ល្មមសមគួរហើយ មិនបាច់ឃោសនាដឹកនាំបបួលអ្នកដទៃទេ គិតរួច ក៏ថ្វាយទានតែម្នាក់ឯង មិនឃោសនាបបួលអ្នកដទៃឡើយ អ្នកនោះ រមែងបានភោគសម្បត្តិតែម្យ៉ាង មិនបានបរិវារសម្បត្តិទេ ក្នុងទីដែលខ្លួនកើតហើយ,

មនុស្សខ្លះចេះតែឃោសនាបបួលអ្នកដទៃ ឯខ្លួនឯងមិនបានឲ្យទានទេ អ្នកនោះរមែងបានតែបរិវារសម្បទាម្យ៉ាង មិនបានភោគសម្បទាទេ ក្នុងទីដែលខ្លួនកើតហើយ, មនុស្សខ្លះ ខ្លួនឯងក៏មិនបានឲ្យទាន សូម្បីអ្នកដទៃក៏មិនបបួលដែរ អ្នកនោះរមែងមិនបានទាំងភោគសម្បទា ទាំងបរិវារសម្បទា ក្នុងទីដែលខ្លួនកើតហើយ ជាមនុស្សស៊ីដែលគេចិញ្ចឹមជីវិត, មនុស្សខ្លះ ខ្លួនឯងក៏ឲ្យទាន អ្នកដទៃក៏បបួល អ្នកនោះ រមែងបានទាំងភោគសម្បទាទាំងបរិវារសម្បទា ក្នុងទីដែលខ្លួនកើតហើយ ។

មានបុរសជាបណ្ឌិតម្នាក់ ឈរស្តាប់ព្រះធម៌ទេសនា នៅក្នុងទីជិត គិតថា សម្បត្តិទាំងពីរយ៉ាង នឹងកើតមានដល់អញយ៉ាងណា គ្រាទេះអញនឹងធ្វើយ៉ាងនោះ ។ គាត់ក៏ថ្វាយបង្គំព្រះសាស្តា ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងថ្ងៃព្រឹកស្អែក សូមព្រះអង្គទទួលភិក្ខា របស់ខ្ញុំព្រះអង្គ ។ ព្រះសាស្តាត្រាស់សួរថា អ្នកត្រូវការភិក្ខុចំនួនប៉ុន្មានរូប? ។ ចុះបរិវាររបស់ព្រះអង្គមានប៉ុន្មាន? ។ មានចំនួនពីរម៉ឺនរូប ។ សូមព្រះអង្គព្រមទាំងភិក្ខុសង្ឃទាំងអស់ ទទួលចង្ហាន់របស់ខ្ញុំព្រះអង្គក្នុងថ្ងៃព្រឹកស្អែក ។ ព្រះសាស្តាទ្រង់ទទួលនិមន្តហើយ ។ ឯបណ្ឌិតបុរស ចូលទៅក្នុងស្រុក ហើយដើរប្រកាសឃោសនាថា អម្មុតា តា អស់លោកអ្នកនាងជាបងប្អូនដូនតាម៉ែឪ ! ក្នុងថ្ងៃព្រឹកស្អែកនេះ ខ្ញុំនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធានទុករួចហើយ លោកអ្នកទាំងឡាយ ចូរថ្វាយទានដល់ភិក្ខុទាំង-

ឡាយតាមសេចក្តីអាចនឹងធ្វើបាន  កាលជនទាំងឡាយកំណត់ដឹងកម្លាំងរបស់ខ្លួនហើយឆ្លើយថា  យើងខ្ញុំនឹងថ្វាយដល់ភិក្ខុដប់រូប ម្ភៃរូប មួយរយរូប ប្រាំរយរូប ដូច្នេះ គាត់ក៏កត់ត្រាពាក្យរបស់អ្នកទាំងអស់នោះទុកក្នុងបញ្ជី  តាំងពីដើមរៀងមក ។ ក្នុងសម័យនោះ  មានបុរសម្នាក់ប្រាកដឈ្មោះថា  មហាទុគ្គតៈ  ព្រោះមានភាពជាមនុស្សទាល់ក្រណាស់នៅក្នុងព្រះនគរនោះ ។  បណ្ឌិតបុរស  ក្រឡេកឃើញមហាទុគ្គតៈនោះដើរមកចំមុខខ្លួនក៏ប្រាប់ថា នែសម្លាញ់  មហាទុគ្គតៈ !  ខ្ញុំនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធាន  ដើម្បីភត្តកិច្ចក្នុងថ្ងៃព្រឹកស្អែក,  អ្នកនគរទាំងឡាយនឹងនាំគ្នាថ្វាយទាន  តើអ្នកឯងនឹងទទួលប្រគេនចង្ហាន់ដល់ភិក្ខុប៉ុន្មានរូបដែរ ។  មហាទុគ្គតៈ ឆ្លើយថា  លោក ! ខ្ញុំមានប្រយោជន៍អ្វីដោយភិក្ខុទាំងឡាយ  ពួកអ្នកដែលមានទ្រព្យ  ទើបគេត្រូវការដោយភិក្ខុទាំងឡាយ, ឯខ្ញុំគ្មានតែអង្ករប្រមាណមួយនាឡិ ដើម្បីនឹងបបរក្នុងថ្ងៃព្រឹកស្អែក  ក៏មិនទាន់មានទេ, ខ្ញុំធ្វើការស៊ីឈ្នួលគេចិញ្ចឹមជីវិត  មិនទាន់ត្រូវការដោយភិក្ខុទាំងឡាយទេ ។  ធម្មតាអ្នកដែលដឹកនាំគេ  ត្រូវតែជាអ្នកឈ្លាសវៃប៉ិនប្រសប់ណាស់  ព្រោះដូច្នោះ  បណ្ឌិតបុរសនោះ  សូម្បីកាលមហាទុគ្គតៈ និយាយថា "គ្មានអង្ករ" ក៏នៅតែមិនឈប់ស្ងៀម, បង្អុលពន្យល់យ៉ាងនេះ ថា  សម្លាញ់ មហាទុគ្គតៈ ! មនុស្សជាច្រើន ក្នុងព្រះនគរនេះ  គេបរិភោគភោជនដ៏ល្អ  ស្លៀកពាក់សំពត់សាច់ម៉ត់ល្អ

ស្អិតស្អាងខ្លួនដោយគ្រឿងអាភរណៈផ្សេងៗ ដេកលើដំណេកដ៏មានសិរី ហោយសម្បត្តិសម្បូណ៌សប្បាយ ចំណែកខ្លួនអ្នកឯងធ្វើការស៊ីឈ្នួលគេ ពេញមួយថ្ងៃ នៅតែមិនបានអាហារល្មមឆ្អែត កាលបើដូច្នេះ អ្នកឯងមិន ទាន់ដឹងខ្លួនទេឬថា អញមិនបានទ្រព្យអ្វីៗ ព្រោះមិនបានធ្វើអំពើល្អ ៗ ទុកមកពីកាលមុន ៗ បាទ! ខ្ញុំដឹងយ៉ាងហ្នឹងដែរ លោក! ៗ បើអ្នកដឹង ហើយ ហេតុអ្វីគ្រានេះ បានជាអ្នកមិនព្រមធ្វើបុណ្យ. អ្នកនៅក្មេងកំលោះ សម្បូណ៌ដោយកម្លាំងកាយ បើធ្វើការឈ្នួល ហើយថ្វាយទានតាមកម្លាំង ដែលរកអង្ករបាន មិនគួរឬ ៗ កាលបើបណ្ឌិតបុរសពន្យល់យ៉ាងច្បាស់ លាស់ដូច្នេះ មហាទុគ្គតៈ កើតសេចក្តីស្លុតចិត្ត ហើយឆ្លើយទូលថា លោកបូរកត់ភិក្ខុមួយរូបទុកក្នុងបញ្ជីឲ្យខ្ញុំផង ខ្ញុំនឹងធ្វើការឈ្នួលយ៉ាងណា មួយហើយ នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប ៗ បណ្ឌិតបុរស មិនបាន ចុះឈ្មោះគាត់ទុកក្នុងបញ្ជីផងទេ ដោយគិតថា ចាំបាច់អ្វី ដោយភិក្ខុមួយ រូប ដែលអញត្រូវចុះទុកក្នុងបញ្ជី ៗ មហាទុគ្គតៈ ទៅដល់ផ្ទះហើយ ប្រាប់ភរិយាថា នាងដ៏ចម្រើន! ក្នុងថ្ងៃព្រឹកស្អែក អ្នកនគរគេនាំគ្នាធ្វើភត្ត ថ្វាយដល់ព្រះសង្ឃ, ឯអ្នកដឹកនាំគេប្រាប់បងថា អ្នកចូរទទួលប្រគេនចង្ហាន់ ដល់ភិក្ខុមួយរូប ចុះ, ក្នុងថ្ងៃព្រឹកស្អែក យើងទាំងពីរនាក់នឹងប្រគេនចង្ហាន់ ដល់ភិក្ខុមួយរូប ៗ លំដាប់នោះ ភរិយារបស់គេ មិននិយាយថា យើងទាំង ពីរនាក់ជាមនុស្សទាល់ក្រណាស់ ហេតុអ្វីបានជាអ្នកហ៊ានទទួលព្រមតាម

ពាក្យគេដូច្នេះទេ តែបែរជានិយាយថា បង! អ្នកធ្វើអំពើល្អហើយ ដ្បិតពីកាលមុនៗ យើងទាំងពីរនាក់មិនបានថ្វាយទានអ្វីទុកមកសោះ បានជាដល់មកជាតិនេះកើតជាអ្នកកម្សត់ទុគ៌តដល់ម៉្លឹង យើងទាំងពីរនាក់ធ្វើការឈ្នួលហើយ នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប, និយាយព្រមព្រៀងគ្នារួច ទាំងពីរនាក់បានចេញទៅរកទីកន្លែងអ្នកជួល ៗ លោកមហាសេដ្ឋីបានឃើញមហាទុគ្គតៈ មកដល់ហើយសួរថា សម្លាញ់ មហាទុគ្គតៈ! អ្នកមកនឹងធ្វើការឈ្នួលឬ ? ។ បាទ! ខ្ញុំបាទនឹងធ្វើ ។ អ្នកនឹងទទួលធ្វើការយ៉ាងណា ? ។ បើលោកឲ្យខ្ញុំបាទធ្វើការយ៉ាងណា ខ្ញុំបាទនឹងធ្វើការយ៉ាងនោះ ។ បើដូច្នោះ ក្នុងថ្ងៃព្រឹកស្អែកនេះ យើងនឹងប្រគេនចង្ហាន់ព្រះភិក្ខុសង្ឃ ប្រាំរយរូប អ្នកចូរមក ចូរទៅពុះឧសចុះ, ប្រាប់រួចយកកាំបិតនិងពូថៅមកប្រគល់ឲ្យ ។ មហាទុគ្គតៈ កើតក្សេមយ៉ាងណាទេហើយ មានសេចក្ដីឧស្សាហ៍ប្រឹងប្រែងណាស់ ពេលកាំបិតបាក់ពូ-ថៅ ពេលពូថៅបាក់កាំបិត ទំពុះឧសឥតឈប់ ។ លំដាប់នោះ លោកសេដ្ឋីសួរបុរសនោះថា សម្លាញ់! ថ្ងៃនេះ អ្នកឯងខំប្រឹងធ្វើការលើសពីធម្មតា តើមានហេតុអ្វីអេះ? លោកម្ចាស់! ខ្ញុំបាទនឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប ។ លោកសេដ្ឋីស្ដាប់ភាសារបស់បុរសហើយ មានចិត្តជ្រះថ្លាគិតថា បុរសនេះ ធ្វើអំពើជាការប្រពៃដែលបុគ្គលធ្វើបាន, គាត់មិនព្រមជាអ្នកនៅស្ងៀមចំពោះមនុស្សទាល់ក្រទេ នៅតែនិយាយថា ខ្ញុំធ្វើការ

ឈ្នួលបានអង្ករហើយ នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូបដែរ ៗ ចំណែកភរិយារបស់សេដ្ឋី ឃើញភរិយារបស់មហាទុគ្គតៈ ហើយសួរថា នាងនឹងធ្វើការយ៉ាងណា ? ៗ បើលោកស្រីឲ្យខ្ញុំធ្វើការយ៉ាងណា ខ្ញុំនឹងយ៉ាងនោះ ៗ ភរិយាសេដ្ឋីប្រាប់ឲ្យនាងនោះចូលទៅឯរោងត្បាល់បុកស្រូវ ប្រាប់ស្រីបម្រើឲ្យយកគ្រឿងប្រើប្រាស់ មានបន្ទះនិងអង្រែជាដើម ប្រគល់ឲ្យភរិយាបុរសកម្សត់ ៗ នាងសប្បាយចិត្តណាស់ ធ្វើការហាក់ដូចជាច្រៀងរាំ បុកស្រូវផង រែងអង្ករផង ៗ លំដាប់នោះ លោកស្រីភរិយារបស់សេដ្ឋីសួរនាងថា នែនាង! នាងត្រេកអរកាយសប្បាយចិត្តណាស់នឹងធ្វើការងារ ចុះមានហេតុអ្វី? ៗ ខ្ញុំទាំងពីរនាក់ប្តីប្រពន្ធ ធ្វើការឈ្នួលនេះរួចហើយ នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប ៗ ភរិយាសេដ្ឋី ឮពាក្យនាងហើយជ្រះថ្លានឹងនាងថា ស្រីនេះធ្វើអំពើជាកម្រដែលបុគ្គលនឹងធ្វើបាន ៗ នៅវេលាដែលមហាទុគ្គតៈ ពុះឧសរួចស្រេចហើយ លោកសេដ្ឋីក៏ឲ្យអង្ករស្រូវសាលីបួននាឡិ ប្រាប់ថា នេះ ជាថ្លៃឈ្នួលរបស់អ្នក ហើយឲ្យអង្ករស្រូវសាលីបួននាឡិទៀត ប្រាប់ថា នេះ ជារង្វាន់របស់អ្នក ៗ បុរសនោះទៅដល់ផ្ទះហើយប្រាប់ភរិយាថា បងធ្វើការឈ្នួលបានស្រូវសាលីហើយ ស្រូវសាលីនេះនឹងធ្វើជាអាហារ នាងចូរទិញយកទធិនិងប្រេងនិងគ្រឿងហារទាំងឡាយ ដោយថ្លៃឈ្នួលដែលនាងបានហើយ គឺថា ប្តីប្រាប់ប្រពន្ធឲ្យយកថ្លៃឈ្នួលដែលប្រពន្ធបាននោះ ទៅទិញទធិជាដើម ៗ

ចំណែកកិរិយារបស់សេដ្ឋី ឲ្យសប្បិមួយដបទធិមួយចាន គ្រឿងហារមួយមុខទៀត អង្ករនៃស្រូវសាលីសបរិសុទ្ធមួយនាឡិ ដល់កិរិយារបស់មហាទុគ្គតៈ នោះ ៗ ប្តីប្រពន្ធទាំងពីរនាក់ បានអង្កររួមគ្នាជាប្រាំនាឡិ ដោយប្រការដូច្នេះ ៗ ប្តីប្រពន្ធទាំងពីរនាក់ សប្បាយចិត្តណាស់ដោយគិតថា យើងទាំងពីរនាក់បានទេយ្យធម៌ហើយ[1] ក៏ក្រោកឡើងអំពីព្រហាម ៗ នាងកិរិយានិយាយ នឹងមហាទុគ្គតៈ ជាប្តីថា អ្នកចូរទៅរកបន្លែមក ៗ មហាទុគ្គតៈ ទៅរកទិញបន្លែក្នុងផ្សារ មិនឃើញមាន ទើបដើរទៅឆ្នេរស្ទឹង មានចិត្តរីករាយ ដោយគិតថា អញនឹងបានថ្វាយភោជនដល់លោកម្ចាស់ទាំងឡាយ ហើយក៏ស្រែកច្រៀងជាភ្លេងបេះបន្លែ ៗ ឯនាយព្រានឈរបង់សំណាញ់គិតថា ប្រហែលជាសំឡេងរបស់ មហាទុគ្គតៈ ទើបស្រែកសួរថា អ្នកឯងមានចិត្តរីករាយខ្លាំងណាស់ ស្រែកច្រៀងជាភ្លេង តើមានហេតុអ្វី? ៗ ខ្ញុំបេះបន្លែ សម្លាញ់! ៗ អ្នកនឹងយកបន្លែទៅធ្វើអ្វី ? ៗ នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប ៗ ភិក្ខុរូបណាឆាន់បន្លែ.របស់អ្នកឯង ភិក្ខុរូបនោះមានចិត្តសប្បាយណាស់ ៗ ខ្ញុំនឹងធ្វើដូចម្ដេចបាន សម្លាញ់! មានតែនឹងប្រគេនលោកឆាន់ដោយបន្លែដែលខ្ញុំបានទៅហើយ ៗ បើដូច្នោះ អ្នកចូរមកណេះសិន ៗ នឹងឲ្យខ្ញុំទៅធ្វើអ្វីសម្លាញ់ ? ៗ អ្នកចូរដោតត្រីទាំងនេះឲ្យជាត្រណោត មួយត្រណោត

---

១- គឺវត្ថុដែលសម្រាប់បរិច្ចាគ ។

ថ្ងៃមួយកាក់ខ្លះ មួយត្រណោត ថ្ងៃប្រាំសេនខ្លះ ថ្ងៃមួយរៀលខ្លះ ។ មហាទុគ្គតៈ បានផ្ញើតាមបន្ទាប់នាយព្រានសំណាញ់ ។ អ្នកនគរទាំងឡាយទិញយកត្រណោតត្រីដែល មហាទុគ្គតៈ ដោតទុកស្រេចនោះទៅ ដើម្បីប្រយោជន៍ដល់ភិក្ខុដែលខ្លួនបាននិមន្តហើយៗ ។ កាលមហាទុគ្គតៈ កំពុងតែដោតត្រណោតត្រី ក៏ដល់ពេលភិក្ខាចារ កំណត់ពេលបានហើយនិយាយថា ខ្ញុំនឹងទៅផ្ទះហើយសម្លាញ់ ! ដ្បិតវេលានេះជាពេលភិក្ខុទាំងឡាយនិមន្តមក ។ នាយព្រានសួរថា ចុះត្រីត្រណោតអ្វីៗ មាននៅសល់ខ្លះដែរឬទេ ។ មហាទុគ្គតៈ ឆ្លើយថា គ្មានទេសម្លាញ់ ! អស់រលីងទៅហើយ ។ នាយព្រានប្រាប់ថា បើដូច្នោះ ត្រីធ្ពិនស្រស់បួន យើងកប់ទុកក្នុងដីខ្សាច់ដើម្បីប្រយោជន៍ខ្លួន បើអ្នកប្រាថ្នានឹងប្រគេនភិក្ខុគាត់ ចូរយកត្រីធ្ពិនស្រស់ទាំងបួននេះទៅចុះ ជារួចក៏ឲ្យត្រីទាំងនោះទៅមហាទុគ្គតៈ ។

ក្នុងវេលាបច្ចូសសម័យថ្ងៃនោះ ព្រះបរមសាស្តាទ្រង់ពិចារណាមើលសត្វ ឃើញមហាទុគ្គតៈ ចូលទៅក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទើបទ្រង់រំពឹងមើលថា ហេតុអ្វីហ្ន៎ ! ទ្រង់ព្រះតម្រិះឃើញថា មហាទុគ្គតៈ ព្រមទាំងភរិយា គិតគ្នាថា នឹងប្រគេនបង្កាន់ដល់ភិក្ខុមួយរូប បានធ្វើការឈ្នួលពីថ្ងៃម្សិលមិញ គាត់នឹងបានភិក្ខុរូបណាអេះ ? ទើបទ្រង់ពិនិត្យមើលតទៅទៀតថា មនុស្សទាំងឡាយ នឹង

កាន់យកភិក្ខុ តាមសញ្ញាដែលគេកត់ទុកក្នុងបញ្ជី នឹងឲ្យអង្គុយឆាន់ក្នុងផ្ទះរបស់ខ្លួន ៗ, ឯមហាទុគ្គតៈ ក្រៅពីតថាគត មុខជាមិនបានភិក្ខុរូបណាផ្សេងទៀតទេ ។

បានឮថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ រមែងទ្រង់ធ្វើការអនុគ្រោះចំពោះមនុស្សកម្សត់ទុគ៌តទាំងឡាយ ។ ព្រោះដូច្នេះ ព្រះបរមសាស្តាទ្រង់ធ្វើសរីរកិច្ចអំពីព្រហាម ទ្រង់មានព្រះតម្រិះថា នឹងសង្គ្រោះមហាទុគ្គតៈ ដូច្នេះ ហើយស្តេចចូលទៅកាន់ព្រះគន្ធកុដីគង់នៅ ។ កាលមហាទុគ្គតៈ យូរត្រីដើរទៅដល់ផ្ទះខ្លួន បណ្ឌុកម្ពលសិលាសនៈ របស់ព្រះឥន្ទ ក៏សម្តែងនូវអាការក្តៅ ។ ព្រះឥន្ទទ្រង់ពិចារណាថា មានហេតុអ្វីពម្លែកអេះ ? ទ្រង់ឃើញថា ពីថ្ងៃម្សិលមិញ មហាទុគ្គតៈ ព្រមទាំងភរិយារបស់ខ្លួនគិតថា នឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប បានធ្វើការឈ្នួល តើគាត់នឹងបានភិក្ខុរូបណាហ្ន៎ ? ទ្រង់ព្រះចិន្តាតទៅទៀតថា ភិក្ខុរូបឯទៃពុំមានដល់គាត់ទេ, មានតែព្រះសាស្តាគង់នៅក្នុងព្រះគន្ធកុដិ [illegible] ដែលតាំងព្រះហឫទ័យថា នឹងធ្វើការសង្គ្រោះដល់មហាទុគ្គតៈ ។ គប្បីថ្វាយបបរនឹងភត្តជាមួយនឹងសម្លសម្រេចហើយ [illegible] ដល់ខ្លួនចំពោះព្រះតថាគត ដូច្នេះ អញត្រូវតែទៅផ្ទះ [illegible] មហាទុគ្គតៈ ហើយក្លែងខ្លួនធ្វើជាអ្នកគ្រួ គឺអ្នកដាំស្ល, ទើប [illegible] មិនឲ្យអ្នកដទៃស្គាល់ ស្តេចទៅដល់ជិតផ្ទះរបស់គាត់ ហើយត្រាស់

សួរថា កិច្ចការអ្វី ៗ របស់អ្នកណា ដែលត្រូវការជួលគេធ្វើ មានដែរឬទេ? មហាទុគ្គតៈ ឃើញតាឥន្ទហើយនិយាយថា សំឡាញ់ទឹងធ្វើអ្វី? ៗ ខ្ញុំចេះចំណេះគ្រប់យ៉ាង, ឈ្មោះថាចំណេះដែលខ្ញុំពុំចេះដឹងនោះគ្មានទេ, ខ្ញុំស្ទាត់ជំនាញខាងតុបតែងនូវបាយបរនិងភត្តជាដើម ៗ បើនឹងខ្ញុំត្រូវការដោយកិច្ចការរបស់អ្នក ប៉ុន្តែ ពុំមានថ្លៃឈ្នួល ដែលខ្ញុំនឹងគប្បីឲ្យដល់អ្នកទេ ៗ ចុះកិច្ចការអ្វីទៅដែលអ្នកត្រូវធ្វើ? ៗ ខ្ញុំប្រាថ្នានឹងប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប ចង់ឲ្យអ្នកចាត់ចែងបរនិងភត្ត ៗ បើអ្នកចាត់ចែងប្រគេនចង្ហាន់ដល់ភិក្ខុ ខ្ញុំមិនត្រូវការយកថ្លៃឈ្នួលទេ សូមតែអ្នកផ្សាយចំណែកបុណ្យឲ្យខ្ញុំ បានដែរឬទេ ៗ កាលបើដូច្នោះ ប្រពៃណាស់ហើយសំឡាញ់! អ្នកចូរមកចុះ ៗ តាឥន្ទ ក៏ចូលទៅក្នុងផ្ទះរបស់គាត់ ហើយឲ្យយកអង្ករជាដើមមកឲ្យ រួចឲ្យ មហាទុគ្គតៈ ទៅ, ប្រាប់ថា អ្នកចូរទៅនាំយកភិក្ខុ ដែលត្រូវបានដល់ខ្លួនមក ៗ ចំណែកបុរសអ្នកខ្វល់ខ្វាយក្នុងការ បញ្ជូនភិក្ខុទាំងឡាយទៅផ្ទះរបស់ជននោះ ៗ តាមកំណត់ដែលខ្លួនកត់ទុកក្នុងបញ្ជីនោះអស់ ៗ មហាទុគ្គតៈ ចូលទៅដល់បុរសនោះ ហើយនិយាយការថា អ្នកចូរឲ្យភិក្ខុមកខ្ញុំ ៗ ក្នុងខណៈនោះអ្នកកាន់បញ្ជីស្រាប់តែភ្ញាក់ខ្លួនព្រើត និយាយថា ខ្ញុំភ្លេចភិក្ខុរបស់អ្នកទៅហើយ ៗ មហាទុគ្គតៈ ហាក់ដូចជាគេយកលំពែងដ៏មុតមកចាក់ត្រង់ទ្រូង ផ្អងដើមដៃឡើងស្រែកយំនិយាយថា សំឡាញ់! លោកដូចម្ដេច

បានជាអ្នកធ្វើឲ្យខ្ញុំវិនាស, អ្នកបបួលខ្ញុំពីថ្ងៃម្សិលមុញ, ខ្ញុំព្រមទាំងករិយា ធ្វើការឈ្នួលពីព្រលឹមដល់ព្រលប់ ពីព្រឹកមិញនេះ ខ្ញុំស្ទុះស្ទើងទៅរកបេះបន្លែនៅឆ្នេរស្ទឹងបានមកហើយ, អ្នកចូរឲ្យភិក្ខុមួយរូបកុំខាន ។ មនុស្សទាំងឡាយមកប្រជុំគ្នាមើល សួរថា មានរឿងអ្វីមហាទុគ្គតៈ ។ ប្រាប់សេចក្ដីនោះសព្វគ្រប់ ។ មនុស្សទាំងនោះសួរអ្នកកាន់បញ្ជីថា បានឮថា សំឡាញ់ឯង បបួលដឹកនាំមហាទុគ្គតៈ នេះថា អ្នកចូរធ្វើការឈ្នួល ហើយប្រគេនចង្ហាន់ដល់ភិក្ខុមួយរូប មែនឬទេ? - បាទ! មែនហើយ ។ កាលអ្នកចាត់ភិក្ខុដល់ត្រឹមនេះ មិនឲ្យភិក្ខុមួយរូបដល់មហាទុគ្គតនេះ ជាកម្មអាក្រក់ណាស់ ។ អ្នកកាន់បញ្ជីអៀនខ្មាសនឹងសំដីរបស់អ្នកទាំងនោះ ទើបនិយាយនឹង មហាទុគ្គតៈ ថា សំឡាញ់មហាទុគ្គតៈ អ្នកកុំធ្វើខ្ញុំឲ្យវិនាសឡើយ ខ្ញុំត្រូវជំទៀលគេជាច្រើន ព្រោះហេតុតែអ្នក ឥឡូវមនុស្សទាំងឡាយ នាំយកភិក្ខុដែលខ្លួនត្រូវបាន ៗ តាមកំណត់ដែលខ្ញុំកត់ទុកក្នុងបញ្ជីអស់ទៅហើយ, ឈ្មោះថាអ្នកដែលនឹងហ៊ាននាំយកភិក្ខុគង់ក្នុងផ្ទះរបស់ខ្លួនរួចហើយ ទៅឲ្យអ្នកឯង នេះមិនដែលមានទំនៀមទេ, ឯព្រះសាស្ដាស្រង់ព្រះភក្ត្រស្រេចហើយគង់ក្នុងព្រះគន្ធកុដិ, ចំណែកព្រះរាជា ព្រះយុវ-រាជនិងសេនាបតីជាដើម នាំគ្នាអង្គុយចាំព្រះសាស្ដាស្ដេចចេញពីព្រះគន្ធ-កុដិដោយគំនិតថា នឹងទទួលបាត្ររបស់ព្រះសាស្ដាយកទៅ, ធម្មតាព្រះពុទ្ធជាម្ចាស់ទាំងឡាយតែងទ្រង់ធ្វើសេចក្ដីអនុគ្រោះចំពោះមនុស្សទាល់ក្រ,

ចូរអ្នកទៅឯវិហារ ហើយទូលព្រះសាស្តាថា ខ្ញុំព្រះអង្គជាមនុស្សកម្សត់ទុគ៌តណាស់ ព្រះអង្គ ! សូមព្រះអង្គ ធ្វើការសង្គ្រោះដល់ខ្ញុំព្រះអង្គដូច្នេះ ។ បើបុណ្យរបស់អ្នកមាន អ្នកនឹងបានជាប្រាកដ ។ មហាទុគ្គតៈក៏ប្រញាប់ទៅឯវិហារ ។ លំដាប់នោះ ព្រះរាជានិងព្រះយុវរាជជាដើម និយាយហាមឃាត់ មហាទុគ្គតៈ ថា នែ មហាទុគ្គតៈ ! វេលានេះ មិនមែនជាកាលធ្វើភត្តទេ អ្នកមកធ្វើអ្វីដូច្នេះ? ព្រោះខ្លួនធ្លាប់ឃើញ មហាទុគ្គតៈ ពីថ្ងៃមុនៗ ជាអ្នកសុំបាយសល់ដែលសេសសល់ក្នុងវិហារ ។ មហាទុគ្គតៈឆ្លើយថា លោកម្ចាស់ ! ខ្ញុំដឹងហើយថា វេលានេះមិនមែនជាកាលរបស់ភត្តទេ គឺមិនទាន់ដល់ពេលឆាន់ចង្ហាន់ទេ ក៏ប៉ុន្តែខ្ញុំមកដើម្បីថ្វាយបង្គំព្រះសាស្តា ថារួច ក៏ចូលទៅក្រាបក្បាលត្រង់ធរណីទ្វារព្រះគន្ធកុដិ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ! ក្នុងព្រះនគរនេះ មនុស្សដែលទាល់ក្រលំបាកជាងខ្ញុំព្រះអង្គ គ្មានទេ, សូមព្រះអង្គជាទីពឹងរបស់ខ្ញុំព្រះអង្គ សូមទ្រង់សង្គ្រោះដល់ខ្ញុំព្រះអង្គផង ។ ព្រះបរមសាស្តាបើកទ្វារព្រះគន្ធកុដិ យកបាត្រមកដាក់លើដៃរបស់មហាទុគ្គតៈ ។ មហាទុគ្គតៈ សប្បាយចិត្តយ៉ាងក្រៃលែង ដូចបានសិរី គឺភាពជាស្តេចចក្រពត្តិ ព្រះរាជានិងព្រះយុវរាជជាដើម ងាកសម្លឹងមើលមុខគ្នាទៅវិញទៅមក ។ ពុំមាននរណាមួយអាចនឹងហ៊ានដណ្តើមយកបាត្រ ដែលព្រះសាស្តាប្រទានដល់មហាទុគ្គតៈ

ដោយអាងអំណាចខ្លួនជាធំបានទេ ។ ឯជនទាំងឡាយ ក៏និយាយអង្វរមហាទុគ្គតៈ ថា សំឡាញ់ មហាទុគ្គតៈ ! អ្នកប្តូរឲ្យបាត្ររបស់ព្រះសាស្តាមកយើង យើងនឹងឲ្យប្រាក់មួយពាន់រៀល ឬមួយសែនរៀលទៅអ្នក, អ្នកឯង ជាមនុស្សទាល់ក្រណាស់ យកប្រាក់ទៅចុះ, អ្នកឯងឥតបានប្រយោជន៍អ្វីអំពីបាត្រនេះទេ ។ មហាទុគ្គតឆ្លើយថា ខ្ញុំមិនព្រមឲ្យបាត្រទៅអ្នកណាទេ, ខ្ញុំមិនចង់បានប្រាក់, ខ្ញុំមិនត្រូវការនឹងប្រាក់កាសទេ នឹងនិមន្តព្រះសាស្តាឲ្យសោយតែប៉ុណ្ណោះ ។ អ្នកឯទៀត ៗ អង្វរសូមយកបាត្រពីមហាទុគ្គត មិនបានសោះ ។ ចំណែកព្រះរាជាទ្រង់ព្រះតម្រិះថា សូម្បីអញនិយាយលួងលោមឲ្យប្រាក់កាសគេ ក៏នៅតែមិនព្រមឲ្យបាត្ររបស់ព្រះសាស្តា ម្យ៉ាងទៀត អ្នកណា ៗ ក៏មិនអាចដណ្តើមបាត្រ ដែលព្រះសាស្តាប្រទានឲ្យដោយព្រះអង្គឯងដែរ ឈ្មោះថាទេយ្យ-ធម៌របស់គេនឹងល្អវិសេសត្រឹមណា, ក្នុងវេលាដែលគេថ្វាយទេយ្យធម៌រួចអញនឹងនាំព្រះសាស្តាទៅដំណាក់ ហើយនឹងថ្វាយអាហារ ដែលគេតាក់តែងទុកបម្រុងឲ្យអញ, ទ្រង់ព្រះតម្រិះដូច្នេះហើយ បានស្តេចតាមព្រះសា-ស្តាទៅ ។ ឯព្រះទេវរាជ ចាត់ចែងបវរគន្ធនិងបន្ទំជាដើមស្រេចហើយក៏ក្រាលអាសនៈដ៏សមគួរជាទីគង់របស់ព្រះសាស្តា ។ មហាទុគ្គតៈនាំព្រះសាស្តាទៅដល់ផ្ទះហើយក្រាបទូលថា សូមអញ្ជើញព្រះអង្គស្តេចចូលទៅ ។ ឯគេហស្ថានទីលំនៅរបស់មហាទុគ្គតៈនោះ ទាបពេក បុគ្គលមិន

ឱនចុះហើយ មិនអាចចូលទៅបានឡើយ ។ មែនពិត ធម្មតាព្រះពុទ្ធជាម្ចាស់ទាំងឡាយ កាលស្ដេចចូលទៅក្នុងផ្ទះ មិនទ្រង់ឱនចូលទៅទេ គឺក្នុងវេលាដែលព្រះពុទ្ធជាម្ចាស់ស្ដេចចូលទៅក្នុងផ្ទះ មហាប្រឹថពីស្រុតចុះក្រោម ឯផ្ទះអណ្ដែតខ្ពស់ឡើងទៅលើ ។ រឿងនេះ ជាផលរបស់ទានដែលព្រះពុទ្ធជាម្ចាស់ទាំងឡាយថ្វាយល្អហើយ ។ ឯក្នុងវេលាដែលព្រះពុទ្ធជាម្ចាស់ស្ដេចត្រឡប់ទៅវិញ ទីទាំងពួងជាស្ថានតាំងនៅដោយប្រក្រតីតាមដើម ។ ព្រោះហេតុនោះ ព្រះសាស្ដាឈរហើយស្ដេចចូលទៅក្នុងផ្ទះ គង់លើអាសនៈដែលព្រះឥន្ទ្រតាក់តែងថ្វាយ ។ កាលព្រះសាស្ដាគង់ហើយ ព្រះរាជាត្រាស់សួរថា សម្លាញ់ មហាទុគ្គតៈ! សូម្បីកាលយើងអង្វរសុំ អ្នកក៏មិនព្រមឲ្យបាត្ររបស់ព្រះសាស្ដាសោះ យើងនឹងសូមមើលឲ្យឃើញសិន តើសក្ការៈដែលអ្នកធ្វើថ្វាយចំពោះព្រះសាស្ដានោះដូចម្ដេចទៅ ។ លំដាប់នោះ ព្រះឥន្ទ្របើកបបរនិងភត្តជាដើមបង្ហាញឲ្យស្ដេចទត ។ ក្លិនគ្រឿងអប់របស់អាហារទាំងនោះ បានបក់ផ្សាយទូទៅពេញព្រះនគរ ។ ព្រះរាជា ទតឃើញបបរនិងភត្តជាដើម ហើយទូលព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន ! ខ្ញុំមកគិតថា ទេយ្យធម៌របស់ មហាទុគ្គតៈ នឹងល្អត្រកាលត្រឹមណា កាលគាត់ថ្វាយទេយ្យ-ធម៌រួចហើយ នឹងនាំព្រះអង្គទៅកាន់ព្រះដំណាក់ ហើយនឹងថ្វាយអាហារដែលគេតាក់តែងទុកបម្រុងខ្លួន ដូច្នេះ បានជាតាមព្រះអង្គមក, អាហារ

បែបនេះ ខ្ញុំព្រះអង្គមិនដែលបានឃើញសោះឡើយ, កាលបើខ្ញុំព្រះអង្គ នៅក្នុងទីនេះ មហាទុគ្គតៈ គប្បីលំបាក, ខ្ញុំព្រះអង្គនឹងទូលលា ដូច្នេះ ហើយ ស្តេចថ្វាយបង្គំព្រះសាស្តាចៀសចេញទៅ ។ ឯព្រះឥន្ទថ្វាយបបរ ជាដើម អង្គាសព្រះសាស្តាដោយគោរព ។ ព្រះសាស្តាធ្វើភត្តកិច្ចស្រេច ហើយ ធ្វើអនុមោទនា រួចស្តេចក្រោកចាកអាសនៈស្តេចចេញទៅ ។ ព្រះឥន្ទ បានឲ្យសញ្ញាដល់ មហាទុគ្គតៈ ។ ក៏ទទួលបាត្រជូនដំណើរព្រះសាស្តាទៅ ។ ព្រះឥន្ទស្តេចត្រឡប់មកឈរ ត្រង់ទ្វារផ្ទះរបស់មហា-ទុគ្គតៈ ទតមើលអាកាស ។ ភ្លៀងជាវិការនៃរតនៈ ៧ យ៉ាង ធ្លាក់មកពីអាកាស ញុំាងភាជនៈទាំងអស់ក្នុងផ្ទះរបស់មហាទុគ្គតៈឲ្យពេញ រួចញុំាងផ្ទះទាំងមូលឲ្យពេញទៀត ។ ក្នុងផ្ទះមហាទុគ្គតៈ គ្មានចន្លោះភល់ទំនេរឡើយ ភរិយារបស់មហាទុគ្គតៈ ដឹកដៃទារកចេញមកឈរនៅខាងក្រៅ ។ មហាទុគ្គតៈ ជូនដំណើរព្រះសាស្តាទៅហើយវិលមកដល់ផ្ទះវិញ ឃើញក្មេងឈរនៅខាងក្រៅសួរថា មានរឿងអ្វី ? ។ ភរិយាប្រាប់ថា បង ! ផ្ទះយើងទាំងមូល ពេញទៅដោយកែវ ៧ ប្រការ គ្មានភលចន្លោះ ដើម្បីនឹងដើរចូលទៅទេ ។ មហាទុគ្គតៈ គិតថា ទានដែលអញថ្វាយហើយ ឲ្យផលក្នុងថ្ងៃនេះឯង (ឃើញទាន់ភ្នែក) គិតរួចក៏ទៅគាល់ព្រះរាជាថ្វាយបង្គំ, កាលព្រះអង្គត្រាស់សួរថា មកមានការធុរៈអ្វី ? ក៏ទូលថា បពិត្រព្រះអង្គ ! ផ្ទះខ្ញុំព្រះអង្គ ពេញទៅដោយកែវ ៧ ប្រការ សូមព្រះ

អង្គយកទ្រព្យនោះចុះ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ឯធានដែលបុរសនេះថ្វាយចំពោះព្រះពុទ្ធជាម្ចាស់ ដល់នូវទីបំផុត ក្នុងថ្ងៃនេះឯង, ហើយត្រាស់ថា បានអ្វីទៅយកទើបល្អ ។ សូមព្រះអង្គព្រះរាជទានរទេះមួយពាន់ ដើម្បីដឹកយកទ្រព្យមក ។ ព្រះរាជាទ្រង់បញ្ជូនរទេះទៅឲ្យមួយពាន់ បង្គាប់ឲ្យដញ្ជូនទ្រព្យមកគរទុកក្នុងព្រះលានហ្លួង បានជាគំនរប្រមាណមួយដើមត្នោត ។ ព្រះរាជាបង្គាប់ឲ្យហៅអ្នកនគរមកប្រជុំគ្នា ហើយត្រាស់សួរថា ក្នុងព្រះនគរនេះ អ្នកណាមានទ្រព្យប្រមាណប៉ុណ្ណេះដែរឬ ? អ្នកនគរទូលថា គ្មានទេព្រះអង្គ ! ។ ធ្វើអ្វីឲ្យគេដែលជាអ្នកមានទ្រព្យប្រមាណប៉ុណ្ណោះ ទើបសមគួរ ។ តាំងឲ្យគេធ្វើជាសេដ្ឋីទើបសមគួរ ព្រះអង្គ ! ។ ព្រះរាជាទ្រង់ធ្វើសក្ការៈយ៉ាងធំ ដល់មហាទុគ្គតៈ ហើយព្រះរាជទានតំណែងសេដ្ឋី ។ លំដាប់នោះ ព្រះរាជាត្រាស់ព្រះរាជទានភូមិស្ថានទីសង់ផ្ទះរបស់សេដ្ឋីក្នុងកាលមុនមក ដល់សេដ្ឋីនោះ ត្រាស់ថា អ្នកចូរឲ្យមនុស្សកាប់គាស់យកគុម្ពឈើដែលកើតក្នុងទីនោះចេញទៅ ហើយសង់ផ្ទះទៅចុះ ។ កាលជនទាំងឡាយជម្រះស្ថានទីនោះ ដើម្បីឲ្យសេដ្ឋីនោះ ប្រាបពាស្រាបនៃផែនដីឲ្យស្មើ កំណប់ទ្រព្យទាំងឡាយ ផុសឡើងមល គ្នានឹងគ្នា (ចុះជឿត) ។ កាលសេដ្ឋីនោះក្រាបទូលចំពោះព្រះរាជាហើយ ព្រះអង្គត្រាស់ថា ទ្រព្យនេះ បានកើតដោយបុណ្យរបស់អ្នកម្នាក់ឯង អ្នកចូរយកតែម្នាក់ឯងចុះ ។ សេដ្ឋីនោះ ធ្វើផ្ទះស្រេចហើយ បានថ្វាយ

មហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធានអស់ ៧ ថ្ងៃ ។ តពីនោះមក សេដ្ឋីនោះតាំងនៅដរាបដល់អស់អាយុ ធ្វើបុណ្យទាំងឡាយ ក្នុងវេលាអស់អាយុ ក៏ទៅកើតក្នុងទេវលោក សោយសម្បត្តិទិព្វអស់មួយពុទ្ធន្តរ ក្នុងកាលនៃព្រះពុទ្ធជាម្ចាស់នេះ ច្យុតចាកអត្តភាពនោះហើយមកចាប់បដិសន្ធិ ក្នុងផ្ទៃរបស់ធីតាអ្នកធំ ក្នុងត្រកូលឧបដ្ឋាក របស់ព្រះសារីបុត្តត្ថេរ ក្នុងនគរសាវត្ថី ។

លំដាប់នោះ មាតាបិតា របស់នាង ដឹងថា នាងមានគភ៌ហើយ បានឲ្យថ្នាំជាគ្រឿងរក្សាគភ៌ ។ លុះសម័យដទៃទៀត នាងកើតជម្ងឺចាញ់ផ្ទៃមានចំណង់យ៉ាងនេះថា ធ្វើម្តេចហ្ន៎ អញគប្បីបានថ្វាយទានដោយរសត្រីក្តិនក្រហម ដល់ភិក្ខុប្រាំរយរូបមានព្រះធម្មសេនាបតីជាដើម, គប្បីបានស្លៀកដណ្តប់សំពត់ដែលបុគ្គលប្រលាក់ដោយទឹកអម្ពុត អង្គុយក្នុងទីបំផុតនៃអាសនៈ ហើយបរិភោគភត្តជាសំណល់នៃភិក្ខុទាំងនោះ ។ នាងប្រាប់ចំណង់ដល់មាតាបិតា ហើយក៏បានធ្វើដូច្នោះ ។ ជម្ងឺចាញ់ផ្ទៃ គឺចំណង់នោះក៏បាត់ទៅ ។ ចំណេរតមក សូម្បីក្នុងមង្គលទាំង ៧ របស់នាង ខាងមុខពីកាលនោះ ក៏ញាតិទាំងឡាយនិមន្តភិក្ខុប្រាំរយរូបមានព្រះធម្មសេនាបតីជាប្រធាន ឲ្យឆាន់ដោយរសត្រីក្តិនក្រហមដូចគ្នា ។ គប្បីជ្រាបរឿងក៏រាំងក្នុងដោយន័យដូចពោលហើយ ក្នុងរឿងនៃតិស្សកុមារចុះ ។ ប៉ុន្តែនេះ ជាវេលានៃការឲ្យនូវរសនៃត្រីក្តិនក្រហម ដែលកុមារនេះឲ្យហើយ

ក្នុងកាលនៃខ្លួនកើតជាមនុស្សកម្សត់ទុគ៌ត ។ ក៏ក្នុងថ្ងៃតាំងឈ្មោះ, មាតារបស់កុមារនោះពោលថា បពិត្រលោកជាម្ចាស់ដ៏ចម្រើន ! លោកម្ចាស់សូមឲ្យសិក្ខាបទដល់ខ្ញុំប្រុសរបស់លោកម្ចាស់ ។ ព្រះថេរៈសួរថា ទារកនេះ ឈ្មោះអ្វី? ។ មាតាទូលថា បពិត្រលោកជាម្ចាស់! តាំងអំពីកាលដែលកុមារនេះមកចាប់បដិសន្ធិក្នុងផ្ទៃ មនុស្សគនិងមនុស្សឆ្កួត ក្នុងផ្ទះនេះត្រឡប់ទៅជាបណ្ឌិតទាំងអស់ ព្រោះដូច្នោះ បុត្ររបស់ខ្ញុំគួរឲ្យឈ្មោះថា បណ្ឌិតកុមារ ណាស់ ។ ព្រះថេរៈបានឲ្យសិក្ខាបទតាំងអំពីថ្ងៃដែលកុមារនោះកើតហើយ ។ មាតារបស់កុមារនោះគិតថា អញនឹងមិនជំទាស់អធ្យាស្រ័យនៃបុត្ររបស់អញទេ ។ ក្នុងវេលាមានអាយុ ៧ ខួប កុមារនោះបាននិយាយនឹង តាថា ខ្ញុំនឹងបួសក្នុងសម្នាក់របស់ព្រះថេរៈ ។ មាតាឆ្លើយថា ប្រពៃណាស់ហើយកូន! ម៉ែគិតទុករួចហើយថា នឹងមិនជំទាស់អធ្យាស្រ័យរបស់កូនទេ, ទើបនិមន្តព្រះថេរៈឲ្យឆាន់ រួចទូលថា ខ្ញុំប្រុសរបស់លោកម្ចាស់ជាក្មេងចង់បួស, ក្នុងវេលារសៀល ខ្ញុំនឹងនាំវាទៅវិហារ, សូមព្រះថេរៈនិមន្តទៅមុនចុះ, ហើយហៅពួកញាតិឲ្យមកប្រជុំគ្នា ប្រាប់ថា យើងទាំងឡាយ នឹងធ្វើសក្ការៈដែលគួរធ្វើ ក្នុងវេលាបុត្ររបស់ខ្ញុំនៅជាគ្រហស្ថ ក្នុងថ្ងៃនេះ, ប្រាប់រួចបបួលគ្នាធ្វើសក្ការៈធំ នាំយកកុមារនោះទៅវិហារ ប្រគល់ប្រគេនដល់ព្រះថេរៈ រួចទូលថា លោកម្ចាស់ សូមឲ្យកុមារនេះបួសចុះ ។ ព្រះថេរៈប្រាប់ថា បព្វជ្ជាជាការលំបាកធ្វើណាស់,

កាលកុមារឆ្លើយថា ខ្ញុំនឹងធ្វើតាមឱវាទរបស់លោកម្ចាស់, ព្រះថេរៈប្រាប់ថា បើដូច្នោះ អ្នកចូរមក!, រួចកោរសក់ ស្រេចហើយប្រាប់ តចៈ-បញ្ចកកម្មដ្ឋាន ( គឺអារម្មណ៍ជាទីតាំងនៃកម្មមានស្បែកជាគម្រប់ប្រាំជាអារម្មណ៍ ) ឲ្យហើយឲ្យបួស ។ ឯមាតាបិតារបស់សាមណេរនោះ នៅក្នុងវិហារ(១)អស់ ៧ ថ្ងៃ ថ្វាយភត្តដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយសេចក្ដីទុក្ខក្រហាមដូចគ្នា ទើបបានវិលមកផ្ទះវិញ ក្នុងវេលារសៀលថ្ងៃទី ៧ ។ ក្នុងថ្ងៃទី ៨ កាលព្រះថេរៈចូលទៅក្នុងស្រុក ក៏នាំយកសាមណេរទៅផង មិនបាននិមន្តទៅជាមួយនឹងភិក្ខុសង្ឃទេ ។

មានពាក្យ បុច្ឆា ជ្រៀតចូលមកថា ព្រោះហេតុអ្វី ? ។ វិស្សជ្ជនាថា ការទទួលបាត្រនិងចីវរ ប្ដូរឥរិយាបថរបស់សាមណេរនោះ នៅមិនទាន់ជាការនាំមកនូវសេចក្ដីជ្រះថ្លាទេ, មួយទៀត វត្តដែលព្រះថេរៈគប្បីធ្វើក៏មាននៅក្នុងវិហារ, ម្យ៉ាងទៀត កាលភិក្ខុសង្ឃចូលទៅក្នុងស្រុកហើយ ព្រះថេរៈនិមន្តត្រួតត្រាមើលទូទៅពេញវិហារ បោសទីកន្លែងដែលគេមិនបានបោស, តម្កល់ទឹកប្រើ ទឹកឆាន់ ទុកក្នុងភាជន៍ទទេ, ទុកដាក់គ្រែតាំងដែលគេទុកចោលរាត់រាយ ទើបចូលទៅស្រុកខាងក្រោយ, ម្យ៉ាងទៀត ព្រះថេរៈគិតថា ពួកញាតិយោមកាលចូលទៅឃើញវិហារទទេ កុំឲ្យនិយាយ

---

១ ក្នុងគ្រាពុទ្ធកាល ទីវត្តទាំងមូល គេហៅថា វិហារ ។ មិនមែនវត្តដោយឡែក, វិហារដោយឡែក ដូចសព្វថ្ងៃនេះទេ ។

បានថា លោកទាំងឡាយ ចូរមើលទឹកនៃដ៏ស្តាប់ធម៌ របស់ពួកសាវ័កនៃ ព្រះសមណគោតម ដូច្នេះ, ប្រតិបត្តិពេញរំហាររួច ទើបចូលទៅក្នុងស្រុក ជាខាងក្រោយ, ព្រោះហេតុនោះ ក្នុងថ្ងៃនោះ លោកឲ្យសាមណេរកាន់ បាត្រនិងចីវរចូលទៅស្រុកក្នុងវេលាថ្ងៃខ្ពស់បន្តិច ។ កាលសាមណេរដើរ ទៅជាមួយនឹងព្រះឧបជ្ឈាយ៍ ឃើញប្រឡាយទឹកក្នុងចន្លោះផ្លូវ ក៏សួរថា នេះ គេហៅអ្វី ? ព្រះករុណា! គេហៅប្រឡាយទឹក សាមណេរ! ។ គេធ្វើអ្វីដោយប្រឡាយទឹកនេះ? ។ គេបង្វែរនាំទឹកមកខាងឯណោះឯណេះ ដើម្បីធ្វើសស្សកម្ម (សន្ទូង) របស់ខ្លួន ។ ចុះទឹកនេះ មានចិត្តដែរឬ ទេ? ។ គ្មានទេ អាវុសោ! ។ គេនាំទឹកដែលពុំមានចិត្តដូច្នេះ ទៅ បានដែលខ្លួនប្រាថ្នាហើយៗ ឬ ? ។ យ៉ាងនោះហើយ អាវុសោ! ។ សាមណេរគិត ថាបើជនទាំងឡាយ គេនាំទឹកដែលពុំមានចិត្តដូច្នេះ ទៅ កាន់បានដែលខ្លួនប្រាថ្នាហើយៗ បានហេតុម្តេច ក៏ឯអ្នកដែលមានចិត្តនឹង មិនអាចញ៉ាំងចិត្ត ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ហើយធ្វើសមណ- ធម៌? ។ កាលសាមណេរ ដើរតទៅខាងមុខទៀតឃើញជាងធ្នូកំពុងកម្តៅ ឈើឲ្យក្តៅក្នុងភ្លើង ហើយសម្លឹងមើលដោយចុងភ្នែកពត់ឲ្យត្រង់ ដើម្បី ធ្វើកូនសរ ក៏សួរថា ព្រះករុណា! មនុស្សពួកនេះ គេហៅពួកអ្វី? ។ គេហៅជាងកូនសរ ។ ចុះគេធ្វើអ្វីដោយឈើនេះ ។ គេយកឈើនេះកម្តៅក្នុង ឲ្យក្តៅហើយពត់ឈើឲ្យត្រង់ ដើម្បីធ្វើកូនសរ ។ ឈើនោះមានចិត្តដែរឬ

ទេ ព្រះគុណ ? ។ គ្មានចិត្តទេ អាវុសោ! ។ សាមណេរគិតថា បើជនទាំងឡាយ កាន់យកឈើដែលឥតចិត្តពេលភ្លើងឲ្យក្តៅ ពត់ឲ្យត្រង់បាន ម្តេចក៏មនុស្សដែលមានចិត្ត នឹងមិនអាចញ៉ាំងចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងអំណាចហើយធ្វើសមណធម៌ ។ លុះសាមណេរដើរតទៅមុខទៀត ឃើញជាងចាំងកង់ផុំទិងក្ងៀររថជាដើម សួរថា ព្រះគុណ! មនុស្សពួកនេះគេហៅពួកអ្វី? ។ គេហៅពួកជាងចាំង អាវុសោ! ។ គេធ្វើអ្វី? ។ គេយកឈើទាំងនេះធ្វើកង់យានជាដើម ។ ចុះឈើទាំងនេះ មានចិត្តដែរឬទេ ព្រះគុណ? ។ ពុំមានចិត្តទេ ។ លំដាប់នោះ សាមណេរមានបរិវិតក្កថា បើជនទាំងឡាយគេយកដុំឈើដែលឥតចិត្ត ធ្វើកង់ជាដើមបាន ចុះហេតុអ្វី មនុស្សដែលមានចិត្ត ទើបមិនអាចញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ហើយធ្វើសមណធម៌ ។ សាមណេរ ឃើញហេតុទាំងនេះហើយ ពោលថា ទានប្រោស បើព្រះគុណកាន់យកបាត្រនិងចីវររបស់ព្រះគុណទៅ ខ្ញុំព្រះករុណាសូមលាត្រឡប់ទៅវិហារវិញ ។

ព្រះថេរៈមិនគិតថា សាមណេរក្មេងនេះ បួសហើយមិនយូរ កំពុងដើរតាមអញ ហ៊ានពោលយ៉ាងនេះទេ, ទើបប្រាប់ថា អ្នកចូរឲ្យមក! ហើយក៏ទទួលបាត្រនិងចីវររបស់លោកទៅ ។ ឯសាមណេរ សំពះលាឧបជ្ឈាយ៍ ហើយកាលនឹងវិលទៅវិញ ក៏ផ្តាំថា បើព្រះគុណនាំយកអាហារមកឲ្យខ្ញុំព្រះករុណា សូមនាំមកដោយរសត្រីឆ្អិនក្រហមតែប៉ុណ្ណោះ ។

យើងនឹងបានពីណា អាវុសោ ! ។ បើព្រះគុណមិនបានដោយបុណ្យរបស់ព្រះគុណទេ គង់តែនឹងបានដោយបុណ្យរបស់ខ្ញុំព្រះករុណាដែរ ។ ព្រះថេរៈ គិតក្រែងមានអន្តរាយដល់សាមណេរ ដែលអង្គុយនៅខាងក្រៅ ទើបឲ្យកូនសោ ហើយផ្តាំថា អ្នកឯង ចូរបើកទ្វារបន្ទប់លំនៅរបស់យើង ហើយចូលទៅអង្គុយខាងក្នុងចុះ ។ សាមណេរក៏ធ្វើតាមព្រះឧបជ្ឈាយ៍ផ្តាំ ហើយ ញុំាងញាណឲ្យស្ងប់ចុះក្នុងករជកាយរបស់ខ្លួន អង្គុយពិចារណាអត្តភាព ។

គ្រានោះ អាសនៈរបស់ព្រះឥន្ទ្រសម្តែងអាការគឺភាពជាអាសនៈក្តៅ ដោយតេជះនៃគុណរបស់សាមណេរ ។ ព្រះឥន្ទ្រពិចារណាមើលថា មានហេតុអ្វីហ្ន៎? ទ្រង់ព្រះតម្រិះថា បណ្ឌិតសាមណេរឲ្យបាត្រនិងចីវរដល់ព្រះឧបជ្ឈាយ៍ហើយត្រឡប់មកវិហារវិញ តាំងចិត្តថា នឹងធ្វើសមណធម៌ត្រូវអញទៅក្នុងទីនោះ ទើបគួរ គិតរួចត្រាស់ហៅមហារាជទាំង ៤ មកប្រាប់ថា អ្នកចូរដេញសត្វស្លាបដែលហើរត្រាច់នៅក្នុងព្រៃជិតវិហារ ហើយនៅចាំថែរក្សាឲ្យជុំវិញ, ត្រាស់ប្រាប់ចន្ទទេវបុត្រថា អ្នកចូរទាញទប់មណ្ឌលនៃព្រះចន្ទទុកសិន, ត្រាស់ប្រាប់សុរិយទេវបុត្រថា អ្នកចូរទាញទប់មណ្ឌលនៃព្រះអាទិត្យទុកសិន, ចំណែកព្រះអង្គ ស្តេចទៅឈរចាំរក្សាក្នុងទីនៃខ្សែសម្រាប់ទាញ (ត្រង់ទ្វារ) ។ ក្នុងវិហារ សូម្បីតែសំឡេងនៃស្លឹកឈើចាស់ក៏គ្មានដែរ ។ ចិត្តរបស់សាមណេរ បាននឹងធឹងហើយ ។ សាមណេរ

ពិចារណាអត្តភាព ក៏បានសម្រេចផលទាំងបី ក្នុងចន្លោះកត្តនោះឯង ។ ចំណែកព្រះថេរៈគិតថា សាមណេរអង្គុយក្នុងព្រះវិហារ អញអាចនឹងរកបានភោជនយកទៅឲ្យ ក្នុងត្រកូលឈ្មោះឯណោះ គិតហើយក៏និមន្តទៅឯត្រកូលឧបដ្ឋាក ដែលមានសេចក្តីស្រឡាញ់ និងសេចក្តីគោរព មួយកន្លែង ។ ក្នុងថ្ងៃនោះ មនុស្សទាំងឡាយក្នុងត្រកូលនោះ បានត្រីទ្ទីទក្រហមជាច្រើន អង្គុយចាំមើលដំណើរមករបស់ព្រះថេរៈផ្លូវ ៗ លុះឃើញព្រះថេរៈនិមន្តមកដល់ ក៏និមន្តឲ្យចូលទៅខាងក្នុងទូលថា ព្រះករុណាម្ចាស់និមន្តមកក្នុងទីនេះប្រពៃហើយ ទូលរួច ប្រគេនបបរនិងចង្អែមជាដើម បានប្រគេនបិណ្ឌបាតដោយសត្រីទ្ទីទក្រហម ។ ព្រះថេរសម្តែងអាការមិននាំយកទៅ ។ មនុស្សទាំងឡាយទូលថា និមន្តឆាន់ចុះ ទានប្រោស! ព្រះគុណម្ចាស់នឹងបានខូរកត្តដែលនឹងនាំយកទៅ, ក្នុងវេលាស្រេចកត្តកិច្ចយកភោជនលាយដោយសត្រីទ្ទីទក្រហម ដាក់ពេញបាត្ររបស់ព្រះថេរៈហើយប្រគេន ។ ព្រះថេរៈប្រញាប់និមន្តមក ដោយគិតថា សាមណេររបស់អញឃ្លានហើយ ។ ក្នុងថ្ងៃនោះ ចំណែកព្រះសាស្តាសោយតាំងពីព្រឹករួចស្រេច ស្តេចទៅវិហារ ទ្រង់ពិចារណាថា បណ្ឌិតសាមណេរឲ្យបាត្រនិងចីវរដល់ព្រះឧបជ្ឈាយ៍ ហើយត្រឡប់មកវិញ ប្រាថ្នានឹងធ្វើសមណធម៌ កិច្ចនៃបព្វជិតរបស់សាមណេរនឹងដល់នូវទីបំផុតឬទេ? ទ្រង់ជ្រាបថា សាមណេរបានសម្រេចផលទាំងបីហើយ ទ្រង់ពិចារណាថា ធម៌ជា

ឧបនិស្ស័យ នៃព្រះអរហត្ត មានឬគ្មានទេ ? ទ្រង់ឃើញថា មាន, ទ្រង់ពិចារណាតទៅទៀតថា សាមណេរ នឹងអាចសម្រេចព្រះអរហត្ត ក្នុងវេលាមុនភត្តតែម្តងឬទេ ? ទ្រង់ជ្រាបថា នឹងអាចបានសម្រេច ។ លំដាប់នោះ ព្រះអង្គទ្រង់ព្រះបរិវិតក្កថា បើសារីបុត្តយកភត្តប្រញាប់មក ដើម្បីឲ្យសាមណេរ មុខជានឹងធ្វើនូវអន្តរាយដល់សាមណេរនោះ តថាគត នឹងទៅអង្គុយចាំរក្សាត្រង់មាត់ទ្វារ លុះសារីបុត្ត ទៅដល់ហើយ តថា-គតនឹងសួរប្រស្នាបួនប្រការដល់លោក, កាលលោកឆ្លើយប្រស្នា, សាម-ណេរនឹងបានសម្រេចព្រះ អរហត្ត ព្រមទាំងបដិសម្ភិទាញាណ, ទ្រង់ជ្រាបដូច្នេះហើយ ស្តេចចេញអំពីព្រះគន្ធកុដិ ទៅទ្រង់ឈរនៅជិតមាត់ទ្វារ ត្រាស់សួរប្រស្នាបួនប្រការ នឹងព្រះថេរៈដែលមកដល់ហើយ ។ ព្រះថេរៈក៏ឆ្លើយប្រស្នាដែលព្រះសាស្តាត្រាស់សួរគ្រប់ប្រការ ។

ក្នុងប្រស្នានោះ មានពាក្យបុច្ឆានិងវិសជ្ជនាតទៅនេះ : "បានឮមកថា ព្រះសាស្តាត្រាស់សួរព្រះថេរៈថា សារីបុត្ត អ្នកបានអ្វីយកមក? ។ បានអាហារយកមក ព្រះអង្គ ! ។ ចុះអាហារនាំមកនូវអ្វី? ។ នាំមកនូវវេទនា ។ ចុះវេទនានាំមកនូវអ្វី? ។ នាំមកនូវរូប ។ ចុះរូបនាំមកនូវអ្វី? ។ នាំមកនូវផស្សៈ" ។

ក្នុងប្រស្នានោះ មានអធិប្បាយដូចតទៅនេះ ៖

មែនពិត អាហារដែលបុគ្គលឃ្លាន តែងបរិភោគហើយបន្ទោបង់សេចក្ដីឃ្លានរបស់បុគ្គលនោះ "នាំមកនូវសុខវេទនា", កាលសុខវេទនាកើតដល់បុគ្គលដែលដល់ហើយ នូវសុខដោយការបរិភោគអាហារ រមែងមានសេចក្ដីបរិបូណ៌នៃវណ្ណៈនាសរីរៈ "វេទនានាំរូបមក" យ៉ាងនេះ, កំបុគ្គលអ្នកដល់សុខហើយ រមែងមានសុខសោមនស្សកើតឡើងដោយអំណាចនៃរូបដែលកើតព្រោះអាហារ គិតថា ឥឡូវនេះសេចក្ដីជ្រះថ្លាចិត្តកើតដល់អញហើយ ដេកឬអង្គុយ រមែងបានសុខសម្ផស្ស ។ កាលព្រះថេរៈវិសជ្ជនាប្រស្នាបួនប្រការយ៉ាងនេះចប់ហើយ សាមណេរក៏បានសម្រេចព្រះអរហត្ត ព្រមទាំង បដិសម្ភិទាញាណ ។ ទើបព្រះសាស្ដា ទ្រង់ត្រាស់នឹងព្រះថេរៈថា សារីបុត្ត! អ្នកចូរទៅចុះ! អ្នកចូរឲ្យភត្តដល់សាមណេររបស់អ្នកចុះ ។ ព្រះថេរៈ ក៏ទៅគោះទ្វារហៅសាមណេរ ។ សាមណេរបើកទ្វារចេញមកទទួលបាត្រ អំពីព្រះហស្តព្រះថេរៈដាក់ទុកក្នុងចំណែកម្ខាង ហើយបក់ព្រះថេរៈដោយផ្លិតស្លឹកត្នោត ។ ព្រះថេរៈទើបពោលនឹងសាមណេរថា សាមណេរ! អ្នកចូរធ្វើភត្តកិច្ចចុះ ។ សាមណេរសួរថា ចុះព្រះគុណម្ចាស់? ។ ព្រះថេរៈប្រាប់ថា យើងធ្វើភត្តកិច្ចរួចហើយ អ្នកចូរធ្វើចុះ ។ ក្មេងអាយុ ៧ ខួបបួសហើយ, ក្នុងថ្ងៃទី ៨ បានសម្រេចព្រះ អរហត្ត ដូចជាផ្កាឈូកដែលរីកហើយក្នុងថ្ងៃនោះ អង្គុយពិចារណាពំនូតបាយក្នុងមាត់ បានធ្វើភត្តកិច្ចរួចស្រេចហើយ ។

ក្នុងវេលាសាមណេរលាងបាត្រទុកដាក់រួចស្រេចហើយនោះ ចន្ទទេវ-បុត្រ ថែង ចន្ទមណ្ឌល, សុរិយទេវបុត្រ ថែង សុរិយ-មណ្ឌល, មហារាជទាំងបួនថែងនៅរក្សាក្នុងទិសទាំងបួន, សក្កៈ-ទេវរាជ ថែងរក្សាត្រង់មាត់ទ្វារ ។ ព្រះអាទិត្យលឿនទៅហួសពាក់កណ្ដាល (ថ្ងៃត្រង់) ។ ភិក្ខុទាំងឡាយតិះដៀលថា ស្រមោលហួសប្រមាណហើយ ព្រះអាទិត្យលឿនទៅ ហួសពីពាក់កណ្ដាល (ថ្ងៃត្រង់) ហើយ, សាមណេរឆាន់បាយវេលានេះ តើហេតុនេះដូចម្ដេចទៅ ? ។ ព្រះសាស្ដាទ្រង់ជ្រាបហេតុនោះហើយ ស្ដេចមកដល់ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ! ពួកអ្នកនិយាយគ្នាពីរឿងអ្វី ។ កាលពួកភិក្ខុក្រាបទូលទ្រង់ជ្រាបហើយ ព្រះអង្គត្រាស់ថា យ៉ាងហ្នឹងហើយ ភិក្ខុទាំងឡាយ ! ក្នុងវេលាអ្នកមានបុណ្យធ្វើសមណធម៌ ចន្ទទេវបុត្រទាញទប់ ចន្ទមណ្ឌល ទុក, សុរិយទេវបុត្រ ទាញទប់សុរិយមណ្ឌល ទុក, មហារាជទាំងបួន នៅចាំរក្សាទិសទាំងបួនក្នុងព្រៃជិតវិហារ, សក្កទេវរាជ ស្ដេចមកនៅចាំរក្សាត្រង់ទ្វារ, សូម្បីតថាគត ក៏មិនបានអង្គុយស្ងៀម ដោយគិតថាតថាគតជាព្រះពុទ្ធដូច្នេះដែរ ឧស្សាហ៍ដើរទៅនៅចាំរក្សាបុត្រតថាគតត្រង់មាត់ទ្វារ, បណ្ឌិតទាំងឡាយឃើញមនុស្សបង្ហូរទឹក នាំយកទឹកក្នុងប្រឡាយទៅបាន ទិងឃើញជាងធ្នូសរពត់ធ្នូសរឲ្យត្រង់បាន ទិងឃើញជាងចាំងកំពុងចាំង

ឈើ ក៏កាន់យកមកធ្វើឲ្យជាអារម្មណ៍តែត្រឹមប៉ុណ្ណោះ ទើងអាចទូន្មានខ្លួន ហើយកាន់យកព្រះអរហត្តបាន, ព្រះអង្គទ្រង់ត្រាស់ដូច្នេះហើយ កាល ទ្រង់តអនុសន្ធិ ទើបសម្តែងធម៌ដោយបទគាថានេះថា ៖

ឧទកំ ហិ នយន្តិ នេត្តិកា
ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា
អត្តានំ ទមយន្តិ បណ្ឌិតា ។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ, អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មាន ខ្លួន (ដូច្នោះដែរ) ។

ក្នុងវេលាចប់ធម្មទេសនា ជនជាច្រើននាក់បានសម្រេចសោតាបត្តិ-ផលជាដើម ។

សេចក្តីសង្ខេបក្នុងរឿង បណ្ឌិតសាមណេរ នេះ ៖

មានបុរសកម្សត់ទុគ៌តម្នាក់ ធ្វើការស៊ីឈ្នួលគេចិញ្ចឹមជីវិត កើត ចិត្តសទ្ធាជ្រះថ្លាបានថ្វាយតាខចំពោះព្រះមហាសាវក្ក, ផលបុណ្យនោះ បណ្តាលឲ្យព្រះឥន្ទ្របាចរគន: ៧ ប្រការឲ្យយ៉ាងច្រើន រហូតដល់បាន

តំណែងសេដ្ឋីទៀត, លុះច្យុតពីអត្តភាពនោះហើយ បានមកកើតក្នុងត្រ-កូលជាឧបដ្ឋាកនៃព្រះសារីបុត្តត្ថេរបាននាមថា "បណ្ឌិត", ផលបុណ្យតាមជាប់ប្រកំតឲ្យបានសម្រេចព្រះ អរហត្ត ក្នុងអាយុ ៧ ខួប ។

រឿងបណ្ឌិតសាមណេរ ចប់ ។

## ប៊ូ - ប៉ូ

អ្នកមានចំណេះវិជ្ជាផ្សេង ៗ
កុំប្រឡងនឹងអ្នកមានបុណ្យ

អ្នកមានប្រាជ្ញា តែខ្វះវាសនា បុណ្យព្រេង [illegible]
នោះដូចឈើខ្ទឹម ដុះលើមកនឹងព្រៃ [illegible]
ឲ្យ[illegible]ខ្ពង់ខ្ពស់

ផល-ធិត

# វិចារណកថា

## ការផ្លាស់ប្តូរប្រពៃណី ក្នុងរឿងរកគូស្រករ

ប្រពៃណីក្តី ទំនៀមក្តី ទម្លាប់ក្តី ពាក្យនេះមានន័យប្រហែលៗគ្នា បើធ្ងន់ស្រាល ក៏តែបន្តិចបន្តួចប៉ុណ្ណោះ ។ រួមសេចក្តីទៅ គឺមានន័យជានិយម ប្រកាន់ទិនភ្ជាប់ប្រព្រឹត្ត ដ៏យូរអង្វែងមក ។ ការយកបាយទុកជាអាហារទីមួយ សម្រាប់ចិញ្ចឹមជីវិត គឺជាប្រពៃណីម៉្យាង ការយកនំបុ័ង ទុកជាអាហារទីមួយសម្រាប់ចិញ្ចឹមជីវិត គឺជាប្រពៃណីម៉្យាងទៀត ។ល។

ក្នុងសាកលលោក តាមការសង្កេត ឃើញថាមានប្រពៃណីប្លែកៗគ្នាច្រើនអនេក ខ្លះទទួលទានបាយនឹងដៃ ខ្លះនឹងចង្កឹះ ខ្លះនឹងស្លាបព្រា ខ្លះស្លៀកខោ ខ្លះសំពត់ ខ្លះរុំ ខ្លះសារុង ។ល។

តើប្រពៃណីនេះ មានទទួលការប្រែប្រួលដែរឬទេ ?

ព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់សម្តែងថា: អ្វីៗក្នុងលោក សុទ្ធតែមិនទៀងតាំងអស់ ។ ដូច្នេះ សំនួរខាងលើនេះ ត្រូវទុកជាមោឃៈ ប្រសិនបើត្រូវគោរពតាមព្រះឱវាទរបស់ព្រះអង្គ ។

បណ្តាប្រពៃណីខ្មែរតាំងឡាយខ្លះរបស់យើង ដែលមានការប្រែប្រួលនោះ មានប្រពៃណីមួយគួរឲ្យចាប់អារម្មណ៍ជាងគេ គឺរឿងរកគូ

ស្រុកនេះឯង ។ ហេតុដូចម្ដេចក៏ដូច្នេះ ? ក៏មកពីមានការប្រែប្រួលព្រាសស្រុក ។

តាមប្រពៃណីដើមរបស់ខ្មែរយើង ការរកគូស្រករឲ្យបុត្រធីតា គឺតម្រូវឲ្យខាងប្រុសទៅស្ដីដណ្ដឹងខាងស្រី ហើយសេចក្ដីបង្គាប់ទាំងប៉ុន្មានគឺខាងស្រីលើកទម្លាក់មកលើខាងប្រុស ទោះបីច្រើនតិចឬធ្ងន់ស្រាលដូចម្ដេច អនុលោមទៅតាមការសន្ដោស ឬមិនសន្ដោសគ្នាទៅវិញទៅមក ឬអនុលោមទៅតាមធនធានតិចច្រើនរបស់ខាងប្រុសដែលទ្រាំទ្របាន ឬមិនបានប៉ុណ្ណោះ ។ ប្រពៃណីបែបនេះ គឺត្រូវជនជាតិខ្មែរគោរពដំហូរហែមក ជាច្រើនសតវត្សណាស់មកហើយ ។

រឿងប្រែប្រួលប្រពៃណីនៃប្រទេសនីមួយ ៗ ទោះបីតិចក្ដីឬច្រើនក្ដី គឺអាស្រ័យដោយកត្តាដ៏ច្រើន ។ ឯកត្តាដ៏ធំចម្បងជាងគេ គឺសម្ភារៈនិយមនេះឯង ។ មែនពិត សម្ភារៈនិយមរមែងតែដើរមុខគេ ១ ទាំងអស់អ៊ីចឹងមែនហើយ ដ្បិតថាការបង្កបង្កើតអ្វីមួយ ត្រូវតែពឹងផ្អែកទៅលើសម្ភារនិយមនេះឯងជាបឋមខានពុំបានឡើយ ។ ក៏ប៉ុន្តែបើយើងប្រកាន់នាំជ្រុលពេកតែទៅលើមុខនេះ គ្មានងាកមើលទៅខាងសីលធម៌ផងនោះ និងជាហេតុនាំឲ្យបានសេចក្ដីសុខដុមរមនារវាងមនុស្សទាំងឡាយក្នុងសង្គមមិនខាន ។ ព្រោះតែការប្រកាន់សម្ភារនិយមខ្លាំងពេកនេះហើយ ទើបគេបង្កើតទ្រឹស្ដីព្រៃម្យ៉ាងថា: «មនុស្ស បងប្អូនគ្នាតែ

ខ្លួនទេ ចំណែកប្រាក់មិនមែនបង្អួនទេ" ។ ដោយអាស្រ័យការប្រកាន់ទ្រឹស្តីនេះហើយ បានជាសម័យបច្ចុប្បន្ននេះ មានមនុស្សភាគច្រើនហ៊ានធ្វើឲ្យប្រពៃណីខ្មែរខាងរកគូស្រករ មានសភាពប្រែប្រួលប្រាសស្រកីដូច្នេះ ។

រឿងប្រែប្រួលប្រាសប្រកីនេះ កាលក្នុងជំនាន់អាណាព្យាបាល ក៏មានខ្លះដែរតែកាតតិចណាស់ តិចតាល់តែមិនសូវមានអ្នកណាចាប់ក្តឹកដល់ ។ ក្នុងសម័យនោះរឿងនេះកើតមានចំពោះតែគ្រួសារវរជនខ្លះប៉ុណ្ណោះ ជាវរជនដែលមានឥទ្ធិពលជាងគេក្នុងផ្លូវកិច្ចការរាជការ ។

ក៏ឯសម័យសង្គមនេះ ការផ្លាស់ប្តូរប្រពៃណីក្នុងរឿងរកគូស្រករគឺលេចឃើញជាក់ច្បាស់ដូចថ្ងៃ ក្នុងចំណោមជនជាតិខ្មែរភាគច្រើនដាច់ខាត ។

មានការណ៍មួយគួរឲ្យកៀនខ្មាសនិងគួរឲ្យអស់សំណើចផង គឺនៅត្រង់មានអ្នកស៊ីក្បាលហាច ។ ប្រពៃណីដ៏ចាស់ក្រិនមកហើយ មិនមែនជាគ្មានឥទ្ធិពលសោះទេ សូម្បីក្នុងសម័យនេះក្តី គឺរមែងធ្វើឲ្យអ្នកប្រកាន់និងបន្តប្រពៃណីមានការគិតអៀម និងខ្មាសអៀនមិនហ៊ានបញ្ចេញមុខត្រង់ ៗ ខ្លះដែរ ។ ហេតុដូច្នេះហើយ ទើបមានកត្តាចំឡែកមួយបានលេចមុខចេញមកជាប៉ាំង គឺអ្នកស៊ីក្បាលហាបនេះឯង ។ គឺជាគ្រឿងសម្ភារៈសព្វយ៉ាងនោះពីខាងស្រីទាំងអស់ : "របស់ព្រះ បូជាព្រះ" ។

សព្វថ្ងៃអ្នកស៊ីក្បាលហាប ជាស្រីក៏មាន ជាប្រុសក៏មាន តែបើតាមការសង្កេត គឺស្រីភាគច្រើន ។ រឿងនេះមិនខុសពីអ្នកដើរសារខាងទិញរថយន្ត ឬលក់រថយន្ត ខាងលក់ស្រូវ លក់ជ្រូក ។ល។ ឡើយ ។ អ្នកស៊ីក្បាលហាបនេះ ជួនកាលបបួលបង្គាប់ពីខាងស្រីថា បើរកបានប្រុសមានប្រាក់ខែធុនប៉ុណ្ណេះ ត្រូវបានក្បាលហាបប៉ុណ្ណេះ បើរកបានប្រុសមានប្រាក់បៀវត្សធុនប៉ុណ្ណេះ ត្រូវបានក្បាលហាបលើសឬថយចុះៗ ឯរឿងក្បាលហាបតិចឬច្រើន អនុលោមទៅតាមទំហំបៀវត្សនៃសាមីខ្លួនខាងប្រុស ។ ជួនកាលអ្នកស៊ីក្បាលហាបរកបានសាមីខ្លួនខាងប្រុស ៣-៤ នាក់ ដាក់វេចខ្ចប់យកទៅជាមួយ រួចដើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយ ពីស្រុកមួយទៅស្រុក ពីខេត្តមួយទៅខេត្តមួយ ដើម្បីស្វែងរកផ្ទះណាដែលមានកូនស្រីនៅលីវ ។ កាលបើបានជួបប្រទះហើយ អ្នកស៊ីក្បាលហាបក៏ស្រាយបង្ហើបយកឈ្មោះមកបង្ហាញព្រមទាំងបរិយាយអំពីឋានៈ និងមុខងារក្នុងកិច្ចការនៃសាមីខ្លួនខាងប្រុស ប្រាប់គ្រួសារខាងស្រី ដោយវិធីបញ្ចុះបញ្ចូលផ្សេងៗផង ដើម្បីសណ្ដំទឹកចិត្ត ។ រីឯក្បាលហាបនោះ គឺអនុលោមទៅតាមឋានៈខ្ពស់ទាបក្នុងកិច្ចការរាជការ មានមួយពាន់-ពីរពាន់-បីពាន់ ។ល។ មិនតែក្បាលហាបប៉ុណ្ណោះទេ គឺនៅថ្ងៃទឹកតែដែលខាងប្រុសត្រូវផ្ដល់ទៅឱ្យខាងប្រុសព្រមទាំងតម្លៃរៀបអាពាហ៍ពិពាហ៍ផងទៀត ។ លុះត្រូវរ៉ូវគ្នាហើយ ទើបគេការកូនខាងស្រីយកទៅឲ្យខាងប្រុស

សម្រាប់ពិនិត្យមើល ឬមួយក៏ខាងស្រីកំណត់ពេលវេលា ឲ្យខាងប្រុសយកជូនខ្លួនវិញ ដើម្បីពិនិត្យរូបសម្បត្តិខាងស្រី ហើយទើបសម្រេចការណ៍ជាស្ថាពរ ប្រសិនបើមានការព្រមព្រៀងគ្នាពីគូភាគីទាំងពីរ ។

ចំពោះរឿងនេះមិនសម្រេចតែត្រឹមតម្លៃទឹកដៃប៉ុណ្ណោះទេ គឺជួនកាលខាងប្រុសមិនស្រុបតាមផងក៏មានដែរ ព្រោះមានខ្លះត្រូវការតម្លៃទឹកដៃផង ត្រូវការរូបសម្បត្តិផង ហើយដែលមិនព្រមនោះ គឺមកពីខុសខាងរូបសម្បត្តិ ។ តែបើតាមការសង្កេត ឃើញថាភាគច្រើនពេញចិត្តនឹងតម្លៃទឹកដៃណាស់ ត្រង់រូបសម្បត្តិល្មមៗក៏បានហើយ ។

សេចក្តីដូចពោលខាងលើ អាចបណ្តាលឲ្យផលមិនប្រពៃពីភេទស្រីក្នុងយុវភាពប្រពៃណីបានចាត់ទុកជាវត្ថុបរិសុទ្ធ និងមានតម្លៃថ្លៃថ្នូរជាទីគោរពផង បុរសណាប្រាថ្នាចង់បានជាគូប្រចាំជីវិត ត្រូវតែចាត់ឲ្យអ្នកផ្ទួរចៅមហា ទៅនិយាយដែចូរស្តីដណ្តឹងតាមសម្រួល បើព្រមព្រៀងគ្នាហើយ ការកិច្ចខាងរៀបចំគ្រឿងបណ្ណាការព្រមទាំងពិធីជប់លៀងភ្ញៀវ ស្រេចនៅលើខាងប្រុស ។ នេះមិនដូច្នោះ បុប្ផាបែរជាទៅស្វែករកគូន សុំឲ្យមេក្តាមកក្រេបលំអងកេសរដ៏បរិសុទ្ធរបស់ខ្លួនទៅវិញ ។ ភេទប្រុស តាមហូរហែមក គេទុកជាភេទប្រកបដោយថាមភាព ភេទអង់អាចលើកិត្តិយសស្រីព្រហ្មចារី ក៏ទៅជាដូចម្តេច តើនៅត្រង់ណា? កិច្ចការផ្សេងៗជាខាងក្រៅគេហដ្ឋាន មានកិច្ចប្រកបមុខរបរសម្រាប់

ចិញ្ចឹមជីវិត  កិច្ចត្រួតត្រាការរកជការនានា  កិច្ចធ្វើសង្គ្រាមដើម្បីការពារបូរណភាពទឹកដីជាដើម ត្រូវជាភារៈរបស់ខ្លួនហើយ ទោះបីលទ្ធិប្រជាធិបតេយ្យបានអនុញ្ញាតឲ្យស្ត្រីនិងបុរសមានសិទ្ធិស្មើគ្នា នៅចំពោះមុខច្បាប់ក្តី ៗ ឥឡូវភេទនេះ នៅជាបណ្តាយឲ្យគេទិញដូចជ្រូកឬឲ្យគេទិញដូចឪឡឹក ត្រឡាច តាមអំពើចិត្តបាន ។ តើកិត្តិយសភេទប្រុសនៅត្រង់ណា ?

លទ្ធផលមិនគាប់ប្រសើរទាំងពីរបែប ដូចពោលមកនេះ តើបណ្តាលមកអំពីអ្វី ? តើមានអ្វីជាមូលហេតុ ? ឆ្លើយថាមូលហេតុនោះ គ្មានអ្វីក្រៅពី ការប្រកាន់សម្ភារនិយមហួសប្រមាណពេកតែប៉ុណ្ណោះឯង ៗ ដូចយើងឃើញស្រាប់ ក្នុងពិភពលោកតាំងពីសតវត្សទី ១៩ រហូតមកដល់សតវត្សទី ២០ នេះ ខាងក្រោយឥទ្ធិពលនៃអាស៊ីទូចបានចុះអន់ថយមក ទ្វីបខាងបស្ចិមទិស ជាអ្នកប្រកាន់សម្ភារនិយម ៗ ពេលចុងក្រោយនេះ សហរដ្ឋអាមេរិកក៏បានឡើងឋានៈជាមេក្លោង ខាងលទ្ធិនេះ ៗ តើលោកបានស្គាល់សុខសន្តិភាពដែរទេ ? ការខ្វះសុខសន្តិភាពនេះមានបុព្វហេតុតែពីការប្រកាន់សម្ភារនិយមហួសប្រមាណនេះឯង ៗ

ឥឡូវជំងឺនេះបានចូលមកក្នុងប្រទេសយើងហើយ ៗ តែដោយយើងខ្វះឥទ្ធិពលខាងវិទ្យាសាស្ត្រនិងខាងសឹក ការប្រកាន់សម្ភារនិយមនេះ ក៏ស្ទុះទៅជ្រៀតជ្រែកចូលត្រង់កន្លែងស្លូតបូត គឺការផ្លាស់ប្តូរប្រពៃ-

ណីក្នុងរឿងរកគូស្រករនេះឯងទៅវិញ ។

ទោះជាយ៉ាងនេះក្តី ក៏គង់មានខាងស្រីខ្លះ ត្រូវក្ខាត់ដៃជើងហើយ ផ្តួលតាក់ទឹងហឹងហោង ព្រោះតែយុវបុរសខ្វះដៃរ ។ ខាងស្រីបានទិញ យុវបុរសចិញ្ចឹមប្រោះទុក (មិនទាន់ចប់កិច្ចសិក្សា ហើយខ្លាចក្រែងទិញ យកមិនទាន់គេ) ដោយចំណាយចិញ្ចឹមមុន ព្រមទាំងទិញមធ្យោបាយ ដឹកនាំឲ្យប្រើផង មានម៉ូតូជាដើម ។ លុះដល់ទីបំផុត យុវបុរសយើង កែប្រែគំនិតជាថ្មី ដោយជាប់ស្នេហាទៅលើនារីដទៃ ដែលមានសោភណភាពគ្រាន់បើជាង ។ មធ្យោបាយក្រឡិចក្រឡុចនេះ បានធ្វើឲ្យខាងស្រីយើងប្រទ្យោតតោតតួង ព្រមទាំងយំមិនចេញទឹកភ្នែកផង ព្រោះគ្មានកិច្ចសន្យាអ្វីដ៏ត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែផែកបែបនេះជាភាគតិចទេ ។

នេះហើយ គេហៅថា: ការផ្លាស់ប្តូរប្រពៃណីប្រាសស្រុក ។

ផេង-ជ្រឹម (២៨ ៨ ៦៩)

# ចម្រៀង បញ្ចសិខគន្ធព្វទេវបុត្រ

## ដកស្រង់អំពីសក្កបញ្ហសូត្រ សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ ភាគ ១៧ មករៀបរៀងជាពាក្យកាព្យ

### ព្រហ្មកីតិ

កាលដែលព្រះជិនស្រី ទើបត្រាស់ថ្មីហើយចមកត សម្រន់-សម្រាកឈប់ គង់ក្រោមម្លប់អជបាល ៗ និះគ្រាធដ៏ត្រឈៃ នៅក្នុងព្រៃគួរត្រអាល ទីនោះចាត់តាមកាល ហៅសប្តាហៈទីប្រាំ ៗ ទ្រង់សោយសេវិមុត្តិ វិសេសផុតពាកកង់កម្ម កិលេសដ៏សាំញ៉ាំ ដែលដេកត្រាំក្នុងហឫទ័យ ៗ គឺសព្រោះនិព្វាន ដ៏ជាបានឥតទុក្ខភ័យ ហៅសុខសែនប្រពៃ ទៀបគល់ជ្រៃនោះឯងណា ៗ

គ្រានោះទេវបុត្រ បរិសុទ្ធមាននាមថា "បញ្ចសិខគន្ធព្វ" ឋិតនៅនាតាវត្តិង្ស ៗ ជាអ្នកស្ទាត់ក្នុងល្បែង ត្បុកកំប្លែងដីរីងប៉ុង ពួកទេពទទួលដឹង ស្គាល់ថាជាអ្នកចំណាន ៗ ចំណាប់ក្នុងសួគា គ្មានអ្នកណាប្រៀបធៀបបាន ខាងការលេងកំសាន្ត លំហែប្រាណសព្វ ៗ កាល ៗ គន្ធព្វទេពនោះឯង ចិត្តចំបែងកាមបណ្តាល គឺចង់លេងក្រសាល ត្រេកត្រអាលនឹងធីតា ៗ នៃតិម្ពុរាជ មានអំណាច

ដ៏ក្លៀវក្លា ឈ្មោះនាងសុរិយា(១) វច្ឆសាប្រសើរសោយ ៗ តែនាងមិនរវល់ មិនព្រមយល់ប្រគល់កាយ ធ្វើឫកហាក់នឿយណាយ ព្រោះធោមធាយនាងជាប់ចិត្ត ៗ ស្រឡាញ់ប្រុសដទៃ ឆើតប្រពៃគួរស្នេហ៍ស្និទ្ធ មាននាមជាកំរិត „សិខណ្ឌិទេវបុត្រ” ៗ ជាកូនមាតលីសារថីបរិសុទ្ធ នៅឋានប្រសើរផុត គឺត្រៃត្រឹង្សសឹងប្រពៃ ៗ ទុកជាបញ្ចសិខៈ គន្ធព្វៈរិះគិតវៃ រកកលផ្សេងដទៃ ដ៏ប្រពៃមកលៃបន់ៗ នាងនៅតែមិនដោយ មិនព្រមឲ្យប៉ះដល់អង្គ មិនងាកភ័ក្ត្រតម្រង់ចំពោះត្រង់តិចតួចសោះ ៗ ទើបអ្នកទេពគន្ធព្វ កាន់ពិណគាប់ដោយចិត្តស្មោះ គគាតចូលចំពោះ កាន់សំណាក់នៃបរម ៗ តិម្ពុរុកៈបិតា លើកហត្ថាឡើងប្រណម្យ រំតៃខ្សែពិណឲ្យសម ទំនងសម្លេងរបស់ខ្លួនៗ ហើយតាំងផ្ដើមចម្រៀង ដេញពិណច្រៀងឡើងក្រអួន សម្រួបប្រគបជូន បែបន់ទូនកន្ថា ៗ ទាក់ទងដោយព្រះពុទ្ធ ព្រះធម៌សុទ្ធព្រះសង្ឃថ្លា ចម្រុះលាយកាមា ដោយគាថាដូច្នេះ ៖

ពាក្យ ៥

ឱសូរ្យាវច្ឆសាធីតារម្យ !

រៀមសូមឱនលំទោនកាយថ្វាយបង្គំ

ដល់ឧត្តមបិតាដ៏នៃកញ្ញា ៗ

---

១- ក្នុងបាលី ៖ "សុរិយវច្ឆសា" ។

ទោមខឹមទ្ទួនស្ងួនមាសផ្អឹនផ្ដុំភ្ញិនសាយ
នាងមានកាយផ្សាយពន្លឺភ្លឺផ្លេកថ្លា
ក័ក្រិតផ្ទុំផង់វង់មូលក្នុំសមនាសោ
ចាំងមុខាហាញញឹមស្រស់ប្រិមប្រិយ៍ ។
សក់ខ្មៅយន់ទ្រទន់ជ្រៀងជ្រវិលវេវវ្ញ
អង្កាញ់ជ្រួញអង្គួញខ្ទង់ខ្ទង់ពិសី
បើកលក្ខណបានមកបងគ្រកងបី
រម្មះបេតីសិរីបិតចិត្តឥតអាក់ ។
ដូចដើរផ្លូវគ្រោះកំដៅសុបសៅខ្លួន
ស្រែកទឹកជួនជួនប្រទះស្រះគ្រជាក់
ត្រេកអរក្ដាត់បាត់បារម្ភក្រំថ្លាំងថ្លាក់
អាស្រ័យដាក់សំណាក់ស្រួលឥតអួលអន់ ។
ឬដូចជាញាយធម៌លែងញ័រញាប់(១)
ជាទីគាប់ជាប់ហឫទ័យនៃអរហន្ត
បើបងបានបានរួមរក់ស្នេហ៍គ្រទឹងតន់
ទឹងបានស្រទន់សម្រេកស្រែកក្តុងប្រាណ ។
បងគ្របាល់ទល់គ្រហាយកាយចំប្រប់

១- ព្រះនិព្វាន ។

ស្មើរសន្ធប់ចប់ឧកណ្ឋកល្យាណ
សូមនាងស្ដួយជួយជីវិតគិតឲ្យបាន
ដូរក្នុងប្រាណក្សាន្តទុក្ខតឹងរឹងអនេក ។
រៀមសូមអែបនែបនៅនិត្យជិតថនា[1]
នៃកញ្ញាថ្ង វរលក្ខណ៍ក៏ក្រៃល្អឯក
សូមក្រមុំកុំខេរខឹងប្រឹងប្រកែក
សូមរំលែកចែកដាក់ទានមានផលា ។
បងងោងងប់ទប់មិនបានប្រាណក្តួលក្តៅ
ព្រោះតែក្ដៅពៅនាងល្អសក្តិថ្វា
ដូចដំរីក្ដីចុះប្រេងវែងខ្ទោចផ្សា
ដោយតណ្ហាក្លាក្នុងចិត្តឥតគិតស្លាប់ ។
ចិត្តរៀមងប់ស៊ប់លើស្ងួននួនស្នេហ៍ស្និទ្ធ
រឹងប្រឹតរឹតប្រកាន់ម៉ាន់ចំណាប់
ដកមិនរួចគួចយ៉ាងស្អិតចិត្តក្រឡាប់
ហាក់ដូចផ្កាប់ស្លាប់រហ៊ីណាស្រីពៅ ។
ដូចជាត្រីធីសន្លួចខ្វួចទាំងប្រាណ
ដោះមិនបានប្រាទមិនភ្ជាត់ជាប់មាត់ជ្រៅ

---
១- ដោះ ។

ដួងចិត្តបងប៉ងប្អូនប្អូនទូនឆោមឆៅ
ប្រាណមិនទៅនៅមិនស្ងៀមរៀមទុក្ខា ៗ
នៃឆោមឆាយកាយសស្ងួលបណ្ឌូលលេបេក
ពូរក្រឡេកត្រេកត្រេកគន្ទុបបង៉ា
ការរួបរឹតពិតជាបងប៉ងប្រាថ្នា
សូមដីវ៉ាកុំថាម្ដេចហើយគេចចេញ ៗ
កាមនៃបងចងចិន្ដាឥតក្លាក្លំ
តែស្ដន់ក្បៀសមស្រទន់ទ្រលន់ពេញ
បែរជាច្រើនកើនចំណែកបែកចំណេញ
នាំជន្ទួញពេញជន្ទឿរចិត្ត ៗ
ដូចជាទានមានតិចភ្ជួចស្ដួចស្ដើងទេ
ប៉ុន្ដែគេរេគំនិតគិតសុចរិត
ឲ្យដល់លោកគោកកិលេសវិសេសសិទ្ធិ៍
ផលនោះពិតរឹតចំណេញពេញទូលាយ ៗ
ឧទ្ទឹមខ្លួនទួនពិសីស្រីបំឡែក
រូបល្អឯកប្លែកសង្ហាថ្នាឆើតឆាយ
បុណ្យក្រាស់ក្រៃលែងលប់ផ្ញើរលើបានកាយ
គឺបែកពាយថ្វាយដល់ព្រះឈ្នះតណ្ហា ៗ

បុណ្យនោះនៃតែជំនួយជួយឲ្យបាន
ចួបកល្យាណប្រាណជំនិតជិតកាយា
កុំឲ្យល្អៀងឃ្លៀងចំណង់បង់អាសា
បំណាច់ហាថាស្រឡាញ់បាញ់តម្រង់ ។
ព្រះវជិតបុទ្ធិ៍វិសុទ្ធផុតថ្លឹងថ្លែង
ប្រុងប្រឹងប្រែងស្វែងទិញានបាំនផ្ទះផង់
មិនគិតម៉ាយណាយល់បាកយ៉ាកដល់អង្គ
ព្រះទ័យត្រង់ផ្គង់ចំពោះនោះយ៉ាងណា ។
រំខួនបងប៉ងចណ្ឌាលហើយចូលមក
ប្រឹងស្វែងរកពន្ធកសួនទួនបុប្ផា
សូមឲ្យបានប្រាណនៃបទិត្យជិតធីតា
ត្រេកតណ្ហាសេយ្យា(១)ខាងយ៉ាងនោះឯង ។
បើព្រមព្រមមូលមិត្រស្និទ្ធស្នេហ៍ស្នង
សមបំណងបងប្រាថ្នាណាំចំពេញ
រៀមអរពេក ត្រេកត្រអាលអស់កាលវែង
ផុតចំបែងវែងជាសុខស្រណុកក្រៃ ។
ដូចព្រះពុទ្ធផុតកិលេសវិសេសសាល

---

១- ដំណេក ។

ទ្រង់ត្រអាលក្រសាលធ្យានទឹងញាណញៀយ
ឥតមានទុក្ខក្រប្រជ្រៀតបៀតព្រះទ័យ
លែងមានភ័យជ័យជំនះឈ្នះឥតសល់ ។
ប្រសិនណាជាកោសិយសិរីវុឌ្ឍ[1]
ឲ្យពរពិតគិតសម្រាំងតាំងតម្កល់
បើកឲ្យបងប៉ងទឹមខ្លួនស្ងួនទិម្ងល
បងលែងទល់អំពល់ចិត្តគិតទុក្ខា ។
ហៃកល្យាណមានរូបឆោមលៈមព័ណ៌ឆើត
ពង់ពៅស្ងួតកើតជាស្រីស្ញើថ្វា
រៀមសូមឱនលំទោនកាយថ្វាយវន្ទា
ដល់បិតាប៉ាអនុជត្រលុចលេន ។
ដែលឧបមាដូចរុក្ខាមានផ្កាស
ក្រអូបល្អងំគាប់ចិត្តឥតគិតគន់
ពួកអ្នកផងប៉ងតម្រេកត្រេកពេកពន់
ណាល្ងតល្ងន់សម្ពួស្យទន់ទ្រលន់អើយ ? ។

កុដ្ឋលីលា

កាលបើនន្ទាឆើតឆាយ ប្រៀនដោយលែបខាយ យ៉ាងនេះចប់

---
១-ព្រះឥន្ទ ។

ហើយ ៗ សូរ្យាធីតាត្រាណាត្រើយ នាងពុំកន្តើយ ព្រងើយដូចមុន ៗ
បែរជាស្រឡាញ់សិប់ស៊ុន ចំពោះរូបយុន តុកទេពគន្ធព្វ ៗ ដួងចិត្ត
នៃនាងញ័រញាប់ ស្រពោនស្រពាប់ ដោយកាមរាគា ៗ រើបនាង
ញញឹមក័ក្រ្តា ញឹកញ៉ាក់ឆ្លើយថា ហៃបងដំនិត ៗ អ្នកបងចេះច្រៀង
ពេកពិត លួងលោមដួងចិត្ត នៃប្អូនពិសី ៗ ចេះក្រងកែវចងសម្តី
ចម្រៀងបែបថ្មី ប្រកបតម្រូវ ៗ ព្រះពុទ្ធព្រះធម៌ជាថ្នូរ ព្រះសង្ឃត្រឹម
ត្រូវ តម្រូវលាយកាម ៗ ទាល់តែប្អូនស្រីដោយតាម ធ្លាក់ចិត្តចុះស្នាម
កិលេសតណ្ហា ៗ នុះនុអ្នកបងថ្លៃថ្លា ព្រះពុទ្ធនោះណា មិនដែលចួប
ក័ក្រ្ត ៗ កាលខ្ញុំទៅលេងរួមរ័ក កំពូងសំណាក់ ពេងសុធម្មា ៗ ពួ
គេសរសើរពល់គ្នា ថាព្រះភគវ៉ ប្រសើរបំផុត ៗ ជាប្រាជ្ញអង់អាច
ចំហុត ព្រះកាយបរិសុទ្ធ បញ្ចេញរស្មី ៗ ហៃបងប៉ិនក្រងសម្តី
ដូចេះប្អូនស្រី ឥតបីប្រកែក ៗ ប្អូនមិនធ្លាប់គិតគរកែក ចូរប្រុសល្អឯក
ចួបគ្នាថ្ងៃនេះ ៗ គន្ធព្វមានភ័ព្វថាអេះ អើហ្នឹងហៅចេះ ស្តាប់សូរចម្រៀងៗ
បំណាងដែលបងប៉ងទៀង គិតឥតឃ្លាតឃ្លៀង ត្រង់ហ្នឹងហើយពៅ ៗ
ថាហើយញញឹមចូលទៅ អែបនែបទិត្យទៅ ក្បែរពៅសូរ្យា ៗ
ទុនទបក្រែ ប បពីតា ព្រឺព្រួចអាត្មា ហាក់ដូចក្រឡាប់ ៗ សម្ផស្ស
ប្រុសស្រីចំណាប់ តែប៉ះពាល់ប៉ុាប់ ក្រឡាប់ក្នុងកវិល ៗ ក្នុងក្លៃទៅជា
ភ្នែកព្រិល ល្វៀងបើលមើល មិនច្បាស់ទេណា ៗ ចំណង់បើសម្ផស្សថ្លា

នៃពួកទេព្តា យ៉ាងណាទៅអេះ ៗ ណ្ហើយចុះខ្ញុំសូមឈប់ស្ទេះ បញ្ចប់
ត្រឹមនេះ អស់អាថ៌សេចក្តី ៗ ខ្ញុំទើបនឹងរៀនតែងថ្មី សូមពួកកវី
កុំបួញបាញមាត់ ៗ បើឃើញមានខុសក្បាំងក្បាត់ សូមជួយផ្ទៀងផ្ទាត់
តម្រង់ឲ្យបាន ៗ មួយទៀតខ្ញុំធ្វើប៉ះពាន ទៅលើពាក្យគ្មាន នៅក្នុង
ព្រះសូត្រ ៗ លើសខ្វះតិចតួចព្រោះប្រួត កាត់លៃសម្រួត សម្រួល
ឃ្លាកាព្យ ៗ សូមកុំឲ្យខ្ញុំមានបាប អាក្រក់ខ្លះខ្លាប ជាប់ដល់អបាយ ៗ
ព្រោះខ្ញុំឥតមានក្លែងក្លាយ រៀនតែងបរិយាយ ដោយចិត្តជ្រះថ្លា ៗ
សន្មតថាចប់កាព្យា ប៉ុណ្ណោះឯងណា និដ្ឋិតាចប់ហោង ៗ

ញុង - សឿង

"ចំឡងចេញពីទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ ១៩៤៣-លេ៖-៥"

# ផ្នែកអក្សរសាស្ត្រ

## វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាំង-ខាត់ រៀបរៀង*

អភិសំស្តុ ធាតុ សរសើរក្រៃលែង ស្តូត្រសរសើរ ។

អភិសំស្ថា ធាតុ តាំងនៅ ឋិតនៅ ។ -ស្ថិត គុ. ដែលឋិតនៅ ។

អភិសំស្ព្ឫឝ ធាតុ ងូតទឹក ។ ដកយក ។

អភិសំស្ម្ឫ ធាតុ នឹកដល់ គិតដល់ ។

អភិសំហិត គុ. ដែលប្រយុទ្ធ ។

អភិសំហិត គុ. ដែលទទួលស្គាល់ ។ ដែលទាក់ទង ។

អភិសំកល្ប បុំ. អភិសំកល្ប សេចក្តីប្រាថ្នា ។

អភិសំក្រុទ្ធ គុ. ដែលក្រេវក្រោធ ។

អភិសំក្រុឝ ធាតុ ស្រែកហៅ ។

អភិសំក្សិប ធាតុ បង្រួម ។ -ក្សិប្ត គុ. ដែលបង្រួម ដែលធ្វើឲ្យតូច ។

អភិសំខ្យា ធាតុ រៀបរាប់ ។

អភិសំខ្យា ស្ត្រី. អភិសំខ្យា ចំនួន ។

អភិសំខ្យេយ គុ. ដែលគួររាប់ ។

អភិសំគម៑ ធាតុ ទៅជួប គោរពរួមគ្នា ។ -គត គុ. ដែលជួបជុំគ្នា។

អភិសំគុប្ត គុ. ដែលគ្រប់គ្រងប្រពៃ ដែលការពារមាំ ។

អភិសំជ្ញិត គុ. ដែលតែងតាំង ដែលហៅរក ។

អភិសំជ្វរ៑ ធាតុ ព្រួយបារម្ភ ប្រណែន ។

អភិសញ្ជ ធាតុ ធ្វើបដិសណ្ឋារ ។ -សញ្ជត គុ. ដែលប្រកបដោយកិត្តិយស ។

អភិសំតប្ត គុ. ដែលក្ដៅក្រៃលែង ។

អភិសំត្យជ៑ ធាតុ បោះបង់បោល ។

អភិសំត្រស្ត គុ. ដែលតក់ស្លុតក្រៃលែង ។

អភិសំទេហ   នបុំ. អភិសំទេហ  អង្គជាតិ ។

អភិសំធក   គុ. ដែលកុហក ។

អភិសំជា   ធាតុ  ដាក់សរ(លើធ្នូ) តម្រង់ ។ គិតដល់ ។ ព្រមព្រៀង គ្របទៅលើ បំភ័ន្ត ។ -ជាយ៍ គុ. ដែលជាប់ ។ -ជិត គុ. ដែលផ្សំគ្នា ដែលប្រកប ។

អភិសំជា   ស្ត្រី. អភិសំជា កិរិយាពោលអះអាង សម្ដី ។

អភិសំជាន   នបុំ. អភិសំជាន កិរិយាជាប់ កិរិយាទាក់ទង សម្ដី កិរិយាបះញោត ។

អភិសំធិ   ស្ត្រី. អភិសន្ធិ សេចក្ដីប្រាថ្នា បំណង ។ សេចក្ដីព្រមព្រៀង សន្ធិសញ្ញា ។

អភិសំធីន   គុ. ដែលបញ្ចូក់ ។

អភិសន្ធ   គុ. ដែលប្រកបដោយបរិក្ខារ ។

អភិសិន៍   ធាតុ  នាំទៅ ។

អភិសមាគម៑   ធាតុ  មកចំ ។

អភិសមាបទ៑ ធាតុ ធ្លាក់ទៅក្នុង ។

អភិសមាយា ធាតុ ចូលទៅព្រមគ្នា ។

អភិសមាយុក្ត គុ. ដែលប្រកបដោយ ។ ដូចពាក្យ សមាហិត ។

អភិសមាវ្ឫត៑ ធាតុ ចូលមកវិញ ។

អភិសមីក្ស៑ ធាតុ មើល ។

អភិសមីរ៑ ធាតុ ធ្វើចលនា ។

អភិសមេ (តិ) ធាតុ ប្រជុំគ្នា ។ -សមេត គុ. ដែលប្រជុំគ្នា ។

អភិសំបត៑ ធាតុ ប្រញាប់ ស្រូតរូត ។

អភិសំបទ៑ ធាតុ មកដល់ បានសម្រេច ។ -បន្ន គុ. ដែលបានដល់ ឬ បានសម្រេច ។

អភិសំបូជ៑ ធាតុ គោរពបូជា ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង្វ-គាង

ប្រែ-រៀបរៀង

(៣)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាតបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ុន

ឯខុងបេង ក៏នាំទ័ពទៅក្នុងស្រុកងិនទៃ ទើបឲ្យទាហានទៅស៊ើបដំណើរការមើលថា បេងហេកទឹងទៅតាំងនៅដំបន់ឯណា, ទាហានល្បាតវិលមកជម្រាបថា ៖ បេងហេកទៅបាំលុតត័តកុត ទៅហួយស្រុកអគោកុក លើកទាហានទៅតាំងនៅត្បូងត្រាំងស៊ូងដោហួស៊ុយ ជាច្រើនណាស់, ខុងបេងបានឮដូច្នោះ ក៏ចាត់ចែងទាហានលើកទៅដល់ស៊ូងដោហួស៊ុយ ឃើញទាហានលុតត័តកុតរូបរាងជាថែបអ្នកលើ ហើយឃើញទឹកនោះក៏ខ្មួរសង្វែរ ក្រោមរបរិកពេង ១ ទើបឲ្យគេហៅពួកអ្នកស្រុកមកដណ្ដឹងសួរយកការ, អ្នកស្រុកឆ្លើយថា ទឹកក្នុងស៊ូងដោហួស៊ុយនោះបើផឹក [illegible] ណា មនុស្សក្នុងប្រទេសនេះឯង មិនដឹង [illegible] ត្រូវតែស្លាប់ក្នុងវេលានោះ, បើអ្នកស្រុកអគោកុកឯង

ទៅផងផឹក ក៏ឲ្យកើតសតិបញ្ញាទិងកម្លាំងច្រើនឡើង, ខុនបេងព្រួយព្រោះ ក៏ភ័យណាស់ ចាត់អ៊ុយអៀនឲ្យតាំងបន្ទាយ នៅក្បែរស្ទឹងនោះ ៗ ឯខ្លួន ខុនបេងថយទ័ពចេញទៅតាំងនៅឆ្ងាយប្រមាណ ២៥០ សិន (១០ គីឡូម៉ែត្រ) ហើយក៏ដាប់ទាហានទាំងពួងមិនឲ្យដងទឹកនោះផឹកសោះ ៗ

ឯទៅអ័ទទិងគេហ៊ុំ ឃើញខុនបេងទៅតាំងបន្ទាយនៅដូច្នោះ ក៏ លើកទាហានចូលទៅត្រើយម្ខាង ដើម្បីច្បាំងយកបន្ទាយអ៊ុយអៀន ៗ ក៏ លើកចេញទៅតាំងនៅក្រៅបន្ទាយ លុះទៅអ័នទិងគេហ្វ៊ី លើកទ័ពទៅ ដល់ ក៏ដេញទាហានឲ្យចុះតច្បាំងជាពន្លឹក, អ៊ុយអៀនឃើញទាហាន ក្រុតឥតកុតកាន់យាំទិងគន់ចង់ដល់អាវុធទាំងពួង ក៏សាយទ័ពវិលទៅបន្ទាយ ខុនបេង, ទៅអ័នទិងគេហ្វ៊ី ក៏លើកទាហានចូលត្រឡប់មកបន្ទាយ, អ៊ុយ អៀនឲ្យទាហានតាមទៅល្បាតស៊ើបយកការ ឃើញទាហានលុតឥតកុត គ្មានផែនទិងទូក ដេះលើក្រោះធ្ងន់ទឹកទៅបាន ក៏យកសេចក្តីទៅជម្រាបខុន បេងគ្រប់ប្រការ ៗ

ខុនបេងបានស្តាប់ ក៏ឲ្យទឹកសង្ស័យ ទើបហៅលិគីមកសួរថា ហេតុ ផលទាំងនេះ តើនឹងជាប្រការម្តេច ? លិគីថា ឯទាហានតិចកៈប៉េងពួកនេះ មានកម្លាំងពលំ ពាក់ក្រោះផ្តៅត្រាំប្រេងគន់ធន់ដល់អាវុធគ្រប់ៗ គ្នា, ឯយើង ទឹងច្បាំងយកជ័យជម្នះពួកនោះ ឃើញពិបាកណាស់ សូមឲ្យមហាឧបរាជ ត្រឡប់ទៅស្រុកសេឈួនវិញសិនចុះ, បេងហោកក៏អន់តប្រឹះវះគិតប៉ុណ្ណឹង

ហើយ មុខជាមិនអាចនឹងតាមយើងបានទេ ។ ខុនបេងក៏សសំណើច ហើយថា យើងបានធ្វើការជ្រុលហួសមកដល់ត្រឹមនេះហើយ នឹងលើកទ័ពថយត្រឡប់វិលទៅវិញ មិនត្រូវសោះ, ពេលព្រឹកនេះ យើងនឹងគិតកលឧបាយយកជ័យជម្នះឲ្យបាន, ហើយខុនបេងក៏ចាត់ចែងឲ្យជូឡុងនិងអ៊ុយអៀនទៅក្រោយបន្ទាយ ។

លុះដល់ពេលព្រឹក ខុនបេងក៏ឡើងជិះរទេះតូច នាំទាហានស្និទ្ធនិងពួកអ្នកស្រុក លើកទៅតាមផ្លូវស៊ីងទិសឯជើង, លុះដល់ជើងភ្នំ ខុនបេងក៏ចុះពីលើរទេះ ដើរទៅដល់ភ្នំធំមួយអន្ទើ កំពូលភ្នំនោះ ជាទំនួលមានសណ្ឋានដូចរូបពស់ ស្ដើកប គ្មានដើមឈើ, ក្បែរទួលនោះ មានកំពែងថ្មជាមួនមាំ ហើយមានផ្លូវធំ ១, ខុនបេងក៏សួរថា ទីនេះ ឈ្មោះអ្វី ? អ្នកស្រុកឆ្លើយជម្រាបថា ឈ្មោះប៉ូប៉ូស៊ុក គឺទួលពស់លូន, ផ្លូវធំដែលចុះទៅនោះ ត្រង់ទៅលើស្រុកសាំកាំង, ខុនបេងឮដូច្នោះ ក៏មានអំណរណាស់ថា ការយើងគ្រានេះ មុខជានឹងសម្រេចប្រាកដ, ហើយក៏ចុះពីលើកំពូលភ្នំ ទៅឡើងរទេះតូច វិលមកបន្ទាយវិញ, ខុនបេងបង្គាប់ម៉ាតាយឲ្យយករទេះ ១០ ដែលផ្ទុកខ្លូធ្វើត្រៀមទុកពីស្រុកមក ៗ បើកឡើង, ក្នុងទូនោះ ដាក់ឡតឈើ ១.៣០៩, ក្នុងឡតនោះ ដាក់ផាវដែកទីនគ្រាប់ជាច្រើន, ខុនបេង ក៏បង្គាប់ម៉ាតាយថា អ្នកឯង ត្រូវនាំទាហានឲ្យយករទេះ១០នេះ ទៅបង្កប់នៅក្បែរទួលប៉ូប៉ូស៊ុក ត្រៀមការទុកឲ្យព្រមក្នុង

១៥ ថ្ងៃ ។ ម៉ាតាយទទួលប្រសាសន៍ហើយក៏លាខុនបេនទៅ, ខុនបេនក៏ឲ្យជួឡុននាំទាហានទៅតាំងស្កាត់ នៅក្បែរមាត់ថ្មរ. ដែលទឹងទៅស្រុកសាំកាំង ឲ្យត្រៀមការទុកព្រមស្រេច, ជួឡុនក៏លើកទាហានទៅ, ខុនបេនឲ្យអ៊ុយអៀនទៅនៅបន្ទាយក្បែរមាត់ស្ទឹង ពោហ្វូស៊ុយ ហើយបង្គាប់ថា បើទាហានលុកតក់តកុតៈលើកមកច្បាំង ក៏ឲ្យធ្វើជាបែកថយរត់ បញ្ឆោតឲ្យដេញតាមទៅដល់ទួលចូប៉ូស្លុក, បើឃើញទង់សដោតនៅត្រង់ណាឲ្យចូលទៅឈប់នៅត្រង់នោះ ។ អ៊ុយអៀនបានស្តាប់មិនបានដឹងកន្ទកលឧបាយខុនបេន ក៏គិតតូចចិត្តថា ខុនបេនក្លែងឲ្យខ្ញុំបានទទួលសេចក្តីអាប់យសដល់សត្រូវខ្លាំង តែគិតខ្លាចអាជ្ញាខ្លាំង ក៏មិនអាចតប្រកែកស្តេច ក៏លើកពលទៅតាំងនៅតាមបង្គាប់, ខុនបេន ក៏ឲ្យកៀវសេកនិងកៀវង៉ីម៉ាតង នាំទាហានដែលបញ្ចុះបញ្ចូលបាន ២.០០០ នោះ ទៅតាំងបន្ទាយ ៧ កាយគ្នាទៅតាមធ្នេរស្ទឹងចូប៉ូស្លុក ឲ្យដោតទង់សទុកជាសម្គាល់ ។

ឯបេនយោក កាលលើកទ័ពមកដល់ពោហ្វូស៊ុយ ឃើញកងទ័ពទៅតាំងនៅថ្នល់នោះ ក៏និយាយនឹងលុកតក់តកុតថា ខុនបេននេះ ជាមនុស្សមានសតិបញ្ញាខាងធ្វើកលឧបាយល្បិចបញ្ឆោតផ្សេង ៗ, បើនឹងធ្វើសឹកនឹងខុន-បេននោះ ត្រូវតែកំចាត់ទាហានទាំងពួងជាមុនឲ្យហើយ ថាបើច្បាំងនឹងខុនបេនទៅដល់ជាយព្រៃ និងជើងភ្នំទីសំខាន់ ទោះបើនឹងបានចំណាប់យ៉ាងណា ក៏កុំឲ្យដេញជិតតាម, លុកតក់តកុតថា អ្នកកុំព្រួយបារម្ភ, ឯភ្នក

ស្រុកសេឈួនដែលមានកលឧបាយច្រើនយ៉ាងណា យើងក៏អាចដឹងការបានទាំងអស់, យើងនឹងនាំទាហានគង់មុខលើកចូលទៅមុន សម្លាប់ខុងបេងឲ្យបាន, ខុនអ្នកចូរនាំទាហានការពារនៅជាក្រោយចុះ, ហើយលុតត័តកុត ក៏លើកទាហានចូលត្រើយទៅច្បាំងនឹងទ័ពអ៊ុយអៀន ។ ក៏លើកទាហានចេញតទឹងលុតត័តកុតបាន ៩ ក្លេះ, អ៊ុយអៀនធ្វើជាចាញ់ដោះបោលបន្ទាយ បំផាយសេះរត់ទៅ, លុតត័តកុតក៏លើកទ័ពចូលត្រឡប់មកបន្ទាយវិញ, អ៊ុយអៀនក៏វិលចូលបន្ទាយវិញដែរ ។

លុះព្រឹកឡើង ថ្ងៃ ១ លុតត័តកុត ក៏លើកទ័ពចូលទៅច្បាំងទៀត, អ៊ុយអៀនចេញច្បាំងបាន ៧ ក្លេងធ្វើជាចាញ់ទាញសេះរត់, លុតត័តកុតឲ្យទាហានដេញតាមទៅឆ្ងាយប្រមាណ ៨០ សិន (៣២០០ម៉ែត្រ) ឃើញយើងស្ងាត់គ្មានមនុស្សម្នាចេញមកតច្បាំង ក៏ត្រឡប់មកប្រាប់លុតត័តកុតគ្រប់ប្រការ, លុតត័តកុត បានស្តាប់ ក៏បបួលទាហានគង់ធំ លើកតាមទៅ, អ៊ុយអៀនឃើញលុតត័តកុតដេញតាមជិតនឹងទាន់ ក៏ឲ្យទាហានដោះបោល រត់ចូលទៅក្នុងបន្ទាយទង់ស, លុតត័តកុតឃើញដូច្នោះ ក៏មានចិត្តកំរើបលើកទាហានតាមទៅដល់បន្ទាយអ៊ុយអៀន ។ ក៏ចេញច្បាំងនឹងលុតត័តកុតបាន ៣ ក្លេង ហើយដោះបោលបន្ទាយ បំផាយសេះរត់ទៅចូលនៅក្នុងបន្ទាយទង់សទី ២, លុតត័តកុតក៏លើកទាហានដេញតាមទៅ, អ៊ុយអៀនចេញច្បាំងបាន ៣ ក្លេង បំផាយសេះរត់ទៅទៀត តែអ៊ុយអៀន

បានចេញតដៃនឹងលុតត័តកុត ហើយធ្វើជាបាញ់ដល់ ១៥ គ្រា ពេល បន្ទាយ ៧ អន្ទើ, លុតត័តកុតរឹតតែមានចិត្តកំរើប បំផាយសេះដេញហួស ទៅមុខពាហានរួចត្រឡប់វិលមកវិញប្រាប់ថា ក្នុងព្រៃនោះ មានពាហាន ពួនបង្កប់ជោគទង់ទុកជាច្រើន, បេងហេកបានឮដូច្នោះ ក៏អស់សំណើច ហើយថា ឯខុងបេងនោះពូកែតែខាងកលឧបាយ, បើនឹងច្បាំងគ្នាដោយ កម្លាំងថ្ងៃដៃក៏ស៊ូទីងយើងមិនបានទេ, យើងធ្វើសឹកគ្រានេះ មានជ័យជម្នះ ១៥ គ្រា បានបន្ទាយ ៧ អន្ទើ, ពាហានខុងបេងសឹងតែខ្ទេចយើងណាស់ ហើយ, យើងត្រូវបង្អង់តាំស្ដាប់ខុងបេងមើលសិន, មុខជាខុងបេងនឹងបាញ់ ប្រៀបយើងជាប្រាកដ, លុតត័តកុតក៏យល់ឃើញផង ទើបបោះទ័ពនៅទី នេះ ១ យប់ ។

លុះព្រឹកឡើង ប៊ុយអៀន ក៏លើកពាហានចេញច្បាំងបញ្ឆោតលុតត័ត-កុតទៀត, លុតត័តកុតឲ្យបេងហេកនៅរក្សាបន្ទាយ, ឯខ្លួនឯងតែងតួពាក់ គ្រោះប្រដាប់ពេជ្រពាក់ផ្កាំ ជិះលើ-កដំរីចេញមុខពាហាន ប៊ុយអៀនបាន ឃើញដូច្នោះ ក៏ស្រែកជេរលុតត័តកុតជាច្រើន ហើយបំផាយសេះរត់, លុត ត័តកុតព្រះហើយ ខឹងណាស់ ភ្នែកក្រហមដូចភ្លើង ក៏បរដំរីដេញពាហានឲ្យ លើកតាមប៊ុយអៀន ឃើញទង់សជោគនៅលើកំពូលភ្នំបុប្ផសុក ក៏បំផាយ សេះរុកពានតានឡើងទៅ, លុតត័តកុតឡើងទៅដល់ ឃើញទីនោះស្ងាប គ្មានដើមឈើជាទីកំបាំងដែលខុងបេងនឹងបង្កប់ពាហានទុក ក៏ប្រមាទបន្តិច

នាំទាហានដេញតាមអ៊ុយអៀនទៅ, លុះទៅដល់ផ្លូវដែលម៉ាតាយបង្កប់ទា-
ហាន ជូនពេលព្រលប់ លុតត័តកុតឃើញរទេះដែលម៉ាតងយកទៅដាក់
កណ្តាលផ្លូវ សម្គាល់ថាខុងបេងបោលរទេះនោះចុះរត់ទៅហើយ ក៏បង្ខំ
លើកទាហានតាមទៅ ដល់ផ្លូវដែលជូឡុងជញ្ជូនថ្មសិលានិងកាត់ឈើខ្ទប់
ទុកនោះ លុតត័តកុតក៏មានអំណរណាស់ ឲ្យទាហានចូលទៅរញ្ជូនថ្មនិង
ឈើនោះជាច្រួលច្របល់ ប្រញាប់នឹងតាមខុងបេងទៅ, ជូឡុងក៏ឲ្យទា-
ហានយកភ្លើងដុតឆេះឡើងសន្ធោសន្ធៅពេញផ្លូវព្រៃពីខាងក្រោយ, លុត-
ត័តកុតឃើញភ្លើងឆេះស្ទាក់ផ្លូវ ក៏ភ័យរត់ទៅបណ្តោយ, ម៉ាតាយក៏ឲ្យដុត
ភ្លើងគ្រប់រទេះ, ឈ្នួនក៏ឆាបឆេះព័ទ្ធជុំវិញ, ដាវដែកនោះមិញ ក៏ផ្ទុះបែក
ស្ទើរទឹងធ្លាយរហែកកំទិចព្រៃនៅទីនោះ ។

លុតត័តកុតឃើញភ្លើងឆេះព័ទ្ធជុំវិញដូច្នោះ មិនដឹងនឹងធ្វើប្រការម្តេច,
ភ្លើងក៏ឆេះពលដូចគេរោច ឆេះចាប់ដល់ក្រោះទាហាន រាលដាលពលគ្រប់
គ្នា, លុតត័តកុត និងពលយោធាទាំង ៣ ម៉ឺន ក៏ស្លាប់នៅកណ្តាលភ្លើង
នោះទាំងអស់ ។

ខុងបេងឡើងឈរនៅលើកំពូលភ្នំ ក្រឡេកឃើញលុតត័តកុតនិងពល
ជាប់កណ្តាលចំណោមភ្លើង ត្រូវនឹងដាវដែកដាក់គ្រាប់បែក ធ្លាយលាន់ឮ
សន្ធឹកគគ្រឹកគគ្រេង ត្រូវស្លាប់ពលលើងឆេះទាំងអស់ ខ្លះនៅរស់ដាច់ដៃ
ដាច់ជើងខ្ទាក់ក្នុងបែកលលាដ៍ក្បាល បណ្តាលឲ្យមានក្លិនអសោចនៃខ្មោច

អស្រុកអប់សព្វទិសទី, ខុនបែនក៏បង្កើតព្រឺព្រួចក្នុងឥន្ទ្រិយជាទីសង្វេគ មានទឹកភ្នែកនោះហូរស្រក់ចាក់ចុះមកដោយករុណាធម្មចិត្ត អាណិតមនុស្សដែលស្លាប់ គិតឃើញឆាប់ថា ខ្លួនអញធ្វើការគ្រានេះ ទោះនឹងបានសេចក្ដីគាប់ប្រសើរយ៉ាងណា រីអាយុនៃអាត្មាក៏នឹងខ្ចុះអស់ត្រឹមនេះឯង ព្រោះកម្មស្ពានដែលធ្វើឲ្យជីវិតគេវិនាសច្រើនណាស់មកហើយ, ឯអស់ពួកទាហានទាំងប៉ុន្មាន ក៏សឹងមានសេចក្ដីសំវេគអាណិតអនាថគ្រប់ៗគ្នា ។

ខណៈភ្លើងឆេះលុកត័តកុតនិងពលយោធា នៅទីនោះ ខុនបែនឲ្យតៀងនាំទាហាន ១ ០០០ ធ្វើកលជាតេប៉ាក់ទ័ពទៅរកបែនហេកឯបន្ទាយ ហើយឲ្យប្រាប់ថា ឥឡូវ លុកត័តកុតព័ទ្ធខុនបែនជាប់ក្នុងចំណោមហើយ, អស់យើងទាំងឡាយឃើញថា សេចក្ដីស្លាប់នឹងមានមកដល់ខ្លួន បានជានាំគ្នាតែមកពឹងលោក, សូមឲ្យលោក ប្រញាប់លើកទ័ពល្បូនឡើងទៅព្រួតទៀត, កាលតៀងលើកទៅដល់ ហើយបាននិយាយការដូច្នោះ, បែនហេកក៏សម្គាល់ថាមែន ទើបលើកទាហានឡើងទៅ ទាំងពេលកណ្ដាលយប់, លុះទៅដល់ជើងភ្នំ ឃើញភ្លើងឆេះក្ដុំរុងរឿង ហើយធុំក្លិនស្អុយអស្រុកខ្មោចអាសោចខ្លាំងណាស់, បែនហេកនឹកភ័យ គិតត្រឡប់ចុះមកវិញ, ម៉ាតងនិងតៀងក៏ដេញទាហានឲ្យចូលប្រកាប់ប្រសព្វគ្នាចូលទៅ, បែនហេកស្រែកដោយសំឡេងខ្លាំង, ទាហានទាំងពួង ក៏រត់ច្រួលច្របល់ចូលបន្ទំជាទាហានខុនបែនទាំងអស់, បែនហេកក៏បំផាយសេះស្ទុះបំពារទ័ពតេ

ទៅដល់ច្រកភ្នំមួយ អន្ទើ ប្រទះនឹងខុនបេងឡើងជិះរទេះតូចនាំទាហានមកស្ទាក់ពីមុខ, ខុនបេងក៏ស្រែកដោយសំឡេងខ្លាំងថា អាចោរក្បត់! អាឯងរត់ទៅណា? ប៉េងហោកភ័យណាស់ញាក់សេះរត់ ទទួលមាតាយលើកទាហានស្ទាក់ផ្លូវពីមុខពីអាង ព័ទ្ធជុំវិញ ក៏ចាប់ខ្លួនប៉េងហោកបាន ហើយនាំបណ្ដើរទៅជូនខុនបេង ។

ឯខុនបេង លុះប៉េងហោករត់ទៅហើយ ក៏ឲ្យអង់ប៉ែង និងគៀវអេកនាំទាហានស្រូតទៅវាយបន្ទាយប៉េងហោក ឯប៊ឹងគោហ្វស៊ុយ ចាប់បានខ្លួនអាន់ចុកយ៉ុងនិងស៊ត្រប័ក្ខពួកទាំងអស់, ខុនបេងក៏នាំកងទ័ពត្រឡប់មកបន្ទាយវិញ ហើយនិយាយនឹងទាហានទាំងពួងថា យើងគិតកលឧបាយធ្វើសឹកមានជ័យជម្នះស្រួលណាស់ សូម្បីតែកូនទាហានម្នាក់ ក៏មិនបានខូចសោះ, កាលលុតត័តកុតដេញអ៊ុយអៀនទៅដល់ជាយភ្នំ នោះយើងក៏បានយកតែទង់ជ័យទៅដោតបញ្ឆោតទុកក្នុងព្រៃ, ក៏សម្គាល់ថា ទាហានទាំងនៅក្នុងទីនោះច្រើនណាស់ បានជាមិនអាចនឹងលើកតាមទៅ ត្រឡប់ដេញអ៊ុយអៀនឡើងទៅលើភ្នំវិញ, បានជាយើងឲ្យម៉ាតាយយករទេះដែលផ្ទុកដីនៅនោះ ទៅដាក់ចោលកណ្ដាលផ្លូវ ហើយយើងឲ្យយកដាវដែកដាក់គ្រាប់បែកកប់ក្នុងដីបន្តឈ្នួសសម្រាប់អុជគ្រាប់កន្ទុង, លុតត័តកុតទ្រើសទ្រូនដ៏អង់អាចមិនខ្លាចគំនិត ៉ គិតមិនដល់ក៏ចាញ់កលយើង ហើយលុតត័តកុតក្លែងទៅបោះបន្ទាយនៅក្នុងស៊ឹងគោហ្វស៊ុយ នឹងបញ្ឆោតយើងឲ្យ

ស្លាប់ដោយទឹកមានពិសពុល, យើងគិតយល់ថា ទាហានលុតត័តកុតពាក់ការក្រោះផ្ដៅជ្រលក់ច្រើន បានជាយើងយកក្មេងការគេបពិសទៅវិញខ្លះ ៗ គេក៏បាញ់តបះយើងវិញ, ទាហានលុតត័តកុតនោះមិញ ណាដែលមានខ្ចីដៃខ្លាំងពូកែណាស់ ក៏ត្រូវស្លាប់នៅក្នុងក្មេងនោះអស់ទៅហើយ, យើងគិតអនុគ្រោះ គួរឲ្យសង្វេគអាណិតពន់ប្រមាណ, គេជះផលដែលយើងបានតាំងចិត្តធ្វើកជការ ដោយថ្វាយព្រះតេជព្រះគុណអម្ចាស់លើសិរសាដោយចេតនាសុចរិត សូមកុំឲ្យមានរោកជាបជិតតទៅឡើយ ។

អស់ពលទាហានទាំងពួងបានឮហើយ ក៏នាំគ្នាទូលតំនាប់ដោយគោ·ពះហើយថា ឯគំនិតប្រាជ្ញាមហាឧបរាជនោះ ជ្រាលជ្រៅពន្លឹកណាស់ កុំថាតែមនុស្សដើរលើដី សូម្បីទេពារក្ស ដ៏មានរិទ្ធិសិទ្ធិសក្តិហើរហោះបាន ក៏មិនប្រមាណការសញ្ញាចិត្ត គិតមិនដល់យល់តម្រិះ របស់មហាឧបរាជបានឡើយ ។

ខណៈនោះ ទទួលម៉ាតាយនូវអស់ទាហាននាំបេងហោកទាំងចំណងចូលមក ព្រមទាំងបេងហ៊ីវ តួឡៃ និងនាងចុកយ៉ុង, ខុងបេង ក៏ឲ្យស្រាយចំណងចេញទាំងអស់, បេងហោក ក៏ក្រាបចុះគំនាប់តាមសភាព, ខុងបេងក៏ឲ្យបេងហោក បេងហ៊ីវ តួឡៃ និងនាងចុកយ៉ុង ចេញទៅអង្គុយពីចម្ងាយហើយឲ្យទាហានរៀបតុលៀងអាហារស្រាបាយ ឲ្យអ្នកអស់ទាំងនេះបរិភោគ ។

ខណៈនោះ កាលឈ្មោះទាំង ៤ នាក់ ផឹកសុរាទៅទើនោះ, ខុនបេន ក៏ប្រើតាហានម្នាក់តែងគលទៅនិយាយនឹងបេនហេកថា ឥឡូវមហាឧប-រាជនឹងឲ្យបើកលែងអស់លោកទៅវិញម្ដងទៀត បើលោកនឹងបន់ធ្វើសឹក តស៊ូនឹងមហាឧបរាជឲ្យឃើញថ្វីដៃយ៉ាងណា ក៏តាមចិត្ត យើងនឹងលែងឲ្យ ទៅបញ្ចុះបញ្ចូលតាហានលើកមកច្បាំង ឲ្យអស់ថ្វីដៃចុះ នឹងឃើញច្បាស់ ជានរណាឈ្នះ នរណាចាញ់, បេនហេកឮដូច្នោះ ក៏នឹកអៀនខ្មាសក្នុង ចិត្តណាស់ អន្ទះយសម្រក់ទឹកភ្នែកហើយថា ពីដើមមក ព្រោះមិនទាន់បាន ដឹងឃើញ, ការដែលធ្វើសឹកនឹងគេ ១ ចាប់បានហើយលែងទៅវិញដល់ ៧ គ្រាដូច្នេះនេះ ហេតុពីព្រោះយើងជាមនុស្សផ្សេងប្រទេសគ្នាក៏មែន តែ យើងក៏គង់ស្គាល់ខុសនិងត្រូវ មានសេចក្ដីអៀនខ្មាសខ្លះដែរ, ខ្លួនយើងនឹង ករយាទូវអស់ស័ត្រូបក្ខពួកទាំងប៉ុន្មាន មិនហ៊ានធ្វើសង្គ្រាមតទៅទៀតទេ, សូមនាំគ្នាទៅក្រាបក្រោមបាទជើងមហាឧបរាជ សុំតែអាយុជីវិតទៅចុះ ទើបត្រូវ, ថាហើយ បេនហេកក៏នាំគ្នាចូលទៅសំពះខុនបេនដោយគោ-រព ហើយថា ខ្លួនខ្ញុំបាទបានធ្វើសេចក្ដីខុសធ្ងន់នឹងមហាឧបរាជ ១ មាន សេចក្ដីករុណាទុកអាយុជីវិត បើកលែងទៅ ៦ គ្រាហើយ, សូមមហាឧប-រាជអត់ទោសប្រោសប្រណីខ្ញុំបាទចុះ ព្រោះតាំងពីថ្ងៃនេះតទៅ ខ្ញុំបាទ លែងគិតគំនិតវៀចអាក្រក់នឹងមហាឧបរាជទៀតហើយ ។

ខុនបេនសួរថា អ្នកឯង ព្រមចំណុះចុះចូលយើងហើយឬនៅ ?

បេងហោកឆ្លើយថា ខ្ញុំបាទសូមចំណុះចុះចាញ់មហាឧបរាជតទៅរហូតដល់កូនដល់ចៅ, និយាយហើយក៏យំ, ខុនបេងក៏អញ្ជើញបេងហោកឲ្យឡើងអង្គុយលើកៅអីទឹមគ្នា ឲ្យបរិភោគអាហារសេពសុរា ហើយខុនបេងក៏តាំងឲ្យបេងហោកទៅជាចៅហ្វាយស្រុកដូចដើម, ឯបណ្ដាអាណាខេត្រនិងពលទាហាន ដែលចំណុះចុះចូលទៅនឹងខុនបេងទាំងប៉ុន្មាន ក៏បង្វិលឲ្យបេងហោកវិញទាំងអស់ ។ បីហុយ (នាយទាហាន) និយាយនឹងខុនបេងថា មហាឧបរាជមកធ្វើការគ្រានេះ ក៏លំបាកពលទាហានណាស់, ឥឡូវបេងហោកស្ម័គ្រចំណុះចុះចូលហើយ ដែលមហាឧបរាជនឹងលើកឲ្យបេងហោកនៅឈររក្សាខេត្រតែម្នាក់ឯងនោះ ខ្មាំងក្រុងបេងហោកនឹងប្រែចិត្តក្រឡប់ឡើងវិញ យូរទៅឯមុខ នឹងបានសេចក្ដីព្រួយរំខាន, ហេតុនេះ សូមឲ្យមហាឧបរាជតាំងពួកយើងពីនាយឲ្យនៅជួយត្រួតត្រាផង ។

ខុនបេងថា ក្នុងស្រុកបេងហោកនេះ ខុសគេទគ្នានឹងស្រុកយើងឯនាយ ៣ ប្រការ គឺពួកអ្នកស្រុកអាយនេះ ស៊ីតែសាច់សត្វស្រស់ទៅជាអាហារប្រការ ១ ។ យើងដែលលើកកងទ័ពមកនេះ គឺបានសម្លាប់បងប្អូនញាតិសន្តានអ្នកស្រុកនេះអស់ច្រើនណាស់ មុខជាអ្នកស្រុកនេះ នឹងមានចិត្តគុំគួននិងសងសឹកពួកយើងវិញ ប្រការ ២ ។ ក្នុងស្រុកនេះ គ្មានច្បាប់សម្រាប់ប្រវេណី ជាទីទំនុកបម្រុងឲ្យត្រង់តាមគន្លងធម៌ ដូចប្រទេសឯទៀតសោះ, បើនរណាប្រព្រឹត្តទាស់ល្មើសនឹងចិត្តចៅហ្វាយស្រុកហើយក៏ត្រូវសម្លាប់ចេញបាន ប្រការ ៣ ។

បើយើងនឹងឲ្យមន្ត្រីពីនាយ ហើយនិងទាហាន នៅកាន់កាប់រក្សា ឃើញថា ជាការលំបាកណាស់ គង់នឹងបានសេចក្តីក្តៅរំខានជាក្រោយ, មួយទៀត បេងហោកក៏អស់តម្រិះប្រាជ្ញា គេខ្លាចថ្វីដៃយើងណាស់ហើយ កាលណាឡើយនឹងហ៊ានកម្រើកចិត្តគិតវៀចតទៅទៀត ។

បេងហោកនិងស្ម័គ្របក្ខពួកទាំងអស់បានឮដូច្នោះ ក៏នាំគ្នាទូលគំនាប់ក្រាបសំពះខុនបេងដោយសេចក្តីខ្លាច ហើយក៏នាំគ្នាលាចេញទៅ, បណ្តាមហាជននៅក្នុងទីស្រុកនោះ ក៏សឹងនាំគ្នាសង់ជាសាលាទេពារក្ស ហើយឆ្លាក់ធ្វើជារូបខុនបេង ទុកជាទីសក្ការៈបូជា ចារឹកនាមថា ដូហ៊ូ ប្រែថា រូបអាពុកអ្នកស្រុក ទាំងអស់គ្នា ។

បេងហោក ក៏ចាត់ការរើសយកទ្រព្យមានតម្លៃ គឺចិញ្ចៀន កែវកង និងមាសប្រាក់ នាំយកមកជូនគំនាប់ខុនបេងជាច្រើន ហើយប្តេជ្ញាថា ខ្លួនខ្ញុំបានជាខ្ញុំមហាឧបរាជតទៅ បើមហាឧបរាជនឹងមានកិច្ចធុរៈអ្វីៗ ឲ្យតែកូនទាហានកាន់សំបុត្រមកដល់ខ្ញុំបាទចុះ, ខ្ញុំបាទនឹងទទួលប្រតិបត្តិ តាមប្រសាសន៍គ្រប់ប្រការ ។

ខុនបេងបានឮដូច្នោះ ក៏ឲ្យបំណាច់រង្វាន់ទាហានតាមសមគួរ ហើយក៏ចាត់គ្នាឲ្យអ៊ុយអៀនជាទ័ពមុខ, តួខុនបេងលើកទាហានតាមទៅជាទ័ពហ្លួង លើកទៅស្រុកសេឈួន, បេងហោកនិងអស់អ្នកស្រុកក៏លើកគ្នាជូនដំណើរទៅ, លុះលើកទៅដល់ស្ទឹងឡូកស៊ុយ, អ៊ុយអៀនក្រឡេកឃើញ

ព្យុះខ្យល់បក់បោកអណ្តែតសំពៅជុំថ្មចុះពីលើគោក, ក្នុងស្ទឹងនោះ ចុះអ័ព្ទងងឹត បិទៈជាយពពក នឹងរកផ្លូវច្រកចូលទៅក៏មិនរួច, ក្រុយអឿនក៏ថយទ័ពត្រឡប់ មកជម្រាបខុនបេនវិញ, ខុនបេន ក៏បង្ខំលើកពលទៅដល់ស្ទឹងឡុកស៊ុយ ឃើញហេតុវិបរិតចម្លែកណាស់ ក៏សួរបេនហោកថា ហេតុផលប្រការម្តេច បានជាដូច្នេះ ? ។

បេនហោកជម្រាបថា ក្នុងទីស្ទឹងនេះ មានបិសាចកាចសម្តែងរិទ្ធិ ពីដើមមកក៏ធ្លាប់មានដូច្នេះ, សូមឲ្យលោកយកក្បាលមនុស្ស ៤៩ និងសេះស ក្របីខ្មៅ មកសែនបួងសួង ទើបបាត់វិបរិតដូច្នេះ, ខុនបេនថា យើងធ្វើសឹកសង្គ្រាមនឹងគ្នា ពាល់តែស្រេចការ, ផែនដីក៏កប់ទាបតាមធម្មតាដូច្នេះហើយ, សូម្បីមនុស្សតាស់ជកម្នាក់ ក៏មិនដែលស្លាប់បំពោះដៃយើង, មកឥឡូវយើងដល់ទីស្ទឹងនេះ ជិតនឹងចូលដែនវិញហើយ, នឹងឲ្យយើងត្រឡប់មកសម្លាប់ជីវិតមនុស្សនិងសត្វនោះ មិនត្រូវសោះ, ខុនបេនក៏ចេញទៅឈរមើលពិគ្រោះនៅឆ្នេរស្ទឹងនោះ ឃើញព្យុះបក់បោកខ្លាំងណាស់ នឹងគិតចូលទៅមិនរួច, ទើបឲ្យកេហៅអ្នកស្រុកមកសាកសួរ, អ្នកស្រុកឆ្លើយជម្រាបថា តាំងពីមហាឧប ·ជលើកចូលស្ទឹង·នេះ មកធ្វើសឹក ក៏មានកើតជាគដូច្នេះជាដកចមកមិនដាច់ តែដល់ពេលព្រលប់ហើយរហូតទៅដប់ក្លឹ ចេះតែឮសំឡេងបិសាចស្រែកយំទ្រហឹងអឹងកាប់, ឃើញរូបអណ្តើកជាប់ទៅតាមផ្សែពពក, គ្មាននរណានឹងអាចចូលទៅមកបាន, ខុនបេន

បានស្តាប់ ទើបថា ដែលកើតហេតុទាំងនេះ ក៏ព្រោះទោសខ្លួនយើងឯង កាលគ្រាយើងប្រើម៉ាគាយឲ្យនាំទាហាន ១.០០០ លើកទៅនោះ ទាហានទាំងនោះ ក៏ស្លាប់អស់នៅក្នុងស្ទឹងនេះ, ហើយកាលធ្វើសឹកនៅនោះ ទាហានចេងហោក ក៏ស្លាប់ក្នុងទីនេះជាច្រើន, បិសាចទាំងពួងចង់ពៀរពេកនឹងយើង ទើបបណ្តាលឲ្យឃើញដូច្នេះ, យើងគិតឃើញទាំងម្ល៉េះ ត្រូវរៀបធ្វើការសែនគំនាប់ឲ្យបាត់ទៅវិញឲ្យបាន, អ្នកស្រុកទាំងពួង បានស្តាប់ដូច្នោះ ក៏ប្រាប់សេចក្តីដល់ខុងបេង ដូចចេងហោកនិយាយគ្រប់ប្រការ, ខុងបេងក៏ថា អ្នកពល់គ្នាកុំព្រួយបារម្ភឡើយ, ការនេះ យើងនឹងរិះគិតធ្វើឯង ។

ខណៈនោះ ខុងបេងបង្គាប់ទាហានឲ្យសម្លាប់សេះសក្របីខ្មៅ ហើយឲ្យយកម្សៅមកសូនឲ្យជាលលាដក្បាល ៤៩ ដុំ, លុះពេលកណ្តាលយប់ ក៏ឲ្យលើកចេញទៅតាំងនៅឆ្នេរស្ទឹង, ខុងបេងក៏តែងខ្លួនស្លៀកពាក់ចេញទៅអុជទៀនធូបនិងប្រទីប ៤៩ ហើយតែងជាសេចក្តីប្រកាសសូត្របួងសួងឲ្យគៀកកតជាអ្នកសូត្រសេចក្តីថា គ្រានេះ ព្រះចៅឡៅសៀនគ្រងរាជ-សម្បត្តិបាន ៣ ឆ្នាំ (ព.ស.៧៦៩) មានព្រះតម្រាស់ត្រាស់ប្រើយើងជាឧប-រាជឲ្យលើកទ័ពមកប្រាបប្រាមសត្រូវផ្សេងប្រទេស, យើងក៏តាំងចិត្តគិតធ្វើរាជការថ្វាយធួងព្រះតេជព្រះគុណ មិនបានគិតនឿយព្រួយលំបាក ទាល់តែបានសម្រេចការសង្គ្រាមមានជ័យជម្នះសត្រូវហើយ, ឯទាហានទាំងពួងដែលមានចិត្តសត្យសុចរិត បានដើរដោយមកជាមួយនឹងយើង ក៏ទំនើងនឹង

តាំងចិត្តជួយទំនុកបម្រុងព្រះចៅឡាវសៀនដូចគ្នា, វេលានេះ មិនទាន់ស្រេចការ, អ្នកទាំងអស់គ្នាក៏ក្ស័យជីវិតទៅខ្លះ, ហេតុនេះ គួរអស់អ្នកទាំងដឹងច្បាស់ថាជាកម្មរបស់យើងហើយ មិនគួរឡើយនឹងមកចងចិត្តអាឃាតធ្វើអ្វីទៀត គួរតែនាំសាច់ញាតិមិត្រសម្លាញ់ទៅស្រុកវិញ ជាមួយនឹងយើងចុះ, ក្លួនចៅនៅឯណោះ នឹងបានសែនព្រេនបូជាតាមទំនៀមបុណ្យ, យើងក៏នឹងបានក្រាបទូលព្រះចៅឡាវសៀន ឲ្យទ្រង់ប្រោសព្រះរាជទានបំណាច់ផ្ទាន់ឲ្យដល់សាច់សាលោហិតរបស់អស់អ្នក ឲ្យដល់ខ្មាត, ទោះទាំងទាហានបេងហេកទៀត ដែលបានមកក្ស័យក្នុងទីនេះ ក៏ចូរត្រិះរិះទំកេសេចក្តីសុខទំនុកបម្រុងខ្លួនរបស់ខ្លួន កុំបីមកគុំគួនវិលវល់ ធ្វើឲ្យយើងព្រួយអំពល់តទៅទៀតឡើយ គួរហើយនឹងគិតដល់ព្រះចៅឡាវសៀន ដែលគ្រងរាជសម្បត្តិជាបរមក្សត្រទ្រង់ធម៌ តមកពីបុរាណពង្សប្រវេណី ហើយត្រូវឃើញដល់យើងជាទីមហាឧបការ ដែលមានសេចក្តីសត្យសប្បុរស, ចូរទទួលនូវរបស់ជាគ្រឿងពលិការ ដែលយើងបូជានេះ ហើយចូរវិលវិញទៅកាន់ឋានទីជាទីលំនៅ តាមគាប់អធ្យាស្រ័យចុះ ៗ លុះសូត្រប្រកាសចប់ចុះវេលាណា ខុនបេង ក៏គុជក្រដាស គុជផាវ វាយឃ្មោះ ហើយយំសោកសោរឡោះគាល័យពួកទាហានដែលក្ស័យ តាមសេចក្តីសង្វេគចិត្តក្នុងគ្រានោះ ៗ

ឯពិសាចដែលជាទាហានខុនបេង និងទាហានបេងហេកដែលមកប្រជុំក្នុងទីនោះ ឃើញខុនបេងធ្វើពិការបួងសួងហើយយំសោកដូច្នោះ ក៏

ស្រុះគ្នាយំអាណិតអនាថព្រួចហាំងអឹងកង, ឯព្យុះខ្យល់ និងរលកផង ក៏ស្ងប់ស្ងាត់បាត់អស់ទៅក្នុងខណៈនោះ, ខុនបេនឃើញដូច្នោះ ក៏បង្កើតចិត្តសោមនស្សត្រេកអរ ឲ្យទាហានយកគ្រឿងបែនទាំងអស់ បណ្តែតតាមទឹកទៅ, លុះវេលាព្រឹក ខុនបេនក៏ឲ្យវាយឃ្មោះគោះគងទូងគេរី លើកទាហានចូងផលធី ទៅត្រើយម្ខាង រំលងចូលទៅដល់ស្រុកអេងធៀង ហើយបាត់ឲ្យលីឃីនៅឈររក្សាស្រុកនោះ រួចបង្គាប់បេនហេកថា អ្នកចូរនាំទាហានវិលទៅវិញចុះ, អំណើះតទៅ ត្រូវឲ្យអ្នកខំយកចិត្តទុកដាក់រក្សាសេចក្តីសុខ ឲ្យអ្នកស្រុកបានសេចក្តីសុខសម្រាន្ត ហើយត្រូវឲ្យយកចិត្តសេនាទាហាន ឲ្យរាប់អានស្រឡាញ់ដោយស្មោះ កុំបីឲ្យមនុស្សទាំងអស់បានសេចក្តីក្តៅក្រហាយឡើយ ។ បេនហេក ទទួលឱវាទហើយ ក៏គំនាប់លាត្រឡប់ទៅខែត្រវិញ ។ ឯខុនបេននោះវិញ ក៏លើកទ័ពស្រូតរូតទៅដល់ស្រុកសេឈួន ។

ខណៈនោះ ព្រះចៅឡៅសៀន បានទ្រង់ជ្រាបថា ខុនបេនមានជ័យជម្នះហើយលើកទ័ពត្រឡប់មកដល់ ក៏ទ្រង់មានព្រះទ័យត្រេកសោមនស្សណាស់ ទ្រង់ថេព្រះទីនាំងយានរហ័សចេញទៅទទួលខុនបេន ដល់ក្រៅក្រុង ចម្ងាយផ្លូវ ៣០០ សិន (១២គីឡូម៉ែត្រ), លុះទតព្រះនេត្រឃើញខុន-បេនពីចម្ងាយ ក៏ស្តេចកែក្រាយចុះយានព្រះបាទទៅចាំនៅក្បែរផ្លូវ, ខុន-បេនពិះពេះកួចបរទៅ ក៏ក្រឡេកឃើញច្បាស់ ភ័យណាស់ ចុះពីលើសេះ

ចូលទៅក្រាបថ្វាយបង្គំ ហើយទូលថា ទូលព្រះបង្គំជាខ្ញុំ បានទៅធ្វើសឹក នឹងបេងហេកគ្រោះនេះ ក៏មានជ័យជម្នះ ហើយបានប្រាបប្រាមសត្រូវតាម និគមធំតូច បានកបតាបអស់ហើយ ដែលទូលព្រះបង្គំជាខ្ញុំទៅចំធ្វើការឱ្យ យូរ ពុំបានឆាប់រហ័ស នាំឱ្យព្រះអង្គព្រួយព្រះទ័យទោមនស្ស ព្រោះកិច្ច រាជការនោះ ទោសកំហុសលើទូលព្រះបង្គំជាខ្ញុំទាំងប៉ុន្មាន សូមព្រះអង្គ ទ្រង់អនុញ្ញាត ឱ្យគង់ជាខ្ញុំព្រះរាជការតទៅ ។

ព្រះចៅឡៅសៀនទ្រង់ព្រះបណ្ដាប់ ក៏ចាប់ដៃខុងបេងឱ្យឡើងលើរនេះ ហើយព្រះអង្គក៏ទ្រង់ថេព្រះទីនាំង ត្រឡប់ចូលព្រះបរមរាជវាំងវិញ ព្រះចៅឡៅសៀន ទ្រង់មានព្រះរាជហឫទ័យសោមនស្សប្រីតា ចាត់ឱ្យ រៀបតុល្យៀងភោជនាហារក្នុងទីព្រះបាន បានស្រេច ស្ដេចក៏ឱ្យអញ្ជើញ ខុងបេងមហាឧបរាជ និងសេនាទាហានទៅទទួលអាហារ ហើយទ្រង់ព្រះ ករុណាចែកបំណាច់រង្វាន់តាមគុណានុរូប ។ ខុងបេង ក៏យកគ្រឿងបណ្ណា-ការយ៉ាងល្អៗ សម្រាប់អាណាខេត្តដែលវាយបានទាំង ៣០០ ស្រុកនោះ នាំទៅក្រាបបង្គំទូលថ្វាយ ព្រះចៅឡៅសៀន ហើយក្រាបទូលឱ្យព្រះរាជ-ទានបំណាច់រង្វាន់ ដល់កិរិយាបុត្រព្រួសពលទាហាន ដែលបានទៅស្លាប់ក្នុង សង្គ្រាម តាមគួរសមជាច្រើន, ទាហានទាំងប៉ុន្មាន ក៏មានសេចក្ដីត្រេក អរគ្រប់ៗគ្នា ខំតាំងចិត្តគិតធ្វើរាជការថ្វាយព្រះចៅឡៅសៀន ដោយសុច-រិតអស់ពីចិត្ត ។

ចប់ខ្សែ ៧០ ។

# សាមកុក ទី ៣១

តាំងពីព្រះចៅចូភី បានរាជសម្បត្តិ នាងគុយហេង (ព្រះស្នំ) ធ្វើកលឧបាយជាមួយនឹង តៀវថូ(ខន្ទី) កប់រូបព្រះចៅចូភីក្រោមក្រឡាបន្ទំនាងអៀនស៊ី (អគ្គមហេសី), ព្រះចៅចូភីលុះកល, សម្លាប់នាងអៀនស៊ីស្លាប់, រហូតដល់ខុងបេងវាយបានស្រុកឡាំអ័ន, អងបេងចាប់ខូនហៃហ្វូ-លិមបាន ។

---

ឯព្រះចៅចូភី ហ៊ូតោ តាំងពីមិនទាន់បានរាជសម្បត្តិ កើតបុត្រានឹង នាងអៀនស៊ី ឈ្មោះចូយ៉យ នាងអៀនស៊ីនោះ ដើមឡើយជាកូនប្រសា អួនសៀវ, កាលត្រាចូចូ ទៅវាយបានស្រុកងៀបគុន, ចូភីក៏បាននាងនេះ មកធ្វើជាភរិយា, លុះព្រះចៅចូភី បានរាជសម្បត្តិ ទើបលើកនាងអៀនស៊ី ជាអគ្គមហេសីឯក, ក្រោយមក យកនាងគុយហេងជាបុត្រីគុយហ៊ុយ ធ្វើមហេសីខាងឆ្វេង, នាងនោះរូបល្អ, ព្រះចៅចូភីសព្វព្រះទ័យណាស់, គុយហ៊ុយជាបិតា គិតចង់ឲ្យបុត្រីអាត្មាបានធ្វើធំបណ្ដាច់ ទើបចូលទៅគិត ការសម្រេចនឹងតៀវថូជាខន្ទី ។

តៀវថូគិតថា កុំឲ្យគុយហ៊ុយព្រួយបារម្ភ ព្រោះឥឡូវនេះ ព្រះចៅ ចូភីទ្រង់ព្រះប្រឈួន សូមឲ្យអ្នកគិតកលឧបាយធ្វើរូបព្រះចៅចូភី ហើយ សរសេរឆ្នាំ ខែ ថ្ងៃព្រះកំណើតជាប់ជាមួយនឹងរូបនោះ នាំយកទៅកប់ទុក ក្រោមគ្រែបន្ទំនាងអៀនស៊ី, ខ្ញុំនឹងទៅចាប់ជីកយករូបនោះ ទៅថ្វាយព្រះ ចៅចូភី ៗ មុខជានឹងទ្រង់ព្រះពិរោធ ឲ្យសម្លាប់នាងអៀនស៊ីពុំខាន, បុត្រ

អ្នកគង់ទីងបានជាធំបណ្ដាច់តែឯង, គុយហ៊ុយបានស្ដាប់ដូច្នោះ ក៏យល់ឃើញត្រូវ ទើបចេញទៅធ្វើរូបនោះ ហើយនាំទៅកប់ក្រោមព្រះដំណាក់, គៀវថូគីទៅស្ទាក់ចាប់យករូបនោះ ទៅថ្វាយព្រះចៅចូគី ៗ មិនបានដឹងក្នុងកលឧបាយ ក៏ក្ដៅក្រហាយក្នុងព្រះទ័យ ចាប់ទោសអគ្គមហេសីថា ក្លែងធ្វើព្រះអង្គឲ្យទ្រង់អាពាធ ក៏ត្រាស់ប្រើពេជ្ឈឃាដ ឲ្យនាំនាងអៀនស៊ីទៅប្រហារជីវិតបង់, ហើយទ្រង់តាំងនាងគុយហេងជាអគ្គមហេសី តែនាងនោះមិនមានព្រះរាជបុត្រីបុត្រា ឃើញចូយ៉យជាបុត្រនាងអៀនស៊ី មានតម្រិះប្រាជ្ញាស្រស់ស្រួច ក៏គួបចិត្តគិតស្រឡាញ់ ទើបអស់អញ្ញថ្នមបីបាច់ជាបុត្របណ្ដូលបណ្ដាច់ ដូចកើតពីឧទរ, ចូយ៉យក៏ចម្រើនវ័យបាន ១៥ ឆ្នាំ ចេះចាំវិជ្ជាសិល្បសាស្ត្រឆ្លាត ពូកែខាងបាញ់ធ្នូនិងប្រើអាវុធទាំងពួង ៗ

លុះព្រះចៅចូគី សោយរាជសម្បត្តិ បាន ៧ ឆ្នាំ (ព.ស. ៧៦៩) ដល់ខែផល្គុន រដូវក្ដៅ, ព្រះចៅចូគី ក៏នាំចូយ៉យជាព្រះរាជឱរសចេញទៅប្រពាតព្រៃ ដើម្បីដេញបាញ់សត្វ ជាទីប្រៀបបង្ហាត់វិជ្ជា, បណ្ដាខ្ញុំរាជការទូរពលទាហាន ក៏កៀងបានប្រើសមេនិងកូនចេញមកពីព្រៃ, ព្រះចៅចូគី ក៏ទ្រង់ធ្នូដ៏យបាញ់ទៅត្រូវមេប្រើសស្លាប់, កូនប្រើស ក៏បោលក្រឡាប់រត់សំដៅទៅចំមុខចូយ៉យ ៗ មានចិត្តអាណិតណាស់ ប្រាសប្រែក្រឡេទម្លាក់ធ្នូនៅស្ងៀមមិនបាញ់ ព្រះចៅចូគីជាបិតា ត្រាស់ថា ម្នាលបុត្រសម្លាញ់ ហេតុម្ដេចបានជាបាមិនបាញ់កូនប្រើសដូច្នោះ, ចូយ៉យក្រាបទូលដោយ

ស្នោះថា ប្រើសមេគួន ព្រះបិតាបាញ់មេវាក្ស័យសូន្យជីវិតទៅហើយ ទូលព្រះបង្គំជាខ្ញុំ ឃើញកូនវារស់នៅឡើយ វាក៏គិតភ័យបោលត្រង់មកលើមនុស្សម្នា វាមិនដឹងខ្លាចដោយអំណាចសេចក្ដីអាល័យមេវា ក៏កំព្រាដូចរូបទូលព្រះបង្គំជាខ្ញុំដែរ, ទូលព្រះបង្គំជាខ្ញុំមានចិត្តអាណិតវាណាស់ ទឹងលើកដៃហ៊ានបាញ់មិនបាន សូមព្រះរាជទានទោស ។

ព្រះចៅបូគី បានទ្រង់ព្រះសណ្ដាប់ព្រះរាជទូរស ក៏ទ្រង់ថ្ងស់ព្រះភក្ត្រ ធ្លាក់ព្រះទ័យបង្កើតសេចក្ដីអាណិតរាជបុត្រា រួចធ្នូពីព្រះហត្ថាធ្លាក់ទៅដល់ដី គិតថាបុត្រយើងនៅក្មេងសេចក្ដីក៏មែន តែមានចិត្តគិតមេត្តាសត្វ គួរទឹងគ្រងរាជសម្បត្តិជាម្ចាស់ផែនដីបាន គិតហើយ ក៏ឡើងគង់លើព្រះរាជយានទាំព្រះរាជបុត្រវិលចូលមកព្រះបរមរាជវាំងវិញ, ព្រះចៅបូគី ក៏ទ្រង់តាំងចូយ៉យរាជបុត្រាជាកេងន្ទួនអង គឺស្ដេចតាំងក្រុម ។

លុះដល់ខែអាសាធ ព្រះចៅបូគី ទ្រង់ប្រឈួនធ្ងន់ដោយរោគខ្យល់, ពេទ្យព្យាបាលប៉ុន្មានក៏មិនស្រាក ទើបមានព្រះតម្រាស់ឲ្យហៅចូដិន ១ គាន់កុង ១ សុម៉ាអ៊ុ ១ ដែលជានាហ្មឺនធំ ហើយនឹងចូយ៉យរាជបុត្រ ឲ្យចូលគាល់ផ្គាល់ព្រះអង្គ, ព្រះចៅបូគីទ្រង់ត្រាស់ថា វេលានេះ ខ្លួនយើងឈឺធ្ងន់ណាស់ មើលទៅមុខជាធន់ពុំបាន, ហើយយើងក៏មានសេចក្ដីព្រួយដោយចូយ៉យនៅក្មេងសេចក្ដីខ្លីគំនិត, បើកាលណាយើងអស់អាយុជីវិតទៅ, អ្នកទាំងអស់ធ្លាប់នៅធ្វើរាជការជាមួយនឹងយើងដូចម្ដេច, ចូរ

ជួយឈឺឆ្អាលពលការ រក្សាសេចក្ដីសុខ ទំនុកបម្រុងស្រុកទេស ឲ្យបានរបៀបរាយដោយធម៌, សូម្បីកិរិយាបុត្ររបស់យើងៗ បានឧបត្ថម្ភយ៉ាងណា សុំឲ្យជួយព្យាបាលគេឲ្យយ៉ាងនោះផងចុះ, នាម៉ឺនទាំង ៣ នាក់ បានឮព្រះតម្រាស់ ក៏ទូលហើសតបថា សូមកុំឲ្យព្រះអង្គទ្រង់ព្រះបរិវិតក្កឡើយ ទូលព្រះបង្គំជាខ្ញុំទាំង ៣ នាក់នេះហើយ នឹងតាំងចិត្តធ្វើពលការថ្វាយខ្លួនព្រះតេជព្រះគុណ ដរាបទាល់អស់ជីវិត, ព្រះចៅបូកក៏ត្រាស់ថា យើងបានឃើញហេតុផ:ទីសាគេទុក្ខចិត្តណាស់ ព្រោះខ្លោងទ្វារព្រះនគរជាទីប្រជុំធំឥតហេតុផលអ្វីសោះ ស្រាប់តែបាក់រលុះចុះឯង ឃើញថាខ្លួនយើងនឹងអស់បុណ្យជាក់ស្ដែងប្រាកដក្នុងគ្រានេះ ។

ខណៈនោះ មានពួកខន្ទីចូលទៅទូលថា បូហ៊ីរជានាម៉ឺនធំសម្រាប់កម្ចាត់សត្រូវខាងទិសឯកើត សុំចូលមកគាល់, ព្រះចៅបូកក៏ត្រាស់ហៅឲ្យចូលទៅ ហើយទ្រង់ព្រះកន្សែងពិលាប ត្រាស់សួរបូហ៊ីរថា អ្នកជានាម៉ឺនធំ បានជួយប្រាបប្រាមសត្រូវ តាំងពីស្រុកហ៊ូតោនៅមិនទាន់បានជាទីមាំមួន រហូតមកដល់ទាល់ធំទូលាយត្រឹមនេះហើយ ខ្លួនយើងក៏នៅល្មមនៅឡើយមិនទាន់នឹងដកប៉ុន្មាន ទើបបានតែ ៤០ ឆ្នាំ បានសោយរាជ្យ ៧ ឆ្នាំ ជាផលកម្មនាំឲ្យកើតកេតុធ្ងន់ យើងក៏ឃើញថានឹងគង់នៅតទៅពុំបានទេ, អ្នកនៅឯក្រោយ ចូរជួយទំនុកបម្រុងបុត្រយើងដោយសុចរិត ឲ្យចិត្តយើងអស់ព្រួយវិតក្កផងចុះ, លុះត្រាស់ចប់ព្រះរាជ

ព្រះចៅចូភ័ក៏ទិវង្គត ។

ចូជិន ១ តាន់កុង ១ សុម៉ាអ៊ី ១ នូវអស់នាម៉ឺនមុខមន្ត្រីតូចធំ ក៏ប្រជុំអញ្ជើញចូយ៉យឲ្យឡើងគ្រងរាជសម្បត្តិ តាំងនាមក្សត្រជាព្រះចៅតៃង៉ុយហង់តេ (ព.ស. ៧៧១), លុះព្រះចៅចូយ៉យសោយរាជសម្បត្តិជាក្សត្រាធិរាជ ក៏ទ្រង់ឲ្យអំណាចលើកលែងមនុស្សទោសក្នុងគុកទាំងអស់ ហើយទើបចាត់ចែងតែងការព្រះបរមសពព្រះចៅចូភី ជាបិតាតាមប្រពៃណី, លុះធ្វើស្រេច ស្តេចក៏តាំងនាម៉ឺនមុខមន្ត្រីឲ្យឡើងយសសក្តិ តាមថ្នាក់តូចធំជាលំដាប់ ត.ម.ដែលមានគុណ ត.ប់ក្នុងរាជការ ហើយទ្រង់មានព្រះតម្រាស់ទឹងសុម៉ាអ៊ីថា ស្រុកសេលៀងនោះ ជាប់ជិតគ្នានឹងស្រុកសេឈួន ជាស្រុកមុខសឹក លុះតែមានអ្នកប្រាជ្ញដ៏អធិកជ្រៅជ្រះ មានតបះក្បៀវក្លាហាន ទើបបានទៅនៅរក្សាខាប់ខ្ជួន ។ សុម៉ាអ៊ីបានឮព្រះតម្រាស់ ក៏តែងរៀងក៏ក្រាបទូលថ្វាយ សុំចេញទៅយកអាសានៅរក្សាស្រុកសេលៀង ។ ព្រះចៅចូយ៉យ ក៏យល់ព្រមចាត់សុម៉ាអ៊ី ឲ្យចេញទៅនៅស្រុកសេលៀង ។

(នៅមានត)

# រឿង
# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក ក៉ាប៊ិដ្រូ ណាត តាម៉ារ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ២៩

នាងកាមាលានៅក្មេងណាស់ ម្ល៉ោះហើយទុក្ខព្រួយ មិនសូវនៅត្រាំក្នុងបេះដូងនាងបានយូរពេលទេ ឲ្យតែមានឱកាសល្អបន្តិច នាងភ្លេចទុក្ខភ្លាម ។

រាល់ព្រឹក អ៊ុយមេស្ហតែងយកបន្លែពីចំណតកប៉ាល់មកឲ្យនាង ។

— លោកមា មើលត្រសក់អីល្អម្ល៉េះ សណ្ដែក ថៃថាវ អីក៏ល្អៗ ណាស់ដែរ ប៉ុន្តែកមេស្ហមិនដែលពេញចិត្តទេ ព្រោះគេចេះតែមានចិត្តសង្ស័យថា: កុមារកំព្រាលួចបេះដំណាំអ្នកស្រុកដូចមុនទៀតហើយនាងកាមាលាខឹងក៏ប្រាប់ថា: ។

— នែបង! កុំចេះតែថា ខ្ញុំរាប់លុយឲ្យវាទៅទិញគេនឹងដៃខ្ញុំណា! ។

— ឱ, ហ្នឹងរឹតតែបានលួចពីផ្ទះទៅទៀត, វាលួចយកលុយដែលអូនឲ្យហើយ, វាលួចដំណាំគេទៀត ។

ដើម្បីនឹងដេញដើងកុមារកំព្រា រមេស្ហសួរថ្លៃបន្លែ ប៉ុន្តែគេគិត

មើលទៅនៅតែឃើញថាប្រាក់ដែលចាយនោះ មិនទាន់សមនឹងរបស់ដែលបានមកសោះ ព្រោះឃើញដូចជាថោកពេក ៗ អ៊ុយមេស្ហមិនសប្បាយចិត្តនឹងគេដេញដោលក៏ឆ្លើយថា ៗ

— បើខ្ញុំចេះគិតលុយកាក់ត្រឹមត្រូវ ខ្ញុំមិនមែននៅទីនេះទេ ម៉្លេះខ្ញុំទៅធ្វើជាមេហាងបាត់ទៅហើយ មែនទេលោកតា ?

— ណ្ហើយកុំនិយាយ ចាំបាយហើយស៊ីមដដែក (លោកតានិយាយ) ឯសណ្តែកវិញខែនេះមានទៅស្រូវរកឯណា ថែមទាំងនៅក្នុងស្រុកដែលយើងមិនស្គាល់គេផងនោះ ប៉ុន្តែណ្ហើយ កុំខ្វល់អ្នកណាថាអីថាទៅរកមនុស្សឯណាឲ្យចេះរករបស់ដែលយើងត្រូវការឲ្យបានទាន់ចិត្តដូចវាហ្នឹង ៗ

ពេលមេស្ហឮតានិយាយកាន់ជើងក្មេង ស្ងប់ខ្មាសមាបន្តិចទៅទៀត តែតាតរឹងណាស់ គាត់នៅតែចចេសទៀត ៗ

វាជាក្មេងខូចប្រាជ្ញា បើគ្នាខំប្រមូលបានបន្តិចបន្តួចហើយយើងបន្ថប បង្អាក់ទៅទៀត ក្រែងបានស្តាយក្រោយ មុននឹងយើងទៅដល់ទីដៅនៃអ៊ុយមេស្ហ យកបន្ទុទៅលាងទៅកុំនៅស្តាប់អី ៗ

តែកាលណាពេលមេស្ហស្ងប់ខ្ទាស អ៊ុយមេស្ហរត់ទៅជិតនាងកាមាលាភ្លាម ហើយបើតាំងតែពីបានមាយើងចូលថែមមក នាងកាមាលាកាន់តែបានគ្នាច្រើនគ្រាន់នឹងនិយាយលេងនៅពេលធ្វើការ ទុកឲ្យពេលមេស្ហនៅប្រឆ្នូវក្រពើតែឯងមួយថ្ងៃវាល់ៗណ្ហក ការស៊ុំនិស្ហាលរវាងមា អ៊ុយ-

មេឃ ទិននាងកាមាណាក៏ កាន់តែមានសភាពជិតឡើងមួយថ្ងៃបន្តិច ៗ ប៉ុន្តែបុរសយើងនៅតែមានកិរិយាបែបធ្ងន់ទឹងថ្កល់ វិស័យដូចនាគដែលមានជម្រៅបាតស៊ីទឹកជ្រៅពេក មិនហ៊ានចូលទៅក្បែរច្រាំងខ្សាចគៀន ហើយត្រូវតែបោះយុថ្កាកណ្ដាលទន្លេតែម្នាក់ឯង ឯចំណែកទូកតូចៗដទៃ គេចេះតែចូលទៅ ទោះជាទឹករាក់យ៉ាងណាក៏ចេះតែទៅរួចទាំងអស់ ៗ

ព្រឹកមួយនោះ ពេលអ្នកដំណើរក្រោកចេញពីដំណេកមក ផ្ទៃមេឃមានសុទ្ធតែផ្ទាំងពពកស្អាប់បាំងជិត រសាត់លឿនស្ទើរពីជើងមេឃម្ខាងទៅជើងមេឃម្ខាង ទឹកភ្លៀងធ្លាក់ចុះមួយពាំមេត បន្តិចព្រះអាទិត្យក៏បើកឡើងវិញ ដោយខ្យល់ខ្លាំងបក់ផាត់ពពក ទឹកហូរដោយជុំៗនៅក្នុងផ្ទៃទន្លេ ទូកតូចតាចៈលាតរលកក្ដឹបក្ដែត ៗ គួរឲ្យភ័យរត់រកច្រាំង ពួកអ្នកភូមិស្រីៗដែលចុះមកដងទឹកកំពង់យកទៅប្រើប្រាស់ មិនហ៊ានបង្អែរបង្អង់យូរឡើយឯផ្ទៃទន្លេក៏រញ្ជួយហាក់ដូចជាគេអង្រួន រីឯកប៉ាល់ក៏ចេះតែបន្តដំណើរជាធម្មតា នាងកាមាណាក៏រៀបចំធ្វើបាយតាមធម្មតាដែរ ៗ

— មើលទៅល្ងាចនេះធ្វើអ្វីមិនកើតទេ មេឃមិនស្រលះទេណ៎ា ធ្វើអ្វីធ្វើឲ្យហើយពីព្រឹកទៅ (មានិយាយបណ្ដើរងើយមើលមេឃបណ្ដើរ) ដាក់អង្ករដាក់អីមកចាំជួយ ៗ

ក្រោយពេលបាយល្ងាច ខ្យល់ក៏កាន់តែខ្លាំងឡើង ៗ ព្រះអាទិត្យក៏លិចបាត់ដោយគ្មានអ្នកណាមួយចាប់ភ្នែកសោះ នាងក៏ចូលរកទីសំបតមុខ

ពេលធម្មតា ដោយមេឃមានព្យុះខ្យល់ ។ មិនយូរប៉ុន្មានពត្រីកាលក៏ ១ ម្នាក់ស្បៃ ខ្មៅងងឹតគ្រប់ផែនដីជាមួយនឹងភ្លៀងព្យុះសង្ឃរ ។

ឮខ្យល់ព្យុះខ្លាំង នាងកាមាលាភ័យណាស់ ស្ទុះចេញមករកគេ ឯងឲ្យទៅនៅជិតនាង - ។

— កុំភ័យ កប៉ាល់ប៉ុណ្ណេះហើយភ័យអីទៀត ទៅគេងទៅ ខ្ញុំឥត ទៅណាឆ្ងាយទេ ខ្ញុំក៏មិនទាន់គេងដែរ (ការមេស្ហនិយាយ) - ។

ការមេស្ហចេញផុតទៅ លោកមាពក្រពត្តិចូលមក ។

កុំខ្លាចអីអ្នកនាង ខ្ញុំមិនឲ្យខ្យល់ព្យុះកំណាចនេះ បាស់សក់អ្នកនាង មួយសរសៃបានឡើយ ប៉ុន្តែទោះជាលោកមាយើងខំអួតអាងយកខ្លួនពាំង ការយ៉ាងម្តេច ក៏នាងកាមាលានៅតែមិនបាត់ភ័យ នាងខំស្ទុះចេញតាម លោកតូហើយស្រែកអង្វរគាត់ថា: ។

— លោកតូ ! លោកតូ ! ចូលមកអង្គុយជិតខ្ញុំមក អាណិតខ្ញុំ ទៅ លោកមាបែបអស់អែកមិនចង់ហ៊ានចូល ក៏ឆ្លើយតបថា: -

— ទេ អ្នកនាង ពេលនេះជាពេលដែលអ្នកនាងនឹងលោកប្រុសត្រូវ សម្រាន្ត ខ្ញុំត្រូវតែ . . . (លោកមានិយាយបណ្តើរ ឈានជើងចូល បណ្តើរ) លុះគាត់មើលទៅមិនឃើញការមេស្ហ គាត់ឆ្ងល់ ហើយសួរនាងថា:

— លោកប្រុសទៅណា មេឃអាក្រក់យ៉ាងហ្នឹងលោកចេញទៅក្រៅ ធ្វើអី ?

ឮស្នូរមាត់លោកគ្រូ កាមេស្ហក៏ងើយពីបន្ទប់ខ្លួនមក លោកគ្រូហាល ក្នុងរកសម្លេង ឃើញកាមេស្ហដេកលើគ្រែកើយខ្នើយយ៉ាងខ្ពស់ កំពុងតែមើលសៀវភៅ ។

— លោកអើយ ប្រពន្ធលោកមិនហ៊ានទៅតែឯង ម្ដេចក៏លោកនៅចាំមើលសៀវភៅអ៊ីម្ល៉េះ ម្ដេចក៏មិនទុកសិនទៅ ?

ឮពាក្យមានិយាយទីងកាមេស្ហ នាងកាមាលាខឹងហោស់ទប់មិនបាន នាងចាប់ដៃលោកមាគូសថយក្រោយ ។

— ទេលោកគ្រូ លោកគ្រូមានប្រសាសន៍អ៊ីអ៊ីចឹង ពេលនោះខ្យល់ព្យុះខ្លាំងណាស់ លប់បាត់សម្លេងនាងកាមាលា កាមេស្ហស្ដាប់មិនឮ ឮតែមាត់លោកគ្រូ គាត់ធ្ងល់ ហើយងាកមកមើលមុខនាងបែបស្រឡាំងកាំង ។ កាមេស្ហដាក់សៀវភៅចុះ ដើរតាមមក ។

— មានការអ៊ីហ្នឹង ម្ដេចក៏ . . . .

- ទេ!ទេ! ឥតមានការអ៊ីទេ (នាងឆ្លើយតបដោយមិនងើបមើលមុខកាមេស្ហសោះ) ខ្ញុំចង់ឲ្យគាត់មកនិយាយលេងទីងខ្ញុំ ហើយគាត់ស្មានថាខ្ញុំខ្លាច ប៉ុន្តែសំដីនាងធ្វើឲ្យកាមេស្ហយល់ថា "បើប្រសិនជាអ្នកយល់ថាខ្ញុំត្រូវការអ្នកដើម្បីមកនៅជិតខ្ញុំ នោះច្បាស់ជាខុសហើយ ខ្ញុំមិនបាច់ត្រូវការអ្នកណាមកកំដរខ្ញុំទេ" នាងនិយាយទៅកាន់លោកមាថែមទៀតថា:

—យប់ជ្រៅណាស់ហើយ លោកមាអញ្ជើញទៅសម្រាន្តចុះ ហើយ សូមលោកមាជួយមើលអ៊ុយមេស្ហផងមើល ក្រែងវាខ្លាចព្រោះខ្យល់ខ្លាំង ណាស់ ។

— ខ្ញុំឥតខ្លាចអ្វីទេ ម៉ែ ។

នាងក្រឡេកតាមសម្លឹងទៅ ឃើញក្មេងកំព្រានៅអង្គុយកៀនទ្វារ ញ័រទទ្រើត នាងស្ទុះទៅជិត ហើយស្រែកឲ្យថា „យីមើលហ្ន៎ ទទឹក ជោក ក្មេងចំកួតនេះ„ ។

—ទៅ ? នៅដេកក្នុងបន្ទប់ជាមួយលោកមាទៅ អ៊ុយមេស្ហក៏ក្រោក ដើរតាមក្រោយលោកមាទៅ ភមេស្ហនៅតែឯងជាមួយនឹងនាងកាមាលា អ្នកសួរទៅនាង :

—អូនចង់ឲ្យបងនៅនិយាយលេងជាមួយអូនទំរាំអូនងុយគេងទេ ?

—ទេបង ខ្ញុំអរគុណហើយ ខ្ញុំងុយគេងហើយ ។

គ្រាន់តែឮចម្លើយនាង អ្នកយល់ដល់ជម្រៅចិត្តនាងទៅហើយ តែ អ្នកមិនរកមធ្យោបាយនឹងទាញមកវិញទេ ព្រោះនាងមានខមាន ចិត្តមិន ព្រមសារភាពថាខ្លួនស្រឡាញ់ ហើយត្រូវការអ្នកឡើយ អ្នកក៏ដើរចូល ទៅក្នុងបន្ទប់អ្នកទៅទុកនាងឲ្យនៅក្នុងភាពអន្ទះអន្ទែង គេងក៏ពុំលក់ តែ ទំនៅសម្ងំស្តាប់សូរខ្យល់ព្យុះពេកពោកបក់ទាន់តែខ្លាំង ក្រុមនាវិកក៏គ្មាន

អ្នកណាមួយផេកដែរ ពេលស្ងប់ម្តងៗ ឮស្នូរតែសម្លេងខ្សែរស្ពាប់ពង សម្លេងចញ្ជារបស់លោកនាក់ប្រមុខ នៅក្នុងបន្ទប់គ្រឿងចក្រ ។ នៅពេលមានខ្យល់ព្យុះខ្លាំងបែបនេះ យុក្ដាតែម្យ៉ាងមិនអាចទប់កប៉ាល់ឲ្យហ្នឹងបានទេ ទាល់តែប្រើគ្រឿងចក្រឲ្យដើរបន្តិចៗផង ទើបបាន ។

លុះក្បៀងទឹងខ្យល់ស្ងប់បន្តិចទៅ នាងកាមាលាក៏ក្រោកចេញមកខាងក្រៅ ខ្យល់នៅមានសន្ទុះខ្លាំងនៅឡើយបក់រំលាលប់បញ្ចេញស្នូរ ៗប៉ី ដូចសម្លេងថ្ងូរនៃផែនឈឺចាប់ ហើយមើលទៅផ្ទៃមេឃ ព្រះច័ន្ទចំត្រជរបញ្ចេញរស្មីក្រស្រអាប់តាមចន្លោះដុំពពក ដែលបេះតែរសាត់លឿនស្ទៅរំសាយដូចគេចង ងាកមើលទៅក្រោយ ឃើញតែផ្ទៃខៀវងងឹតជាប់ពីទឹកទៅមេឃ នាងកាមាលាឈចណ្តែតអារម្មណ៍តែម្នាក់ឯងដូចជាសប្បាយបន្តិច ដូចជាព្រួយបន្តិច ។

## វគ្គទី ៣០

លុះភ្លឺស្វាងឡើង ព្យុះខ្យល់ក៏ស្ងប់ផង លោកមាចក្រពត្តិក្រោកពីព្រលឹម ហើយដើរចូលទៅមើលពេទ្យ ៗ លុះឃើញអាអ៊ើពកចូលទៅ អ្នកព្យុះងើបក្បាល តែលេះតាយាយលាក្រោចថាពេទ្យកុំបានមិត្រជាមួយប្រពន្ធទេ ពីយប់មិញនេះ ។ តែដើម្បីកុំឲ្យអាស្វរក្អាន់ ពេទ្យចាប់

និយាយមុខក្រាម ។

— យី ! ថ្ងៃនេះអ័ព្ទអួរណាស់ លោកមាសម្រាន្តបានឬទេ ?

ទ ! លោកកាមេស្ហ ខ្ញុំចំណាស់នេះហើយខ្ញុំមិនមែនមិនញាប់ដោះស្រាយបញ្ហាស្រុកស្នាញទេ លោកឃើញខ្ញុំចេះតែនិយាយប៉ប្រូចប៉ប្រូចដូចមនុស្សលីលាហើយតិចណាស់ដែលថា ខ្ញុំរកផ្លូវចេញមិនរួចអំពីបញ្ហាទាំងនោះ ប៉ុន្តែមនុស្សបែបលោកខ្ញុំមិនទាន់ដែលជួបនៅឡើយទេ ។

ញូតែប៉ុណ្ណោះកាមេស្ហថ្ងាស់ទឹកមុខមួយរំពេច តែអ្នកខំសើចហើយ. និយាយបន្ទប់ក្បាមថា :

— មើល់លោកមា បើសិនជាខ្ញុំស្រាយបញ្ហាស្រុកស្នាញរបស់ខ្ញុំមិនរួច តើជាទោសឧកក្រិដ្ឋប៉ុយ៉ាងណា ? មានការខ្លះយើងមើលឃើញតែពីសំបក មិនដឹងជាមានការគាថិកប៉ុាំងយ៉ាងម្ដេច លោកមាកុំប្រញាប់តែដាក់ទោសឲ្យខ្ញុំពេក ។

— ត្រូវ ហើយលោក ប៉ុន្តែសូមលោកជ្រាបថា ចុះបើគេមិនទុកចិត្តយើង ទោះជាយើងខំចង់យល់ការរបស់គេយ៉ាងណាក៏ទៅពុំរួចដែរ ព្រោះមនុស្សខ្លះគ្រាន់តែស្គាល់ក្បាម ហាក់ដូចជាមានការស្និទ្ធស្នាលតែនៅយូរបន្តិចទៅ ស្រាប់តែចេញជាបញ្ហារាយមិនបែកតែម្ដង ។

លោកកាមេស្ហ បើប្រសិនជាលោកត្រិះរិះបន្តិចទៅ លោកនឹងមិនប្រកាន់ចឹងនឹងខ្ញុំទេ

— គឺព្រោះតែខ្ញុំបានគិតច្រើនដែរហើយបានជាខ្ញុំមិនខឹង ប៉ុន្តែខ្ញុំសូមជម្រាបមាថា ទោះខ្ញុំខឹងក្តី មិនខឹងក្តី ទោះលោកមាអន់ចិត្តនឹងខ្ញុំក្តី មិនអន់ក្តី បញ្ហាស្ត្រីស្នាញក៏នៅតែមាន មិនដឹងជាលាស់ពេលទៅណាឲ្យផុតបានទេ ៗ

មុនដំបូងកាមេស្ហគិតថា ការចងមិត្រជាមួយនឹងតាចាស់នោះមុខជាមិនឥតប្រយោជន៍ដល់អ្នកទេ ព្រោះអ្នកត្រូវការតាំងទីលំនៅ នៅ ghazidour (គ្ហាស៊ីបូរ) ដែលជាស្រុកដែលអ្នកមិនដែលស្គាល់សោះ តែឥឡូវនេះអ្នកយល់ថាការចងមិត្តនឹងតានេះនាំឲ្យវិនាសដល់អ្នកទៅវិញទេ ព្រោះគាត់បេះតែចង់ដឹងការពិតរបស់អ្នកគិត ហើយអ្នកក៏សម្រេចចិត្តថា ត្រូវតែទៅរកនៅទីកន្លែងណាដែលគ្មានគេស្គាល់ ទើបសុខ ៗ

លុះជិតទៅដល់គ្ហាស៊ីបូរី កាមេស្ហនិយាយទៅកាន់លោកមាចក្របត្តិថា: ៗ

— មើលទៅ ខ្ញុំទៅបើកការហោល័យមេដារីនៅស្រុកលោកមាមិនកើតទេ ខ្ញុំចង់ចុះរហូតទៅបេណារេសតែម្តងហើយ ៗ

—លោកក្តួយគឺភក្តីគិតឲ្យស្រេចតែម្តងទៅ កុំម្តងទៅនេះ ម្តងទៅនោះ ដូច្នេះមិនកើតទេ . . . . ៗ

ក្រោយបន្តិចមក លោកតាយើងក៏ទៅរៀបចំបាយ ដើម្បីនឹងចុះ ៗ នាងកាមាលាសួរគាត់ថា:

លោកមាមិនស្រួលខ្លួនឬបានជាមិននិយាយលេងនឹងខ្ញុំសោះ ឮសម្ដីចំអកសរបស់នាងកាមាលាលោកទឹកភ្នែកញ៉ែកតបទៅវិញ ។

–កុំថែរជាបោចជាក់កំហុសមកឲ្យខ្ញុំទៅវិញនោះ បើយកខ្ញុំមកបញ្ជរ បោលឲ្យខ្ញុំរត់ទៅរកនាងដូចម្ដេច (លោកមានិយាយបណ្ដើរងើបមើលមុខនាងបណ្ដើរ) ប៉ុន្ដែលុះមើលទៅឃើញនាងធ្វើឡេងឡង់ គាត់ក៏សួរបន្ថែមថា: ចុះនាងមិនដឹងថានាងត្រូវទៅរហូតដល់ Bénarès ទេឬ ?

នាងគ្រាន់តែមើលមុខគាត់ស្ងៀមមិនឆ្លើយ មួយសន្ទុះទើបនាងនិយាយ: ។

– មើលលោកមា ជាក់អ៊ីចឹងមិនស្រួលទេឲ្យខ្ញុំរៀបជូនវិញ ។

លោកមាមិនសូវពួយមាត់សោះ ព្រោះគាត់អន់ចិត្ដនឹងនាងកាមាលាដែលសុខចិត្ដផាស់ទៅចុះឯ Bénarès វិញតាមប្ដី ដោយមិនប្រកែកអ្វីបន្ដិចសោះ គាត់នឹកក្នុងចិត្ដគាត់ថា: “មែនហើយចំណាស់ឯងហើយខំទៅចង់មិត្ដនឹងគេក្មេង ៗ ធ្វើអ្វីទៀត” ។

លោកមាកំពុងគិតក្នុងចិត្ដដូច្នេះ ស្រាប់តែឮសូរមាត់ក្មេងស្មាដើររកនាងកាមាលាដើម្បីប្រាប់ឲ្យនាងដឹងថាមិនចុះទៅ Ghazipour ទេ ទៅចុះឯ Bénarès វិញ ។

–កុំអាលរៀបចំអី បើយើងមិនចុះនៅនេះទេចាំទៅចុះនៅ Bénarès វិញខ្ញុំចូលចិត្ដទៅបើកកន្ទុងគេស៊ីឯណោះវិញមិនពេញចិត្ដទេ ?

-ទេ! នាងឆ្លើយទាំងមិនងើបមើលមុខកមេស្ហផង, ខ្ញុំចុះនៅគ្ហាស៊ីពុរ ខ្ញុំរៀបចំឥវ៉ាន់ ខ្ញុំអស់ហើយ ។

—គិតនៅតែឯងឬ ? (កមេស្ហសួរបញ្ឆាក់បែបស្រងាកចិត្ត ដោយឮនាងប្រកែកដាច់អហង្ការពេក ។

—ចុះមានលោកមាហើយតើ ( នាងងាកមើលមុខលោកមា តែលោកមារគេចខ្លួនឆ្លើយកាត់ភ្លាម) ។

យីចុះមេចមកតាមខ្ញុំទៅវិញ គិតប្តីនាងទីងទីងខ្ញុំ នាងកាមាលានៅតែរឹងថានាងចុះនៅ Ghazipour ដដែល ព្រោះនាងចង់បញ្ចេញឲ្យកមេស្ហដឹងថា នាងមានសេរីភាពពេញបរិបូណ៌ ទីងធ្វើអ្វីទាំងអស់ ព្រោះនាងគ្មានម្ចាស់ចិត្ត ។

ក្នុងកត្រីកាលនោះ ល្ងះខ្យល់ផាត់ពពកខ្មៀនខ្មៅស្អាប់បាត់អស់បញ្ចេញផ្ទៃមេឃស្រឡះឆេង មើលទៅគួរឲ្យស្រឡះចិត្ត ប៉ុន្តែកមេស្ហដែលអង្គុយទស្សនាធម្មជាតិ មានចិត្តខ្វល់ខ្វាយវិស័យដូចសូត្រដំពាក់កេមុខមិនឃើញ ព្រោះអ្នកគិតថា:

ការរស់នៅជាមួយនាងកាមាលា ដោយបន្ទំប៉ាក់ន្តែកអ្នកស្រុកបែបនេះ តែនាងកាមាលាក្តៅក្រហាយ មុខជាកាសខ្ពង់ ទ្រើយបើកសនាលើកនាងដាក់ក្នុងរទ្ធេះដៃឲ្យហើយ ទទួលនាងជាប្រពន្ធទៅចុះម្យ៉ាងទៀតមុខនឹងបានទៅដល់នាងហិមណាលិនី អ្នកត្រូវប្រយុទ្ធយកជ័យ

ដំនះលើសត្រូវមួយគង់យ៉ាងធំសារម្បើម ដើម្បីកុំឲ្យនាងមានគំនិតសង្ស័យលើចិត្តរបស់អ្នក ប៉ុន្តែចុះមានមធ្យោបាយណា ដើម្បីសឲ្យនាងជឿជាក់ថាអ្នកមានគំចិត្តបរិសុទ្ធ បើសិនជាអ្នកគេថ្វេទីងបង្ហាញសេចក្តីបរិសុទ្ធចិត្តអ្នកឃើញ ក៏នៅតែជៀសអាសន្នមិនរួច ចំពោះរូបនាងកាមាលាវិញ គិតទៅគិតមក នៅតែឃើញថាជៀសទទួលនាងកាមាលាជាប្រពន្ធមិនរួច .. ឯចំណែកនាងហិមណាលិនីវិញ បើសិនជានាងនឹកអ្នកតាំងស្អប់ខ្ពើមវិញ នោះជាការប្រសើរទៅវិញទេ ព្រោះមានមនុស្សម្នាក់ទៀត ត្រៀមខ្លួនចាំតែទទួលនាងស្រេចទៅហើយ ។

## វគ្គទី ៣១

— នែ៎! អ៊ុយមេស្ហ! ឯងចុះទៅណាដែរ ។

- ខ្ញុំ ទៅជាមួយម៉ែ ។

— ចុះអញទិញសំបុត្រឲ្យឯងរហូតដល់ Bénarès ហើយតើ អញទីងអ្នកឯងទេដែលត្រូវចុះទៅភ្នាស៊ីប៉ីរនេះ ។

— ទេ ! ខ្ញុំចុះដែរ ខ្ញុំមិនទៅ Bénarès ទេ

កមេស្ហមិនស្គាល់ថាអ៊ុយមេស្ហ ចេះតែតាមអ្នករហូតយ៉ាងនេះទេ លុះព្វាក្នុងនោះឆ្លើយថាខ្ញុំទៅតាមម៉ែ ដែលជួបនៅបន្ទប់រទេះអ្នកទីកង្វល់ ហើយក៏ខ្សឹបសួរនាងកាមាលាថា :

— យើងយកវាទៅជាមួយយើងរហូតឬ ?

— ចុះវាមានអ្នកណា ក្រៅពីយើង ។

— វាមានបងប្អូននៅ Bénarés ដែរទេតើ !

— ប៉ុន្តែវាចូលចិត្តនៅជាមួយយើងជាង ។

នែ ! ស៊ុយមេស្ហ ទៅជិតលោកម៉ាទៅ មើលគេឲ្យមែនទែនណា៎ ប្រយ័ត្នវង្វេង មនុស្សច្រើនណាស់ ។

តាំងពីដើមរៀងមក នាងកាមាលាចាត់ចែងការដូចជាមេផ្ទះ ហើយស្តាប់បង្គាប់មេស្ហហាក់ដូចជាប្រពន្ធ តែការស្តាប់បង្គាប់ត្រូវចប់នៅពេលនេះ ។

ស៊ីមេស្ហកាន់កញ្ចប់សម្បត្តិមួយតូចរបស់វានៅដៃ ចេះតែដើរតាមនាងកាមាលា តត្រកមួយម៉ាត់ក៏មិនស្តី ។

លោកម៉ាយើងមានទីលំនៅតូចមួយនៅចន្លោះក្រុងនិង ភូមិពួកអឺរ៉ុប នៅពីមុខលំនៅនោះមានអណ្តូងមួយធ្វើដោយថ្ម នៅពីក្រោយផ្ទះមានចំការស្វាយ នៅខាងមុខផ្ទះនោះមានសួនបន្លែ ហើយគាត់បានធ្វើរបងដោយថ្មយ៉ាងខាប់ល្អមព័ទ្ធជុំវិញ ។ លោកម៉ាបានទទួលកៀរទាំងបីនាក់ឲ្យនៅសំណាក់ផ្ទះគាត់ជាបណ្តោះអាសន្នសិន ទំរាំរកផ្ទះស្រួលបួលបាន ។

អ្នកស្រីឃាវីតាគីទីជាប្រពន្ធលោកម៉ា ដែលប្តីគាត់តែងតែ [illegible] ប្រាប់នាងកាមាលាថា : គាត់ជាមនុស្សមិនរឹងប៉ឹងទេ ដូចជាមិនមាន

គិនអ៊ីបង្ហាញឲ្យយើងឃើញថា គាត់មនុស្សខ្សោយសោះ ។ គាត់មានបំណាស់ជាងពាក់កណ្តាលមនុស្សទៅហើយមែន តែទឹកមុខគាត់បង្ហាញឲ្យឃើញថា គាត់ជាអ្នកនៅមានកម្លាំងពលំគ្រប់គ្រាន់ ហើយជាអ្នកឆ្លាតផង សក់គាត់មានស្កូវខ្លះតែត្រង់គុម្ពត្រចៀកប៉ុណ្ណោះ ។

កាលដែលគាត់ទើបនឹងរៀបការជាមួយនឹងប្តីនេះ គាត់បានឈឺជម្ងឺគ្រុនយូរពេក ហើយពេទ្យបានប្រាប់គាត់ថា ទាល់តែផ្លាស់ខ្យល់អាកាស ទើបជម្ងឺគាត់អាចស្រាកបាន ហេតុដូច្នេះហើយទើបប្តីគាត់មករកទីកន្លែងនៅក្នុងគ្ហាស៊ីបូរីនេះ ហើយប្រកបរបរជាមេសាលារៀនឯកជន ។

សុខភាពអ្នកស្រីហារីការិនី ក៏បានស្រួលដូចដើមវិញជាយូរដែរមកហើយ ប៉ុន្តែការដែលមកតាំងនៅតែឯងឆ្ងាយពីញាតិមិត្ត ក៏ធ្វើឲ្យអ្នកព្រួយដូចជាមានជម្ងឺប្រចាំកាយដែរ ។

ក្រោយពីបានអញ្ជើញភ្ញៀវឲ្យចូលទៅក្នុងបន្ទប់មួយនៅក្បែររានហាលហើយ លោកម្ចាស់ដើរចូលទៅរកប្រពន្ធគាត់ ដែលកំពុងតែរៀបចានឆ្នាំងហាលថ្ងៃ ទាំងបង្អើរស្រូវនៅក្បែរខ្លួនផង ។

— ឯងនេះបេះតែអ៊ុចឹង ហាមមិនស្តាប់សោះ អាកាសត្រជាក់យ៉ាងហ្នឹងហើយ មកនៅកណ្តាលវាលគ្មានក្រមារមួយគ្របខ្លួនទៀត ។

— អូនមិនត្រជាក់ ? ក្តៅចង់របកខ្លួនទៅហើយមិនគិតទេ ។

— បើអ៊ុំចង់ទិញក្រូសវិញមែនទេ ?

— ហ្នឹងហើយ ចាំខ្ញុំទិញមួយ ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ដឹងថាឯងទៅមានការត្រឹកឃ្យូរម្ល៉េះ ?

—ទ ! មានរឿងវែងណាស់ កុំអាលចង់ដឹង មកនេះសិន មានមិត្តគេមកលេង ហើយយើងត្រូវទទួលគេ ......

មិនមែនទើបតែម្តងនេះទេ ដែលលោកមានាំភ្ញៀវមកឲ្យប្រពន្ធ ប៉ុន្តែមុន ៗ មានមកតែម្នាក់ ៗ ម្តងនេះឃើញគ្នាច្រើន អ្នកស្រីផ្ទុះមាត់ថា :

—យីដល់ទៅបីនាក់ម្ល៉េះ ឲ្យគេនៅត្រង់ណា ?

—ទេ ទៅជួបនឹងគេសិនទៅ រួចសឹមយើងគិតរៀបចំឲ្យគេនៅត្រង់ណា ៗ សិលាទៅណាហើយ ?

—កំពុងតែដួតទឹកឲ្យក្មេង ៗ

បន្ទាប់មកលោកមាក៏នាំប្រពន្ធគាត់ចេញទៅទទួលភ្ញៀវ ។ នាងកាមាលាធ្វើគារវកិច្ចចំពោះស្រីមេផ្ទះតាមអាយុរបស់ខ្លួន ។ អ្នកស្រីមេផ្ទះយកដៃស្ទាបចង្ការនាងហើយ បែរទៅនិយាយនឹងប្តីថា :

—នាងនេះមុខដូចពិចកូនយើងណាស់ ពុកអា !

ពិចជាកូនច្បងរបស់គាត់ ដែលមានប្តីទៅនៅឯកាឡាបាបាដ ។ លោកមាព្រួប្រពន្ធគាត់ថានាងនេះដូចពិចគាត់ស៊ីបខ្ទិប ព្រោះវាគ្មានដូចអ្វី

បន្តិចសោះ ប៉ុន្តែប្រពន្ធគាត់ឲ្យតែឃើញអ្នកណាល្អ ចូលចិត្តតែថាដូចកូនគាត់ ៗ បើសិនជាយកនាងសុីលា មកប្រដូចនឹងនាងកាមាលាឃើញថានៅក្រោមគេទៅហើយ ម្ល៉ោះហើយដើម្បីមានប្រៀបជាងគេ គាត់តែងតែយកមនុស្សដែលគេពុំដែលឃើញមកប្រដូច ដើម្បីបំបាត់មាត់គេ ៗ

– ខ្ញុំមានសេចក្តីរីករាយណាស់នឹងបាននាងមកនៅជាមួយ ប៉ុន្តែ ខ្ញុំខ្លាចតែគ្មានប្រដាប់គ្រប់គ្រាន់ តាមសេចក្តីត្រូវការរបស់នាង ៗ ផ្ទះថ្មីរបស់ខ្ញុំរៀបចំមិនទាន់ហើយ បានជានាំគ្នាមកនៅប្រប្រៀតគ្នានៅទីនេះ ៗ

តាមពិតលោកមាមានផ្ទះថ្មីមួយខ្នងមែន សំរាប់គាត់លក់ដូរ ប៉ុន្តែ ផ្ទះនោះ គ្មានកន្លែងនៅស្រួលបានទេ លុះលោកមាយើងឮគាត់ប្រពន្ធអួតប្រាប់គេថា មានផ្ទះថ្មី ធ្វើមិនទាន់ហើយគាត់ចង់សើច តែគាត់មិនបន្ទុចបង្អាក់ប្រពន្ធគាត់ទេ រួចគាត់ងាកទៅនិយាយនឹងនាងកាមាលា :

ខ្ញុំសង្ឃឹមថានាងនឹងមិនទាស់អំពីការខ្វះខាតនេះទេមែនទេ? ឯណាបារ៉ី ឯងល្អណាស់ត្រូវការកន្លែងជ្រក ហើយព្រះអាទិត្យមិនមែនផ្តល់ផលល្អដល់ឯងទេ

បារ៉ីហើយគាត់ក៏ចេញទៅតែកមេស្រា ទុកអ្នកស្រីបារីកាកិទទៀននៅតែពីរនាក់នឹងនាងកាមាលា ៗ ឆ្លៀតឱកាសស្ងាត់នោះ អ្នកស្រីចង់ដឹងណាស់ពីដំណឹងស្នេហ៍ :

— លោកប្តីនាងធ្វើជាមេឃុំឬ ? លោកធ្វើប៉ុន្មានឆ្នាំហើយ ? មួយខែៗបានចំណូលប៉ុន្មានទៅដែរ ?

ចា៎! លោកពុំទាន់បានធ្វើទៅឡើយទេ? បើអ៊ីចឹងលោករកបរធ្វើទៅ? ឪពុកម្តាយលោកទុកទ្រព្យសម្បត្តិច្រើនឬ? មើលតែនាងមិនដឹង? ដូចជាអស់សំណើច មើលទៅជាមិនដឹងរឿងអ្វីពីគ្រួសារប្តីនាងទៅវិញ គេឲ្យនាងមួយខែប៉ុន្មាន សំពត់ចាក់ប៉ុន្មានផ្ទះសម្បែង? នាងគ្មានម្តាយក្មេក មុខជាត្រូវធ្វើការស៊ីខ្លួនឯងទាំងអស់ហើយ នាងនៅក្មេងយ៉ាងនេះមុខជា ធុញទាល់ហើយ ប្តីពួកកូនស្រីខ្ញុំ គេប្រគល់ប្រាក់ដែលគេរកបានទាំងប៉ុន្មានឲ្យកាន់ទាំងអស់ . . . ។

លុះឮសំដីនិយាយកៀកកៀបសួរគ្រប់តែពីស្ត្រីជាមេផ្ទះ នាងទើបឃើញថាខ្លួននាងគ្មានលក្ខណៈជាមេផ្ទះសោះ បើសំគាល់ឃើញការរស់នៅសព្វថ្ងៃជាមួយនឹងកោះទេ ព្រោះថា នាងគ្មានដឹងអ្វីពីគេទាំងអស់ទាំងអតីតប្រវត្តិរបស់គេ ទាំងរបបរបស់គេ ទាំងគ្រួសាររបស់គេ ក៏នាងមិនស្គាល់ លុះនឹកឃើញដូច្នេះ នាងនៅជាភៀនកន្ទើបមួយវាតមិនរួច ។ ឃើញនាងមិនសូវតបនឹងពាក្យ ក្មួយស្រីនោះនៅតែសួរថែម? មើលក៏ផងដែរ [illegible] នាងបានប្តី! នាង [illegible] ប្តីកូនស្រីខ្ញុំគេទិញ [illegible] ដើម្បីនឹងទិញ [illegible] ឲ្យប្រពន្ធគេពីប៉ុន្មាន. . . . [illegible]

មក សំនួរក៏ត្រូវដាច់ ៗ ក្មេងស្រីតូចនោះ មានអាយុប្រហែលជាពីរឆ្នាំ គឺជាកូននាងសិលាជា ។ នាងសិលាជាមានមុខមាត់មិនល្អប៉ុន្មានទេ នាងមានសម្បុរខ្មៅ តែនាងមានទឹកមុខស្រស់បស់ ហើយមានថ្ងាសទូលាយ ៗ

ចំណែកគ្រូមីជាកូននាងសិលាជា នាងក្រឡេកមើលភ្ញៀវ ហើយនិយាយទៅកាន់នាងកាមាលាថា:

„ ជំរាបសួរអ្នកមីង „ ៗ នាងគ្រូមីដែលហៅនាងកាមាលាថាអ្នកមីងនោះ មិនមែនមកពីឃើញនាងដូចម្ដាយមីងវាទេ គឺមកពីនាងតូចនេះមានទម្លាប់ដូច្នេះ គឺថាឲ្យតែឃើញស្រីណាបែបសមរម្យក៏ហៅមីងទាំងអស់ ៗ

អ្នកស្រី ហារីកាតិទី ជយទៅរៀបចំកន្ទេលជូនភ្ញៀវ ៗ នាងសិលាជាក៏ដឹកដៃនាងកាមាលាចូលទៅក្នុងបន្ទប់ខ្លួន មិនយូរប៉ុន្មានស្រីទាំងពីរនាក់នោះក៏ស្និទ្ធស្នាលនឹងគ្នា ដូចជាមិត្តចាស់យូរមកហើយ ៗ ថ្វីបើនាងសិលាជាមានអាយុច្រើនជាងនាងកាមាលា ប៉ុន្តែនាងកាមាលាមានគំនិតទូលាយ ហើយមានយោបល់ល្អសមរម្យដូចមនុស្សមានវ័យច្រើន ៗ ការដែលមានគំនិតទូលាយបែបនេះ ប្រហែលជាមកអំពីនាងមិនទាន់ដែលត្រូវមាន [illegible] មើលទៅ ៗ ព្រោះនាងមិនទាន់ [illegible] :

" នៃ [illegible] ធ្វើការដែលគេបង្គាប់ឯនេះ" ឬក៏ថា :

[illegible] ហេតុដូច្នេះហើយបាន

ជានាងហ៊ានឈមមុខគេសព្វមនុស្ស ដោយមានឫកពារក្រអឺត បីដូចបុប្ផាមួយទងដែលបញ្ចេញសម្រស់បប្រិមនៅចុងទងយ៉ាងខ្ពស់លលៃ ។

ក្រោយពីការស្ងៀមស្ងាត់បន្តិចមក នាងសិលាក៏ចាប់ពប់រៀបអំពីប្ដីនាងឈ្មោះប៊ីពីន ដែលធ្វើការនៅកេងស្គាកៀន ។ លោកមាយ៉េងមានកូនស្រីតែពីរនាក់គត់ នាងបងបានទៅតាមប្ដី ឯនាងប្អូន ដើម្បីកុំឲ្យនាងចេញទៅឆ្ងាយអំពីគាត់ គាត់សុខចិត្តឲ្យនាងទៅបុរសម្នាក់ក្រ ហើយសុខចិត្តទទួលផ្គត់ផ្គង់គ្រួសារកូនគ្រប់បែបយ៉ាងទាំងអស់ កុំឲ្យតែចេញពោលគាត់ ។

(នៅមានត)

# កម្រងទំនុកបុរាណខ្មែរ

សហ. លី-ធាមតេង ប្រមូលប្រែង

## [ តពីលេខមុន ]

ក្នុងទស្សនាវដ្ដីលេខមុន យើងបានបង្ហាញទំនុកបុរាណខ្លះជាទំនុកបែបច្រៀងឆ្លើយឆ្លង ប្រុស-ស្រី [illegible] តាមសៀវភៅខ្លះដែលតម្កល់នៅពុទ្ធសាសនបណ្ឌិត្យ ។ ដោយហេតុនេះ យើងសូមបង្ហាញតទៅទៀត នូវទំនុកប្រភេទដូចគ្នា ហើយយើងរង់ចាំការជូននូវអត្ថបទជាកំណត់ចងចាំទំនុកច្រៀងពីគ្រប់មជ្ឈដ្ឋានអ្នកអានរបស់យើង តាមសេចក្ដីអំពាវនាវរបស់យើង ដែលបានផ្សាយក្នុងលេខមុនរួចហើយ ។

### ទំនុកខ្លះៗ ដែលយើងប្រមូលបានដោះ ដូចតទៅ :

ប្រុស- ចង្កាដៃកក្ដក    គ្រាប់ដៃបរិភោគ
ស្រីដែលបងនឹងលែង    ប្រុះខែម៉ែខែណា ។
បានៈទៅស្អាតប្រែ    ប្អូនកចង្ការ
បានទៅទានណា    បងលិស្នាតាម ។
ក្រាងប្រុំហាត្ថ    ព្រួញប្រុំបំតាម
[illegible]
ដើងបងកែរម៉ែ    ភ្លេកបង់ភ្លើ

ដើរតាមដងព្រៃ ផ្លូវឆ្ងាយទូរគម ៗ
បានដល់មាត់ព្រែក ក្អែខ្ញកកយំ
ដើរដល់ដើមក្តុំ ក្អៈសេកនិយាយ ៗ
ក្អសូរល្វើយ ៗ ដោយតាមព្រះពាយ
មាត់សេកនិយាយ ហាកសោមូងស្រី ៗ
សំឡៀងទឹកហូរ រាករំជួយភ្ញី
បងស្រវៃមើញស្រី ហាក់ថ្លៃនះនិងក ៗ
បងឈានដើមដើរ ខ្ញុំស្ទះស្មែងរក
តាមដោយជ្រងព្រែក ចិត្តបងសែនខ្វល់ ៗ
បងផ្ដាំតាមទឹក ទឹកហូរមិនដល់
បងផ្ដាំតាមខ្យល់ ខ្យល់ឥតវិញ្ញាណ ៗ

(តាមការចងចាំរបស់ សមា. ព្រួច - ភុម)

(ប្រុស)- ផ្គរលាន់ឮសាន ព្រានទៅអង្គុយ
ស្រីយកប្ដីគ បានបុណ្យដល់ចាស់ ៗ
(ស្រី) ស្រីណាកាចា ស្រីហ្នឹងកម្រកាស់
បានបុណ្យដល់ចាស់ បានបីឡូបៅចិន ៗ

×

កាប៉ិចៗអើយ ក្តិចទ្រយល្ហុង

សន្ទូមន្ទូង ជូនបាយអាចាំង

អាចាំងៗអើយ ដេកកៀនជញ្ជាំង

ត្អឹកក្តុងក្តាំង កាប៉ិចរលូក

×

(ម៉ែ)- កាតុបម៉ែអើយ ម៉ែឲ្យចាំតា

រស់ទៅណា តាស៊ីស្រូវអស់

(ក្មេង)- អ្នកម៉ែឪកូន កូនទៅកាប់ឧស

ចំបាប់នឹងប្រុស ហាក់ព្រមួយល្វែង ៗ

បើម៉ែមិនជឿ ទៅសួរជូនប្រែង

ដំបូកដើមស្នែង កន្ទុងក្តៅៗ ៗ

(តាមការចងចាំរបស់អ្នកស្រី ពេជ - សល់)

ស្រអែមខ្មៅស៊ើរ ស្រអែមខ្មៅស៊ើរ

បងបាំងដៃមើល ស្រអែមមានទ្រូង ៗ

កុកហើរលើមេឃ លែងគីជាប់ផង
ស្រអែមមានខ្ទង់ លែងគីដៃបង ៗ
ស្រអែមខ្មៅម៉្ដ ស្រអែមខ្មៅម៉្ដ
មេកងឡើងកក់ ស្រអែមរៀបខ្លួន ៗ
រៀបចាំងកន្ទេលចិន រៀបចាំងកន្ទេលយួន
ស្រអែមរៀបខ្លួន ទទួលមេកង ៗ
ស្រីតាបក្រមែ ស្រីតាបទ្រមែ
ដើរដោយក្ដីស្រែ ស្រដែងបាំងបាត់ ៗ
បងមានស្មារតី បងរត់ទៅស្កាត់
ស្រដែងបាំងបុះគ បាត់ខ្មៅបងហើយ ៗ

×

ប្រុស- បារីបងបាច់ ស្វារវេចកន្សែង
សង្សារបងមិនលែង ស៊ូរៃបងប្រពន្ធ ៗ
ស្រី- បារីបងបាច់ ស្វារវេចកន្សែង
បើបងបងលែង ជូនប្អូនទៅម៉ែ ៗ
បងទៅស្រុកក្រុង ប្អូនទៅស្រុកស្រែ
ជូនប្អូនទៅម៉ែ ទៅស៊ីក្ដាមខ្យង ៗ

×

ប្រុស- សារិកាកែវអើយ　　សារិកាកែវកើប
បងលោមឲ្យស៊ើប　　គ្រាន់មើលជើងឆ្មេញ ៗ
បងមើលជើងសក់　　រត់ផ្លូវរមេញ
បងមើលជើងឆ្មេញ　　ឆ្មេញត្រឹមខ្មៅស្រិល ៗ

×

ស្រី- អ្នកប្រុសខ្លួនលទ់　　អ្នកប្រុសខ្លួនលទ់
ខ្លួនឥតប្រពន្ធ　　ឆាកស្វាដៃឯង ៗ
ឆាកទៅឆាកមក　　ដូចគេប្រវែង
ឆាកស្វាដៃឯង　　ប្រណាកមុតដៃ ៗ

×

ប្រុស- ស្រឡាញ់សក់ជ្រង　　ដូចទងពោត
ស្រឡាញ់សក់ធ្មាត់　　ដូចសក់សារិកាកែវ ៗ
ស្រីសដើរមុខ　　ស្រីខ្មៅដើរក្រោយ
ផានណាណាគឲ្យ　　សំពោងផ្កាឫស ៗ
ទាំងពីរនាក់អើយ　　ខ្ទឹមដូចគុក
ពីរនាក់មុខ　　ដងខ្លួនដូចគ្នា ៗ
ស្រីសដើរការ　　ស្រីខ្មៅដើរខ្ជិល
បងត្រូវ [illegible]　　បងយកទាំងពីរ ៗ

ស្រីសដេរនើប　　ស្រីខ្មៅដេរខុទ
ដាក់មុខស្រពោន　　ទឹងអ័ទឹងបង ៗ
ម្ជុលតែចាក់　　ចិត្តោមតែបង
ដេរស្បៃឲ្យបង　　បងលាទៅបួស ៗ

(តាមការចងចាំរបស់លោក កែវ-ហង្ស ឯកសារទំនៀមទម្លាប់ លេខ ៦៨-០៣២)

ប្រុស- ស្រីអើយនាងស្រី　　ទៅណាមកណី
ចូលមកសុំស្លា　　បងសួរដំណេក
ស្រីដេកត្រង់ណា　　ចូលមកសុំស្លាជាមួយទឹងបង ៗ
ពៅអើយស្រីពៅ　　ពៅអើយស្រីពៅ
ពេលល្ងាចបងទៅ　　ស្រីចាប់ខ្លែងផង ៗ
នាងចាប់អាលុក　　ពានៅអាគ្រង់
ស្រីចាប់ខ្លែងផង　　ព្រលប់បងដល់ ៗ
ស្រី- អ្នកហានផ្តាំនេះ　　មុខគួរឲ្យឆ្ងល់
ព្រលប់បងដល់　　ដល់កន្លែងណា ៗ
អ្នកដល់ដីដូន　　ឬដល់ដីតា
ដល់កន្លែងណា　　វាចាប្រាប់ប្អូន ៗ
ប្រុស- នាងអើយនាងស្រី　　នាងអើយនាងស្រី

បើនាងយកប្តី ស្រីកុំទោលបង ។
ដាក់ប្តីពីមុខ ដាក់បងពីខ្នង
ស្រីកុំទោលបង សង្សារយូរហើយ ។

(ប្រមូលបានពី BEFEO ឆ្នាំ ១៩៤១ ដែលនិយាយពីចម្រៀងជនជាតិសម្រែនិងព័រ)

ផ្នែកកំណត់-ប្រវត្តិការណ៍

# ព្រះរាជជីវប្រវត្តិ

## នៃសម្តេចព្រះមហាសុមេធាធិបតី (ជួន-ណាត)

## ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ

សម្តេចបានប្រសូត្រនៅថ្ងៃអង្គារ ១១ រោច ខែផល្គុន ឆ្នាំវកចស័ក ព.ស. ២៤២៧ គឺថ្ងៃទី ១១ មីនា គ.ស. ១៨៨៣ នៅភូមិកំរៀង សង្កាត់ការកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បិតានាម ជួង មាតានាម យក់ (ត្រកូលនេះមានបុត្រតែពីរគត់គឺ សម្តេច ហើយនិងឧកញ៉ាសោភណមន្ត្រី ជួង ឆុត ជាប្អូន របស់សម្តេច) ។

កាលនៅជាកុមារ បានសិក្សាអក្សរ និងលេខ ដរាបដល់ជន្មាយុ ១៤ ឆ្នាំ បានបួសជាសាមណេរ ក្នុងថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំ ចសំរិទ្ធិស័ក ព.ស. ២៤៤១ (ឧសភា គ.ស. ១៨៩៧) នៅវត្តពោធិព្រឹក្ស (ហៅវត្តពោល្យ) សង្កាត់លាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ បួសជាសាមណេរបានពីរឆ្នាំ (ក្នុង ព.ស. ២៤៤៣ គ.ស. ១៨៨៩) សម្តេចបានចូលសិក្សាព្រះបរិយត្តិធម៌ នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ លុះបានជន្មាយុគម្រប់ ២១ ឆ្នាំ នៅថ្ងៃ ១៤ កើត ខែជេស្ឋ ឆ្នាំកោរឆស័ក ព.ស ២៤ ៨ (មិថុនា ១៩០៤) សម្តេចបានទៅសូមបំពេញឧបសម្បទាជាភិក្ខុនៅវត្តពោធិព្រឹក្ស ដែលជាវត្តដើម មានព្រះតេជព្រះគុណព្រះឧត្ត-

យោសាចារ្យ ម៉ា កោត សុវណ្ណប្បញ្ញោ កាលនៅជាចៅអធិការវត្ត ពោធិព្រឹក្ស ជាព្រះឧបជ្ឈាយ៍ ព្រះតេជព្រះគុណ កែវ ម៉ម មិស្សធាគោ ជាគ្រូសូត្រកម្មវាចាចារ្យ និងព្រះតេជព្រះគុណ អ៊ុង ចឹម តិក្ខប្បញ្ញោ ជាគ្រូសូត្រអនុសាវនាចារ្យ ។ សម្តេចបានទ្រង់ទទួលព្រះនាមបញ្ញត្តិ ថា ជោតញ្ញាណោ ។ បានទ្រង់បំពេញជាភិក្ខុ ហើយសម្តេចនិមន្តត្រឡប់ មកគង់នៅវត្តឧណ្ណាលោមវិញ ។

## បំណេះវិជ្ជា និង កិច្ចការដែលសម្តេចទ្រង់បាន បំពេញក្នុងព្រះពុទ្ធសាសនា

ក្រៅអំពីភាសាខ្មែរ ដែលសម្តេចទ្រង់បានស្រាវជ្រាវយល់ដល់ ឫសគល់ពិតប្រាកដ សម្តេចបានសិក្សាភាសាបាលី អាចអានឬសន្ទនា តាមសំនៀងជាតិបរទេសទាំងអស់ គឺសំនៀង លង្កា ភូមា មន សៀម និង លាវ បានឥតមានទើសទាក់ ។

នៅ ព.ស. ២៤៦៦ និង ២៤៦៧ គ.ស. ១៩២២ និង ១៩២៣ សម្តេចកាលនៅជាព្រះគ្រូសំស្គា (ជាមួយសម្តេចព្រះសង្ឃនាយក ហួត តាត វជិរប្បញ្ញោ កាលនៅជាព្រះគ្រូសិរិវិជ្ជា) បាននិមន្ត ទៅបំពេញវិជ្ជាខាងភាសាសំស្ក្រឹត និង អក្សរសិលាចារឹកជាដើម នៅ សាលាបារាំងសែសចុងបូព៌ាប្រទេស នៅក្រុងហាណូយ (វៀតណាមខាង

ដើម ) ក្នុងសំណាក់លោកល្វី-ហ្វីណូត៍ (ជាតិបារាំងសែស) ជាចាងហ្វាងសាលានេះ ។

សម្ដេចទ្រង់ចេះអក្សរនិងភាសាសៀម ភាសាលាវ យ៉ាងជាក់លាក់ និងភាសាបារាំងសែសល្មមប្រាស្រ័យការបាន ដោយសំនៀងគួរសរសើរ ភាសាអង់គ្លេស និងភាសាវៀតណាមផង ។

នៅ ព.ស. ២៤៥៧ គ.ស ១៩១៣ សម្ដេចទ្រង់បានចូលប្រឡងដេញប្រយោគក្នុងព្រះឧបោសថវត្តនាគម វិហារព្រះកែវមរកតក្រុងភ្នំពេញ ចំពោះព្រះភក្ត្រ ព្រះករុណា ព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិ បាន ៤ ប្រយោគ ដែលជាប្រយោគជាន់ខ្ពស់បំផុតក្នុងសម័យនោះ ។

ព.ស. ២៤៥៩ គ.ស ១៩១៥ សម្ដេចទ្រង់បានប្រឡងជាប់លេខ ២ បានទទួលការតែងតាំងជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ដែលសព្វថ្ងៃមានឈ្មោះថា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។

ព.ស. ២៤៦៣ គ.ស. ១៩១៩ សម្ដេចទ្រង់បានធ្វើជាសមាជិកនៃក្រុមជំនុំតែងវចនានុក្រមខ្មែរ ដែលទ្រង់ជាលេខាធិការកាន់កិច្ចការផ្ទាល់ លុះត្រាបានចប់ចុងចប់ដើម ។

ព.ស. ២៤៦៩ គ.ស. ១៩២៥ សម្ដេចបានធ្វើជាសមាជិកនៃក្រុមជំនុំពិនិត្យសេចក្ដីខុសត្រូវ នៃសៀវភៅនានាដែលសាលាបាលីជាន់ខ្ពស់បោះពុម្ពផ្សាយ ។

ព.ស. ២៤៧០ គ.ស. ១៩២៦ តមកជាច្រើនឆ្នាំ សម្ដេចទ្រង់បានទទួលការតែងតាំងជាមេប្រយោគ ក្នុងការប្រឡងយកវិញ្ញាបនបត្របឋមសិក្សាខ្មែរ(១) នៅក្រុងភ្នំពេញ ។

ព.ស. ២៤៧១ គ.ស. ១៩២៧ សម្ដេចទ្រង់បានទទួលការតែងតាំងជាសមាជិក នៃក្រុមជំនុំផ្ទៀងសម្រេចវចនានុក្រមខ្មែរ ហើយសម្ដេចទ្រង់បានទទួលភារៈ ផ្ទៀវចនានុក្រមតែមួយព្រះអង្គឯង ដរាបដល់បានចប់សព្វគ្រប់ ក្មានបោះពុម្ពផ្សាយទាំងភាគ ១ ទាំងភាគ ២ ។

ក្នុងឆ្នាំដដែល នេះ សម្ដេចបានទ្រង់ទទួលការតែងតាំងជាសមាជិកនៃក្រុមអភិបាលជំនុំផ្ដាច់ឆ្នាំ សម្រាប់ព្រះរាជបណ្ណាល័យកម្ពុជា ដែលសព្វថ្ងៃនេះហៅថា "បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ" ។

ព.ស. ២៤៧៤ គ.ស. ១៩៣០ សម្ដេចបានទ្រង់ទទួលការតែងតាំងក្នុងមុខងារជាចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ។

ក្នុងឆ្នាំដដែលនោះ សម្ដេចបានទ្រង់ទទួលការតែងតាំងជាសមាជិកជំនួយនៃក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ។

ព.ស. ២៤៧៦ គ.ស. ១៩៣២ សម្ដេចបានទ្រង់ទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំ ខាងការស្រាវជ្រាវ ជ្រើសរើសរកពាក្យពេចន៍ក្នុងផ្ទៃនៃគតិនិពន្ធខ្មែរបុរាណ ដើម្បីប្រមូលបញ្ចូលពាក្យទាំងនេះទៅក្នុងវចនា-

---

១- និង ប្រឡងយកសញ្ញាបត្របឋមសិក្សាជាន់ខ្ពស់បារាំង-ខ្មែរ ។

នុក្រមខ្មែរ ។

ព.ស. ២៤៧៧ គ.ស. ១៩៣៣ សម្តេចបានទ្រង់ទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំពិនិត្យសៀវភៅ ដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ ។

ព.ស. ២៤៧៨ គ.ស ១៩៣៤ សម្តេចបានទ្រង់ទទួលការតែងតាំងជាសមាជិក នៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរប្រៀបធៀបនឹងពាក្យបារាំង សំរាប់ប្រើក្នុងកិច្ចការរាជការ ។

ព.ស. ២៤៧៩ គ.ស. ១៩៣៥ សម្តេចបានទ្រង់ទទួលការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាបាលី សំស្ក្រឹត ខ្មែរ និងលាវប្រចាំថ្នាក់ទីបំផុតនៃមធ្យមសិក្សា នៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ ។

ព.ស. ២៤៨៦ គ.ស. ១៩៤២ សម្តេចបានទ្រង់ទទួលការតែងតាំងជាចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ (ដែលសព្វថ្ងៃកែប្រែឈ្មោះជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត) ។

ព.ស. ២៤៨៨ គ.ស. ១៩៤៤ សម្តេចបានទ្រង់ទទួលតំណែងជាចៅអធិការ វត្តឧណ្ណាលោម ។

ព.ស. ២៤៨៩ គ.ស. ១៩៤៥ សម្តេចបានទ្រង់ទទួលនាទីជាអធិបតីនៃមេសភា គឺក្រុមជំនុំជាន់ខ្ពស់របស់ព្រះសង្ឃ ។

ព.ស.២៤៩១ គ.ស. ១៩៤៧ សម្តេចបានទ្រង់ទទួលនាទីជាអនុប្រធានគណៈកម្មការវប្បធម៌ ផ្នែកអក្សរ "ក" នៃគណៈកម្មការជាតិខាងការសិក្សា ។

ព.ស.២៤៩២ គ.ស.១៩៤៨ សម្តេចបានទ្រង់ទទួលនាទីជាប្រធាននៃគណៈកម្មការធម្មវិន័យ ពិនិត្យការផ្សាយសៀវភៅសម្រាប់សាលាធម្មវិន័យ ក្នុងព្រះរាជាណាចក្រ ។

គ.ស.១៩៦១ រហូតមក សម្តេចទ្រង់ប្រោសមេត្តាទទួលនិមន្តពីសមាគមអ្នកនិពន្ធខ្មែរធ្វើជាព្រះប្រធាន នៃសម្ភាសន៍អក្សរសាស្ត្រផ្សាយតាមវិទ្យុរៀងរាល់ថ្ងៃសុក្រ ។

គ.ស ១៩៦៤ ទ្រង់ទទួលព្រះឋានៈជាប្រធានគណៈកម្មការពិនិត្យស្នាដៃអត្ថបទផ្សាយជារឿងខាងប្រវត្តិសាស្ត្រខ្មែរ ។

គ.ស.១៩៦៩ ព្រះអង្គទ្រង់ទទួលការតែងតាំងជាប្រធានគណៈកម្មការពិនិត្យ និងកំណត់អំពីន័យរបស់ទង់ជាតិខ្មែរ ។

## ព្រះកិច្ចការដែលសម្តេចទ្រង់បានបំពេញ ក្នុងព្រះពុទ្ធសាសនានៅបរទេស

នៅ ព.ស. ២៤៧៩ គ.ស ១៩៣៦ សម្តេចបានទ្រង់ដឹកនាំគណៈប្រតិភូនៃមន្ត្រីសង្ឃទៅកាន់ក្រុងវៀងចន្ទន៍ និងក្រុងហ្លួងព្រះបាង

ប្រទេសលាវ ដើម្បីប្រមូលក្នុងពិធីសម្ពោធពុទ្ធសាសនបណ្ឌិត្យ ប្រទេសលាវផង ដើម្បីជំនុំពិភាក្សាអំពីការសិក្សា សម្រាប់សាលាបាលីនៅប្រទេសលាវផង ។

នៅ ព.ស ២៤៧៧ គ.ស. ១៩៣៣ សម្ដេចបានទ្រង់ដឹកនាំគណៈប្រតិភូព្រះសង្ឃខ្មែរទៅធ្វើទស្សនាចរណ៍ បំពោះវត្តខ្មែរទាំងឡាយក្នុងដែនកូសាំងស៊ីន (ប្រទេសវៀតណាមខាងត្បូង) ។

នៅ ព.ស. ២៤៨៣ គ.ស. ១៩៣៩ សម្ដេចបានទ្រង់ដឹកនាំគណៈប្រតិភូមួយទៅកាន់ប្រទេសលាវម្ដងទៀត ដើម្បីប្រជុំប្រឹក្សាកិច្ចការនៃពុទ្ធសាសនបណ្ឌិត្យ ប្រទេសលាវ និងការសិក្សាសម្រាប់សាលាបាលីនៅប្រទេសលាវផង ដើម្បីជួយរំលឹកដាស់តឿនប្រជាជាតិលាវនៅក្នុងទីប្រជុំជន ក្នុងខេត្តនានា នៃព្រះរាជអាណាចក្រលាវ ឲ្យខំប្រឹងយកចិត្តទុកដាក់ក្នុងការសិក្សានិងការប្រតិបត្តិ ឲ្យបានត្រឹមត្រូវតាមគន្លងព្រះពុទ្ធសាសនាផង ។

នៅ ព.ស. ២៤៨៧ គ.ស. ១៩៤៣ សម្ដេចបានទ្រង់ទទួលនាទីជាសមាជិកធ្វើយគ្នងនៃសាលាបាក់ងសែស នៅចុងបូព៌ាប្រទេស ហើយនៅ ព.ស. ២៤៩២ គ.ស. ១៩៤៨ សម្ដេចបានទ្រង់ទទួលនាទីជាសមាជិកកិត្តិយស នៃសាលានេះ ដរាបរៀងមក ។

នៅ ព.ស. ២៤៩៤ គ.ស. ១៩៥០ សម្ដេចបានទ្រង់ដឹកនាំ

គណៈប្រតិភូខ្មែរទៅប្រជុំសន្និសីទ ដើម្បីបង្កើតពុទ្ធិកសមាគមពិភពលោក នៅក្រុងកោលម្បូ លង្កាទ្វីប ។

នៅ ព.ស. ២៤៩៧ គ.ស. ១៩៥៣ សម្តេចបានទ្រង់ដឹកនាំ គណៈប្រតិភូខ្មែរ ទៅបំពេញបេសកកម្មសុឆន្ទៈ ប្រឹក្សាសម្រេចរឿងធ្វើ ឆដ្ឋសង្គាយនានៅក្រុងរង្គូន សហភាពភូមា ។

កន្លងឆ្នាំជាបន្ទាប់ នៅ ព.ស. ២៤៩៨ គស. ១.៩៥៤ សម្តេចបានទ្រង់ដឹកនាំគណៈប្រតិភូខ្មែរ និមន្តទៅកាន់ក្រុងរង្គូន ប្រទេសភូមា ម្តងទៀត ដើម្បីប្រមូលកិច្ចការប្រជុំធ្វើឆដ្ឋសង្គាយនា សម័យប្រជុំដំបូង ។

កន្លងមួយឆ្នាំ [illegible] ព.ស. ២៤៩៩ គ.ស. ១៩៥៥ សម្តេចទ្រង់បានដឹកនាំគណៈប្រតិភូខ្មែរ ទៅកាន់ឆដ្ឋសង្គាយនា ក្រុងរង្គូន ប្រទេសភូមា ជាលើកទីបី ដើម្បីប្រជុំហើយបិទសម័យប្រចាំឆ្នាំ ។

នៅ ព.ស. ២៥០៣ គ.ស. ១៩៥៩ សម្តេចទ្រង់បានដឹកនាំ គណៈប្រតិភូខ្មែរទៅកាន់ក្រុងជាកាតា និងក្រុងសុមារ៉ាំង កោះជ្វា ប្រទេសឥណ្ឌូនេស៊ី ដើម្បីប្រារព្ធកុសលពិធីបុណ្យវិសាខបូជា ព.ស. ២៥០៣ ពិធីបញ្ចុះខណ្ឌសីមា និងពិធីសន្មតគេហឧបោសថ ព្រមទាំងជាព្រះឧបជ្ឈាយ៍ បំបួសកុលបុត្រ អ្នកប្រទេសនោះចំនួនបីរូបផង ។

## សមណសក្តិដែលសម្តេចបានទទួលជាលំដាប់

ដោយព្រះរាជការកិច្ចការដ៏ធំៗ ដែលសម្តេចបានទ្រង់បំពេញ

ក្នុងព្រះពុទ្ធសាសនានោះ សម្ដេចក៏តែងបានឡើងសមណសក្តិជាលំដាប់លំដោយដូចតទៅនេះ គឺ :

ព.ស. ២៤៥៤ គ.ស. ១៩១០ សម្ដេចបានទទួលការតែងតាំងក្នុងសមណសក្តិជាព្រះបាឡាត់សាក្យបុត្តិយ៍ (បាឡាត់របស់ព្រះសាក្យវង្ស ឈុន វត្តឧណ្ណាលោម) ។

ព.ស. ២៤៥៦ គ.ស. ១៩១២ សម្ដេចបានទទួលសមណសក្តិជាព្រះគ្រូសង្ឃសត្ថា (ទីបាំអនុក្រមសម្រាប់ឯក របស់សម្ដេចព្រះមហាសង្ឃរាជព្រះទាម (ទៀង) ។

ព.ស. ២៤៧៤ គ.ស. ១៩៣១ សម្ដេចបានឡើងសមណសក្តិជា ព្រះសាសនសោភ័ណ (រាជាគណៈកិត្តិយស) ។

ព.ស. ២៤៨៤ គ.ស. ១៩៤០ សម្ដេចបានឡើងសមណសក្តិជាព្រះពុទ្ធឃោសាចារ្យ (រាជាគណៈថ្នាក់ទី ២) ។

ព.ស. ២៤៨៨ គ.ស. ១៩៤៤ សម្ដេចបានឡើងសមណសក្តិជាព្រះពោធិវង្ស (រាជាគណៈថ្នាក់ទី ១) ។

ព.ស. ២៤៩២ គ.ស. ១៩៤៨ សម្ដេចបានឡើងសមណសក្តិជាន់ខ្ពស់បំផុត ជាព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ។

លុះដល់មក ព.ស. ២៤៩៤ គ.ស. ១៩៥០ ព្រះករុណាជាម្ចាស់ជីវិតទ្រង់បានប្រោសប្រគេនព្រះឋានៈ ជាសម្ដេចព្រះមហាសុមេធាធិបតី

សង្ឃនាយកគណៈមហានិកាយ ។

មួយវិញទៀត នៅ ព.ស. ២៤៩៨ គ.ស. ១៩៥៤ រដ្ឋាភិបាលនៃសហភាពភូមា បានប្រគេនព្រះឋានៈសម្តេច ជាព្រះអគ្គមហាបណ្ឌិតនៃសហភាពភូមា ។

លុះដល់មក ព.ស. ២៥០១ គ.ស. ១៩៥៧ រដ្ឋាភិបាលនៃសហភាពភូមា បានសុំតម្កើងព្រះឋានៈសម្តេចជា ព្រះអភិធជមហារដ្ឋគុរុនៃសហភាពភូមា ដែលជាសមណសក្តិដ៏ខ្ពង់ខ្ពស់បំផុតមានតែមួយអង្គក្នុងសហភាពភូមា ។

ខែកុម្ភៈ គ.ស. ១៩៦៤ អ្នកនិពន្ធខ្មែរទាំងអស់ បានថ្វាយឋានៈព្រះអង្គជា "ព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ" និងជាសមាជិកកិត្តិយសនៃសមាគមអ្នកនិពន្ធខ្មែរផង ។

ព.ស. ២៥០៧ គ.ស. ១៩៦៣ សម្តេចព្រះ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា ទ្រង់បានប្រោសប្រគេនព្រះឋានៈសម្តេចជាសម្តេចព្រះសង្ឃរាជថ្នាក់ទី១ ។

ថ្ងៃទី ២៨ ឧសភា ១៩៦៧ ទ្រង់បានទទួលសញ្ញាបត្រ "បណ្ឌិតអក្សរសាស្ត្រ" ពេញលក្ខណៈ អំពីសម្តេចព្រះប្រមុខរដ្ឋ ក្នុងនាមមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ នៃពុទ្ធិកសាកលវិទ្យាល័យ ។

# គ្រឿងឥស្សរិយយស

សម្តេចបានទទួលគ្រឿងឥស្សរិយយសដូចតទៅនេះគឺ :

- មេដាយអស្សឫទ្ធិមុនីសាភរណ៍ នៅ ព.ស. ២៤៦១ គ.ស. ១៩១៧ ។

- មេដាយអស្សឫទ្ធិព្រះរាជាណាចក្រកម្ពុជា នៅ ព.ស. ២៤៧៦ គ.ស. ១៩៣២ ។

- មេដាយអស្សឫទ្ធិដំរីមួយលាន និង ស្វេតច្ឆត្រ ប្រទេសលាវ នៅ ព.ស. ២៤៧៦ គ.ស. ១៩៣២ ។

- មេដាយ សេនានៃបណ្ឌិតសភា សាធារណៈរដ្ឋបារាំង នៅ ព.ស. ២៤៨១ គ.ស. ១៩៣៧ ។

- មេដាយអស្សឫទ្ធិ ដឺឡាឡេស្យុងដុណ្ណើរ នៃសាធារណរដ្ឋបារាំង នៅ ព.ស.២៤៨៦ គ.ស. ១៩៤២ ។

- មេដាយ សេនានៃព្រះរាជាណាចក្រកម្ពុជា នៅ ព.ស. ២៤៨៥ គ.ស. ១៩៤៤ ។

- មេដាយ សេនា ដឺឡាឡេស្យុងដុណ្ណើរ នៃសាធារណរដ្ឋបារាំង នៅ ព.ស. ២៤៩២ គ.ស. ១៩៤៨ ។

- មេដាយ មហាសិរីវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា នៅ ព.ស. ២៥០៥ គ.ស. ១៩៦២ ។

- មេដាយ មហាសិរីវឌ្ឍសុវត្ថារា នៅ ព.ស ២៥០៦ គ.ស. ១៩៦៣ ។

- មេដាយ ជាតូបការ ដែលជាគ្រឿងឥស្សរិយយសធំបំផុត ក្នុងព្រះរាជាណាចក្រកម្ពុជា នៅ ព.ស. ២៥១៣ គ.ស. ១៩៦៩ ។

## កិច្ចការជាស្នាព្រះហស្តនៃសម្តេច

កិច្ចការឯទៀតក្រៅពីមុខការខាងលើនេះ ដែលសុទ្ធសឹងតែជាការមានប្រយោជន៍ជាសាធារណៈក្នុងព្រះពុទ្ធសាសនា និងប្រទេសជាតិនោះ នៅមានច្រើនទៅទៀត និយាយដោយសង្ខេប គឺចាប់តាំងពីឆ្នាំជូតសប្តស័ក ព.ស. ២៤៧១ គ.ស. ១៩២៨ រៀងមក សម្តេចបានធ្វើការឧបត្ថម្ភវត្តពោធិព្រឹក្ស (ហៅវត្តពោលៀ) ក្នុងសង្កាត់លាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានព្រំប្រទល់ជាប់គ្នា និងឃុំកោះកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាទីជាតិភូមិរបស់សម្តេចដោយសម្តេចបានជាវទីដីជុំវិញវត្ត ចំនួនជាង ៣ ហិកតា ពង្រីកទីវត្តឲ្យធំទូលាយច្រើនជាងពីដើម បានជួយឧបត្ថម្ភលើកថ្នល់ភ្ជាប់ពីថ្នល់ជាតិមកចូលវត្តស្រកី និងវត្តពោធិព្រឹក្ស រួមចម្ងាយ ៣ គីឡូម៉ែត្រ បានស្ថាបនាវិហារបេតុងអារម៉េ សាលាបាលីរង (ពុទ្ធិកបឋមសិក្សា) រៀបចំទីវត្តតាំងមូលឲ្យមានទេសភាពសមរម្យតាមសម័យនិយម ស្ថាបនាស្ពានធំ ១ និងស្ពានតូច ១ សុទ្ធតែ

បេតុងអារម៉េធុងស្តុងតូច កាំងព្រំប្រទល់ឃុំណាំងកែន និងឃុំកោះកោះ បានឧបត្ថម្ភក្នុងការស្ថាបនាសាលាបឋមសិក្សាបំពេញវគ្គ " សុភី-ពោធិព្រឹក្ស" ៣ ខ្នង តាំងពី គ.ស. ១៩៤៨ រៀងរហូតដល់សាលារៀននេះ ឡើងដល់ថ្នាក់ឧត្តមដ្ឋាន ( សម្រាប់កូនចៅអ្នកស្រុកដើមវត្តសុភី និងវត្តពោធិព្រឹក្ស ) បានឧបត្ថម្ភឲ្យថ្នល់លំនោះ បានចាត់គ្រឿងសម្ភារ-ក្រៀម ប្រើការបានដោយស្រួល បានជាវទីដី ៣ ហិកតាកន្លះ បានស្ថាបនាខ្លោងទ្វារបេតុងអារម៉េ ១ បានស្ថាបនា អាសថសាលា (សាលាសំណាក់) ១ខ្នង បានឲ្យជីកស្រះមួយទំហំ ១០០ ម៉ែត្រ ៤ ជ្រុងនៅត្រង់ទីថ្នល់បែកចេញពីថ្នល់ជាតិក្នុងឃុំកោះកោះ បានជួយឧបត្ថម្ភឲ្យជីកអណ្តូងយោង ១៦ កន្លែង អណ្តូងបុកប្រើស្នប់ ៣ កន្លែង បានស្ថាបនាគិលានដ្ឋាន ១ ខ្នង ប្រសូតិគ្រឹះ (មន្ទីរសម្ភព) ១ ខ្នង ដោយបេតុងអារម៉េ និងកំពែងបេតុងអារម៉េ បណ្តោយ ១០០ ម៉ែត្រ ទទឹង ៥២ ម៉ែត្រព័ទ្ធជុំវិញមន្ទីរទាំង ២ ខ្នងនេះ បានស្ថាបនា "អគារគត្តីទីសំណាក់" ក្នុងកំពែងនេះដែរ បានស្ថាបនាអគារបេតុងអារម៉េ ២ ខ្នងក្រៅកំពែងនោះ សម្រាប់គិលានសមណៈ បានចាត់ការឲ្យលើកទំនប់ទឹក ១ កន្លែង បណ្តោយ ៩០០ ម៉ែត្រ ទទឹក ៨០០ ម៉ែត្រ ( ដោយសម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់សព្វព្រះរាជហឫទ័យ ប្រោសប្រទានព្រះរាជានុញ្ញាតឲ្យលើកទំនប់នេះ) បានឧបត្ថម្ភ

ឲ្យវេយ្យាវច្ចករដាំដំណាំលើទីដីខាងលើនេះ ជាប្រយោជន៍ដល់គិលានដ្ឋាន និងប្រសូតិគ្រឹះនៅក្នុងអនាគតកាល (ស្ថាបនកម្មទាំងនេះនៅក្នុងភូមិស្រែបន្ទាយ ឃុំកោះកោះ) បានលះបង់ទីដី ១ កន្លែង ដែលសម្តេចបានជាវហើយនោះ ជូនព្រះរាជរដ្ឋាភិបាលឲ្យស្ថាបនាអគារមណ្ឌលទីតកម្ម (ប៉ុស្តិ៍ប៉ូលិស) និងមន្ទីររាជសហករណ៍ ។ល។

## កិច្ចការជាស្នាព្រះហស្តខាងអក្សរសាស្ត្រ

សម្តេចបានកសាង គម្ពីរដីកាជាច្រើន ហើយសម្តេចបានប្រែភាសាបាលីរៀបរៀងជាសៀវភៅច្រើនច្បាប់ ។ សៀវភៅដែលកម្រធ្វើកើត ហើយដែលមានប្រយោជន៍ច្រើននោះគឺៈ ។

១. វចនានុក្រមខ្មែរ (មាន២ ភាគ) ក្នុង ព.ស. ២៤៦១ គ.ស ១៩១៩ និងឆ្នាំតៗមក ។

២- កច្ចាយនូបត្ថម្ភកៈ (វេយ្យាករណ៍បាលីមាន ២ ភាគ) បានធ្វើពី ព.ស. ២៤៦២ គ.ស. ១៩២០ ។

៣- គិហិបដិបត្តិ ក្នុង ព.ស. ២៤៦៨ គ.ស. ១៩២៦ ជាមួយនិងព្រះឧត្តមមុនី អ៊ុម-ស៊ូ និង សម្តេច ហួត-តាត តាមបញ្ជានៃព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម ថោង (ពុទ្ធសាសនបណ្ឌិត្យ) ។

៤. សាមណេរវិន័យ ក្នុង ព.ស. ២៤៦០ គ.ស, ១៩១៧ ជាមួយនិងព្រះថេរៈទាំង ២ អង្គខាងលើនេះដែរ ។

៥- បាតិមោក្ខសង្ខេប (សម្រាយ) ព.ស. ២៤៧០ គ.ស. ១៩២៨

មានសៀវភៅឯទៀតៗ ជាច្រើន ដែលជាការបន្ទាប់បន្សំគឺ :

៦- កាព្យលោកធម៌ បោះពុម្ពដំបូងក្នុង ព.ស. ២៥០០ គ.ស. ១៩៥៧ ។ កាព្យនេះទ្រង់តែងកាលនៅជាព្រះគ្រូសំសត្ថា ។

៧- នាគោបមាទិកថា ព.ស. ២៤៧៥ គ.ស. ១៩៣៣ ។

៨- ព.ស. ២៤៨៤ គ.ស. ១៩៤១ សម្តេចបានតែងសុភមង្គលគាថាបាលី បច្ឆាវត្ត ៧ គាថា ព្រមទាំងប្រែជាសម្រាយផង សម្រាប់សូត្រថ្វាយ សុភមង្គលសួស្តី ចំពោះព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ។

៩- អត្ថបទផ្សេងៗ ជាច្រើនក្នុងទស្សនាវដ្តី កម្ពុជសុរិយា របស់ពុទ្ធសាសនបណ្ឌិត្យ តាំងពីឆ្នាំដំបូងតៗមក ដែលពុំអាចស្រាវជ្រាវមកកប់រៀបក្នុងទីនេះបាន សព្វគ្រប់ឡើយ ។

## អវសានកាល

លុះមកដល់វេលាថ្ងៃអង្គារ ១២ កើតខែភទ្របទ ឆ្នាំរកា ឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ២៣ កញ្ញា ១៩៦៩ វេលាម៉ោង ១៥,៤៥ នាទី ព្រះសង្ឃដែលគាល់បម្រើព្រះអង្គបានឮសម្លេងកណ្តឹងរោទ៍ ប៉ុក ខុសធម្មតាពីក្នុងក្រឡាព្រះបន្ទំ ក៏ប្រញាប់គ្នាចូលទៅគាល់ជាបន្ទាន់ គ្រានោះព្រះអង្គមានបន្ទូលថា "ចុកទ្រូងណាស់ៗ" ។ ក្រោយពីពេលបាត់

ការឲ្យទៅតាមគ្រូពេទ្យទាំងឡាយគឺ លោកវេជ្ជបណ្ឌិត ផា-ប៉េងជុង មី-សាមីឌី យូ-គិមយ៉ាង ព្រំ-ភួង រស់-សារី វេជ្ជបណ្ឌិតជាតិបារាំងឈ្មោះ ម៉ាប៉ាស្ស ជាដើម បានចូលមកព្យាបាលជាបន្ទាន់ ឃើញថាព្រះអាការរោគមិនជាធួនប៉ុន្មានទេ ប៉ុន្តែពោះបីយ៉ាងណា ក៏ក្រសួងសុខាភិបាលបានចាត់លោកគ្រូពេទ្យ យូ-គិមយ៉ាង និង លី-គិមសាង ឲ្យមករក្សាព្រះរោគ និងប្រគបឱសថថ្វាយជាដរាប រហូតដល់ថ្ងៃព្រហស្បតិ៍ ១៤ កើត ខែភទ្របទ ត្រូវនិងថ្ងៃទី ២៥ កញ្ញា ១៩៦៩ វេលាម៉ោង ២០ និង ២០ នាទី ព្រះអស្សាសបស្សាសៈនៃព្រះអង្គបានចាកចេញពីព្រះកាយ ទ្រង់សោយទីវង្គតដោយស្ងប់ស្ងៀម នៅក្នុងព្រះរាជដំណាក់ព្រះអង្គ នាវត្តឧណ្ណាលោម ។

ក្នុងរយៈកាលដែលទ្រង់ប្រឈួននេះ ឯកឧត្តម អ៊ុង-ហ៊ុងសាង តាមព្រះរាជបញ្ជានៃសម្តេចសហធិវិន ព្រះប្រមុខរដ្ឋ បានចាត់អស់លោកវេជ្ជបណ្ឌិតខ្មែរ បារាំង ដ៏ជំនាញៗ ទាំងទទួលខ្វល់ខ្វាយព្យាបាលព្រះរោគព្រះអង្គយ៉ាងពេញសមត្ថភាព ប៉ុន្តែធ្វើម្តេចឡើយនឹងយកជ័យជំនះបានលើកអនិច្ចធម៌នោះ ។

សម្តេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់បានដឹងព្រះអង្គជាមុនតាំងពីថ្ងៃប្រឈួនទ្រង់មានព្រះបន្ទូលប្រាប់ព្រះសង្ឃ និងអស់លោកដែលមកថ្វាយបង្គំសាកសួរព្រះសុខភាពថា : អាត្មាហាក់ដូចជាគ្មានសង្ឃឹមទេ ...

ព្រះរាជបន្ទូលនេះធ្វើឲ្យយើងទាំងអស់គ្នាមានការតក់ស្លុតណាស់ ប៉ុន្តែយើងទាំងអស់
គ្នានៅតែជឿថា : ព្រះអង្គនឹងនៅគង់ព្រះជន្មាយុតទៅទៀតបាន ពីព្រោះ
សង្កេតទៅ ព្រះសរីរាង្គព្រះអង្គ ពុំឃើញមានប្រែប្រួលប៉ុន្មាន ម្យ៉ាង
វិញទៀត ទ្រង់នៅចាំព្រះស្មារតីល្អណាស់ អាចមានបន្ទូលសាកសួរ
សំណេះសំណាលនិងអស់លោកដែលមកក្រាបបង្គំគាល់នោះបាន ៗ ជា
ពិសេស កាលពីព្រឹកនៃថ្ងៃសោយព្រះទិវង្គតនេះ សហជីវិនឯកឧត្តម
លន់ ណុល នាយករដ្ឋមន្ត្រី និងអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-សិរីមតៈ
ឧបនាយករដ្ឋមន្ត្រីទី ១ បានចូលក្រាបបង្គំគាល់ព្រះអង្គ ដើម្បីសាកសួរ
ព្រះរោគព្រះអង្គផង និងដើម្បីក្រាបបង្គំលាព្រះអង្គទៅកាន់បរទេសផង ៗ
គ្រានោះ ព្រះអង្គបានទទួលរាក់ទាក់ហើយបានប្រសិទ្ធិពរជូនចំពោះឯក
ឧត្តម នាយករដ្ឋមន្ត្រី និងថ្វាយចំពោះអ្នកអង្គម្ចាស់ឧបនាយករដ្ឋមន្ត្រីទី ១
សូមទៅបំពេញបេសកកម្មនៅប្រទេសគេ បានជោគជ័យផង ៗ ក្រោយ
មកទៀត សម្តេចព្រះសង្ឃរាជជាទីគោរព ក៏បានព្រះរាជទានសន្ទនាជា
មួយសហជីវិន ប៊ី-ឡុច រដ្ឋលេខាធិការក្រសួងធម្មការ និងសហជីវិន
ទ្រិញ-ហ៊ាញ ប្រធានសមាគមអ្នកនិពន្ធខ្មែរ អំពីការធ្វើចេតិយ ៗ
ព្រះអង្គទ្រង់មានបន្ទូលហូរហែ ហើយនិទានអំពីចេតិយឈ្មោះ សិង្គុត្តរៈ
នៅសហភាពភូមាថែមទៀតផង ៗ រួចព្រះអង្គត្រាស់រំលឹកអំពីការបោះ
ពុម្ពវចនានុក្រម ដែលទ្រង់បានពិនិត្យកែសម្រួលបន្ថែមពាក្យជាច្រើនទៀត

ទោះបីជកទិនព្យាធិចេះតែបៀតបៀនព្រះអង្គហើយក្តី ៗ សភាពអស់ទាំងនេះសឲ្យឃើញថាព្រះអង្គនៅរឹងប៉ឹងណាស់ មិនគួរឡើយប្រែប្រួលទៅជា យើងរាល់គ្នាមានការសោយសោកដូច្នេះសោះ ៗ នេះហើយសមដូច ព្រះពុទ្ធដីការបស់ព្រះអង្គដែលទ្រង់មានព្រះបន្ទូលជារឿយ ៗ ថា : មនុស្សជួបគ្នាញ៉ង់ពីព្រឹក លុះល្ងាចក៏អាចបែកគ្នាហូត សភាពនេះត្រូវដូចព្រះបន្ទូលនោះណាស់ ព្រះអង្គយាងទៅចោលពុទ្ធបរិស័ទរាល់គ្នាហាក់គ្មានព្រាងទុក ជាទីគួរឲ្យស្តាយណាស់ រកពាក្យថ្លែងពុំបានទេព្រះអង្គសោយព្រះទីវង្គត ធ្វើឲ្យរញ្ជួយមួយសកលកម្ពុជា ព្រោះព្រះអង្គប្រកបដោយគុណធម៌គួរគោរពប្រពៃក្រៃលែង ៗ

១១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤១ ខែ វិច្ឆិកា

ព.ស. ២៥១៣ គ.ស. ១៩៦៩

-ភ្នំពេញ-

១១

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ

## ផ្នែកសាសនា

ទំព័រ


១— ទស្សនវិជ្ជាពុទ្ធសាសនា ព្រះមហាវីរិយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង ១១៤៥

២— រឿងតាមណិចន្ទ សហ.ផល-ទិត រៀបរៀង . . . ១១៥៧


## ផ្នែកអក្សរសាស្ត្រ


៣ – វិចារណកថា : របៀបនិយាយ សហ. ផេង-ជ្រីវ រៀបរៀង. . . ១២០៩

៤— វចនានុក្រមសំស្ក្រឹតខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ១២១៦

៥— រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ១២២០

៦— រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ អ្នកស្រីពេជ-សល់ ប្រែរៀបរៀង. . ១២៣៦

៧— ល្បើកអក របស់ព្រះបម្រើនទីយ សហ. លី-ធាមតេង ស្រាវជ្រាវ . ១២៤៩


## ផ្នែកកំណត់-ប្រវត្តិការណ៍


៨— ព្រះរាជក្រឹត្យតែងតាំងសម្តេចព្រះសុមេធាធិបតីសង្ឃនាយក . . ១២៦០

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០ ។

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ,
ឲ្យជុំសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ·

ប ព

# ទស្សនវិជ្ជាពុទ្ធសាសនា

ព្រះមហាវីរិយបណ្ឌិតោ ទាំង - ខាត់ រៀបរៀង

(តពីលេខមុន)

៦- ជីវិតផ្សេង សរីរៈផ្សេង = អញ្ញំ ជីវំ អញ្ញំ សរីរំ

៧- សត្វស្លាប់ហើយ កើតទៀត = ហោតិ តថាគតោ បរម្មរណា

៨- សត្វស្លាប់ហើយ មិនកើតទៀត = ន ហោតិ តថាគតោ បរម្មរណា

៩- សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន = ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា

១០- សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិន

មែន = នេវ ហោតិ ន ច ហោតិ តថាគតោ បរម្មរណា

ប្រស្នាទាំងនេះ ព្រះសម្ពុទ្ធមិនទាន់បានសម្តែងដល់អាត្មាអញទេ បើដូច្នោះគួរតែអាត្មាអញចូលទៅក្រាបបង្គំទូលសួរ ចំពោះព្រះភក្ត្រព្រះអង្គ បើទ្រង់មិនព្រមសម្តែងដល់អាត្មាអញទេ អាត្មាអញលែងបួស លែងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះអង្គ ហើយលាសិក្ខាបទត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ" ។

ថ្ងៃមួយតមក មាលុង្ក្យបុត្តចូលទៅក្រាបបង្គំគាល់សួរប្រស្នានេះ តាមដែលខ្លួនបានគិតទុកមុន ។ ទ្រង់ព្រះសណ្តាប់ហើយ ព្រះសម្ពុទ្ធត្រាស់តបថា : "តថាគតមិនបានហៅអ្នកឲ្យចូលមកបួស ហើយធ្វើកតិកាថានឹងសម្តែងធម៌នេះប្រាប់ដល់អ្នកទេ ចុះអ្នកមកអុកជាទុក្ខប្រាប់តថាគតធ្វើអ្វី ? ទ្រង់ត្រាស់តទៅថា :

"ម្នាលមាលុង្ក្យបុត្ត ! បើមានអ្នកណាម្នាក់ មកនិយាយប្រាប់តថាគតថា ខ្ញុំព្រះអង្គមិនទាន់បួសប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះអង្គទេ បើទ្រង់ព្រះករុណាមិនទាន់បានសម្តែងប្រទានខ្ញុំព្រះអង្គថា "លោកទៀង" ។ល។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន" ដូច្នេះ អ្នកនោះមុខជាស្លាប់សោះបង់ទៅមុនតថាគតសម្តែងប្រាប់មិនខាន ប្រៀបដូចបុរសត្រូវសរ ហើយនិយាយប្រាប់គ្រូពេទ្យថា ខ្ញុំមិនទាន់ឲ្យលោកដកយកសរនេះទេ ទាល់ខ្ញុំបានដឹងថា :

-អ្នកណាជាអ្នកបាញ់សរនោះ ជាក្សត្រ ឬជាព្រាហ្មណ៍ ជាវេស្ស ឬជាសុទ្ទ មនុស្សទាប ឬខ្ពស់ សម្បុរខ្មៅ ពណ៌សណ្ដែកបាយ ឬប្រផេះ នៅស្រុកនិគមណាសិន,

-ធ្នូនោះ ជាកាំភ្លឹង ឬធ្នូស្នា ខ្សែធ្នូនេះ ជាសម្បកពក់ ពន្ទុងឫស្សី សរសៃសត្វ សម្បកខ្ញែងតា ឬ រលឹទឹកដោះសិន,

-សរដែលមុតនោះ ជាព្រៃឈើ ឈើស្រុក, ជាសរសៀតដោយស្លាបសត្វត្មាត ប្រមង់ ខ្លែង ក្អែក ឬ ទុងសិន,

-សរនេះរុំដោយសរសៃកន្ទុយគោ ក្របី សីហាខ្មៅ ឬ ស្វា សិន,

-សរនេះ មានមុខមូល មុខសំប៉ែត មានដៀង មុខស្រោបដែក មុខដូចកន្ទាក ឬ សរធ្វើពីឆ្អឹងគ្រាំងសិន សឹមខ្ញុំព្រមឲ្យវេជ្ជដកយកសរនេះចេញពីកាយខ្ញុំ ។

មាលុង្ក្យបុត្ត ! បុរសត្រូវសរនោះ នៅរង់ចាំដឹងមុនមិនទាន់ទេ ទឹងត្រូវស្លាប់មុន ឥតប្រយោជន៍អសារបង់ពុំមានឡើយ ។

មាលុង្ក្យបុត្ត ! បើចាំដឹងថា "លោកទៀង ។ល។ សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន" សិន សឹមប្រព្រឹត្តព្រហ្មចរិយធម៌ =(ព្រហ្មចរិយវាស) ក្រោយ បើគេទៅតែមិនទាន់ដឹងមុនទេ ក៏ឥត "ប្រយោជន៍,, ដែរ ព្រោះធម៌ជាសិក្សត្រូវដូចជា ជាតិ ព្យាធិ មរណៈ សោក គរ បរិទេវ ទុក្ខ ទោមនស្ស

ឧបាយាស បេះតែបៀតបៀនសត្វជានិច្ច ជាធម៌ដែលតថាគតបញ្ញត្តិថា "មានសេចក្តីទោសពិត" ក្នុងបច្ចុប្បន្នកាលនេះ ។

មាលុង្ក្យបុត្ត! ការប្រព្រឹត្តិព្រហ្មចរិយធម៌ មិនមែនពឹងផ្អែកទៅលើ ទិដ្ឋិ (Dogme) ដូចបានពោលមកទាំងអស់នេះទេ ការដែលត្រូវធ្វើភ្លាម ៗ គឺប្រស្នាបន្ទាន់ដែលកំពុងផុតសត្វលោកឲ្យទៅឲ្យធេះពេលពលស្ទះស្ទាអន្ទះសានោះគឺ ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវ ទុក្ខ ទោមនស្ស ឧបាយាស ព្រមទាំងធម៌ "ទីបំផុតទុក្ខ" ទាំងអស់នេះសុទ្ធតែជាប្រស្នាបន្ទាន់ ត្រូវធ្វើភ្លាម ៗ បង្អង់ទុកយូរតទៅទៀតពុំបានឡើយ ។

មាលុង្ក្យបុត្ត! ចូរអ្នកចាំទុកក្នុងចិត្តចុះថា "នេះជាធម៌ដែលតថាគតត្រូវសម្តែង ដូចតថាគតបានសម្តែងរួចហើយ, នេះជាធម៌ដែលតថាគតមិនសម្តែង ដូចតថាគតមិនសម្តែងហើយ ។ ឯធម៌ដែលតថាគតមិនសម្តែងនោះគឺ លោកទៀង ។ល។ សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ ហេតុអ្វីក៏តថាគតមិនសម្តែងការយល់ឃើញ= (ទិដ្ឋិ) នោះ ?

មាលុង្ក្យបុត្ត! បានជាតថាគតមិនសម្តែង ព្រោះទិដ្ឋិនេះមិនមានប្រយោជន៍ មិនមែនជាការចាំបាច់ មិនមែនជាខាងដើមនៃព្រហ្មចរិយធម៌ មិនមែននាំឲ្យកើតសេចក្តីនឿយណាយការប្រាសចាកកតៈការរលត់ទុក្ខការស្ងប់

ការដឹងច្បាស់ ការត្រាស់ដឹង និព្វាន ឡើយ ។

អ្វីដែលតថាគតសម្តែង ?

មាលុង្ក្យបុត្ត! តថាគតតែងសម្តែងថា "នេះទុក្ខ នេះហេតុនាំឲ្យកើតទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះបដិបទាជាផ្លូវនាំទៅកាន់ការរំលត់ទុក្ខ"

ហេតុអ្វីក៏តថាគតសម្តែងធម៌នេះ ?

មាលុង្ក្យបុត្ត! ព្រោះថាធម៌នេះ មានប្រយោជន៍[1] សំខាន់ណាស់ ចាំបាច់ណាស់ ជាខាងដើមនៃ ព្រហ្មចរិយធម៌ នាំឲ្យកើតក្តីនឿយណាយ ប្រាសចាកកតរំលត់ទុក្ខ ស្ងប់ ដឹងច្បាស់ ត្រាស់ដឹង និព្វាន" ។

សេចក្តីនេះ នាំឲ្យយើងយល់ច្បាស់ថា ពុទ្ធសាសនា ជាសាសនារំដោះទុក្ខ រំដោះទុក្ខយ៉ាងអស់ដើង ដែលមិនធ្លាប់មានមកក្នុងប្រវត្តិសាស្ត្រសាសនានៃសកលលោកឡើយ ។ ពុទ្ធសាសនា មានទឹកមុខទៅខាងលោកុត្តរធម៌ ។

មួយទៀត ប្រស្នាយើងដែលនេះ[2] មានចោទឡើងច្រើនណាស់

---

១- កស្មា ចតំ មាលុង្ក្យបុត្ត មយា ព្យាកតំ ឯតញ្ហិ មាលុង្ក្យបុត្ត អត្ថសញ្ហិតំ ឯតំ អាទិព្រហ្មចរិយំ ឯតំ និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ តស្មា តំ មយា ព្យាកតំ ។

២- មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក អគ្គិវច្ឆសូត្រសៀវភៅទី ២៤ ទំព័រ ៨ ។

ក្នុងសម័យពុទ្ធកាល ប្រស្នានេះក៏ចោទខ្លាំងណាស់ ព្រោះសម័យនេះ ជាសម័យភ្ញាក់រលឹក ៗ មានបរិញ្វាជកា ម្នាក់ មានការជឿនូវចំពោះទិដ្ឋិ(Dogme) ដូចយើងបានដកស្រង់មកហើយនេះដែរ ៗ សម័យមួយអង្គព្រះសម្ពុទ្ធទ្រង់ប្រថាប់សម្រេចព្រះឥរិយាបថនៅក្នុងវត្តជេតវណាកម ជាអារាមអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយជិតក្រុងសាវត្ថី កាលនោះមាន បរិញ្វាជកា ម្នាក់ឈ្មោះ វច្ឆគោត្រ ចូលទៅក្រាបបង្គំគាល់ព្រះអង្គ ហើយលើកយកប្រស្នាដដែលនេះ មកក្រាបទូលសួរព្រះអង្គថាៈ

"សូមទ្រង់ព្រះមេត្តាប្រោស! ចុះព្រះអង្គមានការយល់ឃើញ ទិដ្ឋិ= (Dogme) ថា លោកទៀង–លោកមិនទៀង–លោក មានទីបំផុត លោកមិនមានទីបំផុត-ជីវិតគឺសរីរៈ-ជីវិតផ្សេង សរីរៈផ្សេង-សត្វស្លាប់ហើយ កើតទៀត-សត្វស្លាប់ហើយ មិនកើតទៀត-សត្វស្លាប់ហើយ កើតទៀតក៏មានមិនកើតទៀតក៏មាន-សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន នេះសេចក្តីពិត ដទៃពីនេះ សុទ្ធតែជាមោឃៈទាំងអស់ ដូច្នេះឬ?

"ទេ ទេ វច្ឆ! ព្រះសម្ពុទ្ធតថាគតមិនមានការយល់ឃើញ–ទិដ្ឋិ ដូច្នេះទេ" ។

"សូមទ្រង់ព្រះមេត្តាប្រោស! បរិញ្វាជកវច្ឆគោត្រ ក្រាបទូលសួរ ដដែលទៀត! កាលខ្ញុំព្រះអង្គក្រាបទូលសួរខាងលើនេះ ព្រះមានបុណ្យ តបថា ទ្រង់មិនមានការយល់ឃើញ=ទិដ្ឋិ យ៉ាងនេះទេ ចុះដូច្នេះតើ

ព្រះមានបុណ្យមានការយល់ឃើញថា មានទោសដូចម្ដេចខ្លះ ?

"វច្ឆ! ព្រះសម្ពុទ្ធតបតទៅ តថាគតបានត្រាស់ដឹងថា (១) ធម៌ទាំងនេះជា ទិដ្ឋិសាំញ៉ាំ ជាទិដ្ឋិវង្វេង ជាទិដ្ឋិបះបើក ជាទិដ្ឋិ យ្វេងយ្វាង ជាទិដ្ឋិនាំសត្វឲ្យលិចទៅក្នុងអន្ទង់ទុក្ខ វេទុក្ខ លំបាក ចង្អៀតចង្អល់ ក្ដៅពេលពល មិននាំឲ្យនឿយណាយ ប្រាសចាកកាត់ រលត់ស្ងប់ ដឹងច្បាស់ ត្រាស់ដឹង និព្វាន ឡើយ" ។ តថាគតឃើញទោសនេះហើយ បានជាតថាគតមិនមានការយល់ឃើញ = ទិដ្ឋិ (Dogme) នោះឯង ។

សូមទ្រង់ព្រះមេត្តាប្រោស! បរិព្វាជកវច្ឆគោត្រក្រាបទូលសួរដេញតទៅទៀត ចុះព្រះមានបុណ្យ មានការយល់ឃើញ = ទិដ្ឋិ នេះបន្តិចបន្តួចខ្លះដែរឬទេ ?

មិនមានទេ វច្ឆ! ព្រះសម្ពុទ្ធត្រាស់តទៅទៀត តថាគតបានលះបង់ការយល់ឃើញ = ទិដ្ឋិ នេះចោលអស់ហើយ ព្រោះតថាគតបានត្រាស់ថា: "រូបដូច្នេះ ហេតុដែលនាំឲ្យកើតរូបដូច្នេះ ហេតុដែលនាំឲ្យរលត់រូបដូច្នេះ វេទនាដូច្នេះ ហេតុដែលនាំឲ្យកើតវេទនាដូច្នេះសញ្ញាដូច្នេះ

---

១- ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសំយោជនំ សទុក្ខំ សវិឃាតំ សឧបាយាសំ សបរិឡាហំ ន និព្វិទាយ ន វិរាគាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។

ហេតុដែលនាំឲ្យកើតសញ្ញាដូច្នេះ ហេតុដែលនាំឲ្យរលត់សញ្ញាដូច្នេះ សង្ខារដូច្នេះ ហេតុដែលនាំឲ្យកើតសង្ខារដូច្នេះ ហេតុដែលនាំឲ្យរលត់សង្ខារដូច្នេះ វិញ្ញាណដូច្នេះ ហេតុដែលនាំឲ្យកើតវិញ្ញាណដូច្នេះ ហេតុដែលនាំឲ្យរលត់វិញ្ញាណដូច្នេះ” ព្រោះហេតុនោះ បានជាតថាគតពោលថា: តថាគតរួចស្រឡះហើយ ព្រោះមិនប្រកាន់មាំ ព្រោះអស់ទៅ ព្រោះប្រាសចាករាគ ព្រោះរលត់ទៅ ព្រោះលះបង់ ព្រោះលាស់បោលចេញនូវសេចក្តីមមិលឆ្ងាយទាំងពួង នូវសេចក្តីបន្ទោកបន្ទាបទាំងពួង និងអហង្ការ មមង្ការ អនុស័យ (១) ទាំងពួង ។

សូមទ្រង់ព្រះមេត្តាប្រោស ! បរិញ្ជកវច្ឆគោត្រ ក្រាបសួរសេចក្តីផ្សេងមួយទៀត, ចុះភិក្ខុដែលមានចិត្តរួចស្រឡះហើយ វិមុត្តិចិត្ត តើទៅកើតឯណាទៀតដែរឬទេ ?

ម្នាលវច្ឆៈ ! ទ្រង់ត្រាស់តប, បើនិយាយថា: កើតទៀត ក៏មិនគួរ ។

សូមទ្រង់ព្រះមេត្តាប្រោស ! បរិញ្ជកវច្ឆគោត្រ ក្រាបទូលសួរទៀត, បើដូច្នោះ មានតែមិនកើតទៀត ឬ ?

ម្នាលវច្ឆៈ ! ទ្រង់ត្រាស់តប, បើនិយាយថា: មិនកើតទៀត ក៏មិនគួរ ។

សូមទ្រង់ព្រះមេត្តាប្រោស ! បរិញ្ជកវច្ឆគោត្រ ក្រាបទូល

(១) [illegible] ទិដ្ឋិ តណ្ហា មានៈ ទាំង៣ ប្រការនេះ ។

បន្ថែមទៀតបើដូច្នោះ មានតែ កើតទៀតខ្លះ មិនកើតទៀតខ្លះឬ ?

ទេ វច្ឆ ! ទ្រង់ត្រាស់តបបន្ថែម, បើនិយាយថា: កើតទៀតខ្លះ មិនកើតទៀតខ្លះ ដូច្នេះ ក៏មិនត្រូវដែរ ។

សូមទ្រង់ព្រះមេត្តាប្រោស ! បរិញ្វាជកវច្ឆគោត្រ ក្រាបទូលសួរបញ្ជាក់ទៀត, បើដូច្នោះ មានតែ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះឬ ?

ទេទេ វច្ឆ ! ទ្រង់ត្រាស់បញ្ជាក់, និយាយថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះ ក៏នៅតែមិនត្រូវដែរ ។

សូមទ្រង់ព្រះមេត្តាប្រោស ! បរិញ្វាជកវច្ឆគោត្រ ទុញទាល់គំនិត ក្រាបទូលដោយត្រង់ថា: ខ្ញុំព្រះអង្គមិនយល់ទាល់តែសោះ ខ្ញុំព្រះអង្គជាមនុស្សងងឹតងងល់អស់ទៅហើយ ។

"អើ វច្ឆ! ព្រះពិជិតមារត្រាស់បណ្ដោយតាម អ្នកមិនត្រូវយល់មែន អ្នកជាមនុស្សងងឹតងងល់មែន ; ព្រោះថា ធម៌នេះជ្រាលជ្រៅអ្នកឃើញបាន ដោយកម្រ ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់ ជាធម៌ថ្លៃថ្លា ប្រសើរ ត្រិះរិះ វិតក្កៈ មិនបាន ជាធម៌ល្អិតសុខុម មានតែអ្នកប្រាជ្ញទើបដឹងបាន ។

វច្ឆ អើយ! ទ្រង់ត្រាស់តទៅទៀត, ធម៌នេះ ខ្លួនអ្នកមានការយល់ឃើញ= ទិដ្ឋិ (Dogme) ដទៃ មានការពេញចិត្តដទៃ មានការគាប់ចិត្តដទៃ មានអាចារ្យដទៃ តែងដឹងបានដោយកម្រណាស់ ។

នែ វក្ក ! ទ្រង់ត្រឡប់សួរទៅវិញ, បើមានភ្លើងកំពុងឆេះនៅមុខអ្នក អ្នកក៏បានដឹងថា មានភ្លើងកំពុងតែឆេះនៅមុខអាត្មាអញដែរ បើមានគេសួរអ្នកថា ភ្លើងដែលកំពុងតែឆេះនៅក្នុងទីចំពោះមុខអ្នកនេះ អាស្រ័យដោយអ្វី ?

សូមទ្រង់ព្រះមេត្តាប្រោស ! បរិព្វាជកវក្កគោត្រក្រាបទូល, បើមានគេសួរខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងឆ្លើយថា ភ្លើងដែលឆេះនេះ អាស្រ័យដោយស្មៅនិងអង្កត់ឧស ។

អើវក្ក ! ទ្រង់ដេញសួរតទៅ, ចុះបើភ្លើងនេះ រលត់ទៅវិញទៅក្នុងទីចំពោះមុខអ្នក ហើយមានគេសួរអ្នកថា ភ្លើងដែលរលត់ទៅក្នុងទីចំពោះមុខអ្នកនេះ ទៅណា ? ទៅខាងកើត ឬខាងលិច ? ទៅខាងត្បូង ឬ ខាងជើង ? បើគេសួរយ៉ាងនេះ តើអ្នកដោះស្រាយថាដូចម្តេច ?

សូមទ្រង់ព្រះមេត្តាប្រោស ! បរិព្វាជកវក្កគោត្រ ក្រាបទូលដោយត្រង់ខ្ញុំព្រះអង្គក៏តាល់គំនិតនឹងដោះស្រាយដែរ ដឹងឆ្លើយដូចម្តេចក៏មិនត្រូវ ព្រោះមើលទៅឃើញ ស្មៅនិងអង្កត់ឧសឆេះអស់ទៅហើយ នៅសល់តែកំញម ឯភ្លើងរលត់បាត់អស់ទៅហើយ មើលមិនឃើញថាទៅឯណាទេ ។

អើវក្កអើយ ! ទ្រង់ត្រាស់ពន្យល់តទៅទៀត, ការបែបបុគ្គលបញ្ញត្តិ វេសត្វបញ្ញត្តិដោយរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។

រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាខន្ធបញ្ចកៈនេះ តថាគតលះបង់ចោលអស់ហើយ កាប់ឫសគល់ចោលបង់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក លែងកើតមានជា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ទៀតហើយ មិនកើតជាធម្មតា ។ តថាគតរួចស្រឡះ ចាកចំណែកនៃ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ នេះអស់ហើយ ជាអ្នកជ្រៅដោយគុណ ដែលបុគ្គលប្រមាណមិនបាន ស្ទង់បានដោយកម្រដូចសមុទ្រ ទើបថា កើតទៀតក៏មិនគួរ មិនកើតទៀតក៏មិនគួរ កើតខ្លះ មិនកើតខ្លះ ក៏មិនគួរ កើតទៀត ក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក៏មិនគួរដែរ ។

ទីបំផុត ធម្មកថា បរិព្វាជកវច្ឆគោត្រ ក្រាបទៀបបាទាគ្គ ព្រះសម្ពុទ្ធហើយពោលសរសើរពុទ្ធគុណថា:

"បពិត្រព្រះគោតមដ៏ចម្រើន ! មហាសាលព្រឹក្សដុះនៅជិតគ្រាមក្តី:នៅជិតនិគមក្តី ប្រកបដោយសាខាធំហើយដោយស្លឹកច្រើន ទើបឈើសាខា ធំហើយដោយស្លឹកនេះ វិនាសទៅដោយអនិច្ចតាធម៌ សំបកនិងក្រមរទាំងឡាយ វិនាសអស់ទៅ ស្រាយវិនាសអស់ទៅនៅសល់តែខ្លឹមសុទ្ធយ៉ាងណាមិញ ធម្មវិន័យព្រះអង្គនេះ បរិសុទ្ធ ផុតផង់អស់ពីសាខា ស្លឹកស្លឹក សំបក ក្រមរ ស្រាយលើង នៅសល់តែខ្លឹមសុទ្ធ យ៉ាងនោះឯង" ។

សូមទ្រង់ព្រះមេត្តាប្រោស ! បរិព្វាជវច្ឆគោត្រ ថាថ្លែងតទៅទៀត, ពុទ្ធដីកានេះ ពិរោះណាស់ ! ស្វាក្ខាតធម៌ នេះ ដូចជាគេផ្ងារនូវវត្ថុ ដែលគេផ្កាប់ ឬបើកនូវគម្របដែលគេគ្រប ឬក៏ដូចគេប្រាប់ផ្លូវដល់មនុស្សវង្វេង ពុំនោះសោតដូចគេដុតប្រទីបគ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា អ្នកមានភ្នែកភ្លឺ នឹងបានឃើញរូបទាំងឡាយយ៉ាងច្បាស់ ។

# រឿងគាមណិចន្ទ

ជាតកដ្ឋកថា ចក្កកាត

តិកនិបាតវណ្ណនា

សហជីវិន **ផល-ធិក** នៅពុទ្ធសាសនបណ្ឌិត្យ

---

## ការពិភាក្សាជ្រើសរើសរជ្ជទាយាទ

ក្រោយពេលដែលផុតថ្វាយព្រះភ្លើងបូជាព្រះបរមសព នៃព្រះបាទជនសន្ធ ព្រះចៅក្រុងពារាណសី យ៉ាងឧឡារិកក្រៃលែងរួចហើយ, នៅក្នុងថ្ងៃទី ៧ គណៈរដ្ឋមន្ត្រីចតុស្តម្ភ ព្រមទាំងព្រាហ្មណ៍ពិទូបណ្ឌិតករីភជានុសិដ្ឋ ជាក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក បានមកជួបជុំប្រជុំគ្នា នៅមហាសាលវិចិត្រ នាខាងមុខព្រះលានប្រាសាទពេជពាំង ដើម្បីជ្រើសរើសបេក្ខជនរជ្ជទាយាទ ទទួលគ្រងរាជសម្បត្តិតទៅ ។ បណ្ដាឥស្សរជនទាំងនោះ, ឥស្សរជនភាគមួយ ឲ្យយោបល់ថា “ព្រះករុណាជាម្ចាស់ជីវិត ដែលទ្រង់សោយព្រះទិវង្គតទៅ ប្រដិមានព្រះរាជបុត្រមួយព្រះរាជកុមារជាព្រះសន្តតិវង្សដែរ ប៉ុន្តែព្រះរាជកុមារនេះ នៅជាព្រះកុមារតូចពេក, ទើបនឹងមានព្រះជន្ម ៧ ឆ្នាំ ទោះបីទ្រង់ប្រកបលក្ខណ៍ល្អត្រឹមត្រូវព្រមទាំងគុណការៈលោកិយនេះបស់ក្នុងគុណពិតព្រះរាជនិមិត្តហើយ ក៏មិនគួរនឹងថ្វាយរាជ្យបានដែរ ពីព្រោះរាជសម្បត្តិ មិនមែនជាកំណាត់នៃផ្ទាល់របស់បុគ្គលម្នាក់ទេ

តាមពិត គឺជាភ័ព្វសំណាងនៃប្រជារាស្ត្រខ្មែរដែរ, បើព្រះរាជកុមារអង្គនេះ
នៅជាព្រះកុមារពេក រមែងតែខាតគន្ធច្រើន មិនយល់វែងឆ្ងាយ ចាត់
ការរដ្ឋ, ប្រទេសជាតិ នឹងធ្លាក់ចុះក្នុងអនាធិបតេយ្យ ដែលនាំឱ្យរាស្ត្រ
ប្រជាក្តៅក្រហាយមិនលែងឡើយ ” ។ តស្រដែងមួយភាគទៀត
ឱ្យយោបល់ថា “អស់លោកយល់ដូច្នេះ ក៏ប្រសើរហើយ ប៉ុន្តែ តាម
យោបល់យើងថា “មនុស្សពិសេស ដែលមានប្រាជ្ញា, ស្មារតី, បុណ្យ
ប្រសប់ក្រៃពេក មិនមែនទៅចំពោះតែកេស់ព្រឹទ្ធាចារ្យទេ គង់ក្មេងខ្លះ អាច
យល់ដឹងក្រៃពេកដែរ គឺមាន ។ អស់លោកជ្រាបហើយថា ហេតុអ្វីបាន
ជាព្រះមកុដរាជកុមារនេះ ទទួលបានព្រះនាមថា “ករុណាសម្តេចរាជ-
កុមារ ” ? ព្រោះតែរូបព្រះអង្គ ដោយលក្ខណៈព្រះកេស្រ្តជាដុំចង្កៀង
គញ្ចក់ក្រហម អញ្ចឹង ?, ព្រោះយើងថា “ព្រះកេស្រ្តក៏ជាដុំចង្កៀងនេះ
ឃើញថាសមហេតុផលណាស់ទៅទៀត គឺព្រះរាជកុមារនេះក៏វៃហួសពី
មនុស្សធម្មតា, បើប្រៀបធៀបនឹងវត្ថុមួយ, របស់នោះ ដូចជាញែកធាតុ
ប្រាប់ព្រះអង្គភ្លឺស្រស់ បើប្រៀបធៀបមកមនុស្សវិញ ក៏ដូចជាមនុស្ស
នោះ ប្រាជ្ញាវាងវៃដ៏ល្អ អាចរកបានតែព្រះអង្គដែរ ។ ហេតុដូច្នេះ
ហើយ [illegible] ដល់ប្រទេសជាតិ [illegible]
[illegible] ឡើយ ។ តាមយោបល់
[illegible]

សមគួរណាស់ គ្មានការវិនាសអន្តរាយអ្វីឡើយ ។

យោបល់តាំងពីនេះ បានចេញមុនក្រោយប្រឆាំងគ្នារស់រយៈវេលាជិត ២ ម៉ោង គឺដល់ម៉ោង ៧ ល្ងាច ក៏បានស្របគ្នាវិញថា ត្រូវធ្វើការពិសោធ ចំពោះប្រាជ្ញាញាណរបស់ព្រះរាជកុមារជាមុនសិន សឹមសម្រេចយកលទ្ធផលជាខាងក្រោយ ។

## វិញ្ញាសាពិសោធថ្វាយរាជសម្បត្តិ

កាំនៃចក្រ គឺ ឈ្នួលទេះ បានវិលមកដល់, ជម្ពាតតាំងឡាយ ដែលត្រូវស្ដិតក្នុងហោងនៃព្រះរាជពិធីថ្មីឲ្យត្រៀមស្រះពាន ក៏ប្រែជាចាប់បញ្ចេញស្នួស្រស់បំព្រង បន្ទប់ពេលចេញបុប្ផាប្រកបពណ៌ខៀវ ៗ និងផ្កាយគ៌នព្វយណបប, ព្រោះព្រះសុរិយាកំតាមទិសក្រោយ ដូចជាបង្ហាញនូវក្ដីរីករាយសប្បាយដែលកំពុងរីករាយហើយ ។

នៅមហាសាលវិនិច្ឆ័យខាងមុខព្រះបរមរាជវាំង, ខាងកើត, មានព្រះរាជវង្សានុវង្ស និងសេនាអាមាត្យមន្ត្រីនៃព្រះរាជាណាចក្រ ជាច្រើនរបអង្គុយលើជើងតាំងជាសត្តតដុះ ៗ, ហើយនៅខាងក្រៅវិញ, មានប្រជាជន កកស្រមាប់ ខ្លះឈរ ខ្លះអង្គុយ នៅជុំវិញសាល ។

មិនយូរប៉ុន្មាន, ក្រុមរាជបុរសបានឲ្យសញ្ញាថា ព្រះអាណាសម្ដេចរាជកុមារបានមកដល់ហើយ ៗ ខ្ពុមជនជាច្រើនរូប ឈរចាំថ្វាយព្រះកិត្តិយសនៅមាត់ផ្លូវចូលទៅកាន់មហាសាល ។ គេនាំព្រះរាជដំណើរ

ចូលទៅដល់ព្រះរាជបល្ល័ង្កមួយ ដែលវិចិត្របទារៀបចំយ៉ាងស្អាត នៅខាងមុខទីប្រជុំ ។ ឥស្សរជនទាំងអស់ ដែលក្រោកឈរចាំទទួលព្រះរាជដំណើរ ជាមួយនឹងសូរស័ព្ទជយឃោសនៃពួកប្រជារាស្ត្រ ក៏អង្គុយចុះទៅវិញតាមព្រះរាជបញ្ជា ។ ព្រះរាជកុមារទ្រង់មានព្រះសូរសីហនាទស្រស់ស្រាយរាក់ទាក់ជាមួយនឹងទីប្រជុំ មួយរំពេច ដោយសម្រួលព្រះឥរិយាបថបន្តិចមក ។ លំដាប់នោះ ប្រធានទីប្រជុំ បានបញ្ជាឲ្យភ្នាក់ងារ នាំវិញ្ញាសាចូលមកថ្វាយព្រះរាជកុមារ ។

## វិញ្ញាសាទីមួយ

កំពុងទន្ទេញផ្អាក សន្ទឹងនៅចាំហៀងខាងស្ដាំ ដែលបទារិចិត្រដោយសរសៃកំប្លុះមាស ជាក្បាច់ក្បូរស់រវើក បានបើកចេញ នូវរូបមនុស្សចម្លែកម្នាក់ ដែលដើរកណ្ដាលបុរសពុកមាត់ពីរនាក់ ។ មនុស្សនោះ ពាក់អាវ-ស-កត្រង់ ស្លៀកសំពត់ចងក្បិនស ហើយមានសំពត់សម្លុយផ្ទាំងពាទា សមកាត្តាជាអាពាវ្យយ៉ាងឯក ប៉ុន្តែ ពុកមាត់ក្រឡើមក្រឡើម ត្រូវនឹងមុខកំបុដផង នាំឲ្យអ្នកទាំងពួងលួចសើចសើរគ្រប់គ្នា ។ លុះដើរចូលទៅដល់ខាងមុខព្រះភក្ត្រព្រះរាជកុមារ, អ្នកនាំទាំងពីរនាក់ ក៏បង្គាប់ឲ្យមនុស្សនោះអង្គុយចុះ ហើយឲ្យថ្វាយបង្គំព្រះរាជកុមារ រួចឲ្យអង្គុយនៅមួយកន្លែងយ៉ាងស្រួល ។

ក្រោយដែលបុរសនោះ អង្គុយស្រួលបួលហើយ លោកបុរោហិតបានចូលទៅក្រាបថ្វាយបង្គំទូលព្រះរាជកុមារថា:

ៈ បពិត្រព្រះរាជកុមារជាម្ចាស់ ! សូមល្អងធូលីព្រះបាទ ទ្រង់ជ្រាបបុរសនេះ, នៅក្នុងរជ្ជកាលនៃព្រះបិតាព្រះអង្គ, លោកជាវិស្វករបច្ចេក-ទេសយ៉ាងជំនាញ ។ លោកចេះដឹងខាងវត្ថុវិជ្ជា អាចមើលស្គាល់ទឹកដីជ័យភូមិ រហូតដល់អាចមើលដឹង នូវភូមិឋានដែលមានកែវ ៧ ប្រការ ។ លោកជាអាចារ្យយ៉ាងសំខាន់ អាចស្គាល់នូវលក្ខណៈគុណ-ទោសរបស់ដី សូម្បីតែទីតាំង ព្រះរាជដំណាក់ទាំងនេះ ក៏លោកអាចារ្យនេះ បានកំណត់ឲ្យដែរ ។ បពិត្រព្រះរាជកុមារជាម្ចាស់ ! ដោយអាស្រ័យហេតុនេះ សូមព្រះអង្គទ្រង់ប្រោសប្រណីតែងតាំងលោកអាចារ្យនេះ ក្នុងឋានន្តរ-ស័ក្តិខ្ពង់ខ្ពស់ណាមួយ ដើម្បីជាប្រយោជន៍ដល់ព្រះរាជាណាចក្រ របស់ព្រះអង្គ ។

ព្រះអង្គម្ចាស់ លុះទ្រង់ព្រះសណ្តាប់ពាក្យលោកបុរោហិតក្រាបទូលដូច្នោះ ទ្រង់ពិនិត្យមើលរូបបុរសនោះដោយព្រះប្រាជ្ញាញាណ ពុំឃើញលក្ខណៈត្រង់ណាឲ្យសមនឹងពាក្យបុរោហិតក្រាបទូលសោះ ។ ផ្ទុយទៅវិញ ទោះបីព្រះអង្គនៅវ័យក្មេង ទើបនឹងមានព្រះជន្ម ៧ ឆ្នាំ ក៏អាចស្គាល់ច្បាស់ថា បុរសនេះ ពុំមែនជាជាតិមនុស្សទេ គឺពិតជាសត្វស្វា ពីព្រោះសត្វស្វា ទោះបីគេយកវាមកបង្ហាត់ឲ្យត្រាប់តាមអាការៈនៃមនុស្ស

ហើយគេគ្រាន់តែរកឲ្យដូចជាមនុស្សស្រុកខ្លួនសោធ ក៏វាពុំអាចបោលនូវលក្ខណៈជាស្វារបស់វាបានដែរ ហើយជាធម្មតារបស់សត្វស្វា វាមិនដែលចេះចាត់ការ ឬកសាងអ្វីមួយដែលពុំទាន់ស្រេច ឲ្យសម្រេចបានទេ ផ្ទុយទៅវិញ វាចេះដឹងតែខាងបំផ្លាញនូវអ្វីៗ ដែលគេធ្វើស្រេចហើយឲ្យហិនហោចទៅវិញតែប៉ុណ្ណោះ" ។ លុះទ្រង់ព្រះចិន្តាដូច្នេះហើយ ព្រះអង្គទ្រង់តបទំនង វិញ្ញាសានោះ ដោយព្រះគាថាថា :

ជាយំ យកាំ ភ្នុសលោ លោលោ អនេ រលីម្នុ ទោ
កាម៌ ករត ពោ បទ្ទសេយ្យ ឃរំ ធម្មមិធំ ភ្នុលំ ។

(ប្រែថា)

វានេះ ពុំមែនជាអ្នកប៉ិនប្រសប់ ខាងការចាត់ការ ឬ ស្ថាបនាផ្ទះសម្បែងបានទេ វាជាសត្វលីលា មានទម្រង់គប្បច ពូកែតែបំផ្លាញនូវអ្វីៗ ដែលគេធ្វើស្រេចហើយ តែប៉ុណ្ណោះ, ត្រកូលវានេះ មានតែចំនៀមដូច្នេះឯង ។

ឮព្រះបន្ទូលដូច្នោះ តស្សជនទាំងអស់ ក៏ទះដៃប្រសើរឡើង ជាសញ្ញានៃការយល់ស្របព្រះយោបល់ ហើយក្រាបទូលថា : ពិតប្រាកដដូចព្រះបន្ទូលមែនហើយ ។ ព្រឹត្តិការណ៍នេះ ក៏ប្រកបដោយជោគជ័យយ៉ាងក្រៃលែង ដោយការថ្វាយស័ព្ទសាធុការពរពីប្រជានិករដែលនៅ

រង់ចាំចង់ដឹងក្នុងរឿងដោះស្រាយនោះ ៗ រួចហើយ គេក៏នាំសត្វស្វា ក្លែងជាមនុស្សត្រឡប់ចូលទៅវិញ ៗ

## វិញ្ញាសាទីពីរ

ក្រោយពេលដែលស្ងប់ស្ងាត់ភាគស្ញប់ខ្សឹបខ្សៀវគ្នា ពណ៌នាសរសើរ អំពីព្រះប្រាជ្ញាញាណរបស់ព្រះរាជកុមារដ៏តូចនោះមកបន្តិច , រាំងខននៅដដែល ក៏បន្ទោះពេញរូបបុរសពិសេសម្នាក់ទៀត ដែលមានបុរសពីរនាក់ ដើរអមចូលមកក្រាបថ្វាយបង្គំព្រះរាជកុមារ ដូចមុនទៀត ។ បុរសនោះ ស្លៀកពាក់តាមរបៀបមន្ត្រីកិត្តិយសហ៊ានសង្ហា ប៉ុន្តែមានអាការៈប្រហែល គ្នានឹងបុរសលើកមុនដែរ ។ ក្រោយដែលបានអង្គុយនៅមួយកន្លែងសម គួរហើយ , លោកបុរោហិតព្រឹទ្ធាចារ្យ ក៏ចូលទៅប្រណិបត្តក្រាបទូលព្រះ រាជកុមារថា :

—បពិត្រព្រះរាជកុមារជាអម្ចាស់ ! បុរសឧត្តមនេះ កាលក្នុងរជ្ជ នៃព្រះបាទរាជបិតារបស់ព្រះអង្គ , គាត់ធ្លាប់បានធ្វើជាមន្ត្រីខាងតុលាការ ធំជាឧកញ៉ាយោមរាជ ច្រើនឆ្នាំហើយ , គាត់ជាបុរសជំនាញ ដេះចាំ ច្បាស់លាស់ណាស់ខាងតម្រាកាត់ក្តី ហើយក៏ស្គាល់ចិត្តអធ្យាស្រ័យ របស់មនុស្សម្នាផង ការកាត់ក្តី វិនិច្ឆ័យបានដោយយុត្តិធម៌ រាល់ករណី មួយប្រាកដដោយគ្រប់ , បពិត្រព្រះរាជកុមារជាអម្ចាស់ ! សូមព្រះអង្គ

ទ្រង់សង្គ្រោះប្រោសប្រាណព្រះរាជទានឋានន្តរស័ក្តិ ដល់បុរសនេះ ឲ្យបានជាបរិវារយកក្រសួងតុលាការ ដើម្បីជាប្រយោជន៍ ដល់ប្រជារាស្ត្ររួមជាតិរបស់ព្រះអង្គ ដូចពេលមុនផង ទើបសមគួរ, សូមទ្រង់ជ្រាប ។

ព្រះរាជកុមារ ទ្រង់ពិចារណារូបលក្ខណៈ របស់បុរសចម្លែកនេះ, ទ្រង់យល់ក្នុងអំពីពាក្យក្រាបបង្គំទូលរបស់លោកបុរោហិត, ទ្រង់មានព្រះចិន្តាថា «ធម្មតាមនុស្សទូទៅ ពុំឃើញមានមនុស្សណាម្នាក់មានរោមដុះស្រមូវដូចបុរសនេះសោះ, បុរសនេះ ប្រាកដជាពុំមែនមនុស្សជាតិទេ វាជាសត្វស្វា ជាសត្វឥតចិត្ត ។ វានេះ ប្រាកដជាពុំអាចធ្វើការកាត់ក្តីដូចពាក្យគេថានេះបានឡើយ ។ លុះទ្រង់ជ្រាបច្បាស់ដូច្នេះហើយ, ទើបទ្រង់មានព្រះបន្ទូលតបវិញ្ញាសា ដោយព្រះគាថាជាលើកទីពីរថា :

ន យិទំ ចិត្តវតោ លោមំ នាយំ អស្សាសិកោ មិគោ
សត្តំ មេ ជនសន្ធេន នាយំ កិញ្ចិ វិជានាតិ ។

(ប្រែថា)

រោមរបស់មនុស្សអ្នកមានចិត្ត ពុំមែនដូច្នេះទេ, វានេះ គឺជាម្រឹគដែលពុំអាចនឹងសម្រួលចិត្តនូវស្រ័យនៃជនទូទៅបានឡើយ, ព្រះបាទជនសន្ធៈម្ចាស់ ជាព្រះរាជបិតារបស់ខ្ញុំ ទ្រង់បានពោលទុកនូវក្បួនគម្រាថា “វានេះ ជាសត្វ [illegible] ចេះដឹងអ្វីបន្តិចឡើយ” ។

ឮព្រះបន្ទូលសួរសំណាងដូច្នេះ, ពួកឧត្តមមន្ត្រីទាំងអស់ ក៏ថ្វាយសទ្ទុសញ្ញាដូចមុន ជាមួយនឹងបណ្ដាក្រេត្ត ៗ គេកាំងឡាយ មានប្រើតាប្រមាទឲ្យយ៉ាងក្រៃលែង ចំពោះការពោលភាសាគយ៉ាងជាក់លាក់របស់ព្រះរាជកុមារដែលបិតទៅក្នុងកុមារភាពដូច្នេះ ៗ ក្រោយពេលដែលត្រូវនាំបុរសស្មានោះចេញទៅ ទិងពេលដែលស្ងប់ស្ងៀមបន្តិចមក គេក៏បញ្ជាឲ្យនាំបុរសម្នាក់ ចូលមកក្រោមបល្ល័ង្កគាល់ទៀត ៗ

## វិញ្ញាសាទីបី

កំនែនទៀតពិចិត្រដែលនោះ ហាក់ដូចជាពុំអស់ចិត្ត ក៏បង្ហូចចេញនូវរូបបុរសម្នាក់ ជាមួយនឹងអ្នកដើរតាមពីរនាក់មកទៀត ៗ បុរសនេះស្លៀកពាក់ស្អាតបាត តែសម្លៀកបំពាក់ពុំមានជាថ្លៃថ្នូរទេ តាមរបៀបដូចជាមនុស្សអ្នកស្រុកសាមញ្ញ ៗ បុរសទីបីនេះ ក៏មានជំហរភាបជាងអ្នកដើរតាម ហើយមានដំណើរតេះតះ ៗ ដូចជាបុរសទាំងពីរមុនដែរ ៗ ក្រោយពេលដែលបុរសនោះ លុតជង្គង់ ក្រាបថ្វាយបង្គំព្រះបរមរាជកុមាររួចស្ងៀមកន្ទុំសម្លឹងហើយ, លោកបុរោហិត ក៏ទូលទៅក្រាបបង្គំទូលព្រះរាជកុមារថា :

—បពិត្រព្រះរាជកុមារជាម្ចាស់ ! បុរសរូបនេះ ពិតមែនតែតាមជាមនុស្សមានរូបសម្រាក់ មិនសមជាទីពិតពិលមើលមើល នៃជនទូទៅមែន

ប៉ុន្តែ ក្នុងកាលរាជ្យរបស់ព្រះវររាជបិតាព្រះអង្គ, គាត់មានកេរ្តិ៍ឈ្មោះល្បីខ្ទរទៅទាំងនគរថា ជាអ្នកមានវត្តប្រណិប័តន៍ បម្រើមាតាបិតា ព្រមទាំងមានការគោរពគ្រូកូលរៀមច្បងណាស់ ទឹងរកបុរសណាមួយប្រដូច ដោយកម្រ ។ ហេតុនេះ គួរតែព្រះអង្គម្ចាស់! ទ្រង់មានព្រះមេត្តាប្រោសប្រណីសង្គ្រោះគាត់ផង ។

ម្តងនេះ, ព្រះរាជកុមារក៏ទ្រង់ពិនិត្យពិចារណារូបលក្ខណៈបុរសនោះ ដោយវិចារណញ្ញាណទៀត, ទ្រង់យល់ច្បាស់ថា "ធម្មតាសត្វស្វាទាំងឡាយ ជាសត្វមានចិត្តរពិលរពូចខូចណាស់, វាពុំដែលស្គាល់គុណទីងទោសចំពោះឧបការគុណនៃជនណាមួយ ហើយចេះដឹងធ្វើអំពើល្អតបតដល់គេវិញបានដូច្នេះទេ, វាអាចចេះធ្វើតែអំពើអាក្រក់ ទៅតាមចិត្តរពិលរពូចក្ខាម ៗ របស់វាតែប៉ុណ្ណោះ ។ លុះទ្រង់មានព្រះចិន្តាដូច្នេះហើយ ព្រះអង្គទ្រង់មានព្រះរាជបន្ទូលតបវិញ្ញាហា ដោយព្រះគាថា ជាលើកទីបី ថា:

ន មាតរំ បិតរំ វា ភាតរំ ភគិនិំ សកំ
ករេយ្យ តាទិសោ បោសោ សិដ្ឋំ ទសរថេន មេ ។

(ប្រែថា)

ព្រះបាទ ទសរថ ជាព្រះបរមរាជបិតារបស់ខ្ញុំ ទ្រង់បានប្រៀន

ប្រដៅផ្ទះថា "សត្វរបៀបនេះ វាមិនអាចនឹងចេះចិញ្ចឹមម្ដាយឪពុក ឬបងប្អូនប្រុស-ស្រីរបស់ខ្លួនបានទេ" ។

ព្រះបន្ទូលសូរសីហនាទលើកទីបីនេះ ក៏ប្រៀបបាននឹងសូរស័ព្ទគងរំពងនៃមហាភេរីដែលគេទូងឲ្យលាន់ឡើងនៅទីជិតត្នោះទឹកល្ហល្ហាច ។ ឯសូរសម្រែកគឹកកងហើយថ្វាយជយឃោស និងស័ព្ទសាធុការពរ របស់ប្រជាជនដ៏ណែនណាន់តាន់តាប់ ក៏លាន់ឡើងប្រៀបបាននឹងសូរលាន់គឃរបស់មហាភេរីដែលចេញមកពីផ្ទៃធំធេងនៃទឹកដែរ ។ ក្រោយពេលដែលឥស្សរជនទាំងអស់ថ្វាយយោបល់ស្រប ចំពោះព្រះរាជបន្ទូលហើយ, លោកបុរោហិត បានសុំព្រះរាជឱកាសថ្វាយព្រះរាជស្វាមីភក្តិ និងប្រកាសជាឧឡារិកចំពោះទីប្រជុំក្រុមប្រឹក្សាទាំងអស់ថា:

អស់លោកទាំងឡាយ ! នេះ ជាវារៈបញ្ចប់នៃវិញ្ញាសាពិសោធន៍ថ្វាយរាជសម្បត្តិ ។ អស់លោកភាគខ្លះ ដែលយល់ថា ព្រះរាជកុមារទ្រង់នៅក្នុងកុមារភាពពេក ក្រែងខ្វះព្រះវិចារណញ្ញាណ ពុំអាចនឹងដឹកនាំប្រជារាស្ត្របាននោះ ឥឡូវអស់លោកបានឃើញច្បាស់ផ្ទាល់ភ្នែកស្រាប់ហើយ ។ អម្បូលសត្វដែលមានអវយវៈដូចមនុស្ស ចេះដើរជើងពីរ ចេះក្រាបបង្គំ ចេះអង្គុយប្រណម ហើយតុបតែងស្លៀកពាក់ដូចជាមនុស្សសុទ្ធសាធ, ក៏ព្រះរាជកុមារទ្រង់ស្គាល់ច្បាស់ ពុំអាចអ្នកណា យកមកបន្លំបំភ័ន្តបង្អិលព្រះសតិសម្បជញ្ញៈព្រះអង្គបានឡើយ ។

ជាពិសេសទៅទៀត ព្រះអង្គទ្រង់ភាន់វៃជាបំផុត អាចជ្រើសរើសយកគាសិតក្បួនតម្រាដ៏បុរាណ យ៉ាងសមក្រៃលែង មកដោះស្រាយវិញ្ញាសានេះយ៉ាងត្រឹមត្រូវ ដែលមិនទាន់មានបុគ្គលណាមួយមកប្រដូចបានដោយស្រួលណាស់ ។ ដូច្នេះ កង់ទីនេះ យើងខ្ញុំនឹងសុំបញ្ចប់ការពិសោធ ហើយកំណត់វេលា ៧ ថ្ងៃខាងមុខទៀត ទើបនឹងសូមប្រកាសលទ្ធផលជាសាធារណៈ ។

ទីប្រជុំទាំងអស់ បានលាន់ឮសំឡេងសូរទះដៃ ជាសញ្ញានៃការយល់ព្រម ។ ប្រជាជននៅខាងក្រៅ ក៏ស្រែកជយឃោសលាន់រំពងគងគឹក ព្រមទាំងនាំគ្នាស្រែកថ្វាយប្រជាធិចំពោះព្រះរាជកុមារជាខ្លាំងរាក ស្ទើរក្តុកក្តឹកទីព្រះលាននៃព្រះរាជវាំង ។

បន្ទាប់មក ព្រះរាជកុមារទ្រង់មានព្រះបន្ទូលស្រស់ស្រាយ ជាមួយក្រុមឥស្សរជននិងប្រជាពលរដ្ឋទាំងនោះយ៉ាងរីករាយរួចហើយ ទើបព្រះអង្គទ្រង់និវត្តចូលកាន់ព្រះរាជដំណាក់វិញ ជាមួយនឹងព្រះរាជបរិវារយ៉ាងកុះករដូចកាលដែលព្រះអង្គយាងមកដែរ ។

លុះគម្រប់ ៧ ថ្ងៃ គឺកំណត់ពិធីទី ៨ , ក្រោយពេលដែលក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក និងឧត្តមជននៃព្រះរាជាណាចក្រ បានប្រជុំមតិគ្នាជាឯកច្ឆន្ទថានឹងថ្វាយរាជសម្បត្តិចំពោះព្រះរាជកុមារមក, ព្រះ[illegible] ក៏ចេញដើរគ្រប់ច្រកល្ហកទីវាំង ដើម្បីគោរពតាមប្រកាសលទ្ធផលនេះ ជូនជាដំណឹងដល់ប្រជាកស្រិកក្នុងព្រះនគរ ហើយជាពិសេស មិនបានស្តាប់

ប្រជាមតិនៃរាស្ត្រទូទៅផង ៗ ប៉ុន្តែ ប្រជារាស្ត្រខ្សត់ខ្សោយ រឹតតែត្រេក អរចំពោះការថ្វាយរាជសម្បត្តិនេះ ណាស់ទៅទៀត ៗ គ្រប់គ្នារង់ចាំ តែនឹងទៅថ្វាយព្រះពរក្នុងថ្ងៃរាជាភិសេកប៉ុណ្ណោះ ៗ

## ព្រះកិត្តិនាមល្បីល្បាញ

កាលដែលព្រះ មហាជនកជនអារដ្ឋនាយក ទ្រង់បាន ទទួលព្រះរាជាភិសេកជាឯកមហាក្សត្រិយ៍ តំណព្រះវររាជបិតា តាមប្រពៃ-ណីកម្ពុជហើយ ទ្រង់មានព្រះនាមថា ព្រះបាទ អានន្ទសម្ដេចរាជ បរមបពិត្រព្រះចៅក្រុងពារាណសីជាអម្ចាស់ជីវិតលើត្បូង ៗ ទ្រង់មានព្រះកិត្តិនាមល្បីល្បាញខ្ចរខ្ចាយទូទៅពេញទាំងសកលជម្ពូទ្វីបថា ជាអ្នកប្រាជ្ញម្នាក់ លើសលែងអ្នកប្រាជ្ញទាំងពួង, ការណ៍ណា ដែលពុំអាចគិតបាន ក្រៃលែង ក៏ព្រះអង្គអាចជ្រះមើលដោយព្រះវិចារណញ្ញាណ ឃើញច្បាស់ពិត ៗ ដូចជាទេវតាធាយថ្វាយ ៗ ហេតុដូច្នេះហើយ ទើបជាអ្នកនិពន្ធ បានចុះនូវរឿងហេតុ ១៤ រឿង ទុកជាពាក្យានុគន្ធប្រវត្តិរបស់ព្រះអង្គ ៗ

រឿងទាំង ១៤ នោះគឺ

គោលោ កុក្កុតា មាយោ ទេវ នន្ទ្យតោ [illegible] គោ ជគោ

គណិកោ តរុណី សប្បោ មិគោ [illegible] ទេវ

កាកោ គបគណ្ឌោ ទេវ អគ្គោ [illegible]

រឿងគោ ១ រឿងកូន ១ រឿងសេះ ១ រឿងជាងដែង ១ រឿងចៅសង្កាត់ ១ រឿងស្រីផ្កាមាស ១ រឿងស្ត្រីក្មេង ១ រឿងពស់ ១ រឿងសត្វម្រឹគ ១ រឿងសត្វទា ១ រឿងទេវតា ១ រឿងនាគ ១ រឿងតាបស ១ រឿងយុវជនព្រាហ្មណ៍ ១ ។

រឿងទាំង ១៤ នេះ មានប្រវត្តិទាក់ទងគ្នាជាលំដាប់លំដោយ ជាមួយនឹងលោកតា គាមណិចន្ទ ដូចពណ៌នាទៅខាងក្រោម ។

## លោកតាគាមណិចន្ទ

លោក គាមណិចន្ទ(១) ជាបុរសចាស់ម្នាក់ អាយុប្រមាណជា ៩០ ឆ្នាំហើយ ។ ជីវភាពរបស់គាត់សព្វថ្ងៃ ដោយកសិកម្ម ។ ភូមិផ្ទះរបស់គាត់ ទើបនឹងកឡើងថ្មី តាំងនៅចម្ងាយពីរាជធានី ប្រមាណជា ៣ យោជន៍ ឬ ៤៨ គីឡូម៉ែត្រ ។ គាត់រស់នៅជាសុខសាន្តជាមួយភរិយាកម្សត់ ដែលឥតមានកូនចៅម្នាក់សោះ ។ បើតាមប្រវត្តិរបស់គាត់, ដើមឡើយ, គាត់ជាមនុស្សអ្នកធំម្នាក់ គឺកាលដែលព្រះបាទជនស័ន្ធមហារាជទ្រង់គង់ព្រះជន្មនៅឡើយ, គាត់នេះឯង ជាមហាត្ថិក យ៉ាងជិតស្និទ្ធរបស់ព្រះអង្គ ប៉ុន្តែ ដល់ព្រះមហាក្សត្រិយ៍ជាបិតានេះ ទ្រង់ទិវង្គតទៅហើយព្រះបាទ អានាសមុទ្ទរាជ ជារាជបុត្រ ទ្រង់សោយរាជ្យឡើង, គាត់ក៏ប្រែបត្តទៅជាមនុស្សមានការនឿយណាយជីវភាពក្នុងវាំង

១- គាមណិ ប្រែថា អ្នកធំ ។

ដោយយល់ឃើញថាៈ កាលព្រះវរបិតាទ្រង់គង់នៅ, រូបគាត់ គឺជាមនុស្សចាស់ សមគួរណាស់ នឹងនៅបម្រើព្រះរាជា ប៉ុន្តែ ឥឡូវនេះព្រះរាជបុត្រនៅក្មេងក្មេងណាស់ ឡើងសោយរាជ្យ មិនសមគួរនឹងគាត់ដែលជាមនុស្សកញ្ចាស់ហើយនៅបម្រើសោះ ព្រោះថា តាមទំនៀមរាជ្យនីមួយ ៗ សមរម្យតែមនុស្សជារាជបម្រើមានវ័យស្រហុល ៗ គ្នាដែរ ៗ គាត់គិតដូច្នេះហើយ ក៏ត្រិះរិះជ្រើសរើសមុខរបរដែលនឹងត្រូវប្រកបចិញ្ចឹមជីវិត ៗ ឃើញថា កសិកម្ម ជាការងារល្អបំផុត ក៏សម្រេចចិត្តដើរចេញ ពីជីវភាពក្នុងរាជវាំង នាំភរិយាសម្លាញ់ទៅនៅស្រុកស្រែនេះឯង ៗ គាត់កាប់កាយរាស់ព្រៃយកដីធ្វើស្រែចម្ការ ប៉ុន្តែ ដល់រដូវភ្ជួររាស់ គាត់លែលគគោពុំមានបាន, ដូច្នេះហើយ បានជាភរិយាគាត់គិតគ្នាព្រមឲ្យគាត់ទៅខ្ចីគោមួយនឹមពីមិត្តសម្លាញ់របស់គាត់ម្នាក់ ដែលនៅមិនឆ្ងាយពីភូមិរបស់គាត់ប៉ុន្មាន ៗ លុះយកគោនោះ មកភ្ជួររាស់របកលំតាមសេចក្តីត្រូវការហើយ គាត់ក៏ឲ្យគោស៊ីស្មៅ ផុសណាន់សត្វពាហនៈហាក់ថាក់ថ្មម នាំត្រឡប់យកទៅឲ្យម្ចាស់វិញ ៗ ទៅដល់មុខផ្ទះ, គោទាំងពីរ ក៏នាំគ្នាដើរដេយទៅក្នុងក្រោលរាគមទម្លាប់ យ៉ាងស្រួល ៗ ជួនជាពេលនោះម្ចាស់គោ ទាំងប្តីប្រពន្ធ កំពុងតែរៀបចំនឹងបរិភោគអាហារពេលល្ងាច ស្រាប់តែឆាកទៅឃើញ គោមណាំងពួ ដែលនាំគោចូលមក, បុរសជាប្តី ក៏លើកដានឡើង ហាមាត់ប្រុងនឹងស្រែកហៅអញ្ជើញឲ្យពិសា

បាយ ស្រាប់តែប្រពន្ធទាញដៃចុះមកវិញ ជាសញ្ញាឲ្យឈប់ ។ លោកតាមណិចន្ទ ក្រឡេកទៅឃើញកិរិយាៈដូច្នោះ ក៏យល់ភ្លាមថា "អ្នកទាំងនុះ បម្រុងនឹងហៅគាត់ឲ្យចូលហូបបាយ", ប៉ុន្តែ ដើម្បីកុំឲ្យគេទើសទាល់ចិត្ត ដោយហេតុអ្វីមួយ, កាលបើឃើញគោចូលដល់ក្រោលហើយ គាត់ក៏ប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះវិញ ដោយឥតទាំងបានស្រែកប្រគល់ប្រាប់ ឬ លាម្ចាស់គោមួយម៉ាត់សោះ ។

ថ្ងៃដន្យពេលរាត្រីនោះ មានពួកចោរចូលទៅកាត់ក្រោល លួចយកគោទាំងនោះទៅបាត់ ។ ព្រលឹមឡើង ម្ចាស់គោដែលពុំបានដឹងថាចោរលួចគោសោះ ក៏ចុះទៅមើលក្រោល ស្រាប់តែពុំឃើញគោ ក៏នឹកគិតថា "អៃយ៉ា ! ចោរលួចគោអស់ហើ ! ធ្វើយ៉ាងម៉េចអំបេះ នឹងបានគោប្រើទៀត ? មានតែផ្លូវម្យ៉ាង គឺត្រូវទៅទារសំណងនេះ អំពីលោកតាមណិចន្ទ ទើបបាន ។ គិតហើយ បុរសនោះ ក៏ប្រញាប់ប្រញាប់ទៅរកលោក តាមណិចន្ទ ទាំងព្រលឹម ហើយសម្តីទារគោយ៉ាងកំណាចថា:

— នែ លោកតាមណិចន្ទ ឯណាគោយើង ?

— ទេ ! គោឯណាទៀត បើយើងយកទៅឲ្យវិញហើយ ?

— ចុះអ្នកឯងយកទៅឲ្យយើងពីអង្កាល់ តើបានប្រាប់ប្រគល់គោនោះដល់យើងដែរឬទេ ?

— យើងពុំបាននិយាយប្រគល់គោដល់អ្នកទេ ប៉ុន្តែ គោទាំងពីរច្បាស់ជាចូលទៅក្នុងក្រោលរបស់អ្នកពិតប្រាកដហើយ សូមអ្នក និងប្រពន្ធរបស់អ្នក ក៏បានឃើញនឹងភ្នែកដែរ ?

— ទេ! យើងពុំមានឃើញទេ, បើអ្នកពុំបាននិយាយប្រគល់គោដល់យើងហើយ ចាំបាច់ដែកក្ដី ត្រូវសងគោមកយើងវិញ ពីព្រោះគោពុំឃើញមាននៅក្នុងក្រោលទេ ។

— ទេ! មេចក៏ត្រូវឲ្យយើងសង, ពិតមែនតែយើងមិនបានប្រគល់ឲ្យ ប៉ុន្តែ គោទាំងពីរចូលក្នុងក្រោលហើយតើ ?

បុរសម្ចាស់គោ កាលដឹងថាលោក តាមណិបន្ធ ប្រកែកដាច់អហង្ការពុំព្រមសង ក៏ខុនរើសដុំក្រួសមួយដុំ លើកឡើងបង្ហាញលោក តាមណិបន្ធ ថា "នែ! នេះជាកដទូតនាំអ្នក បើអ្នកពុំព្រមសងដូច្នេះ ចូរអ្នកមកជាមួយនឹងយើង" ។

តាមសេចក្ដីតំណាលថា ទំនៀមទម្លាប់ក្នុងជនបទនោះ កាលបើមានការវិវាទចោទប្រកាន់រឿងហេតុណាមួយ រវាងគ្នានឹងគ្នា អ្នកដើមចោទមានសិទ្ធិ នឹងកោះហៅអ្នកចុងចោទ ឲ្យចូលខ្លួនទៅកាន់ព្រះរាជសម្នាក់ដោយវិធីតែងតាំងរាជបម្រើ គឺគេចាប់យកដុំក្រួស ឬគ្រឿងអ្វីមួយបង្ហាញអ្នកចុងចោទ ហើយប្រកាសប្រាប់ថា " ដុំក្រួសជាដើមនេះជាកដទូតនាំអ្នក ចូរអ្នកមក" តែប៉ុណ្ណោះ អ្នកចុងចោទត្រូវតែទៅតាម

អ្នកដើមហេតុជាកំហិត, បើពុំទៅទេ អ្នកចុងហេតុ នឹងត្រូវកដអាថ្យាជា ទម្ងន់ ៗ ព្រោះហេតុដូច្នោះហើយ បានជាលោក តាម ឈាំ ចន្ទ គ្រាន់តែឮពាក្យម្ចាស់គេថា "កជទូត" ប៉ុណ្ណោះ មិនហ៊ានរឹងទទឹង ក៏ព្រមចេញទៅជាមួយនឹងគេភ្លាម ៗ

គេដឹងចិត្តមិត្រភ័ក្តិ ក្នុងខណៈដែលជួយសម្រាលកិច្ចធុរៈ តែគេដឹងចិត្តអមិត្រ ក្នុងខណៈដែលជួយទម្ងន់តែទុក្ខសោកដល់គ្នានឹងគ្នាទៅវិញ ៗ

លោក តាម ឈាំ ចន្ទ ផ្ដាំភរិយាសម្លាញ់ឲ្យមើលកិច្ចការណា ដែលចាំបាច់ជាស្រេច ក៏ចេញដំណើរទៅជាមួយនឹងម្ចាស់គេ ដោយមុខស្រពោនស្រពាប់ដែលបង្ហាញនូវសេចក្ដីទុក្ខ តឹងចង្អៀតដើមទ្រូងជាទីបំផុត ៗ លោកដើរបណ្ដើរ នឹកឃើញរាសីអាក្រក់របស់លោកបណ្ដើរ, តើនឹងបានសំណាងមកពីណាសងគេ ? ៗ សង្ឃឹមការវិនិច្ឆ័យប្រកបដោយយុត្តិធម៌ នៃព្រះមហាក្សត្រិយ៍ក៏ពុំបាន ព្រោះទ្រង់នៅក្នុងកុមារភាពពេក ធ្វើម្ដេចនឹងយល់ហេតុការណ៍អាថ៌កំបាំងនេះបាន !, ឱ ! អាគ្នាអញនេះអើយ! ដើមឡើយថា ប្រឹងចៀសវាងជីវភាពក្នុងវាំង, គេចឲ្យឆ្ងាយពីវាំង, ចុះចង្រៃអី ក៏មកនាំបណ្ដាលឲ្យចូលទៅក្នុងវាំងវិញដូច្នេះ ! តើអញ មានអ្នកណាជាទីពឹង ? ៗ គាត់គិតជាមួយនឹងដំណើរដើរទៅ រហូតដល់ភូមិមួយ ៗ ព្រះទិនករ ក៏រះជិតថ្ងៃត្រង់ទៅហើយ គាត់ឃ្លានបាយពេកណាស់ ក៏និយាយប្រាប់ម្ចាស់គេថា : មិត្រអើយ! សូមមិត្រ

ឯង នៅរង់ចាំខ្ញុំត្រង់ទីនេះសិនហើយណា ! ខ្ញុំឃ្លានបាយណាស់, ខ្ញុំចូលទៅរកផ្ទះមិត្រសម្លាញ់ខ្ញុំម្នាក់តែមួយភ្លែត ទម្រាំតែខ្ញុំស្រស់ស្រូបបន្តិច ហើយខ្ញុំវិលមកវិញ នឹងទៅជាមួយអ្នកទៀត ។ ម្ចាស់គោ យល់ព្រមឲ្យទៅ ។ លោកក៏រួសរាន់ចូលទៅក្នុងភូមិ ដើរតម្រង់ទៅចំផ្ទះសម្លាញ់ចាស់ ។ ជួនជាវេលានោះ សម្លាញ់គាត់ពុំបាននៅផ្ទះ, នៅតែភរិយា ។ នាងភរិយា លុះឃើញលោកទៅដល់ ក៏ស្ទុះមកទទួលរាក់ទាក់សំណេះសំណាល សួរដំណើរ ។ លោកក៏ប្រាប់ថា :

— ខ្ញុំមានដំណើរទៅព្រះរាជវាំង ប៉ុន្តែ ចូលមកសុំបាយស្រស់ស្រូបបន្តិច ពីព្រោះខ្ញុំដើររមក រកុនវេលាបាយទៅហើយ ! ។

ឱ ! លោកបងកុំបារម្ភថ្វី ទោះបីសម្លាញ់លោកពុំនៅ ក៏នៅរូបខ្ញុំដែរ, សូមលោកនៅពិសាបាយនេះសិនចុះ, ប៉ុន្តែបាយម្ហូបស្រាប់ ពុំទាន់មានទេ, សូមសម្រាកខ្លួនបង្អង់បន្តិច ខ្ញុំនឹងដាំជូន ។

— ណ្ហើយ ! បើគ្មានបាយម្ហូបស្រាប់ទេ, ចូរនាងកុំខ្វល់រវល់អី ! ខ្ញុំសុំលាសិនហើយ ព្រោះដំណើរខ្ញុំប្រញាប់ណាស់ ។

— ទេ ! ទេ ! មិនព្រមទេ ! មកដល់ផ្ទះខ្ញុំហើយ ទៅវិញភ្លាមដូច្នេះ ខ្ញុំមិនព្រមទេ, សូមលោកបង្អង់តែបន្តិច ក៏ខ្ញុំអាចដាំម្ហូបជូនបានភ្លាម, ហើយបើលោករង់ចាំទៅ ក្រែងបានជួបនឹងសម្លាញ់របស់លោកផង, សុំកុំអាលទៅណា ! ។

ថាតែប៉ុណ្ណោះ គរុហានៃសម្លាញ់នោះ ក៏ស្ទុះស្ទាប្រញាប់ប្រញាល់បង្កាត់ភ្លើងចង្ក្រាន ទាញធ្នាំងឡើងទៅលើក្រង់អង្ករ ដើម្បីយកអង្ករដាក់ឆ្នាំងដាំបាយ ។ គួរឲ្យអាសូរណាស់! មិនដឹងជាចង្រៃអី ឲ្យក្លាត់ស្មៀតរបូតដៃដើងធ្លាក់ក៏រខ្ទិចមកដី, នាងទើបនឹងមានកូនក្នុងពោះ ៧ ខែផង ក៏រលូតកូនចេញមកយ៉ាងឈឺផ្សាស្ទើរបាត់ស្មារតី ។ ស្រាប់តែពេលនោះ ប្តីនាងក៏មកដល់ដែរ, ឃើញដូច្នោះ ក៏ស្រែកឡូឡាថា :

—ដឹះ! លោក តាមណិចន្ទ! ហេតុអ្វីក៏មកវាយប្រពន្ធយើងឲ្យរលូតកូន, ឲ្យកូនយើងស្លាប់អីចឹង ?

—ទេ! លោកអើយ! ប្រពន្ធមិត្តឯងរបូតដៃធ្លាក់ពីលើក្រង់អង្ករមកខ្លួននាងទេតើ!

—ទេ! មិនមែនទេ! អ្នកឯងច្បាស់ជាវាយប្រពន្ធខ្ញុំ, ហើយបើទុកជាអ្នកឯងមិនវាយ, ក៏អ្នកឯងប្រើប្រពន្ធខ្ញុំដែលមានផ្ទៃពោះធំប៉ុណ្ណឹង ឲ្យឡើងយកអង្ករដែរ!

—ទេ! ខ្ញុំឥតបានប្រើទេ, នាងស្ម័គ្រចិត្តឃាត់ខ្ញុំហើយធ្វើខ្លួនឯងទាំងអស់ទេតើ! ។

—ចុះបើកុំតែអ្នកឯងមកឲ្យរវល់ តើធ្វើម៉េចប្រពន្ធខ្ញុំនឹងទៅជាអ៊ីចឹង, អ្នកឯងច្បាស់ជាវាយប្រពន្ធខ្ញុំហើយ ត្រូវសងកូនខ្ញុំដែលស្លាប់នោះមកវិញទើបបាន ។

–លោកម្ចាស់អើយ ! តើខ្ញុំនឹងធ្វើដូចម្ដេចកើត បើកូនស្លាប់ដូច្នេះ, ហើយខ្ញុំទៀត ក៏គ្មានកូនមួយនឹងយកមកសងអ្នកទៀត តើខ្ញុំធ្វើយ៉ាងម៉េចទៅ ! ខ្ញុំឥតបានវាយប្រពន្ធអ្នកឯងទេ ! ៗ

បុរសប្ដី ដឹងថាលោកចង្កប្រកែករឹងរូស ក៏កើតក្ដៅក្ដួលឆួលឆេះ សោកសង្រេងអាណិតប្រពន្ធ និងស្ដាយកូន, ទុនរើសកម្បិតផ្ទាំងមួយបង្ហាញទៅថា:

–បើអ្នកឯងមិនព្រមសងទេ, នេះ ជាកាជួតនាំអ្នក, ចូរអ្នកឯងមកជាមួយនឹងយើង ៗ ជាតែប៉ុណ្ណោះ ក៏រៀបចំប្រពន្ធផ្ញើនឹងញាតិមិត្ត រួចចេញដំណើរជាមួយលោក តាមណាំចង្ក ៗ លោកតាមណាំចង្ក ក៏ត្រូវបានបុរសដើមចោទ ២ អ្នក ដើរអមនាំទៅ ៗ លុះចូលទៅដល់ជិតផ្លូវក្ដីមួយទៀត ស្រាប់តែឃើញបុរសម្នាក់រត់ហត់ឈ្លួបដេញស្ទាក់សេះមួយដែលរបូតដាច់ខ្សែចាប់ពុំបាន ៗ គង្វាលសេះ ឃើញសេះខ្លួនរត់តម្រង់មកជិតអ្នកទាំងបី ក៏ស្រែកថា លោកអុំអើយ ! ចោលសេះខ្ញុំឲ្យបែរមកវិញផង ?

លោកចង្ក ស្ទុះក្ដុតស្រែកបង្អើល ហើយរើសដុំថ្មមួយដុំចោលសេះនោះម៉ាំងជាបន្ទាន់ គួរឲ្យហួសចិត្តណាស់ ដុំថ្មគប់ល្មមសោះ ស្រាប់តែទង្គិកនឹងជើងសេះ ធ្វើឲ្យជើងសេះបាក់ផស់ ដូចជាដើមល្ហុងខ្ញ

បាក់ ៗ គង្វាលសេះ ឃើញសេះបាក់ជើងដួលស្រុប ដោយស្នាដៃលោកចន្ទ ក៏ក្តៅខ្លាំងណាស់ ស្រែកឡូឡាថា :

—ដើះ ! ម៉េចក៏អ៊ុំឯងចោលបំបាក់ជើងសេះខ្ញុំអីចឹង ?

—ទេ ! ក្មួយ, អ៊ុំចោលនេះ មានបំណងថា នឹងជួយដេញសេះតាមពាក្យអង្វររបស់ក្មួយទេ ! ស្រាប់តែទៅត្រូវចំជើងវាវិញ បាក់ខ្ទេចយ៉ាងនេះ, អ៊ុំឥតមានបំណងនឹងចោលបំបាក់ជើងវាទេ ! ។

—ខ្ញុំគ្រាន់តែឲ្យដេញសេះឲ្យបែរទៅវិញប៉ុណ្ណោះ អ៊ុំឯង ហ៊ានទៅចោលបំបាក់ជើងសេះខ្ញុំ, ឥឡូវត្រូវតែអ៊ុំឯងសងសេះខ្ញុំវិញ ទើបខ្ញុំសុខចិត្ត ។

—ក្មួយអើយ ! តើអ៊ុំបានសេះពីណានឹងសងក្មួយ ! ។

គង្វាលសេះ ខឹងប្រឡោត ស្តីបន្ទោសលោកចន្ទជាច្រើន រួចចាប់ក្រសមួយចុំជាពងទូត នាំលោកចន្ទ ធ្វើដំណើរទៅដូចជាបុរសឯទៀត ៗ នោះដែរ ។

ផ្លូវវាលស្រឡះធំធេងល្ហល្ហ តែដោយចិត្តលោកតាមណាំចន្ទ ណែនណាន់ដោយកង្វល់ទុក្ខព្រួយមួយរយចំពូក គាត់មើលទៅសព្វទិសទី ហាក់ដូចជាចង្អៀតណែនរកផ្លូវយាត្រាពុំបាន ។ គាត់ដើរទាំងមុខស្រពោនស្រពាប់ នឹកទៅវាសនាអភ័ព្វរបស់គាត់ ដែលគាត់ចង់គេចចៀសវាងមិនឲ្យជួបប្រទះអ្វី វាបេះតែប្រានឲ្យទៅជួបប្រទះ នឹងហេតុការណ៍

នោះៗ, ឱ! អញអើយ អម្បាលត្រឹមតែសំណាងគោមួយនឹម រកមិនបានទៅហើយ តើចាំបាច់និយាយអីទៅដល់ការត្រូវពិន័យរឿងលួចកូននិងសំណាងសេះទៀត, តើអញបានមកពីណាទៅ? អញនេះ ស្លាប់ទៅប្រសើរជាង ព្រោះថា ជីវិតនេះ ពិតជាមានតម្លៃខ្ពស់បំផុតជាងអ្វីៗទាំងអស់ តែចំពោះអញ ដែលជាប់រយោងដោយហេតុការណ៍សែនទុក្ខយ៉ាងនេះ តើជីវិតអញវាមានតម្លៃអ្វី? ការស្លាប់ដោយខ្លួនឯង ពិតជាស្រួលជាងការស្លាប់ដោយទារុណកម្មរបស់អ្នកដទៃ ។ លោកចង្កុមានទឹកមុខឡើងខ្មៅជាំ គិតមួយរយមួយសែនចំពូកពុំចុះឆ្លាយ លុះដើរទៅដល់ពាក់កណ្ដាលផ្លូវ ងាកទៅឃើញគុម្ពមួយមានជ្រោះម្ខាងបោតសន្ទឹមនៅជិតផ្លូវទៅ ។ គាត់ក៏បែរទៅនិយាយនឹងអ្នកដើមពោធទាំងបីនាក់ថា សូមអ្នកទាំងអស់គ្នាបង្អង់សិន ខ្ញុំឈឺចត់ជើងណាស់ ៗ ថាហើយ ក៏ចូលទៅក្នុងព្រៃ រួចដើរវាងឡើងទៅលើកំពូលភ្នំពោត ឈរលើកដៃប្រណមចំពោះទេវតា សច្ចាមួយសន្ទុះ ក៏ហក់រឹងទៅក្នុងជ្រោះយ៉ាងជ្រៅ ៗ ទម្ងន់ខ្លួនរបស់គាត់ធ្លាក់ស្ទូចជាដុំថ្ម ពោះប៉ះនឹងមែកឈើមែកឫស្សី ក៏បាក់ប្រាវធ្លាយទៅគ្មានសល់ ។ ប៉ុន្តែ មិនដឹងជាបែជន្យអ្វី កាលដែលធ្លាក់ប្រាវទៅ ស្រាប់តែជើងទាំងពីររបស់គាត់ ធ្លាក់ទៅចំលើស្មាជាងដែង (១) ម្នាក់ដែលកំពុងដញ្ញូខឫស្សី ៗ ជាងដែង ដោយឥត

១- ជាងត្បាញកន្ទេលឫស្សី ។

ដឹងខ្លួនសោះ ក៏ដួលផ្កាប់មុខ ទង្គុកក្បាលនឹងថ្មមាំង ដាច់ខ្យល់ម៉ាត់ស្លាប់មួយរំពេច ។ ឯលោកតាមណិចន្ទ ទៅជាប្រែខ្លួន តតេះតតះប្រវេប្រវាក្រោកឡើងបានវិញ ។ កូនកំលោះជាងដែក ដែលកំពុងជញ្ជូនឫស្សីជាមួយឪពុក ងាកទៅឃើញដូច្នោះ ក៏ស្រែកហៅយំគក់ទ្រូងស្ទុះទៅប្រសោបឪពុកដែលស្លាប់ ស្រែកពោលប្រកាន់លោកចន្ទថា

— យើ! តាចោរមនុស្សឃាត ម៉េចក៏អាឯងមកសម្លាប់ឪពុកអញ?

— មិនមែនទេ ក្មួយ! ខ្ញុំហក់ពីលើកំពូលភ្នំមកនេះ ដោយបំណងថា នឹងសម្លាប់ខ្លួនឯងទេ? តែមិនដឹងជាកាលកម្មអ្វី បានជាមកធ្លាក់ចំលើឪពុកក្មួយនេះទៅវិញ ។

— ទេ! ខ្ញុំមិនសុខចិត្តទេ! កន្លែងឯទៀតម៉េចក៏មិនលោត មកលោតលើឪពុកខ្ញុំឯណេះវិញ, ខ្ញុំមិនព្រមទេ ត្រូវសងឪពុកខ្ញុំវិញ ។

— ឱ! ព្រះម្ចាស់អើយ មនុស្សស្លាប់ទៅហើយ តើឲ្យខ្ញុំសងយ៉ាងម៉េចកើត ។

កូនជាងដែក ខឹងណាស់ ប្រទេចផ្តាសាលោកចន្ទជាច្រើន រួចលើកសពឪពុកដាក់មួយកន្ទែលស្រួលបួល ហើយកាន់ថ្មមួយដុំ បង្ខាញជារាជទូតនាំលោកចន្ទចេញទៅ ដូចអ្នកទុនៗដែរ ។

# បណ្ដាំលោកចៅសង្កាត់

ឥឡូវ លោកតាមហាចង្ក ទៅជាមានអ្នកដើរតាមដល់ទៅ ៤ នាក់ ដោយហែមជុំវិញនាំបណ្ដើរទៅ ៗ លុះទៅដល់ភូមិមួយ បាន ជួបនឹងចៅសង្កាត់ម្នាក់, ក្រោយដែលដឹងពត៌មានថា លោកចង្កទៅគាល់ ស្ដេច, លោកចៅសង្កាត់ ក៏អង្វរសុំឲ្យលោកចង្កនាំពាក្យបណ្ដាំទៅទូល ព្រះរាជាផង ។ លោកចង្ក ក៏សុខចិត្តព្រមទទួលយកទៅ ។ លោក ចៅសង្កាត់ត្រេកអរណាស់ និយាយប្រាប់ថា :

— កាលពីដើម ខ្ញុំនេះ តាមប្រក្រតី ជាអ្នកមានរូបសម្បត្តិស្អាត បាត មានទ្រព្យធនធានច្រើន មានយសបរិវារ ហើយគ្មានរោគាអ្វី បៀតបៀនទេ ស្រាប់តែមកដល់ឥឡូវនេះ ខ្ញុំនេះ បែរទៅជាអ្នកក្រី ក្រទុគ៌ត ថែមទាំងកើតរោគឈឺទៀតផង តើវាមានហេតុយ៉ាងម៉េច ក្នុងរឿងហ្នឹង សូមលោកមេត្តានាំទៅទូលព្រះរាជាឲ្យព្រះអង្គប្រោសដោះ ស្រាយឲ្យខ្ញុំផង ព្រោះឮល្បីល្បាញថា ព្រះរាជា ទ្រង់ជាអ្នកប្រាជ្ញ ព្រះអង្គនឹងដោះស្រាយបានពុំខាន ហើយលោក កាលវិលមកវិញ សូមមេត្តាយកព្រះរាជសាសន៍នោះមកប្រាប់ខ្ញុំផង ។

— បាទ ! មិនអីទេ, ចាំខ្ញុំនាំទៅទូលព្រះអង្គឲ្យ ។

## បណ្ដាំស្រីពេស្យា

លោកតាមហាចន្ទ លុះទទួលបណ្ដាំលោកមេស្រុកហើយ ក៏នាំគ្នាទៅរហូតដល់ភូមិមួយទៀត ។ ស្ត្រីផ្កាមាសម្នាក់ក្នុងភូមិនោះ បានឃើញលោកចន្ទទៅដល់ ក៏សាកសួរពត៌មានដូចមេស្រុកដែរ ។ លុះបានដឹងថា លោកទៅគាល់ហ្លួង ក៏អរណាស់ អង្វរករសូមផ្ញើពាក្យបណ្ដាំមួយទៅទូលព្រះពជាឲ្យទ្រង់ដោះស្រាយថា:

— លោកអុំ ! ខ្ញុំឮកិត្តិស័ព្ទល្បីថា ហ្លួងថ្មីយើង មានប្រាជ្ញាណាស់, សូមលោកអុំមេត្តានាំយកបណ្ដាំរបស់ខ្ញុំទៅផង ថា កាលពីដើម ខ្ញុំនេះ រកថ្ងៃឈ្នួលកបណាស់ ក៏ប៉ុន្តែដល់មកឥឡូវនេះ ស្ទើរតែរកស្លាមួយម៉ាត់ ធីពុំបានផង, មិនសូវមានគេមករកស្នេហ៍ស្និទ្ធនឹងខ្ញុំសោះ, តើរឿងហ្នឹងភយ៉ាងមេច ? សូមលោកអុំទូលសួរព្រះពជាហើយមកប្រាប់ខ្ញុំផង ។

— បាទ ! ចាំខ្ញុំទូលថ្វាយតាមបណ្ដាំនាង ។

## បណ្ដាំស្ត្រីក្មេង

លោក តាមហាចន្ទ ទទួលបណ្ដាំស្រីផ្កាមាសរួច, ក៏នាំគ្នាស្រូតដំណើរទៅទៀត ។ លុះដល់ភូមិមួយ បានឃើញស្ត្រីក្មេងម្នាក់ ក្នុងភូមិនោះ ។ ស្ត្រីក្មេងនោះ ឃើញលោកចន្ទទៅដល់ ហើយដឹងពត៌មាន ថាទៅគាល់ហ្លួង ក៏សុំផ្ដាំពាក្យបណ្ដាំទៅទូលព្រះពជាថា:

–សូមលោកអ៊ុំ មេត្តាក្រាបទូលសួរព្រះរាជាផង ថា នាងខ្ញុំនេះដូចជាចេះតែរសាប់រសល់ តក់ក្រហល់ក្ដៅក្រហាយ មិនអាចនៅទីផ្ទះរបស់ប្ដីខ្លួនបានសោះ ហើយទីងទៅនៅផ្ទះម៉ែឪខ្លួនឯណោះ ក៏មិនកើតដែរ, តើរឿងហ្នឹង វាមានហេតុបច្ច័យយ៉ាងម៉េច ? សូមលោកក្រាបទូលព្រះរាជា ហើយមកប្រាប់សេចក្ដីដោះស្រាយដល់ខ្ញុំផង ។

–មិនអីទេនាង ! ចាំខ្ញុំទូលស្ដេចឲ្យ ។

## រឿងពស់

ក្រោយដែលទទួលបណ្ដាំស្ត្រីក្មេងនោះហើយ លោកចង្កូទិនពួកអ្នកដើមហេតុ ក៏ស្រូតដំណើរទៅដល់ផ្លូវធំមួយ ។ កសិករម្នាក់ឃើញអ្នកទាំងបួនរូបកំពុងដើរទៅ ក៏ស្រែកសួរពត៌មាន ។ លុះបានដឹងថាទៅគាល់ព្រះរាជា, កសិករនោះ ក៏សូមផ្ដាំពាក្យទៅក្រាបទូលព្រះរាជាដោយដំណាលប្រាប់ថា :

–លោកអ៊ុំ ! នឹ ! នៅក្នុងជំបូកធំនោះ ដែលមានព្រៃស៊ុមទ្រុំជិតផ្លូវនេះ មានសត្វពស់មួយធំណាស់អាស្រ័យនៅ ។ តាមការណ៍សង្កេតរបស់ខ្ញុំ ក៏ដូចជាអ្នកភូមិទាំងអស់គ្នាដែរ ឃើញអាការៈរបស់ពស់នោះ ចំឡែកណាស់ គឺពស់នោះ កាលបើទីងចេញអំពីជំបូកទៅស្វែងរកចំណីអាហារ សូម្បីតែកំពុងត្រូវស្រេកឃ្លាន មានពោះដូរស្វត

មានសរីរៈរាងកាយស្គមស្វិតយ៉ាងណា ក៏ចេញទៅពីដំបូកលំបាកណាស់ ហាក់ដូចជាប្រឹងប្រអូសប្រទាញរាងកាយ ដែលពេញណែនចង្អៀត នឹងរន្ធពេក ប៉ុន្តែ ដល់ពេលត្រឡប់មកវិញ ទោះបីកំពុងឆ្អែតស្កប់ស្កល់ទាល់ក មានរាងកាយធាត់ថ្លោសធំយ៉ាងណាក៏ដោយ ក៏បែរជាចូលទៅយ៉ាងងាយរហ័សស្រួលពេក ហាក់ដូចជាគ្មានប៉ះនឹងមាត់រន្ធសោះ ។ លោកអុំ! សូមលោកអុំមេត្តាក្រាបទូលសួរព្រះរាជាផង ថា តើវាមានហេតុកេខយ៉ាងម៉េចក្នុងរឿងហ្នឹង ? ខ្ញុំសង្ស័យថា ហ្លួងប៉ាយើង ទ្រង់មានព្រះប្រាជ្ញាញាណ នឹងប្រោសព្រះរាជទានពាក្យដោះសាបានពុំខាន ហើយសូមលោកអុំមកប្រាប់ខ្ញុំផង ។

## រឿងសត្វម្រឹគ

លោកតាមណិចន្ទ ក៏បានព្រមទទួលបណ្ដាំរឿងពស់នោះហើយ នាំគ្នាធ្វើដំណើរតទៅទៀត, លុះចេញពីនោះបន្តិចទៅ បានជួបនឹងបុរសម្នាក់, បុរសនោះ ឃើញលោកចន្ទ និងបុរសទាំង ៤ នាក់ទៅដល់ ក៏រាក់ទាក់សួរដំណើរដូចអ្នកទាំងពួងដែរ ហើយក្រោយដែលបានឮថា ទៅថ្វាយបង្គំព្រះមហាក្សត្រិយ៍ ក៏មានចិត្តរីករាយ និយាយផ្ដាំឲ្យក្រាបទូលសួរព្រះអង្គថា :

— លោកអុំជាទីគោរព ! សូមលោកអុំនាំយកពាក្យខ្ញុំទៅទូលស្ដេច

ផង ថា : មានម្រឹគមួយ ជាសត្វរស់នៅអាស្រ័យនឹងស្មៅ តែពុំអាច អាស្រ័យស៊ីស្មៅបាន ចំពោះតែស្មៅនៅក្រោមដើមឈើធំ មួយដើមនេះប៉ុណ្ណោះ ពុំអាចស៊ីស្មៅនៅទីឯណាទៀតបានសោះ ហាក់ដូចជាស្មៅឯទៀត ពុំមែនជាធម្មជាតិសម្រាប់ញុំាងជីវិតឲ្យរស់នៅបានទេ, តើរឿងហ្នឹង វាមកពីហេតុបច្ច័យដូចម្ដេច ? ។ ព្រះរាជាជាម្ចាស់ ទ្រង់នឹងជ្រាបរឿងនេះពុំខាន ព្រោះបានឮកិត្តិនាមល្បីល្បាញ ថា ព្រះអង្គមានប្រាជ្ញាណាស់ ហើយសូមលោកអ៊ុំវិលមកប្រាប់ព្រះរាជសាសន៍នោះដល់ខ្ញុំផង ។

# រឿងសត្វទា

លោក តាមណាំ ចន្ទ ទទួលពាក្យបណ្ដាំនោះស្រេច ក៏ចេញពីទីនោះទៅទៀតបន្តិច បានជួបនឹងបុរសម្នាក់ទៀត ។ បុរសនោះ ឃើញលោក ចន្ទ ទៅដល់ ក៏សាកសួរអំពីដំណើរទៅដូចគ្នា រួចសូមផ្ដាំផ្ញើពាក្យទៅទូលស្ដេចថា :

—លោកអ៊ុំដ៏ចម្រើន ! មានសត្វទាមួយ បើទំនៅលើដំបូកនោះដូចជាពេញចិត្តសប្បាយរីករាយចិត្តនឹងទំនៅដោយសុខស្រួលណាស់ តែបើទៅទំនៅកន្លែងដទៃក្រៅពីនេះវិញ ហាក់ដូចជាតក់ក្រហល់ទំនៅពុំបានសោះ, សូមលោកអ៊ុំក្រាបទូលសួរព្រះរាជាផង ថា តើរឿងហ្នឹងវាយ៉ាងម៉េច បានជាដូច្នោះ ? រួចមកប្រាប់ខ្ញុំផង ! ។

## រឿងរុក្ខទេវតា

លោក តាមណិពន្ធ ទទួលបណ្ដាំនោះរួច ក៏ស្រូតរូតដំណើរទៅមុខទៀត ។ ដោយព្រះចន្ទក៏ចរជ្រេះសៀលបន្តិចទៅ កម្ដៅក៏ផ្សាយខ្លាំង នាំឲ្យអ្នកតាំងនោះនឿយហត់ក្នុងដំណើរ ក៏នាំគ្នាចូលឈប់សម្រាកនៅក្រោមម្លប់ដើមឈើមួយដែលនៅជិតផ្លូវធំ ។ រុក្ខទេវតាមួយអង្គ ដែលអាស្រ័យនៅទីព្រឹក្សានោះ លុះឃើញបុរសទាំងបួនចូលមកសម្រាកនៅទីនោះ ក៏និម្មិតឲ្យប្រាកដរូប ហើយចូលទៅសួរដំណើររបស់អ្នកទាំងនោះទៀត ។ លុះដឹងដំណើរសព្វគ្រប់ ក៏សុំផ្ដាំផ្ញើពាក្យទៅទូលសួរព្រះចៅជាអម្ចាស់ដែរ ថា :

– ខ្ញុំបានឮព្រះកិត្តិនាមល្បីល្បាញ ថា ព្រះពជា ជាមហាបណ្ឌិត, សូមលោកយកបណ្ដាំខ្ញុំទៅក្រាបទូលព្រះអង្គផង ថា : ខ្ញុំនេះ ពីដើមតែងតែបានទទួលលាភសក្ការបូជាអធិកច្រើនណាស់, ឥឡូវនេះ ស្រាប់តែមកអត្តៈខាត់ក្រីក្រ សូម្បីតែស្លឹកឈើមួយក្ដាប់ ស្ទើរតែគ្មានគេបូជាផង, តើរឿងនេះ វាមកពីអ្វី ? សូមលោកទូលសួរព្រះពជា ហើយមកប្រាប់ខ្ញុំវិញផង ។

## រឿងតាគាល

ក្រោយដែលបានទទួលបណ្ដាំរុក្ខទេវតាហើយ, បន្ទាប់ពីការឈប់

សម្រាលស្រួលបន្តិច លោកចៅក្ដីក៏នាំគ្នាបន្តដំណើរទៅទៀត រហូតដល់ស្រះមួយ ។ ទាំងអស់គ្នាក៏ចុះសំដៅទៅរកទឹកក្នុងស្រះ, ក្បែរផឹកទឹកលាងស្រឡាបខ្លួន ដើម្បីបន្ទោបង់ក្ដៅក្រហាយដោយកម្ដៅព្រះអាទិត្យ ។ ស្រាប់តែពេលនោះ នាគមួយដែលអាស្រ័យនៅក្នុងស្រះនោះ ផុសចេញពីផ្ទៃទឹកឡើង ហើយប្រែកសួរអំពីដំណើររបស់អ្នកទាំងប្អូន ។ អ្នកទាំងបួន ក៏ប្រាប់តាមដំណើររឿងរ៉ាវហេតុមុន ៗ នាគឮថាគេនាំគ្នាទៅគាល់ព្រះនរបតី, ក៏មានចិត្តរីករាយ សូមផ្ដាំផ្ញើពាក្យទៅក្រាបទូល ហើយរៀបរាប់ថា :

- លោកអ្នកអើយ ! ខ្ញុំឈ្មោះព្រះសមុទ្រថា ព្រះពជ៉ា ទ្រង់ជាអ្នកប្រាជ្ញ, សូមលោកក្រាបទូលសួរព្រះអង្គថា នៅក្នុងស្រះដ៏រមណីយដ្ឋាននេះ កាលពីដើម មានទឹកស្អាតថ្លាថ្លូវពណ៌ដូចកែវមណី, ស្រាប់តែឥឡូវនេះ ប្រែជាល្អក់ខ្ចប់ ដោយសារបង្ហាយពកម្ពាយតា, សូមលោកសួរបញ្ជាក់ព្រះរាជាថា តើមានរឿងហេតុអ្វីហ្នឹងម៉េច បានជាអ៊ីចឹងទៅវិញ, ហើយសូមលោកប្រាប់ខ្ញុំផង ។

## រឿងតាបស

បន្ទាប់ពីចាកចេញពីនាគ លោកចៅក្ដីក៏នាំគ្នាដើរមកដល់ទីរហោស្ថានដ៏ស្ងាត់ ជួបនឹងតាបសដែលគាស-

ស្រ័យនៅក្នុងទីនោះ ៗ ពួកតាបស បានសាកសួរអំពីដំណើរអ្នកទាំងនោះ លុះបានពត៌មានហើយ ក៏សូមផ្ដាំពាក្យទៅទូលថ្វាយព្រះរាជាដែរ ដោយរៀបរាប់ប្រាប់ថា :

— ពីដើមឡើយ នៅក្នុងទីអាពមនេះ ផលព្រឹក្សតូចធំ មានផ្លែរយោនរយោន ប្រកបដោយរសជាតិឆ្ងាញ់ពីសារផ្អែមក្រអូបឈ្ងុយឈ្ងប់ពន់ពេកណាស់, ស្រាប់តែឥឡូវនេះ រុក្ខជាតិទាំងនេះ ក៏ក្លាយទៅដូចជាអាកសំណល់ គ្មានឱជារសផ្អែមឆ្ងាញ់ពីសារអ្វីសោះ, សូមលោកទូលសួរព្រះរាជាផង, តើវាមានហេតុកេទយ៉ាងម៉េច ក្នុងរឿងហ្នឹង ? ហើយសូមមកប្រាប់អាត្មាទាំងឡាយផង ៗ

## រឿងយុវជនព្រាហ្មណ៍

លុះបានទទួលពាក្យបណ្ដាំពួកតាបស ហើយចេញផុតពីនោះទៅ, លោកចន្ទ ក៏នាំគ្នាដើរសំដៅទៅទ្វារព្រះរាជធានី តាមមហាវិថីមួយ ៗ មានវិទ្យាល័យមួយ តាំងនៅប្រទទឹងផ្លូវនោះ ៗ ក្រុមយុវជនព្រាហ្មណ៍ជាច្រើននាក់ ដែលនៅសិក្សាក្នុងវិទ្យាល័យនោះ បានឃើញលោកតាតាមណិចន្ទ ក៏នាំគ្នាស្រែកសួរ ៗ លុះដឹងថាលោកចន្ទ ចូលរាំងដូច្នោះ ក៏សូមផ្ដាំពាក្យទៅទូលសួរព្រះ សម្មតិទេព ដោយដំណាលប្រាប់ថា :

— លោកគ្រូជាទីគោរពអើយ! ពួកយើងខ្ញុំនេះ កាលពីដើម ឲ្យតែបានសិក្សាស្វាធ្យាយមន្តវិជ្ជាការណាណាហើយ, មន្តវិជ្ជាការនោះនោះ សុទ្ធតែនៅចាំប្រាកដ ជាក់ច្បាស់ណាស់, មិនដឹងជាព្រោះហេតុដូចម្តេច? ឥឡូវនេះ ស្រាប់តែបែរជាប្រឹងរៀនសូត្រមិនព្រមដក់ជាប់ចាំសោះ ដូចជាដាក់ទឹកក្នុងក្អមធ្លុះ, លែងប្រាកដប្រជា ភ្លេចភ្លាំងងងឹតដូចយប់ទៅវិញ សូមលោកទូលសួរព្រះរាជាផង ថា តើរឿងហ្នឹង វាមានបុព្វហេតុយ៉ាងម៉េច? ហើយសូមវិលមកប្រាប់ពួកយើងខ្ញុំផង ។

— មិនអីទេ ខ្ញុំនឹងនាំយកពាក្យបណ្តាំនេះ ទៅទូលសួរព្រះរាជាឲ្យអ្នកទាំងអស់គ្នាបាន ។

## ព្រះរាជវិនិច្ឆ័យ

លោកតាមណិចន្ទ លុះបានទទួលបណ្តាំដូច្នេះហើយ ក៏យាត្រាចូលរាជធានី ឆ្ពោះទៅកាន់ព្រះបរមរាជវាំង ។ ពេលនោះ ព្រះរាជា ស្តេចចេញប្រថាប់គង់មហាសាលវិនិច្ឆ័យ ។

## រឿងគោ

ក្រោយដែលបានព្រះរាជានុញ្ញាតហើយ បុរសជាម្ចាស់គោ ក៏នាំតាមណិចន្ទ ចូលទៅគាល់ ។ ឯព្រះរាជា រាជាសមុទ្រ ទ្រង់ទតឃើញលោក ចន្ទក្លាយ ក៏ទ្រង់ស្គាល់ច្បាស់ថា លោកតានេះ ធ្លាប់

ធ្វើជាមហាតលិករបស់បិតាអញ គាត់ធ្លាប់បានបី-ពថ្នាក់ថ្នមអញពីមុនមក ខ្វះដែរ ចុះគាត់ទៅនៅឯណាអេះ បានជាបាត់អស់ពេលទាំងប៉ុណ្ណឹង ។ ព្រះអង្គទ្រង់ព្រះចិន្តាហើយ ទ្រង់មានព្រះរាជទុក្ខសោកស្ងួរស្ងែសរ៉ាវ ដោយស្និទ្ធស្នាលថា:

— យី! លោកតាចន្ទទេតើ! ចុះលោកអញ្ជើញទៅណា បានជាបាត់ខ្លួនអស់ពេលទាំងម៉្លឹង, ខ្ញុំខានឃើញលោកយូរហើយ ហើយលោកអញ្ជើញមកនេះមានកិច្ចការធុរៈអ្វីដែរ ?

— សូមទ្រង់ព្រះមេត្តាប្រោស ចាប់តាំងតែអំពីព្រះសម្មតិទេពជាអម្ចាស់ទ្រង់សោយព្រះសុវណ្ណគតទៅម៉្លេះ ដែលទូលព្រះបង្គំជាខ្ញុំលួងចូ-លីព្រះបាទ បានចេញពីនេះទៅនៅអាស្រ័យឯជនបទ ប្រកបការកសិ-កម្មចិញ្ចឹមជីវិត តាមបែបជីវភាពនៃកសិករសាមញ្ញ, ឯដំណើរដែលទូលព្រះបង្គំជាខ្ញុំមកនេះ ដោយបុរសម្នាក់នោះទេះ បានបង្ហាញរាជទូតបង្ខំឲ្យខ្ញុំព្រះអង្គមកកាន់ព្រះរាជសម្នាក់នៃលួងចូលីព្រះបាទ ព្រោះមានបុព្វហេតុក្តីក្តាំអំពីរឿងគោ ។

— ល្អហើយលោកតា? លោកតាមានគំនិតល្អណាស់ មិនជាប់ជំ-ពាក់នឹងបុណ្យស័ក្តិ ស្ម័គ្រចិត្តទៅប្រកបរបរកសិកម្ម ដែលជារបរអាយុជី-វិតនៃមនុស្សលោក ខ្ញុំសូមសរសើរលោក, សូមចាត់ទុកលោកជាជនគម្រូដ៏ក្លាហាន ហើយខ្ញុំសូមអំពាវនាវ អស់អំពីដួងហឫទ័យ សូមឲ្យ

តម្រាប់ដ៏ល្អរបស់លោកនេះ មានប្រសិទ្ធិភាពដល់យុវជន និងឥស្សរជនទូទៅ, ឱ! លោកតា បើកុំតែមានគេបង្ខំឲ្យមក ប្រហែលជាលោកមិនមកជិតខ្ញុំទេមើលទៅ! ដូច្នេះ ការដែលគេបង្ខំឲ្យលោកតាមកនេះ ជាការល្អវិសេសដែរ ព្រោះជាហេតុឲ្យខ្ញុំបានជួបមុខលោកក្នុងពេលនេះ! ចុះបុរសម្ចាស់គោនោះ ណាមួយ ? នៅឯណា ? ។

លោកជន្ទ បង្ហាញប្រុសម្ចាស់គោ :

— បពិត្រព្រះសម្មតិទេព, នេះ!

ព្រះរាជាទ្រង់សួរបញ្ជាក់ទៅម្ចាស់គោ :

— មើលអ្នក! ឮថាអ្នកបានបង្ហាញរាជទូតដល់លោកតានេះ អ៊ីចឹងមែនឬទេ ?

ម្ចាស់គោក្រាបទូល :

— បពិត្រព្រះសម្មតិទេព! ពិតមែន!

ព្រះរាជា :

— ចុះមានរឿងហេតុយ៉ាងម៉េចទៅ ?

ម្ចាស់គោ :

— បពិត្រព្រះសម្មតិទេព! ព្រោះហេតុលោកនេះ ពុំព្រមសងគោមួយនឹម ដល់ទូលព្រះបង្គំវិញសោះ ។

ព្រះរាជា :

- មេចលោកតា! ដូចពាក្យគេថាក៏ចុះមែនឬ ?

លោកតាមណិចន្ទ :

—បពិត្រព្រះសម្មតិទេព! រឿងនេះសូមព្រះបពិត្រទ្រង់សណ្ដាប់ នូវទូលព្រះបង្គំជាខ្ញុំ ។ រួចលោកចន្ទ ក៏ក្រាបទូលប្រវត្តិសព្វគ្រប់តាំងពីទៅខ្ចីគោ រហូតយកគោទៅសងវិញ ទិងរហូតដល់ម្ចាស់គោទៅតាមទារយកសំណង ។

ព្រះកដាទ្រង់បែរមកសួរម្ចាស់គោវិញ :

— នែអ្នក! កាលគោចូលទៅក្នុងក្រោលក្រោយផ្ទះរបស់អ្នក តើអ្នកបានឃើញដែរឬទេ ?

ម្ចាស់គោ :

— ទូលព្រះបង្គំពុំបានឃើញទេ!

ព្រះកដា ទ្រង់បញ្ចេញព្រះសូរសីហនាទ យ៉ាងក្ដៀវក្ដាថា :

— នែអ្នក ! អ្នកឯងមិនធ្លាប់ឮអ្នកផងនិយាយថា យើង ជាស្ដេច នទាមព្រោកដជា ព្រះកដាមានព្រះកក្រ្ដាថ្វាធ្ងះមុះមុតដូចកញ្ចក់ទេឬអ្វី? ចូរអ្នកកុំនិយាយកុហក, ហើយចូរកុំគិតភ័យរង្កៀសចិត្តអី, ចូរនិយាយឲ្យត្រង់មក ?

ម្ចាស់គោភ័យរន្ធត់ ពុំអាចទឹនលាក់បាន ក៏ក្រាបទូលថា :

— បពិត្រព្រះសម្មតិទេព! ទូលព្រះបង្គំបានឃើញដែរ ប៉ុន្ដែ

លោកកាមណិចន្ទ ពុំបានប្រគល់គោឲ្យទូលព្រះបង្គំទេ ។

ព្រះរាជាទ្រង់ព្រះបន្ទូលទៅកាន់លោកចន្ទ :

— អើ ! លោកតាកាមណិ រឿងគោនេះ ត្រូវតែពិន័យលោកឲ្យសងគេចុះ ព្រោះលោកមិនបានប្រគល់ដោយស័ព្ទកថាទៅម្ចាស់គោ, ប៉ុន្តែ ចំពោះរូបបុរសម្ចាស់គោនេះវិញ បានឃើញដែរ តែរជានិយាយកុហកដោយចេតនាថា មិនបានឃើញៈទៅវិញ, ដូច្នេះ ចំពោះពួកចោរដែលជាអ្នកលួចគោ ជាការៈ របស់រាជការមានសមត្ថកិច្ចដេញអន្តិតរក, តែចំពោះរូបបុរសម្ចាស់គោនេះ ត្រូវលោកតាទទួលសិទ្ធិជាព្រះរាជអាជ្ញាធ្វើកម្មការ ខ្វៀលភ្នែកគាត់ទាំងប្រពន្ធទាំងប្តីឲ្យអស់ រួចលោកសងតម្លៃគោ ២៥ កហាបណៈទៅគាត់ចុះ ។

លុះព្រះរាជា ទ្រង់មានព្រះរាជឧត្តរៈដូចនេះហើយ ពួករាជបុរសក៏នាំបុរសម្ចាស់គោនោះឲ្យចេញមកក្រៅវិញ ។ បុរសម្ចាស់គោ ភ័យរន្ធត់ស្ញើរស្ញុតប្រាណ គិតថា “តើកមានប្រយោជន៍អ្វីអំពីតម្លៃគោ ២៤ កហាបណៈហ្នឹង បើអាត្មាអញត្រូវគេខ្វៀលភ្នែកឲ្យខ្វាក់អស់ទៅហើយ” ។ គាត់ឱនក្បាលក្រាបលូនទៅជិតបាទជើងលោកកាមណិចន្ទ អង្វរករថា “លោកម្ចាស់អើយ! រឿងសំណងគោនោះ ខ្ញុំឈប់ទារហើយ សូមឲ្យតែរូបគាប៉ុណ្ណឹងទៅ ហើយសូមលោកយកប្រាក់ប៉ុណ្ណេះទៀតទៅចុះ សូមកុំឲ្យតែខ្វៀលភ្នែកខ្ញុំ និងភ្នែកប្រពន្ធខ្ញុំធ្វើអ្វី?” ។ គាត់សូក

ប្រាក់ថែមទៀត ដើម្បីរក្សាចិត្តលោកចង្កូ ហើយបែងទៅទពាក់ទពាម កំប្រញាប់ប្រញាល់មិតទៅផ្ទះវិញ ។

## រឿងក្ងន

បន្ទាប់មក បុរសទីពីរ ក៏នាំលោកចង្កូចូលទៅទៀត ។ ព្រះរាជាទ្រង់សួរបុរសនោះថា:

– អើអ្នក ! ចុះអ្នកមានរឿងអ្វីដែរ ?

បុរសក្រាបទូល :

– បពិត្រព្រះសម្មតិទេព លោកតាមណាចង្កូនេះ បានស៊ីយប្រពន្ធទូលព្រះបង្គំឲ្យលួចកូន ។

ព្រះរាជាទ្រង់សួរទៅលោកចង្កូ :

– អីចឹងមែនទេ លោកតា ?

លោកចង្កូ :

– សូមព្រះមហារាជ ទ្រង់ព្រះសណ្ដាប់ទូលព្រះបង្គំ... ។

គាត់បានក្រាបទូលដំណើរយ៉ាងពិស្ដារសព្វគ្រប់ទូលព្រះរាជា, ព្រះរាជាទ្រង់បញ្ជាក់ទៀតថា :

– ក្រែងលោកតាបានស៊ីយប្រពន្ធបុរសនេះ ឲ្យលួចកូនមែនទេហ្អី ! ចូរប្រាប់ឲ្យត្រង់មក កុំលាក់ថ្វី ?

លោកចក្ខុ :

– បពិត្រព្រះសម្មតិទេព! ទូលព្រះបង្គំប្រាកដជាពុំបានវាយទេ!

ព្រះរាជាទ្រង់បែរទៅសួរបុរសនោះវិញ :

– នែអ្នក! អ្នកអាចធ្វើតក់ដែលអ្នកចោទថាលោកតានេះវាយឲ្យរលូតកូននោះ ឲ្យបានឡើងវិញភ្លាមឬទេ ?

បុរស :

–ខ្ញុំព្រះអង្គពុំអាចធ្វើបានទេ !

ព្រះរាជា :

– បើអីចឹង, ឥឡូវនេះ អ្នកនឹងគិតយ៉ាងម៉េចទៅវិញ ?

បុរស :

– ទូលព្រះបង្គំជាខ្ញុំ សុំឲ្យតែបានកូននោះមកវិញប៉ុណ្ណោះ !

ព្រះរាជា :

- បើអ៊ីចឹងងាយទេ! នែលោកតា! ត្រូវលោកទៅនាំយកប្រពន្ធបុរសនេះទៅទុកធ្វើជាគ្រួសាររបស់លោក ដរាបតែដល់នាងនោះកើតកូនមួយ សឹមនាំត្រឡប់ទៅឲ្យបុរសនេះវិញណា ! ។

ពួករាជបុរស គំនាំបុរសទាំងនោះចេញទៅក្រៅវិញ, បុរសនោះមានសេចក្តីព្រួយភ័យក្រៃលែង ក្រាបព្រួនចូលទៅជិតបាតជើងលោកចក្ខុ សុំអង្វរកុំឲ្យលោកចក្ខុបំបែកបំបាក់គ្រួសារខ្ញុំ រួចជូនប្រាក់

ស្ទូកចិត្តខ្លះទៀត ទើបប្រញាប់ប្រញាល់រត់ទៅផ្ទះវិញ ដូចជាអ្នកម្ចាស់គោដែរ ។

## រឿងសេះ

បន្ទាប់ពីនោះ បុរសទីបីជាគង្វាលសេះ ក៏នាំលោកចង្កូលទៅគាល់ទៀត រួចក្រាបទូលព្រះរាជាថា :

- បពិត្រព្រះសម្ពតិទេព ! លោកគា គាមណិចង្កូ នេះ ហោលបំបាក់ជើងសេះរបស់ទូលព្រះបង្គំ !

ព្រះរាជាទ្រង់សួរលោកគាចង្កូ :

- មេចលោកគា ? ដូចជាពាក្យគេថាអ៊ីចឹងមែនទេ ?

លោកចង្កូ ក៏ថ្វាយបង្គំក្រាបទូលព្រះរាជាតាមរឿងហូរហែ ។ ព្រះរាជទ្រង់បញ្ឆាក់ទៅអ្នកគង្វាលសេះថា :

- ពួថា អ្នកឯង បាននិយាយសុំឲ្យលោកចង្កូ វាយបំបែរសេះឲ្យមែនទេ ?

គង្វាលសេះ :

- ទូលព្រះបង្គំ ពុំបាននិយាយទេ ?

ព្រះរាជា :

- និយាយឲ្យត្រង់មក ! មែនឬពុំមែន ?

ឮព្រះសូរសីហនាទដូច្នោះ គង្វាលសេះស្ទើរស្មុគស្មោរតី ពុំអាចនឹងលាក់លៀមសេចក្ដីពិតបាន ក៏ក្រាបទូលតាមត្រង់ថា :

-.បពិត្រព្រះសម្មតិទេព ! ទូលព្រះបង្គំបាននិយាយមែន !

ព្រះរាជថា :

- អើលោកតា ! អ្នកនេះបាននិយាយមែន តែជាហ៊ាននិយាយមុសាវាទ ថាពុំបាននិយាយទៅវិញ, បើដូច្នោះត្រូវពេកកាត់អណ្ដាតបុរសនេះហាលចេញ រួចទៅយកសេះនោះមក ហើយចេញថ្លៃមួយពាន់កហាបណៈសងទៅបុរសនេះចុះ ។

គង្វាលសេះភ័យណាស់, លុះរាជបុរសនាំមកក្រៅហើយ, ក៏យកប្រាក់កាសទៅសូកលោកចង្ក សុំឲ្យតែរួចគ្នា កុំឲ្យលោកកាត់អណ្ដាតខ្លួន រួចប្រញាប់រួសរាន់វិលទៅផ្ទះវិញភ្លាម ។

# រឿងជាងថែង

ក្រោយដែលគង្វាលសេះចេញទៅផុត, កូនជាងដែង ក៏នាំលោកចង្កចូលទៅក្រាបបង្គំគាល់ទៀត ។ ក្រោយដែលបានព្រះរាជឱកាសហើយ ក៏ក្រាបទូលព្រះរាជាថា :

-បពិត្រព្រះសម្មតិទេព ! លោកតានេះ ជាចោរមនុស្សឃាតបានធ្វើឃាតកម្មចំពោះប្អូនឪពុកទូលព្រះបង្គំ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់សួរទៅលោក ចន្ទ :

- ម៉េចលោកតា ! អ៊ុចឹងមែនទេ ?

លោកចន្ទ ក៏ក្រាបបង្គំទូលដោយពិស្តារ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់មានព្រះបន្ទូលសួរកូនជាងដែកថា :

— បើអ៊ុចឹង, ឥឡូវនេះ អ្នកគិតយ៉ាងណាទៅវិញ ?

កូនជាងដែក :

— ទូលព្រះបង្គំ ចង់បានតែឪពុកមកវិញប៉ុណ្ណោះ !

ព្រះពុទ្ធ :

— នែអ្នក ! ឮថា អ្នកចង់បានតែឪពុកមកវិញប៉ុណ្ណោះ, ក៏ប៉ុន្តែធម្មតាមនុស្សដែលស្លាប់ទៅហើយ អ្នកណាឡើយ នឹងអាចប្រស់ឲ្យរស់មកវិញបាន, បើអ៊ុចឹង មានតែលោកតាទៅនាំយកម្តាយអ្នកនេះ មកធ្វើជាមេផ្ទះលោក ដើម្បីនឹងឲ្យលោកបានជាឪពុកអ្នកនេះផងចុះ ។

កូនជាងដែក ភ័យណាស់, លុះឮពុកផងបុរសនាំមកខាងក្រៅ ក៏ក្រាបអង្វរករលោកចន្ទថា : "ឱលោកម្ចាស់អើយ ! សូមលោកមេត្តាកុំបំបាក់បំបែកគ្រួសាររបស់ឪពុកខ្ញុំ ដែលទើបនឹងទទួលអនិច្ចកម្ម ដូច្នេះអី !, រឿងនេះ ខ្ញុំសូមរួចគ្នាទៅចុះ ហើយខ្ញុំសូមជូនប្រាក់នេះ ចំពោះលោក, សូមឲ្យតែលោកមេត្តាគ្រួសារឪពុកខ្ញុំផង" ។ កូនជាងដែកអង្វរករលោកចន្ទរួច ក៏រួសរាន់វិលទៅផ្ទះវិញ ដូចជាបុរសមុនៗដែរ ។

ក្នុងថ្ងៃនេះ លោកតាមណិចន្ទ មានជោគជ័យលើគូក្តីយ៉ាងត្រចះត្រចង់ជាអស្ចារ្យ, លោកមានចិត្តរីករាយណាស់ បានចូលទៅក្រាបបង្គំទូលព្រះរាជាថា :

– បពិត្រព្រះសម្មតិទេព មានអ្នកខ្លះទៀតពុំបានមកទេ ប៉ុន្តែបានផ្ញើពាក្យបណ្តាំមកសុំទូលសួរព្រះអង្គ បើព្រះសម្មតិទេព ពុំមានព្រះរាជហឫទ័យយល់ទាស់ទេ ទូលព្រះបង្គំជាខ្ញុំនឹងសូមព្រះរាជវរោកាសក្រាបទូល ?

ព្រះរាជា :

– មិនជាអ្វីទេ លោកតា! បាន, សូមលោកនិយាយចុះ ?

លោក តាមណិចន្ទ លុះបានព្រះរាជវរោកាសហើយ ក៏ក្រាបបង្គំទូលនូវរឿងមួយ ៗ ជាលំដាប់ហូរហែ ដោយទូលសាយករឿងយុវជនព្រាហ្មណ៍ជាទីមួយតទៅ ។ រីឯព្រះរាជា ក៏ទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ដោះស្រាយជាលំដាប់លំដោយ ជកបអស់រឿងទាំងនោះ ។

តើព្រះអង្គទ្រង់ដោះស្រាយយ៉ាងម៉េចខ្លះ ?

# រឿងយុវជនព្រាហ្មណ៍

ជាតម្បូង ព្រះអង្គទ្រង់សវនាការនូវពាក្យបណ្តាំទីមួយ ហើយទ្រង់ព្យាករព្រះបន្ទូលថា :

កាលពីដើម, នៅក្នុងទីអាស្រ័យរបស់យុវជនទាំងនោះ មានមាន់

ឈ្មោលមួយ ជាសត្វដឹងស្គាល់ពេលវេលាត្រឹមត្រូវ ហើយតែងតែរងាវ ជាសព្ទកយុវជនទាំងនោះជាប្រក្រតីទៀងទាត់ ។ ពួកយុវជនទាំងនោះ កាលបើឮសព្ទមាន់នោះរងាវជាស់ហើយ ក៏ភ្ញាក់ពីនិទ្រាក្រោកឡើង ធ្វើនូវការសិក្សា ស្វាធ្យាយ នូវមន្តវិជ្ជាដែលរៀន ៗ ខ្លួនបានសិក្សាហើយ និងត្រូវសិក្សាតទៅទៀត រួចស្រួលបួល ទើបអរុណរះឡើងច្បាស់ ។ ហេតុដូច្នេះហើយបានជា មន្តវិជ្ជាការទាំងឡាយណាណា ដែលគេបានរៀនរួចហើយ មន្តវិជ្ជាការនោះនោះ មិនងាយនឹងភ្លេចភ្លាំងបាត់ទៅវិញឡើយ ហើយវិជ្ជាដែលចាប់រៀនទៅមុខ ក៏ឆាប់ដក់ជាប់ចាំបានងាយ ពុំសូវលំបាក, ប៉ុន្តែ លុះដល់មកសព្វថ្ងៃនេះ នៅក្នុងទីអាស្រ័យរបស់គេទាំងនោះ បែរជាមានតែមាន់ដែលរងាវពុំទៀងទាត់ តាមពេលវេលានៅវិញ ។ មាន់នោះ ជួនកាល រងាវនៅពេលយប់ជ្រៅពេក ជួនកាល ក៏រងាវនៅពេលភ្លឺច្បាស់ហួសហើយ ។ ពួកយុវជនទាំងនោះ រវល់តែវិលវល់តាមសព្ទមាន់ គឺកាលបើក្រោកឡើងសិក្សាតាមសព្ទមាន់នោះរងាវក្នុងពេលយប់ជ្រៅពេក ក៏សិក្សាពុំស្រួល ព្រោះងងុយងោក, ម្ល៉ោះហើយ ក៏រៀនទាំងងោកងក់ដេកលក់ទៅវិញអស់, តែបើក្រោកឡើងសិក្សាតាមសព្ទមាន់នោះ រងាវក្នុងពេលភ្លឺច្បាស់ហួសហើយ ក៏ខំប្រឹងសិក្សាសូត្រហាត់នូវមន្តវិជ្ជាការដែលរៀនហើយពុំទាន់ ព្រោះផុតពេលនឹងស្វាធ្យាយ, ដូច្នេះហើយបានជា មន្តវិជ្ជាដែលពួកគេទាំងនោះ

បានសិក្សារួចហើយ ក៏ផ្លាស់ទាំងភ្លាំងក្អេចទៅវិញអស់យ៉ាងនេះ ។

# រឿងតាបស

ចំពោះពាក្យបណ្តាំទីពីរនេះ ព្រះអង្គទ្រង់មានព្រះបន្ទូលថា :

— ពួកតាបសទាំងនោះ កាលពីដើម ឧស្សាហ៍នាំគ្នាធ្វើសមណធម៌ ប្រកបរឿយ ៗ នូវកសិណបរិកម្មណាស់, ប៉ុន្តែ លុះដល់មកសព្វថ្ងៃនេះ បែរជានាំគ្នាទៅធ្វើតែអំពើមិនមែនជាសមណកិច្ចទៅវិញ ។ ផ្លែឈើតូចធំទាំងឡាយ ដែលកើតមាននៅក្នុងអាស្រមនោះ ក៏លោកដ៏ចម្រើនទាំងនោះ ចេះតែនាំគ្នាបេះបោចហុចឲ្យឧបដ្ឋាករៀង ៗ ខ្លួន, ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ តាមវិធីឲ្យទៅឲ្យមក ។ ព្រោះហេតុដូច្នោះហើយ បានជាឈើតូចធំក្នុងអាស្រមនោះ ចេះតែលេបហិនហោចទៅ ហើយទាំងផ្លែសោតទៀត ក៏ខ្សោះអស់រសជាតិផ្អែមឆ្ងាញ់ពីសា លែងដូចពីកាលមុន ៗ ប៉ុន្តែ ប្រសិនណាជាពួកលោកទាំងនោះ ត្រឡប់ជានាំគ្នាប្រឹងប្រែងប្រកបសមណធម៌ ដូចពេលមុនទៅវិញ ឈើទាំងនោះ ក៏នឹងបានល្អណាស់ ទ្រឈឹងទ្រឈៃមានផ្លែយោនយាន ប្រកបដោយជាតិទុជារសផ្អែមឆ្ងាញ់ពីសាឡើងវិញពុំខាន, តើពួកតាបសទាំងនោះ ពុំបានជ្រាបថាពជត្រកូលយើង ជាអ្នកប្រាជ្ញទេឬ? ចូរលោកតាទៅប្រាប់ពួកតាបសទាំងនោះ ឲ្យនាំគ្នាខំធ្វើសមណធម៌វិញទៅ ! ។

## រឿងនាគរាជ

ចំពោះពាក្យបណ្តាំទីបី ព្រះអង្គទ្រង់បំភ្លឺថា :

ប្តូរហេតុដែលបណ្តាលឲ្យស្រះដ៏រមណីយនោះ នៅជាមានទឹកកករ ល្អក់ខ្វល់ ដេរដាសដោយចកបាយភរ គឺមកពីពួកនាគទាំងនោះ ចេះតែឈ្លោះទាស់ទែងដេញប្រហាំគ្នា, បើប្រសិនណាជាពួកនាគទាំងនោះ មានសាមគ្គីស្រុះស្រួលនឹងគ្នា ដូចកាលពីដើមវិញ, ទឹកស្រះនោះ គង់នឹងរងថាធូរវិញពុំខាន ។

## រឿងរុក្ខទេវតា

ចំពោះពាក្យបណ្តាំទីបួននេះ ព្រះអង្គទ្រង់ពន្យល់ថា :

រុក្ខទេវតានោះ ពីដើម តែងជួយការពាររក្សាអ្នកដំណើរទាំងឡាយ ដែលដើរមកតាមផ្លូវជិតដងព្រៃនោះ, ហេតុដូច្នោះ បានជាពួកមនុស្សទួទៅដែលដើរមកដល់ទីនោះ ក៏នាំគ្នាធ្វើពលិកម្មជាច្រើនប្រការ ដល់រុក្ខ-ទេវតានោះ, ដល់មកឥឡូវនេះ រុក្ខទេវតានោះលែងរវល់ការពាររក្សាគេ បានជាលែងបានពលិកម្មអំពីគេដែរ, តែប្រសិនណាបើរុក្ខទេវតានោះ ខំប្រឹងថែរក្សាការពារមនុស្សទាំងឡាយ ដូចពីមុនទៀតនោះ, ក៏នឹងបានបរិ-បូណ៌លាភសក្ការៈដ៏លើសលប់វិញពុំខាន ។ រុក្ខទេវតានោះមិនបានដឹងថាព្រះរាជាជាអ្នកប្រាជ្ញទេ, ហេតុដូច្នេះ ចូរលោកតាទៅប្រាប់រុក្ខទេវតា

នោះ ឲ្យប្រឹងថែរក្សាការពារពួកមនុស្សដែលធ្វើដំណើរតាមដងព្រៃនោះវិញទៅ ។

## រឿងសត្វទទា

ចំពោះពាក្យបណ្ដាំទីប្រាំនេះ ព្រះអង្គទ្រង់ដោះស្រាយថា ៖

សត្វទទានោះ ដែលចូលចិត្តតែទំនៅលើដើមដំបូកនោះ ពីព្រោះនៅខាងក្រោមដំបូកនោះ មានកំណប់ទ្រព្យដ៏ល្អជាច្រើនកប់នៅ ។ ចូរលោកតា ទៅហើយគាស់យកកំណប់ទ្រព្យទាំងនោះ ទុកជាសម្បត្តិរបស់ខ្លួនទៅចុះ ។

## រឿងម្រឹគ

ចំពោះពាក្យបណ្ដាំទីប្រាំមួយនេះ ព្រះអង្គទ្រង់បញ្ជាក់ថា :

នៅទីនោះ មានដើមឈើមួយដើមយ៉ាងធំ ប្រកបដោយមែកនិងស្លឹកសាខា មានឃ្មុំមួយសំបុកធំណាស់ នៅលើដើមឈើនោះ, ម្រឹគនោះវាជាប់ចិត្តស្អិតទាញតែនឹងស្មៅ ដែលផ្កាយៈឡើមដោយជាតិដ៏ផ្អែមនៃទឹកឃ្មុំ នៅជុំវិញក្រោមព្រឹក្សានោះ បានជាពុំអាចនឹងទៅស៊ីស្មៅនៅទីដទៃទៀតបាន ។ ចូរលោកទៅយកផ្លិតនៃឃ្មុំដ៏ធំនោះ ហើយបញ្ចូនទឹកឃ្មុំដ៏ច្រើនមកឲ្យយើងខ្លះ រួចសេសសល់អំពីនោះ ចូរយកទៅបរិភោគខ្លួនឯងចុះ ។

# រឿងសត្វពស់

ចំពោះពាក្យបណ្តាំទីប្រាំពីរនេះ ព្រះអង្គទ្រង់បកថា:

នៅក្រោមដំបូក ដែលពស់នោះអាស្រ័យនៅ មានកំណប់ទ្រព្យដ៏ល្អល្អជាច្រើន, សត្វពស់នោះ ជាសត្វនៅរក្សាទ្រព្យនោះ, ព្រោះហេតុដូច្នេះឯង បានជាក្នុងកាលដែលវាទឹងចេញទៅស្វែងយកចំណីអាហារ, ដោយការជាប់ចំពាក់ចិត្តខ្លាំងនឹងទ្រព្យពេក ក៏ចេញទៅទាំងទើសទាល់ហាក់ដូចជាមានសរីរៈរាងកាយធំសម្បើមណាស់, លុះស្វែងរកចំណីអាហារបានហើយ, ក្នុងកាលដែលទឹងចូលទៅវិញ, ដោយចិត្តប្រតិព័ទ្ធស្នេហានឹងទ្រព្យនោះខ្លាំងពេក, វាស្ទុះរត់ចូលទៅយ៉ាងរហ័ស ហាក់ដូចគ្មានទើសទាក់នឹងអ្វីសោះ, ចូរលោកតាទៅគាស់កាយយកកំណប់ទ្រព្យនោះចុះ ។

# រឿងស្រីក្មេង

ចំពោះពាក្យបណ្តាំទីប្រាំបីនេះ ព្រះអង្គទ្រង់វិនិច្ឆ័យថា :

មានបុរសកំឡោះដ៏កុំព្រាខម្នាក់ ជាសាហាយរបស់ស្រីក្មេងនោះ ។ បុរសនោះ នៅក្នុងស្រុកមួយ ត្រង់រវាងចន្លោះកណ្តាលផ្លូវពីស្រុកខាងប្តីនាង ទៅស្រុកខាងម្តាយឪពុកនាង ។ នាងនោះ កាលណាទឹករសាហាយវា មិនអាចនៅនឹងផ្ទះប្តីបាន ក៏ប្រាប់ប្តីថា វាទឹងទៅលេងម្តាយ

ឳពុក ប៉ុន្តែ វាត្រូវទៅដេកនៅរួមស្នេហានឹងសាហាយវា ប្រមាណពីរបីយប់ ទើបវាទៅដល់ផ្ទះម្តាយឳពុក ។ លុះទៅនៅនឹងផ្ទះម្តាយឳពុកបានពីរបីថ្ងៃហើយ វានឹកមកសហាយវាទៀត; ទើបលាម្តាយឳពុកវា ថា វាទៅផ្ទះប្តីវាវិញ ប៉ុន្តែ បំណងវាចង់មកដេកស្នេហាតែនឹងផ្ទះសហាយវាជានិច្ចកាល, លុះវានៅរួមស្នេហ៍ស្និទ្ធអស់ចិត្តនឹងប្រុសវាពីរបីថ្ងៃរួច ទើបវាទៅដល់ផ្ទះប្តី ។ បូរលោកទៅប្រាប់ស្រីនោះផង ថា នគរនេះ ជានគរមាននះស្តុចសោយកផ្សដែរ, ចូរនាងនៅតែនឹងផ្ទះប្តីបានហើយ កុំប្រហែសធ្វេសប្រព្រឹត្តអនាចារគេទៅទៀតឲ្យសោះ, ប្រយ័ត្នតែអ្នកកជការចាប់បានមុខជានាងគ្មានជីវិតរស់នៅទេ ។

## រឿងស្រីពេស្យា

ចំពោះពាក្យបណ្តាំទីប្រាំបួននេះ ព្រះអង្គទ្រង់បង្ហាញន័យថា:

ស្រីពេស្យានោះ បានជាពីដើមបានថ្លៃឈ្នួល យ៉ាងច្រើនបរិបូណពីព្រោះមានទំនៀមទម្លាប់ទៀងទាត់ល្អ គឺបើទទួលថ្លៃឈ្នួលអំពីដៃប្រុសណាហើយ ក៏ព្រមទទួលស្នេហ៍ស្និទ្ធតែនឹងប្រុសនោះជាមុន មិនព្រមទទួលយកថ្លៃឈ្នួលអំពីដៃប្រុសដទៃទៀតឡើយ ប៉ុន្តែដល់មកឥឡូវនេះនាងនោះបានបោះបង់ទំនៀមធម្មតារបស់ខ្លួនចោលអស់ គឺបើបានទទួលថ្លៃឈ្នួលប្រចាំចិត្តពីប្រុសនេះហើយ មិនទាន់បានជាគ្នីនឹងគ្នាផង ក៏ទៅទទួលថ្លៃឈ្នួលពីដៃប្រុសម្នាក់ទៀត ហើយបើកដៃឲ្យប្រុសក្រោយនេះបាន

នុកាសមុន បណ្ដោះបណ្ដោយឲ្យប្រុសមុនខកប្រាណ ទៅជាបាននុកាសក្រោយវិញ ។ អំពើនេះឯង ដែលនាំបណ្ដាលឲ្យស្រីនោះ ធ្វើបរេតដើមខុននេះពុំប្រកប ហើយថ្លៃឈ្នួល ក៏បេះតែខ្សត់ទៅ ហូតដល់លែងមានប្រុសណាម្នាក់ទៅជិតស្នេហ៍ស្និទ្ធទាក់ទងសោះ, ប៉ុន្តែ បើបែរជាតាំងនៅក្នុងទំនៀមធម្មតា ដូចពីកាលមុនវិញ ស្រីនោះនឹងបានថ្លៃឈ្នួលបរិបូណ៌ដូចមុនវិញដែរ ។ ចូរលោកទៅណែនាំស្រីពេស្យានោះ ឲ្យប្រែទៅឋិតនៅក្នុងទំនៀមធម្មតាវិញទៅ ! ។

## រឿងចៅសង្កាត់

ចំពោះពាក្យបណ្ដាំទីដប់នេះ ព្រះអង្គទ្រង់បើកកាយ យ៉ាងច្បាស់ថា:

លោកចៅសង្កាត់នោះ កាលពីដើមឡើយគាត់ជាមនុស្សទៀងត្រង់កាត់ក្ដីដោយសុចរិតយុត្តិធម៌ សមរម្យតាមច្បាប់, មនុស្សក្នុងស្រុកទូទៅមានស្វាមីភក្ដិ ស្រឡាញ់ពេញចិត្តនឹងគាត់ណាស់ តែងនាំគ្នាយកគ្រឿងបណ្ណាការជំនូនដ៏ច្រើនទៅជូនគាត់ដោយស្មោះស្ម័គ្រ, ហេតុដូច្នោះហើយបានជាគាត់មានធនធានច្រើន មានរូបសម្បត្តិស្រស់បស់ បរិបូណ៌ដោយយសបរិវារ, ប៉ុន្តែក្រោយមក គាត់នេះទៅជាមនុស្សគម្រក់ ចូលចិត្តតែស៊ីសំណូកសូកប៉ាន់ លែងកាត់ក្ដីតាមច្បាប់ត្រឹមត្រូវទៅវិញ ។ ហេតុនេះ បានជាគាត់ទៅជាមនុស្សក្រទុគ៌ត កំព្រា តាំងត្រូវគេលើងញាំញី

ផង ៗ ការណ៍នេះ ប្រសិនណាជាគាត់ប្រែចិត្តគំនិតឲ្យល្អ គាត់ក៏ក្ដាំ តាមចំណាំច្បាប់ដល់អ្នកស្រុក ដូចពីដើមវិញ, គាត់ក៏គង់នឹងមានសភាព ដូចពីដើមវិញដែរ ៗ ចូរលោកទៅប្រាប់គាត់ ឲ្យគាត់ក៏ត្រឹមត្រូវតាម ច្បាប់វិញទៅ ។ ៗ

## ដំណើរនិវត្តនៃលោកគាមណិចន្ទ

ព្រះបាទ អាទាសមុខរាជ ជាអម្ចាស់ជីវិតលើត្បូង ទ្រង់បាន ដោះស្រាយបញ្ហាទាំងអស់សព្វគ្រប់ ដោយព្រះប្រាជ្ញាញាណ ដូចជាអដ្ឋ សព្ទាពាទ តាមពាក្យបង្គំក្រាបទូលរបស់លោក គាមណិចន្ទ ហើយ ស្ដេចទ្រង់ព្រះរាជទានទ្រព្យសម្បត្តិជាច្រើន ដល់លោក គាមណិចន្ទ រួចទ្រង់ប្រទានស្រុកដែលគាត់ទៅតាំងភូមិផ្ទះនៅហើយនោះ ឲ្យជាព្រហ្ម-ទានដល់គាត់ទៀត, រួចទ្រង់ព្រះរាជានុញ្ញាតឲ្យគាត់ត្រឡប់ទៅផ្ទះវិញ ។ លោក គាមណិចន្ទ ក៏បានធ្វើដំណើរចេញអំពីព្រះរាជធានីទៅគេហ-ដ្ឋានវិញ ដោយសុវត្ថិភាព ប៉ុន្តែ នៅតាមផ្លូវ គាត់បាននៀងចូលប្រាប់ ព្រះរាជសាសន៍ ដែលទ្រង់ប្រទានទៅនោះ ដល់ក្រុមយុវជនព្រាហ្មណ៍ ដល់ពួកតាបស ដល់គនានគរាជនិងដល់រុក្ខទេវតា ហើយទើបទៅគាស់ គាយយកកំណប់ទ្រព្យអំពីដំបូកដែលជាទ្រនំរបស់សត្វទា រួចទៅយក ឃ្មុំអំពីមហាព្រឹក្សជាទីដែលម្រឹគស៊ីស្មៅ ហើយបញ្ជូនទឹកឃ្មុំដំបៅនោះ

ទៅថ្វាយព្រះរាជា ។ លោកទៅគាស់ទម្លាយដំបូកដែលជាទីនៅអាស្រ័យរបស់ពស់ កាយយកទ្រព្យកំណប់ទាំងនោះជាស្រេច ទើបធៀងដំណើរចូលទៅប្រាប់ព្រះរាជសាសន៍ ដល់ស្ត្រីក្មេង ដល់ស្ត្រីពេស្យា និងដល់ចៅបង្កាត់ តាមលំអានសេចក្តី ដែលព្រះរាជាទ្រង់មានព្រះរាជឱង្ការ ។ គាត់បានធ្វើដំណើរទៅកាន់ស្រុកភូមិរបស់គាត់ ដោយយសស័ក្តិ យ៉ាងអធិកឧត្តម ហើយក៏ចាត់ចែងទីឋានតាំងនៅជាស្ថាពរ ក្នុងស្រុកដែលជាព្រហ្មទានរបស់ព្រះរាជានោះ ជាសុខក្សេមក្សាន្ត ដរាបដល់អស់ជន្មាយុ ។

## ជាអវសាន

ព្រះបាទអាធាសមុទ្ររាជ ជាបរមក្សត្រិយ៍អម្ចាស់ជីវិត ព្រះអង្គទ្រង់មានព្រះបរមនាមកាន់តែល្បីល្បាញខ្ទាំងខ្ទរទៅពេញសកលជម្ពូទ្វីប ហើយព្រះអង្គ ទ្រង់បំពេញព្រះរាជកុសលមានទាននិងសីលជាដើម ជារៀងរាបដរាបដល់អវសាននៃព្រះជន្មាយុ ។ លុះទ្រង់សោយព្រះទិវង្គតទៅ ស្តេចទៅកើតនៅឋានសួគ៌ទេវលោក ជាសុខក្សេមក្សាន្តហោង ។

-ចប់-

# វិចារណកថា

## របៀបនិយាយ

លោក ដេង - ស្រីវ រៀបរៀង

---

ការនិយាយស្តីជាការតម្រូវចាំបាច់សម្រាប់មនុស្សលោក ដូចជាសត្វទាំងឡាយដែលត្រូវតែចេះស្រែក ចេះរោទ៍ ចេះហៅ ចេះច្រៀង យំហូច ព្រុសដូច្នោះដែរ ។ល។ មនុស្សគ មនុស្សថ្លង់ ក៏អាចរស់នៅបានដូចមនុស្សផងទាំងពួងដែរ គ្រាន់តែមានជីវភាពពុំសូវបានចេញមុខស្រឡះស្រឡំដូចគេប៉ុណ្ណោះ ។

អត្ថប្រយោជន៍ និងអនត្ថប្រយោជន៍ បណ្តាលមកពីការនិយាយស្តីនៃមនុស្សមានច្រើនអនេកប្បការណាស់ ។ ដូច្នេះការអប់រំក្នុងការនិយាយស្តី រមែងហុចនូវលទ្ធផលដ៏ប្រសើរ ចំពោះមនុស្សទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។

តាមការកត់សំគាល់និងការសង្កេតឃើញ គឺមានមនុស្សភាគច្រើនណាស់ ដែលគ្មានការអប់រំខាងការនិយាយស្តីសោះ ។ បានសេចក្តីថាមនុស្សចូលចិត្តនិយាយតែការក្លែងបន្លំ ចូលចិត្តនិយាយយកបាតដៃជាខ្នងដៃ ចូលចិត្តនិយាយបង្ហើងជាន ។

តើហេតុដូចម្តេច ក៏មនុស្សចូលចិត្តតែប្រព្រឹត្តដូច្នេះ ? ចម្លើយមានដូចតទៅ : បុព្វហេតុដែលនាំឲ្យមនុស្សនិយមនិយាយស្តីតែបែបនេះ គឺ

នៅត្រង់មានចិត្តជាប់ជ្រុលហួសប្រមាណទៅលើសម្ភារៈនេះឯង ។ ចិត្តមនុស្សណាក៏ដូចចិត្តមនុស្សណាដែរ គឺឋិតនៅក្រោមក្រញាំដ៏មុតសាហាវនៃតណ្ហា មិនអាចងាករេរួចទៅណាបានឡើយ ។ សម្ភារនិយមនេះហើយ ជាសមាជិកសំណប់ទីមួយរបស់តណ្ហា ។ ដូច្នេះពាក្យថាតណ្ហានិងសម្ភារនិយម ស្ទើរតែអាចទុកជាវេវចនៈនឹងគ្នាបាន ព្រោះព្រះពុទ្ធបរមគ្រូទ្រង់តែងត្រាស់ប្រៀនប្រដៅថា: តណ្ហាជាអ្នកផ្តល់សុខទុក្ខដល់មនុស្សលោក ។ ពិនិត្យសង្កេតទៅឃើញថា ព្រះឱវាទដ៏ថ្លៃថ្លានេះមានសារៈបំផុត វិញ្ញូជនទាំងឡាយនិយមនាំគ្នាកំចាត់ពោលនូវតណ្ហានេះ តែជាការណ៍លំបាកក្រៃលែង ត្បិតតណ្ហាឬសម្ភារនិយមនេះ ជាការណ៍ចាំបាច់របស់មនុស្សទៅហើយ ។ រឿងនេះ មានឧបមាដូចមាណពណាម្នាក់រូបស្អាត ត្រូវពួកមហាចោរក្នុងព្រៃក៏ចាប់បំរុងយកទៅសម្លាប់ ដោយប្រការណាមួយ ។ នៅពេលណាខ្លួនមិនព្រមទទួលស្នេហានៃធីតាជាកូនមហាចោរនោះទេ ខ្លួនមុខជាជៀសមិនផុតពីជីវិតក្ស័យឡើយ ។ ដើម្បីឲ្យបានរួចរស់ជីវិត មាណពយើងនោះកាតព្វកិច្ចត្រូវតែបណ្តោយខ្លួនឲ្យចូលទៅប្រឡាក់ប្រឡូស ជាមួយធីតាកូនមហាចោរនោះទើបបាន ។ តែការព្រមសុខចិត្តទទួលស្នេហានៃធីតានេះ គឺគ្រាន់តែជាមធ្យោបាយ ជាស្ពានសម្រាប់ឈានរំដោះ អាត្មាចេញពីកណ្តាប់ដៃមហាចោរតែប៉ុណ្ណោះឯង ។ រីឯមនុស្សលោកសព្វថ្ងៃ ភាគតិចជាអប្បបរមាណាស់ដែលមាន

គំនិតដ៏ប្រពៃបែបនេះ ។ ហេតុដូច្នេះ ទើបគេជួបប្រទះតែមនុស្សប្រើពាក្យសំដីកាឡៃស្ទើរតែគ្រប់រូប ។ គេនិយាយជាមួយយើងថាយ៉ាងនេះ តែដល់គេអនុវត្ត រំផុយពីសម្ដីដែលបាននិយាយរួចហើយនោះទៅវិញ ។ ដូច្នេះហើយ ទើមនុស្សបង្កើតជាទ្រឹស្ដីមួយ ហើយដែលមនុស្សសព្វថ្ងៃលើកយកមកប្រតិបត្តិស្ទើរកល់គ្នាថា: "ស៊ីឲ្យសាច់ មិនត្រូវប្រាប់ព្រៃ" ។

តាមការសង្កេត ឃើញថាការអនុវត្តិទ្រឹស្ដីនេះ រមែងផ្ដល់នូវលទ្ធផលដ៏គាប់ប្រសើរពិតប្រាកដមែន គ្រាន់តែប្រាសចាកមនុស្សធម៌ប៉ុណ្ណោះ ជាមនុស្សធម៌ ដែលបណ្ឌិតទាំងឡាយ គ្រប់សម័យនិយមគោរពជាហូរហែមកនោះ ។ ទាំងនេះ សឲ្យឃើញថាទ្រឹស្ដី ដែលគេបានបង្កើតមកនេះ មានប្រសិទ្ធិភាពខ្លាំងណាស់ ខ្លាំងពាល់តែមនុស្សទូទៅអត់ទ្រាំពុំបាន ត្រូវតែលើកយកមកអនុវត្តស្ទើរតែគ្រប់គ្នា ដែលជាហេតុបណ្ដាលឲ្យកើតជាក្មេងចេះសន្ទោសន្ទៅ មួងត្រង់នេះ មួងត្រង់នោះ ទីបំផុតគឺចេះទូទៅទាំងក្នុងពិភពលោក ។ ឯរបៀបនិយាយរបស់គេ មានច្រើនប្រការដូចតទៅ បើមានម្នាក់ចង់សឲ្យបានគួរសម ហើយសួរទៅម្នាក់ទៀតដែលមានកោតទ្រព្យគួរសមថា "បងឯងទៅលក់ត្រង់កន្លែងណា ភូមិណា ស្រុកណា ខេត្តណា បានជាលក់ដាច់ដាច់អស់ហើយចំណេញក៏ច្រើនផង ?" ។ គេមិនប្រាប់ត្រង់ទេ បើគេទៅលក់ឯកើត គេប្រាប់ថាឯលិចទៅវិញ ដោយមានគំនិតចង់រក្សាទុកកន្លែងនោះសម្រាប់

តែខ្លួនមួយ ៗ –"បងឯងទៅចាប់ត្រីបឹងណា ? គេថាបឹងផ្សេងក្រៅពីបឹងដែលគេទៅចាប់នោះ ។ ហេតុដល់កិច្ចការផងទាំងពួង មានកិច្ចការរដ្ឋជាដើម គេនិយមយកតែសីលទី ៤ មកញាំញីជានិច្ច ដោយឥតកោតញញើតនឹងទទួលនូវវិបាកឡើយ ។

ដូចយ៉ាងក្នុងពេលខ្លះ គេនិយមនិយាយគម្រាម និយាយសំឡុត និយាយបំភ័យប្តូបន្ទាប ដើម្បីស្វែងរកអត្ថប្រយោជន៍ ក្នុងពេលខ្លះ គេនិយាយអង្វរដ៏ផ្អែមល្ហែម និយាយទទូចហើយទទូចទៀត និយាយសរសើរបញ្ជោរលើកដើង ឥតអៀនខ្មាស ជួនកាលហេតុដល់និយាយហួសហេតុ ទាល់តែបរិភោគដីផងខ្លួនក៏មានដែរ ក្នុងកណ្តាលជំនុំចំណោម នេះក៏ព្រោះតែសម្ការនិយម បានសង្កត់គន្លងជាប់ វត្ថុរូបនេះឯង ។

ចំពោះការប្រើពាក្យសម្តីក្នុងរឿងក្លូវិញ ជាបឋម គឺរុក្ខសំដីផ្អែមត្រជាក់វិស័យទឹកឃ្មុំ តែសូមកុំប្រហែសធ្វេសឱ្យសោះ លោតែក្អាត់ស្អៀតទៅក្នុង ដោយខ្វះដើងឧក មុខជាត្រូវទទួលថ្នាំពិសចូលពោះ ក្អែកឡើងសដូចក្អែកក្រើស្មោមិនខានឡើយ ។ ព្រោះពាក្យសំដីដែលគេយកមកប្រើក្នុងការទូត ប្រើជាពាក្យកេងយកតែផលប្រយោជន៍ សម្រាប់តែប្រទេសនីមួយ ៗ ដែលគេជាតំណាងរៀងខ្លួននោះ ។ សារុបសេចក្តីទៅ ការប្រើពាក្យសម្តីរបស់បុព្វជន វៀរលែងតែក្នុងការលេងសើច គឺត្រូវតែជាន់ឈ្លីនូវសីលទី ៤ ជានិច្ចកាល ។

មែនពិត អ្វីៗ ទាំងអស់របស់លោកិយ សុទ្ធតែមានភាពពិសេសជាធម្មតា ៗ គេនិយាយក្រឡាប់ផ្កាប់ផ្ងារ បាតដៃជាខ្នងដៃ ជាមួយអ្នកដទៃ តែគេគង់គោរពសីលទី ៤ ម្ដងម្កាលដែរ ជាមួយកូនចៅរបស់ខ្លួន ជាមួយកល្យាណមិត្តរបស់ខ្លួនខ្លះមិនខាន នេះក៏ព្រោះតែចង់ឲ្យបរិវាររបស់ខ្លួនបានទទួលផលប្រយោជន៍ ៗ មនុស្សទាំងអស់ មិនដែលពេញចិត្តចង់ឲ្យមនុស្សផងគ្នាមានឋានៈឧត្តុង្គឧត្តមដូចខ្លួនឡើយ វៀរលែងតែសាច់ញាតិខ្លះចេញ ៗ ដោយទ្រង់យល់ច្បាស់យ៉ាងនេះហើយ ទើបព្រះពុទ្ធបរមគ្រូដែលជាអច្ឆរិយបុគ្គល ទ្រង់ប្រៀនប្រដៅទុកមកថា: "អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោសិយា" ដែលមានន័យខ្មែរថា: "ខ្លួនត្រូវតែទីពឹងខ្លួន ខានពុំបានឡើយ ព្រោះអ្នកដទៃ មិនអាចជាទីពំនឹងរបស់ខ្លួនបានពាល់តែសោះ" ។ ន័យរបស់ព្រះពុទ្ធឱវាទនេះ មានភាពដ៏ជ្រាលជ្រៅក្រៃលែង គឺថាអំពើរបស់មនុស្សបើចង់ឲ្យមានប្រសិទ្ធិភាពត្រូវតែកុំពឹងលើអ្នកដទៃ តែក្នុងទីនេះខ្ញុំលើកយកតែវាចាមកពោល និងទុកជាគោលបំណង សម្រាប់វែកញែក ៗ ព្រះពជសម្ភារទ្រង់ថែងទុកមកថា: "កុំទុកចិត្តអតិប្បាយ" ៗ បើយកផ្នែកភាសិតនេះមកវែកញែកក៏អាចបញ្ចូលទៅក្នុងព្រះពុទ្ធឱវាទខាងលើនេះបានផងដែរ គឺថាពាក្យសម្ដីរបស់អ្នកដទៃ ស្ដីអំពីការស្វែងរកផលប្រយោជន៍ មិនត្រូវយកទុកជាមូលដ្ឋាន សម្រាប់ការស្រាវជ្រាវរកអត្ថប្រយោជន៍ ដើម្បីអាត្មាបាអញជាមាំ

មួយឡើយ ។ ព្រោះសេចក្ដីថារបៀបនិយាយរបស់មនុស្សលោក មិនគប្បីទុកជាប្រមាណឡើយ ត្រូវតែលើកយកមកពិចារណាត្រិះរិះ ឲ្យបានហ្មត់ចត់បន្តិចប្រសិនបើគេចង់អនុវត្តរបៀបនិយាយនេះ ។

សូមជម្រាបបញ្ជាក់ជាទីអវសានថា គឺសីលទី៤នេះហើយ ដែលជាប្រភពនៃសុខសន្តិភាព និងជាប្រភពខាងបណ្ដុះបណ្ដាលពូជមនុស្សរបស់មនុស្សនៅក្នុងបរលោក ។ ផ្ទុយទៅវិញការមិនគោរពសីលទី ៤ នេះហើយដែលជាប្រភពនៃអសន្តិសុខ នៃសង្គ្រាមដែលយើងធ្លាប់បានដឹងតាមប្រវត្តិសាស្ត្រ និងធ្លាប់បានស្គាល់ដ៏ជាក់ស្ដែងក្នុងសម័យបច្ចុប្បន្ននេះ ។

រួមសេចក្ដីទៅ យើងជាមនុស្សត្រូវតែខំដុសខាត់សីលទី ៤ នេះឲ្យបានស្អាតផូរផង់ មិនគប្បីបណ្ដោយឲ្យសម្ភារៈនិយមធ្វើជានាយទៅហ្វាយដិះជាន់ជ្រុលហួសព្រំដែន ជ្រុលហួសក្របខណ្ឌនៃយើងជាមនុស្សលោកឡើយ ។ ជាជាតិសាសន៍ដទៃចុះ ធ្វើម្ដេចគ្នាបានជាមិនយល់មិនដឹងនូវច្បាប់មនុស្សធម៌នេះហើយបើដឹងខ្លះ ក៏មិនជាហ្មត់ចត់ប៉ុន្មានបានជាគ្នាបេះតែធ្វើៗទៅតាមតែសម្ភារនិយមដឹកប្រមុះ ប្រៀបបាននិងសត្វតិរច្ឆាន ចុះយើងកាល់គ្នាជាពុទ្ធសាសនិក ហេតុអ្វីក៏ទៅជាមិនគោរពសីលទី ៤ ដែរ បើបានដឹងបានឮហើយនោះ ។ ច្បាប់រដ្ឋធម្មនុញ្ញមានចែងយ៉ាងជាក់ច្បាស់ត្រង់មាត្រាទី ៨ ថា: ព្រះពុទ្ធសាសនា ត្រូវទុកជា

សាសនារបស់រដ្ឋ មានសេចក្ដីថាប្រជារាស្ត្រខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនាទូទៅក្នុងកម្ពុជរដ្ឋតាំងមូល ។ ហើយបើយើងបែរជាមិនគោរពសីលទី ៤ នេះទៅវិញ ន័យរបស់មាត្រានេះ ត្រូវស្រកទម្ងន់អស់ខ្លះហើយ ។

ផ្នែកអក្សរសាស្ត្រ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាំង-ទាត់ រៀបរៀង*

អភិសំប្របទ៑ ធាតុ ចូលរួម ដំណែង ក្រឡា ។

អភិសំប្រយា ធាតុ ចូលទៅជិត ។

អភិសំប្រវ្ឫត៑ ធាតុ ផ្លាស់ប្តូរ ។

អភិសំប្រាប៑ (អាប៑) ធាតុ ដល់លុះ សម្រេច ។ -ប្រាប្ត គុ. ដែលលុះ។

អភិសំប្រេក្ស៑(ត្ត្វ)ក្ស៑) ធាតុ យល់យល់ យល់ច្បាស់ ។

អភិសំប្លុ ធាតុ ងូតទឹក ។ -ប្លុត គុ. ដែលដោរជន់

ដែលលង់លិច ។ អត្ថប្បដិរូបៈដែលចូលក្នុង ។

អភិសំពន្ធ គុ. អភិសម្ពន្ធ ចំណង (ប្តីប្រពន្ធ)។

អភិសំពាធ គុ. អភិសម្ពាធ ដែលតាន់តាប់ ដាហ្វូង ។

អភិសំពុទ្ធ គុ. ដែលត្រាស់ដឹង ។

អភិសំភគ្គ   គុ. ដែលបែក ដែលបាក់ ។

អភិសំភូ   ធាតុ កើតក្រៃលែង កើតទៅជា ។ ចូលទៅក្នុង។ គោរព។

អភិសំភូត   គុ ដែលប្រកបដោយ ។

អភិសម្មត   គុ. អភិសម្មត ដែលមានកិត្តិយស។

អភិសំមូឡ   គុ. ដែលរលាយសព្វ ។

អភិសរ   បុំ. អភិសរ សហជីវិន ។ចោរ។

អភិសរណ   នបុំ. អភិសរណ៍ កិរិយាណាត់ជួបគ្នា (គូសង្សារ) ។

អភិសតិ   បុំ. អភិសតិ កិរិយាបង្កើត ។

អភិសាន្ត   បុំ. អភិសាន្ត ពាក្យសម្រាលចិត្ត ។

អភិសារ   បុំ. អភិសារ កិរិយាចូលកាយ ទីជួប ។ កងទ័ព ។ ពហុ
អ្នកកាសិរ ។

អភិសាយមី   ក្រិ.វិ. ល្ងាចក្រៃពេក ។

អភិសារណ   នបុំ. អភិសារណ៍ កិរិយាទៅជួបគ្នា ។

អភិសារិកា   ស្ត្រី. អភិសារិកា ស្ត្រីអ្នកទៅកាន់ទីជួប៖ ស្នេហា៖ ។

អភិសារិន៑ គុ. អ្នកទៅជួប ។

អភិសិធ៑ ធាតុ សម្រេចបានដល់ ។

អភិសិសារយិសុ គុ. អ្នកចង់ទៅជួបសហាយ : (ស្នេហា) ។

អភិសូបិត គុ ដែលចាក់តាំង ។

អភិសប្ឫ ធាតុ ទៅជិត ដើរបញ្ច្រាសគ្នា ។ នាំទៅ ចូលលុក ទៅ
ជួប ។ –សប្ឫត គុ. ដែលមកជិត ដែលចូលទៅជិត។

អភិសប្ឫជ៑ ធាតុ អនុញ្ញាត ។ -សប្ឫឞ្ធ គុ. ដែលទទួលពាក្យ
អនុញ្ញាត ។

អភិស្នេហា បុំ. ស្នេហាក្រៃលែង ។ សេចក្ដីលំអៀង។

អភិស្ប្ឫគ ធាតុ ពាល់ស្ទាប ។

អភិស្មិ ធាតុ សើចក្រៃលែង។

អភិស្យន្ទ មើល អភិឞ្យន្ទ ។

អភិស្រុ ធាតុ បង្ហូរ ។

អភិហតិ ស្ត្រី. ការគុណ (សារ)។

អភិហនន ធាតុ ប្រហារ សម្លាប់ ។ ភយ (ស្គរ) ។ -ហត គុ. ដែលសម្លាប់, ជាចំណី ។

អភិហរណ នបុំ. កិរិយានាំមក ។

អភិហត្ឫ ការក. អ្នកពង្រត់ អ្នកចាប់ដោយកម្លាំង ។

អភិហារ បុំ. អភិហារ កិរិយាចាប់ពង្រត់ ។

អភិហិម្សន នបុំ. អំពើអាក្រក់ ។

អភិហិត គុ. ដែលតែងតាំង, ដែលហៅរក ។

អភិហុ ធាតុ ស្រោច បូជា ។

អភិហ្ឫ ធាតុ ជូន,ជក ។ ជូន (អាហារ) ។ ពាក់ : គ្រឿងក្រោះ ។ ភយ ។

អភិហ្ឫប៊ ធាតុ រឹកភយ ។

អភិហេឋ ធាតុ កញ្ច្រៀវ ។

អភី (ឥ) ធាតុ ចូលជិត ដើរចូល តាម ។ ធ្លាក់ដល់ ។ កើត ។

អភី គុ. ដែលឥតខ្លាច ដែលហ៊ាន ។ -ក មើលអភីក ។ -គ គុ. ឥតខ្លាច ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

នូ-កាន

ប្រែ-រៀបរៀង

(៩)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នករិះរៃឆ្លាសបើបានអាន |
| នឹងចេះឧបាយកលចំណាន | ទាំងមានសន្តានស្នេហាជាតិ |

យូរ-អ៊ុន

ខណៈពួកល្បាតស៊ើបការដឹងថា ប៊ូគីទិវ័គ, ប៊ូយ៉យ ជាកូនបុត្របានឡើងសោយរាជ្យជំនួសបិតា ហើយតាំងស៊ុម៉ាអ៊ីដែលមានតម្រិះប្រាជ្ញាឲ្យទៅឈរគេ្យាស្រុកសេលៀង, អ្នកស៊ើបការ ក៏នាំរាជពត៌មានចូលទៅជម្រាបខុងបេងគ្រប់ប្រការ, ខុងបេងដឹងដូច្នោះ ក៏ព្រួយចិត្តណាស់ ថាស៊ុម៉ាអ៊ីនោះ ជាមនុស្សមានតម្រិះប្រាជ្ញាស្រួចប្រស់ បើបានបញ្ចុះបញ្ចូលពលទាហានបានច្រើនហើយ មិនលែងឡើយនឹងលើកទ័ពមកធ្វើអន្តរាយដល់ផែនរបស់យើង, ត្រូវយើងគិតលើកទាហានទៅវាយយកស្រុកហ៊ូតោកាត់សឹកចេញជាមុនទើបបាន, បើស៊ុម៉ាអ៊ីអស់កម្លាំង មិនមានទីអាស្រ័យវេលាណា គង់នឹងប្រវាមកទ័ពនឹងយើងវាងនេះ, ម៉ាចេកទិកឃើញ ក៏និយាយតបទៅនឹងខុងបេងវិញថា មហាឧបរាជលើកកងទ័ពទៅច្បាំងនឹងបេងហោក ទើបតែនឹងត្រឡប់មកសោះ, ទាហានទាំងអស់មិនទាន់បាត់

ហត់នឿយ, បើនឹងលើកទៅវាយស្រុកហ៊្វូគោទៀតហើយ ផ្លូវនោះ ក៏ឆ្ងាយដាច់អាល័យ, ទាហាន នឹងលើកទៅ ក៏បានសេចក្ដីព្រួយលំបាកណាស់, សុំឲ្យលោកឈប់បង្អង់កុំអាលរូតរះពេក, ខ្ញុំបាទនឹងគិតឧបាយកលឲ្យវៃឆ្លូក ដើម្បីឲ្យចូយ៉យសម្លាប់សុម៉ាអ៊ីចេញឲ្យបាន, ខុងបេងក៏សួរពតិមានថា កលរបស់អ្នកនឹងធ្វើ ដូចម្ដេច ? ។

ម៉ាបេកឆ្លើយថា ដែលចូយ៉យឲ្យសុម៉ាអ៊ីមកនៅរក្សាស្រុកសេ-លៀងនោះ, ចូយ៉យ ក៏នៅមានចិត្តកំណាន់ មិនទាន់ទុកចិត្តសុម៉ាអ៊ីជាប្រាកដទេ, ខ្ញុំបាទឃើញកលឧបាយមួយ, ត្រូវសរសេរសំបុត្រ ហើយចាត់បម្រើឲ្យលបយកទៅបិទនៅទ្វារស្រុក ឡុកអៀង និងអាណាខែត្រឯទៀតៗ ថា សុម៉ាអ៊ីគិតក្បត់, បើចូយ៉យដឹងហើយ គង់នឹងសម្លាប់សុ-ម៉ាអ៊ីចេញ, ខុងបេងបានស្ដាប់សព្ទ ក៏នឹកឃើញយល់ត្រូវ, ទើបឲ្យសរ-សេរសំបុត្រជាសេចក្ដីថា ខ្លួនយើងឈ្មោះសុម៉ាអ៊ី ជាទីនាហ្មឺនធំ ប្រាប់ដំណឹងដល់អ្នកទាំងពួង, ពីដើម ព្រះចៅវ៉ុយអង បំណងនឹងប្រគល់រាជ-សម្បត្តិឲ្យចូស៊ក, តែមានមនុស្សអាច គិតញុះញង់ព្រះចៅចូភី ទើបបង្វែររាជសម្បត្តិឲ្យបានទៅចូភីវិញ, ឥឡូវ ចូភីបង្វែររាជសម្បត្តិឲ្យទៅព្រះចៅចូយ៉យជាបុត្រា, ចូយ៉យនោះ នៅក្មេងសេចក្ដី ខ្លីគំនិត នឹងគិតធ្វើការអ្វីៗ ក៏មិនមានសេចក្ដីប្រណីអាណិតរាស្ត្រសោះ, គេទៅនឹងបានសេចក្ដីអាប់យសរលាយរាជសម្បត្តិអសារឥតការ, យើងជាទាហ្មឺនធំ នឹងសម្ងំ

ស្ងៀមនៅឲ្យផែនដីជាចលាចល ក៏មិនគួរ ទើបយើងត្រូវបញ្ចុះបញ្ចូលពលទាហានឲ្យបានច្រើនហើយ នឹងលើកទៅកម្ចាត់ចួយ៉យចេញ ដើម្បីនឹងលើកចូស៊ិតឲ្យសោយរាជសម្បត្តិវិញ តាមតម្រិះព្រះចៅវ៉ុយអង់ជាតម្បូង, បើអ្នកទាំងពួង យល់ព្រមល្មមនឹងចូលធ្វើការជាមួយនឹងយើង ក៏សូមឲ្យស្រូតប្រញាប់រហ័សនាំអស់ពួកកៀនទៅចូលនឹងយើងចុះ, បើអ្នកឯណាបានឃើញសេចក្តីសំបុត្រនេះហើយ មិនចូលនឹងយើងទេ, បើយើងបានធ្វើការសម្រេចតាមគ្នាវេលាណា យើងនឹងត្រូវប្រហារជីវិត ឲ្យអស់ទាំងគោត្រ ។

ខុនបេងឲ្យសរសេរសំបុត្រនោត មានសេចក្តីដូចៗ គ្នាដូច្នេះហើយ ក៏ចាត់បម្រើឲ្យដើរបំបែកគ្នា លបយកទៅបិទសព្វទ្វារស្រុក ដែលគិតទុកកល់អន្ទើ ហើយឲ្យបម្រើនាំយកទៅបិទៈនៅទ្វារស្រុក ឡុកអៀង ជាក្រោយ ។

លុះព្រឹកឡើង ស្រាប់តែនាយទ្វារ បានឃើញសំបុត្របិទដូច្នោះ ក៏នាំចូលយកទៅថ្វាយព្រះចៅចូយ៉យ ។ ទតព្រះនេត្រចប់សព្វសេចក្តី ក៏មានព្រះទ័យតក់ស្លុតរន្ធត់វិញ្ញាណ បានប្រជុំទីប្រឹក្សាទាំងពួង មកពិគ្រោះថា វេលានេះ សុម៉ាអ៊ីចេញជាក្បត់ហើយ, អស់អ្នកទាំងឡាយនឹងយល់ឃើញប្រការម្តេច ? ហួហិម ទូលថា កាលព្រះចៅវ៉ុយអង់ នៅគង់ព្រះជន្មនៅឡើយ ក៏មិនបានទុកព្រះទ័យនឹងសុម៉ាអ៊ីជាប្រាកដ បានត្រាស់

ជារឿយៗ ថា សុម៉ាអ៊ីនេះ បើនឹងដប់លៀងឲ្យធ្វើធំត្រួតត្រាៈលើទាហាន វេលាណា គឺគង់នឹងក្បាបិត្ត គិតក្បត់ផែនដីវេលានោះ, ដែលសុម៉ាអ៊ីធ្វើរឿងក៏ជាផ្លូវឧបាយថ្វាយសុំខ្លួនចេញទៅយកភាសាថា ជាអ្នករក្សាស្រុកសេលៀងនោះ ប្រាថ្នានឹងបញ្ចុះបញ្ចូលទាហាន ឲ្យបានជាកម្លាំងមាំមួន ដើម្បីនឹងតាំងខ្លួនធ្វើធំ សមជាក្បត់នឹងផែនដីជាប្រាកដ ។

អងឡង់បានព្ទូលច្បោះ ក៏ទូលថា សុម៉ាអ៊ី ជាមនុស្សមានសតិបញ្ញាធ្មៀវឆ្លាស ហើយចំណានបទបាថនឹងការសង្គ្រាម ធ្លាប់បានច្បាំងជាច្រើនគ្រា, បើសុម៉ាអ៊ីតាំងខ្លួនបានដូចហ្លួហិមថា យើងក៏ធ្វើការលំបាកទៅមុខ, សូមព្រះអង្គកុំទ្រង់ទុកព្រះទ័យ គប្បីតែនឹងលើកភាហានទៅកម្ចាត់ចេញឲ្យឆាប់រហ័ស ទាន់កម្លាំងនៅតិច កុំឲ្យគេឡូះតស៊ូបាន ។

ព្រះចៅចូយ៉យទ្រង់ព្រះសណ្ដាប់ ក៏យល់ត្រូវ ទើបតម្រូវឲ្យរៀបចាត់ទាហានៈលើកចេញទៅ, ចូដិនទូល ថាកាលព្រះបិតាព្រះអង្គទៀបនឹងទ្រង់អស់ព្រះជន្ម ក៏បានផ្ញើឥការផែនដីឲ្យប្រលបង្គំនិងសុម៉ាអ៊ី ឲ្យជួយទំនុកបម្រុង, សុម៉ាអ៊ីក៏គង់មិនប្រែបិត្តគិតក្បត់នឹងព្រះអង្គទេ, ដែលមានគេមកសរសេរៈផ្ទាតបិទទុកយ៉ាងនេះ, ទូលព្រះបង្គំជាខ្ញុំឃើញថា ប្រហែលជាកលឧបាយរបស់ខុងបេងទាត ឬពុំនោះក៏ជាគំនិតស៊ុនក្ងួនក្លែងធ្វើដោយអំពើឥច្ឆា ប្រាថ្នានឹងឲ្យចៅហ្វាយនិងបាវមានមន្ទិលពិការបិត្តនឹងគ្នា, ដែបព្រះអង្គទ្រង់នឹងលើកពលយោធាៈទៅកម្ចាត់តែម្ដង ពុំទាន់ទេ. គួរទ្រង់ត្រូវ

ឲ្យល្អិតល្អន់សិនចុះ ។

ព្រះចៅចូយ៉យត្រាស់ថា ដែលអ្នកឃាត់ហាមយើងមិនឲ្យលើកទ័ពទៅចាប់សុម៉ាអ៊ីនោះ បើប្រសិនណាជាសុម៉ាអ៊ីប្រែចិត្តជាក្បត់ប្រាកដស្មោះចំពោះមានកម្លាំងខ្លាំងឡើង តើអ្នកនឹងរិះគិតយ៉ាងម្ដេចទៅទៀត? ចូជិនទូលថា ព្រះអង្គទ្រង់ព្រះតម្រិះដូច្នោះ ក៏គួរហើយ, ប៉ុន្តែថា បើនឹងលើកទ័ពទៅគ្រានេះតែម្ដង, ចុះបើសុម៉ាអ៊ី ដឹងខ្លួនជាមុន, យើងនឹងមិនធ្វើការដោយលំបាកទេឬ? បើដូច្នេះ សូមឲ្យព្រះអង្គប្រើកលឧបាយឲ្យដំណឹងទៅថា ទ្រង់នឹងទៅរៀបចំស្រុកទេសឲ្យរៀបរយ ឲ្យសុម៉ាអ៊ី ៗ ក៏នឹងសម្គាល់ថាពិតត្រង់ គង់តែនឹងចេញមកទទួលដល់ក្រៅស្រុក សឹមយើងគ្រលុកចាប់ខ្លួន នឹងបានដោយងាយ ។

ព្រះចៅចូយ៉យយល់ត្រូវ ទើបត្រាស់បង្គាប់ឲ្យចូជិនកេណ្ឌពលបាន ១០ ម៉ឺន តាំងក្បួនហែស្ដេចចេញចាកស្រុកហ៊ូតោ ថានឹងទៅរៀបចំស្រុកសេលៀនឲ្យសុម៉ាអ៊ី, ឯសុម៉ាអ៊ីដឹងថា ព្រះចៅចូយ៉យស្ដេចទៅដល់ដែនស្រុកសេលៀន ក៏មានសេចក្ដីត្រេកអរណាស់ នាំទាហាន ៥០.០០០ ចេញមកទទួលស្ដេច, អស់នាម៉ឺនទាំងពួង ក៏ក្រាបទូលព្រះចៅចូយ៉យថា ឃើញជាសុម៉ាអ៊ីចេញក. .ជាក្បត់មែនពិតហើយ បានជាលើកទាហានចេញមកច្រើនដូច្នេះ ។ ព្រះចៅចូយ៉យទ្រង់ព្រះសណ្ដាប់ ក៏តែតែឆ្ងល់ក្នុង

ព្រះទ័យណាស់ ទើបឲ្យចូហ៊ាវលើកទាហានជាកងមុខចេញទៅមុន ។

ឯស៊ុម៉ាអ៊ីឃើញចូហ៊ាវលើកទ័ពមក សម្គាល់ថា ព្រះចៅចូយ៉យស្តេចលើកមក ក៏តម្រង់ចូលទៅប្រាថ្នានឹងទទួលស្តេច, ចូហ៊ាវក៏ស្រែកទៅឲ្យស៊ុម៉ាអ៊ីថា អ្នកឯង ជានាម៉ឺនមានឈ្មោះថាជាអ្នកទៀងត្រង់នឹងកជការមកពីដើម, ព្រះចៅចូភី បានផ្ញើកជការផែនដីឲ្យអ្នកជួយទំនុកបម្រុង, ឥឡូវហេតុម្តេច បានជាអ្នកឯងមកប្រែចិត្ត គិតក្បត់ទាស់នឹងព្រះចៅចូយ៉យដូច្នេះ? ស៊ុម៉ាអ៊ីបានឮដូច្នោះ ក៏ភ្ញាក់ចិត្តកិតភ័យស្ញាំងកាំងរឹងអស់ទាំងខ្លួន មានវាចាឆ្លើយថា ខ្ញុំតាំងចិត្តធ្វើការកជការថ្វាយធ្ងន់ព្រះតេជព្រះគុណព្រះករុណាជាម្ចាស់ដោយសុចរិត ហេតុម្តេចបានជាអ្នកមកថាដូច្នេះ? ចូហ៊ាវក៏ពណ៌នាពាក្យរឿងតាមសំបុត្រឆោតដែលបិទនៅគប់ទ្វារស្រុក ហើយមានអ្នកក្រោទ្វារនាំទៅថ្វាយព្រះចៅចូយ៉យ ឲ្យស្តាប់សព្វប្រការ ។

ស៊ុម៉ាអ៊ីឆ្លើយថា បើដូច្នោះ ខ្ញុំសុំចូលទៅក្រាបបង្គំគាល់ព្រះចៅចូយ៉យឲ្យបានបញ្ជាស់សេចក្តីចុះ, ស៊ុម៉ាអ៊ី ក៏ឲ្យពួកទាហានដែលទៅជាមួយនោះថយទៅនៅពីចម្ងាយ ហើយខ្លួនក៏ចុះពីលើសេះ ដើរចូលទៅដល់មុខរថព្រះទីនាំងព្រះចៅចូយ៉យ, ស៊ុម៉ាអ៊ីក្រាបថ្វាយបង្គំ ហើយទូលថាកាលព្រះបិតាព្រះអង្គ គង់ព្រះជន្មនៅ ក៏ឃើញថា ទូលព្រះបង្គំជាខ្ញុំ ជាមនុស្សត្រឹមត្រូវសុចរិត បានជាទ្រង់ផ្ញើកប្ចាជការផែនដី ឲ្យទូលព្រះបង្គំជាខ្ញុំ ជួយឧបត្ថម្ភថែរក្សាព្រះអង្គ ឲ្យគង់កងរាជសម្បត្តិជាសុខក្សេមក្សាន្ត,

ទូលព្រះបង្គំជាខ្ញុំ ក៏មិនបានគិតជាទុច្ចរិតនឹងព្រះអង្គសោះ មានតែសេចក្តីត្រង់ស្មោះរហូតមកដល់ថ្ងៃនេះ, ដែលបង្កើតហេតុដូច្នេះ គឺជាកលឧបាយខុនបេងនិងស៊ិនគួន មកគុំគួនធ្វើឲ្យព្រះអង្គទ្រង់ស្អប់ទូលព្រះបង្គំជាខ្ញុំពិត, បើដូច្នេះ ទូលព្រះបង្គំជាខ្ញុំសុំយកអាយុជីវិតទៅផ្ទូរយកស្រុកសេឈូននិងស្រុកកាំងតាំង មកថ្វាយព្រះអង្គឲ្យបាន ទើបព្រះអង្គនឹងទ្រង់រាប់អានថាទូលព្រះបង្គំជាខ្ញុំ ជាខ្ញុំក្រោមព្រះបាទមែន ។

ហ្វូហាមបានស្តាប់ហើយ ឆ្លើយទូលទាស់ថា ដែលស៊ុម៉ាក៊ីសុំយកអាសារដូច្នេះ ជាប្រយោជន៍នឹងតាំងខ្លួនឲ្យមាំមួនធំឡើងទៀត, សុំកុំឲ្យព្រះអង្គជឿទុកព្រះទ័យឲ្យសោះ, គួរតែទ្រង់នឹងទារយកគ្រឿងកិត្តិយសសម្រាប់ងារ ហើយដកហូតត្រាពីស៊ុម៉ាអ៊ី ឲ្យចេញពីទីមន្ត្រី ទើបត្រូវ, ព្រះចៅចូយ៉យក៏យល់ឃើញត្រូវផង ទើបឲ្យដកហូតងារស៊ុម៉ាអ៊ីចេញជារាស្ត្រធម្មតា ហើយឲ្យវិលទៅធ្វើស្រែចម្ការឯទីលំនៅដើម រួចតាំងឲ្យចូហ៊ុវទៅនៅឈររក្សាស្រុកសេរលៀង, ព្រះចៅចូយ៉យ ក៏លើកទ័ពត្រឡប់ទៅស្រុកហ៊ូតោវិញ ។

ឯខុនបេង លុះដឹងថា ស៊ុម៉ាអ៊ីត្រូវហូតងារចេញចាកតំណែងដូច្នោះ ក៏មានអំណរណាស់ ទើបនិយាយថា ឥឡូវព្រះចៅចូយ៉យចាញ់កលយើងហើយ, យើងត្រូវទៅវាយយកស្រុកឡកអៀងឲ្យបាន, លុះពេលព្រឹក, នាម៉ឺនមុខមន្ត្រីចូលគាល់គ្រប់គ្នា, ខុនបេង ក៏តែងរឿងការថ្វាយព្រះចៅ

ទៀវសៀន សេចក្ដីថា ទូលព្រះបង្គំជាខ្ញុំខុងបេង សូមក្រាបបង្គំទូលសូម
ទ្រង់ជ្រាប ព្រោះព្រះចៅឡៅពី បានធ្វើសង្គ្រាមប្រាបប្រាមផែនដីនៅ
មិនទាន់ពបពាបសោះ, អាណាខេត្តទាំងអស់ក្នុងប្រទេសចិន ត្រឡប់ទៅ
ជា ៣ កុក, ព្រះអង្គក៏ទ្រង់ព្រះវិតក្កទាល់តែក្លាយជាពេកទ្រង់សុវណ្ណគត
ទៅ, ឥឡូវ ស្រុកសេឈួនជាស្រុកតូចពេក ទីងតាំងជាស្រុកឯកពជជាទី
ពុំបាន, សូមព្រះអង្គទ្រង់ព្រះតម្រិះដោយស្មោះស្មាន កុំមានតូចព្រះទ័យអ្វី
ឡើយ, គ្រានេះហើយ មាននាម៉ឺនមុខមន្ត្រីច្រើនណាស់ សុទ្ធតែជាអ្នក
ក្លៀវក្លាស មានតម្រិះប្រាជ្ញា ទាំងទាហានសេនា ក៏មានថ្វីដៃខ្លាំងពូកែ
ព្រមល្មមនឹងធ្វើការយកអាសារថ្វាយព្រះតេជព្រះគុណបានទាំងអស់ ដូច
មានឈ្មោះខាងក្រោយនេះគឺ គុយហ៊ុវដី ១ ប៊ិហ៊ុយ ១ តីនអ៊ុន ១ បីនាក់នេះ
ជានាយទាហានឯក មានថ្វីដៃខ្លាំងពូកែស្ទាត់ក្នុងការសង្គ្រាម ធ្លាប់បាន
តាមធ្វើសឹកមកមានជ័យជម្នះពល់ជង, ឈ្មោះទាំងនេះ ព្រះចៅឡៅពីក៏
ទ្រង់ទុកព្រះទ័យពប់អានមកពីដើម គួរព្រះអង្គនឹងទ្រង់ប្រឹក្សាពិគ្រោះដោយ
កិច្ចការទាំងពួងផងចុះ, ឯខ្ញុំទូលព្រះបង្គំនោះ ក៏ជាមនុស្សទាប
គំនិតទេ, កាលពីដើម នៅក្នុងស្រុកឡាំអៀង ព្រះចៅឡៅពីមានព្រះ
ទ័យឧស្សាហ៍ស្ដេចយាត្រាទៅរកដល់ ៣ ដង ទទួលយកទូលព្រះបង្គំជា
ខ្ញុំមកជួយធ្វើការ, ទោះបីលើសលោះខុសត្រូវយ៉ាងណា ក៏ទ្រង់ព្រះ
មហាករុណាមិនប្រកាន់ទោសឡើយ, គ្រានេះ ទូលព្រះបង្គំជាខ្ញុំគិតព្រះ

គេដព្រះគុណណាស់ហើយ បានជាស៊ូប្ដូរជីវិតក្រោមព្រះបាទ, ព្រះអង្គក៏ទ្រង់សន្មតផ្ដាំទុកថា ឲ្យទូលព្រះបង្គំជាខ្ញុំជំនួយឧបត្ថម្ភទំនុកបម្រុងផែនដីឲ្យបានសេចក្ដីសុខតទៅ, ឥឡូវ ទូលព្រះបង្គំជាខ្ញុំ សុំអាសាលើកទ័ពទៅវាយយកស្រុកឡុកអៀងមកថ្វាយ, សូមអញ្ជើញព្រះអង្គគង់នៅឲ្យសប្បាយក្នុងរាជសម្បត្តិចុះ, ពោះព្រះអង្គទ្រង់មានកិច្ចរាជការជាធុរៈ ដោយហេតុអ្វីៗទៅថ្ងៃក្រោយ ក៏សូមឲ្យប្រឹក្សាពិគ្រោះនឹងអស់នាម៉ឺនដែលមានសតិបញ្ញា, សូមព្រះអង្គទ្រង់ឲ្យដូចយៀងយ៉ាងនៃព្រះចៅឡាវពីរាព្រះវររាជបិតាចុះ ។

ព្រះចៅឡាវសៀនបានទ្រង់ព្រះសណ្ដាប់សុភអក្សរ ក៏ត្រាស់ប្រាប់ព្ធនឹងខុនបេងថា លោកទៅធ្វើសឹកនឹងបេងហោក ទើបតែនឹងវិលត្រឡប់មកមិនទាន់បាត់ហត់នឿយ គួរហើយតែនឹងឈប់សម្រាកយកកម្លាំងពលទាហានឲ្យបានបរិបូណ៌សិនចុះ, ខុនបេងទូលថា ឯស្រុកឡុកអៀងនោះទូលព្រះបង្គំជាខ្ញុំគិតនឹងលើកទ័ពទៅវាយយូរហើយ តែឃើញថាបេងហោកជាសឹកបត្រូវនៅពីម្ខាង ក្រែងជាទ័ពវាយខ្នងពីក្រោយ បានជាទៅធ្វើឲ្យបេងហោកបរាជ័យ, ឥឡូវ បេងហោកក៏អស់ដៃ ទទួលចំណុះចុះចាញ់ហើយ ត្រូវតែលើកទៅវាយយកស្រុកហ្វូកោឲ្យបានទៀត ។

ចៅដីវ៉ាំងនាម៉ឺនធំញ្ញូវបោះ ក៏និយាយនឹងខុនបេងថា កាលពីយប់មិញ ខ្ញុំភ្ញាក់បានពិគ្រោះមើលឫក្សលើអាកាស ឃើញផ្កាយប្រចាំ

ស្រុកខាងជើង មានសេចក្តីចំរើនទៅឡើយ, មហាឧបរាជក៏មានប្រាជ្ញាស្រាប់ហើយ អាចនឹងជ្រាបសព្វកិច្ចការទាំងពួង, ដែលនឹងលើកលែងទៅវាយស្រុកហ៊ូកោនោះ ក្រែងមិនសម្រេច បានបំណាច់តែមានទៀយព្រួយការទទេ ទទឹង? ។

ខុងបេងថា ដែលនឹងប្រកាន់យកឫក្សលើអាកាស ជាប្រមាណនោះ មិនបានទេ, ត្រូវតែពិគ្រោះយកកិច្ចការក្នុងស្រុកទេសជាប្រមាណវិញ ទើបត្រូវពិត, ទោះបីជាផ្កាយប្រចាំស្រុកនឹងវិបរិតយ៉ាងណា បើមិនមានខ្មាំងសត្រូវមកបៀតបៀនទេ, ស្រុកនោះក៏នៅបានជាប្រក្រតី, ឥឡូវ, យើងនឹងលើកទ័ពទៅតាំងនៅស្រុកហាំនតុង ស្តាប់ដំណឹងជាថ្មី គេនឹងជាម្តេច, បើឃើញថា ឡុកសៀងវាទកិច្ចជាខ្ទោះ គួរនឹងធ្វើការបាន យើងក៏ត្រូវលើកពលទាហានទៅវាយតែម្តង ។

ទៅដីវ បេះតែហាមឃាត់ខុងបេងជាច្រើនសារ, ខុងបេង មិនព្រមស្តាប់ ទើបបង្គាប់ឲ្យ គុយហ៊ុយជី, បំហ៊ុយ, តងអ៊ុន, ហៀងឆុង, តងជីន, ប៉េវអ៊ួន, តៀវហ៊ី, គោវខង, គោប៊ឹ, ហៀវហង, បេងគង, ឡៃប៊ិន, អ៊ុនបេក, លិប៉ួន, ហ៊ុយស៊ុ, ទៅដីវ នូវអស់នាម៉ឺនធំៗចំនួន ១០០ ប៉ាយ ជានាយត្រួតលើទាហានទៅគ្រប់ស្រុកតេរពួន, ហើយខុងបេងក៏ថ្វាយបង្គំលាមកកាន់ទ័ពលំនៅវិញ ប្រូចាត់ចែងនាយទាហានពីរនាក់ គឺ អ៊ុយអៀន, តៀវ-អ៊ុក, អេងបេង, ល៉ហុង, លីអ៊ី, ម៉ាតាយ, ហៀវហ៊ូ, មាតង, តៀវង៉ី, ឡៅតាំ,

បេងជឺ, ម៉ាបេក, អួនលិម, ង៉ីអ៊ុ, កោសៀង, ង៉ីប៊ុន, អៀវង៉ី, ឡៅប៉ៅ, ខៅអ៊ុន, តេងហាំ, ឡៅពីន, គួយ៉ុង, អជី, ងៀមអាន, ហៀនស៊ិប, តង៉ី, តគី, សេងហ៊ួ, ហួនគី, អួនគៀន, ក័ងឃួត, គួនហ៊ុន, គៀវប៉ៅ នឹងលើកទៅវាយស្រុកហ៊ួគោ ហើយឲ្យលិវយៀមទៅនៅរក្សាបន្ទាយមុខគយស្រុកកាំងតាំង ។

ខណៈកាលឃុនបេងតាត់រៀបទ័ពនឹងលើកទៅនោះ ជាទេសកាលខែពិសាខ ព្រះចៅឡៅសៀនសោយរាជសម្បត្តិបាន ៨ ឆ្នាំ (ព.ស.៧.៧០) ឯដូឡុង ដឹងថាឃុនបេងនឹងលើកទ័ពទៅវាយស្រុកហ៊ួគោដូច្នោះ ក៏ចូលទៅគំនាប់ឃុនបេងហើយ ជម្រាបថា ខ្ញុំបាទនេះ ចាស់តែត្រឹមអាយុនិងសតិបញ្ញា, ឯកម្លាំងពលាការនិងថ្វីដៃដែលច្បាំង នៅខ្លាំងពូកែទៅឡើយ ។

ឃុនបេងឮហើយឆ្លើយថា យើងបានទៅប្រាប់ប្រាមបេងហេកម្ដងនេះ ម៉ាឈៀវស្លាប់, យើងគិតស្ដាយណាស់ ដូចជាបាក់ដៃម្ខាងទៅ, តែខ្លួនអ្នកមួយ ដែលជាមនុស្សចាស់មកពីដែនដីមុន គួរអ្នកខំអត់ធន់នៅធ្វើរាជការឯកាយ ឲ្យស្រួលសប្បាយខ្លួនចុះ, បើអ្នកនឹងទៅខាងណោះ ក្រែងនឹងថ្លោះការក្នុងទ័ពច្បាំង នឹងបង់កេរ្ដិ៍ឈ្មោះយសសក្ដិរបស់អ្នកស្រុកសេឈួនទេដឹង ។

ដូឡុងឆ្លើយថា ខ្ញុំបាទបានធ្វើសឹកមកតាំងពីកម្លោះ លុះដល់ចំណាស់ប៉ុណ្ណេះហើយ មិនដែលថ្លោះដោយសត្រូវនឹងមើលងាយបានឡើយ, កើត

មកជាជាតិទាហាន គ្មានស្តាយជីវិតសោះ, ទោះបីនឹងស្លាប់ក្នុងទីចម្បាំង ក៏ចង់មានកេរ្តិ៍ឈ្មោះទុកវែងឆ្ងាយ, ឥឡូវ ខ្ញុំបាទសុំនាំទាហានពីអាយលើកទៅជាទ័ពមុនលោក ។ សូមទទួលឲ្យខ្ញុំបាទទៅផងចុះ, ខុងបេង និយាយកំផែកឃាត់ដល់ ៣ ដង, ជូឡុង ក៏មិនព្រមឈប់ខាន ចេះតែសុំខ្លួនទៅឲ្យបាន, ខុងបេងថា បើអ្នកនឹងទៅ ក៏ទៅចុះ, យើងនឹងឲ្យតេងជិទៅជាមួយ ឲ្យបានជាគ្នា, បើមានការក្រងាយ ត្រូវនិយាយពិគ្រោះឲ្យដឹងការជ្រៅរាក់ ហើយខុងបេងក៏ប្រគល់ទាហានឯក ៦០ នាក់ និងកូនទាហាន ៥.០០០ ឲ្យជូឡុង ។ ក៏មានអំណរណាស់ សំពះលាចេញនាំពលទាហាននោះមិញស្រូតទៅជាទ័ពមុខ ។

ខុងបេង ក៏ចូលទៅក្រាបថ្វាយបង្គំលាព្រះចៅឡៅសៀន ហើយលើកទាហានចេញអំពីព្រះរាជធានីទីក្រុងសេឈួន, អស់បណ្តានាម៉ឺនតូចធំ ក៏នាំគ្នាចេញទៅ ជូនដំណើរដល់ក្រៅក្រុង ចម្ងាយ ៥០ សិន (២ គីឡូម៉ែត្រ), ខុងបេង ក៏ឲ្យទាហានលើកទង់ជ័យ ហែជាក្បួនទ័ពទៅដល់ស្រុកហានតុង ។

ឯស្រុកគុយល្បាតខាងស្រុកហ្វីតោបានដឹងការ ក៏នាំសារទៅក្រាបទូលព្រះចៅចូយយ៉ឺឲ្យជ្រាបសេចក្តី ថា ខុងបេងលើកទាហាន ប្រមាណ ៣០ ម៉ឺនទៅតាំងនៅស្រុកហានតុង ហើយឲ្យជូឡុងនិងតេងជិជានាយកងមុខ លើកចូលស្រុកចូលមកក្នុងដែនស្រុកយើងហើយ ។

ព្រះចៅចូយ៉យ បានជ្រាបដូច្នោះ ក៏ព្រួយព្រះទ័យណាស់ ត្រាស់ប្រឹក្សាទីងនាម៉ឺន នូវនាយទាហានទាំងពួងថា សឹកគ្រានេះ ជាធំពន្ទឹកណាប់ អស់អ្នកទាំងពួងនឹងយល់ឃើញដូចម្ដេច? គួរនឹងចាត់ប្រើនរណាឲ្យចេញទៅធ្វើការតស៊ូទល់នឹងទាហានស្រុកសេឈួនបាន ? ហៃហួលិមជាកូនហៃហ៊ានទុន បានស្ដាប់ព្រះតម្រាស់ ក៏នឹកខឹងណាស់នឹងហាងតុងដែលបញ្ឆោតសម្លាប់ហៃហួអៀនជាមា ទើបខាំមាត់គគ្រឹតធ្មេញ ហើយទូលថា មាទូលព្រះបង្គំជាខ្ញុំស្លាប់ទៅ ក៏នៅមិនទាន់សងសឹកនឹងអាស្រុកសេឈួនសោះ, ទូលព្រះបង្គំជាខ្ញុំ សុំអាសាដោយស្មោះ ទៅនាំទាហានស្រុកសេលៀងដែលមានថ្វីដៃ លើកទៅវាយចំពោះសេឈួនឲ្យបានវិញ ។ ឯហៃហួលិមនេះ ជាមនុស្សមានសតិបញ្ញាតិច តែចូយ៉យទ្រង់មានចិត្តអាណិតស្រឡាញ់ណាស់ ព្រោះមានពូជជាអ្នកទៀងត្រង់នឹងចៅហ្វាយនាយ, លុះហៃហួលិមសុំទទួលអាសា, ចូយ៉យក៏ទ្រង់ព្រះចិន្ដាត្រេកអរណាស់ ត្រាស់ឲ្យកេណ្ឌទាហានស្រុកសេលៀងដែលមានថ្វីដៃ ២០ ម៉ឺនឲ្យចេញទៅធ្វើសឹកនឹង [illegible] ។ អងឡង់ទូលថា ដែលឲ្យហៃហួលិមចេញទៅធ្វើជាមេទ័ពនោះ ទូលព្រះបង្គំជាខ្ញុំមិនទាន់យល់ឃើញផងសោះ ព្រោះហៃហួលិមនោះ ជាមនុស្សខោហេប្រ៉ើន ហើយមិនធ្លាប់ធ្វើការសឹកឲ្យស្ទាញស្ទាត់, ឯខុងបេង ជាមនុស្សមានសតិបញ្ញាឈ្លៀវឆ្លាស, បើនឹងសង្រ្គាមធ្វើការរ៉ូ ក៏ប្រកបដោយកលឧបាយជាប្រមាណ, តាមដោយស្ទួន

ឃើញថា ហៃហ្វូលិមទឹងស៊ូថ្វីដៃខុងបេងពុំបានទេ ។

ហៃហ្វូលិមឮដូច្នោះ ខឹងណាស់ ស្រែកគំហកឲ្យអងឡងថា ហេតុម្ដេច អ្នកឯងមកចរចាមើលងាយយើងដូច្នេះ? ដែលអ្នកឯងកប់ថា ខុងបេងចេះដឹងណាស់នោះ មែនហើយ, តែថ្វីដៃច្បាំង មិនមែនខ្លាំងពូកែស្មើនឹងយើងទេ, យើងចេញទៅតស៊ូយកជ័យជម្នះខុងបេងឲ្យបាន, បើមិនសមតាមពាក្យយើងប្រមាណថាដូច្នេះ, យើង ក៏មិនវិលវេះមកគាល់ឲ្យឃើញព្រះភក្ត្រព្រះករុណាតទៅឡើយ, ហៃហ្វូលិមនិយាយហើយ ក៏ថ្វាយបង្គំលាចេញទៅ លើកពលយោធា ៤០ម៉ឺន ទៅតាំងនៅស្រុកតៀងអ័ន ។

ឯខុងបេង ក៏លើកទ័ពចេញពីស្រុកហ័នតុង ទៅដល់ស្រុកកែអៀងទីដែលបញ្ចុះសពមាឈៀវ, ខុងបេងនិងម៉ាតាយ ក៏តែងគ្រឿងសែនទៅគំនាប់សពតាមទំនៀម, ទទួលទាហានចូលមកជម្រាបថា ឥឡូវ ចូយ៉យឲ្យហៃហ្វូលិមនាំទាហានមកចាំទទួលកងទ័ពលោក នៅនាស្រុកតៀងអ័នច្រើនណាស់, អ៊ុយអៀនបានឮដូច្នោះ ក៏និយាយនឹងខុងបេងថា ហៃ-ហ្វូលិមមានថ្វីដៃខ្លាំងពូកែក៏មែនហើយ តែទន់ខ្វះសេចក្ដីរិះគិត ព្រោះដ្បិតមិនធ្លាប់ធ្វើការធំ, ខ្ញុំបាទសុំគិតកលឧបាយយកទាហាន ៥.០០០ លើកទ័ពទៅតាំងនៅតំបន់ខាងជើង ខាងទិសឯកើត ស្កាត់ផ្លូវស្រុកតៀងអ័នដែលពឹងទៅស្រុកឡុកអៀង, បើហៃហ្វូលិម នឹងលើកទាហានចេញតដៃនឹងខ្ញុំបាទហើយ សឹមលោកលើកទាហានវាយប្រហារទៅពីក្រោយ វាយ

យកស្រុកគៀងអ៊ន គង់ទឹងបានដោយងាយ, ហៃហ្វូលិមលើសកម្លាំង ទឹងៈចាលស្រុក រត់ទៅស្រុកឡុកអៀង, យើងក៏ត្រូវលើកដេញតាមទៅ វាយយកស្រុកឡុកអៀងទៀត ក៏ទឹងបានដោយងាយ ។

ខុងបេងឮហើយ ក៏អស់សំណើច ហើយថា គំនិតអ្នកឯងទឹងសម្ដែង អំណាចយកជ័យជម្នះតែម្ខាងធ្វើម្ដេចបាន ! អ្នកកុំអាលស្មានមើលងាយទាហានស្រុកឡុកអៀងដូច្នោះ, ដែលអ្នកទឹងលើកទាហាន ៥.០០០ ប៉ុណ្ណោះ ទៅបោះស្នាក់កណ្ដាលផ្លូវ ក្រែងទាហានស្រុកឡុកអៀងដឹងទៅ ទឹងលើកមកវាយខ្នប់ពីក្រោយ, អ្នកឯងទឹងមិនក្ស័យស្លាប់ក្នុងកណ្ដាប់ដៃសត្រូវទេឬ? យើងធ្វើការធំយ៉ាងនេះ ហើយមករះយកឫក្សដោគ ដោយមកធ្វើការឲ្យ ថ្វោះទឹងសត្រូវដូច្នេះ មិនបានទេ, អ៊ុយអៀនថា បើមហាឧបកដមិនយល់ ដូចគំនិតខ្ញុំបាទ ថាទឹងលើកទាហានវាយសន្ធឹញពីមុខចូលទៅទេ ហៃហ្វូ-លិមក៏ទឹងលើកចេញទៅដោយពេញកម្លាំង, ពោះយើងទឹងច្បាំងវាយបាន ស្រុកឡុកអៀង ក៏គង់ប្រើការ, អស់ពលយោធា ក៏ទឹងបានសេចក្ដីលំបាកណាស់, ខុងបេងថា ៖ នោះ អ្នកកុំព្រួយបារម្ភ ខ្ញុំទឹងលើកទាហានសម្រុក បំពារចូលទៅយកជ័យជម្នះឲ្យបាន, អ៊ុយអៀនក៏ពាល់គំនិត នៅស្ងៀម ពុំហ៊ានតតបទៅទៀត, ខុងបេង ក៏លើកទាហានទៅប្រាប់ជូឡុង ឲ្យបង្ខំ ស្រូតចូលទៅវាយស្រុកគៀងអ៊ន ។

ឯហៃហ្វូលិម តាំងទ័ពនៅក្នុងស្រុកនោះ លុះដឹងថាជូឡុងលើកទ័ពជិតចូលមកដល់ក្នុំហងបេងស័ន ក៏ចាត់ទាហាន ៥.០០០ ចូលតទឹងជូឡុង, ហ័នតេក (នាយទាហានក្នុងស្រុកសេលៀង) និងកូន ៤ នាក់ ឈ្មោះហ័ន-អេង, ហ័នអៀវ, ហ័នខេង, ហ័នគី, ក៏និយាយនឹងហៃហ្វូលិមថា ខ្ញុំបាទ និងកូនខ្ញុំ ៤ នាក់ សុំអាសានាំពលយោធា ៨០.០០០ ជាទ័ពមុខចេញតតាំងនឹងជូឡុង, ហៃហ្វូលិមឮដូច្នោះ ក៏គិតឃើញថា ហ័នតេកមានកម្លាំងក្លាហាន ក៏មានអំណរណាស់ ឲ្យបំណាច់រង្វាន់ជាច្រើន ហើយក៏ចាត់ទាហាន ៨០.០០០ ឲ្យហ័នតេក ៗ ក៏តែងគ្រឿងជិះសេះកាន់ពូថៅធំដងវែងនាំបុត្រលើកទ័ពចេញអំពីកំពែងស្រុកទៅក្នុំហងបេងស័ន, ទទួលទ័ពជូឡុងលើកចេញមក, ហ័នតេកនឹងកូន ៤ នាក់ ក៏បំផាយសេះកាំពូថៅចេញមុខទាហាន ហើយស្រែកដេរជូឡុង ថា អាចោរព្លូកក្បត់ផែនដី ហេតុអ្វីឯងមិនស្រឡាញ់អាយុជីវិតសោះ អាចហ៊ានពានលើគ្រោះចូលមកក្នុងដែនអញ ៗ

(នៅមានត)

# រឿង

# គ្រោះថ្នាក់ធារាដោយខ្យល់ព្យុះ

របស់លោក រ៉ាប៊ិន្ទ្រណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ៣២

កមេស្ហកំពុងតែទៅទាក់ទងនិយាយអំពីរឿងជួលផ្ទះ ធ្វើទីសំណាក់ការមេធាវីទៅម្តុំមាត់ទន្លេគង្គា ហើយអ្នកត្រូវត្រឡប់ទៅគាល់ក័ត្តាវិញផង ដើម្បីនឹងសុំច្បាប់ទម្លាប់នឹងបូរទឹកទន្លេនោះផង ដើម្បីនឹងទៅទិញឥវ៉ាន់ផ្សេងៗ សម្រាប់ទឹកទន្លេថ្មីនោះផង ប៉ុន្តែចិត្តអ្នកពុំចង់ទៅសោះហើយបេះតែពន្យាពេលថ្ងៃនេះជាថ្ងៃនោះ ។

ផ្ទះលោកមាចក្របត្តិចង្អៀតចង្អល់ណាស់ ម្ល៉ោះហើយនាងកាមាលាត្រូវចូលទៅនៅជាមួយនឹងស្រីៗ ឯកមេស្ហក៏ត្រូវនៅនឹងបន្ទប់មួយតូចជាប់នឹងកនហាលខាងមុខ ។ ប៉ុន្តែ តែដល់ថ្ងៃអាទិត្យ បិពិនដែលជាប្តីនាងសិលាជា ត្រូវបានឈប់សម្រាក ហើយទៅជួបនឹងប្រពន្ធកូន ។ នាងសិលាជាមិនៈ ៈ ដីរទៅលេងបោលនាងកាមាលាទេ ប៉ុន្តែនាងមិនអាចនឹងខានជួបប្តីកើត ព្រោះមួយអាទិត្យគ្នាមកផ្ទះតែម្តង សមគួរនឹងហៅប្តី ដោយសារតែនាងកាមាលាប៉ុណ្ណោះ ។

ដើម្បីកុំឲ្យនាងកាមាលាទៅតែម្នាក់ឯង នាងសិលាជាគឺទឹកតែម្នាក់ឯងថា ត្រូវនាំកមេស្ហូទីងនាងកាមាលាឲ្យជាទីងគ្នាវិញទៅ ពីព្រោះតាំងតែពីឲ្យអ្នកទាំងពីរនេះនៅបែកគ្នា កមេស្ហូក៏មិនរកនាងកាមាលា នាងកាមាលាក៏មិនទៅមេះមោះរកកមេស្ហូ ប្រហែលជានាងចិងទីងកមេស្ហូ ដែលមិនព្រមចូលទៅរកនាងមុនហើយមើលទៅ ។

លុះត្រឡប់មកពីផ្ទះតទឹកវិញនាងសិលាជានិយាយទៅកាន់នាងកាមាលាថា:

- មកនេះមក ខ្ញុំជួយជជុសសក់ឲ្យធាប់ស្អូត នាងចំនិយាយជម្រុញឲ្យនាងកាមាលាពាក់អាវពណ៌ឲ្យឆើត នាងកាមាលាប្រកែក មិនព្រមធ្វើតាម ។

លុះរួចបាយថ្ងៃត្រង់ នៅពេលដែលម្តាយនាងចូលសម្រាន្ត នាងទៅខ្សឹបប្តីនាងថា:

— ទៅប្រាប់កមេស្ហូបន្តិចទៅ ថានាងកាមាលាឲ្យទៅជួបមួយភ្លែត នាងនៅចាំក្នុងបន្ទប់ ។

បពិនជាមនុស្សព្រំស្ងូវចេះនិយាយស្តីទេ អ្នកមិនចូលចិត្តធ្វើជាអ្នកនាំសារបៀបនេះប៉ុន្មានទេ ប៉ុន្តែគេទៅតាំងចំ ដោយមិនចង់ឲ្យមានរឿងមាត់ក ។

ពេលដែលបពិនចូលទៅ អ្នកឃើញកមេស្ហូគងគងអន្ទាក់ខ្លាផ្ទាល់

ទឹងព្រំទៅកន្លហលមើលសារពតិមាន លុះឃើញបីពីនគើតក្បាលចូលទៅ អ្នកស្ទុះក្រោកអង្គុយ តាមធម្មតាកាមេស្ហមិនចូលចិត្តឃើញមុខបីពីនទេ ពីព្រោះមុខមនុស្សនេះមិនទទួលភ្ញៀវសោះ ។

— នាងកាមាលាឲ្យលោកអញ្ជើញទៅបន្ទប់នាងមួយភ្លែត ព្ធដូច្នោះកាមេស្ហទឹកអព្រួប អ្នកស្បូវខ្ពូនអ្នកថា : (តើគួរទុកនាងជាប្រពន្ធតែម្តងទៅ ឬយ៉ាងណា ? ចុះបើនាងអន់ចិត្តតាំងពីប៉ុន្មានថ្ងៃមកហើយតើទឹងទៅនិយាយរកនាងបែបយ៉ាងម៉េច ដើម្បីឲ្យនាងបាត់ខឹង ពីព្រោះតែរឿងស្រីហើយទឹងប្រុសនៅជាមួយគ្នាមិនមែនជាប្តីជាប្រពន្ធនេះហើយ ដែលនាំឲ្យអ្នកពិបាកលៃលករកេជួលផ្ទះនៅតែពីរនាក់) ។ លុះព្ធថានាងចង់ជួបអ្នក អ្នកស្ទុះក្រោកដើរតាមបីពីនរេវ ក្រែងនាងចង់ជំនុំការអ្វីអំពីរឿងរកផ្ទះសម្បែង ។

កាមេស្ហដើរចូលទៅឈរពីក្រោយខ្នងនាងកាមាលា ហើយហៅនាងតិច ៗ នាងងាកមុខមកឃើញកាមេស្ហ ស្រាប់តែឡើងមុខក្រហមចេញបំហាយក្តៅកាយពីខ្លួនមួយរំពេច ។ នាងស្ញៀកពាក់តែងខ្លួនស្អាតណាស់ថ្ងៃនេះ កាមេស្ហហាក់ដូចជាចាញ់សម្រស់នាងក្នុងមួយរំពេចនោះ អ្នកដើរចូលទៅជិតនាង ហាក់ដូចជាភ្លេចស្មារតី ក្អកសម្ងំនាងសព្វសព្វាង្គកាយ ហើយនិយាយថ្នម ៗ ទៅរកនាង :

– នាងបានឲ្យគេទៅហៅខ្ញុំឬកាមាលា ?

– ទេ ! តើខ្ញុំមានការអ្វីនឹងឲ្យគេហៅបងមក ?

– បើកាមាលាមិនឲ្យគេហៅមកមែន តើជាទោសពៃអ្វី ? មានទោសឧក្រិដ្ឋឯណា ?

– មែនហើយ ប៉ុន្តែខ្ញុំមិនបានប្រើគេឲ្យហៅបងមកទេ ?

( នាងខំប្រកែកញ៉ាំមាត់ )

– ចុះបើបងមកដោយអូនមិនហៅ តើអូនដេញបងឬ ?

ចុះអ្នកឯទៀតនៅក្នុងផ្ទះនេះ គេដឹងថាបងចូលមកក្នុងបន្ទប់ខ្ញុំទាំងថ្ងៃយ៉ាងនេះ គេថាម្ដេចទៅ ?

កាមេស្ហទ្រាំមិនបាន ស្ទុះស្រវាចាប់នាងជាប់ហើយថា :

– បើអ៊ីចឹង មកនៅបន្ទប់បងវិញខាងនោះឥតមានអ្នកណាទេអូន ?

នាងកាមាលាខ្លាចស្ទង់ភ័យផង ខំបម្រះរូបអំពីរង្វង់ដៃកាមេស្ហ ហើយរត់ចូលទៅបន្ទប់មួយទៀត ព្រួញភ្លាបិទឈឹង ៗ

កាមេស្ហគ្រាន់តែឃើញថានាងនៅមិនទាន់បាត់ចិត្តនឹងអ្នកនៅឡើយ តែអ្នកនឹកម្សូរមៅនឹងឲ្យប្អូនសារចាប់ដៃទៅទាំងមិនអស់ចិត្ត ៗ អ្នកត្រឡប់ចូលទៅក្នុងបន្ទប់អ្នកវិញ ចាប់កាសែតមើលបន្តទៅទៀត ប៉ុន្តែខ្លួនអ្នកនៅញ័រប្រេប់នៅឡើយ គេ ខ្វាក់ខ្វល់អ្នកមានបេះដូងមួយវិលវៀន

បីដូចយ៉ាផ្ទាំងពពកសាត់លឿនស្រេវ តាមកម្លាំងតាខ្យល់ជូន មកគ្រឡប់ វិលវល់រកទិសដៅគ្មានធាតុក្តើងក្នុងខ្លួន អ្នកក៏ហាក់ដូចជាឡើងកម្រិតខុស ធម្មតាដោយសារតែបានប៉ះសាច់នាងមួយវិនាទីប៉ុណ្ណោះ ៗ

ពេលនោះនាងសិលាទៅគោះទ្វារនាងកាមាលា លុះមិនឮនាងឆ្លើយ សោះ នាងលូកដៃទៅទាញគន្លឹះទ្វារបើកឡើង ស្រាប់តែឃើញនាងគេង បង្ហូរទឹកភ្នែកសស្រាក់ហាក់ដូចជាអស់សង្ឃឹម នាងសិលាទៅអង្គុយក្បែរ នាងហើយសួរនាងថា :

– ថីនឹង ! បានជាយំ ?

– មកពីបងឯងទៅហៅគាត់មកទីណា !

អ្នកនៅក្នុងផ្ទះនោះទាំងប៉ុន្មានគ្មានអ្នកណាមួយដឹងថា បេះដូងនាង កាមាលាមានដំបៅទេ ហើយបើសិនជានាងដឹងខ្លួនមុន ថាកមេស្ហទឹងចូល មករកនាងៗ ក៏មិនដូច្នោះដែរ នេះគឺមកពីនាងកាមាលាមិនដឹងខ្លួនសោះ ៗ នាងកំពុងតែនឹកកយមាយទៅឆ្ងាយឯនោះ ស្រាប់តែភ្ញាក់មកឃើញបុរស ដែលនាងផ្ដុំចិត្តស្រឡាញ់នៅបង្កើយ ហាក់ដូចជាមានអ្វីមកធក់សតិ នាង ចេញផុតអំពីខ្លួន កម្លាំងអរទឹងក៏យមានបន្ទុះខ្លាំងហើយហ៊ានប្រាណនាង ក៏ងកគិតអ្វីមិនទាន់ចេះតែថាបុរុះចមិនទៅ ហើយនាងនឹកស្ដាយក្រោយៗ

តែនាងសិលាគ្មានយល់អ្វីក្នុងជម្រៅចិត្តនាងកាមាលាសោះទេ . . . នាងខំលួងសួរនាងថា

-កាមេស្ហថាអ្វីមិនសមរម្យ ឲ្យនាងឬ ?

-ឥតមានថាអ្វីទេ ប៉ុន្តែម្តេចក៏អ្នកបងទៅហៅគាត់មក ?

-បងខុសហើយអូន បងសុំទោស ។

## វគ្គទី ៣៣

នៅកាលក័ត្តា កាមេស្ហគិតតែធ្វើការ អ្នកមិនហ៊ានដាក់ជើងដល់កាលូប្ឡាទេ ។ អ្នកតាំងទីលំនៅៗជាដើប៉ាក់ គឹកខ្មែរដែលអ្នកធ្លាប់នៅពីមុន ប៉ុន្តែដោយមិនសូវមានការមមាញឹក មួយថ្ងៃៗហាក់ដូចជាយូរក្រៃពេក ណាអ្នកមិនចង់ឲ្យពួកម៉ាកបាស់ៗឃើញមុខអ្នកផង ការរស់នៅដោយលាក់បាំងនេះ ធ្វើឲ្យអ្នកតែតែអផ្សុកណាស់ទៅទៀត ។

លុះមកនៅតែម្នាក់ឯងទៅ ចិត្តគំនិតរបស់អ្នកក៏ហាក់ដូចជាធ្លាប់ អ្នកនឹកដល់សម្រស់របស់នាងកាមា.ហ បើប្រសិនជាយកនាងមកនៅជាមួយក្នុងផ្ទះដ៏ស្ងាត់ល្អនេះ . . . . ហើយអ្នកសម្រេចចិត្តថា ត្រូវឈប់គិតពីរឿងនាងហិមណាលទៀតពីថ្ងៃនេះទៅ ។

រឿងដែលកាមេស្ហមកគិតគំពីបញ្ជាប់ទម្លាប់នោះ បើសិនជាចង់ឈប់រួចផុតទៅហើយ ប៉ុន្តែកាមេស្ហជាមនុស្សទម្លាប់ឃើត ធ្វើការអ្វីមួយៗ មិនបេះដាច់ស្រេចទេ ម្ល៉ោះហើយទើបត្រូវចំណាយពេលយូរ ។

ឥឡូវនេះកិច្ចការទាំងប៉ុន្មានហើយស្រេចអស់ អ្នកត្រូវរៀបចំត្រឡប់

ទៅគ្នាស៊ីប្អូនវិញ ប៉ុន្តែមុននឹងទៅ គេចង់ដើរមួយជុំសិន ទៅមើលកន្លែងស្នេហាចាស់តើយ៉ាងម្តេចទៅហើយ ? គិតហើយអ្នកចាប់ក្រដាសមកសរសេរសំបុត្រ ១ ទុកឲ្យនាងហិមណាលិនី ប្រាប់រឿងក៏នាងឲ្យអស់ហើយផ្តាច់ខ្ទុតគ្នាតែម្តង ។

សរសេររួចអ្នកដាក់សំបុត្រក្នុងហោប៉ៅ ហើយចាំឲ្យតែថ្ងៃលិចទើងអាលដើរទៅរង់មើលក្រែងឃើញអ្នកបម្រើនាង គេនឹងទិញវាដើម្បីឲ្យវាយកសំបុត្រនោះទៅឲ្យនាងផ្ទាល់ ។

លុះព្រះអាទិត្យអស្តង្គតទៅ ស្បៃរាត្រីកាលក៏រាយគ្របផែនដី រាមេស្ហក៏ធ្វើដំណើរចេញទៅតម្រង់ផ្ទះនាងហិមណាលិនីទាំងបេះដូងដើរញ័រចម្រប់ ប៉ុន្តែលុះអ្នកទៅដល់ គ្មានឃើញទ្វារបង្អួចមួយបើកសោះឡើយ ក្នុងផ្ទះក៏ពុំឃើញអុជ ហាក់ដូចជាគ្មានមនុស្សនៅ អ្នកចូលទៅគោះទ្វារមួយសន្ទុះ មនុស្សម្នាក់ចេញមកបើកទ្វារ ។

— ស៊ូទាន់មែនទេ ?

ទាន — ខ្ញុំបាទ នឹងហើយ ?

— លោកអញ្ជើញទៅណាអស់ហើយ ?

— ទានអញ្ជើញទៅឯជើងជាមួយនឹងកូនស្រីលោកទៅហើយ ?

— ទៅតែពីរនាក់ នឹងនាងទេឬ ?

— ទាន ! ជាមួយនឹងណាលិន បាប៊ូដែរ ។

— ណាលិន ចាប៊ូជាអ្នកណា?

— ខ្ញុំបាទមិនសូវដឹងដែរ....ៗ

កាមេស្ហទឹកថា ណាលិន ប្រហែលជាមនុស្សម្នាក់ដែលធ្លាប់មកលេងទីផ្ទះនោះហើយមើលទៅ ប៉ុន្តែពោះជាកាមេស្ហលេងត្រូវការទឹងទាងហាមណាលិនទះទៀតក៏ដោយ ក៏អ្នកនៅតែទឹកក្ដៅ ហើយស្អប់ណាលិននោះយ៉ាងអស្ចារ្យ ៗ

អ្នកសួរទៅអ្នកបម្រើ......ៗ

— ខ្ញុំអាចឡើងទៅមើលលើផ្ទះមួយភ្លែតបានឬទេ?

អ្នកបម្រើចាប់លើកចង្កៀងជូនដំណើរកាមេស្ហឡើងទៅ កាមេស្ហដើរមើលពីបន្ទប់មួយទៅបន្ទប់មួយ គ្មានឃើញអ្វីប្លែកសោះ ប្លែកតែណាលិនទីមួយ អ្នកឃើញបន្ទប់អ្នកស្រីមៃឃើញរូបនាងទីងអ្នកឈរបណ្ដែតអារម្មណ៍ទាំងពីរនាក់ក្បែរគ្នា អ្នកបណ្ដោយបេះដូងឲ្យដើរញាប់ខុសធម្មតា ទឹកឃើញណាលីនមកឈរនៅកន្លែងរបស់អ្នក អ្នកទឹងក្ដៅឆួល ៗ

## វគ្គទី ៣៤

កាមេស្ហដែលទៅគិតគូររៀនច្បាប់ទម្លាប់បើកការិយាល័យមេធាវីអស់រយៈពេលមួយខែគត់ នាងកាមាលានៅចាំឯផ្ទះលោកមាយូរណាស់ មួយ

ខែប្រហែលគ្នានឹងមួយសត្តវត្ស កាលដែលនាងកាមាលាមិនទាន់បាន មកនៅជាមួយនឹងនាងសិលាជា នាងនៅក្នុងសេចក្តីពេក គ្មានស្គាល់ ការពក់ជ្រៅក្នុងរឿងប្តីប្រពន្ធបន្តិចសោះ លុះនាងបាននាងសិលាជា ជា មិត្តស្និទ្ធស្នាល តរុណីដែលរៀបនឹងរីក ក៏ប្រទ្រន់ក្រោយមួយរំពេច នៅពេលដែលកម្មរស្មីព្រះអាទិត្យចាំងប្រាលឡើង ។ បើសិនជានាង មិនទាន់បានឃើញច្បាស់ដោយភ្នែកនូវការស្និទ្ធស្នាល រវាងប្តីនឹងប្រពន្ធ របស់នាងសិលាជាទេ ការភ្ញាក់រឭកក៏ពុំទាន់មានដំណើររហ័សយ៉ាង នេះដែរ ។

នៅពេលដែលកាមេស្វររស់នៅឯកាល់គុត្តានោះ នាងសិលាជាចំ តៀនឪពុកនាងឲ្យរៀបចំបន្ទប់ដែលជួលទុកឲ្យនាងកាមា.លានោះ ឲ្យ ឆាប់ៗ ដូច្នេះនាងកាមាលា រិតបានផ្ទះមួយនៅកៀកនោកនឹងកាមេស្វ ហើយ នាងសិលាជាចំរកជួលមនុស្សទុកឲ្យបម្រើនាង ។ នៅជុំវិញផ្ទះ ដែលលោកមាជួលនោះ មាននៅសល់ដីទូលាយច្រើន ល្មមអាចយក ធ្វើជាសួនបន្លែឬសួនច្បារបាន មានដើមឈើធំៗដាំជាពីរជួរតាមផ្លូវមួយប្រ វែង ។ នៅផ្លូវនេះទំហំទន្ទេកថយ បើកធ្លាខ្សាច់យ៉ាងទូលាយឆ្ងាយ អំពីផ្ទះ ។ ផ្លូវនោះទំនេរមកយូរហើយ ទើបជាអ៊ូៗតាំងអស់ មាន ភាពដូចជាកត់កយ បែរទៅផ្ទះគ្រួក បែរទៅទីធ្លាព្រៃព្រៃ ប៉ុន្តែនាងកា មាលាសប្បាយចិត្តណាស់ ដោយបានឱកាសបញ្ចេញស្នាដៃជាស្រីមេផ្ទះ

នាងមិនធុញទ្រាន់មិនភ័យពីរឿងនេះឡើយ នាងចាំរៀបចំមួយថ្ងៃមួយថ្ងៃ រាល់ៗ ល្ងាចជាមួយនឹងលោកមា នាងមើលជាន់ធ្វើបន្ទប់បណ្តើរ នាងធ្វើព្រៃសួនបណ្តើរ ។

ការរៀបចំផ្ទះសំបែងធ្វើឲ្យផុសតម្លៃស្ត្រីភាពនៅៈពេលនោះ នាងកាមាលាប្រៀបបាននឹងបក្សីចេញពីទ្រុង ហើយហោះហើរលេងយ៉ាងត្រៀវត្រាតាមចំនង់ចិត្ត ទឹកមុខរីករាយនឹងហត្ថកោសល្យរបស់នាងក្នុងរឿងចាត់ការតាំងអម្បាលមាណធ្វើឲ្យរាមេស្ហទឹកគេគេហើយឆ្ងល់ មនោសញ្ចេតនាមួយថ្មីក៏ដុះឡើងក្នុងចិត្តអ្នក ។ ក្នុងរឿងរៀបចំផ្ទះសំបែងហាក់ដូចជានៅក្នុងរង្វង់ដៃនាងកាមាលាទាំងស្រុង បីដូចជាព្រះមហាក្សត្រមួយព្រះអង្គគង់ពេញសម្បត្តិក្នុងរង្វង់ព្រះហស្ត ។

លុះឃើញនាងធ្វើការងារ ដោយអស់សមត្ថភាពយ៉ាងនេះ រាមេស្ហសប្បាយចិត្តណាស់ ចេះតែចាំរកពាក្យអ្វីនិយាយយកចិត្តនាង ដើម្បីនឹងសម្តែងសេចក្តីស្វាមីភក្រ្តចំពោះនាង ដែលកំពុងតែផ្តល់សុខុមាលភាពដល់ខ្លួន គ្មានគិតនឿយហត់យ៉ាងនេះ ។

— កុំធ្វើអីកាមាលា ហត់ស្លាប់ហើយ ។

នាងកាមាលាងើបមើលមុខរាមេស្ហ ឈប់មួយសំកាន់ស្វាពសត្ញញឹមហើយចាប់បន្តការតទៅទៀត ចាំងរីករាយដោយឃើញរាមេស្ហយកចិត្តទុកដាក់នឹងកិច្ចការរបស់នាង ។

— កាមាលាញាំអីហើយឬនៅហ្នឹង (តាមពិតតឹកមេស្ហដឹងថានាងញាំរួចទៅហើយ) ប៉ុន្តែអ្នកចេះតែរករឿងនិយាយទីងនាង លុះឃើញនាងកាមាលា បោសផ្ទះដៃឯងទៀត កមេស្ហបន្ទោសនាងថាទុកឲ្យក្មេងធ្វើទៅ ។

លោកមាឆ្លើយកាត់ភ្លាម :

— ទេចុះធ្វើការទេតើ មានទៅថាកម្ស៊ី កមេស្ហឯងស្មានថាការបោសប្រាសជាការខ្ញុំគេឬ ឯចំណែកខ្ញុំវិញខ្ញុំយល់ថាប្រសើរណាស់ណា៎ ។ នែ! នាងកាមាលា ខ្ញុំជំរះស្មៅស្អាតហើយ តើនាងចង់ទុកកន្លែងត្រង់ណាដាក់ផើបន្លែ ចង្អុលប្រាប់ខ្ញុំបន្តិចមើល ។

អ្នកទាំងពីរនាក់ ក៏នាំគ្នាដើរត្រសងផ្ដោះទៅកន្លែងដែលនិយាយ ហើយពិគ្រោះគ្នាយ៉ាងយូរ ។

ពេលវេលាក៏ចេះដើរហួសទៅយ៉ាងរហ័ស ប៉ុន្តែគេហស្ថានតូចនោះនៅតែមិនទាន់បានស្អាតស្អំនៅឡើយ ម៉្លោះហើយកមេស្ហទីងនាងកាមាលា ក៏ត្រូវតែត្រឡប់ទៅផ្ទះលោកមាកាលតែល្ងាច ។ មួយថ្ងៃហើយ មួយថ្ងៃទៀត កមេស្ហទន្ទឹងចាំតែពេលផ្ទះរៀបចំហើយស្រេច នឹងបានចូលទៅនៅជាមួយទីងនាងកាមាលាតែពីរនាក់ ដើម្បីនឹងបានកាយកប់ប្រាប់នាងឲ្យអស់សេចក្ដី ដើម្បីនឹងបានថ្នាក់ថ្នមនាងឲ្យអស់ចិត្តដែលខំទ្រាំអត់យូរមកហើយ ....... ។

ប៉ុន្តែកាលវេលាចេះតែកន្លងទៅ ទាល់តែដល់ថ្ងៃដែលកមេសូ្ហ ត្រូវទៅចុះឈ្មោះនៅសាលាជំនុំជម្រះក្តី ដើម្បីឡើងកាត់ក្តីទីងគេ ម្ល៉ោះហើយអ្នកក៏ត្រូវធ្វើដំណើរទៅអាឡាហាបាដ ។

## វគ្គទី ៣៥

កមេសូ្ហចេញផុតទៅបានពីរថ្ងៃ លោកមាក៏ត្រូវទៅកន្លែងនោះដែរ ព្រោះពីធូកូនស្រីគាត់មានជម្ងឺ ។

ថ្ងៃនោះ នាងកាមាលាហៅនាងសិលាជាឲ្យទៅញ៉ាំបាយនៅផ្ទះថ្មីរបស់នាង ។ គេនាំគ្នាធ្វើបាយយកទៅញ៉ាំនៅក្រោមដើមឈើមួយធំក្បែរមាត់ទន្លេ អ៊ុយមេសូ្ហក៏ទៅជាមួយដែរ ។ ទេសភាពមួយដ៏ទ្រលឹងទ្រោឈ ខ្យល់អាកាសល្អនៃទីកន្លែងថ្មីនេះធ្វើឲ្យចិត្តនាងកាមាលាស្បើយកង្វល់រឿងដែលចាំកមេសូ្ហ ប៉ុន្តែគ្រាន់តែថ្ងៃជ្រេបន្តិចសោះ នាងសិលាជាទទូចត្រឡប់ទៅផ្ទះភ្លាម ដោយយកលេះថា ប្តីនាងត្រឡប់មកពីកន្លែងធ្វើការហើយ ក្រែងគេហៅរកនាងមិនឃើញ ។

— យី! បងបើឲ្យគាត់ចូលផ្ទះមុនយើងម្តងទៅមិនបានឬ?

នាងសិលាជាមិនឆ្លើយតបទេ នាងគ្រាន់តែញញឹមក្រវីក្បាល ហើយផ្តាំនាងថា កុំនៅយូរពេក កុំឲ្យយប់ពេក រៀបចំចូលផ្ទះទៅអូនកុំនៅម្នាក់ឯងនៅទីនេះ ។

លុះនាងសិលាជាចេញផុតទៅ នាងកាមាលាក៏រៀបចំឥវ៉ាន់ទំនិញត្រឡប់ទៅផ្ទះវិញ ប៉ុន្តែព្រះអាទិត្យនៅខ្ពស់នៅឡើយ នាងក៏បង្អង់អង្គុយនៅក្រោមម្លប់ឈើ មើលទូកនេសាទដែលបោលស្រមោលដង្កោនទៅលើផ្ទៃមេឃពណ៌ក្រហមឆ្អៅ ។

អ៊ុយមេស្ហូយកស្លាមួយមាត់ ខ្ចប់នឹងក្រដាសមកឲ្យនាង ហើយប្រាប់នាងថា លោកមាឲ្យទេះមកចាំទទួលនាងនៅឯនោះ នាងខំប្រញាប់រត់ទៅមើលផ្ទះមួយក្លូត នៅត្រង់កន្លែងដើងក្រានផុតភ្លើងបង្ហប់ឲ្យមានចំហាយក្តៅការពារត្រជាក់ នៅសិសិររដូវ មានចង្ក្រានមួយសម្រាប់អុជបំភ្លឺ ។ នាងកាមាលាយកកញ្ចប់ស្លាទៅលានៅក្រោមពន្លឺភ្លើង លុះឃើញអក្សរកមេស្ហូនៅនឹងក្រដាសខ្ចប់ស្លា :

– អ៊ុយមេស្ហូ! ឯងយកក្រដាសនេះពីណាមក ?

– ពីក្នុងបន្ទប់លោក . . . . ។

ក្រដាសនេះជាសំបុត្រដែលកមេស្ហូ សរសេរទៅនាងហ៊ិមណាលិនីជាក្រោយបង្អស់ ហើយញីបោះចោលទៅក្នុងគ្រក ដោយពុំបានគិតៗ នាងអានហើយមានទឹកមុខគួរឲ្យភ័យ អ៊ុយមេស្ហូសួរថា:

– ម៉ែ ម្តេចក៏ពីងម្ល៉េះ ? មានរៀងអ្វីឬ ?

នាងនៅឈរធ្ងឹង ទាល់តែបរើលោកមាចូលមកហៅនាងថា រទេះមកចាំនាងយូរណាស់ហើយ ទើបនាងដើរចេញទៅ ។

(នៅមានត)

# ល្បើកអក

[ក]

(ចម្លងពីសាស្ត្រាស្លឹករឹត)

ពាក្យ ៧

ជាតិនេះខ្ញុំខុសព្រោះព្រើលចិត្ត គ្មានគិតមុខក្រោយឲ្យសុខុម
ពាល់តែមកត្រូវទុក្ខធំ ដូចក្អែកបាក់ធ្លាក់សន្តិត់ ៗ
ឥឡូវនេះខ្ញុំសូមក្រាបលា អស់អ្នកពល់គ្នាស្តាប់តាមបទ
អកស្រីស្រដីអស់មួលមត់ ស្ទុះស្ទាត់ហោះហើរលើវេហាស៍ ៗ
ស្រដីអកស្រីតែប៉ុណ្ណោះ ពីនេះទីងថ្លែងថែងពណ៌នា
ពីសត្វទីទុយពីអេង្គា គិតគ្នាញីឈ្មោលនៅព្រៃចាំ ៗ
មានកាលសម័យថ្ងៃមួយណា បក្សាបក្សីស្តីបណ្តាំ
គិតគ្នាកេសុំតាមលំនាំ ព្រមព្រៀងប្រជុំចាំយប់សន្យា ៗ
លង់លុះព្រលប់យប់ងងឹត ទីទុយគង់គិតព្រាកព្រមគ្នា
ស្ទុះលោតហោះហើរលើវេហាស៍ រេរាំរៃរកកល់ស្រែ ៗ
ឃើញជាស្ទាបទម្លាក់ចុះ ដល់ដីហើយស្ទុះលោតឡប់ឡែ
រកក្តាមដើរតាមចង្អូរស្រែ ឃើញរន្ធហុយរន្ធហែប្រថុយចឹក ៗ
ជាគម្ចាំកាយទីទុយញី ញ៉ាមបានក្តាមស៊ីអរអើក
កន្ទឹកលោតលេងមិនមានទឹក លុះទៀបទៅព្រឹកព្រះសុរិយា ៗ

ទន់ប្រាណពានលើឯអន្ទាក់ ជាប់ជាក់ពាក់ខ្ទាប់ផ្កាប់មុខា
ព្យួរដើរត្រង់ឡើងជើងអាត្មា សិរសាលិចលង់ក្នុងទឹកក្បៀយ ៗ
ទីទុយឈ្លោលយល់ប្រពន្ធជាប់ អន្ទាក់រូតខ្ទាប់កិតក័យក្រៃ
តក់ស្លុតរន្ធត់ឥតឧបមេយ្យ កុលខ្ទងទៅព្យួទីនោះណា ៗ
ពប់រៀបទំនួញទួញប្រពន្ធ ជាខ្ញុំនោមយន់កែវកនិដ្ឋា
រៀមស្ម័គ្រស្រក្សស្មើផ្ទួនដីរ៉ា ស្នេហ៍ដំរិតកស្ដាស្ដាយមិនស្បើយ ៗ
ស្ដាយរូបស្ដាយអង្គទ្រង់ប្អូនស្រី ស្ដាយចិត្តបតីគ្មានពីរឡើយ
ស្ដាយចិត្តធ្លាប់ស្និទ្ធបៀតបង្កើយ ស្ដាយអើយស្ដាយសព្វគ្រប់ប្រការ ៗ
ប្រកាន់តាមច្បាប់ជាទុគ្រង ស្រីល្អមិនដែលពាល់ចិន្ដា
ប្រព្រឹត្តតាមចិត្តនៃជេដ្ឋា គេពោលយ៉ាងណាមិនថាអ្វី ៗ
នុកែវចរណៃថ្លៃម្សិលមិញ ត្រមង់ត្រមង់មានមេត្រី
ទុំទឹមកៀកកិតជិតនឹងប្ដី បតីមួរសស្មោះចិន្ដា ៗ
ចប្ដូលបងមករកក្ដាមស៊ី មាសមេសាបមាត់បងណាសា
បង់ព្រមតាមចិត្តឥតបើប៉ា មិនដឹងដ៏រ៉ាមាសមកក្បៀយ ៗ
ជាកម្មនាំប្អូនឲ្យប្រាសចង ឲ្យប្លះឲ្យប្លាងសែនអាល័យ
អាឡោះស្រណោះទឹកវេត្រៃថ្ងៃ តែងស្រមៃក្រៃព្រះមេះមិនបេះ ស្បើយ ៗ
ចង់រំពះរកទីទុយណា ឲ្យជួបកនិដ្ឋាមិនបានឡើយ
ខុសកាយធ្លាយចិត្តមិត្តអាសអើយ មិនដឹងណាឡើយឲ្យជួបស្រី ៗ

ស្ដាយរូប ៗ ស្រីដូចគេលាង    ស្ដាយនាង ៗ រៀនល្អពិសី
ស្ដាយមុខ ៗ សដូចសំឡី    ស្ដាយស្ដី ៗ ដូចរតាំងគង ។
ស្ដាយមាត់ ៗ ស្រួចដូចបន្ទា    នខាចុងស្រួចស្រស់វែង
ស្ដាយសាច់ៗម៉ដ្ឋខៀវទងវង    ស្ដាយឈ្ងងត្រឹមត្រៀបតម្រៀបរៀង ។
ស្ដាយក្លិនៗឈ្ងុយស្អុយឆ្អាបឆ្អេះ    ស្ដាយចេះលៃបខាយកាយបែរបៀន
បែរបៀតចេះស្លៀកបត់បញ្ជៀង    បញ្ចិតដេកផ្អៀងមិនអង់អាក់ ។
ទំទុយខ្ញួញសព្វាកយទំនុក    កើតទុក្ខទឹកភ្នែកស្រក់សស្រាក់
លង់លុះក្ស័យស្រានបំព្រាងជាក់    លោតចំកអន្ទាក់ទាញបណ្ដាច់ ។
ប្រឹងចិតបន្តិចលេចមនុស្សម្នាក់    ជាម្ចាស់អន្ទាក់មកដល់ចាប់
ទំទុយភ័យស្លុះជ្រុះទាំងកាចម៍    ញាប់ញ័រសព្វសាច់ប្រឹងហើរទៅ ។
ដល់ទីទ្រទំទំប្រផ្ទុក    សំកុកសំកាំងតាំងទុកនៅ
ខ្ញួញជាទុំណាមាស់នោមខ្មៅ    ម្ដេចចៅចោលបង់ឲ្យកំព្រា ។
ធ្លាប់ទំមទំទ្រទំមួយ    មិនដែលព្រួយព្រាសព្រាណឃ្លាតឃ្លា
ឃ្លាតខ្លួនសម្លាត់មួយវេលា    ឲ្យជារំខានបន្តិចគ្មាន ។
ឥឡូវព្រាសទៅទាំងប្រស់ៗ    ហេតុព្រោះពិតពីសេចក្ដីឃ្លាន
នាំកាយឲ្យកើតអន្តរធាន    ទាំងនេះហេតុមានពៀរពីព្រេង ។
បណ្ដាលឲ្យបងចង់ស៊ីក្ដាម    បញ្ឆោតលោតតាមដោយវង្វេង
ប្រសព្វកព្វគ្នាគាំងពីក្នុង    មិនដែលគិតខ្វេងយ៉ាងដូច្នោះ ។

ខ្ញុំយំតែងតែយំវិយោគ    សែនសោកសព្វថ្ងៃក្រៃស្មើរប្រេះ
ធ្លាក់ថ្លើមស្លុតសេចរេចរេះ    ធុញថប់ផ្សេះៗពល់ខែឆ្នាំ ។
មិនមានស្រាន្តស្រន់អន់ទុក្ខា    ទើបគិតថែថាអញនឹងចាំ
នៅនេះឲ្យស្រាលស្រយាកកម្ម    យូរឆ្នាំណាស់ហើយមិនឃើញបាត់ ។
ប្ដេះគួរអញៈហើរលើវេហាស៍    រកប្អូនពុំឃាសង្សារសត្យ
ក្រែងទាន់ទោះកើតៈដោយទីស្ងាត់    ជាសត្វស៊ីៗដខៃទៅ ។
ខ្ញុំគិតហ្មោះហើយហើរឡើង    ចរចើងចំណីព្រៃព្រឹក្សព្រៅ
ក្រឡេកមើលៈមេឃៈឃើញខ្មៅៗ    ប្រឹងហើរលឿនស្ទៀលង់លុះដល់ ។
ឃើញសត្វអកញីកិលាពលន់    ខ្ញុំគិតគន់ស្ដាប់កិច្ចកល
ព្ទអករៀបរប់សព្វគ្មានសល់    ទឹកធ្វល់ក្នុងចិត្តឥតស្រាកស្រាន្ត ។
ដោយសារជាសត្វកាត់គិតផ្ដាស    ថាក្រែងមុំមាសគូបុកណា
ស្ដាប់ខ្ញុំយំមកប្រកប្រាណ    ជាអ្នកទឹងមានគួរម័ត្យ ។
ទើបហើរលលើរកគូគ្រង    ទំនងរលឹកនឹកឥតអាក់
ខ្ញុំគិតហ្មោះស្ទុះចូលជាក់    ដល់ជាក់ស្ងប់ស្ងាប់ស្ទុះស្ទួរថា -
ហៃប្អូនពិសីស្រីអកអើយ    អូនអើយសូមចិត្តមិត្តមេត្តា
ត្រិតបងចង់ដឹងកិច្ចកលការ    ចុះយ៉ាងណាអ្នកអូនឯងយំ ។
កណ្ដាងកណ្ដាចដោយវេហាស៍    ម្នាក់ឯងឥតគ្នាស្ងាត់ជ្រងំ
កើតហេតុភេទអ្វីស្រីមាសមុំ    ស្រអុំឲ្យបងសែនសង្ស័យ ។

ស្វាមីមិត្តមាសប្រាសទៅណា ប្រាប់ក៏មាសមេកុំកែខ
ចង់គិតអាណិតអ្នកអួនក្រៃ ដូចជាមាននិស្ស័យពីព្រេងនាយ ៗ
នឹងហើរជៀសពេលទៅពុំបាន ចង់តែចរចូលមកនិយាយ
ចូរសួនទួនប្រាប់សព្វសម្ដាយ ឲ្យអាយបានដឹងដំណើរទាន់ ៗ
គ្រានោះនាងអកស្ដាប់ទីទុយ បន្ទុយបន្ទោរសីបំព្រាន
សូមប្រាណអ្នកស្រីស្រដីរាង ជាអ្នកបំព្រានមិនចង់ស្ដី ៗ
ចុះប្រាណបានកើតជារូបខ្ញុំ ទុកពុំចម្លែកនឹងលោកិយ
អស់គេទុក្ខតែពីអ្វីៗ មិនអប្រិយដូចប្រាណខ្ញុំនេះណា ៗ
តាំងតែកើតទុក្ខគ្មានពីអ្វី ទុក្ខតែពីប្ដីប្រាសអាសា
ពេលប្រាណកណ្ដែងឯងឯកា មិនចង់ជាចៅះក្ដៅចិត្តណាស់ ៗ
ទីទុយបានស្ដាប់សព្វអកស្រី ប្រាប់ថាប្រាសប្ដីប្រាកដច្បាស់
មានចិត្តគិតស្នេហ៍ប្រែក្រឡាស់ ស្ការស្មុះបក្ខាថាមាសបង ៗ
បើបោះមោះទៅឯក្រោមក៏ ដេជ្ជានឹងប្រាប់ណុងទួនល្អង
ឲ្យដឹងជាទស្មោះសោះសៅហ្មង ឲ្យស្បើយទុក្ខផងណាៈឆោមឆ្មៅ ៗ
អកត្រូទីទុយប្រចុយថា បងគិតយ៉ាងណាឲ្យបាត់ក្ដៅ
ទីទុយត្រូហើយឆ្លើយទៅពៅ ស្រណោស្រណាំហាំស្ដាប់បង ៗ
អកថាបើបោះប្រុសចរពោ ទីទុយថាអង្គណុចទួនល្អង
បើទៅចង់ស្ដាប់ស័ព្ទសាសង មាសបងចុះទៅនៅចុងឈើ ៗ

បងនឹងនិយាយឲ្យមាសមិត្ត ស្តាប់ឲ្យអស់ចិត្តមិនរុះរើ
បញ្ឆោតកែកកៃប្រែពាក្យពើ ឆ្លុះឆ្លើយល្ងង់ល្ងង់អកស្រី ។
អកស្តាប់ចាប់ចិត្តចង់ដឹងដាន ទឹកស្មានទីទុយមានប្រណី
និយាយប្រាប់ប្រាយពីរឿងប្តី បក្សីអកចុះចង់ដឹងការ ។
ដល់ដើមឈើតាលទំនៅនិត្យ ទីទុយទំជិតកិតកាយា
អកយល់ទីទុយធ្វើណាសា ស្តីថាអ្នកបងកុំធ្វើចេះ ។
ខ្លួនអ្នកជាប្រុសមោះមកថ្វី ខ្លួនខ្ញុំជាស្រីមានទុក្ខម៉្លេះ
អ្នកធ្វើក្អេងក្អាងថាដូច្នេះ ហាក់ដូចខ្ញុំនេះសហាយស្មន់ ។
ទីទុយស្តាប់អកឡកឡប់វ៉ា ហៃកែវកនិដ្ឋានកុំអាលអន់
បងគិតអាណិតនាងប្អូនតន់ ទ្រង់ទ្រាយកម្លាំងតាំងកាយា ។
ឃើញទំទ្រទំទាន់ទ្រេតទ្រោត បងសោកជួយទប់កែវកនិដ្ឋា
ដោយបងអាណិតគិតមេត្តា កុំយកទោសាណាទោមស្និទ្ធ ។
អកស្តាប់សាសព្វសត្វទីទុយ គិតថាសុខអុយកុំដូចចិត្ត
ប្រាកដជាគាត់នេះអាណិត ខ្លួនអញពិតៗដោយកំព្រា ។
អកគិតជឿចិត្តទីទុយហើយ ទើបឆ្លើយថាបងខ្ញុំស្មាលា
បងស្មានជាបក្សីធ្វើមិនជា ប្អូនក្សាក័យកិតគិតខ្លាចខ្លួន ។
ឥឡូវស្តាប់ទៅជឿចិត្តហើយ បងអើយឃើញចិត្តអាណិតជួន
មែនមានមេត្រីប្រណីស្ងួន មាំមួនពិតៗឥតសង្កា ។

ចុះម៉េចអ្នកថាឲ្យខ្ញុំចុះ អ្នកប្រុសប្រាមប្រាប់ពីមាត់ហ្ន៎
ឲ្យបានស្បើយល្ហើយពីទុក្ខា ប្រាប់ក៏អ្នកបងបើអាណិត ៗ
ទីទុយស្តែងស្តាប់សព្វសំដី អកស្រីអ្នកប្រាប់ដូច្នោះពិត
ទើបឆ្លើយវឹងវៃហៃមាសមិត្ត ផ្ចង់ចិត្តចាំស្តាប់នៃរៀមក៏ ៗ
រៀមរិះរឿងគេយកមកថ្លែង ទុកអូនឯងអើយកុំសង្កា
កាលនោះជាគ្រានៃជេដ្ឋា នាំគូស្នេហាទៅរកត្រី ៗ
ដល់ស្រែមួយនោះចុះរកក្តាម កម្មពៀរតែងតាមទីទុយញី
ជាន់ជាប់អន្ទាក់ក្ស័យជីវី ចោលតីណាងនៅតែម្នាក់ឯង ៗ
កំព្រាអង្គាជោះពោះម៉ាយ ចង់សោកសែនស្តាយចិត្តចំបែង
អាណោចិត្តអាណិតខ្លួនកន្ទេង តឹងតែងសង្រេងកន្ទេងផ្សា ៗ
យូរឆ្នាំដេកម្មរង្កៀសទុក្ខ គ្មានសុខស្រាលស្រន់អន់ថ្ងៃណា
ថ្ងៃនេះរៀមរិះក្នុងចិន្តា ចង់ចរយាត្រាត្រេចរកគូ ៗ
ក្រែងជួនចាប់ជាតិជាអ្វី ៗ ឲ្យដឹងសេចក្តីទីងគ្រាន់ធូរ
ត្បិតប្រាសនិរាសកំលង់យូរ ល្មមគូកើតបានប្រាណធំធាត់ ៗ
មកគិតដូចនោះស្មុះហើយមក ស្វែងរកណាងនួនស្ងួនកំសត់
ទុបាតសង្វាតមិនគិតហត់ ព្រោះចង់រលឹកទឹកអាល័យ ៗ
ហេតុតែផលឯងពីព្រេងមាន ពីព្រេងនិទ្ទានកែវចារណៃ
ព្រាត់គូគិតកើតេលព្វថ្ងៃ សង្ស័យសង្ក្រៃតែដូចគ្នា ៗ

បងនឹកថាខ្លួនស្ងួនវិលក្ខណ៍ តួដើមរៀមក្បួមអង្គា
អង្គីដទៃទៀតនានា ប្រាកដជារាប់ជាតិជាអូនឯង ៗ
បានជាមានប្ដីដទៃផ្សេង មិនមែនព្រេងទើបព្រាត់ឲ្យចំបែង
បងចាំគូផ្ដាំនៅជាក់ស្ដែង បងឯងមានគូជាដើមមិញ ៗ
ភេទពង្សវង្សសត្វដូចគ្នា ទឹងប្រាសឃ្លាតឃ្លាស្លាប់ទៅវិញ
ជាគ្រោះឲ្យបងរងទុក្ខមិញ ករន្ធួញកន្ទួលអួលអន់ចិត្ត ៗ
យូរឆ្នាំកម្មស្រាលបណ្ដាលឆាប់ គូមុនដែលស្លាប់ដល់កម្រិត
កម្រើកប្រាណកើតជារូបស្និទ្ធ ល្អឥតប្រៀបផ្ទឹមត្រឹមមិនបាន ៗ
ប៉ុន្ដែថាប្រែភេទជាអក ហើរកែតួក្បួមប្រាណ
លោកផ្ដាំឲ្យចាំគូបុរាណ បើជួបជួនបានប្រទះគ្នា ៗ
ជួបនៅនាព្រៃដោយដីដែន ពុំមែនជាគូជាភរិយា
បើបានជួបប្រាណលើវេហាស៍ ថាហើយជាក់ជាគូពីព្រេង ៗ
គ្រូផ្ដាំបងចាំពិតពុំភ្លេច ចំណាំមុខក្រោយក្រែងវង្វេង
ឥឡូវជួបហើយស្បើយទុក្ខពេង មិនថាលឹកលេងទេមាសបង ៗ
ចូរកែវកំសាន្ដកុំសោយសោក សែនសោយគាមោក្ខឲ្យមួហ្ង
ឲ្យមួម៉ៅក្ដៅចិត្តណាខ្លួនល្អង កុំសាសងឡើយខ្លួនសង្ស័យ ៗ
អកស្ដាប់សាសតួទីទុយថ្លែង រៀនឯងជាក់មុខធ្វើក្ជើះ ៗ (១)

---

១- ត្រង់នេះបាត់ចុងជួន ប្រហែលជាអ្នកចារចម្លងដោយល្បើងឃ្លាតក៏ពុំដឹង ។

ទញ់ទាល់ខ្វល់ទុក្ខមុខមិនរីក ចាំតែផ្ដឹកថ្ងាសឈ្ងើយធ្ងន់ ៗ
អ្នកបងប្អូនសាសន្តិទាន លើកដាក់ដោយមានកល់ប្រាជ្ញា
កាត់ជំរុះបន្ទុំឲ្យបានការ ចុះទុកាលណាទឹងសៀយទុក្ខ ៗ
អ្នកព្រានកត់យកតែសបត្តិ បញ្ចោតស្រីឲ្យស្រួលបន្ទាល់ទុក
ងើយងោយដោយក្ដាមតាមទំនុក ដូចកុកកើចជង់គង់មានភ័យ ៗ
បើស្រីដទៃទៀតមិនថា តាមតែប្រាជ្ញាគិតកែខៃ
កិច្ចកម្មញាំញីមិនសំចៃ បំភ័យឲ្យក្លាត់បង់ខ្លួនប្រាណ ៗ
ថ្ងោះថ្ងោយដោយអ្នករក្សារមរស បង់កេរ្តិ៍បង់ឈ្មោះមិនគិតអាន
មិនគិតក្ដុយប្រចុយតាមតែបាន គិតស្មានជាស្នោះអស់ចិន្ដា ៗ
វែងខ្ទួនខ្ទុំបញ្ចោត កុំម្ចាតនោះពួន គប់ហើយណា
បង់ស្មានជាបានដង់កលការ ថែថាបំបាត់កំចាត់ទុក្ខ ៗ
ដឹងគ្រប់លោមលួងលោមចង់ ឲ្យបានអង្គុទឹងអួតទៅមុខ
កុំធ្វើអំពើស៊ុកគ្រលុក ខ្មាសអស់អ្នកស្រុកគេនិន្ទា ៗ
ទីទុយស្ដាប់អកឡុកមិនរួច ទឹកព្រួយចាំប្រឹងចឹងបំពារ
បំពានចន្ទ្រានលោកឡើងស្គា បាទាជាន់ខ្នងកងគន្ទុយ ៗ
ក្ដោបក្ដាប់ទុយអកឡុកលួងលោម ប្រឹងរុះពេមព្រោងព្រាតព្រួយ
អកអន់អាក់ចិត្តគិតប្រចុយ ថាសុខអត់ឲ្យតាមចិន្ដា ៗ
ត្បិតគេបន្ទុំព្រាំតាមកល អកខ្វល់គិតខ្វែនណែនទុក

រីឯអស់កម្លាំងទន់កាយា ធ្លាក់ពីព្រឹក្សាដល់ផែនដី ៗ

ទង្គក់ទង្គត់ស្លុតស្លាប់ស្លុក ធ្លាក់ផ្លុកទាំងពីរក្នុងទឹកខ្វិ

ជាកម្មនាំសត្វបក្សាសី ចូលចាប់ជាតិប្រឡាំងកាស ៗ

សេចក្ដីដែលកពប្រសព្វកាម កំពុងចិត្តចាំមូលមិត្តផាស

ទៅកើតជាសត្វប្រឡាំងកាស ឥតខ្មាសឱបគ្នាគ្មានរបេះ ៗ

យប់ថ្ងៃអាស្រ័យលើខ្នងគ្នា ដូចជាយើងយល់ឥឡូវនេះ

ចិត្តកម្មចាំជាប់ដូចទាក់ស្រេះ ក្រណាស់អ្នកបេះកាត់តាមបាន ៗ

ទាំងឡាយគួរគិតចិត្តចងចាំ រីកម្មនេះឯងវែងស្មើប្រាណ

ប្រយ័ត្នប្រុងកាត់ឲ្យបង់បាន តែឲ្យខុសខានខួបអង្គា ៗ

រីឯអកក្នុំទាំងឈ្មោលញី នៅដើមគតិកាលនោះណា

ដែលស្លាប់ចាប់ជាតិដោយសញ្ញា កើតជាបក្សាសត្វកេងកង ៗ

បង្កើតហេតុកេទប្រច័ណ្ឌប្ដី មិនពីហេតុអ្វីសោះជាម្ដង

តែពីអកតាលកាលហើរធ្លង ប៉ុនប៉ងថាទៅរកចំណី ៗ

ខុសពុំបានដូចខសន្យា ប្រែជាទៅរកឯចង់ស្រី

ហោលហាស់ក្រឡាស់ឱបតែថ្មី សេចក្ដីនេះឯងកេងកងសត្វ ៗ

តែញីពងមិញចេញកាលណា បក្សាក្រោបក្រុងប្រុងប្រយ័ត្ន

បក្សីយកប្ដីចិទបំបាត់ ខំកាត់តែរន្ធឲ្យដង្ហើម ៗ

ធ្វើហេតុហាក់ផ្ដាលពីកាលអក សត្វញីធ្វើឲ្យកឲ្យទន់ថ្មើម

មិនមានទិលខ្ចបដូចយ៉ាងដើម    ចូរស្បើមឲ្យស្បថខិតជៀសចេញ ៚
រឿងនេះរិះលេងជាល្បែងល្បង    ពុំមានទំនងពីមុនមិញ
កុំចូលចិត្តជឿអស់អញម្នេញ    ពិតពេញពុំមានក្នុងគម្ពីរ ៚
លើកលេងជាល្បែងល្បងប្រាជ្ញ    ដោយសារនៅព្រើលនឹងស្រើញ
គិតក្រែងកំសាន្តចិត្តណោងកី    ជាទីសម្រាន្តកម្សាន្តទុក្ខ ៚
ចៅក្រមញុំាងខ្ញុំពឹងគេលើក    ជាល្បើកនេះឯងក្រែងអ្នកស្រុក
អ្នកស្រែចំការណាអផ្សុក    វិតក្កនឹងគិតកូនប្រពន្ធ ៚
មើលលេងក្រែងបានស្រាន្តស្រាលចិត្ត    បានគិតសន្សំខំឲ្យជួន
ក្រលៀសជៀសតាកជាក់គិតគន់    គិតគួររកបុណ្យបំបាត់បាប ៚
រឿងនេះរិះព្រើលមើលប្រៀនប្រាណ    ប្រៀនប្រដូនឲ្យបានទៅដពប
ព្រះបម្រើនទ័យលៃលើកកាព្យ    កំណាព្យកំណត់ម៉ត់ជ៏ឡេវ ៚

–ចប់–

# ផ្នែកកំណត់-ប្រវត្តិការណ៍

## ព្រះរាជាណាចក្រកម្ពុជា

លេខ ២៩ ររ.

## ព្រះរាជក្រឹត្យ

សម្ដេចព្រះ នរោត្តម សីហនុ ឧបយុវរាជ

ជាប្រមុខរដ្ឋ

បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៤៩៩-៦៩ ប.រ. ចុះថ្ងៃទី ១៤ ខែសីហា គ.ស. ១៩៦៩ ស្ដីពីការតែងតាំងគណៈរដ្ឋមន្ត្រី ។

បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ៨០៩-ប.រ. ចុះថ្ងៃទី ៣០ ខែធ្នូ គ.ស. ១៩៦៤ ស្ដីពីការរៀបចំជាថ្មី នៃក្រសួងធម្មការ និង សាសនៈ សិក្សាធិការ ។

បានទ្រង់យល់ព្រះរាជក្រមលេខ ១៤-នស. ចុះថ្ងៃទី ៩ ខែកុម្ភៈ គ.ស. ១៩៤៣ ស្ដីពីការរៀបចំរាជការក្រសួងពុទ្ធចក្រក្នុងព្រះរាជាណាចក្រ ដែលកែប្រែដោយព្រះរាជក្រមលេខ ៦៨-នស. ចុះថ្ងៃទី ១៥ ខែកញ្ញា គ.ស. ១៩៤៣ និងព្រះរាជក្រមលេខ-១-ររ. ចុះថ្ងៃទី ២៦ ខែឧសភា គ.ស. ១៩៤៨ ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ២៤-ររ. ចុះថ្ងៃទី ២៨ ខែវិច្ឆិកា គ.ស. ១៩៦៣ ស្ដីពីការតែងតាំងសម្ដេចព្រះមហាសុមេធាធិបតី

ជួន - ណាត ជាសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៩៣ - ន.វ. ចុះថ្ងៃទី ២៦ ខែឧសភា គ.ស. ១៩៤៨ ស្តីពីការតែងតាំងព្រះគ្រូ ហួត - តាត ជាព្រះពោធិវង្ស រាជាគណៈថ្នាក់ទី ១ នៃគណៈមហានិកាយ ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ២៤ - ន.វ. ចុះថ្ងៃទី ២៤ ខែកក្កដា គ.ស. ១៩៦៤ ស្តីពីការលើកឋានន្តរស័ក្តិព្រះគ្រូ ហួត - តាត ជាសម្តេចព្រះពោធិវង្ស នៃគណៈមហានិកាយ ។

តាមព្រះរាជបំណងយើង ។

ទ្រង់ត្រាស់បង្គាប់ដូចមានខាងក្រោមនេះ

ប្រការ ១— សម្តេចព្រះពោធិវង្ស ហួត-តាត ត្រូវបានលើកព្រះសមណសក្តិ ជាសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ ជំនួសសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត ព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ ដែលទ្រង់សោយព្រះទិវង្គត ។

ប្រការ ២ — អគ្គអធិការ អគ្គនាយកក្រសួងនានានៃព្រះបរមរាជវាំង និងរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ និងសាសនសិក្សាធិការ ត្រូវទទួលការៈចាត់ការរៀងខ្លួន ឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

ធ្វើនៅព្រះបរមរាជវាំង ក្រុងភ្នំពេញ នៅថ្ងៃទី ២៧ កញ្ញា ១៩៦៩

សម្តេចទ្រង់ឡាយព្រះហស្តលេខា : នរោត្តម សីហនុ

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ សូមឡាយព្រះហស្ដលេខា

សម្ដេចព្រះប្រមុខរដ្ឋ

អ្នកអង្គម្ចាស់

អគ្គនាយកក្រសួងនានា នៃ ព្រះបរមរាជវាំង

ព្រះហស្ដលេខា : ន.រោត្តម-កន្តុល

បានចម្លងត្រឹមត្រូវតាមដើម :

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុក

ក្រសួងធម្មការ និង សាសនសិក្សាធិការ,

ឌី-ឌុច

១២

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤១ ខែ ធ្នូ

ព.ស. ២៥១៣ គ.ស. ១៩៦៩

-ភ្នំពេញ-

១២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
បេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ | ផ្នែកសាសនា | ទំព័រ

១– រូប ជីវតិ មជ្ឈានំ តាមគោត្ត ន ជីវតិ សហ.ផេង.ជ្រីវ រៀបរៀង ១២៦៣
២– រឿងសុមនសាមណេរ លោក ប៊ូ-ប៊ូ រៀបរៀង . . . . ១២៦៧

## ផ្នែកអក្សរសាស្ត្រ

៣ – វបនានុក្រមសំស្ក្រឹតខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ១២៩២
៤ – រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ១២៩៦
៥– ឯកសារ : សត្វចិញ្ចឹម សហ. ចាប-រិត រៀបរៀង . . . ១៣១៤
៦– រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ អ្នកស្រីពេជ-សល់ ប្រែរៀបរៀង. . ១៣៤២
៧ – ប្រវត្តិគ្រូក្មេង នៅកំពង់ចាម អ្នកស្រី ពេជ-សល់ រៀបរៀង . . ១៣៥៩

## ផ្នែកកំណត់-ប្រវត្តិការណ៍

៨– ព្រះសង្ឃដីកា នៃសម្ដេចព្រះមហាសុមេធាធិបតីស្ដីពីការរួបរួមសាមគ្គី . ១៣៦៧
៩ – បុគ្គលិកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ចូលក្រាបបង្គំគាល់ព្រះបរមសព
នៃសម្ដេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួត-ណាត . . . ១៣៧៥
១០– បញ្ជីអត្ថបទដែលបានចុះផ្សាយក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៦៩ . . ១៣៨៧

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០៛០០ ។

ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ,
ឲ្យផុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា "

ក ព

# វិចារណកថា

## សេចក្តីអត្ថាធិប្បាយព្រះពុទ្ធភាសិត

រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ

លោក ដេង - ជ្រីវ រៀបរៀង

---

សម្តេចព្រះសង្ឃរាជជោតញ្ញាណោ ជួន-ណាត ជាទីគោរពសក្ការៈរបស់យើង ដែលព្រះអង្គទើបតែយាងចូលទិវង្គត ដ៏ជាទីសោកស្តាយនោះ ព្រះអង្គទ្រង់មានព្រះចំណារមួយ លើកម្រងអត្ថបទជាច្រើនដែលទ្រង់ប្រគល់ឲ្យទៅទស្សនាវដ្តីពុទ្ធចក្រ សម្រាប់បោះពុម្ពនោះ មានពុទ្ធភាសិតមួយឃ្លាថា "រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ" ហើយព្រះអង្គទ្រង់បាននិពន្ធបន្ថែម ជាពាក្យកាព្យថា ៖

រូបនៃសព្វសត្វ តែងវិបត្តិចាស់ជរា
ឯនាមនិងគោត្តា ឥតជរាដូចរូបឡើយ ។

សូន្យបាត់តែរូបទៅ    កេរ្តិ៍ឈ្មោះនៅជិតចង្កើយ
បើគេមិនគោះតើយ    គេអាចស្គាល់យូរអង្វែង ។

ព្រះឱវាទនៃព្រះពុទ្ធបរមគ្រូ ដែលសម្តេចព្រះសង្ឃរាជជាអម្ចាស់ទ្រង់លើកយកមកទូន្មាន ចុះក្នុងកថាខណ្ឌចុងក្រោយនៃព្រះរាជបណ្តាំរបស់ព្រះអង្គនោះ មានអត្ថន័យដ៏ជ្រាលជ្រៅ យ៉ាងទូលំទូលាយពន់ពេកណាស់ ចំពោះមនុស្សទាំងឡាយ ពិសេស ចំពោះជនជាតិខ្មែរ ជាពុទ្ធសាសនិកយើងនេះ ។

ដូច្នេះ យើងសូមធ្វើអត្ថាធិប្បាយ ដោយសង្ខេប នូវព្រះពុទ្ធភាសិតនេះ ដើម្បីជាសណ្តាប់ នៃពុទ្ធបរិស័ទទាំងឡាយ ដូចតទៅ ៖

“ រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ ” ប្រែថា ៖

រូបកាយនៃសព្វសត្វទាំងឡាយ រមែងតែជួបប្រទះនូវភាពគ្រាំគ្រានិងចាស់ជរាជានិច្ច ដោយហេតុក្តៅនិងធាតុត្រជាក់ ប្រកែកពុំបានឡើយ ហើយរមែងដល់ភាពសោះសូន្យ ក្នុងទីអវសានគ្មានសត្វលោកណាម្នាក់អាចជៀសផុតបានទាល់តែសោះ គឺថារូបកាយសត្វលោក បើកាលណាវិញ្ញាណនិងភ្លើងធាតុថយចេញផុតហើយ តែងតែដេកនៅលើផែនដី ដូចអង្កត់ឧសរកប្រយោជន៍គ្មាន ព្រមទាំងគ្មាននរណាទឹកនាឡើយ មានតែនាមនិងគោត្រប៉ុណ្ណោះទេ ដែលមិនចេះគ្រាំគ្រាមិនចេះចាស់ និងមិនសាបសូន្យ ។ ចំណុច ព្រះបដិមាភាសា នៃសម្តេចព្រះសង្ឃរាជ

ជាម្ចាស់នេះ សឲ្យឃើញនូវទឹកព្រះរាជហឫទ័យប្រកបដោយធម៌មេត្តាករុណារបស់ព្រះអង្គ មុននឹងទ្រង់សោយព្រះទិវង្គត ចំពោះពុទ្ធបរិស័ទជាជនជាតិខ្មែរយើងទាំងឡាយជាកូនចៅព្រះអង្គក្នុងកម្ពុជរដ្ឋ ក្រែងពុំបានយល់ច្បាស់នូវរឿងនេះ ហើយបេះតែបណ្តែតបណ្តោយអាត្មាឲ្យប្រព្រឹត្តទៅតាមយថាកម្ម ៗ ព្រះអង្គទ្រង់មានព្រះបំណងក្នុងគ្រាអវសាន ចង់ប្រៀនប្រដៅពុទ្ធបរិស័ទទាំងឡាយឲ្យយល់ច្បាស់ថា គួរតែប្បីណែនាំគ្នាខំប្រឹងកសាងកុសលឬកិច្ចកសាងអ្វីជាប្រយោជន៍មនុស្សផងគ្នា កុំបីធ្វេសប្រហែសឲ្យសោះ ព្រោះតែកាលណារូបរាងកាយយើងពល់គ្នា ត្រូវសេចក្តីស្លាប់គ្របសង្កត់ ហើយរូបកាយនេះ ត្រូវគេនាំយកទៅបោះបង់ចោល ឬកប់ចោល ឬក៏យកទៅបូជាក្នុងទីសមសានជាអសារបង់ គ្មានសំណល់អ្វីជាការណ៍មានប្រយោជន៍ឡើយ គឺទៅសល់តែនាមនិងគោត្រឬកេរ្តិ៍ឈ្មោះប៉ុណ្ណោះទេ ដែលមិនបាត់ទៅណា ៗ កេរ្តិ៍ឈ្មោះនេះរមែងបិតទៅជាប់ក្នុងដួងវិញ្ញាណនៃបច្ឆាជនជាធម្មតា កេរ្តិ៍ឈ្មោះនោះបើល្អក្តី ឬអាក្រក់ក្តីមិនបាត់ទៅណាឡើយ អ្នកមានកេរ្តិ៍ឈ្មោះល្អរមែងធ្វើឲ្យគេពោលសរសើរ ឲ្យគេបេះតែនឹករលឹក ឲ្យគេស្តាយស្រណោះគ្មានឈប់ អ្នកមានកេរ្តិ៍ឈ្មោះអាក្រក់រមែងធ្វើឲ្យគេស្អប់ខ្ពើម ឲ្យគេប្រទេចផ្តាសា មិនតែប៉ុណ្ណោះសោតថែមទាំងធ្វើឲ្យកូនចៅរបស់ខ្លួន ត្រូវទទួលការអាម៉ាស់មុខការអៀនខ្មាសដោយសារផង ៗ គុណសម្បត្តិនិងគុណវិបត្តិទាំងពីរបែប

នេះ ស្រេចលើយើងជាអ្នកជ្រើសយកចុះ តែព្រះរាជហឫទ័យនៃសម្តេចសង្ឃរាជជាអម្ចាស់ ទ្រង់ប្រាថ្នាឲ្យយើងជ្រើសយកគុណសម្បត្តិហើយ ។

ដូច្នេះ គួរយើងទាំងឡាយចៀរចាកគំនិតពុករលួយ ទាំងប្រាំប្រការឲ្យជ្រះស្រឡះចេញពីខន្ធសន្តាន នោះកេរ្តិ៍ឈ្មោះរបស់យើងនឹងឋិតនៅក្រអូបប្រាសខ្យល់រាល់រាំងបច្ឆាជនទាំងឡាយ បើពុំដូច្នោះទេ រូបកាយស្លាប់បាត់បង់ទៅ យើងថែរជាទុកកេរ្តិ៍អសោច ឲ្យកូនចៅនៅឯក្រោយមិនខានឡើយ ។

នេះហើយជាចំណុចសំខាន់បំផុត ខាងមានព្រះរាជហឫទ័យប្រកបដោយព្រហ្មវិហារធម៌នៃសម្តេចព្រះសង្ឃរាជជាអម្ចាស់ មកលើយើងគ្រប់គ្នាជាសិស្សគណ ជាពុទ្ធបរិស័ទ ពិសេសជនជាតិខ្មែរទាំងមូល ក្នុងកម្ពុជរដ្ឋនេះឯង ។ បំណាច់មានភ័ព្វវាសនា បានកើតមកជាមនុស្សម្តងកាលបាត់បង់ជីវិតទៅ ត្រូវឲ្យមានស្នាដៃអ្វីមួយ ទុកជាប្រយោជន៍នៃបច្ឆាជន យ៉ាងហោចណាស់ក៏ឲ្យមានឈ្មោះល្អ ទុកជាគម្រាប់ ឬ ជាគ្រូនៃកូនចៅ ព្រមទាំងជនរួមជាតិផងកុំខាន កុំឲ្យគេពោលថាថារស់នៅត្រាន់តែទម្ងន់ផែនដីនោះ ។

# រឿងសុមនសាមណេរ

អដ្ឋកថាធម្មបទ ភិក្ខុវគ្គទី ២៥ ភាគទី ៨

ព្រះមហាឡ៊ូ ឡ៉ូ រៀបរៀង

កាលព្រះបរមសាស្ដាគង់ក្នុងបុព្វារាម ទ្រង់ប្រារព្ធនឹង សុមនសាមណេរ សម្ដែងធម៌ដោយបទគាថា ថា យោ ហវេ ដូច្នេះជាដើម ។

អនុបុព្វីកថា ក្នុងរឿងនេះ ដូចតទៅ ៖

សេចក្ដីពិស្ដារថា កាលគ្រាសាសនានៃព្រះពុទ្ធព្រះនាមថា បទុមុត្តរៈ មានកុលបុត្រម្នាក់ឃើញព្រះសាស្ដាទ្រង់តាំងភិក្ខុមួយរូបទុកក្នុងតំណែង ជាអ្នកប្រសើរលើសជាងភិក្ខុបណ្ដាដែលបានទិព្វចក្ខុ ក៏ប្រាថ្នាឲ្យបានទិព្វចក្ខុនោះ ទើបនិមន្តព្រះសាស្ដាថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធាន អស់ ៧ ថ្ងៃ តាំងសេចក្ដីប្រាថ្នាទុកថា បពិត្រព្រះអង្គដ៏ចម្រើន ! សូមឲ្យខ្ញុំព្រះអង្គ បានជាអ្នកកំពូលប្រសើរជាងភិក្ខុបណ្ដាដែលបានទិព្វចក្ខុក្នុងសាសនានៃព្រះពុទ្ធមួយព្រះអង្គ ។ ព្រះសាស្ដាទ្រង់ពិចារណាមើលទៅមុខ រហូតមួយសែនកប្ប ទ្រង់ជ្រាបថា សេចក្ដីប្រាថ្នារបស់គេនឹងបានសម្រេច ទើបទ្រង់ព្យាករថា ក្នុងទីបំផុតនៃសែនកប្ប តាំងអំពីនេះទៅ អ្នកនឹងបានជាព្រះ អនុរុទ្ធត្ថេរ ជាកំពូលប្រសើរជាងភិក្ខុបណ្ដាដែលបានទិព្វចក្ខុក្នុងសាសនានៃព្រះពុទ្ធព្រះនាមថា គោតម ។ កុលបុត្រ

បានព្យាករណ៍នោះ នឹកសម្គាល់សម្បត្តិនោះថា ហាក់ដូចជាខ្លួននឹងបានសម្រេចក្នុងថ្ងៃស្អែក ៗ លុះព្រះសាស្តាបរិនិព្វានទៅ កុលបុត្រនោះសួរកិច្ចអ្នកបរិកម្មទិព្វចក្ខុទាំងឡាយ ហើយកសាងគោមជាច្រើនពាន់ ព័ទ្ធជុំវិញព្រះស្តូបមាសចម្ងាយរយៈផ្លូវ៧ យោជន៍ ឲ្យយកគោមនោះបូជា, លុះច្យុតចាកភពនោះ ហើយបានទៅកើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវតានិងមនុស្សអស់មួយសែនកប្ប ហើយទៅកើតក្នុងត្រកូលអ្នកកម្សត់ទុគ៌តក្នុងនគរពារាណសី ទីពឹងអាស្រ័យនឹង សុមនសេដ្ឋី ជាអ្នកទទួលប្រតដឹកនាំស្មៅឲ្យសេដ្ឋីនោះចិញ្ចឹមជីវិត ៗ បុរសនេះមាននាមប្រាកដថា អន្នភារៈ ៗ ឯលោកសុមនសេដ្ឋីបានថ្វាយទានធំៗ ក្នុងនគរនោះជានិច្ចកាល ៗ បំណារក្រោយមក ថ្ងៃមួយ ព្រះឧបរិដ្ឋបច្ចេកពុទ្ធចេញចាកសមាបត្តិនៅក្នុងភ្នំគន្ធមាទន៍ត្រិះរិះថា ថ្ងៃនេះអាត្មានឹងអនុគ្រោះដល់អ្នកណាហ្ន៎! ទើបបានជ្រាបថា ថ្ងៃនេះ អាត្មាអញគួរនឹងអនុគ្រោះដល់អន្នភារបុរស ដ្បិតឥឡូវនេះ គេកំពុងតែជញ្ជូនស្មៅចេញពីព្រៃមកផ្ទះ, គិតស្រេច ក៏កាន់បាត្រនិងចីវរ ហោះមកដោយឫទ្ធិ ប្រាកដចំពោះមុខអន្នភារបុរស ៗ ឃើញលោកកាន់បាត្រមកទទេគ្មានបាយដូច្នោះ ក៏សួរថា "លោកម្ចាស់! បានភិក្ខាហារខ្លះហើយឬនៅ?" កាលលោកឆ្លើយថា "នឹងបាន អ្នកមានបុណ្យច្រើន!" ទើបទូលថា "បើដូច្នោះសូមលោកម្ចាស់មេត្តាប្រោសសត្វរង់ចាំបន្តិចសិន" ដាក់ចោលបាច់ស្មៅហើយ

ប្រញាប់ទៅផ្ទះសួរភរិយាថា "នាង ! អាហារជាចំណែកដែលចាប់ទុកឲ្យយើង មានដែរឬទេ?" កាលបានឮនាងភរិយាឆ្លើយថា "មាន" ក៏ប្រញាប់មកទទួលយកបាត្ររបស់ ព្រះបច្ចេកពុទ្ធទៅ គិតថា "កាលអញប្រាថ្នានឹងឲ្យទាន គ្មានទេយ្យធម៌ គឺតែសម្រាប់ឲ្យទាន, កាលមានទេយ្យធម៌ហើយ, គ្មានលោកអ្នកទទួលទាន, ប៉ុន្តែ មកដល់ថ្ងៃនេះលោកអ្នកទទួលទាន ក៏អញបានជួប, ទាំងទេយ្យធម៌ក៏មាន, នេះ ជាលាភរបស់អញប្រសើរណាស់" គិតហើយ ទៅដល់ផ្ទះ យកអាហារដាក់ចុះក្នុងបាត្រហើយនាំត្រឡប់មកប្រគេនព្រះ បច្ចេកពុទ្ធវិញ រួចតាំងសេចក្ដីប្រាថ្នាទុកថា "ដោយការឲ្យទាននេះ,សេចក្ដីទ័លក្រ សូមកុំឲ្យកើតមានដល់ខ្ញុំឡើយ, សូម្បីតែពាក្យថា "គ្មាន" ក៏សូមកុំឲ្យមានដល់ខ្ញុំគ្រប់ ៗ ភពរៀងទៅ, បពិត្រលោកម្ចាស់ សូមឲ្យខ្ញុំរួចផុតអំពីការចិញ្ចឹមជីវិតដោយទ័លក្រលំបាកយ៉ាងនេះ, សូម្បីតែបទថា "គ្មាន" ក៏សូមកុំឲ្យខ្ញុំបានឮសោះឡើយ" ។ ព្រះ បច្ចេកពុទ្ធ ធ្វើការអនុមោទនាថា ចូរឲ្យបានផលសម្រេចតាមប្រាថ្នានោះចុះ, ម្នាលអ្នកមានបុណ្យធំ" ! រួចលោកនិមន្តចេញទៅ ។ ចំណែកទេវតាដែលឋិតនៅក្នុងឆត្រ (សម្រាប់យស) របស់លោកសុមនសេដ្ឋី ក៏ឲ្យសាធុការដល់បីដងថា :

គួរឲ្យរីករាយចិត្តពេកណាស់ ទានដ៏ជាកំពូល ដែល អន្នភារបុរសថ្វាយហើយដល់ព្រះ ឧបរិដ្ឋ ដូច្នេះ ។ ខណៈនោះ សេដ្ឋីសួរ

ថា "យើងថ្វាយទានអស់វេលាប៉ុណ្ណេះឆ្នាំ អ្នកមិនឃើញទេឬ ?" ទេវតាឆ្លើយថា "ខ្ញុំមិនឲ្យសាធុការព្រោះទានរបស់លោកទេ !, ក៏សាធុការនេះខ្ញុំបន្លឺឡើង ព្រោះជ្រះថ្លានឹងបិណ្ឌបាតទាន ដែលអន្នភារបុរស ថ្វាយដល់ព្រះ ឧបរិដ្ឋ" ។ សេដ្ឋីគិតថា គួរឲ្យអស្ចារ្យណាស់ ! អញថ្វាយទានអស់វេលាដល់ប៉ុណ្ណេះឆ្នាំ មិនអាចនឹងញុំាងទេវតាឲ្យ ។ សាធុការបាន, ឯអន្នភារបុរសអាស្រ័យទីពឹងអញចិញ្ចឹមជីវិត ធ្វើឲ្យទេវតាឲ្យសាធុការបាន ព្រោះបិណ្ឌបាតទានតែមួយប៉ុណ្ណោះ, អញត្រូវតែធ្វើទ្រព្យឲ្យល្មមសមគួរក្នុងទាននោះ យកបិណ្ឌបាតទាននោះមកជារបស់អញវិញ, ទើបប្រើបម្រើឲ្យហៅអន្នភារបុរស មកសួរថា "ថ្ងៃនេះ តើឯងបានឲ្យអ្វីទៅអ្នកណាខ្លះ ?", អន្នភារបុរសឆ្លើយថា "ទានព្រោស ! ថ្ងៃនេះ ខ្ញុំបាទបានថ្វាយអាហារដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធ" ។ សេដ្ឋីប្រាប់ថា "ណ្ហើយចុះ ! ឯងយកកហាបណៈ[១] នេះទៅ ហើយឲ្យប្តូរបិណ្ឌបាតនោះមកយើង" ។ អន្នភារបុរសឆ្លើយថា "ជូនមិនបានទេ ទានព្រោស !" ។ សេដ្ឋីបន្ថែមប្រាក់ឡើងដល់មួយពាន់រៀល ។ សូម្បីសេដ្ឋីឲ្យប្រាក់ឡើងដល់មួយពាន់រៀល ក៏នៅតែអន្នភារបុរសមិនព្រមឲ្យបិណ្ឌបាតនោះដែរ ។ ខណៈនោះ សេដ្ឋីនិយាយទៀតថា "ណ្ហើយចុះ ! បើឯងមិនឲ្យបិណ្ឌបាតទេ ក៏ត្រូវយកប្រាក់មួយពាន់រៀលនេះទៅចុះ ហើយប្តូរឲ្យចំណែក

---

១- គឺមួយរៀល ។

បុណ្យខ្លះមកយើង ៗ បុរសនោះឆ្លើយថា "បាំខ្ញុំបាទរត់ទៅសួរលោកសិន រួចនឹងមកជម្រាបវិញ" ថាហើយក៏ រត់យ៉ាងលឿន ទៅតាមព្រះបច្ចេកពុទ្ធ "ទាន់ហើយទូលសួរថា ពានព្រោស! លោកសុមនសេដ្ឋី ឲ្យប្រាក់ខ្ញុំមួយពាន់រៀល ហើយសូមយកចំណែកបុណ្យខ្លះកុសលបិណ្ឌបាតរបស់ព្រះគុណម្ចាស់, ដូច្នេះ តើនឹងឲ្យខ្ញុំធ្វើដូចម្តេច ព្រះករុណា ? ៗ

ខណៈនោះ ព្រះបច្ចេកពុទ្ធ បានពន្យល់ដោយឧបមាប្រៀបធៀបឲ្យអន្នភារបុរសនោះស្តាប់ថា "ម្នាល បណ្ឌិត! បបរមួយចាបក្តី ចាបមួយវែកក្តី ដែលអ្នកបានឲ្យទានរួចហើយ, កាលបើអ្នកចែកចំណែកបុណ្យកុសលបបរចាបនោះទៅឲ្យអ្នកឯទៀតហើយ, បបរចាបមួយវែកនោះ រឹតតែចម្រើនទ្វេច្រើនភាគឡើងទៀត, បើឲ្យគេចំនួនប៉ុន្មានភាគ ក៏ចម្រើនឡើងចំនួនប៉ុណ្ណោះភាគដែរ, ឯអ្នកឯងឲ្យបិណ្ឌបាតត្រឹមតែមួយចំណែកដល់អាត្មា, កាលបើអ្នកចែកចំណែកបុណ្យកុសលទាននេះទៅឲ្យលោក សុមនសេដ្ឋី, បិណ្ឌបាតមួយចំណែកប៉ុណ្ណោះ នឹងកើតកើនឡើងទៅដល់ពីរចំណែក គឺរបស់អ្នកឯងមួយចំណែក របស់លោកសេដ្ឋីនោះមួយចំណែក, ប្រៀបដូចប្រទីបតែមួយគេអុជទុកក្នុងផ្ទះមួយ ហើយមានអ្នកផ្ទះរាប់រយត្រកូលឯទៀតយកប្រទីបរបស់ខ្លួនមួយ ៗ ម្នាក់ មានទាំងប្រេងទាំងប្រឆេះស្រាប់ ទៅអុជចម្លងយកភ្លើងពីប្រទីបមួយ

នោះបន្តទៅទៀត ដូចេះ តើអ្នកយល់ថា ពន្លឺភ្លើងរបស់ប្រទីបដើមមួយនោះនៅមានដែរឬគឺអស់ ? ។

បុរសឆ្លើយថា ពន្លឺភ្លើងរបស់ប្រទីបដើមមួយនោះ រឹតតែភ្លឺខ្លាំងឡើងជាងពន្លឺមុនទៅទៀត លោកម្ចាស់ ! ។

រួចអន្នការបុរស ទូលថា "បើដូច្នោះ ជាការប្រពៃណាស់ព្រះគុណម្ចាស់ !" ថារួច ថ្វាយបង្គំលាព្រះបច្ចេកពុទ្ធ វិលមកជម្រាបលោកសេដ្ឋីវិញថា" ធានប្រោស ! សូមលោកទទួលយកចំណែកផលបុណ្យចុះ" ។ សេដ្ឋីទទួលថា "បើដូច្នោះ អ្នកចូរទទួលយកប្រាក់ទាំងអស់នេះទៅចុះ" ។ អន្នការបុរស ប្រកែកថា "ធានប្រោស! ខ្ញុំបាទមិនបានលក់បិណ្ឌបាតទេ, ខ្ញុំបាទសូមចែកជូនតែចំណែកផលបុណ្យប៉ុណ្ណោះដោយសទ្ធា" ។ សេដ្ឋីឆ្លើយថា "បើអ្នកឲ្យដោយសទ្ធា, ខ្ញុំសូមបូជាគុណរបស់អ្នក, ចូរយកប្រាក់ទៅចុះ, ហើយតាំងពីថ្ងៃនេះទៅ អ្នកកុំធ្វើការងារគេឡើយ, ចូរសង់ផ្ទះនៅក្បែរផ្លូវចុះ, គ្រឿងការរបស់អ្វីជាចាំបាច់ របស់គ្រប់មុខ អ្នកចូរមកយកអំពីខ្ញុំចុះ ។

រីឯបិណ្ឌបាត ដែលថ្វាយដល់លោកចេញពីនិរោធ រមែងបានទទួលផលក្នុងខណៈនោះ ។ ព្រោះដូច្នោះ សូម្បីព្រះរាជាបានទ្រង់ព្រះសណ្តាប់ដំណឹងនោះហើយ ទ្រង់ត្រាស់បញ្ជាឲ្យហៅ អន្នការបុរសចូលទៅគាល់ ទ្រង់ទទួលយកចំណែកបុណ្យ ហើយព្រះរាជទាន

សម្បត្តិជាច្រើន រួចព្រះកដទានតំណែងសេដ្ឋី ដល់បុរសនោះទៀត ។ សេដ្ឋីថ្មីនេះ បានជាសម្លាញ់នឹងសុមនសេដ្ឋី ធ្វើបុណ្យដរាបដល់ក្ស័យជីវិត ច្យុតចាកភពនោះហើយទៅកើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវតានិងមនុស្ស, លុះមកដល់ពុទ្ធុប្បាទកាលនេះ បានមកចាប់បដិសន្ធិក្នុងវាំងស្តេចសក្យៈ ព្រះនាម អមិតោទនៈ, ព្រះប្រយូរញាតិបានដាក់នាមថា អនុរុទ្ធ ជាព្រះកនិដ្ឋភាតារបស់ស្តេចសក្យៈមហានាម ជាព្រះឱរសរបស់ព្រះ ចុល្លបិតា (មា) របស់ព្រះសាស្តា ជាបរមសុខុមាលជាតិមានបុណ្យច្រើន ។

បានឮថា ថ្ងៃមួយ កាលដែលស្តេចសក្យៈទាំងប្រាំមួយអង្គ ទ្រង់ក្រសាលអង្គុញយកនំធ្វើជាខ្នាប់ (គ្រឿងសម្គាល់នៃការចាញ់ឈ្នះ) ព្រះអង្គម្ចាស់អនុរុទ្ធ ចាញ់ ក៏ប្រើបម្រើទៅដល់ព្រះមាតា ដើម្បីត្រូវការនំ ។ ព្រះមាតាយកភាជនៈមាសខ្នាតធំដាក់នំពេញបញ្ជូនទៅឲ្យ ។ អ្នកបម្រើមកយកនំទៅថ្វាយ ដល់បីលើក, ក្នុងលើកទីបួន ព្រះមាតាប្រាប់ទៅថា ឥឡូវនេះនំគ្មានទេ ។ ព្រះអង្គម្ចាស់អនុរុទ្ធ បានឮពាក្យប្រាប់របស់ព្រះមាតាហើយ យល់ថា ឥឡូវនេះ ប្រហែលជានឹងមាននំដែលឈ្មោះថា "គ្មាន" ព្រោះមិនធ្លាប់ឮពាក្យថា "គ្មាន" សោះ, ទើបប្រើអ្នកបម្រើថា "ចូរឯងទៅយកនំគ្មាននោះមកចុះ" ។ កាលព្រះមាតារបស់ព្រះអង្គម្ចាស់បានឮពាក្យ ដែលអ្នកបម្រើមកទូលថា "បពិត្រព្រះនាងម្ចាស់ ! សូម

ព្រះនាងឲ្យនំគ្មានមកចុះ" ដូច្នេះហើយក៏គិតថា "បុត្ររបស់អញ មិនធ្លាប់ឮពាក្យថា"គ្មាន"ទេ, ធ្វើម្ដេចហ្ន៎ អញនឹងឲ្យបុត្របានដឹងសេចក្ដីដែលនំនោះគ្មាន" គិតយ៉ាងនេះហើយ ក៏លាងថាសមាសឲ្យស្អាត ហើយយកថាសមាសមួយទៀតគ្របឲ្យជិតពីលើ ហើយប្រាប់ថា "ហ៎ ! យកទៅចុះ ! ឯងចូរយកថាសនេះទៅឲ្យបុត្ររបស់អញ" ។

ខណៈនោះ ទេវតាអ្នករក្សាព្រះនគរគិតថា "ម្ចាស់របស់អញ កាលគ្រាកើតជា អន្នភារបុរស បានថ្វាយអាហារជាចំណែករបស់ខ្លួនដល់ព្រះ ឧបរិដ្ឋបច្ចេកពុទ្ធ ហើយតាំងសេចក្ដីប្រាថ្នាទុកថា សូមកុំឲ្យខ្ញុំបានឮបទថា'គ្មាន' ឡើយ, ដូច្នេះ បើអញដឹងសេចក្ដីនោះហើយនៅតែធ្វើព្រងើយកន្តើយ, ក្បាលរបស់អញក៏ត្រូវបែកចេញជា ៧ ភាគ" គិតរួចក៏យកនំទិព្វដាក់ក្នុងថាសមាសពេញ ។ បុរសនោះនាំយកថាសមកហើយ តម្កល់ទុកក្នុងសម្នាក់របស់ព្រះអង្គម្ចាស់សក្យៈទាំងនោះ ហើយបើកគម្របឡើង ។ ក្លិនរបស់នំនោះ ធុំសាយផ្សាយទៅពេញព្រះនគរ ។ ក៏កាលដែលព្រះអង្គម្ចាស់ទាំងនោះលើកនំឡើង ដាក់ក្នុងព្រះឱស, ឯឱជារស ក៏បានជ្រួតជ្រាបទៅសព្វសរសៃសម្រាប់ទទួលរសជាតិទាំង ៧ ពាន់ ។ ព្រះអង្គម្ចាស់ អនុរុទ្ធ ទ្រង់ត្រិះរិះថា "កាលមុនពីពេលនេះព្រះមាតាប្រហែលជាមិនស្រឡាញ់អញទេ បានជាក្នុងវេលាមុនៗ លោកមិនដែលធ្វើនំគ្មានឲ្យអញ", ទើបទៅទូលសួរព្រះមាតាថា "ម៉ែ ! ខ្ញុំមិនជា

ទីស្រឡាញ់របស់ម៉ែទេឬ ?

ព្រះមាតាទូលសួរថា កូន ! ឯងជាម៉េច ? ឯងជាទីស្រឡាញ់យ៉ាងក្រៃលែងរបស់ម៉ែ ជាងភ្នែកទាំងពីរ ជាងដួងហឫទ័យ ។

ព្រះអនុរុទ្ធឆ្លើយថា ម៉ែ ! បើខ្ញុំជាទីស្រឡាញ់របស់ម៉ែ ហេតុអ្វីបានជាកាលពីដើម ម៉ែមិនដែលធ្វើនំគ្មាននេះឲ្យខ្ញុំខ្លះផង ។ ព្រះមាតាសួរអ្នកបម្រើថា នែអ្នក ! ក្នុងថាសមានវត្ថុអ្វីខ្លះដែរឬ ? អ្នកបម្រើឆ្លើយថា មាន ព្រះនាង !, ថាសពេញទៅដោយនំ, នំបែបនេះ ខ្ញុំមិនដែលឃើញសោះឡើយ ។ ព្រះមាតាគិតថា បុត្ររបស់អញបានធ្វើបុណ្យទុកមក ទេវតាឃើញថាសទទេ ក៏បញ្ជូននំទិព្វទៅឲ្យ ។ ព្រះអនុរុទ្ធបាននិយាយនឹងមាតាតទៅទៀតថា ម៉ែ ! នំបែបនេះ ខ្ញុំមិនដែលបានទទួលទានសោះ ចាប់ដើមតាំងតែពីថ្ងៃនេះទៅ សូមម៉ែធ្វើតែនំគ្មានម្យ៉ាងប៉ុណ្ណោះឲ្យខ្ញុំ ។ តាំងពីថ្ងៃនោះមក កាលបើព្រះអនុរុទ្ធ និយាយថាចង់បរិភោគនំ ព្រះមាតាក៏លាងថាសមាស ហើយយកថាសមាសមួយទៀតគ្របផ្ញើទៅឲ្យ ។ ទេវតាក៏ដាក់នំទិព្វពេញថាសនោះ ។ ព្រះអនុ-រុទ្ធ កាលនៅជាឃរាវាស មិនបានដឹងសេចក្តីរបស់បទថា "គ្មាន" ទេ, បរិភោគតែនំទិព្វប៉ុណ្ណោះ ។ ក៏កាលដែលឱរសរបស់ស្តេចសក្យៈនាំគ្នាចេញបួសតាមលំដាប់ត្រកូល ដើម្បីជាបរិវាររបស់ព្រះសាស្តា, កាលស្តេចសក្យៈមហានាមនិយាយថា កូនក្នុងត្រកូលរបស់យើង នៅពុំ

ទាន់មានអ្នកណាចេញបួសទេ, អ្នកឬខ្ញុំ គួរតែនឹងបួស ? ។ ព្រះអនុរុទ្ធ ឆ្លើយថា ខ្ញុំជាមនុស្សទន់ខ្សោយ មិនអាចនឹងបួសបានទេ ។ ស្ដេចមហានាម ឆ្លើយថា បើដូច្នោះ អ្នកចូររៀនការងារចុះ, យើងនឹងទៅបួស ។ ព្រះអនុរុទ្ធ សួរថា ដែលហៅថាការងារ គឺអ្វី ? ក៏ព្រះអនុរុទ្ធ មិនបានដឹងសូម្បីតែទីកើតនៃអាហារ ( ឆ្នាំងបាយ ) ដូម្ដេចនឹងទៅដឹងដល់ការងារ ? ព្រោះដូច្នោះ បានជាសួរយ៉ាងនោះ ។

ថ្ងៃមួយ ស្ដេចទាំងបីអង្គគឺ អនុរុទ្ធ១ ភទ្ទិយៈ១ កិម្ពិលៈ១ ប្រឹក្សាគ្នាថា បាយកើតឡើងពីទីណា ? បណ្ដាស្ដេចបីអង្គនោះ ព្រះកិម្ពិលៈ ឆ្លើយឡើងថា បាយកើតឡើងក្នុងជង្រុក ។ ព្រោះថា ថ្ងៃមួយ ព្រះកិម្ពិលៈ បានឃើញស្រូវដែលគេជញ្ជូនដាក់ក្នុងជង្រុក, បានជានិយាយយ៉ាងនោះ ដោយសម្គាល់ថា បាយកើតក្នុងជង្រុក ។ ខណៈនោះ ព្រះភទ្ទិយៈ ឃាត់ព្រះកិម្ពិលៈថា អ្នកមិនទាន់ដឹងទេ, បាយរមែងកើតឡើងក្នុងឆ្នាំងបាយទេតើ ។ ព្រោះថា ថ្ងៃមួយ ព្រះភទ្ទិយៈ បានឃើញគេដួសបាយចេញពីឆ្នាំង ទើបចូលចិត្តថា បាយកើតឡើងក្នុងឆ្នាំងនោះឯង បានជានិយាយដូច្នោះ ។ ព្រះអនុរុទ្ធ និយាយទៅនឹងបងប្រុសទាំងពីរអង្គថា ព្រះអង្គទាំងពីរក៏នៅតែមិនទាន់ជ្រាបដែរ បាយតែងកើតឡើងក្នុងថាសមាសធំកម្ពស់មួយគក់ ។ ព្រះអនុរុទ្ធ មិនដែលបានឃើញគេចុកអង្ករដណ្ដាំបាយទេ, ធ្លាប់បានឃើញតែ

បាយ ដែលគេដួសដាក់ជាសមាប តម្កល់ទុកខាងមុខខ្លួនប៉ុណ្ណោះ, ព្រោះ ដូច្នោះ បានជាសម្គាល់ថា បាយកើតឡើងក្នុងថាសមាសនោះឯង ទើប និយាយដូច្នោះ ៗ កុលបុត្រអ្នកមានបុណ្យច្រើន សូម្បីតែទីកើតបាយ ក៏មិនដឹង ធ្វើម្ដេចនឹងដឹងការងារបាន! ៗ

ព្រះ អនុរុទ្ធ នោះ ដែលដឹងការងារពុំមានទីបំផុតនេះ ដោយ សារបងនិយាយប្រាប់ មានន័យជាដើមថា "មកណេះ អនុរុទ្ធ ប្អូន! យើងនឹងប្រៀនប្រដៅកិច្ចការរបស់អ្នកនៅគ្រប់គ្រងផ្ទះដល់អ្នក, មុនដំបូង ត្រូវឲ្យភ្ជួរស្រែ" ដូច្នេះ, ព្រះ អនុរុទ្ធ ត្រិះរិះថា "ប្រយោជន៍អ្វីដល់អញ ដោយការគ្រប់គ្រងផ្ទះ" ទើបបង្គំលាមាតា ហើយចេញទៅជាមួយនឹង សាក្យកុមារ ប្រាំអង្គ មានព្រះ ភទ្ទិយ: ជាប្រធាន, ចូលទៅ គាល់ព្រះសាស្ដានៅអនុបិយម្ពវ័ន ហើយសូមបួស ៗ ព្រះអនុរុទ្ធ បួស ស្រេចហើយ ជាអ្នកប្រតិបត្តិត្រូវផ្លូវ ធ្វើឲ្យជាក់ច្បាស់វិជ្ជាទាំងបី អង្គុយ នៅលើអាសនៈតែមួយអាចនឹងសំឡឹងមើលលោកធាតុកប់ពាន់ ដោយ ទិព្វចក្ខុ ឃើញដូចជាផ្លែកន្ទួតព្រៃដែលដាក់លើបាតដៃដូច្នោះ, ទើបបាន បន្លឺឧទានឡើងថា: "អញពេកនិវាសនៈ ខាងក្រោយបាន, ទិព្វចក្ខុ អញក៏បានជម្រះហើយ, អញបានដល់សេចក្ដីសម្រេចវិជ្ជាបីហើយ, ពាក្យ ប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ អញបានធ្វើតាមរួចហើយ" ដូច្នេះ ហើយពិចារណាមើលថា "សម្បត្តិនេះ អញបានព្រោះធ្វើអ្វីអេះ" បាន

ក្រាបថា "ព្រោះបានតាំងសេចក្ដីអញប្រាថ្នា ក្នុងទីជិតព្រះបាទរបស់ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា បទុមុត្តរៈ" ហើយក្រាបតទៅទៀតថា "កាលអញត្រាច់ស្ដាត់ទៅក្នុងវដ្ដសង្សារ បានកើតជាបុរសឈ្មោះអន្នភារៈ ពឹងពាក់អាស្រ័យនឹងសុមនសេដ្ឋីចិញ្ចឹមជីវិត នៅក្នុងព្រះនគរពារាណសី កាលជាតិឯណោះ" ដូច្នេះ ហើយពោលថា ៖

"កាលជាតិមុន ខ្ញុំកើតជាអន្នភារបុរស ជាមនុស្សកម្សត់ ទុគ្គតអ្នករកស្មៅ, ខ្ញុំបានថ្វាយបិណ្ឌបាតដល់ព្រះឧបរិដ្ឋ អ្នកទ្រង់យស" ដូច្នេះ ។

ខណៈនោះ គំនិតនេះកើតឡើងដល់លោកថា "សុមនសេដ្ឋីជាសម្លាញ់របស់អញ ដែលបានឲ្យកហាបណៈ អំពីបិណ្ឌបាតដែលអញថ្វាយដល់ព្រះឧបរិដ្ឋ ហើយសូមទទួលយកចំណែកបុណ្យកាលគ្រានោះ ឥឡូវនេះ ទៅកើតនៅទីណា"? ។ ខណៈនោះ លោកបានឃើញសេដ្ឋីនោះ ទៅកើតជាចូឡសុមនៈ ក្នុងចំនួនបុត្រពីរនាក់គឺ មហាសុមនៈនិងចូឡសុមនៈ ជាបុត្ររបស់ឧបាសកនាមថា មហាមុណ្ឌកៈ នៅក្នុងមុណ្ឌនិគមជិតជើងភ្នំ ដែលក្បែរព្រៃធំនេះហើយ ។ លុះលោកឃើញហើយក៏គិតថា កាលបើអញទៅក្នុងទីនោះ នឹងមានប្រយោជន៍ខ្លះដែរឬទេ? ។ លោកពិចារណាមើលឃើញថា កាលអញទៅក្នុងទីនោះ ចូឡសុមនៈ មានអាយុត្រឹមតែ ៧ ឆ្នាំនឹងចេញបួស ហើយនឹងបានសម្រេចព្រះអរហត្ត ក្នុងវេលាដែលកោរសក់នុ៎ះឯង ។ កាល

លោកឃើញហើយ ដល់ថ្ងៃជិតចូលវស្សា បាននិមន្តទៅតាមផ្លូវអាកាស ចុះត្រង់មាត់ទ្វារ ។ ចំណែកមហាមុណ្ឌកឧបាសក កាលពីមុនក៏ជាមនុស្សធ្លាប់ស្និទ្ធស្នាលរបស់ព្រះថេរៈដែរ ។ គាត់បានឃើញព្រះថេរៈកំពុងឈរចាំបិណ្ឌបាតនៅទីនោះ ហើយប្រាប់មហាសុមនៈ ដែលជាកូនថាកូន ! ព្រះអនុរុទ្ធត្ថេរជាម្ចាស់យើងនិមន្តមកហើយ កូនចូរទៅទទួលយកបាត្ររបស់លោកមកទុក រហូតដល់វេលាដែលពុំមានអ្នកណាទទួល, អញនឹងក្រាលអាសនៈ ។ មហាសុមនៈ បានធ្វើតាមពាក្យបិតានោះហើយ ។ ឧបាសកអង្គាសព្រះថេរៈដោយគោរព កន្សែងរបស់ខ្លួនរួចហើយទទួលបដិញ្ញាដើម្បីការឱ្យនៅចាំវស្សាអស់ត្រៃមាស ។ ព្រះថេរៈទទួលនិមន្តហើយ ។ ឧបាសកក៏នៅចាំមើលថែរក្សាបម្រើព្រះថេរៈអស់បីខែ ហាក់ដូចតែមួយថ្ងៃ, ដល់ថ្ងៃមហាបវារណា បាននាំយកត្រៃចីវរនិងវត្ថុជាច្រើនមុខ មានស្ករអំពៅ ប្រេងនិងអង្ករជាដើម មកតម្កល់ទុកជិតបាទាព្រះថេរៈ ហើយទូលថា និមន្តលោកម្ចាស់ទទួលទុកចុះ ។

ព្រះថេរៈ – ល្មើយ ! កុំអីឧបាសក ! អាត្មាមិនត្រូវការនឹងវត្ថុទាំងនេះទេ ។

ឧបាសក – នេះសំពត់ចំណាំវស្សា សូមលោកម្ចាស់ទទួលទុកចុះ ។

ព្រះថេរៈ – ល្មើយកុំ ឧបាសក !

ឧបាសក – ហេតុអ្វីបានជាលោកម្ចាស់មិនព្រមទទួលយក ?

ព្រះថេរៈ — ដ្បិតសាមណេរជាកប្បិយការកៈ ក្នុងសម្នាក់របស់អាត្មាគ្មានទេ ។

ឧបាសក បើដូច្នោះមហាសុមនៈ ជាបុត្ររបស់ខ្ញុំព្រះករុណានឹងបួសជាសាមណេរ ។

ព្រះថេរ — ឧបាសក ! អាត្មាមិនត្រូវការ មហាសុមនៈទេ ។

ឧបាសក— បើដូច្នោះ លោកម្ចាស់ឲ្យ ចូឡសុមនៈបួសចុះ ។

ព្រះថេរៈ ព្រមទទួលពាក្យ ហើយឲ្យចូឡសុមនៈបួស ។ ចូឡសុ-មនៈ នោះ បានសម្រេចព្រះអរហត្តក្នុងវេលាដែលកោរសក់នុ៎ះឯង ។ ព្រះថេរៈ គង់នៅជាមួយនឹងសាមណេរក្នុងទីនោះ ប្រមាណអស់កន្លះខែ (រាប់ពីត្រឹមថ្ងៃមហាបវារណាមក) តាំងព្រះទ័យថានឹងទៅគាល់ព្រះសាស្តា, ទើបបានលាពួកញាតិរបស់សាមណេរ ទៅតាមផ្លូវអាកាស ចុះត្រង់ខ្ទម (កុដិ) ដែលនៅក្នុងព្រៃនាហិមវន្តប្រទេស ។ ឯព្រះថេរៈជាអ្នកប្រារព្ធសេចក្តីព្យាយាមតាមប្រក្រតី កាលលោកកំពុងចង្ក្រមក្នុងយប់មុន និងយប់តមកទៀត ក្នុងព្រៃនោះ ខ្យល់ចុកសៀតពោះបានកើតឡើងហើយ ។ ខណៈនោះ សាមណេរឃើញព្រះថេរៈលំបាក ទើបទូលសួរថា បានព្រោស ! ព្រះគុណមិនសប្បាយឬអ្វី ?

ព្រះថេរៈ- ខ្យល់ចុកសៀតពោះកើតឡើងដល់យើង ។

សាមណេរ- កាលពេលមុន ធ្លាប់ជាបាត់ចុកឬទេ ។

ព្រះថេរៈ- ល្អប់ជាប្អាត់បុក សាមណេរ!

សាមណេរ- ធ្វើម្ដេចទើបនឹងបានជា ព្រះគុណ!

ព្រះថេរៈ- កាលបើបានទឹកក្នុងស្រះអនោតត្តមកឆាន់ ទើបជាសាមណេរ!

សាមណេរ- បើដូច្នោះ ខ្ញុំនឹងទៅយកមកប្រគេន ៗ

ព្រះថេរៈ- នឹងទៅយកបានឬ សាមណេរ!

សាមណេរ- ទៅយកបាន ពានព្រោស!

ព្រះថេរៈ- បើដូច្នោះ ស្ដេចនាគនាមថា បន្នគៈ នៅស្រះអនោតត្តស្គាល់យើង, អ្នកចូរប្រាប់ដល់គេ ហើយយកទឹកមួយក្អមមក ដើម្បីប្រើជាថ្នាំ ៗ សាមណេរទទួលពាក្យថ្វាយបង្គំលាព្រះឧបជ្ឈាយ៍ ហើយហោះឡើងកាន់វេហាស៍, ទៅដល់ទីស្រះនោះចម្ងាយ ៥ រយយោជន៍ក៏ថ្ងៃនោះ ស្ដេចនាគមានអ្នកកំដោមពេបព្រហ្មថានឹងលេងទឹក គ្រាន់តែក្រឡេកឃើញសាមណេរទៅដល់ភ្លាម ស្រាប់តែក្រោធខឹងថា "សមណៈគ្រគោលនេះ គ្រាប់ទៅជ្រុះធន់ធូលីនៅបាតជើងលើក្បាលរបស់អញ នឹងមកយកទឹកក្នុងស្រះអនោតត្ត, ឥឡូវនេះ អញមិនឲ្យយកទឹកបានទេ" ខឹងយ៉ាងនេះហើយ បានដេកដកពាំងបិទស្រះអនោតត្តទំហំដល់៥០យោជន៍ ផិតដូចជាគេយកថាសខ្ទាតចំគ្របផ្ទាំងបាយទុកដូច្នោះ ៗ សាមណេរលុះបានឃើញអាការរបស់ស្ដេចនាគ ក៏ជ្រាបថាគេខឹង, ទើបពោលគាថា

នេះសេចក្តីថា :

ស្តេចនាគអ្នកមានតេជ:ក្លា មានកម្លាំងច្រើន សូមចាំស្តាប់ពាក្យអាត្មាសិន, ឲ្យទឹកដល់អាត្មាបន្តិចមកចុះ, អាត្មាត្រូវការធ្វើជាថ្នាំ បានជាមកយក ។

ស្តេចនាគស្តាប់ពាក្យនោះ ទើបពោលគាថានេះសេចក្តីថា :

ទាល់ទិសបូព៌ា ស្ទឹងធំឈ្មោះគង្គាទៅជាប់ជិតមហាសមុទ្រ លោកចូរទៅយកទឹកនានអំពីនោះទៅចុះ ។

សាមណេរបានឮដូច្នោះ គិតថា "ស្តេចនាគនេះ មុខជាមិនព្រមឲ្យទឹកដោយសេចក្តីឥច្ឆារបស់ខ្លួន, អញនឹងធ្វើពលការឲ្យគាត់ដឹងមហានុភាពនឹងសង្កត់គាត់ ហើយយកទឹកទៅឲ្យបាន" គិតរួចពោលថា "មហាបពិត្រ ! ព្រះឧបជ្ឈាយ៍ប្រើអាត្មាឲ្យមកយកទឹក អំពីស្រះអនោតត្តនេះ, ហេតុនោះ អាត្មានឹងយកទឹកនេះទៅឲ្យទាល់តែបាន, ចូរមហារាជចៀសចេញទៅ, កុំឃាំងអាត្មាឡើយ" ហើយពោលគាថានេះ សេចក្តីថា៖

អាត្មានឹងយកទឹកអំពីស្រះនេះឲ្យបាន, អាត្មាត្រូវការដោយទឹកនេះឯង, បើកម្លាំងខ្លាំងក្លារបស់ព្រះអង្គមាន អញ្ជើញឃាំងទាំងទុកចុះ, លោកជាស្តេចនាគ.

ខណ:នោះ ស្តេចនាគឆ្លើយថា "លោកសាមណេរ ! បើលោកមានសេចក្តីព្យាយាម, ខ្ញុំពេញចិត្តនឹងពាក្យសម្តីរបស់លោកហើយ អញ្ជើញ

លោកយកទឹករបស់ខ្ញុំទៅចុះ" ។

ពេលនោះ សាមណេរឆ្លើយថា "មហាបពិត្រ! បើដូច្នោះ អាត្មានឹងយកទឹកទៅ", កាលដែលស្ដេចនាគឆ្លើយថា "បើលោកអាចយកបាន, ចូរយកទៅចុះ" ដូច្នេះហើយ ក៏ទទួលប្ដេជ្ញាគ្រប់បីដងថា "បើដូច្នោះ មហាបពិត្រ ចូរជ្រាបឲ្យច្បាស់ចុះ" ហើយគិតថា "ញត្រូវតែសម្ដែងអានុភាពរបស់ព្រះពុទ្ធសាសនា រួចចាំយកទឹកទៅ" ទើបទៅកាន់សម្នាក់របស់ពួកអាកាសដ្ឋកទេវតាជាមុន ។ ទេវតាពួកនោះនាំគ្នាមកថ្វាយបង្គំហើយសួរថា "មានកិច្ចអ្វី លោកម្ចាស់!" ហើយនាំគ្នាឈប់ចាំស្ដាប់ ។ សាមណេរប្រាប់ថា សង្គ្រាមរវាងអាត្មានិងស្ដេច បន្នគ-ជាតករាជ នឹងកើតនៅលើខ្នងស្រះអនោតត្ត: អ្នកទាំងឡាយចូរទៅចាំមើលការចាញ់និងឈ្នះក្នុងទីនោះ" ។ សាមណេរនោះ ចូលទៅរកស្ដេចលោកបាលទាំងបួនអង្គ, និងព្រះឥន្ទ, ស្ដេចសុយាម, ស្ដេចសន្តុសិត, ស្ដេចសុនិម្មិត: និងស្ដេចវសវត្តី ហើយប្រាប់សេចក្ដីនោះ ដោយអាការដូចប្រាប់ពួកអាកាសដ្ឋកទេវតាដែរ ។ តពីនោះមក សាមណេរ ទៅដោយលំដាប់ រហូតដល់ព្រហ្មលោក ។ ពួកព្រហ្មថ្វាយបង្គំហើយសួរថា មានរឿងអ្វី? លោកម្ចាស់! ។ សាមណេរប្រាប់រឿងដូចខាងដើម ។ សាមណេរ ត្រាច់ទៅប្រាប់សព្វប្រកល្ហសល់តែអសញ្ញិសត្វនិងអរូបព្រហ្ម ដោយវេលាត្រឹមតែមួយក្ដួតប៉ុណ្ណោះ

ដោយការយ៉ាងនេះ ៗ ពួកទេវតាគ្រប់ជាន់ ស្តាប់ពាក្យរបស់សាម-ណេរ ហើយបានមកប្រជុំគ្នាបង្កៀតណែនតាន់តាប់ក្នុងផ្ទៃអាកាស ត្រង់ខ្ទង់ស្រះអនោតត្ត ហាក់ដូចផង់កម្ទេចនំដែលបុគ្គល ច្រកចូលក្នុងនាឡិ ៗ កាលបើទេវសមាគមប្រជុំព្រមគ្នាហើយ សាមណេរក៏ទៅឈរលើអាកាស និយាយនឹងស្តេចនាគថា៖ សូមស្តាប់ពាក្យរបស់អាត្មាចុះ លោកស្តេចនាគ អ្នកមានតេជះ ឧត្យោស គឺខ្លាំងពូកែ មានកម្លាំងច្រើន! ចូរឲ្យទឹកអាត្មាមួយក្អម, អាត្មាត្រូវការធ្វើជាថ្នាំ ៗ គ្រានោះ ស្តេចនាគឆ្លើយថា នែសាមណេរតូច! បើលោកមានសេចក្តីព្យាយាម, ខ្ញុំពេញចិត្តនឹងពាក្យសម្តីរបស់លោកហើយ អញ្ជើញលោកយកទឹករបស់ខ្ញុំទៅចុះ ៗ

សាមណេរទទួលបញ្ជារបស់ស្តេចនាគគ្រប់បីដងហើយ ឡើងឈរលើអាកាស និម្មិតកាយជាមហាព្រហ្ម កំពស់ ១២ យោជន៍ ចុះអំពីអាកាសមកជាន់ចុះលើពពាររបស់ស្តេចនាគ សង្កត់ឲ្យមុខស្តេចនាគផ្កាប់ចុះក្រោម ៗ គ្រាន់តែសាមណេរចុះជាន់សង្កត់លើពពា របស់ស្តេចនាគក្បាល ផែនពពាបានស្រុតផតលិចចុះក្រោមប្រមាណប៉ុនវែក ដូចបុរសអ្នកមានកម្លាំងខ្លាំងឈរជាន់លើផ្ទាំងស្បែកបត្តប្រស់ទុក ៗ ក្នុងទីមាត់ស្រះ ដែលផុតពីពពាស្តេចនាគ, ខ្សែទឹកប្រមាណប៉ុនដើមត្នោតខ្ពុរបញ្ចេញបាញ់ឡើងទៅលើ ៗ សាមណេរត្រងទឹកបានពេញក្អម ក្នុង

អាកាសនោះឯង ៗ សមាគមនៃទេវតា បានឲ្យសាធុការដល់សាមណេរ គង់រំពង ៗ ស្តេចនាគអៀនខ្មាសផង ក្រោធខឹងនឹងសាមណេរផង ៗ ភ្នែករបស់ស្តេចនាគមានពណ៌ដូចផ្កាចព្យារ ៗ ស្តេចនាគខឹងថា "សាមណេរនេះ ឲ្យទេវតាមកប្រជុំគ្នារួចបានយកទឹកទៅ (ម៉េចក៏មិនយកឲ្យស្ងាត់ៗ) ធ្វើអញឲ្យអាប់មុខ, អញនឹងតាមទៅចាប់សាមណេរឲ្យបានយកមក ហើយលូកដៃទៅក្នុងមាត់ច្របាច់បេះដូងឲ្យបែកខ្ទេចខ្ទី ឬនឹងចាប់ជើងទាំងពីរគ្រវែងចោលទៅត្រើយសមុទ្រខាងនាយឯណោះ" គិតរួច ក៏ស្ទុះដេញតាមសាមណេរយ៉ាងលឿន ៗ សូម្បីស្តេចនាគលឿនយ៉ាងណា ក៏នៅតែមិនទាន់សាមណេរដែរ ៗ សាមណេរមកដល់ហើយ ប្រគេនទឹកទៅព្រះឧបជ្ឈាយ៍ ទូលថា និមន្តឆាន់ចុះព្រះគុណម្ចាស់ ៗ ចំណែកស្តេចនាគមកដល់ក្រោយឃាត់ថា លោកម្ចាស់ អនុរុទ្ធ សាមណេរយកទឹកដែលខ្ញុំមិនបានឲ្យមក លោកម្ចាស់កុំឆាន់ឡើយ ៗ

ព្រះអនុរុទ្ធត្ថេរ— មែនឬទេ ? សាមណេរ ! ៗ

សាមណេរ— និមន្តឆាន់ចុះ ព្រះគុណម្ចាស់ ! ទឹកដែលខ្ញុំយកមក ស្តេចនាគនេះបានឲ្យហើយ ៗ ព្រះថេរៈ បានជ្រាបស្រេចហើយថា "ធម្មតាការនិយាយកុហករបស់សាមណេរជាព្រះខីណាស្រព គ្មានទេ", ទើបឆាន់ទឹកនោះ ៗ អាពាធចុកសៀតឧទរ ក៏ជាបាត់ក្លាយ ៗ ស្តេចនាគទូលព្រះថេរៈទៀតថា លោកម្ចាស់ ! សាមណេរបានប្រជុំទេវតាទាំង

ពួងឲ្យមកមើល ធ្វើខ្ញុំឲ្យអាប់មុខ, ខ្ញុំប្រុងនឹងខ្វេះយកបេះដូងរបស់លោកចេញ ឬនឹងចាប់លោកគ្រវែងទៅត្រើយសមុទ្រខាងនាយឯណោះ ។ ព្រះថេរៈឆ្លើយថា មហាបពិត្រ ! សាមណេរមានអានុភាពច្រើនណាស់, មហាបពិត្រ មិនអាចតតាំងច្បាំងនឹងសាមណេរបានទេ, ចូរសូមខ្មាលាទោសនឹងសាមណេរ ហើយអញ្ជើញស្តេចត្រឡប់ទៅវិញទៅ ។ ស្តេចនាគនោះ សូម្បីដឹងអានុភាពរបស់សាមណេរដោយខ្លួនឯងរួចហើយ ប៉ុន្តែព្រោះសេចក្តីអាប់មុខ បានជាដេញតាមមក ។ គ្រានោះ ស្តេចនាគសូមខ្មាលាទោសនឹងសាមណេរតាមបង្គាប់ព្រះថេរៈ ហើយបានជាមិត្រស្និទ្ធស្នាលនឹងសាមណេរនោះ រួចបណ្តាំទុកថា "តាំងពីថ្ងៃនេះទៅ, កាលបើលោកម្ចាស់ត្រូវការទឹកក្នុងស្រះអនោតត្ត, លោកម្ចាស់មិនបាច់និមន្តទៅព្រះអង្គឯងទេ គ្រាន់តែឲ្យដំណឹងទៅដល់ខ្ញុំៗនឹងនាំយកទឹកមកថ្វាយភ្លាម" ទូលរួចលាត្រឡប់ទៅវិមានវិញ ។ ចំណែកព្រះថេរៈក៏នាំសាម - ណេរចេញពីទីនោះទៅគាល់ព្រះសាស្តា ។

ព្រះបរមសាស្តាទ្រង់ជ្រាបថា "ព្រះថេរៈនឹងចូលមកគាល់ព្រះអង្គ" ក៏គង់ចាំទតមើលដំណើរមករបស់ព្រះថេរៈ នៅក្នុងប្រាសាទរបស់មាតាមិគារសេដ្ឋី ។ ចំណែកពួកភិក្ខុ ឃើញព្រះថេរៈនិមន្តមក បានក្រោកទទួលបាត្រនិងចីវរ ។ ខណៈនោះ ភិក្ខុពួកខ្លះជាបុថុជ្ជន បានចាប់អង្រួនសាមណេរត្រង់ក្បាលខ្លះ ត្រង់ត្រចៀកខ្លះ ត្រង់ដើមដៃខ្លះ ហើយ

សួរថា ម៉េចមិនទាន់ចង់សឹកទេឬ សាមណេរ ។ ព្រះសាស្ដាទ្រង់ទតឃើញកិរិយារបស់ភិក្ខុទាំងនោះ ទ្រង់ព្រះតម្រិះថា កម្មរបស់ភិក្ខុទាំងនេះធ្ងន់ណាស់ ដ្បិតចាប់សាមណេរដូចជាគេចាប់អសិរពិសត្រង់ក, មិនទាន់ដឹងអានុភាពរបស់សាមណេរទេ, ថ្ងៃនេះ តថាគតគួរតែនឹងសម្ដែងសេចក្ដីល្អរបស់សាមណេរឲ្យឃើញច្បាស់ប្រាកដ ។ ព្រះថេរៈនិមន្តមកដល់ ថ្វាយបង្គំព្រះសាស្ដារួចគង់ស្ងៀម ។ ព្រះសាស្ដាទ្រង់ធ្វើបដិសណ្ឋារៈនឹងព្រះថេរៈហើយត្រាស់ហៅព្រះអានន្ទត្ថេរមកប្រាប់ថា អានន្ទ! តថាគតត្រូវការយកទឹកក្នុងស្រះ អនោតត្តមកលាងជើង, អ្នកចូរយកក្អមឲ្យពួកសាមណេរទៅដងទឹកយកមក ។ ព្រះថេរៈ ទើបឲ្យហៅសាមណេរក្នុងព្រះវិហារប្រមាណប្រាំរយរូបចូលមកប្រជុំគ្នា បណ្ដាសាមណេរទាំងនោះ សុមនសាមណេរ ជាអ្នកបួសថ្មីជាងគេបំផុត ។ ព្រះថេរៈប្រាប់សាមណេរដែលមានវស្សាច្រើនជាងគេថា នែសាមណេរ! ព្រះសាស្ដាមានព្រះបំណងនឹងយកទឹកក្នុងស្រះអនោតត្ត, មកលាងព្រះបាទ, អ្នកចូរយកក្អមទៅដងទឹកយកមកថ្វាយ ។

សាមណេរនោះ បដិសេធគឺប្រកែកថា ខ្ញុំមិនអាចនឹងទៅដងទឹកនោះ យកមកបានទេ ។ ព្រះថេរៈបានសួរសាមណេរដទៃទៀតតាមលំដាប់ ។ សូម្បីសាមណេរទាំងនោះ ក៏និយាយបដិសេធដូចគ្នា ។ បើនឹងតាំងជាប្រស្នាឡើងថា ក្នុងទីប្រជុំនោះ សាមណេរជាព្រះខីណាស្រព

តុំមានទេឬ?, ក៏អាចឆ្លើយបានភ្លាមថា មានជាប្រាកដ, ប៉ុន្តែលោកមិនប្រាថ្នានឹងទៅយកទឹកទេ ដោយគិតថា កម្រងផ្កានេះ ព្រះសាស្តាមិនបានទ្រង់ក្រងទុកដើម្បីឲ្យពួកយើងទេ, ទ្រង់ក្រងទុកដើម្បីឲ្យ សុមនសាមណេរ តែមួយអង្គប៉ុណ្ណោះ ។ ទៅទីបំផុត ក៏ដល់វារៈរបស់ សុមនសាមណេរ ។ ព្រះថេរៈប្រាប់ថា នែសាមណេរ! ព្រះសាស្តាមានព្រះបំណងនឹងយកទឹកក្នុងស្រះអនោតត្ត មកលាងព្រះបាទ, អ្នកចូរយកក្អមទៅដងទឹកយកមក ។ សុមនសាមណេរ គិតថា "កាលបើព្រះសាស្តាទ្រង់ប្រើឲ្យទៅយក ក៏ត្រូវតែទៅយកមក" ទើបថ្វាយបង្គំព្រះសាស្តា ហើយទូលសួរថា បានឮថា ព្រះអង្គប្រើឲ្យខ្ញុំព្រះអង្គឲ្យទៅយកទឹកអំពីស្រះអនោតត្តមែនឬ ? ព្រះអង្គ! ។

ព្រះសាស្តាត្រាស់ថា អើ សុមនៈ! មែនហើយ ។

សុមនសាមណេរនោះ យកដៃចាប់ក្អមធំបំណុះទឹក បានដល់ ៦០ ក្អម យកតែក្អមមួយ ក្នុងបណ្តាក្អមដែលដាក់តម្រៀបទុកក្នុងសេនាសនៈ សឹងជាមាសសុទ្ធដែលនាងវិសាខា កសាងទុក គិតថា "អញមិនត្រូវការនឹងលើកក្អមនេះ ដាក់លើស្មាទេ" ទើបយួរក្អមហើយហោះឡើងកាន់វេហាស៍ បែរមុខទៅត្រង់ព្រៃហិមពាន្ត ។ ស្តេចនាគឃើញសាមណេរ កំពុងតែហោះមកអំពីចម្ងាយពីមា ក៏ស្ទុះទៅទទួលយកស្មាលីក្អមនិយាយថា លោកម្ចាស់! កាលបើមានអ្នកបម្រើដូចជាខ្ញុំ

នេះហើយ ម្ដេចក៏ចាំនិមន្ដមកព្រះអង្គឯង, កាលបើមានសេចក្ដីត្រូវការដោយទឹក ម្ដេចក៏មិនផ្ដាំផ្ញើតែដំណឹងមក ?" ហើយយកក្អមដងទឹកលើកឡើងខ្ញុំឯងទូលថា និមន្ដលោកម្ចាស់ទៅខាងមុខមុនចុះ ខ្ញុំនឹងយកទឹកទៅប្រគេនខ្ញុំឯង ។ សាមណេរឆ្លើយថា "មហាបពិត្រ ! សូមព្រះអង្គឈប់សិន កុំស្ដេចជូនទៅ ព្រោះអាត្មាត្រូវព្រះសម្មាសម្ពុទ្ធត្រាស់ប្រើមក" ប្រាប់ឲ្យស្ដេចនាគត្រឡប់ទៅវិញ ហើយយកម្រាមដៃចាប់ ត្រង់កណ្ដាប់មាត់ក្អមយួរមកតាមអាកាស ។

ខណៈនោះ ព្រះសាស្ដា ទតឃើញសាមណេរកំពុងតែហោះមក ត្រាស់ហៅភិក្ខុទាំងឡាយមកប្រាប់ថា ភិក្ខុទាំងឡាយ ! ពួកអ្នកចូរមើលលីលារបស់សាមណេរចុះ ល្អដូចស្ដេចហង្សក្នុងអាកាស ។ ចំណែកសាមណេរដាក់ក្អមទឹកហើយ ថ្វាយបង្គំព្រះសាស្ដា ហើយឈរគាល់ ។ គ្រានោះ ព្រះសាស្ដាត្រាស់សួរសាមណេរថា សុមនៈ ! អ្នកមានអាយុបានប៉ុន្មានឆ្នាំហើយ ? ។

សុមនសាមណេរ- បាន ៧ ឆ្នាំហើយ ព្រះអង្គ !

ព្រះសាស្ដា- សុមនៈ ! បើដូច្នោះ តាំងអំពីថ្ងៃនេះទៅ អ្នកចូរជាភិក្ខុចុះ ដូច្នេះហើយ ទ្រង់ប្រទានទាយជ្ជឧបសម្បទ ។ បានឮថា សាម-ណេរដែលមានអាយុ ៧ ឆ្នាំ បានទទួលឧបសម្បទមានតែពីរអង្គប៉ុណ្ណោះ គឺ សុមនសាមណេរនេះ មួយអង្គ សោបាកសាមណេរ

មួយអង្គទៀត ។ កាលសុមនសាមណេរ នោះឧបសម្បទហើយ យ៉ាងនេះ ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម៌ថា អស្ចារ្យណាស់ អាវុសោ ! អានុភាពរបស់សាមណេរតូចមានដល់ប៉ុណ្ណេះ មុនអំពីពេលនេះ អានុភាពដូច្នោះ ពួកយើងមិនដែលបានឃើញសោះឡើយ ។ ព្រះសាស្តាស្តេចមកដល់ហើយត្រាស់សួរថា "ភិក្ខុទាំងឡាយ ! ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាពីរឿងអ្វី ?" កាលភិក្ខុទាំងនោះក្រាបទូលទ្រង់ជ្រាបហើយ ត្រាស់ថា "ភិក្ខុទាំងឡាយ ! ក្នុងព្រះសាសនារបស់តថាគត សូម្បីជាក្មេងតូច ប៉ុន្តែជាអ្នកប្រតិបត្តិប្រពៃ គង់រមែងបានសម្បត្តិឃើញច្បាស់បែបនេះដូចគ្នា" កាលទ្រង់សម្តែងធម៌ត្រាស់គាថានេះថា ៖

យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

ភិក្ខុណា នៅកម្លោះ ប្រឹងប្រែង ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញុំាងលោកនេះឱ្យភ្លឺស្វាងបាន ដូចព្រះចន្ទដែលរះផុតអំពីពពក ។

ក្នុងទីបំផុតនៃទេសនា ជនជាច្រើននាក់បានសម្រេចមគ្គផល មានសោតាបត្តិផលជាដើម ។

សេចក្តីសង្ខេបក្នុងរឿងសុមនសាមណេរ ៖

ក្នុងអតីតកាល សុមនសេដ្ឋី បានសុំចែកចំណែកផលបុណ្យនៃបិណ្ឌបាតទានអំពី អន្នភារបុរស ហើយបានធ្វើមហាទានជាច្រើនជាតិ

មកទៀត លុះដល់ជាតិជាទីបំផុត បានកើតក្នុងត្រកូលឧបដ្ឋាកនៃព្រះអនុរុទ្ធត្ថេរ, ដល់អាយុ ៧ ខួបបួសជាសាមណេរ, គ្រាន់តែកោរសក់រួចភ្លាមបានសម្រេចព្រះអរហត្តផល ឈ្មោះ សុមនសាមណេរ ។

បានឮថា សាមណេរដែលមានអាយុ ៧ ឆ្នាំ បានទទួលទាយជ្ជ-ឧបសម្បទតែពីរអង្គប៉ុណ្ណោះ គឺ សុមនសាមណេរមួយអង្គ និង សោបាកសាមណេរ មួយអង្គទៀត ដោយព្រះពុទ្ធានុញ្ញាតថា «តាំងពីថ្ងៃនេះទៅ អ្នកចូរជាភិក្ខុចុះ» ហើយទ្រង់ប្រោសប្រទានទាយជ្ជឧបសម្បទ ។

រឿងសុមនសាមណេរ ចប់ ។

| |
|---|
| អ្នកមានឫទ្ធិជាមហាអំណាច<br>មិនអាចផ្ចាញ់អ្នកមានបុណ្យបានទេ |

# ផ្នែកអក្សរសាស្ត្រ

## វចនានុក្រមសំស្រ្កឹត-ខ្មែរ

(ត)

*ព្រះមហា ឆាង-ខាត់ រៀបរៀង*

អភិក្រម ក្រ.វិ. និរន្តរ៍ ។ អភិក្រុគស៍ ដូចគ្នា។

អភីត គុ. ឥតខ្លាច ។ —វតិ ក្រ.វិ. ដោយឥតខ្លាច។

—ចារិន៍ គុ. ដែលចូលទៅឥតភ្លឹក ។

អភីប្សិត គុ. គួររីករាយ ។

អភីប្សិន៍ គុ. ដែលប្រាថ្នា ។ —អភីប្សុ គុ. ដូចគ្នា។

អភីរុ គុ. ឥតខ្លាច ។ —ក គុ. ដូចគ្នា ។ ស្ត្រី ឈ្មោះឈើ ។

អភីឝុ បុំ. បង្ហៀរសេះ ។ កាំពន្លឺ ។ —មន្ត៍ គុ. ដែលភ្លឺ ។ បុំ. ព្រះអាទិត្យ ។

អភិប្ ធាតុ តម្រង់ ប្រាថ្នា ។ អភីប្ស គុ. ដែល

ប្រាជ្ញា ថ្លៃថ្លា ។ នបុំ.បំណង ។ —អភិប្ត

ទេវិតា ស្ត្រី. ទេពតា ដែលខ្លួនកប់អាន (មុនស្លាប់)

—អភិបំត្ប រៀបចំខ្លួននឹងស្លាប់ ។

អភិសាហ បុំ. ពហុ. ឈ្មោះប្រជាជនមួយ ។

អភិបុ មើល អភិគុ ។

អភិបុទ្រោណ គុ. ដែលមិនមាន ភិបុ និងទ្រោណ ។

អភិសារ បុំ. –អភិសារ កិរិយាចូលលុក ។

អភុត្ត គុ. ដែលមិនបរិភោគ ដែលមិនប្រើប្រាស់ ។—វិត្ត

គុ. អ្នកមិនបានស៊ី ។ — បុព្វ គុ. ដែល

មិនបានប្រើប្រាស់ពីកាលមុន ។

អភុជិប្បាត្ត គបុំ. —ភារិ នៃស្ត្រីមិនមែនជាអ្នកបម្រើ ឬ ជាអ្នកនៅ

ក្រោមបង្គាប់ ។

អភុញ្ជន គុ អ្នកមិនបរិភោគអាហារ ។

អភូត គុ. —អភូត ដែលមិនពិត ខុស ។ —ទោស

គុ. ដែលឥតមានកំហុស ។ —បុព្វ គុ.

ដែលមិនមានក្នុងកាលតាំងពីដើម ។

អភូតលស្បើគិតា ស្ត្រី. ភាវៈនៃកិរិយាមិនពាល់ដី ។

អភូត ស្ត្រី. –អភូតិ កិរិយាមិនមានភព, ហាយនភាព ។

អភូមិ ស្ត្រី. –អភូមិ ទីឋានមិនមែនជាភូមិ ។ –ជិ
គុ. ដែលកើតក្នុងភូមិមិនល្អ ។ –៤ គុ ដែល
មិនឲ្យផលដល់ភូមិ ។

អភូយៈសំនិវត្តិ ស្ត្រី. កិរិយាមិនត្រឡប់មកវិញ ។

អភ្បត គុ ដែលមិនឲ្យតម្លៃ ។

អភ្បត្យាត្មនិ គុ. ដែលមិនធ្វើខ្លួនជាអ្នកបម្រើ ។

អភេត្ប ការក អ្នកមិនក្បត់ ។

អភេទ បុំ. កិរិយាមិនបំបែក ។ គុ. ដែលមិនច្បាស់ ។

អភោគ បុំ. –អភោគ កិរិយាមិនរីករាយ ។

អភោគ្យ គុ. ដែលមិនគប្បីយកគ្នា (ប្ដីប្រពន្ធ) ។

អភោជន នបុំ. –អភោជន កិរិយាមិនបរិភោគអាហារ ។

អភោជ្យ គុ. ដែលគប្បីហាក់មិនឲ្យបរិភោគ, ដែលមិនគប្បី
ចិញ្ចឹម ។

អភ្យគ្រ គុ. ថ្មី ។ នបុំ. ទីជិតខាង ។

អភ្យង្គ បុំ. ពិធីលាបប្រេងប្រសិទ្ធិពរ ។ —អញ្ជនបុំ. ថ្នាំបញ្ចាំ ។

អភ្យញ្ជ ធាតុ លាបប្រេង ។ —អភ្យក្ត គុ. ដែលលាប ។

អភ្យញ្ជក គុ ដែលលាបដែលរឹត ។

អភ្យតិក្រម ធាតុ ដើរកន្លង ។

អភ្យតិវត្ត ធាតុ ប្រព្រឹត្តកន្លង ។

អភ្យតី(តិ) ធាតុ កន្លងក្រៃលែង ។

អភ្យធិក គុ. —អភ្យធិក ដែលអធិកក្រៃលែង ។

អភ្យនុជ្ញា ធាតុ អនុញ្ញាត ព្រមឲ្យ អនុញ្ញាត ។

អភ្យនុជ្ញា ស្ត្រី. សេចក្ដីអនុញ្ញាត ។

អភ្យនុប្រេក្ស ធាតុ សួរដំណឹង ។

អភ្យនុមុទ ធាតុ យល់ព្រម ។

អភ្យនុយុជ ធាតុ សួរ, សួរប្រស្នា ។

អភ្យនុវត្តិ ស្ត្រី. កិរិយាស្រឡាញ់ក្រៃលែង ។

(នៅមានទៀត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង្វ-កា ង

ប្រែ-រៀបរៀង

(ត)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន ទាំងមានសន្ដានស្នេហាជាតិ
>
> យូរ-មុន

ជូឡុងឮដូរបោះ ខឹងណាស់ បំផាយសេះកាន់លំពែងចូលច្បាំងនឹង ហ័នតេក, ហ័នអេង ឃើញដូរបោះ ក៏បន្ទ្រះចូលទៅតទឹងជូឡុងជួសបិតា បាន ៣ ភ្លែង ជូឡុងក៏ចាក់នឹងលំពែងត្រូវហ័នអេងធ្លាក់ពីលើសេះស្លាប់, ហ័នអៀវឃើញបងស្លាប់ ខឹងណាស់ បំផាយសេះកាន់ដាវចូលតទឹងជូឡុង យ៉ាងអង់អាច, ហ័នខេងឃើញបងកម្លាំងតិច ខ្លាចដោះការទឹងជូឡុង ក៏ស្ទុះស្ទង់ទៅហៅហ័នគីជាប្អូន ចូលទៅជួយច្រូតគ្នាជា ៣ មុំ, ជូឡុងក៏ពុំញញើតកោតខ្លាច លើកលំពែងសស្លាប ចាក់ត្រូវហ័នគីធ្លាក់ពីលើសេះ, ពាហានស្ទុះទៅជួយប្រះឡុះគ្រាហ៍យកខ្លួនហ័នគី ចូលទៅក្នុងស្រុកបាន, ជូឡុងក៏ដេញទន្ទ្រានតាមទៅ, ហ័នខេងយកធ្នូបាញ់សំដៅជូឡុង៣ព្រួញ, ជូឡុងក៏យកញញលំពែងគ្រវែងពាត់ក្ដាត់ធ្លាក់ទៅវិញបាន, ហ័នខេងខឹងពន់ប្រមាណ បំផាយសេះចូលទៅកាប់ជូឡុង ១ ក៏លើកធ្នូបាញ់ទៅត្រូវ

កំបៀងហ៊ានះខង់ធ្លាក់ពីលើសេះស្លាប់, ហ៊ានអៀវបំផាយសេះប្រញាប់ចូល ទៅត្រង់លើកដាវតម្រង់នឹងកាប់, ជូឡុងគេចក្រឡាប់ឆក់យកដាវ កាវរួប ផាប់ទាំងខ្លួនហ៊ានអៀវ, ទាហានស្ទុះទៀវទៅជួយចង់បាន, ជូឡុង ក៏ចរបំ-ពានចូលទៅក្នុងកងទ័ពហ៊ានគេក ៗ ក៏ភ័យតក្កមា បំផាយសេះចូលទៅចន្ទុំ ក្នុងពួកទាហានហើយថា ជូឡុងនេះ ពុំតែគេនិយាយថាមានថ្វីដៃខ្លាំងពូកែ ណាស់ លុះមកជួបប្រទះ ក៏ឃើញមែនគ្រប់ប្រការ, ហ៊ានគេកនឹករអាខ្លាច ក៏លើកទាហាន ត្រឡប់ចូលទៅក្នុងស្រុកវិញ, ជូឡុងក៏បំបោលសេះតាម ដេញទៅតែឯង, គេងជីនឹកបារម្ភភ័យ ក៏បំផាយសេះតាមទៅទាំង ២ នាក់ ក៏កាប់ត្រូវទាហានហ៊ានគេក ស្លាប់ច្រើនណាស់, ហ៊ានគេក ឃើញជូឡុង ដេញជិតនឹងប៉ះមកដល់ខ្លួន ក៏ភ័យរលះរលាំងស្ទុះលោតចុះពីលើសេះ ដោះ អាវគ្រោះបោះចោលទៅ ហើយទំសំដៅរត់ចូលទ្វារបាន, ទាហានក៏ច្រាន បិទជាប់ទៅវិញ, ឯជូឡុងនិងគេងជីនោះមិញ ក៏នាំទាហានត្រឡប់ទៅ បន្ទាយឯក្នុងហងចេងស៊ន, គេងជីក៏និយាយនឹងជូឡុងថា មិនបង់មៀត ដែលលោកជាជាតិទាហាន មានអាយុដល់ ៧០ ឆ្នាំ ហើយនៅខ្លាំងពូកែ នឹងគេឯណាស្មើគ្មាន, ជូឡុងឆ្លើយប្ដានថា មហាឧបកដអាចមើលងាយ យើង ថាចាស់ជរា បានជាមិនចង់ឲ្យមកធ្វើការ ក្រែងយើងជរាគ្មានកម្លាំង នឹងច្បាំងពុំបានជ័យជម្នះ បើខ្លាយថ្ងោះ នឹងបានសេចក្ដីអាប់យសខ្មាស សត្រូវ, ឯខ្លួនយើងគិតថា ចាស់តែអាយុប៉ុណ្ណោះ, ឯកម្លាំងនឹងថ្វីដៃនោះ

បើឱ្យគស្ទីទីងក្មេងកម្ទោះ ដែលមានវិជ្ជាខ្លាំងពូកែយ៉ាងណា, យើងក៏ឥត ញញើតខ្លាចសោះឡើយ, និយាយហើយជូឡុងក៏តែងសេចក្ដីសំបុត្រ ១ ច្បាប់ ឱ្យចម្រើចងនាំខ្លួនហ័នអៀវទៅជូនខុងបេង ។

ឯហ័នគេកនោះ លុះចូលទៅដល់ ហែហួលិម ក៏យំជម្រាបសេចក្ដីឱ្យស្ដាប់គ្រប់ប្រការ, ហែហួលិមបានស្ដាប់សព្វគ្រប់ ក៏ខឹងណាស់ លើកទាហានចេញពាកស្រុកទៅដល់កំពង់បេងស័ន ក៏ឱ្យបោះទ័ពបញ្ឈប់តាំងបន្ទាយ, ជូឡុងដឹងការ ក៏ជិះសេះកាន់លំពែងចេញមកជាមួយនឹងទាហាន ១.០០០ នាក់ នៅមុខបន្ទាយ ។

ហែហួលិម តែងគ្រឿងពាក់មួកមាស កាន់ដាវវែងចេញមកបញ្ឈរសេះនៅមុខទាហាន, លុះជូឡុងលើកមកដល់ ហែហួលិមក៏បរសេះចូលប្រយុទ្ធគ្នា, ហ័នគេកថា ជូឡុងសម្លាប់កូនខ្ញុំបាត់អស់, ខ្ញុំបាទសុំចេញទៅសងសឹកជាមុនសិន, ហ័នគេក ក៏បំផាយសេះចេញច្បាំងនឹងជូឡុងបាន ៣ ក្បួន, ជូឡុងលើកលំពែងចាក់ត្រូវហ័នគេកធ្លាក់ពីលើសេះស្លាប់, ហែហួលិម ក៏ថយទ័ពត្រឡប់ទៅបន្ទាយចម្ងាយពីទីនោះ៨០ សិន (៣.២០០ ម៉ែត្រ), ជូឡុងនិងគេងជី ក៏នាំទាហានដេញតាមទៅសម្លាប់ទាហានហែហួលិមស្លាប់ជាច្រើន ។

ហែហួលិមនោះ លុះតាំងបន្ទាយមួយមាំមួនហើយ ក៏ប្រឹក្សានឹងទាហានទាំងពួកថា ជូឡុងនេះ យើងគ្រាន់តែឮល្បីដោយសារគេនិយាយ

យូរមកហើយ មិនដែលបានដឹងស្គាល់យល់ប្រទះឥឡូវ, ទើបឃើញមុខច្បាស់ជាមានថ្វីដៃខ្លាំងពូកែមែន ទឹងរកនរណាតស៊ូក៏មិនបាន, យើងនឹងរិះគានយ៉ាងម្តេច ទើបនឹងយកជ័យជម្នះបាន? ទៀប៊ូជាកូនទៀយ៉ុកឆ្លើយថា ដូឡុង ល្អតែថ្វីដៃទេ, ឯគំនិតគិតគូរមិនចេះ, ពេលព្រឹកនេះ សុំឲ្យលោកចាត់ទាហានចេញទៅបង្កប់ទុកនៅសងខាងផ្លូវ រួចសឹមលើកទ័ពធំចេញទៅច្បាំងនឹងដូឡុង ហើយធ្វើជាចាញ់រត់បញ្ឆោតឲ្យដេញ រួចយើងនឹងបញ្ចេញទាហានឲ្យចោមព័ទ្ធចាប់ខ្លួនដូឡុងឲ្យបាន ។

ហែហូលិមយល់ឃើញត្រូវ ទើបប្រើតាំងហ៊ុទិងជីចេកឲ្យនាំទាហានម្នាក់ ៣ ម៉ឺនលើកទៅបង្កប់នៅសងខាងផ្លូវ, លុះវេលាព្រឹក ហែហូលិមក៏ឲ្យទាហានវាយឃ្មោះស្រែកហ៊ោលើកចេញទៅតម្រង់បន្ទាយដូឡុង ១ ទិងគេងជីឃើញដូច្នោះ ក៏ឡើងសេះ លើកទាហានចេញពីបន្ទាយ, គេងជីឃើញទាហានហែហូលិមធ្វើអាការអង់អាច ក៏គិតសង្ស័យ ទើបស្រដីសួរទៅដូឡុងថា កាលពីម្សិលមិញ ទាហានហែហូលិម ចាញ់ប្រៀបរបស់យើងស្លាប់ជាច្រើនណាស់, ហេតុម្តេច ថ្ងៃនេះ ក៏នៅមិនខ្លាចរអាថ្វីដៃនៅលើកទាហានជាច្រើនក្រែមកច្បាំងនឹងយើងទៀត ឬហែហូលិម មានស្ទៀតនឹងប្រើឧបាយបញ្ឆោតយើងទេដឹង? សុំឲ្យលោករំពឹងគិត ពិនិត្យមើលឲ្យយល់ការសិន, ដូឡុងថា ហែហូលិម នៅក្មេងសេចក្តី គិតប្រិះប្រាជ្ញាណាស់, ទឹកដោះនៅមាត់ មិនទាន់ជ្រាតក្លិននៅឡើយផង, កាល

ណាហើយក៏ទឹងបេះគិតធ្វើឧបាយកល ដូចសេចក្ដីយល់របស់អ្នកថានោះ
ទេ, វេលាថ្ងៃនេះ យើងទំងយកជ័យជម្នះឲ្យបាន ហើយយើងត្រូវរះអាន
ព័ទ្ធចាប់ហៃហ្វលិមជាមុន, និយាយហើយ ដូឡុងក៏បរសេះចូលចំបាំងនឹង
ហៃហ្វលិម, ឡស៊ុយ ក្រឡេកឃើញ ក៏បរសេះចូលតស៊ូនឹងដូឡុងបាន
៣ ក្បួន ឡស៊ុយធ្វើជាចាញ់ទាញសេះរត់, ដូឡុងនឹងគេងដីក៏ញាក់សេះ
ដេញតាមទៅ, នាយទាហានឯកហៃហ្វលិម ៨ នាក់ ឃើញដូច្នោះ ក៏
បណ្ដោយឲ្យហៃហ្វលិមរត់ទៅមុន ហើយក៏នាំគ្នាព័ទ្ធបោមកេមដូឡុងនិង
គេងដីឲ្យនៅជាកណ្ដាល រួចហើយនាយទាហានទាំង ៨ នាក់ ក៏ញាក់
សេះរត់ទៅទៀត, ដូឡុង និងគេងដី ក៏បំផាយសេះដេញប្រចៀតហួស
ចូលទៅ, ទទួលឮសម្លេងទាហានភ័យឃោះក្នុងព្រៃជ្រៅ លាន់ទាំង ៤
ទិស, គេងដីភ័យណាស់ ក្រឡេបញាក់សេះទឹងរត់, ដីបេកស្លុះដេញទា-
ហានព័ទ្ធពីម្ខាងខាងស្ដាំដៃ, តាំងហ៊ុស្លុះដេញទាហានពីព្រៃ នៅខាងឆ្វេង
ព័ទ្ធដូឡុងនិងគេងដីនៅជាកណ្ដាល ហើយកយគ្នាចូលទៅនៅជើងភ្នំខាង
ទិសឧត្ដរ, ដូឡុងឃើញសត្រូវស្លុះស្រព័ទ្ធជុំវិញ ក៏ដេញតាមផ្លូវមិនកថយ
មើលទៅខាងក្រោយទិសឯជើងស្ដើងទាហានជាង់គេ, ដូឡុង ក៏បរសេះបំ-
ពារត្រង់ទៅទឹងរកផ្លូវរត់ចេញ, ឯពួកទាហាន ដេញបោមកេមតាមទៅព័ទ្ធ
ជិតចង្អើះក្ដី, ហៃហ្វលិមនាំទាហានទៅពួនខាងលើកំពូល ដេញទាហាន
ទៀតខ្វលឲ្យប្រមៀលដុំថ្មម្នាក់ចុះមក ដូចគេបាចសាច, ដូឡុង ក៏នៅអង់

អាច ដេញតាមសម្លាប់ទាហានហៃហ្លូលិម តាំងពីព្រលឹម ទាល់ព្រលប់ មិនឈប់សោះ ក៏នៅតែប្រកតែបដោះចេញទៅមិនរួច, ដូឡុងហបហត់ ដូចជានឹងរលែះជើងដៃ ក៏លោតចុះពីលើសេះ រេះចូលទៅអង្គុយអែបនឹង ជើងសិលា, ឯតេងជី ក៏ក្លាត់ព្រាត់បាត់ពីគ្នា មិនដឹងរស់ឬស្លាប់, លុះឃើញ ខែរះស្រអាប់ព្រាងៗ, ពួកសត្រូវដែលព័ទ្ធទាំងសងខាង ក៏ដុតភ្លើងក្លៀងឡើង ទាំង ៤ ទិស ហើយបាញ់នឹងធ្នូចម្រុះទៅត្រង់ដូឡុង បីដូចគ្រាប់ភ្លៀង, ហើយស្រែកថា ដូឡុង! អ្នកឯងត្រូវចេញមុខមកកេយើង ១ នឹងទុកជីវិត, ដូឡុងបានឮដូច្នោះ ក៏ខឹងណាស់ ចាប់លំពែងត្រវ៉ែងលើកឡើង ហើយ ឡើងសេះ បាបង្រុះទៅតាមទាហានដែលព័ទ្ធទាំង៤ ទិស, ទាហានទាំង. នោះ ក៏ប្រឹងស្ទុះប្រចៀតប្រៀតគ្នាចូលទៅ, ដូឡុងអស់សេចក្ដីគិត ក៏ងើប មុខឡើងមើលអាកាស ហើយដកដង្ហើមធំថា យើងធ្វើសឹកសង្គ្រាមរៀង មកតាំងពីកំលោះ លុះចំណាស់ប៉ុណ្ណោះហើយ មិនដែលឡើយនឹងចាញ់ អ្នកឯណា, គ្រានេះ យើងនឹងស្លាប់អសារជាប្រាកដ ។

ខណៈនោះ ទទួលខុងបេងឡេតៀវប៉ៅ នាំទាហាន ៥.០០០ លើក តាមដូឡុងមកទន្ទាន់គ្នា, តៀវប៉ៅឃើញទាហានហៃហ្លូលិមព័ទ្ធដូឡុងនៅ ក្នុងចំណោម ហើយឃើញជីចេកចេញមកស្ទាក់ពីមុខជាប់, តៀវប៉ៅក៏បំ· ផាយសេះសន្ទាប់ចាប់លំពែងប្រវែង ៣ ព្យាមពីរហត្ថរបស់បិតា ចូលទៅ ចាក់ជីចេកធ្លាក់ពីលើសេះស្លាប់ ហើយកាត់យកក្បាលចងព្យួរនឹងកសេះ

ពុះខ្មាយហ្វូងទាហាន ទន្ទ្រានចូលដល់ជូឡុងក្នុងចំណោមបាន, ជូឡុង
ឃើញតៀវប៉ៅចូលទៅដល់ ក៏សែនសល់អំណររកអ្វីប្រៀបពុំបាន, តៀវ-
ប៉ៅក៏ប្រាប់ជូឡុងថា មហាឧបកជយល់ឃើញថា មាមានជកភាពណាស់
ក្រែងប៉ះការទិងសត្រូវ ទើបតម្រូវប្រើខ្ញុំបាទឲ្យលើកទាហាន ៥.០០០
មកខ្ទាន់ជាក្រោយ ហើយជូឡុងនិងតៀវប៉ៅ ក៏លើកទាហាន ៥.០០០
ចេញមកពីក្នុងចំណោម បានពារទន្ទ្រានតម្រង់ទៅទិសបស្ចិម ក្រឡេក
ឃើញក្វនហ៊ិនបំផាយសេះសន្ធឹមមកពីចម្ងាយដៃម្ខាងយួរក្បាលមនុស្ស ពុះ
ខ្មាយចូលមកដល់, ក្វនហ៊ិនក៏ជម្រាបជូឡុងថា មហាឧបកជប្រើខ្ញុំបាទ
ឲ្យនាំទាហាន ៥.០០១ លើកមកជួយលោកមា, ទទួលតាំងហ៊ីទាហាន
ហៃហូលិមនៅកំពងកស្ទាក់ពីមុខ, ខ្ញុំបាទក៏បំផាយសេះសម្រុកចូលទៅកាត់
ក្បាលបាននាំមកនេះ, ឯមហាឧបកជនោះ លើកទ័ពតាមមកជាក្រោយ ៗ

ជូឡុង ក៏ឆ្លើយបណ្ដោយថា ដែលក្មួយទាំងពីរបានលើកមកជួយមា
វេលានេះ មាមានអំណរណាស់, បើដូច្នេះ គួរយើងជួយគ្នា ចាប់ខ្លួន
ហៃហូលិមឲ្យបាន ទើបនឹងមានសេចក្ដីគាប់ប្រសើរ, តៀវប៉ៅនិងក្វន
ហ៊ិន បានស្ដាប់ ក៏យល់ព្រមគ្នា ទើបម្នីម្នាលើកទាហានឡើងទៅលើភ្នំ
ដើម្បីនឹងចាប់ហៃហូលិម, ជូឡុង ក៏បំផាយសេះចុះទៅបបួលកងទាហាន
ពានប្រទះនឹងគេងជី ទើបស្ទុះរួចពីក្នុងចំណោមមក, ជូឡុងក៏នាំយកឡើង
ទៅជាមួយគ្នា ហើយជូឡុង ក៏និយាយនឹងគេងជីថា យើងបានធ្វើសឹក

តាំងពីគ្រាព្រះចៅឡើងគង់ព្រះជន្ម, យើងក៏មិនដែលអាប់ចុះថោះការនឹងសត្រូវសោះ, គួរឬ? វេលានេះ មកអាប់យសបង់ ប្រៀបនឹងអាហៃហ្វូ-លិមក្មេងទឹកដោះទៅមាត់, នេះ ហាក់ជាបានតៀវប៉ៅ គួនហ៊ុន លើកទាហានមកជួយស្កាត់ដោះពីចំណោមបាន កុំអីយើងនឹងបង់ប្រាណ អសារឥតការ, ឥឡូវតៀវប៉ៅ គួនហ៊ុន គេនៅប្រាថ្នាលើកតាមហៃហ្វូលិមទៅលើក្តីហើយ, យើងនឹងនៅព្រងើយ មិនទៅជួយឯណាបាន ត្រូវតែគិតអានសងសឹកវិញ កុំឲ្យខ្មាសមុខវា, នោះផូឡុងនិងតេងជីក៏ម្នីម្នាលើកទាហានឡើងតាមទៅ ក្នុងពេលកណ្តាលយប់ជ្រៅនោះ បញ្ចូលទាហានជាមួយគ្នានឹងតៀវប៉ៅ គួនហ៊ុន រួបបំបែកគ្នាជា ៣ កង ចូងតាមផ្លូវឡើងទៅប្រទះនឹងកងទ័ពហៃហ្វូលិម ក៏ចូលប្រកាប់សម្លាប់គ្នាជាច្រួលច្របល់ ។

ហៃហ្វូលិមក៏ទញ់ទាល់ច្រកផ្លូវនឹងដោះ ចេះតែស្ទុះស្ទាទៅវិញទៅមកជាច្រើនសា ទើបនាំទាហានដែលបានការជាស្និទ្ធ ចំនួន ១០០ បាយនាក់ រត់ប្រពួនប្រញាក់ចុះទៅតាមផ្លូវស្រុកលាំអ៊ន, ទាហានហៃហ្វូលិមដែលសំខាន់ ក៏បែកខ្ញែកគ្នាទៅដោយខ្លួន ខ្វះវេះពួនយកឲ្យរួចតែអាយុជីវិត, គួនហ៊ុននិងតៀវប៉ៅ ក៏ស្រួតមិតលើកទាហានតាមហៃហ្វូលិមទៅ, ហៃហ្វូលិម ក៏រត់កាត់ផ្លូវទៅចូលស្រុកបាន ហើយឲ្យទាហានខ្វាស់បិទទ្វារខ្ទប់ បំបែកពួកកងទ័ពឲ្យត្រួតត្រាលើបន្ទាយដោយមាំមួន ។

តៀវប៉ៅ គួនហ៊ុន ក៏លើកទាហានប៉ះព័ទ្ធជុំវិញកំពែងស្រុកចំនួន១០

ថ្ងៃ, ហៃហ្វលិម នៅសម្ងំមិនចេញច្បាំងសោះ, វេលានោះ មានបម្រើចូល មកប្រាប់ថា មហាឧបកជ លើកព្យុហទ័ព កដល់ដែនស្រុកនេះហើយ, ឯស្រុកកៃអៀង, អៀងប៉េង និង ចឺសៀវទាំង ៣ អះទ្ទីរនេះ តាក់ទាហាន ឲ្យទៅត្រួតត្រាក្យា ៗ ដូទ្បឿង, កេងជ័, កៀវប៉ៅ និង កួនហ៊ុន ទាំង ៤ នាក់ បានដំណឹងដូច្នោះ ក៏នាំគ្នាចេញទៅទទួលគំនាប់ហើយជម្រាប សេចក្តីថា យើងខ្ញុំបានលើកទាហានមកព័ទ្ធស្រុកនេះទុកជាយូរថ្ងៃហើយ នឹងកេបទោះបន្ទ្រុះចូលទៅពុំបាន ៗ ខុងបេងបានស្តាប់ ក៏ឡើងជិះរទេះ គួចបរចូលទៅ មើលឃើញភូមិឋានមានទំនង់ស្រួល ហើយឃើញមាន ទាហានឡើងរក្សាសើនបន្ទាយមាំមួន ទើបនិយាយនឹងទាហានទាំងពួង ថា ស្រុកលាំអ៊ននេះ ជាទីមាំមួនណាស់, បើដូច្នេះ យើងនឹងគិតប្រការ ម្តេច ? បើនឹងបង្អង់ទុកយូរថ្ងៃ ក្រែងចូយ៉ឹយនឹងមិនលើកទ័ពកងទៅកយ យកស្រុកហ៊ានតុងបង់ការ, យើងនឹងមិនខូចអសារទេឬ ? ៗ

កេងជីថា ហៃហ្វលិមជាសាច់សាលោហិតនឹងចូយ៉ឹយ, បើនឹងចាប់ ខ្លួនហៃហ្វលិមនិងទាហាន១០០បាន, ចូយ៉ឹយក៏នឹងអស់តម្រិះគិតគង្គំនិត រត់ចុះ ឃើញថា ការយើងដែលធ្វើនោះ នឹងសម្រេចដោយងាយ, ខុងបេង ក៏យល់ឃើញត្រូវ ទើបគិតកលឧបាយឲ្យប្រាប់ទាហានដែល ស្និទ្ធ ២ នាក់ ឲ្យបន្លំធ្វើជាទាហានហៃហ្វលិម កាន់សំបុត្រទៅឲ្យម៉ាជុន ចៅហ្វាយស្រុកតៀនស៊ុយ និងស៊ុយលៀង ចៅហ្វាយស្រុកហ៊ានតេងជា

សេចក្ដីថា ហៃហ្លួលិមឲ្យលើកទាហានមកជួយ, ទាហានទាំងពីរ ក៏លាខុនបេងទៅ ហើយ ខុនបេង ក៏ហៅស៊ុយអៀន និងគួនហ៊ុន គៀវប៉ៅ មកខ្សឹបបង្គាប់ជាសេចក្ដីសម្ងាត់ ឲ្យលើកទាហានតាមទៅ, ខុនបេងនៅជាក្រោយ ឲ្យជញ្ជូនអុសនិងសម្រាម ទៅគរទុកនៅក្បែរកំពែងស្រុក ជាច្រើន ហើយឲ្យយកភ្លើងដុតឆេះឡើង, ពួកអ្នកស្រុកឃើញដូច្នោះ ក៏នាំគ្នាស្មានថា ខុនបេង ចប់ប្រាជ្ញាបេះកលឧបាយ អស់សេចក្ដីគិតហើយ បានជាយកភ្លើងមកលាបកំពែងស្រុកយើង ។

ឯស៊ុយលៀង ចៅហ្វាយស្រុកហ៊ានតេង ដឹងដំណឹងថា ខុនបេង លើកកងទ័ពទៅព័ទ្ធកំពែងស្រុកលាំអ៊ន, ហៃហ្លួលិមនៅក្នុងចំណោម, ទើបប្រឹក្សាយល់ព្រមនឹងនាយទាហានទាំងពួងថា ហៃហ្លួលិម ជាសាច់សាលោហិតគ្រៈចៅប៉ួយ, យើងនឹងបណ្ដោយនៅស្ងៀម ពុំគួរសោះ, ត្រូវតែលើកទាហានទាំងអស់ទៅជួយការពារស្រុកលាំអ៊ន ដើម្បីនឹងរួសរាន់ដោះយកខ្លួនហៃហ្លួលិម បញ្ជូនឡើងទៅស្រុកក្រុង ទើបនឹងរួចទោសខុស, ខណៈនោះ បម្រើចូលទៅជម្រាបថា ហៃហ្លួលិម ឲ្យបម្រើនាំសំបុត្រមកជូន,ស៊ុយលៀង ក៏ឲ្យហៅចូលទៅ, បម្រើក៏ជូនសំបុត្រទៅហើយជម្រាបថា ដ្បិតខុនបេងលើកទ័ពទៅព័ទ្ធស្រុកលាំអ៊នជាមាំមួនណាស់, ហៃហ្លួលិម ទើបរួតរះប្រើខ្ញុំបាទនាំសំបុត្រមកសុំឲ្យលោកលើកទាហានទៅជួយ ព្រោះឯណោះ ជាទុក្ខព្រួយ ដោយតទល់ពុំឈ្នះ, សព្វថ្ងៃ បានឲ្យដុតភ្លើងជា

សម្រាស ដើម្បីឲ្យលោកលើកទៅឃើញជាសម្គាល់, ឯការធ្វើមិនឲ្យស-ត្រូវដឹងស្គាល់ ជាយូរថ្ងៃមកហើយ ហេតុម្តេចឡើយ ក៏លោកមិនលើកទៅជួយ, ទើបប្រើខ្ញុំបាទមកតែខ្លួនមួយដោយប្រថុយរាស្ត្រ, ខ្ញុំបាទក៏ខំកាប់ទ្វារចេញមកបាន ។ ជម្រាបលោក ចៅហ្វាយស្រុកតៀនស៊ុយ ឲ្យលើកទៅជួយផង, បើទៅហើយថា សុំឲ្យគិតតែវាយទ័ពខុងបេងខ្ទប់ប្រសព្វគ្នាហែហួលិមនឹងវាយទម្លាយបំពារចេញមកពីក្នុង ចាប់ខុងបេងឲ្យបាន ។

ស៊ុយលៀងបាន ស្តាប់បម្រើនិយាយ និងមើលតាមសេចក្តីសំបុត្រ ក៏ចូលចិត្តថាមែនឥតសង្ស័យ, ទើបប្រើបម្រើឲ្យរៀសរវៃកាន់សំបុត្រនោះទៅឲ្យចៅហ្វាយស្រុកតៀនស៊ុយ, ទទួលបម្រើខុងបេងទៅដល់ម្នាក់ទៀត ក៏ចូលទៅជម្រាបស៊ុយលៀងថា ឥឡូវ ម៉ាជុន ចៅហ្វាយស្រុកតៀនស៊ុយ លើកទ័ពចេញទៅជួយស្រុកលាំអ័នហើយ, ថា ឲ្យលោកស្រូតលើកតាមទៅឲ្យឆាប់, ស៊ុយលៀង បានស្តាប់ ក៏ប្រញាប់កេណ្ឌកូនទាហានដែលមានថ្មីដៃលើកចេញចាកស្រុកទៅដល់ទៀបស្រុកលាំអ័ន គ្រឡេកឃើញពន្លឺភ្លើងជាសម្គាល់ ក៏ខំស្រូតទ័ពទៅ នៅចម្ងាយប្រមាណ ៣០០ សិន (១២ គីឡូម៉ែត្រ) កួនហ៊ុន ដែលខុងបេងឲ្យទៅចាំស្ទាក់នៅទីនោះ ក៏បំ-ផាយសេះដេញទាហានចូលទៅប្រកាប់នឹងចាប់ស៊ុយលៀង ។ ក័យស៊ុតក៏ញាក់សេះរត់ទៅ, ទទួលគៀវប៉ឺលើកទាហានស្ទាក់ពីមុខចូលមក កាប់សម្លាប់ទាហាន ស៊ុយលៀងបែកខ្ចាត់ខ្ចាយអស់ ស្លាប់នៅទីនោះ ក៏ច្រើន,

ស៊ីយលៀងនិងទាហានដែលសល់ប្រហែល ១០០ ព្រាយ ក៏នាំគ្នារត់ខ្ចាត់ខ្ចាយទៅស្រុកតាមផ្លូវគាត់, ឯអ៊ុយអៀន ដែលខុងបេងប្រើឲ្យទៅចាំស្កាត់ ក៏លើកទ័ពចូលទៅនៅក្នុងស្រុកហានតេងបាន, លុះឃើញស៊ីយលៀងនិងទាហានទាំងប៉ុន្មានរត់ទៅដល់មុខស្រុក, ក៏ឲ្យយកធ្នូបាញ់បង្រ្គះចេញមក ហើយស្រែកថា យើងឈ្មោះអ៊ុយអៀន ចូលស្រុកបានហើយ ឲ្យប្រញាប់ចូលមកអង្វរលន់តួគំនាប់យើងដោយស្រួលចុះ យើងនឹងទុកជីវិត; ស៊ីយលៀង ឃើញដូច្នោះ ក៏ស្លុតព្រលឹង ប្រឹងបំផាយសេះនឹងវេះរត់ទៅស្រុកតៀនស៊ីយ ក៏ប្រទះនឹងខុងបេងជិះរទេះតូច ១ កាន់ផ្លិតរោមសត្វធំ លើកទាហានស្កាត់ផ្លូវចេញមក, ស៊ីយលៀង ក៏បកត្រឡប់សេះរត់គេចទៅម្ខាង, ក្នុងហ៊ុននិងគៀវប៉ៅ ក៏ព័ទ្ធវាងចូលមកពីមុខពីក្រោយ, ស៊ីយ-លៀង ក៏រត់បណ្ដាយវិលវល់ទាល់គំនិតសោះអស់ដៃ លោតចុះពីលើសេះ ផ្ចោះអាវុធចេញ ចូលទៅគំនាប់ខុងបេង, ខុងបេង ក៏នាំយកខ្លួនស៊ីយលៀងមកបន្ទាយ ហើយសួរអំពីចៅហ្វាយស្រុកលាំអ័ននេះថា តាំងពីហៃហ្លួលមិនទាន់បានមកនៅ តើនរណាជាចៅហ្វាយស្រុកនៅមុន? ស៊ីយលៀងឆ្លើយថា ចៅហ្វាយស្រុកមុននោះ ឈ្មោះគៀវឡុង ជាក្លួយគៀវហ៊ូ, ឯខ្ញុំបាទនិងអ្នកទាំងពីរនាក់នោះ ក៏ជាមនុស្សត្រូវអាធ្យាស្រ័យគ្នា, ខុងបេងថា យើងចង់ឲ្យអ្នកឯងចូលទៅនិយាយការគិតគ្នានឹងគៀវឡុង ដើម្បីចាប់យកខ្លួនហៃហ្លួលមកឲ្យយើង ។ នឹងឲ្យបំណាច់រង្វាន់អ្នកឯង

ហើយនឹងតាំងតាំណែងឲ្យអ្នកឯងធ្វើជាធំតទៅ ក្នុងស្រុកលាំអ៊ននេះ, ស៊ុយលៀងក៏ទទួលភាសាខុងបេង ។ ក៏ថយពលយោធាចេញទៅតាំងបន្ទាយនៅឆ្ងាយពីស្រុកនោះ ២០០ សិន ( ៨ គីឡូម៉ែត្រ ) ។

ស៊ុយលៀង ក៏គំនាប់លាខុងបេង ឡើងសេះចេញទៅដល់ទ្វារស្រុកលាំអ៊ន ហើយហៅអ្នកយាមឲ្យបើកទ្វារ, អៀវឡេង ឃើញហើយ ក៏មិម្មា ដោយត្រេកអរណាស់ ហើយហៅទាហានឲ្យបើកទ្វារទទួលស៊ុយ-លៀង ។ ក៏ចូលទៅគំនាប់គ្នាហើយ ស៊ុយលៀងក៏សាស្រាយ និយាយបញ្ចុះបញ្ចូលអៀវឡេង តាមដែលខុងបេងបង្គាប់ ។

អៀវឡេងឆ្លើយថា ព្រះចៅចូយ៉យមានព្រះតេជព្រះគុណនឹងយើងច្រើនណាស់ ដែលនឹងប្រែចិត្តក្បត់តទៅចូលខាងសត្រូវវិញនោះ មិនគួរសោះឡើយ, បើតាមគំនិតខ្ញុំហើយ ត្រូវតែគិតត្រួតកលខុងបេងវិញ ដើម្បីនឹងយកជ័យជម្នះឲ្យបាន, ថាហើយ ក៏នាំស៊ុយលៀងចូលទៅកាន់ហែហ្វូ-លិម នាំពតិមានឲ្យស្តាប់គ្រប់ប្រការ, ហែហ្វូលិមពុំរាថា ក៏ថា បើដូច្នោះយើងនឹងគិតប្រការម្តេចទៅវិញ ទើបនឹងចាប់ខ្លួនខុងបេងបាន ។

អៀវឡេងថា ខ្ញុំបាទចាំបើកទ្វារទទួលចុះ, បើខុងបេងឃើញចំពោះជាប្រកបដូចសេចក្តីគិតហើយ គង់នឹងលើកចូលមកពុំខាន, យើងនឹងលើកទាហានទោមចាប់ឲ្យបានខ្លួនតែម្តង, ហែហ្វូលិមយល់ឃើញត្រូវ, ស៊ុយ-លៀង ក៏លាចេញទៅឲ្យដំណឹងដល់ខុងបេងឯបន្ទាយ និយាយជម្រាបថា

ខ្ញុំបាទបានចូលទៅគិតគូរគ្នានឹងអៀងឡេង ។ ទទួលថានឹងចាប់ខ្លួនហៃហ្វូ-
លិមជូនលោកឲ្យបាន, តែថាទាហានមានតិច ក្រែងធ្វើការមិនសម្រេចដូច
ចិត្ត បានជាឲ្យខ្ញុំបាទចូលមកគិតជម្រាបលោកឲ្យជ្រាបថា ពេលយប់នេះ
នឹងចាំបើកទ្វារទទួលទ័ពខាងលោក ។ ចូរលោកលើកទ័ពប្រញាប់ចូលទៅ
ក្នុងស្រុកចុះ, ខាងណោះ នឹងជួយព្រួតចាប់ខ្លួនហៃហ្វូលិមឲ្យបាន ។

ខុនបេងបានឮសម្ដីចាំងប៉ុនាន ក៏ក្លែងជាថា ការទាំងនេះ មុខជានឹង
សម្រេចសេចក្ដីប្រាថ្នាតាមប្រាថ្នាអ្នកឯងគិតនោះហើយ, ទើបហៅក្លួនហ៊ុន
និងតៀវប៉ៅចូលទៅខ្សឹបប្រាប់តម្រិះបញ្ឆោះជាសម្ងាត់, ហើយចាត់ទាហាន
ឈ្លើយប្រហែល ១០០ ពួយ បញ្ចូលគ្នានឹងទាហានពីកាយទៅខ្លះ ប្រ-
គល់ឲ្យក្លួនហ៊ុននិងតៀវប៉ៅ, លុះដល់ពេលព្រលប់ ក៏បង្គាប់ឲ្យលើកទៅ
ប្រជុំគ្នា, ខុនបេង ក៏ឲ្យហៅស៊ុយលៀងមកផ្ដាំថា អ្នកឯងចូរនាំទាហាន
អម្បាលនេះចូលទៅមុនចុះ ដើម្បីនឹងឲ្យអៀវឡេងនៅខាងណោះរិះគិតធ្វើ
ការឲ្យមួនមាំ គឺត្រូវនាំទាហានទាំងនេះទៅពួនបង្កប់ឲ្យបាត់ ដល់យាម ២
យប់ស្ងាត់ យើងនឹងលើកទ័ពតាមទៅទៀត, អ្នកឯងចាំធ្វៀតដុតភ្លើងឲ្យ
ឆេះឡើងជាសញ្ញា ហើយចាំបើកទ្វារទទួលយើងចុះ ។

ស៊ុយលៀងបានឮដូច្នោះ កាលបើមិនព្រមទទួលការ ក៏ខ្លាចខុន-
បេងចាប់ពិរុទ្ធបាន ទើបប្រមាណនឹកថា បើកាលណាដល់ពេលកំណត់
ហើយ យើងនឹងសម្លាប់ទាហានពួកនេះចេញឲ្យអស់ រួចសឹមបើកទ្វារជា

បន្ទោះឲ្យខុនបេនចូលទៅជាក្រោយ, ស៊ុយលៀនគិតហើយ ក៏គំនាប់លា ខុនបេនចេញទៅ, ខុនបេនក៏ប្រើកូនហ៊ុន និងគៀវប៉ៅ ឲ្យតែងខ្លួនបន្លំជា កូនទាហានស្រុកហ័នតុង ហើយក៏នាំគ្នាលើកចេញទៅ, ឯគៀវឡេងឈរ នៅលើសើនបន្ទាយ គ្រាឡេងឃើញស៊ុយលៀននាំទាហាន ចន្ទ្រានចូល មក ក៏គិតសង្ស័យណាស់ ទើបឲ្យទាហានស្ទុះប្រញាប់ចុះទៅទាញស្ពាន ឆ្លងគូចេញ ហើយស្រែកសួរថា ទាហានទាំងអស់នេះ លើកមកពីណា? ស៊ុយលៀនស្រែកតបថា យើងនាំទាហានស្រុកហ័នតុងមកជួយទេតើ! ហើយក៏យកសំបុត្រចងនឹងចុងព្រួញ បាញ់ចូលទៅ, គៀវឡេង ឃើញ សំបុត្រនោះ ក៏យកមកមើល ឃើញសេចក្ដីថា ខុនបេនឲ្យបញ្ចូលទាហាន គេផ្សំគ្នា១០០ មកជាមួយ ដើម្បីបញ្ចុះបញ្ចូលជួយធ្វើការ, ឯខ្លួនខុនបេន នឹងលើកតាមមកជាក្រោយឥឡូវនេះហើយ, អ្នកកុំបីព្រួយចិត្តគិតឲ្យបែក ការនេះឡើយ, បើខ្ញុំចូលមកដល់ហើយ គង់នឹងដឹងសេចក្ដីច្បាស់ តាម គំនិតដែលគិត ខ្ញុំនឹងនិយាយឲ្យស្ដាប់ ។

គៀវឡេង បានឃើញសេចក្ដីដូច្នោះ ក៏នាំយកសំបុត្រនោះចូលទៅ បង្ហាញ ហែហ្លួម ៗ សប្បាយចិត្តណាស់ សម្គាល់ថា ខុនបេនចាញ់ តម្រិះខ្លួនដែលប្រើឧបាយកល ទើបបាត់ពលទាហានដែលជាទំនុកទុកចិត្ត ១០០ នាយ ព្រមដោយគ្រឿងសស្ត្រាវុធទាំងឡាយគ្រប់ដៃ ឲ្យទៅពួន បង្កប់ចាំ ហើយបង្គាប់គៀវឡេងឲ្យធ្វើតាមបណ្ដាំថា អ្នកឯងចូរបើកទ្វារ

ស្រុកទទួលស៊ុយលៀងឲ្យលើកចូលមកចុះ, យើងនឹងចាប់តាហានអាំង
អម្បាលនោះសម្លាប់ឲ្យអស់ រួចសឹមបើកឲ្យខ្ញុំនបេងចូលមកទៀត, អៀវ-
ឡេងទទួលបង្គាប់ហើយ ក៏ជយប្រញាប់ទៅបើកទ្វារ ហើយស្រែកហៅ
ថា បើតាហានស្រុកហ័នតុង ក៏ឲ្យប្រៀបប្រុងចូលជាប្រញាប់មកចុះ ។

ក្អួនហ៊ុនឮដូច្នោះ ក៏បំផាយសេះស្ទុះចេញទៅមុនស៊ុយលៀង រង់ទៅ
ផុតមុខតាហាន គ្រាឡេងឃើញអៀវឡេងជិះសេះបញ្ឈរ ក៏បរបំពានត្រង់
ចូលទៅផុតទ្វារ យារដាវឡើង កាប់ត្រូវអៀវឡេងធ្លាក់ពីលើសេះស្លាប់.
ស៊ុយលៀងឃើញហើយ ក៏ឡប់វិញ្ញាណហាក់គ្មានព្រលឹងសោះ បំផាយ
សេះស្ទុះចេញទៅហួសទ្វារ បំពារទឹងចូងស្ពានគូក្រៅ, តៀវប៉ៅក៏ស្រែក
សន្ធាប់យ៉ាំងខ្លាំងថា នែអាចោរអន្ធពាល ! អាឯងហ៊ានគិតកលឧបាយនឹង
បញ្ឆោតមហាឧបកដហើយ ម្តេចក៏រេះរត់ពួនទៅឯណា? ក៏យារលំពែង
ឡើងចាក់ត្រូវស៊ុយលៀងធ្លាក់ពីលើសេះស្លាប់ ។

ក្អួនហ៊ុន ក៏ស្ទុះចូលប្រញាប់ទៅដល់កណ្តាលស្រុក គ្រលុកដេញកាប់
តាហាននិងអ្នកស្រុកភ្ញាក់ផ្អើលជ្រួលច្របល់ខ្លាំងណាស់ ហើយយកភ្លើង
ឈូលដុតផ្ទះចេះឡើងជាសម្គាល់ដែលណាត់គ្នា, ខ្ញុំនបេងក៏បរពលយោធា
ចូលស្រុកបានទាំង ៤ ទិសតែកវរណែនណាន់ទាន់ខ្ទាប់ ។

ហែហូលិម ក៏គិតភ័យស្ទើរស្លាប់ ប្រញាប់ឡើងសេះទាំងក្អកក្អាំងពុំ
ជិនខ្លួន ចំបស្រ្បូតទៅប្រពាក់ប្រពួនតម្រង់ទៅទិសឯត្បូង ប្រទះលើហ្វូង

កងទ័ពអង់ហ៊ើងទប់យាំងនៅពីមុខ, អង់ហ៊ើងក៏ស្ទុះគំហុកដេញចូលមក ព័ទ្ធចាប់ខ្លួនហៃហ្វូលិមបាន ហើយខន្រ្ទានស្ទុះទៅចាក់កាប់សម្លាប់រេហ៍ពលហៃហ្វូលិមស្លាប់គរលើគ្នាជាច្រើនណាស់ ។

ឯខុនផែនចូលស្រុកបាន ក៏ប្រកាសឃោសនាបណ្ដាស្ត្រីអ្នកស្រុកទាំងអស់គ្នាថា អ្នកទាំងឡាយកល់គ្នា កុំបីភ័យខ្លាចអ្វីឡើយ, វេលានេះហើយ មហាឧបរាជនឹងគ្រប់គ្រងថែរក្សា បីដូចបិតាមាតាព្យាបាលបុត្រដើម្បីឲ្យបានសេចក្ដីសុខតទៅ, លុះវេលាព្រឹកឡើង អង់ហ៊ើង ក៏ចងនាំខ្លួនហៃហ្វូលិមទៅជូន ខុនផែន ។ បង្គាប់ឲ្យយកខ្លួនហៃហ្វូលិមទៅឃុំទុកក្នុងរោង, វេលានោះតេងជី ក៏សួរខុនផែនថា ស៊ុយលៀងវាគិតកលឧបាយដោយអាថ៌កំបាំងណាស់ ហេតុម្ដេច បានជាមហាឧបរាជជ្រាបដឹងដល់ ? ខុនផែនឆ្លើយថា យើងដឹងយោបល់ជាស៊ុយលៀងល្អៀងចិត្ត មិនមែនជាគំនិតវាត្រង់ ប្រុងនឹងធ្វើរាជការជាមួយនឹងយើងដោយសុចរិតទេ បានជាយើងគិតក្លែងប្រើវាឲ្យចូលមកក្នុងស្រុក ប្រាថ្នានឹងឲ្យហៃហ្វូលិមឆោតទុកគិតត្រូតករដល់យើង, យើងត្រូវត្រូតកលដល់វា ប្រាថ្នាយកជ័យជម្នះវាចុងដៃឲ្យបាន, ពួកនាយទាហានទាំងអស់បានស្ដាប់ ក៏នាំគ្នាចុះគំនាប់ក្រាបសិរសា សរសើរថា មហាឧបរាជមានតម្រិះប្រាជ្ញាវិសេសក្រៃពេកណាស់ នឹងរកនរណាមកផ្ទឹមប៉ះក៏ពុំបាន ។

ខុនផែននិយាយការថា វេលានេះ ស្រុកលាំអ័ន យើងក៏ជិះជាន់បាន

ស្រេចហើយ នៅឡើយតែទាហានដែលយើងប្រើកាន់សំបុត្រទៅស្រុកគៀនស៊ុយនោះ ម្ដេចក៏មិនឃើញត្រឡប់មកសោះ តើនឹងជាគ្រោះថ្នាក់យ៉ាងណាទៅដឹងហើយ ? គួរហើយនឹងធ្វើសំបុត្រទៅសួរ ឬលើកកងទ័ពទៅវាយយកស្រុកគៀនស៊ុយតែម្ដងទៅចុះ, ថាតែប៉ុណ្ណោះ ក៏ចាត់ឲ្យឡៅតាយនៅរក្សាស្រុកលាំអ័ន, ចាត់អ៊ុយអៀនជាមេកងកំណាន់ទ័ពស្រួចរួចក៏លើកចេញទៅ, ខុងបេង ក៏លើកតាមទៅជាក្រោយដោយលំដាប់ ។

ចប់ទី ៧១ ។

# អំពីសត្វចិញ្ចឹម

## លក្ខណៈ ក្រយៅគោ - ក្រចក - អណ្តាត - ធ្មេញ - អំពីជម្ងឺសា

និង

## រឿងព្រេងទាក់ទងនឹងសត្វគោ

សហជីវិន **ចាប-រិត** គ្រូបង្រៀននៅសាលាបឹងខ្យាង

ស្រុកកណ្តាលស្ទឹង (កណ្តាល) រៀបរៀង

## អំពីសត្វចិញ្ចឹម

នៅក្នុងប្រទេសខ្មែរ មានសត្វចិញ្ចឹមច្រើនប្រភេទណាស់ មិនអាចពណ៌នាឲ្យសព្វគ្រប់បាន ក្នុងទីនេះ នឹងលើកយកតែសត្វគោមកនិយាយដូចតទៅ ៖

គោជាសត្វពាហនៈ គេចិញ្ចឹមសម្រាប់យកសាច់ និងដឹកនាំកស្តារ ឬភ្ជួររាស់ជាដើម អ្នកស្រុកចិញ្ចឹមគោ·ឈ្មោល·ញី គេរើសលក្ខណៈដូចតទៅនេះ ៖

១– មេគោ គេរើសមេគោណា មានសម្បុកពោះ (ពោះធ្លាក់) ក្បាលទ្ធើម ចាស់ៗថាគ្រោយកូន ។

២– គោឈ្មោល ( ថ ) គេរើសឆ្អឹងរឹ, មាឌធំ, ខ្ពស់, ពោះបីប្អា:នោះជាពូជកូនគាត់ឬក៏ជាបុរសម្នា ។

លុះបានកូនមក កូននោះ មានពុកកាត់ទៅបាខ្លះ ទៅមេខ្លះ ។ មេគោមានផ្ទៃពោះ (ជើម) មានចំនួន ៩-១០ ខែ កាលបើជិតគ្រប់ខែហើយ ម្ចាស់គោគេមិនថ្នាក់ថ្នមទេ គេប្រើដឹកនាំឬបំពោល ឲ្យទៀយហត់ ដើម្បីឲ្យលូនពោះ ងាយនឹងកើតកូន ។

អំពីគោបំពាក់មខ្លួនឯងក្ដី ទើបនឹងទិញមកប៉ុក្ដី ៖ ត្រូវមានលក្ខណៈ សម្បុរក្រយៅ-ស្នែង-មាឌ-ដូចតទៅនេះ ៖

១–ពាក្យស្លោកថា ក្រយៅបីស្នែង ចូលព្រៃភ្លើង ប្រពន្ធផិត ។

២–ក្រយៅបីស្នែង របស់ចូលឯង ធ្លាប់អីមិនរក ។

## អំពីក្រយៅ

១– កន្ទុយសក្នុង ក្រៅខ្មៅ "ហៅកាយខ្វាត់" (អាក្រក់) ។

២– កន្ទុយខ្មៅក្នុង សក្រៅ "ហៅស្រោមនាង" (ល្អ)

៣– ទុលអង្គត ។

៤– ហិតសំពុយ ។

៥– ដាក់លេញ (ទាំង ៣ នេះ) លោកថា អាក្រក់ ។

៦– ប្ដោលពោរ : ក្រយៅ លើគល់កន្ទុយ (អាក្រក់) ។

៧– ទ្រនំទន្លេប : ក្រយៅកណ្ដាលខ្នង (ល្អ) ។

៨– ក្រយៅក្រឡាចំ : (នៅលើស្មាចំ) (អាក្រក់) ។

៩– កំពូលប្រាសាទ : (នៅលើបូកចំ) (ល្អ) ។

១០– ក្អែនព្រះ ក្រយៅ នៅមុខផ្ទះក្រាន អមសងខាង ចង ក្រោមផ្ទះពុំបាន ។ បើមានតែមួយហៅថា "បត់ជុំ" ទៅវិញ (ល្អ) ។

១១– អកចាប់ : ក្រយៅអមស្មាសងខាង (អាក្រក់) ។ តែបើមានម្ខាងទេហៅថា "នាងផ្អែក" (ល្អ) ។

១២– ស្រទឹម : ក្រយៅចន្លោះកែក (ល្អ) ។

១៣– គមឃ្នាង : ក្រយៅអមកសងខាង ។

១ – រងឹទឹម ឬ ក្របួចកន្ទុះ : ក្រយៅនៅលើក ។

១៥– ឈ្នាន់ឡើង : ក្រយៅឃៀកសងខាង ។

១៦– អមសំពៅ : ក្រយៅពោះតាំងសងខាង ។

១៧– សៀតថ្កា : ក្រយៅគល់ត្រចៀកសងខាង ។

១៨– កំរទុក : ក្រយៅគល់កន្ទុយសងខាង ។

១៩– ក្រយៅកំណើត : ក្រយៅកណ្ដាលក្បាល ។

២០– ហិតសំពុយ : ក្រយៅចុងច្រមុះ (មិនល្អ) ។

២១ ក្រយៅបង្រ្គុះ : ក្រយៅកណ្ដាលខ្នង ចំលិន ។

២២– ចង្កូតថ្ពាល : លើខ្នងគ្មានក្រយៅ ។

២៣– ដំណើរកែវ : ក្រយៅជើងមុខ ក្រោមដង្កត់ពីខាងក្រោយ (ល្អ)

៦៤- ពាក់លាញ : ក្រយៅជើងក្រោយក្រោមជន្ទន់ពីខាងក្រោយ (មិនល្អ) ។

៦៥– ផើលាមក : ក្រយៅក្រោមគ្គិតអាចម៍ (មិនល្អ) ។

៦៦– រំសាយសក់ : ក្រយៅក្រោយប្រទូលក្បាល ។

លក្ខណៈក្រយៅ ដូចពោលមកខាងលើនេះ មានល្អ មានអាក្រក់ ទីងមិនល្អ មិនអាក្រក់ (មធ្យម) ចំពោះក្រយៅណាល្អ ទីងអាក្រក់មានជាក់សេចក្ដីជាសម្គាល់ហើយ ។ ឯមិនល្អមិនអាក្រក់ (មធ្យម) គ្មានជាក់សេចក្ដីជាអ្វីទេ ។

អំពីសម្បុរចោរមិនហ៊ានលួច : គោណាសម្បុរខ្មៅក្ដី ចម្ប៉ាក្ដី ក្រហមក្ដី ហើយមានពពាល ដូចជាទីរ-ពងខ្ទង-លោង-ត្រគាក-ក-មុខ-ពព្រិកពព្រាក់ គោបែបនេះ ចោរមិនហ៊ានលួចទេ បើចោរណាហ៊ានលួច ចោរនោះត្រូវអស់លក្ខណ៍ ។

អំពីស្នែង : ត្រូវរើសស្នែងប្រក់ខាត គឺស្នែងទាំងពីរ ឈរ-វង្វង់ចូល-ចូវកុំយកស្នែងកែក គឺស្នែងមួយចង្អុលដី- ស្នែងម្ខាងចង្អុលទៅលើ ។ ស្នែងបែបនេះ ចាស់ៗលោកថា គោខូច គាប សមនឹងភាសិតបុរាណថា : «គោស្នែងកែក មនុស្សស្រពៀងភ្នែក កុំយកខ្លួនបៀត» (ចៅជ្រៃ) ។ បើមនុស្សណាមុខវែង ដូចមុខគោ ក៏គេថា ខូច-គាប-ដែរ ដូចភាសិតថា "មែមនុស្សមុខគោ កក្កុកក្រក សម្ដេងស្អកៗ ក្អួត

វកវី" ពាក្យស្លោកមួយទៀតថា "ពុតសិស្សគ្រូបី ពុតស្រីប្ដីលែង ពុតគោជ្រលែង ពុតខ្មែរបន់ម្ចាស់" ។

ពន្យល់: ពាក្យជ្រលែង គឺម្ចាស់បង្អាក់ បង្ខំកមិនបាន លែងចោល ។

អំពីគោទៀងក ឬ គោខ្មៅ: បុរាណច្រើនយកជាដង្វាយគ្រូរៀនមន្ត-អាគម ផ្សេង ៗ ឬក៏មានឈឺធ្ងន់ៗ បន់ថ្វាយខ្មោចឬអ្នកតា គេច្រើនយកគោខ្មៅឬគោទៀងកទៅថ្វាយ ។ សូន្យជាប់ជាទំនៀមថា "ក៏យថ្វាយគោ សេដ្ឋំរោថ្វាយមាន់" ។

## លក្ខណៈក្របក អណ្ដាត ធ្មេញ:

បើកាលណាឧតក្របកជើងមួយក្ដី ពាលកជើងមួយក្ដី ចាស់ៗថា "ចង្រៃ" ។ "បើឧតក្របកជើងទាំង ៤ ក្ដី ឬពាលកជើងទាំង ៤ ក្ដី មិនជាអ្វីទេ" ។

អណ្ដាត: មុននឹងទិញគោ អ្នកទិញគេចាប់មាត់គោហែកមើលអណ្ដាត បើឃើញពណ៌សឬពណ៌ក្រហម លោកថាអណ្ដាតពាំភ្លើង "ចង្រៃ" ។

អំពីធ្មេញ: ត្រូវពិនិត្យមើលធ្មេញទៀត បើឃើញធ្មេញមុខមាន ៨ គេចាត់ថាគោនោះមានលក្ខណៈត្រឹមត្រូវ ។ បើឃើញធ្មេញ ៧ ចុះមកឬក៏ធ្មេញ ៩ ឡើងទៅលើ លោកចាត់ថាគោនោះគ្មានលក្ខណៈត្រឹមត្រូវ (ចង្រៃ) ។

អំពីបង្ហាត់ឱ្យស្គាល់ភាសាមនុស្សនឹងពង្រាប.—

គេទើបនឹងទិញមកថ្មីក្តី គេកូនក្រោល បង្គោលស្នឹងក្តី ត្រូវប្រកប ដោយលក្ខណៈ ក្រយៅសម្បុរ-ស្នែង-ធ្មេញ-អណ្តាត ដូចពោលរួចមក ហើយ ។ ទើបបង្ហាត់វាឲ្យចេះស្តាប់-ស្គាល់-ដូចពាក្យ "រហូ" ឈប់ "ហ៊ី" ទៅ ។ ឲ្យស្គាល់ស្តាំ-ឆ្វេង-ដើរតន្ទង-ដើរសា ។ "ជិត១" មក ជិតម្ចាស់ ។ វិល១ ឲ្យគេត្រឡប់ទៅខាង ដែលខ្លួនមិនចង់ឲ្យទៅ១ "ជើង ១!!" ឲ្យលើកជើង ។

ជាពិសេសគឺឲ្យវាស្គាល់ចាំឈ្មោះវាដូចជាគេហៅថា៖ អាពាល-អា-ត្នោតអាចម្យ៉ា-អាពពកសោត អាក្រឡាញ់ ១ល១ ជាដើម បន្ទាប់មកគេយកគោនោះទៅពង្រាបឲ្យចេះអូសនាស់-ទន្ទឹល-រទេះ ឲ្យស្គាល់ថាៈឆ្វេង ស្តាំ-ម្ចាស់ញាក់ខ្សែខាងនេះ ត្រូវមកខាងនេះ ។ ឲ្យស្គាល់តន្ទង-ដើរសា បត់-បែនពិតប្រាកដទើបបង្ហាត់ទឹមឲ្យថ្នឹក សាំលែងឆ្អើលលែងបោល-លែង លុតក្រាប ឬកៀចដេក ១ល១

ម្យ៉ាងទៀត គោបង្ហាត់មិនបាន ចេះតែលុតក្រាបឬដេក អ្នកបង្ហាត់ គេស្គាល់ក្រយៅខូច គេយកជន្ទញចាក់ចំក្រយៅខូច គោក៏ស្ទុះឡើង ដើរជម្ទា ។

ម្យ៉ាងទៀត គោណាប៉ុនទាញខ្សែ-កន្ទុះ ដាច់ញឹកញាប់ ចាស់ៗ ថាមកពីមានក្រយៅមួយ ហៅថា "ហ៊ិតហ៊ុយ" ស្ថិតនៅចុងច្រមុះ

បានជាគោប៉ុនតាញណាស់ ។

អ្នកស្រាជ . បានតែងកាព្យមួយឈ្មោះ " គាថ័ន្ទស៊ីន " ។ ប្រៀបទៅនឹងគោដែលគេចងនៅនឹងស្ទឹងមួយវិលចុះ . ឡើង ប្រពាក់ផ្លាក់ខ្សែនៅតែកន្លែងមួយ ។ ចាស់ៗប្រដៅក្មេងឲ្យចេះគិតគូរ ធ្វើអំពើណា ដែលមានប្រយោជន៍ ដុំកំភួន-កុំធ្វើការឥតប្រយោជន៍ លោកប្រៀបទៅនឹងគោថា "រទេះបាក់មិនគិត ទៅគិតឯគោលួចដាំង ។

បញ្ជាក់: " គោលួចដាំង " គឺគោបញ្ញោញអង្គជាតិ ។

អំពីកន្លែងចងគោ.– គេធ្វើក្រោលឃ្នង សង់ជាកេង នៅក្បែរផ្ទះប្រលច្ងាយពីផ្ទះក៏មាន ទីកន្លែងនៅ ត្រូវសំអាតជានិច្ច កុំឲ្យមានអាចម៍ប្លុកទឹកនោម ។

អំពីការថែទាំឱ្យស៊ីស្មៅ.– ការឲ្យស៊ីស្មៅត្រូវឲ្យឆ្អែតស្កប់ស្កល់ជានិច្ច ទើបគោមានកម្លាំងធ្វើការ ចៀសវាងតែស្មៅខ្ចី ត្រកួននិងបណ្ដាលទៅពកគរូស (ចុះសាច់) ។

របៀបឱ្យស៊ីគ្មានទោស.– គឺស្មៅ ៦ ភាគ ស្លឹកឈើផ្សេងៗ ១ ភាគ ចំបើង១ភាគ គោនឹងធាប់ធំធាត់ហើយគ្មានជម្ងឺផង ។

អំពីការថែទាំមុននឹងឈឺ ; ១– ម្ចាស់ត្រូវថែទាំជម្ងឺផ្សេងៗ ។ ២– ការពារឲ្យធាប់ធំធាត់ឲ្យជ្រុះរោមចាស់-ដុះរោមថ្មីឡើងវិញ ។

ថ្នាំឃកមកការពារនោះគឺ ១ ទឹកនោមមនុស្ស ២–រំលុំបណ្ដាល

ពេជ្រ ៣– ផ្លែក្រូចសើច ៤– ល័ក្តស្រម៉ ៥– ចំណាំងស្បែង យកមកពុះ-ចិញ្ច្រាំ ត្រាំនៅក្នុងក្រឡ សម្រាប់នោមដាក់រាល់ៗថ្ងៃ ។

ពិធីប្រើក : គេយកឫស្សីប្រ៊ុនកដៃប្រវែង ១ គក់ មានប្រហោងក្នុងផងមកកាប់បញ្ចិតចិតចៀវឲ្យស្អាត រួចដាក់ទឹកនោមទៅក្នុងបំពង់ បន្ទាប់មកគេចាប់គន្ទុះគោផ្ងើយទៅលើ រួចសិកបំពង់តាមមាត់ ទឹកនោមក៏ហូរចូលទៅក្នុងពោះគោទៅ ការប្រើកនេះ ត្រូវធ្វើរាល់ព្រឹក-ល្ងាច ឥតកំណត់ពេលឈប់ឡើយ លុះត្រាតែគោធាត់ស្រួលខ្លួន ហើយទើបឈប់ ។

អំពីគោកើតដំបៅ : បើគោកើតដំបៅនៅត្រង់សាច់ណាមួយ ត្រូវការពារកុំឲ្យដង្កូវរុយពង កម្រនឹងមើលជាណាស់ ។

បើបានជាដង្កូវរុយពង ដាក់ហួសទៅហើយ ត្រូវយកថ្នាំទម្លាក់ដង្កូវសិនសឹមមើលជាខាងក្រោយ ថ្នាំទម្លាក់ដង្កូវនោះគឺយកសាប៊ូខៀវក៏បាន យកទឹកថ្នាំជក់ទៅដាក់ចំលើពីមុខដំបៅក៏បាន ។

ពិធីផ្សះដំបៅ : យកទឹកសម្ងួប ឬ ផ្សម មកដាក់ចំមុខដំបៅ ៤-៥ដង មុខដំបៅនឹងសះជាពុំខាន ។ បើមិនសះទេត្រូវយកដើមធ្វៃស្រែងមកចិតចំណិតតូចៗ ដុតយកផ្សែងបង្ហុយតាមបំពង់ឫស្សីវែងប្រវែង២-៣ហត្ថ ដាក់ឲ្យចំមុខដំបៅក៏បាន ដំបៅនេះត្រូវបង្ហុយព្រឹកល្ងាចរៀងរាល់ថ្ងៃ ដំបៅមុខជានឹងសះពុំខាន ។

សូមបញ្ជាក់ថា: មុននឹងបន្ហុយផ្សែង សូមយកសំបកកណ្ដាល ឬទទឹងសំបកស្វាយព្រៃ មកដាំឲ្យពុះ ទុកឲ្យត្រជាក់ឧណ្ហៗ យកទឹកនេះទៅលាងមុខដំបៅឲ្យស្អាត ដើម្បីឲ្យអស់ខ្ទល់-ខ្ទុះ-អេល ទើបបន្ហុយផ្សែងជាខាងក្រោយ ។ ធម្មតាគោ តែមានដំបៅបេះតែលិទ្ធ ឬត្រដុះមុខដំបៅនឹងគល់ឈើ លុះរលួយអស់ ដូច្នេះត្រូវចងបុស្សី ឧទាហរណ៍ បើដំបៅខាងឆ្វេង ចងបុស្សីពីខាងស្ដាំប្រវែងខ្ទួនវា ដើម្បីកុំឲ្យវាលិទ្ធបាន គឺចុងបុស្សីម្ខាងភ្ជាប់នឹងកន្ទុះ ចុងម្ខាងចងភ្ជាប់នឹងពោះ ។

ម្យ៉ាងទៀត គោច្រើនអេល ទ្រមខ្សោយបន្តិចក្នុងពេលមានដំបៅ សមនឹងពាក្យស្លោកបុរាណថា "គោដំបៅខ្នង ក្អែកហើររំលង រំសាយកន្ទុយ" ។

អំពីថ្លោះឬគ្រេច: បើគោថ្លោះឬគ្រេច ត្រូវយកប្រផេញញី-ឈ្មោល ១ គ្រលែងវែក ១ ពងមាន់ ១, ដីដំបូក ១, មកបុកលាយគ្នា រួចយកបន្ទោះឫស្សីតូចៗ វែងជាព្រួលប្រវែងតែត្រង់កន្លែងឈឺ រួចយកកំណាត់ដាក់ថ្នាំពីលើ យកទៅរុំភ្ជាប់នឹងជើងថ្លោះ ទើបគេយកព្រួលរុំពីលើថ្នាំតទៅទៀត រឹតរុំត្រូវប្រយ័ត្នកុំឲ្យត្រូវទឹក ហើយត្រូវរុំអស់រយៈ ២-៣ ថ្ងៃ ទើបប្រាយម្ដង ។

អំពីជម្ងឺសា: បើគោឈឺ ច្រើនឈឺពេកម្យ៉ាងហៅថា "សា" បើមនុស្ស. វិញគេហៅថា "ខ្យល់" ។

ជម្ងឺសាគោ មានច្រើនយ៉ាងណាស់គឺ : សាទឹក សាភ្លើង ល។

សាទឹក : ចាប់ឈឺធ្វើឲ្យជ្រប់លែងស៊ីស្មៅ ហើយពោះ ។ល។

សាភ្លើង : ធ្វើឲ្យប្រកាច់ក្តៅអន្ទះអន្ទែង ធាក់-ដល់-វ៉ៃមនុស្ស-ពកអាចម៍-សំកុក . . . ។ល។

ពិធីការពារ : កាលបើដឹងថា កើតជម្ងឺសាហើយ ម្ចាស់គោត្រូវទៅអញ្ជើញគ្រូស្តោះសាឲ្យមកពិនិត្យ និងស្តោះផ្លុំ ដោយពិធីសូត្រគាថាដូច្នេះ : "ឧមៈប្រសិទ្ធិស្វស្តិ អញ្ជើញដំមានពារពេលាយាត្រា ព្រះបារមីសូរ អ្នកបន្ទូលប្រើអញស្តោះសាទឹក-សាភ្លើង សាបំបើង សាហើម សាហល់ សាប៉ុក សាទល់ សាអង្គុយ សាមួលខ្លួន ទើបគ្រូប្រើអញស្តោះពីដើមក្របក គ្របកក្អែក ចង្អែកដើមដោះ ចន្ទោះ ទងសួត កុំបីពង់វែត កុំបីពង់វួត លើព្រះមន្តគ្រូអញ ឧមៈសិទ្ធិស្វាហាៈ បរណាចេញទៅ" ។

គាថាបោសគំពេលគោ : "ទេវិ តុទ្ធោ សុហាតុទ្ធោ (៣ចប់) (ពីរឿងជម្ងឺសាទឹងបាលីស្តោះ សាបោសគំពេលគោ បានដំងពីព្រះភិក្ខុ ឈឹម វត្តវិហារបិទមាស) ។

អំពីជំនឿផ្សេងៗ ដែលជាប់ទាក់ទងនឹងសត្វគោ : ចាស់ៗជំនាន់ដើម មានជំនឿថា គោឈឺថ្កាត់ផ្សេងៗ មកពីខុសទិសប្រេញគង្វាល (ព្រោះនៅផ្ទះទីមួយៗ ប្រុងតែមានប្រេញគង្វាលនៅចាំថែរក្សាគោជានិច្ច

កាល ១- ថែរក្សាកុំឲ្យមានជម្ងឺ ២- ថែរក្សាកុំឲ្យចោរលួច ។

ព្រោះហេតុនោះហើយ បានជាគេឃើញមានធ្វើប្រមអំពីឬស្សីវែង វល្លិ៍សម្រាប់ទ្រស្លាធំរជួន១ បំពង់ទឹក១ រំពាត់ ១ ជោគធូប២-៣សរសៃ ព្រមសម្ងន់ចំណីខ្ចប់ជាកញ្ចប់តូចៗ ដាក់លើស្លាធំរជួនំនោះ (ប៉ុន្តែគ្មានស្លាដមទេ) សម្រាប់លើកថ្វាយដល់ម្រេញគង្វាលរៀងរាល់ថ្ងៃសីលទឹងពេញបូណ៌មី ។ល។ បើបានធ្វើដូច្នេះហើយ សត្វទាំងឡាយមុខតែបានសេចក្ដីសុខ-ចម្រើនគ្រប់ៗគ្នា ។ បើថែជាមិនបានធ្វើដូចពោលមកខាងលើទេ សត្វទាំងឡាយនៅក្នុងផ្ទះ ច្រើនឈឺ-ប្លាត់គ្រោះថ្នាក់-ថោះ-ធ្លាយជាមិនខាន ។

អ្នកជឿពិតប្រាកដ ព្រមទាំងធ្វើវណ្ដាប់វណ្ដាបូជា ម្រេញគង្វាល ដូចនិយាយរួចមកហើយរមែងឃើញផ្លែកស្រស់ ។ ដូចតាម្នាក់ឈ្មោះពៅ អាយុ ៨០ ឆ្នាំ នៅភូមិអំពៅព្រៃ គាត់ជាអ្នកចិញ្ចឹមគោឈ្មោល-ញីមួយហ្វូងធំ គាត់សង់រោងមួយទទឹង ៧ម .បណ្ដោយ ១០ម. ប្រក់ស្លឹកសម្រាប់ធ្វើជាក្រោលគោ រាល់ៗថ្ងៃសីល ទឹងថ្ងៃពេញបូណ៌មី គាត់រៀបចំប្រម-ស្លាធំរជួន-ទំ-ចំណី ថ្វាយដល់ម្រេញគង្វាល ដើម្បីឲ្យជួយថែរក្សាគោគាត់ ។

ថ្ងៃមួយនៅវេលាយប់ស្ងាត់ គាត់ដេកមួយស្របក់ នៅលើខ្ទមមួយក្បែរក្រោលគោ លុះភ្ញាក់ឡើងគាត់ខ្មោមាត់ បៀកស្លាបរកោត ស្រាប់តែ

ពោលក្អែកទៅ ឃើញមនុស្សម្នាក់ មាឌធំ ខ្មៅ-ខ្ពស់-សក់ក្រញាញ់ ខុសពីមនុស្សធម្មតា មានស្ពាយបាយសំណុំ ទឹក ១ បំពង់ រំពាត់ ១ ដើរក្បែរក្រោលគោ ៗ ក៏ផ្អើលឈូឆរនៅក្នុងក្រោល មួយសន្ទុះមកទៀតមនុស្សក៏ស្រាប់តែបាត់ទោះ ឹង មិនដឹងជាទៅទីណា ។ មួយសន្ទុះមកទៀត តាពៅដើរមើលសម្រាស់ឫស្សីព័ទ្ធជុំវិញក្រោលគោ នឹងទ្វារច្រកចេញចូល ពុំឃើញរបើកបន្តិចសោះ ។

ក្នុងរឿងនេះ តាពៅនឹកឆ្ងល់ក្នុងចិត្តណាស់ របងក្តី ច្រកចេញចូលក្តី គ្មានរបើក-មនុស្សចូលមកនោះ មាឌធំ ខ្ពស់-ខ្មៅ ប្លែកពីធម្មតា ម៉្លោះហើយគាត់សម្រេចចិត្តថា "ច្បាស់ជាម្រេញគង្វាលហើយ" ។

បន្ទាប់មកទៀត តាពៅយកធូប ៣ សរសៃ អុជបន់ស្រន់អង្វរម្រេញគង្វាល ច្រើនប្រការណាស់ ។ តាំងពីថ្ងៃនោះមក តាពៅប្រគល់កាយថ្វាយខ្លួនលើ "ម្រេញគង្វាល" ឥតឆាករេ គាត់ចាប់ធ្វើស្នាជរដូងខ្ចី ១ ប្រមា ១ រំពាត់ ១ បំពង់ទឹក ១ យ៉ាងថ្មី ៗ សម្រាប់បូជាម្រេញគង្វាលម្តងទៀត ។ តាំងពីពេលនោះមក តាពៅលែងព្រួយនឹងជម្ងឺនឹងចោរលួចគោឡើយ ។

មួយទៀត ចាស់ៗថា បើនៅពេលកំពុងភ្ជួររាស់ក្នុងស្រែ គោនោះមានគ្រោះថ្នាក់ ដូចជាប្រកាច់ ហើមពោះ ប៉ោះ គ្រេច ។ល។ ដែលខ្មែរយើងហៅថា "សា" គេនិយមជឿថា កម្ចាស់ស្រែ

មិនបានរៀបចំធ្វើប្រម សែនក្បាលមាន់ ចំពោះព្រះភូមិដែលនៅថែរក្សាស្រែនោះ ។

មួយទៀត បើឃើញប្រផ្នូលសត្វអ្វីមួយ រត់ធ្លាប ៗ ចូលទឹកចុះឡើង គេនិយមជឿថា ព្រះភូមិរត់ចូលទឹក ប៉ុន្តែ ពុំឲ្យមានគ្រោះថ្នាក់អ្វីដល់អ្នកស្រុកទេ ។

**របៀបលេងភ្នាល់បរគោលឿនៈ–** ក្នុងសម័យ៨០ឆ្នាំកន្លងមកហើយ ព្រះភិក្ខុ នាមយ៉ែម នៅវត្តវិហារបិទមាស បានមានពុទ្ធដីកាថា កាលលោកនៅកម្លោះ លោកជាជើងឯកខាងបរគោលឿន ទោះនៅទីស្រុកណា ក៏មានអ្នកបរគោលឿនសឹងតែគ្រប់កន្លែង ក្នុងពេលលេងម្តងៗត្រូវដាក់ប្រាក់ភ្នាល់ពាន់រៀលក្នុងបក្ខម្ខាងៗ ។

ឯរបៀបភ្នាល់គោនោះ ត្រូវបរភ្នាល់ដោយទឹមរទេះសាឡី បររទាស់ក៏មាន ។ រទេះ-រទាស់ទាំងនោះត្រូវតុបតែងដោយរំយោលក្បី ជាតំរុ-អង្កាំ-ចង្ក្រងចងនៅចុងបន្ទោល ចង្កំស្រោបតាមដង ។

តុបតែងគោដោយមានជាតិក្រហមប៉ាំងមុខ -ស្រោបស្នែង-អង្កាំដាក់តាមហាមជាតិ ចង្ក្រងចង កកន្ទុះប្រឡៅ-ខ្សែ ធ្វើសុទ្ធតែវេញអំបោះឬល្ហៃ ។

**ពិធីរើសគោយកទៅភ្នាល់ :–** គេរើសជើងមុខ ជើងក្រោយ ពងវែង ស្រាវ កន្ទ្រឹង-មាំ -ជើងខាងមុខឈរឡើង កុំឲ្យរួមក្រោម គឺថាឲ្យរាស្មើតាំងពីស្មាលើចុះរៀងមក ពោលឬរត់មិនសូវពាក់ ដងខ្លួនយក

ភងមូល កុំឲ្យពោះធំ "ធ្ងន់ពោះ" ពោលមិនលឿន ។

មុននឹងបរប្រណាំងមួយថ្ងៃ គេត្រូវកេស្មៅឲ្យកស៊ីយ៉ាងស្កប់ស្កល់ ហើយឲ្យគ្រូមកកក្កក់ប្រសិទ្ធិ ដោយរៀបចំសែនព្រេន មានពៃ បាយសី លើកកសី បង់ផ្លង់ទឹក ស្លូត្រលាស់ទឹកទៅលើគោបម្រុងនិងទៅក្នាល់នោះ ។

លុះដល់ពេលបរប្រណាំង គូប្រណាំងទាំងសងខាងសុទ្ធតែមានគ្រូ ចាំបង់ផ្លង់ទឹកដូចៗគ្នា អ្នកប័ក្ខម្ខាងមិនអាចមកពាល់ឬ កាន់ខ្សែគោអ្នកម្ខាងបានឡើយ គេខ្លាចធ្វើមន្ត ខ្លាចដាក់ថ្នាំ ខ្លាចសណ្តំ គោគេឲ្យចាញ់ ។

រីឯអ្នកបរត្រូវរើសរកអ្នកជំនាញខាងបរ និងត្រូវស្លៀកពាក់តាមទំនៀម " គឺស្លៀកសំពត់អន្ទូញចងក្បិន កន្ទ្វីញញាត់ទៅខាងលើត្រឹមជង្គង់ បញ្ចេញជើងខោខ្លៅព្រូនាប់មកខាងក្រៅ ពាក់អាវបំពង់ស ហោប៉ៅក្តោងធំ ជួតក្បាល កាន់ជន្ទួញចង្កូមួយ ធ្វើឫកភាពជាអ្នកសង្ហាអង់អាច ។

បន្ទាប់មកគេប្រមូលគ្នា ទាំងពីរខាងមកកំណត់ទីកន្លែង ដែលជាដើមទី និងចុងទីដែលត្រូវបរ ដោយអ្នកអង់អាចម្នាក់បានឡើងប្រកាសប្រាប់ទីកន្លែងនិងដាក់គម្រូយៈនៅខាងមុខ ។

« បើ គោណាតែហោលចាញ់គោម្ខាង ត្រូវសន្មត់ថាចាញ់ " ។

# រឿងព្រេងដែលជាប់ទាក់ទងនឹងសត្វគោ[១]

ទំនៀមខ្មែរយើងចាស់ៗបានតំណាលថា មានមាណពម្នាក់បានរៀបការពាហ៍ពិពាហ៍នឹងស្រីម្នាក់ តែមាណពនោះគ្មានកូនមួយទាល់តែសោះ ថ្ងៃមួយបាននាំភរិយាទៅបន់សុំកូននៅនឹងលោកតាដើមជ្រៃ ៗ លុះអម្ទងយូរមក ប្រពន្ធមាណពក៏មានគភ៌ទៃ នាងទឹកក្អកចង់បរិភោគផ្លែស្វាយខ្ចីអត់ទ្រាំពុំបាន ចេះតែទៅអង្វរគរប្ដីញឹកញាប់មុងជាពីរដង ប្ដីមិនព្រមរកផ្លែស្វាយឲ្យទាល់តែសោះ ដោយមាណពជាប្ដីបានចាំបណ្ដាំហោរ កាលដែលនាំគ្នាទៅបន់សុំកូនថា "បើនាងជាប្រពន្ធមានគភ៌ពេលណា ត្រូវមានគ្រោះថ្នាក់ដល់ជីវិតនឹងផ្លែស្វាយខ្ចីពុំខាន"

ពេលមួយជាឱកាសដ៏ស្ងាត់ មាណពទៅព្រៃបាត់ទៅ នាងដើរលេងក្បែរផ្ទះ មៀងមើលទ្រុង-ស្ដាំ ឃើញផ្លែស្វាយខ្ចីចំនួន ១ ឬ ២ ប៉ុណ្ណោះ នាងរកទំពក់ឈើកាន់បេះពុំបាន ក៏ដាច់ចិត្តឡើងបេះផ្លែស្វាយ ៗ លុះឡើងបានបន្តិចក៏ស្រាប់តែរបូតជើង-ដៃធ្លាក់មកដី ពេលនោះនាងដួលសន្លប់បាត់ស្មារតី (ស្លាប់ក្នុងខណៈនោះទៅ) កូននៅក្នុងផ្ទៃក៏ប្រសូតចេញមក ៗ កូនច្បងជាសត្វគោ កូនប្អូនជាមនុស្ស ៗ

មាណពជាឪពុក បានចិញ្ចឹមកូនគោនិងកូនមនុស្សដោយដើររកសុំទឹកដោះអ្នកស្រុកឲ្យកូនបៅ ប៉ុន្តែអ្នកស្រុកមិនព្រមឲ្យទាល់តែសោះ ៗ ចេះតែនាំគ្នាដេញចេញមិនឲ្យចូលស្រុកភូមិខ្លាចចង្រៃ ៗ

---

១ រឿងព្រះគោព្រះកែវដែលអ្នកនិពន្ធសរសេរតែងនេះ គឺសរសេរតាមពាក្យអ្នកស្រុក ។

កុមារច្បង មានរូបជាគោឲ្យឈ្មោះ ព្រះគោ កុមារប្អូនមានជាតិជាមនុស្សឲ្យឈ្មោះថា "ព្រះកែវ" ពេលណាព្រះកែវស្រេកទឹកដោះ ព្រះគោក្អកទឹកពីក្នុងពោះឲ្យព្រះកែវបៅផ្អែកស្កប់ស្កល់ ។

ថ្ងៃមួយ ពួកអ្នកស្រុកនាំគ្នាតាមតាប់ព្រះគោ ដើម្បីសម្លាប់យកសាច់បរិភោគ ខំនាំគ្នាដេញថា "អាសត្វចង្រៃ" លុះពួកអ្នកស្រុកមកជិតដល់ហើយ ព្រះគោប្រាប់ព្រះកែវឲ្យតោងខ្លួនកន្ទុយឲ្យជាប់ រួចក៏ហោះផ្លោះរំលងក្បាលអ្នកស្រុកឆ្ពោះត្រង់ទៅលើអាកាស ។

រីឯមាណពជាឪពុក មកពីព្រៃវិញរកកូនពុំឃើញ ក៏ដើរស្រែកដង្ហោយហៅកូនគ្រប់ចន្លោះភូមិ-ព្រៃព្រឹក្សា ដោយសេចក្ដីអាល័យខ្លោចផ្សាទិន្នកូន ក៏ដួលដេកស្លាប់ក្នុងព្រៃទៅ ។

ស្ទុះទុកត្រឹមនេះ និយាយពីព្រះគោ-ព្រះកែវ ដែលហោះទៅជាមួយគ្នា ក៏បបួលបង-ប្អូនចុះសំចតនៅកន្លែងមួយ ជិតស្រះស្រង់នៃព្រះចៅប្រទេសខ្មែរ ។ លុះនៅយូរឆ្នាំបានសេចក្ដីសុខសាន្ត នៅទីនោះមក ព្រះកែវជាប្អូនក៏កាន់តែមានវ័យធំឡើង ពេញកម្លោះ ។

ថ្ងៃមួយ ព្រះរាជបុត្រី ៧ ព្រះអង្គនៃព្រះចៅខ្មែរ បានចេញទៅស្រង់ទឹកស្រះនោះព្រះកែវក៏ចុះទៅលេងទឹកស្រះជាមួយព្រះរាជបុត្រីនោះដែរ ។ ព្រះកែវនិងនាងទៅ បានចិត្តស្នេហានឹងគ្នា ប្រឡូកប្រឡែងញោចគ្នាទៅវិញ-នៅមកយ៉ាងស្និទ្ធស្នាល ។

រឿងនេះបានទ្រង់ជ្រាបដល់ព្រះចៅជាបិតា ព្រះអង្គទ្រង់ព្រះពិរោធយ៉ាងខ្លាំង ហើយឲ្យចាប់នាងពៅនិងព្រះកែវ យកទៅបំបរបង់ឲ្យទៅនៅស្រុកបច្ចន្តគ្រាម ។

ថ្ងៃមួយព្រះចៅក្រុងសៀម ផ្ញើសារមកព្រះចៅស្រុកខ្មែរថា ព្រះអង្គមានបំណងចង់លេងភ្នាល់ទួទៅ ។

ពេលនោះព្រះចៅស្រុកខ្មែរ មានសេចក្ដីបារម្ភក្នុងព្រះទ័យ មិនដឹងជាបានខគរណាជួយទំនុកបម្រុងក្នុងរឿងនេះ ព្រះអគ្គមហេសីទូលព្រះរាជាថា “សូមទ្រង់ព្រះមេត្តាប្រោស នៅក្នុងរឿងនេះចាំទូលព្រះបង្គំជាខ្ញុំទៅស្នើការនឹងព្រះកែវនិងនាងពៅសិន ក្រែងលោគេជួយកើត” ។ លុះគិតរួចហើយព្រះអគ្គមហេសី ក៏ទៅកាន់សំណាក់ព្រះកែវនិងនាងពៅដោយរួសរាន់ ហើយក៏និយាយរឿងរ៉ាវប្រាប់នាងពៅដោយសព្វគ្រប់ ។ នាងពៅនិងព្រះកែវ សុខចិត្តទទួលភារៈនោះនៅលើខ្លួន ខណៈនោះព្រះកែវទៅនិយាយនឹងព្រះគោជាបងឲ្យជួយកិច្ចការដ៏ធ្ងន់នេះ ព្រះគោក៏ព្រមទទួល លុះដល់ពេលណាត់គ្នាថានឹងភ្នាល់ ព្រះគោ-ព្រះកែវនិងនាងពៅ នាំគ្នាចេញពីស្រុកបច្ចន្តគ្រាម មកកាន់រាជធានីនៃព្រះវរបិតា-មាតា ។

កាលបើព្រះគោ-ព្រះកែវ មកដល់ហើយ ក៏ផ្ញើសារទៅថ្វាយស្ដេចក្រុងសៀមថា ឲ្យយាងមកភ្នាល់គ្នាតាមពេលកំណត់ ។ ស្ដេចក្រុងសៀមក៏លើកពលសេនា ហើយនឹងយកមាន់ពូកែមួយមកផង ។

លុះមកដល់ហើយ គឺរៀបចំប្រជល់មាន់ ព្រះគោក៏ក្លែងខ្លួនធ្វើជាមាន់ ជល់តទីងមាន់ស្ដេចក្រុងសៀម ប៉ុន្តែមាន់ស្ដេចសៀមត្រូវបរាជ័យ ។

-លើកទី២ ប្រជល់ដំរី ដំរីព្រះគោមានជ័យជម្នះទៀត ។

-លើកទី៣ ប្រជល់គោ ស្ដេចសៀមឈឺចិត្តណាស់ក៏គេឧបាយកលធ្វើជាគោយន្ត ដើម្បីប្រជល់ទីងព្រះគោដែលមានឫទ្ធិអំណាច ឲ្យវាបាក់បបខ្ទបខ្ទាចវិនាសហិនហោច ដើម្បីនឹងបាយកមាស-ពេជ-ត្បូង-តម្រាពីក្នុងពោះព្រះគោ ជញ្ជូនយកទៅស្រុកសៀមអស់រលីង ។

រឿងដែលនាំមកដោយសង្ខេបនេះ សឲ្យឃើញថានៅស្រុកខ្មែរយើងមានពូជគោពូកែស័ក្ដិសិទ្ធិណាស់ដែរ ។

## "រឿងព្រេងអំពីសត្វគោ - មាន់ - អណ្ដើក - ពស់ និង សត្វរាជសីហ[១]"

មានសេចក្ដីដំណាលថា មានមេក្អែកមួយកាច់សំបុកពងនៅលើដើមកោងកាងក្បែរមាត់សមុទ្រ ពេលមួយមានខ្យល់ព្យុះបក់បោកយ៉ាងខ្លាំង ធ្លាក់សំបុកក្អែកនិងពង ៥ ទៅក្នុងទឹក អណ្ដែតទៅទើរនៅនឹងកោះមួយ កោះនោះមានតានិងយាយពីរនាក់ប្ដីប្រពន្ធគ្មានកូន ក៏រើសយកពងទាំង ៥នោះទៅក្រាទុក លុះដល់កំណត់ថ្ងៃពងទាំង ៥ ក៏ញាស់

១- រឿងក្អែកពង ៥ នេះខ្ញុំបាទបានពីលោកភិក្ខុ ហុន-ទឹម វត្តវិហារប័ទមាស លោកនិយាយប្រាប់សព្វគ្រប់ ។

ចេញមកជាសត្វទីទៃពីគ្នា ពងទី ១ ញាស់ចេញមកជាសត្វ “ មាន់ ” ពងទី ២ ញាស់ជាពស់ ពងទី ៣ ញាស់ជាអណ្តើក ពងទី ៤ ញាស់ជាសត្វគោ ពងទី ៥ ញាស់ជាសត្វសិង្ហ ។

សត្វទាំង ៥ នៅជាមួយនឹងយាយ-តា រៀងរហូតដល់មានវ័យធំរៀងៗខ្លួន បានសាកសួររកម្តាយឪពុករៀងខ្លួន តានិងយាយក៏បានប្រាប់តាមដំណើរហូរហែសព្វគ្រប់ ។ សត្វទាំង ៥ បានស្តាប់តា-យាយដោយសព្វគ្រប់ទៅ ក៏មានសេចក្តីអៀនខ្មាស់នឹងជាតិកំណើតរបស់ខ្លួន ក៏លាតា-យាយស្វែងរៀនវិជ្ជាចំណេះ លុះត្រាតែបានសម្រេចដូចបំណងហើយលះបង់ភេទរបស់ខ្លួន ចេញស្វែងទៅបួសរៀងៗខ្លួន ។

សត្វមាន់បានត្រាស់ជាព្រះពុទ្ធ មាននាមថា “ ព្រះ កកុ-សន្ធោ ” ។ សត្វពស់បានត្រាស់ជាព្រះពុទ្ធមាននាមថា “ ព្រះ គោនាគមនោ ” ។ សត្វអណ្តើកបានត្រាស់ជាព្រះពុទ្ធមាននាមថា “ ព្រះ កស្សបោ ” ។ សត្វគោបានត្រាស់ជាព្រះពុទ្ធ មាននាមថា “ ព្រះ គោត្តមោ ” ។ សត្វសិង្ហៈបានត្រាស់ជាព្រះពុទ្ធមាននាមថា “ ព្រះ សិអារ្យមេត្រី ” ។ ដោយយកនាមកំណើតដំបូងដែលខ្លួនកើតនៅជាមួយនឹងតា-យាយរៀងៗខ្លួនមកដាក់ថា “ ព្រះពុទ្ធនាមមាន់-គោ ។ល។ ហើយនឹងចាំបណ្តាំយាយតា មុននឹងសត្វទាំងនោះលាចេញទៅថា “ ចូរចៅទាំងអស់កុំភ្លេចកំណើតខ្លួនឡើយ ”

ព្រោះហេតុនោះហើយបានជាព្រះពុទ្ធទាំង ៤ ព្រះអង្គនេះឧប្បត្តិឡើងក្នុងលោក ត្រូវយកនាមសត្វកំណើតមកដាក់និងចារិករូបសត្វទាំងនោះនៅពីក្រោមបល្ល័ង្កផង ។

## អំពីសត្វដែលមានប្រយោជន៍ដល់ផ្ទះសម្បែង

ដូចជាសត្វសេក-សារិកាកែវ... កាលណាម្ចាស់បង្ហាត់ឲ្យចេះនិយាយស្តី-ឲ្យស្គាល់មនុស្សនៅក្នុងផ្ទះ និងមនុស្សនៅក្រៅផ្ទះ ពេលណាម្ចាស់មិននៅ មានមនុស្សចំឡែកចូល-សារិកាកែវនិងសេកទាំងនោះ វាស្រែកឡូឡាហៅម្ចាស់ក្នុងនាទីជាសត្វការពារផ្ទះ ។

អំពីសត្វឆ្កែនិងស្វា : សត្វទាំងពីរនេះ ជាសត្វការពារផ្ទះដែរ បើយប់ឬថ្ងៃ មានមនុស្សចំឡែកចូល ឆ្កែនេះវាព្រូសឡូឡា ម្ចាស់ក៏ភ្ញាក់ដឹងខ្លួនដោយសារនេះវា ។ ជួនកាល គេបង្ហាត់ពូជឆ្កែមាឌធំ-ពូជកាច-ម្ចាស់ក៏បានបង្ហាត់ឲ្យចេះសព្វគ្រប់ចាប់ទៀត ។ ពេលណាមានមនុស្សចំឡែកចូល-ឆ្កែទាំងនោះវាខាំតែម្តង សមនឹងពាក្យស្លោកថា “ ឆ្កែជាឲ្យបាយធី ដេកនៅចាំធនធាន ” ។

រឿងសត្វចាំផ្ទះ មាននិទានរឿងព្រេងមួយសម្តែងថា មានជីតាម្នាក់ចិញ្ចឹមស្វាមួយឲ្យនៅចាំផ្ទះ ពេលមួយនាងកណ្តៀតក្អមទៅដងទឹកនៅឯអណ្តូង ហើយផ្តេកកូនខ្ចីឲ្យនៅក្នុងអង្រឹង ទុកស្វាឲ្យនៅចាំផ្ទះ ។

ខណៈនោះមានពស់សាហាវមួយលូនចូលមក បម្រុងនឹងខាំកូនខ្ចី នៅក្នុងអង្រឹង ស្កាក៏ខាំពស់កៃរី ទាល់តែពស់ងាប់ស្ដុកនៅទីនោះទៅ ស្កាដឹងថាពស់ងាប់ហើយ ក៏រត់ទៅប្រាប់ម្ចាស់ឯអណ្តូងទឹក ដោយមានឈាមពស់ប្រឡាក់ជាប់មាត់ផង-ម្ចាស់ កាលបើឃើញសត្វស្ការត់ទៅដល់ (មិនបានពិចារណា) នឹកស្មានថា ស្កាខាំកូនរបស់ខ្លួន ក៏ចាប់ជើងស្កាបោកនឹងដើមឈើស្លាប់ក្នុងខណៈនោះទៅ នាងធីតាកណ្តៀតក្អមមកដល់ផ្ទះឃើញពស់ងាប់នៅក្បែរអង្រឹងកូន ក៏នឹកតូចចិត្តស្តាយក្រោយថា "អញសម្លាប់ស្កាខុសហើយ" ។ រឿងពស់និងស្កា មានជាប់ពៀរនឹងគ្នារហូតមកដល់សព្វថ្ងៃនេះ កាលបើស្កាឃើញពស់វាដេញខាំពស់ទាល់តែងាប់ពុំខានឡើយ ។

<u>សត្វដែលយកមកធ្វើជាពិធី និង មង្គលផ្សេង ៗ</u> : សត្វដែលយកមកធ្វើពិធីផ្សេង ៗ ដូចជាគោ-ឆ្មា ត្រី-មាន់-គីង្គក់-ល័ក្កជុំប្រឡង់ដែលមានកូនរស់នៅខាងក្នុង ។ល។ ក្នុងទីនេះមិនបានយកឆ្មា-ត្រីសំមកនិយាយទេ លើកយកតែសត្វគីង្គក់-មាន់ ល័ក្កស្រម៉មកនិយាយដូចតទៅ :

១- សត្វគោគេ យកមកធ្វើជាពិធីផ្សងមើលផលដំណាំ មើលទឹកក្នុងមួយឆ្នាំ ៗ ថាមានតិចឬច្រើន ។ ដោយគេរៀបចំ តុ ស្មៅ-ស្រូវ-ពោត សណ្តែក ។ល។ ហើយគេលែងគោឲ្យស៊ីវត្ថុទាំងនោះបើគោស៊ីវត្ថុ

រឿងពស់ និង ស្កា ដកស្រង់ពីសៀវភៅគតិលោក ។

ទំនាយថា កូនឆ្នាំនោះមានភ្លៀងប្រាំង សំបូណ៌ផលស្រូវ ឬខ្សត់ ។ល។

២- សត្វមាន់និងគីង្គក់ គេយកមកធ្វើជាមង្គលមួយហៅថា "ស្រោចខ្ទរ" កាលបើកូនខ្ចីមានជម្ងឺដំកាត់ផ្សេង ៗ ដូចជាគ្រុនរងា-កម-រមាស់ កុតកញ្ជ្រិល ។ល។ គ្រូគម្រូវត្រូវត្រង់ស្រោចខ្ទរ យាយតា-ម៉ែ-ឪ ក៏រៀបចំធ្វើកន្ទ្រជាពីថ្នាក់ លើក្រោមនិងដាំដើមចេកមហាត្រកាលមួយដើម មេមាន់ខ្មៅ ១, គីង្គក់ ១, សំពត់អាវឆ្នូត-ស្ពាំ ក្រាស់-កញ្ចក់ ប្រេង ម្សៅ ទឹកអប់ ចត្រ ១ បាយសម្ល បង្អែម (ឆ្នូត-ស្ពាំ) ស្លាជម គ្រប់ជើងសរសរកន និងស្លាជមនៅលើថាស បានបាយ-សម្លបួន ១ កុជ ទៀន-ធូប-រៀបកៀបត្រានៅមុខកន្ទ្រ ។

ដោយមានតា-យាយជាញាតិមិត្រ ចាប់ធ្វើពិធីនេះ ចាប់កុជធូបទៀន អង្ករមួយក្តាប់ ចាប់សំបូងស្រង់ថា "នុះនុ! តេជៈ ថ្ងៃនេះជាថ្ងៃមានឫក្សពារវេលាល្អ សូមអញ្ជើញអស់លោកព្រះវិខ្ទរ មកទទួលសេពសោយនូវក្រយាបូជា មានសំពត់អាវសារវៃស្ស ប្រេង ម្សៅ ក្រាស់ កញ្ចក់ បង្អែមចំអាប រៀបតុ ថាស ឆ្នូត-ស្ពាំ សព្វគ្រប់តាមចំណាំប្រពៃណីពីបុរាណ កាលបើបានសេពសោយរួចហើយ សូមឲ្យដកពិសពែងស្មែងកម្ម ចេញពីអង្គឲ្យជាសះស្បើយល្ហើយបូរខ្លួនប្រាណ និងឲ្យកូនចាបនេះស្រេកទឹករកចំណី ចាប់តាំងពីពេលនេះតទៅ ហក់ ១-២-៣-៤-៥-៦ ៧ ៤ ទៅ (បាចអង្ករមួយចឹប) ថាបីដង ឲ្យទៅជាប់និងមេមាន់

ខ្មៅទីងគីង្គក់នេះចុះ ។

រួចហើយក៏ចាប់បាយ-សម្ល ១ ដាក់ទៅក្នុងកន្ទោង ១ ប្រេងម្សៅទឹកអប់ ចាក់បន្តិច ៗ យកទៅលាបលទ ដើមចេក គីង្គក់ មាន់ និងកូនចាបឈើផងដែរ ហើយឧបកិច្ចបញ្ចេញគ្គាធ្មេងទៀតថា សូមឲ្យជម្ងឺកូនចាបនេះទៅជាប់នឹងមាន់ គីង្គក់ ដើមចេក ឯណោះចុះ ១-២-៣ ៤-៥-៦-៧ ទេ ទៅ (៣ ដង)

បន្ទាប់មកយាយ-តា ចាប់វេញអំបោះខ្សែជា៣ធ្នុង គឺមានពណ៌ស-ក្រហម និងខ្មៅ ដោយមានចងលុយសេន លុយក្បាល ខ្សែចៀ ស្រកាពង្រីល ក្រចកខ្លា ក្រចកខ្លែងស្រាក់ ចំរុះគ្នា រួចយកមកចងកកូនចាបឈើនោះ ដើម្បីការពារកុំឲ្យតារកភ័យភ្ញាក់យំឡូឡា ក្នុងពេលយប់ ការពារស្កុន-បា បន្ទាប ។ល។

ពិធីស្រោចខ្លួននេះមានកំណត់ ៣ ថ្ងៃ ក្នុងមួយថ្ងៃស្រោចបីដងគឺព្រឹក ថ្ងៃត្រង់ ល្ងាច ។ បញ្ចេញគ្រាប់សគ្គ្គាត្រូវធ្វើរៀងរាល់ពេលដែលយកតារកទៅស្រោចទឹកនៅឯកនខ្លួន ។ (ឯរៀបរណ្ដាប់រណ្ដាកស្តុការផ្សេង ១ ដូចថ្ងៃដំបូងគ្មានទេ) មានតែស្រោចទឹកនិងបញ្ចេញគ្គាប៉ុណ្ណោះចំពោះពេលជាបន្ទាប់បន្ទមក ។

---

រឿងពិធីស្រោចខ្លួននេះ ខ្ញុំបាទបានដឹងពីលោកយាយ " សា ង "

អាយុ ៧៧ ឆ្នាំ ដែលត្រូវជា ម្ដាយបង្កើតរបស់ខ្ញុំបាទ

៣-ល័ក្តស្រម៉ ជុំក្រឡង់ : គេយកមកធ្វើជាមង្គលមួយក្នុងពេលឡើងផ្ទះថ្មី ដោយអ្នកមុខអ្នកការចាស់ទុំយកល័ក្តស្រម៉នេះទៅបញ្ចុះក្នុងរន្ធសសរគ្រឹះល្វែងចន្ទ ព្រោះគេយល់ថា ល័ក្តជុំក្រឡង់ជានិមិត្តរូបនៃគូស្រករថ្មីឲ្យចេះស្រឡាញ់គ្នា រួបរួមគ្នាមិនឈ្លោះទាស់ទែងគ្នា ដូចជាល័ក្តជុំក្រឡង់និងឲ្យស្រីមេផ្ទះ ចេះរក្សាគំនិតមារយាទឲ្យគង់វង់ដូចល័ក្តជុំក្រឡង់នោះទើបក៏គេយកល័ក្តមកធ្វើជាមង្គលមួយហៅថាជុំពិលា ជាវិធានស្វាអាចារ្យធ្វើធ្មេញកូនប្រុស - ស្រី រួចយកល័ក្តមកលាបជើងធ្មេញ ដើម្បីឲ្យធ្មេញជាប់យូរ អ្នកក្លែងលេងក្លែងបុកល័ក្តទទាក់មេម្សៅក្នុងពេលធ្វើធ្មេញលាបធ្មេញនោះដែរ ។

អំពីសត្វនិងអាទិទេព : មានសត្វខ្លះគេគោរពបូជាដូចជាអាទិទេពដែរ " គឺសត្វដំរី " ។ សត្វដំរីនេះមានរឿងនិទានដូចតទៅ ៖

ព្រះសិទ្ធិសួស្តីនិងប្រសិទ្ធិសោមជាបងប្អូនបង្កើត ត្រូវជាព្រះរាជបុត្រនៃព្រះឥស្សូរ ។

លុះព្រះសិទ្ធិសួស្តី មានវ័យធំឡើង ក៏ថ្វាយបង្គំលាព្រះបិតាទៅរៀនសិល្បវិជ្ជាការ នៅឯក្រុងពេមៈ ។ បណ្តាសិស្សដែលទៅនៅរៀន

---

រឿងល័ក្តប្រជុំក្រឡង់ បានដឹងពីលោកអាចារ្យតាម " ឡុង "
ជាអាចារ្យកាន់ពិណការនៅភូមិព្រា

ទាំងប៉ុន្មាន មានតែព្រះសិទ្ធិសួស្តីមួយទេ ដែលល្បីឈ្មោះថា ជាអ្នកឈ្លាសវៃ ចេះដឹងជាងសិស្សទាំងពួង អាចារ្យទិសាបាមោក្ខព្រាហ្មណ៍ ក៏មានសេចក្តីស្រឡាញ់រាប់អានព្រះសិទ្ធិសួស្តីខ្លាំងណាស់ ។ ដំណឹងនេះឮដល់ព្រះចៅក្រុងរោម ព្រះចៅក្រុងរោម មានព្រះរាជបុត្រីមួយព្រះអង្គ មានរូបឆោមលោមពណ៌ស្រស់បស់ ជាបុត្រីសំណប់ចិត្តរបស់ព្រះអង្គ។

ពេលខាងក្រោយមក ព្រះចៅសព្វព្រះទ័យ ចង់ផ្សំផ្គុំបុត្រីរបស់ព្រះអង្គជាមួយនឹងព្រះសិទ្ធិសួស្តីឲ្យជា គូ-ស្វាមីភរិយា ។

ថ្ងៃក្រោយមកព្រះចៅត្រាស់បញ្ជាហៅព្រះសិទ្ធិសួស្តី ឲ្យចូលគាល់ព្រះអង្គ ។ព្រះសិទ្ធិសួស្តីក៏ចូលទៅគាល់តាមព្រះរាជបញ្ជា ។ ព្រះចៅក៏មានព្រះបន្ទូលសំណេះសំណាលជាមួយនឹងព្រះសិទ្ធិសួស្តី ដោយសព្វគ្រប់ ហើយមានបន្ទូលទៀតថា ខ្ញុំចង់ឲ្យបុត្រីសំណប់ខ្ញុំ ទៅជាគូស្រករបស់អ្នក តើអ្នកថាដូចម្តេច ? លុះព្រះសិទ្ធិសួស្តី ឮព្រះចៅមានបន្ទូលដូច្នោះហើយ "ទទួលក៏មិនថា ទេក៏មិនថា" ធ្វើអាការៈហាក់ដូចជាភ្ញាក់-ភ្ញាំង ទ្រមឹងស្ងៀម ។

លុះដល់ពេលត្រឡប់ពីព្រះចៅមកវិញ បានចំនួន ២-៣ថ្ងៃ ព្រះសិទ្ធិសួស្តីរំពឹងគិតក្នុងចិត្តថា បើអាត្មាអញទាំនៅទីនេះយូរទៅ មុខជាជាប់ដៃនឹងព្រះរាជបុត្រី ព្រះចៅអង្គនេះពុំខាន ដូច្នេះអាត្មាអញត្រូវ

លបរត់ពីនគរនេះ ឆ្ពោះទៅនគរកំណើតខ្លួនវិញ ៗ គិតស្រេចហើយក៏រៀបចំប្រដាប់ប្រដា សម្លៀកបំពាក់ លបរត់ចេញទៅនៅពេលយ៉ាងស្ងាត់ ៗ ដំណឹងនេះក៏ជ្រួតជ្រាបដល់ព្រះចៅក្រុងពេម ព្រះអង្គទ្រង់ព្រះពិរោធយ៉ាងខ្លាំង ហើយព្រះអង្គទ្រង់បញ្ជាគ្រឿងយន្ត (ម៉ាស៊ីនកាត់) តាមកាត់កព្រះសិទ្ធិសួស្តី ទាន់នៅឯកណ្តាលផ្លូវព្រៃ· យន្តកាត់ក៏ក្បាលយកទៅឯក្រុងពេម ផងខ្លួននៅដេកស្តូកស្តឹងកងដងផ្លូវព្រៃ ៗ

និយាយអំពីព្រះសិទ្ធិសោមជាប្អូន លុះបានដំណឹងថា ព្រះសិទ្ធិសួស្តីជាបងផ្តាំឲ្យមកចាំទទួល នៅនាពាក់កណ្តាលផ្លូវ រៀបដំណើរមកចាំ ទទួលតាមពាក្យបណ្តាំ ៗ

លុះនៅយូរ ៗ ទៅ បាត់មិនឃើញសោះ ក៏ដើររកមើល-ឆ្វេង-ស្តាំ ស្រាប់តែឃើញមនុស្សដួលដេកស្លាប់នៅក្បែរព្រៃ (ឃើញតែដងខ្លួនឥតក្បាល) ព្រះសិទ្ធិសោម ពិនិត្យខ្ទាបមើលចុះ ឡើង ឃើញសុទ្ធតែមន្ត-អាគម-អួមអាម មានមន្តប្រស់មនុស្សឲ្យរស់ជាដើម (សាក់នៅជាប់នឹងដងខ្លួន) ៗ

ព្រះសិទ្ធិសោមចាប់រៀនអាគមប្រស់មនុស្សមុនគេ លុះចេះសព្វគ្រប់ហើយ ក៏តាំងប្រសិទ្ធិប្រស់មនុស្សនោះឲ្យរស់ឡើងបាន តែមុននឹងប្រស់ដើររកក្បាលមនុស្សស្លាប់ពុំបាន ឃើញមានតែក្បាលដំរីមួយស្លាប់

ទៅទីនោះ ក៏កាត់ក្បាលដំរីមកតភ្ជាប់នឹងដងខ្លួន រួចសូត្រមន្តអាគមប្រោស ដងខ្លួនឡើងហើយ ក៏និយាយរឿងរ៉ាវ ដំណើរទំនងប្រាប់ប្អូនដោយ សព្វគ្រប់ ។

ប្អូនក៏និយាយអង្វរបង ឲ្យចូលទៅនៅស្រុកវិញ តែបងមិនព្រម ទាល់តែសោះ ដោយមានសេចក្ដីអៀនខ្មាសអ្នកស្រុក ( ខ្លួនខុសគេ ) ( ក្បាលដំរី ខ្លួនជាមនុស្ស ) ព្រះសិទ្ធិសួស្ដីសុខចិត្តភៀសខ្លួនទៅនៅ ក្នុងព្រៃ ។ ព្រះសិទ្ធិសោមបានរៀនមន្តអាគម និងចម្ងងព្រះសិទ្ធិ-សួស្ដីសព្វគ្រប់ រួចវិលត្រឡប់ចូលនគរវិញ ។

រីឯមន្តអាគម និងធ្វើរូបសួងព្រះសិទ្ធិសួស្ដី សឹងមានជាប់ជាតំណ-វង្សរហូតៗមកដល់សព្វថ្ងៃនេះ ។

ព្រោះហេតុនោះ ទើបគ្រូមន្តអាគមទាំងឡាយ មុននឹងសូត្រ-សែក ស្ដោះ·ផ្លុំមើលជម្ងឺទាំងពួង ត្រូវលើកគុណគ្រូជាដំបូងថា: ឧ:ម: ព្រះ សិទ្ធិសួស្ដីអញ:ហើយ ។ល។ ពាក្យថា ឧ:ម: គឺលើកដល់គ្រូទាំងបី គឺ ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ ។

ដំរីគេគោរពដូចជាអាទិទេព ដោយសារតែក្បាលដំរីទៅភ្ជាប់នឹង ដងខ្លួនមនុស្ស ដែលមានមហិទ្ធិឫទ្ធិអស្ចារ្យប៉ុណ្ណោះទេ ។ ពាក្យថា ដំរីមួយបុះ "គឺដំរី៨" ។ លោកមួយទទួន "គឺលោក ៨ អង្គ" ។

ពាក្យខាងលើនេះ មានប្រើក្នុងសម័យបុរាណ ឧទាហរណ៍ : ព្រះករុណាទ្រង់បញ្ជាសេវកាមាត្យថា “ចូរអ្នកទៅនាំដំរី២ បុះឬ៣បុះ ដើម្បីប្រទក្សិណព្រះបរមរាជវាំង៣ជុំ” ។ “ឬក៏អ្នកឯងចូលទៅនិមន្តលោកមួយទទួងមកគាល់នៅក្នុងព្រះរាជដំណាក់ ។”

“រឿងព្រះសិទ្ធិសួស្តិ៍-ខ្ញុំបាទបានរៀនពីលោកអាចារ្យ ម៉ោ គា អាយុ ពី ឆ្នាំ
នៅភូមិអំពៅព្រៃ

ឯពាក្យថា “បុះ នឹង ទទួង” ខ្ញុំបាទបានឃើញក្នុងសាស្ត្រាបុរាណ ។

# រឿង
# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក រ៉ាប៊ិន្ទ្រ ណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ៣៦

– មិនស្រួលខ្លួនឬកាមាលា ? ( នាងសិលាជាសួរនាងនៅពេលដែលនាងដើរចូលមក )

– ខ្ញុំឥតមានឈឺអ្វីទេបង ! កាលណាទើបលោកមាត្រឡប់មកវិញបង ?

– មិនមុនមួយអាទិត្យទេ យ៉ាងឆាប់អូន មកញុំាបាយឲ្យឆាប់ទៅ នឹងអាលទៅគេងពីព្រលប់ អូនអស់កម្លាំងហើយ ធ្វើការដល់ល្ងាចយ៉ាងនេះ ៗ

ពេលអាសន្នយ៉ាងនេះ ការសង្គ្រោះរបស់នាងមានតែប្រាប់រឿងអាថ៌កំបាំងរបស់នាងឲ្យនាងសិលាជាដឹងឲ្យអស់ថា រមេស្ហដែលអ្នកទាំងអស់គ្នាយល់ថាជាប្ដីនាងនោះ គឺគ្មានត្រូវជាអ្វីនឹងនាងទាល់តែសោះ ប៉ុន្តែ នាងរកហាមាត់ប្រាប់គេមិនកើត ! នាងចូលទៅសម្ងំក្នុងបន្ទប់ដើម្បីនឹងអានសំបុត្រនោះឡើងវិញ ៗ

កូនសំបុត្រនោះ  គ្មាននិយាយអ្វីអំពីនាងហ៊ាមណាលិនីបន្តិចសោះ កាមាណាគ្រាន់តែយល់ថា ស្រីនោះជាគូដណ្តឹងរបស់កាមេស្ហ ដែលត្រូវផ្តាច់ទៅវិញដោយសារតែខ្លួននាង ។ នាងកាមាណាដឹងម្យ៉ាងទៀតថា កាមេស្ហស្រឡាញ់នាងនោះណាស់ ប៉ុន្តែ ការដែលគេសុខចិត្តទទួលនាងនេះ គឺដោយសារតែគេចំទ្រាំទៅទេ ព្រោះថា ធ្វើម្ដេចបើកសនាបង់គេផ្តាច់ទឹងនាង់នេះទៅហើយ  គេសុំខាំមាត់ទ្រាំលែងទៅជួបស្រីដែលជាទីស្រឡាញ់ពិតប្រាកដរបស់គេ ។

លុះមើលសំបុត្រចប់ហើយ នាងកាមាណាចំនឹកអំពីឧប្បត្តិហេតុដែលចេះតែផុសឡើងជាបន្តបន្ទាប់គ្នា នៅពេលដែលនាងនៅជាមួយនឹងកាមេស្ហ តាំងពីបានជួបគ្នានៅលើធ្នេរខ្សាច់ រហូតដល់មកនៅភ្នាស៊ីបូរនេះ ។

ឥឡូវនេះរឿងអ្វី ៗ តាំងប៉ុន្មាន ដែលបិតនៅក្នុងភាពងងឹត ក៏លេចច្បាស់ទែងឡើង ហាក់ដូចជានៅក្នុងរង្វង់ស្មើព្រះទិនករ គឺថាតាំងពីយូរយារណាស់មកហើយ ដែលកាមេស្ហគេដឹងច្បាស់ថាខ្លួននាងនេះមិនមែនជាប្រពន្ធគេទេ ប៉ុន្តែគេមិនដឹងជាធ្វើម្ដេចនឹងលះលាស់នាងចោលបាន ម្ល៉ោះហើយ គេចេះតែបៀមទុកទៅ ឯចំណែកខ្លួននាងវិញ ក៏ចេះតែប្រុងប្រៀបខ្លួនទទួលគេជាប្ដីតាំងនិតស្បូទ្យ គ្មានខ្មាសគ្មានអៀនអ្វីបន្តិចសោះ គិតឃើញដូច្នេះថែមតាំងរឿងអ្វីផ្សេង ៗ ជាមួយនឹងកាមេស្ហទៀតក៏ចេះតែផុសបន្តបន្ទាប់គ្នា ធ្វើឲ្យនាងកាមាណាអៀនអន់ខ្មាសមិនចង់រស់នៅលើ

ផែនដីទៀតសោះ ។ ! ពុទ្ធោអើយ នាងត្រូវកម្មាស់មុខអស់មួយជីវិត ! តើនឹងបានអ្វីយកមកលាងឲ្យជ្រះខ្លួនវៀងកខ្វក់ទាំងនេះបាន ? . . . ។

នាងបើកទ្វារបន្ទប់ដើរចេញទៅកន្លែងសួនច្បារ ពន្លឺខែសិរសិរផ្លូវ មានចំហាយត្រជាក់ស្រេច នៅខាងនាយបន្តិចទៅទៀត ដើមស្វាយធំៗ ធ្វើឲ្យមានភាពងងឹតដោយដុំៗកងវៀងលំបាកវេទនារបស់នាង នាងប្រមើលមើលទៅគ្មានឃើញច្រកណា ដែលនាងអាចគេចខ្លួនចេញរួចសោះ ។ ល្វើយទាំងកម្លាំងចិត្ត ល្វើយទាំងកម្លាំងកាយ ខ្លួន កាមាលាផ្តួលខ្លួនក្រាបទៅលើស្មៅ បីដូចជារូបបដិមាដែលគេប្រានរំលំ នៅស្ងួតស្ងឹងហាក់ដូចជាគ្មានវិញ្ញាណ នាងយំក៏មិនចេញ ថ្ងូរក៏មិនឮ ពុទ្ធោអើយ ! មិនដឹងជានាងក្រាដើរហួសទៅប៉ុន្មានម៉ោងទេ ដែលនាងនៅស្ងួតស្ងឹងយ៉ាងនេះ ប៉ុន្តែ អាកាសត្រជាក់ជ្រាបរហូតដល់ឆ្អឹងខ្នងនាង រំសា ភ្ញាក់ខ្លួនឡើង ពន្លឺព្រះច័ន្ទរះឡើងផាត់ភាពងងឹតស្ទើរតែរលីងដេង នាងក្រោកឡើងដើរសន្សឹម ៗ ចូលទៅកាន់បន្ទប់វិញ ។

នៅពេលដែលនាងបើកភ្នែកស្អែកឡើង នាងឃើញនាងសិលាមកឈរនៅក្បែរខ្លួននាងស្រេចទៅហើយ នាងទឹកអៀនទន់គេងលក់ជ្រុលពេលថ្ងៃ ក៏ខំស្ទុះក្រោកយ៉ាងម៉ា ។

–កុំអាលក្រោកអី អូនគេងមិនទាន់ឆ្អែតទេ មើលភ្នែកអូននៅឡើងជាំនៅឡើយ អូនច្បាស់ជាមានការអ្វីពិភាក្សាចិត្តហើយ អូនប្រាប់បង

ផងមើល ?

គ្រាន់តែឮពាក្យនាងសិលានិយាយដូច្នេះ ទឹកភ្នែកនាងកាមាលាហូរស្រោកមួយរំពេច នាងស្រវាឱបនាងសិលា ហើយយំខ្សឹកខ្សួលយ៉ាងយូរ ៗ បន្តិចមក នាងដោះដៃចេញអំពីនាងសិលា ជូតទឹកភ្នែកហើយធ្វើជាសើចយ៉ាងខ្លាំង ប៉ុន្តែនាងសិលាយល់ជម្រៅទុក្ខនាងកាមាលា បំភាន់នាងម្តេចបាន ៗ

— នែកាមាលា អ្នកមិនបាច់ធ្វើបំភាន់បងទេ បងមិនដែលឃើញមនុស្សណាមានខន្តីដូចអ្នកសោះ ប៉ុន្តែអ្នកកុំស្មានថា បងមិនដឹងថា ព្រួយរឿងអ្វីនោះខុសទេ ៗ តាំងពីកមេស្ហចេញទៅ គេមិនដែលសរសេរសំបុត្រអ្វីមួយមកអ្នកសោះ ហេតុនេះហើយបានជាអ្នកព្រួយណាស់ ទោះជាអ្នកនៅធ្វើឫកសង្ហាយ៉ាងណា ក៏បងយល់ដែរ ៗ អ្នកត្រូវដឹងថា គេរវល់ការច្រើនណាស់ បានជាគ្មានពេលសរសេរសំបុត្រមកអ្នកមិនបាន ម៉្យាងទៀត តែ ២ ថ្ងៃទៀត គេនឹងត្រឡប់មកវិញហើយ អ្នកព្រួយធ្វើអ្វី ? យើចុះក្រុងស៊ីកីធោតម៉្ទេះ យំអស់ទឹកភ្នែកសន្ទឹកឥតប្រយោជន៍ ឈប់គិតរឿងផ្តេសផ្តាសនោះទៅ ញញឹមដាក់បងមួយឱ្យយ៉ាងស្រស់មកមើល៍ ម៉េចមិនទាន់ព្រមបាត់ចិត្តនឹងកមេស្ហទេឬ ? . . . ៗ

នាព្រឹកនោះ នាងសិលាប្រញាប់សរសេរសំបុត្រមួយទៅឪពុក

នាងក្វាម ៖

លោកឪពុក នាងកាមាលាស្រងូតស្រងាត់ខ្លាំងពេកណាស់ ដោយកាមេស្ហមិនព្រមសរសេរសំបុត្រមួយទៅនាងសោះ យើងគួរគិតថា បើប្រសិនជារូបយើងវិញតើយ៉ាងណា បើយកគ្នាទៅពោលក្នុងចំណោមមនុស្សដែលជាអ្នកដទៃទាំងអស់ ហើយទៅបាត់គ្មានឲ្យដំណឹងបន្តិចសោះយ៉ាងនេះ សុំពុកប្រាប់កាមេស្ហថាបើគិតការអ្វី គិតឲ្យឆាប់ៗ ទៅទំងអាលត្រឡប់ទៅផ្ទះ កុំឲ្យនាងទន្ទឹងខ្លាំងពេក ម្យ៉ាងទៀតពុកជួយគិតមើលមើល៍ មានអ្នកខ្លះគេរវល់ជាងកាមេស្ហនេះទៅទៀត ក៏គេឆ្លៀតសរសេរសំបុត្រទៅប្រពន្ធគេកើត ចុះរវល់យើងនេះអ៊ីក៏ជាងគេម៉្លេះ ?

លុះឪពុកនាងសិលាទទួលបានសំបុត្រ គាត់ទៅជួបកាមេស្ហ ហើយក៏បាននិយាយបន្ទោសអ្នកជាច្រើន អំពីរឿងដើរពោលប្រពន្ធមិនឲ្យដំណឹង ។

ប៉ុន្តែបើនិយាយឲ្យសុចរិតទៅវិញអាះ គឺថាកាមេស្ហគ្មានភ្លេចនាងកាមាលាមួយនាទីណាសោះទេ ប៉ុន្តែ បញ្ហានាងកាមាលាទីងអ្នក ក៏ស្មុគ្រស្មាញពេក រាយមិនបែកសោះ បានជាគ្នាលេបទុកទៅ ។

ការដែលនាងសិលានិយាយថា នាងកាមាលាពិបាកចិត្តខ្លាំងណាស់ ព្រោះបាត់កាមេស្ហសូន្យ គឺជាការពិតណាស់ ប៉ុន្តែកាមេស្ហនៅតែកកែក ហាក់ដូចជាមនុស្សម្នាក់ដើរមកដល់ផ្លូវបំបែក ហើយមិនដឹងជាណានៈទៅ

ផ្សំណា ឲ្យបានជួបនឹងសេចក្ដីសុខ ៗ តែម្ដងនេះ គេលែងកកែចិត្តទៀតហើយ គេប្ដេជ្ញាក្នុងចិត្តគេថា ត្រូវតែធ្វើដូចម្ដេចឲ្យនាងកាមាលាបានទទួលសុភមង្គល ៗ ជាព្រហ្មលិខិតមិនគ្រាន់តែបានបងជីវិតនាងនិងជីវិតអ្នកភ្ជាប់គ្នាទៅហើយទេ ថែមទាំងបងបេះដូងអ្នកភ្ជាប់នឹងបេះដូងនាងកាមាលាផង ៗ កាមេស្សរសម្រេចចិត្តដូច្នេះហើយ ក៏ទាញដងប៉ាក-កាយកសរសេរសំបុត្រមួយដោយផ្ចិតផ្ចង់ទៅនាងកាមាលា :

"កាមាលាជាទីស្រឡាញ់ !

សូមប្អូន កុំទុកពាក្យខាងលើនេះ ជាបេនាបទ សម្រាប់ប្រារព្ធប្រើក្នុងសំបុត្រធម្មតាឲ្យសោះ ព្រោះថា បើអូនមិនមែនជាថ្មីមប្រមាត់របស់បងទេ បងក៏មិនយកពាក្យនេះមកប្រើចំពោះអូនដែរ ៗ បើប្រសិនជាអូនពុំជឿ ឬពាក្យដែលបងសរសេរនេះមានពាក្យណាធ្គាំធ្គង ធ្វើឲ្យអូនអាក់ចិត្តដោយបងគ្មានចេតនា សុំឲ្យពាក្យដែលបងសរសេរចេញពីដួងចិត្តដ៏ស្មោះរបស់បងនេះ ក៏បាត់នូវក្ដីសង្ស័យនឹងហើយក្លាយទៅជាសំពត់រុំស្រោបមុខរបួសដែលបងបានធ្វើឲ្យអូនឈឺចាប់ទៅវិញ ដូចសេចក្ដីបងប្រាថ្នា ៗ

:ឡូវនេះ តើយើងនៅរំលាក់លៀមដល់ណាទៀត ?

អាកប្បកិរិយាបងចំពោះអូនតាំងពីមុនមក បានធ្វើឲ្យអូនពិបាកចិត្តជាច្រើន បងក៏ដឹងដែរ តែបើអូននៅតែប្រកាន់ទឹងទឹងបងតទៅទៀត បងនឹង

អាចបានវែកញែកឲ្យឃើញ នូវចិត្តដ៏បរិសុទ្ធរបស់បងចំពោះអូនហើយ ។ ក្នុងខណៈនេះ បងគ្មានពាក្យអ្វីផ្សេងប្រាប់អូន ក្រៅអំពីនិយាយដដែលថា: អូនជាទីស្នេហាបំផុតរបស់បងប៉ុណ្ណោះទេ ហើយនឹងថា បងគ្មានស្រឡាញ់ស្រីឯណាក្រៅឲ្យលើសនឹងរូបអូនឡើយ ពិតមែនហើយតែការដែលបងនិយាយតាំងប៉ុន្មានឆ្នាំនេះ មិនអាចជាការដោះសាជួនលម្អនឹងអំពើឆ្គាំឆ្គងយ៉ាងច្រើន ដែលបងបានធ្វើចំពោះអូនតាំងពីនោះមកទេ ប៉ុន្តែបងមានតែពាក្យប៉ុណ្ណោះ ដើម្បីនឹងបញ្ចេញជាដំបូងជូនអូន ។ ដូច្នេះកាមាលាអូន កាលដែលបងហ៊ានបញ្ចេញពាក្យហៅអូនថា "អូនជាទីស្រឡាញ់"នេះ គឺបងមានបំណងនឹងដាក់ក្រដាសជក់ទឹក ឲ្យស្រូបយកអតីតកាលដ៏ល្អក់ឲ្យអស់ចេញ ហើយដាក់ថ្មផ្ញើគ្រឹះល្អឲ្យមាំសម្រាប់ស្នេហារវាងយើងទាំងពីរនាអនាគតដ៏ខ្លី ។

សូមអូនជឿជាក់ថា បងនឹកតែរូបអូនមួយជានិច្ច គ្មានភ្លេចមួយវេលាណាទេ គឺរូបអូននេះហើយ ដែលជាស្នេហាចំណូលចិត្តនៃបង បើអូនសុខចិត្តឲ្យបងបញ្ជាក់សុភាពឲ្យជាក់ច្បាស់ អនាគតយើងនឹងបានក្ដីសុខ ហើយប្រកបដោយសុភមង្គលផង តែបងចង់ដឹងតទៅទៀតថា តើអូនមានចិត្តស្រឡាញ់បងផងដែរឬទេ ? បញ្ហាស្នេហាទោះហើយ បងមានសង្ឃឹមថា ថ្ងៃណាមួយបងនឹងបានទទួលចម្លើយស្របតាមបំណងរបស់បងមិនខានឡើយ ។ យើងមិនបានបរិយាយដោយពាក្យសំដីមែន

តែយើងបានទុកជូនវិញណាយើង ឲ្យប្រាស្រ័យទាក់ទងគ្នាជាយូរមក ហើយ ការដែលធ្វើឲ្យបងហ៊ានពោលច្បាស់យ៉ាងនេះ គឺមកពីបងស្រឡាញ់អូនពិត ៗ

បងមិនហ៊ានលើកខ្លួនបងថា ជាបុរសមួយរូបគួរជាទីស្នេហារបស់អូនទេ តែបងនឹកថា ការដែលបងស្រឡាញ់អូនដល់កម្រិតនេះ មិនសមបើនឹងឥតអំពើសោះ ៗ

សំបុត្រដែលបងសរសេរនេះ មើលឲ្យសព្វៗទៅហាក់ដូចជាគេសរសេរសៀវភៅរឿងយ៉ាងផ្ចិតផ្ចង់ ហេតុនេះហើយបានជាបងនឹកអៀនបង់តែហែកចោល ប៉ុន្តែបើមិនសរសេរដូច្នេះទេ តើសរសេរអ្វីទៅវិញ ដើម្បីនឹងបញ្ចេញមនោសញ្ចេតនារបស់បងកើត ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយសំបុត្រទី ១ ដំបូងមិនអាចនឹងថ្លែងឲ្យអស់ការរបស់អ្នកសរសេរបានទេ ៗ កាលណាចិត្តអូនទទួលមូលនឹងបងហើយនោះ ទើបបងអាចសរសេរការសំខាន់ៗទៀតបាន គឺថាទាល់តែទ្វារបន្ទប់ទាំងឡាយបើកចំហរអស់ហើយ ទើបខ្យល់អាកាសបក់ចេញចូលបានដោយសេរី កាមា-លាអូន រូបបងក៏ប្រៀបបាននឹងខ្យល់នោះដែរ តើកាលណាទៅអូន ! បងនឹងបានយល់នៃទ្វារបេះដូងអូនបើកចំហរចាំរូបបង ? . . . ៗ

យូរពេលបន្តិចទៅទៀតហើយមើលទៅ . . . ៗ

បង្ខំពាក្យក៏នាំឲ្យខូចការដែរ ស្អែកនេះបងនឹងត្រឡប់ទៅភ្នាស៊ី

បូរីញ ហើយបងសុំឲ្យអូននៅរង់ចាំបងនៅឯផ្ទះយើងកុំខាន ៗ តាំងពីយូរណាស់មកហើយដែលយើងទាំង ២ រូបគ្មានផ្ទះសម្បែងនឹងគេ បងនឹងត្រាំនៅជួលបន្ទះគេទៅទៀតមិនបានឡើយ ឥឡូវនេះបងសង្ឃឹមថា ទោះជាយ៉ាងណាក៏បងមានផ្ទះមួយនៅនឹងគេដែរ ហើយមានរូបអូនជាទីស្នេហានៅគ្រប់គ្រងផ្ទះនោះផង ៗ នៅពេលដែលបងទៅដល់ផ្ទះ បងរីករាយណាស់នឹងបានទទួលកែវភ្នែកអូនទាំងគូរ ប្រកបដោយសេចក្ដីសុខក្សេមក្សាន្ត ៗ

អូននឹកឃើញទេ នៅរាត្រីមួយដែលយើងទាំង ២ នាក់ គេងជិតគ្នានៅលើផ្នូកខ្សាច់នាឆ្នេរទន្លេគង្គា ដែលមានតែផ្ទៃមេឃជាដំបូល សូម្បីតែស្រមោលដំបូលផ្ទះមួយក៏គ្មាន មនុស្សម្នាក់ក៏គ្មាននៅក្បែរយើង .. តែបងនឹកដល់រឿងនេះកាលណាឡើង ហាក់ដូចជាបងបានយល់សប្ដិតែម្ដងនេះ បងនឹងទទួលកែវភ្នែកអូន នៅពេលពេញស្មើនៃទិវានៅក្នុងរង្វង់ជញ្ជាំងបួន ដែលបងអាចចាប់កាន់នូវវត្ថុធាតុបានដោយផ្ទាល់ដៃស្រស់ៗ បងនឹងយល់ក៏ក្រដាំប្រិមប្រិយរបស់អូននៅរង់ចាំបងនៅមាត់ទ្វារ ៗ អូនកាមាលា បងជាស្វាមីយាយចកមួយរូប ដែលចូលទៅសុំទានស្នេហានៅមាត់ទ្វារនៃបេះដូងរបស់អូន សុំអូនកុំបណ្ដេញបងឲ្យថយចេញទៅទាំងដៃទទេ ព្រលឹងបង ?

កាមស្ហូដែលស្មោះចំពោះអូន ៗ

## វគ្គទី ៣៧

ស្អែកឡើង ដោយឃើញមុខនាងកាមាលាចេះតែស្រងូតស្រងាត់ នាងសិលាក៏សួរ :

— មិនទៅផ្ទះឯបឹងកាឡូទេឬ ? ហើយបើបងឲ្យរបស់អូនឯងមួយ អូនឯងឲ្យអីបងវិញ ?

– ខ្ញុំឥតទៅទេ ព្រោះឥតមានការអ្វីធ្វើ ហើយម្យ៉ាងទៀតខ្ញុំគ្មានរបស់អ្វីជូនបងវិញទេ ។

— ឥតមានឥវែនឬ ?

– ព្រោះអូនបានឲ្យអ្វីៗទៅគេដទៃអស់ហើយ ។

– ចុះម៉េចអ៊ីចឹង ?

នាងសិលានិយាយបណ្ដើរ ទាញសំបុត្រមួយចេញពីក្នុងអាវមកបណ្ដើរ នាងកាមាលាក្រឡេកឃើញសំបុត្រឡើងទឹកមុខសស្លាំង រួចងាកមុខចេញផាំង នាងសិលាតាប់ផាប់ ។

— នែកុំក្រអឺតដល់ណាទៀត ធ្វើបុកអ្វីក៏ធ្វើម្ល៉េះ ? បើថាបងកន្ត្រាក់សំបុត្រពីដៃបងក៏កន្ត្រាក់ទៅ ប៉ុន្តែនិយាយសុំបងឲ្យស្រួលមក បានបងឲ្យបងចង់ដឹងថាតើបុកខែងរបស់ នៅបានយូរប៉ុន្មានពេលទៅទៀត ?

នៅពេលនោះ នាងអ៊ូមីដើរចូលមកក្នុងបន្ទប់ កាន់ខ្សែអូសប្រអប់សាប៊ូមួយចូលមកផង ហើយស្រែកហៅនាងកាមាលាថា : មីង ! មីង !

នាងស្ទុះទៅលើកកុមារីបីឡើង ហើយថើបញីញក់ នាងអ៊ូមីរបូតខ្សែចង ប្រអប់សាប៊ូពីដៃ ទធាក់ដៃទធាក់ជើងដើម្បីឲ្យរួចអំពីដៃនាងកាមាលា តែនាងកាមាលាមិនលែងសោះ នាងឧបកុមារីដើរចូលរហូតទៅបន្ទប់មួយទៀតរួចទើបលួងលោមកុំឲ្យយំ ។

នាងសិលាដើរចូលទៅតាមបន្ទាន់ៗគ្នា :

— ណ្ហើយ! កាមាលា បងសុំតាញអូនឯងហើយកុំបាច់ធ្វើថែមទេ! យកសំបុត្រអូនឯងទៅ បងឈប់និយាយលេងទៀតហើយ ថាហើយនាងបោះសំបុត្រទៅលើគ្រែ ហើយក៏លើកកូនពារចេញទៅ ។

នាងកាមាលាចាប់សំបុត្រនោះមក មើលចុះមើលឡើងមួយសន្ទុះ ទើបដាច់ចិត្តហែក ។ នាងទើបនឹងមើលបាន ៣-៤ បន្ទាត់ក៏ស្រាប់តែខឹងឡើងមុខក្រហម ហើយក្រវាត់សំបុត្រចោល តែមិនយូរប៉ុន្មានទេ នាងទៅរើសសំបុត្រនោះមកវិញ ហើយមើលទាល់តែចប់សេចក្តី ។

យើងពិបាកនឹងយល់ណាស់ថា តើនាងកាមាលាយល់ចិត្តរបស់ក-មេស្ហឬមិនយល់ ប៉ុន្តែនាងហាក់ដូចជាខ្ពើមសំបុត្រ ដែលនាងកាន់នៅដៃ ការដែលកមេស្ហសរសេរមកសុំនាង ធ្វើជាមេផ្ទះនៅពេលនេះ ហាក់ដូចជាសរសេរមកជេរប្រមាថនាង ព្រោះខ្លួនដឹងប្រាកដ ហើយថានាងជាប្រពន្ធបុរសមួយដទៃទៀតទេ ឯចំណែកនាងវិញកាលដែលនាងមានចិត្តត្រេកអរនឹងបានជំបូលមួយ ជ្រកតែ ២ នាក់នឹងកមេស្ហ នៅគ្ហាស៊ីបូរនេះ

ក៏នាងមិនបានដឹងថា កាមេស្ហនេះមិនមែនជាប្ដីនាងដែរ នាងស្មានតែគេនេះហើយដែលជាប្ដី ដែលម្ដាយមីងបានរៀបការឲ្យនាង ។

នាងនឹកថា កាមេស្ហដែលសរសេរមកសុំនាងធ្វើជាប្រពន្ធនេះ មិនគឺអ្វីក្រៅអំពីការគណិតគាសូរ នាងដែលជាស្រីកំព្រាប៉ុណ្ណោះ ។ នាងនឹកស្ដាយនឹងអំពើ ដែលនាងបានធ្វើចំពោះកាមេស្ហ ដោយការភ័ន្តច្រឡំ នាងនឹកខ្មាសគៀនមួយជីវិត ពោះជាតាំងពីតូចមកនាងមិនដែលបានធ្វើអ្វីខុសក៏ដោយ ។

ម្យ៉ាងទៀតផ្ទះដែលនាងចង់ប្រាថ្នាមកយូរហើយនោះ ឥឡូវនេះទៅជារូបចម្លែកមួយ គួរឲ្យខ្លាចប៉ុន្តែនាងមិនដឹងជាគេចទៅទីណា ឲ្យផុតអំពីកណ្ដាប់ដៃរសោះ . . .

សម្លេងអ៊ុយមេស្ហក្អកខេះៗ ទាញអារម្មណ៍នាងកាមាលា ដែលកំពុងតែអណ្ដែតតាំងខ្លាចផ្សារ តែនាងមិនងាកមុខមកសោះ អ៊ុយមេស្ហចាំយូរពេក ក៏ប្រថុយហៅនាង នាងដើរមក អ៊ុយមេស្ហនិយាយៈ

– ម៉ែ សុំខ្ញុំបាប៉ាបានទៅជួលពួកល្ខោនមកលេងកំដរការកូនស្រីគាត់ ។

– ហ្នឹងហើយអ៊ុយមេស្ហ ឯងទៅមើលល្ខោននឹងគេចុះណ៎ា ។

សប្បាយចិត្តណាស់ អ៊ុយមេស្ហត្រឡប់ ក្រោយភ័ន្តមួយរំពេច តែនាងកាមាលាហៅគេវិញ :

-នែ! ទៅមើលល្ខោន យកលុយទៅផង ទៅឃើញនាងកាមាលា ឲ្យលុយវា ក្មេងនោះទឹកចូល ព្រោះល្ខោនលេងឲ្យមើលជាសាធារណៈទេតើ មានទិញសំបុត្រចូលឯណា ?

- ម៉ែ! តើលុយនេះសម្រាប់ទិញអ្វី ?

-ទេ! យកទៅ ក្រែងត្រូវការ .... រូបចើងស្បៀកពាក់បែបទំនើង អ្នកផងគេថាយ៉ាងម៉េចទៅ ?

ប៉ុន្តែអ៊ុយមេស្ហមិនដែលរវល់ទឹក អំពីរឿងសម្លៀកបំពាក់វាម្តងណាឡើយ លុះនាងកាមាលារំឭកអំពីរឿងខោអាវ វាគ្រាន់តែញញឹមធ្វើវាហ៊ី . . . ។ នាងកាមាលាហុចក្រមាមួយមានផ្កាធំៗ ឲ្យអ៊ុយមេស្ហរុំខ្លួន ព្រោះក្រមានេះស្រីក៏ប្រើបាន ប្រុសក៏ប្រើបាន អ៊ុយមេស្ហពេញចិត្តណាស់ ស្ទុះទៅឱបជើងនាងកាមាលា ដើម្បីសម្តែងអំណររបស់ខ្លួនហើយរត់ចេញទៅ ។

អ៊ុយមេស្តចេញផុតទៅ នាងកាមាលាទឹកសង្វេគ បន្ទូរទឹកក្អែកតែម្នាក់ឯង ពេលនោះនាងសិលាចូលទៅដល់ ។

- កាមាលា គួនឲ្យសំបុត្របង៉ះមើលផងបានឬទេ ?

( នាងហ៊ានសួរដូច្នេះ ព្រោះអាងធ្លាប់ទុកចិត្តនាងណាស់ នាងមិនដែលមានអាថ៌កំបាំងអ្វីរវាងគ្នាឡើយ ) ។

នាងកាមាលាចន្ទុលប្រាប់ . . .

– ន្ន៎ ! សំបុត្រអ្នកបង ខ្ញុំគ្រវាត់ចោលនៅនោះ អ្នកបងមើលចុះ

នាងសិលាមើលបណ្ដើរ ទឹកក្នុងចិត្តបណ្ដើរ ។

(ចុះនាងកាមាលាខឹងស្អើកយូរម្ល៉េះ? មួយទៀត សេចក្ដីក្នុងសំបុត្រនេះសុទ្ធតែពាក្យផ្អែមដូចជាមនុស្សទើបនឹងស្រឡាញ់គ្នាដំបូង ? ប៉ុន្តែបើប្ដីសរសេរមកប្រពន្ធខ្លួនបែបនេះ ដូចជាគួរឲ្យចង់សើចណាស់ នាងទឹកធ្លាក់ស្លុតទៅនាងកាមាលា) ។

– អូនកាមាលា ប្ដីអូនធ្លាប់សរសេរប្រលោមលោកឬ ?

(គ្រាន់តែឮពាក្យថាប្ដី នាងភ្ញាក់ព្រើត)

– ចា៎ស ! ខ្ញុំមិនបានដឹងដែរ អ្នកបង ។

ចុះអូនឯងរៀបទៅផ្ទះដែលអូនរៀបចំឥឡូវនេះឬ ?

– នាងកាមាលា មិនឆ្លើយទេ គ្រាន់តែងក់ក្បាល ។

ប៉ុន្តែនាងសិលាជាអ្នកនិយាយច្រើន ក៏ចេះតែនិយាយថែមទៀត?

– បងចង់ទៅនៅលេងជាមួយអូនមួយថ្ងៃ តែខាស់មានគេអញ្ជើញទៅអាពាហ៍ពិពាហ៍ខានមិនបាន មិនអីទេ ចាំបងឲ្យម្ដាយបងទៅតាមអូន?

– ចុះអ្នកបងចាំឲ្យអ្នកមីងរវល់នឹងខ្ញុំធ្វើអី នៅផ្ទះឯនោះ គ្មានអ្នកបម្រើទេឬ ?

នៅពេលនោះ នាងគួរមិនកើតបានឡើងវិញមួយ ក៏តាំងតែគួរកាសៀវដែលនៅជិតដៃនាង ហើយនិយាយខ្លាំងៗ ដូចជាក្មេងរៀនអក្សរដំបូង ។

នាងសិលាចុញទឹងកូនពីសពេក ទៅយកទៅដៃចេញ នាងអ៊ូមីចិង ណាស់ ស្រែកយំអស់ទំហឹង នាងកាមាលាស្ទុះទៅលួង លើកកុមារី ឡើង យកទៅដាក់ឲ្យអង្គុយលើគ្រែ ហើយដោះកងមាស ១ គូពាក់ឲ្យ នាង ។ កុមារីសប្បាយចិត្តណាស់ សើចទាំងទឹកភ្នែករហាម ហើយ លើកដៃបង្ហាញម្ដាយ ។ នាងសិលាស្ទុះទៅដោះកងពីដៃកូន យកមកឲ្យ នាងកាមាមាវិញ ហើយបន្ទោសនាងថា :

– នែ ! ប្រយ័ត្នបាត់ណា កុំបណ្ដោយឲ្យក្មេងលេងរបៀបនេះ ។

– ខ្ញុំឲ្យទៅគេទេតើ (នាងនិយាយបណ្ដើរលួងកុមារីដែលស្រែកយំ ស្អើរបែកក្រដាសត្រចៀកបណ្ដើរ)

– ទេ ខ្ញុំមិនយកវិញទេ អ្នកបងកាត់កងទៅ អ្នកបងអាចធ្វើជាកងក ក៏បាន ។

– យី ! កាមាលា បងមិនដែលឃើញអ្នកណាដូចអូនសោះ បងសុំ អរគុណអូន ។

– អ្នកបង ! ខ្ញុំសុំលាអ្នកបងហើយ ថ្ងៃនេះខ្ញុំបានរស់នៅជាមួយ អ្នកបង ប្រកបដោយសេចក្ដីសុខសប្បាយគ្រប់យ៉ាង ។

(ថាតែប៉ុណ្ណោះ ទឹកភ្នែកហូរច្រោក ធ្វើឲ្យនាងរលួលដើមកនិយាយមិន រួច នាងសិលាក៏ទប់ទឹកភ្នែកមិនបានដូចគ្នា) ។

– អូនកុំនៀននិយាយលា ដូចជាគេទៅលែងមកវិញយ៉ាងនេះ ខ្ញុំមិន

ជឿថាយើងទាំងអស់គ្នា ធ្វើឲ្យអូនបានសប្បាយគ្រប់យ៉ាងដូចពាក្យអូនថាទេ ប៉ុន្តែឥឡូវនេះ អូនត្រូវចូលទៅនៅក្នុងផ្ទះរបស់អូន ក្ដី ៗ ទាំងប៉ុន្មាន ក៏ត្រូវតែស្រួលជាងនៅផ្ទះបងហើយ ចាំយើងនាំគ្នាទៅលេងនឹងអូនញយ ៗ តែបន្តិចមុខជាអូនធុញថា "ពុទ្ធោអើយគេមិនទៅផ្ទះគេវិញទេ ឬយ៉ាងម៉េច ? " មិនអីទេអូនស្អែកព្រឹក យ៉ាងយូរថ្ងៃត្រង់បងទៅដល់ផ្ទះអូនហើយ ។

នាងកាមាលាស្ដាប់ហើយ ក៏នៅស្ងៀម ។

លុះនាងកាមាលាទៅដល់ផ្ទះថ្មី អ៊ុយមេស្ហនៅអង្គុយចាំនាងស្រេចទៅហើយ ។

— ឯងនៅទីនេះនៅឡើយទេ ? ក្រែងទៅមើលល្ខោនឬ ?

— ខ្ញុំទៅមើលទៅហើយ តែលុះខ្ញុំដឹងថាម៉ែមកផ្ទះនេះ . . . . . .

— ទៅ ! ទៅ កុំព្រួយរឿងម៉ែអី មានបោយគេនៅបម្រើហើយ ប្រញាប់ទៅ តិចគេលេងល្ខោនហោល . . . . .

លុះអ៊ុយមេស្ហរៀបដើរចេញទៅ នាងផ្ដាំថា:

— ហ្ន ! អ៊ុយមេស្ហ បើលោកមាឯងត្រឡប់មកវិញ ឯង . . . .
(នាងមិនដឹងជាគិតចង់ផ្ដាំថាដូចម្ដេច អ៊ុយមេស្ហក៏បង្អង់ចាំស្ដាប់ចំហរមាត់ជុង ៗ )

— លោកមាជាមិត្តល្អមួយរបស់ឯងណា៎ បើឯងមានការអ្វី និយាយ

ប្រាប់គាត់ទៅ បើឯងស្រឡាញ់ម៉ែ គាត់ច្បាស់ជានឹងជួយដោះទុក្ខឯងមិនខាន ហ្ន៎ ! ចូរឯងកុំភ្លេចប្រាប់គាត់ថា ម៉ែស្រឡាញ់គាត់ណាស់ពុះទេ !

— ខ្ញុំមិនភ្លេចទេម៉ែ ! ថាតែប៉ុណ្ណោះអ៊ុយមេស្ហូចង្ហិលកែងរត់រឹង គ្មានបានយកចិត្តពិចារណាអំពីសម្ដីនាងកាមាលាផ្ដែផ្ដាំនោះសោះ ។

ពេលរសៀលនាងកាមាលាហៅអ្នកបំរើមកប្រាប់ :

— នែ ! ខ្ញុំទៅផ្លូតទឹកឯកំពង់ ឯងមិនបាច់ទៅតាមខ្ញុំទេ មើលតែផ្ទះឲ្យត្រឹមត្រូវទៅ ។

ថាហើយនាងហុចប្រាក់មួយរៀលទៅឲ្យ អ្នកបម្រើ រួចចុះដើរតម្រង់ទៅកំពង់ទឹក . . . ។

(នៅមានត)

# ប្រវត្តិគ្រូឡើងរោង ហៅ គ្រូភ្លេង
## នៅកំពង់ចាម

---

តាមពត៌មានដែលសមាជិកប្រចាំខេត្តកំពង់ចាមឈ្មោះ ចាំយ-ជេងគួ បានឲ្យដំណឹងមកក្រុមជំនុំទំនៀមទម្លាប់ខ្មែរថា នៅថ្ងៃ ១៤ រោច ខែភទ្របទ ឆ្នាំរកា ត្រូវនឹងថ្ងៃទី ១១ ខែតុលា ឆ្នាំ ១៩៦៩ នេះ នៅផ្ទះគ្រូ ង៉ុយ ហៅគ្រូភ្លេង មានធ្វើពិធីឡើងរោងមួយយ៉ាងធំ ។ សមាជិកក្រុមទំនៀមទម្លាប់បាននាំគ្នាទៅយកការណ៍ដល់ទីកន្លែង ដូចមានសេចក្ដីរាយការណ៍ខាងក្រោម :

ក្រុមទំនៀមទម្លាប់បានទៅដល់ក្រុងកំពង់ចាម តាំងតែពីល្ងាចថ្ងៃព្រហស្បតិ៍ទី ៩ ខែតុលា ១៩៦៩ ។ លុះព្រលឹមថ្ងៃទី ១០ តុលា យើងខ្ញុំបានទៅដល់ផ្ទះលោក ចាយ-ហាម នៅកំពង់ចាមក្រុង ។

លោក ចាយ-ហាម មានកូន ៥ នាក់ កូនទី ១ ប្រុស កូនទី២ កើតមកភ្លោះ ប្រុសមួយស្រីមួយ នៅរស់ទាំង ២ នាក់ កូនប្រុសភ្លោះនោះឪពុកឲ្យឈ្មោះ ចាយ-គិមហុង ហៅ " ង៉ុយ " សព្វថ្ងៃមានអាយុ ២៨ ឆ្នាំ ។ បងប្អូន ៤ នាក់ទៀតរបស់ ង៉ុយ មានផ្ទះសម្បែង ហើយបែកទីលំនៅតែសព្វខ្លួន ។ ង៉ុយ នេះបានរៀននៅសាលាបឋមសិក្សា រួចមធ្យមសិក្សា ដល់ថ្នាក់ទី ១ តែឆ្នាំនេះត្រូវឈប់ដោយមានការមមាញឹក

ទឹងសង្គ្រោះអ្នកផង ដែលចេះតែមករកទាំងថ្ងៃទាំងយប់ ។

ដោយឃើញគ្រូជុំយ មានវ័យក្មេងហើយចេះរៀបណ្ដាប់គ្រឿងបូជា គ្រឿងសំណែន តាមប្រពៃណីបុកណសមរម្យពេក យើងទឹកខ្ញុំក៏សួរថា ៖

–លោកគ្រូ លោកគ្រូម្ដេចមិនគិតរៀនសូត្រទឹងគេ បានជាមកធ្វើគ្រូស្ដោះព្រួសនេះទៅវិញ ហើយលោកគ្រូចេះរៀបចំតាមប្រពៃណីបុកណនេះពីអ្នកណា ? លោកចាប់ធ្វើគ្រូតាំងពីអាយុប៉ុន្មាន ?

គ្រូជុំយ ងាកមើលមុខឪពុក ដែលអង្គុយនៅក្បែរបង្អួច រួចក៏ធ្វើសញ្ញាឲ្យយើងខ្ញុំដើរតាមគាត់ទៅក្រោយ ទៅក្បែរកោសនៈព្រះពុទ្ធរូប រៀបកន្ទេលឲ្យយើងខ្ញុំអង្គុយស្រួលបួលហើយ ក៏ចាប់ផ្ដើមនិយាយ នៅពេលនោះ ពួកសិស្សគណរបស់គាត់កំពុងតែមូរបាយសី ធ្វើជម ធ្វើផ្កាស្លឹកត្នោត អ្នកខ្លះចំអិនបាយក្បៀរ អ្នកខ្លះវេញខ្សែចង្កេះ ។ល។ គ្រូជុំយបង្គាប់ការឲ្យគេធ្វើបណ្ដើរ និយាយរឿងប្រាប់យើងខ្ញុំបណ្ដើរ ។

" កាលខ្ញុំបាទទើបទឹងបានអាយុ ១១ ឆ្នាំ ខ្ញុំបាទចេះតែឈឺ ទៅរៀនសូត្រស្ទើរមិនកើត តែដោយឪពុកខ្ញុំបាទគាត់បង្ខំពេកក៏ចេះតែទៅ ។ ថ្ងៃមួយ ខ្ញុំបាទឈឺនោះខ្លាំងមែនទែន ឈឺយូរទាល់តែជ្រុះសក់ក្បាលនៅរ៉ុយ ។ ឪពុកម្ដាយទឹងបងប្អូនខ្ញុំបាទទាំងអស់ចាញ់ចំណោះរង់ចាំតែពេលស្លាប់ ព្រោះខ្ញុំបាទដាច់អាហារច្រើនថ្ងៃហើយ ។ នៅពេលដែលខ្ញុំបាទ

ហៅបាយខ្លាំងពេកនោះ ស្រាប់តែចេញខ្យល់ពីត្រចៀកវែង ក៏និមិត្តឃើញ



តាចាស់ម្នាក់ផុះពុកចង្កាវែង ដូចរូបខាងលើនេះឯង ស្លៀកសពាក់ស ជួតក្បាលជាតីក្រហម ជិះទូកកំប៉ុតក្បាលមក មានយាយចាស់ម្នាក់ ស្លៀកសពាក់សដូចគ្នា អណ្ដើយពីក្រោយមកដល់ចំពោះមុខខ្ញុំបាទ ស្រាប់តែយកប្រវមកសំពងក្បាលខ្ញុំបាទ ៣ ដង ហើយនិយាយចង្អុលមុខខ្ញុំបាទ ថា «ឯងមានទំនាយត្រូវធ្វើគ្រួសគ្រោះគេឯង ត្រូវទទួល តែមិនទទួល

យើងយករូបឯងឥឡូវ ម្យ៉ាងទៀត គេចាត់យើងឲ្យទៅមើលកន្លែងដទៃទៀតហើយ យើងឈប់ថែរក្សាកំណប់ព្រេងរបស់ឯងទៀតហើយ ឯងត្រូវទៅយកមកថែរក្សាខ្លួនឯងចុះ" ឮដូច្នោះ ខ្ញុំបាទសួរថា ៖ លោកជាអ្វី បើឲ្យខ្ញុំទៅយក ធ្វើម្តេចខ្ញុំនឹងដឹងកន្លែង ?

— យើងជាអ្នកសច្ចំ ឯកំណប់របស់ឯងនោះ នៅក្នុបាលីចាស់ កាលណាឯងទៅយកត្រូវទៅពេលថ្ងៃលិច យកចបតូចមួយទៅផង ឯងត្រូវទៅតែម្នាក់ឯង កុំយកអ្នកណាទៅជាមួយឲ្យសោះ កុំភ័យគ្មានអ្នកណាធ្វើអ្វីឯងទេ តែកាលណាឯងទៅដល់ ឯងស្គាល់កន្លែងរបស់ឯងតែម្តង ឯងត្រឡប់ទៅរកម៉ែ-ឪឯងវិញចុះ ផឹកតែទឹកត្រាំផ្កាម្ទះទៅជាហើយ" ថាតែប៉ុណ្ណោះ លោកតានោះក៏អន្តរធានទៅ ខ្ញុំបាទដឹងស្មារតីឡើង ឃើញបងប្អូនយំរហាមគ្រប់គ្នា គេស្មានថាខ្ញុំបាទអស់បានជាមនុស្សម្នាទីងគេហើយ ព្រោះសន្លប់បាត់មាត់បាត់ក ៣ ថ្ងៃ ៣ យប់ តែខ្លួននៅក្តៅ ទើបគេមិនទាន់ហ៊ានយកទៅណាមកណា បេះតែនាំគ្នាចាំមើល ៗ លុះខ្ញុំបាទដឹងខ្លួនឡើង ខ្ញុំបាទនិយាយប្រាប់ ម្តាយខ្ញុំបាទព្រមទាំងគ្រួសារ គេក៏នាំគ្នាធ្វើពិធីបន់ស្រន់ ព្រមព្រៀងឲ្យខ្ញុំបាទធ្វើគ្រូចុះ ឲ្យតែជាសះស្បើយបានព្រលឹងសម្បូរមកវិញ ៗ

ចាប់តាំងពីពេលនោះមក ខ្ញុំបាទបេះតែទទួលទានទឹកផ្កាម្ទះគ្មានថ្នាំសង្កូវអ្វីក្រៅសោះ តែទទួលទានបូលៈទាកាលណាក៏បេះតែមានកម្លាំង

បីដូចបានអាហារពេញពោះ ខ្ញុំបាទក៏បេះតែបានរើប ៗ ឡើង លុះត្រាបានដើរ អន្ទុយ ដូចធម្មតា ៗ ប៉ុន្តែយប់ណាក៏ដូចយប់ណា តែកាលណាខ្ញុំបាទទទួលទានដំណេក ពេះតែឃើញយាយតាស់-តាតាស់ដដែលនោះ មកពន្យល់ឲ្យខ្ញុំបាទឲ្យធ្វើគ្រូសង្គ្រោះគេ និងប្រើខ្ញុំបាទ ឲ្យទៅយកកំណប់ព្រេង ៗ

គន្លងប្រហែលជាមួយខែក្រោយអំពីថ្ងៃដែលសប្តិនោះមក ខ្ញុំបាទដឹងគន់ខ្លួនថាខ្ញុំជាមែនទែន ៗ ថ្ងៃមួយនៅពេលថ្ងៃលិច ខ្ញុំបាទកាន់ចបមួយតូច ដើរតម្រង់ទៅភ្នំបាលីបាស់ តាមការណ៍ដែលអ្នកសប្ដិបានមកប្រាប់សព្វគ្រប់ ៗ ទៅដល់កន្លែងមួយនោះ គ្រាន់តែក្រឡេកឃើញភ្នំ ហាក់ដូចជាប្រាកដក្នុងចិត្តថា « នេះហើយ ដែលជាកន្លែងកំណប់ព្រេង » ទីកតែប៉ុណ្ណោះ កំតាំងជីកមួយរំពេច ជីកបានជម្រៅប្រមាណជាមួយចំអាមប៉ុណ្ណោះ ប៉ះលើតម្របពាងមួយឮសូរផ្ទះ ! បែកចាំងអាចម៍ល័ក្កដែលគេផ្សារភ្ជាប់គ្របទៅនឹងពាង ខ្ញុំយកចបគាស់គ្របចេញ មើលទៅក្នុងពាងឃើញដាវវែងៗពីរុំដោយអំបោះនៅតាំងពីដងដល់ចុងផ្លែ តែឥតមានស្រោមទេ ដាវនោះដាក់បញ្ឈរក្នុងពាង ដែលមានស្នាមដូចពាងខ្ទះលើជើងសព្វថ្ងៃ ៗ មានគីរ៉ាំទមួយបង្វេចទៀត វេចនឹងសំពត់ហូលមួយយ៉ាងចាស់ លុះខ្ញុំបាទលូកដៃទៅពាល់ ហូលនោះផុយជ្រុះជាធូលីមួយរំពេច ៗ

នៅក្នុងបង្វេចសំពត់ហូលនោះ មានក្រាំងបុរាណធ្វើអំពីក្រដាស

ជប់ក្បាល ក្បួនស៊ីកតែវែងៗប្រាំក្បាល តម្រាស៊ីកតែខ្លីប្រាំក្បាល មាន ខ្លួបដាក់ប្រេងល្ង-មានផ្តិលសម្រិទ្ធមួយ រូបបដិមាជាច្រើនអង្គធ្វើអំពី សម្រិទ្ធ ទៀបធ្វើអំពីខាត់ ។ល។ ខ្ញុំរើអីវ៉ាន់ទាំងអស់ចេញពីក្នុងពាង រួច យកក្រមារវេចស្ពាយយកមកផ្ទះវិញ ។



ថ្ងៃបន្ទាប់មក ខ្ញុំបាទយកក្រាំងនិងតម្រាផ្សេងៗនោះមកមើល អក្សរ រលុបៗ មើលបានខ្លះមិនបានខ្លះ ស្រាប់តែដូចជាមានអ្វីមកគ្របខ្ញុំបាទ ហើយខ្ញុំបាទដូចជាមើលទៅចេះតែយល់ ចេះតែភ្លឺ. . . ។ ខ្ញុំបាទក៏ខំ

ទន្ទេញបាលីស្តោះស្ទួនក្នុងក្មេងខ្លះឲ្យចាំ តាមពាក្យដែលអ្នកសប្តំបង្គាប់ ៗ

ថ្ងៃមួយ មានក្មេងម្នាក់នៅជិតផ្ទះខ្ញុំបាទឈឺ ខ្ញុំបាទទឹកបង់ល្បងមន្ត អាគមខ្ញុំបាទមើល គឺសុំខ្លួនលស្តោះក្មេងនោះសាកមើល ស្តោះរួចមិនបានប៉ុន្មានក៏ជា ពូកែសក្តិសិទ្ធិមែន ! ពល់វេលា តែកាលណាខ្ញុំបាទចាល់ត្រង់ណា អ្នកសប្តំមកប្រាប់ខ្ញុំបាទភ្លាម ថែមទាំងបង្គាប់ឲ្យខ្ញុំបាទធ្វើគ្រឿងសក្ការៈផ្សេង ៗ ដែលអស់លោកចូល ហើយសួរខ្ញុំបាទនេះ ធ្វើមុខផ្សេង ៗនៃខ្មោច ដែលត្រូវចូលមកស្ថិតលើរូបខ្ញុំបាទ មានមុខឥសីផ្សេង ៗ មុខព្រះបាទទសមុខ មកុដព្រះឥន្ទ្រម្ចាស់ក្រពុំឈូក .. ។ល។ ទិងសម្លៀកបំពាក់តាមតួខ្មោច ដែលចូលមកសណ្ឋិតនោះ ប៉ុន្តែខ្ញុំបាទពុំទាន់មានប្រាក់កាសទិញដូរ គ្រប់ប្រដាប់ទេ លុះចាយទស្សន៍ឲ្យអ្នកស្រុក អ្នកភូមិជិតខាង បានប្រាក់កាសមក ក៏ខំសន្សំជួលជាងខាងសាលាវិចិត្រសិល្បៈ ធ្វើមុខម្តងមួយ ម្តងមួយ ព្រោះមុខមួយថ្លៃដល់ទៅមួយពាន់ប្រាំរយរៀល ៗ

ក្រោយមកទៀត លោកចាយ បាម បាននិយាយប្រាប់យើងខ្ញុំថា « មានចិនអ្នករកស៊ីម្នាក់នៅចំការលើ ខាងខែត្រកំពង់ចាមនេះដែរ គាត់ជាអ្នកមានទ្រព្យសម្បត្តិ ថ្ងៃមួយពួកចោរប្លន់ចាប់ខ្លួនគាត់យកទៅ ហើយបង្គាប់ឲ្យយកប្រាក់ទៅលោះជាច្រើនម៉ឺនរៀល ៗ ប្រពន្ធគាត់ភ័យណាស់ ណាមួយរកប្រាក់លោះប្តីមិនបាន ណាមួយខ្លាចចោរសម្លាប់ប្តី ក៏រត់ទៅ

រកគ្រូដ៉ុយឲ្យជួយ ត្បិតគាត់ខាល់គំនិតអស់ផ្លូវសង្ឃឹម ។ គ្រូដ៉ុយក៏ប្រាប់ឲ្យរៀបរណ្ដាប់ថ្វាយគ្រូគាត់ ហើយគាត់ប្រាប់ថា "មិនអីទេ ចាំយើងជួយអ៊ីឯង យើងឲ្យប្ដីអ៊ីត់រួចមកវិញ" ។ ប៉ុន្មានថ្ងៃក្រោយមក ចិននោះក៏បានមកដល់ផ្ទះវិញ សួរទៅថាលួចរត់មកមែន ទើបបេះតែមានអ្នកជឿចូលទៅពឹងពាក់កាន់តែច្រើនឡើង ច្រើនឡើង ឯចិនដែលចោរចាប់នេះនៅរស់សព្វថ្ងៃ គ្រូ ដ៉ុយ បានប្រាប់ឈ្មោះសព្វគ្រប់ដែរ តែយើងខ្ញុំមិនបានចាំ ។

សព្វថ្ងៃនេះ នៅផ្ទះគ្រូដ៉ុយ មានធ្វើពិធីលៀងគ្រូរាល់ថ្ងៃសីល តែថ្ងៃ ១៥ កើតនិងថ្ងៃខែដាច់ ធ្វើធំជាងថ្ងៃសីលធម្មតា ហើយបើប្រសិនជាថ្ងៃសីល នោះត្រូវលើថ្ងៃសៅរ៍ ក៏ត្រូវរៀបធំដែរ ។

អ្នកស្រី ពេជ សល់

# រផ្នែកកំណត់-ប្រវត្តិការណ៍

ទីស្ដីការរដ្ឋមន្ត្រី
ក្រសួងធម្មការ
លេខ ២១ កធ

## ព្រះរាជាណាចក្រកម្ពុជា

## សារាចរ

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
ទទួលបន្ទុកក្រសួងធម្មការ និង សាសនសិក្សាធិការ
ជម្រាបមកសហជីវិនប្រតិភូរាជរដ្ឋាភិបាល ប្រចាំក្រុងកែប
បូកគោ និង ខេត្តកណ្ដាល
ជម្រាបមកសហជីវិន អភិបាលក្រុង-អភិបាលខេត្ត-អនុខេត្ត
ក្នុងព្រះរាជាណាចក្រ

កម្មវត្ថុ : ព្រះសង្ឃដីកាសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក គណៈមហានិកាយលេខ ៥៤ គ-កសម ចុះថ្ងៃទី ២៩ តុលា ១៩៦៩ ស្ដីអំពីការប្រតិបត្តិឲ្យត្រឹមត្រូវតាមគន្លងធម៌វិន័យ និងឲ្យមានសាមគ្គីធម៌ ។

យោង : តាមចុតហ្មាយក្រសួងធម្មការលេខ ១០៦២.កធ. ចុះថ្ងៃទី ៤-១១-៦៩ ។

ដ្បិតមានព្រះសង្ឃដីកា សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកគណៈមហានិកាយដូចមានចែងក្នុងកម្មវត្ថុខាងលើ ដែល

ប្រគេនចំពោះព្រះសង្ឃជាព្រះរាជាគណៈ ឋានានុក្រម មេគណ អនុគណ ចៅអធិការ មេក្រុម មេកុដិ មួយអន្លើដោយភិក្ខុសង្ឃសាមណេរទាំងអស់ គ្រប់វត្តនៃគណៈមហានិកាយ សូមប្រតិបត្តិឲ្យបានត្រឹមត្រូវតាមគន្លងព្រះធម្មវិន័យនៃព្រះសម្ពុទ្ធបរមគ្រូ និង សូមឲ្យមានសាមគ្គីធម៌រវាងគ្នានិងគ្នា ដូចបានជូនដំណឹងតាមលិខិតដែលយោងខាងលើ ។

សេចក្តីនេះ សុំសហជីវិន ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង-ខេត្ត អភិបាលក្រុង អភិបាលខេត្ត-អភិបាលអនុខេត្ត ប្រគេនព្រះសង្ឃដីកានេះ ទៅព្រះរាជាគណៈ មេគណ អនុគណ និង ចៅអធិការ វត្តគណៈមហានិកាយ សុំឲ្យប្រតិបត្តិតាមសេចក្តីរំលឹកដាស់តឿនក្នុងព្រះសង្ឃដីកានេះ ហើយសុំឲ្យសហជីវិនរួបរួមជាមួយព្រះមេគណ ដើម្បីថែរក្សានូវសាមគ្គីធម៌ នៅគ្រប់វត្ត ជាប្រយោជន៍សេចក្តីសុខ ចំរើន ថ្កុំថ្កើងរុងរឿង ក្នុងព្រះពុទ្ធសាសនា និង ប្រទេសជាតិយើងតទៅ ។

ជាប់មកជាមួយនេះព្រះសង្ឃដីកាលេខ ៥៤ គ-គសម ចុះថ្ងៃទី ២៩ តុលា ១៩៦៩ ចំនួន . . . . . ច្បាប់ ។

ភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ១៩៦៩

ទី-ឌួច

លេខ ៥៤ ត/កសម

# ព្រះសង្ឃដីកា

សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក គណៈមហានិកាយ

ប្រគេនដំណឹងមកសម្ដេច ព្រះរាជាគណៈ ឋានានុក្រម មេគណ អនុគណ ចៅអធិការ និងព្រះរាជាគណៈ ឋានានុក្រម មេក្រុម និង មេកុដិ គ្រប់វត្ត នៃគណៈមហានិកាយ ក្នុងក្រុង ខេត្ត និងអនុខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

ដ្បិតបន្ទាប់ពីការសោយព្រះទិវង្គត នៃសម្ដេចព្រះមហាសុមេធាធិបតី **ជ. ណ.** ព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ សម្ដេចព្រះ-**នរោត្តម-សីហនុ** ព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ និងជាព្រះអគ្គពុទ្ធ-សាសនូបត្ថម្ភក៍ បានទ្រង់សព្វព្រះរាជហឫទ័យ តែងតាំងខ្ញុំជា សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក គណៈមហានិកាយ ដោយព្រះរាជក្រឹត្យលេខ ២៩.រវ. ចុះថ្ងៃទី ២៧ កញ្ញា ១៩៦៩ ដើម្បីគ្រប់គ្រងគណៈសង្ឃ ក្នុងគណៈមហានិកាយ ស្នងអង្គសម្ដេចព្រះសង្ឃរាជថ្នាក់ទី១ ដែលទ្រង់សោយព្រះទិវង្គត ។

ក្នុងឋានៈខ្ញុំជាព្រះសង្ឃនាយក ខ្ញុំសូមគោរពចំពោះសម្ដេច និងសម្ដែងនូវមនោសញ្ចេតនាប្រកបដោយសេចក្ដីរាប់អានដ៏ស្មោះស្ម័គ្រចំពោះព្រះរាជាគណៈ ឋានានុក្រម មេគណ អនុគណ ចៅអធិការ មេក្រុម

មេកុដ មួយអន្ទើដោយភិក្ខុសង្ឃ សាមណេរទាំងអស់ គ្រប់វត្តនៃគណៈ មហានិកាយ ហើយខ្ញុំសូមឆ្លៀតឱកាសនេះ ផ្ញើព្រះសង្ឃដីកាសន្ទេសមួយ ដើម្បីរំលឹកចំពោះភិក្ខុសង្ឃទាំងអស់ នៃគណៈមហានិកាយ ដូចតទៅ :

១— សូមឲ្យភិក្ខុសង្ឃគ្រប់វត្ត មានការយល់ឃើញត្រឹមត្រូវតាម គន្លងព្រះធម៌វិន័យនៃព្រះសម្ពុទ្ធបរមសាស្តា មានការព្រមព្រៀងគ្នា មានការស្រឡាញ់រាប់អានគ្នាជាសហធម្មិកយ៉ាងជិតស្និទ្ធ ហើយប្រតិបត្តិកុំឲ្យខុសឃ្លាងឃ្លៀងឃ្លាតចាកព្រះពុទ្ធវចនៈឡើយ ព្រោះជាបព្វជិត មួយរូប ៗ មិនគួរប្រកាន់អស្មិមានះ បង្កជម្លោះឈ្លោះទាស់ទែងរវាងបព្វ-ជិតដូចគ្នា និងរវាងពុទ្ធបរិស័ទជាគ្រហស្ថនោះទេ ។ បព្វជិតគ្រប់រូបគួរ តែមានសន្តានចិត្តប្រកបដោយខន្តី ចេះអត់ធន់ ចេះទប់ចិត្ត មានគំនិតនិង អធ្យាស្រ័យចេះអត់ឱន ចំពោះបព្វជិតដូចគ្នា និងចំពោះគ្រហស្ថ ដែលជា ទាយកទាយិកានានា ៗ បព្វជិតគ្រប់រូប មានឈ្មោះថា សមណៈ សក្យបុត្តិយ៍ ជាអ្នកស្ងប់រម្ងាប់ និងជាអ្នករំលត់នូវហឹង្សាគ្រប់ប្រការ មិន គួរបណ្តោយចិត្តអោយក្តៅក្រោធ រហូតដល់បណ្តាលទៅជាមានរឿង អធិករណ៍ នាំឲ្យសៅហ្មងដល់ព្រះពុទ្ធសាសនាឡើយ ។ ព្រះសម្ពុទ្ធបរម-សាស្តារបស់យើង បានសម្តែងចំពោះភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា ឲ្យ មានសាមគ្គីព្រមព្រៀងគ្នា ហើយឲ្យប្រតិបត្តិតាមព្រះធម្មវិន័យ ដែលជា ឫសគល់នៃព្រះពុទ្ធសាសនា ។ ព្រះអង្គបានរំលឹកដាស់តឿនភិក្ខុសង្ឃ

មិនឲ្យបង្កអធិករណ៍ណាមួយឡើយ សមដូចព្រះពុទ្ធដីកាក្នុងគម្ពីរមហាវគ្គ ត្រង់កោសម្ពិកខន្ធកៈ ដែលដកស្រង់គោល ១ ខ្លះមកបង្ហាញជាក់ស្តែងថា "ម្នាលភិក្ខុទាំងឡាយ ចូរអ្នកព្រមព្រៀងគ្នា ចងគ្នាជាបាច់ ៗ ចូរអ្នកកុំបង្កហេតុ ឲ្យកើតទៅជារឿងទាស់ទែងខ្វែងគំនិតគ្នា កុំឈ្លោះគ្នាឡើយ ព្រោះអ្នកពលគ្នា សុទ្ធតែបួសរៀនតាមធម៌វិន័យរបស់តថាគត ៗ ការខ្វែងគំនិតគ្នា និងការបង្កអធិករណ៍មិនចេះឈប់ឈរនេះ ជាមន្ទិលសៅហ្មងដ៏អាក្រក់ អាចធ្វើឲ្យសាសនាតថាគត វិនាសសាបសូន្យបាន ហើយជាហេតុឲ្យមានសេចក្តីទុក្ខផង "ៗ

ម្យ៉ាងទៀត សូមឲ្យភិក្ខុសង្ឃចេះគិតពិចារណា កុំប្រកាន់យកខុសជាត្រូវ ដោយគាន់ថាខ្លួនធ្លាប់ប្រតិបត្តិមកយូរហើយនោះឡើយ ដូចមានសេចក្តីមួយវគ្គ ក្នុងព្រះរាជសុន្ទរកថា នៃសម្តេចព្រះប្រមុខរដ្ឋ នៅឱកាសពិធីថ្វាយសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រ ចំពោះសម្តេចព្រះសង្ឃរាជថាក់ទី ១ថា "អ្នកខ្លះនិយាយខុសទាំងស្រុងថា នៅក្នុងសាសនាយើង មានធម៌ថ្មី ធម៌ចាស់ ៗ តាមការពិត យើងពុំមានធម៌ពីរទេ ៗ ដែលនិយាយថា ធម៌ថ្មីនោះ គឺការដែលចំរើនសម្រិតសម្រាំងព្រះសាសនាឲ្យផុតអំពីជំនឿខុស អំពីការយល់ហួសហេតុផល និងអំពីទម្លាប់ខុស គឺពុំមែនធ្វើឲ្យព្រះពុទ្ធសាសនាទៅជាបែបថ្មីទេ ៗ ការពិត គឺធ្វើឲ្យព្រះសាសនា ត្រឡប់ទៅរកប្រកតដើមដ៏ត្រឹមត្រូវល្អវិញ តែប៉ុណ្ណោះ" ៗ

២- សូមឲ្យភិក្ខុសង្ឃ ក្នុងគណៈមហានិកាយទាំងអស់ តាំងចិត្តសម្រិតសម្រាំងឲ្យមានសាមគ្គីធម៌រវាងគ្នានិងគ្នា ធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ រិះរកមធ្យោបាយ ដើម្បីកម្ចាត់នូវអធិករណ៍គ្រប់បែបយ៉ាងទាំង-អស់ ដែលនឹងកើតមានក្នុងអនាគតកាល ។ រីឯអធិករណ៍ទាំងឡាយដែលបានកើតមានរួចហើយមកដល់នឹងពេលនេះ សូមឲ្យភិក្ខុសង្ឃបំភ្លេចបំបាត់ចោលត្រឹមនេះទៅចុះ ហើយបែរមុខឆ្ពោះទៅរកសេចក្តីប្រតិបត្តិដ៏ត្រឹមត្រូវតាមព្រះធម្មវិន័យ នៃព្រះសម្ពុទ្ធបរមគ្រូរបស់យើងឡើងវិញ ។ សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ជាម្ចាស់ កាលព្រះអង្គគង់ព្រះជន្មាយុនៅឡើយ ព្រះអង្គមានបំណងនឹងកម្ចាត់រឿងអធិករណ៍ផ្សេង ៗ ក្នុងព្រះពុទ្ធ-សាសនាឲ្យអស់រលីង ប៉ុន្តែទ្រង់មានព្រះកាយពលខ្សោយពេក ដោយជរាធម៌ ទ្រង់ក៏ពុំអាចសម្រេចការនេះ ឲ្យសម្រេចតាមព្រះរាជហឫទ័យបានហើយទ្រង់ក៏សោយព្រះទិវង្គតទៅ ។

ដូច្នេះ សូមឲ្យភិក្ខុសង្ឃគ្រប់វត្ត ប្រតិបត្តិដោយត្រឹមត្រូវតាមគន្លងព្រះធម៌វិន័យ កុំបីធ្វេសប្រហែសឲ្យសោះ ។ ប្រសិនបើវត្តណា ដែលមានអធិករណ៍មកយូរហើយក្តី កំពុងមានអធិករណ៍នឹងគ្នាសព្វថ្ងៃនេះក្តីហើយអធិករណ៍នោះពុំទាន់ស្ងប់ស្ងាប់ សូមភិក្ខុសង្ឃនៅវត្តនោះ ព្រមទាំងពុទ្ធបរិស័ទជើងវត្តនោះ តាំងចិត្តជាថ្មី បញ្ចប់អធិករណ៍នោះឲ្យបានសម្រេចដោយជោគជ័យ ដើម្បីជាកិច្ចតបស្នងព្រះមហាករុណាធិគុណ នៃព្រះ-

សម្តេចជាម្ចាស់ ដែលកាលព្រះអង្គទ្រង់គង់ធរមាននៅឡើយ ព្រះអង្គតែងប្រទានទូលព្រះបរមពុទ្ធោវាទ ចំពោះភិក្ខុសង្ឃជាកូនចៅព្រះអង្គ កុំឲ្យមានរឿងអធិករណ៍រវាងគ្នានិងគ្នា ព្រោះថា រឿងអធិករណ៍ ជាហេតុនាំឲ្យមានទុក្ខ និងជាហេតុនាំឲ្យវិនាស ។ ព្រះអង្គទ្រង់ប្រដៅភិក្ខុសង្ឃឲ្យមានសាមគ្គីធម៌រវាងគ្នានិងគ្នាតរៀងទៅ ព្រោះសាមគ្គីធម៌ជាហេតុនាំឲ្យមានសុខសាន្ត ។ ជាពិសេសទៅទៀត ការបញ្ចប់អធិករណ៍នេះ ទុកជាកិច្ចតបស្នងព្រះឧបការគុណ នៃសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ដែលទ្រង់ទើបនឹងសោយព្រះទិវង្គតនេះផង ព្រោះកាលសម្តេចគង់ព្រះជន្មនៅឡើយ ទ្រង់តែងបំពេញកិច្ចការជាប្រយោជន៍ដល់ភិក្ខុសង្ឃ កុំឲ្យកើតវិវាទរវាងគ្នានិងគ្នា រហូតដល់ពេលសោយព្រះទិវង្គត ។

ខ្ញុំមានសង្ឃឹមយ៉ាងមាំថា សម្តេចព្រះរាជាគណៈ ប៉ានានុក្រមគ្រប់តំណែង ជាពិសេស ភិក្ខុសង្ឃទាំងអស់ ក្នុងគណៈមហានិកាយ មុខជានឹងប្រតិបត្តិតាមព្រះសង្ឃដីកានេះ ហើយនឹងមានសាមគ្គីរវាងគ្នានិងគ្នាប្រតិបត្តិតាមព្រះធម៌វិន័យ ឧបត្ថម្ភព្រះពុទ្ធសាសនា ឲ្យបានរុងរឿងស្ថិតស្ថេរចីរកាលតរៀងទៅ ។

ចំណែកពុទ្ធបរិស័ទជាគ្រហស្ថទាំងឡាយ ក៏គប្បីតាំងចិត្តគោរពប្រតិបត្តិតាមព្រះពុទ្ធឱវាទឲ្យបានត្រឹមត្រូវ ហើយគប្បីតាំងចិត្តឲ្យមានសាមគ្គីធម៌ ជាមួយនឹងភិក្ខុសង្ឃផងដែរ ។ លុះតែពុទ្ធបរិស័ទទាំងបព្វជិត ទាំង

គ្រហស្ថ រួបរួមគ្នាធ្វើយ៉ាងនេះ ទើបព្រះពុទ្ធសាសនាក្នុងប្រទេសយើងនឹងមានដំណើរទៅកាន់វឌ្ឍនភាពយ៉ាងបរិបូណ៌ ។

ធ្វើនៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ នៅថ្ងៃពុធ ៣ រោច ខែអស្សុជ
ឆ្នាំរកា ឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ២៩ ខែតុលា គ.ស. ១៩៦៩

បានឃើញហើយ
យល់ព្រម
រដ្ឋលេខាធិការក្រសួងធម្មការ
**ឌី-ទូច**
ឧត្តមមន្ត្រី

សម្ដេចព្រះមហាសុមេធាធិបតី
ព្រះសង្ឃនាយក គណៈមហានិកាយ
ហួត-តាត (វជិរប្បញ្ញោ)

# បុគ្គលិកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ
# ចូលក្រាបបង្គំគាល់ព្រះបរមសពនៃសម្ដេចព្រះសង្ឃរាជ
# ជោតញ្ញាណោ ជួន-ណាត

ថ្ងៃសុក្រ ទី ៣ ខែ ធ្នូ គ.ស. ១៩៦៩ វេលាម៉ោង ៩ ព្រឹក បុគ្គលិកទាំងអស់ នៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យទាំងព្រះសង្ឃទាំងគ្រហស្ថក្រោមព្រះអធិបតីភាពនៃសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ ក្នុងព្រះឋានៈជាអធិបតីនៃក្រុមជំនុំព្រះត្រៃបិដក និងក្រោមការណែនាំនៃសហជីវិន លោក ហ៊ប អាន ជានាយកនៃវិជ្ជាឋាននេះ បានជួបជុំគ្នានិមន្តព្រះសង្ឃ ធ្វើទក្ខិណានុប្បទាន និងចម្រើនព្រះសត្តប្បករណាភិធម្ម បង្សុកូលព្រះបរមសពនៃសម្ដេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន-ណាត ដែលព្រះអង្គទ្រង់មានព្រះគុណូបការដ៏ធំធេងចំពោះវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យតាំងពីគ្រឹះស្ថាននេះកកើតឡើង រហូតដល់ពេលសព្វថ្ងៃ ។ បើគេរំឭកឡើងវិញនូវប្រវត្តិរបស់ពុទ្ធសាសនបណ្ឌិត្យ ក៏គេពុំអាចបំភ្លេចព្រះបរមនាមនៃសម្ដេចព្រះសង្ឃរាជអង្គនេះបានឡើយ ព្រោះបំណងធំនៃវិជ្ជាឋាននេះឯង គឺការស្រាវជ្រាវរកក្បួនច្បាប់ទាំងផ្នែកវប្បធម៌ខ្មែរ និងផ្នែកពុទ្ធសាសនា ដើម្បីយកមករក្សាទុកផង និងពិនិត្យផ្ទៀងផ្ទាត់សម្រាប់បោះពុម្ពផ្សាយផង ។ មិនតែប៉ុណ្ណោះ ទីនេះ ជាទីផ្សាយនូវធម៌វិន័យ

តាមមធ្យោបាយបោះពុម្ពជាសៀវភៅ ឬការបង្ហាត់បង្រៀនផ្ទាល់ ៗ ខ្លួនផង ។ ការងារទាំងនេះហើយ ដែលព្រះបរមសពសម្ដេចព្រះសង្ឃរាជ កាលទ្រង់គង់ព្រះជន្មាយុនៅឡើយ ព្រះអង្គបានបំពេញយ៉ាងសកម្មបំផុត ជាមួយសហធម្មិករបស់ព្រះអង្គ ៤ រូបទៀត គឺព្រះសពព្រះឧត្តមមុនីអ៊ុម-ស៊ូ, ព្រះសពព្រះវិមលធម្មថោង, ព្រះសពសម្ដេចព្រះធម្មលិខិត ល្វី-ឯម និងសម្ដេចព្រះសង្ឃនាយកគណៈមហានិកាយសព្វថ្ងៃនេះ ។

ក្រោយដែលបានជួបជុំគ្នាហើយ ពិធីនមស្សការព្រះរតនត្រ័យ ក៏ចាប់ផ្ដើមឡើង បន្ទាប់មកសហជីវិន លាង ហ៊ាប អាង ថ្លែងសុន្ទរកថាមួយសម្ដែងសមានចិត្ត ភក្ដី និងកតញ្ញុតាធម៌ ចំពោះព្រះបរមសព មានសេចក្ដីទាំងស្រុង ដូចតទៅនេះ៖

សូមព្រះតេជៈតម្កល់លើត្បូង
សូមក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ នៃព្រះ
បរមសពសម្ដេចព្រះសង្ឃរាជជាអម្ចាស់
សូមទ្រង់ជ្រាប ៕

សម្ដេចជាអម្ចាស់!

កូនព្រះបរមនាមនៃសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកជាព្រះអធិបតីនៃក្រុមជំនុំព្រះត្រៃបិដក ព្រមទាំងព្រះសង្ឃគ្រូអាចារ្យជាសមា-

ជិត ដែលមានព្រះតេជៈ ព្រះគុណព្រះមុនីកោសល សូរ-ហាយ ជា ព្រះអធិបតីវង្ស និងព្រះពុទ្ធាចារ្យ ហ៊ុ-ជា ជាអាទិ, ក្នុងនាមនៃបុគ្គលិកទាំងអស់នៃវិជ្ជាល័យពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមចូលមកគោរពចំពោះព្រះបរមសពនៃលម្អងធូលីព្រះបាទ ដោយនាំមកនូវកម្រងផ្កា ទេយ្យវត្ថុ ព្រមទាំងបច្ច័យបួន ដើម្បីនិមន្តព្រះសង្ឃចម្រើនព្រះសត្តប្បករណាភិធម្មបង្សុកូល ឧទ្ទិសបុញ្ញកុសលថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធព្រះករុណាថ្លៃវិសេស សូមសម្តេចជាអម្ចាស់មេត្តាទទួលនូវកុសលផលបុណ្យនេះ អំពីទូលព្រះបង្គំជាខ្ញុំដោយព្រះមេត្តា ។

បពិត្រសម្តេចជាអម្ចាស់ !

ពិតមែនតែព្រះរូបព្រះកាយសម្តេច បានរលត់ទៅហើយក៏ដោយ ក៏ព្រះបរមកិត្តិនាម ព្រះរាជកេរ្តិ៍នៃលម្អងធូលីព្រះបាទ បានផ្តិតជាប់នៅក្នុងហាយវត្ថុ របស់ទូលព្រះបង្គំទាំងអស់គ្នាជានិច្ចអស់កល្បាវសាន ។ ទូលព្រះបង្គំយើងខ្ញុំមានសេចក្តីពេញចិត្តឥតឧបមា ដោយកាលសម្តេចជាអម្ចាស់គង់ព្រះជន្មនៅឡើយ ទូលបង្គំទាំងអស់គ្នា បានបំពេញករណីយកិច្ចក្នុងមុខការរបស់ខ្លួនតាមការសព្វព្រះរាជហឫទ័យ ដូចជា :

ទី ១- បានខិតខំពិនិត្យបោះពុម្ពព្រះត្រៃបិដកចប់សព្វគ្រប់ទាំង ១១០ ភាគ ដែលជាទំហំសៀវភៅយ៉ាងធំ មានរយៈពេលប្រមាណ ៤០ ឆ្នាំ ។ គ្រាន់តែក្នុងរយៈពេល ៣ ឆ្នាំប៉ុណ្ណោះ វិជ្ជាល័យបានប្រឹងញាប់ការបោះ

ពុម្ពផ្សាយព្រះពុទ្ធវចនៈនេះ បានដល់ទៅ ៣៨ ភាគ ។ ចំពោះកិច្ចការបម្រើនព្រះពុទ្ធសាសនានេះ ទូលព្រះបង្គំយើងខ្ញុំ មានសោមនស្សខ្លាំងទៅទៀត ដោយបានរួបរួមធ្វើពិធីសម្ពោធជូនគម្ពីរព្រះត្រៃបិដកទាំង ១១០ ភាគនេះ ជាឧឡារិកបានមុនការសោយព្រះទិវង្គតនៃសម្ដេចតែត្រឹម ៤ ខែ ប៉ុណ្ណោះ, គឺជាបានតបស្នងព្រះមហាករុណាធិគុណ នៃសម្ដេចតាំងទ្រង់គង់ព្រះជន្មាយុនៅឡើយ ។

ទី ២. បានរៀបចំតាំងគណៈកម្មការពិសេស ដែលមានសមាជិកជាព្រះសង្ឃ និង គ្រហស្ថ គឺព្រះសាសនមុនី គាំម ត្វូរ, ព្រះញាណវង្ស អ៊ុម ស៊ុម, លោក ញ៉ុង សៀង, និង ប៉ោង សំអ៊ុ, ដើម្បីរៀបចំផ្ទៀងផ្ទាត់បន្ថែមនូវពាក្យពេចន៍ បោះពុម្ពផ្សាយវចនានុក្រមខ្មែរទាំង ២ ភាគ ជាលើកទី ៥ ក្រោមព្រះរាជូបត្ថម្ភ ផ្ទាល់នៃសម្ដេចជាអម្ចាស់និងបានហើយស្រេចតាំងពីឆ្នាំ ១៩៦៧ ។ កិច្ចការនេះនៅតែបន្តមកទៀត ពោះបំបានបោះពុម្ពសព្វគ្រប់ហើយក៏ដោយ កំណុំងជួលព្រះបាទសព្វព្រះរាជហឫទ័យទ្រង់ការតាំងយប់តាំងថ្ងៃ គ្មានពេលល្ហែ ជាហេតុបណ្ដាលឲ្យព្រះរោគមកញាំញីព្រះកាយរហូតដល់ស្ដេចសោយព្រះទិវាល័យ មុននឹងសម្រេចបោះពុម្ពលើកទី ៦ ។

ទី ៣. បានប្រោសធ្វើពិធីបុណ្យរំលឹកខួបនៃក្រសួង តាំងពីឆ្នាំ ១៩៤៥ មក ដើម្បីឧទ្ទិសកុសលនិងសម្ដែងនូវកតញ្ញុតាធម៌ចំពោះវិញ្ញាណ

កូន នៃព្រះមហាក្សត្រ ព្រះសង្ឃគិកាចារ្យ កវីបណ្ឌិត ដែលមានព្រះគុណ បំពោះវិជ្ជាហ៊ាន តាំងពីថ្ងៃកើតមកនោះ ។

ទី ៤- បានមផ្ដើមការបោះពុម្ពផ្សាយនូវពុទ្ធវចនៈ ដែលអ្នកនិពន្ធ បច្ចុប្បន្នបានរៀបរៀងជាសៀវភៅ ដូចជាស្នាព្រះហស្តសម្ដេចព្រះសង្ឃ នាយកជាម្ចាស់ជាដើម ។

ទី ៥- បានទាក់ទងនឹងក្រសួងអប់រំជាតិ (គណៈកម្មការខាងរៀបបំ កម្មវិធីសិក្សា) ដើម្បីបញ្ចូលនូវសៀវភៅផ្នែកពុទ្ធបក្រមួយចំនួនធំ ទៅ ក្នុងកម្មវិធីមធ្យមសិក្សាខាងសាលាគ្រហស្ថ ឲ្យស្របទៅតាមព្រះរាជហឫ- ទ័យនៃល្អងធូលីព្រះបាទ និងព្រះចិន្ដាប្រោសប្រណីឧបត្ថម្ភ នៃសម្ដេច ព្រះសង្ឃនាយក តាមសេចក្ដីសម្រេចរបស់សមាជជាតិ ។

ទី ៦- បានរើរៀប បំពោះពុម្ពជាថ្មីនូវសៀវភៅ "គិក្ខុបាដិមោក្ខ បាលី" បោះពុម្ពលើកមុនមានខុសអក្ខរាវិរុទ្ធ និងឃ្លៀងឃ្លាតលក្ខណៈ ដើមខ្លះនោះ ដើម្បីតម្រូវតាមសព្វព្រះរាជហឫទ័យ ។

ទី៧- បានទទួលព្រះបរមរាជបញ្ជាបោះពុម្ពនូវសៀវភៅ "កច្ចាយនូ- បត្ថម្ភ" ជាស្នាព្រះហស្តផ្ទាល់របស់ល្អងធូលីព្រះបាទ ដែលបោះពុម្ព លើកក្រោយបានកែប្រែខ្លះខុសព្រះរាជហឫទ័យនោះ ឲ្យបានត្រឹមត្រូវដូច ដើមឡើងវិញ ។

ទី ៨- បានបន្ទាបនូវអ្នកនិពន្ធគ្មានការអៀនខ្មាសខ្លះ និងឈ្មួញ

វិលខូចមួយចំនួន ដែលចូលចិត្តតែលួចដកស្រង់យកអត្ថបទត្រង់ ៗ ឬទាំងស្រុងអំពីសៀវភៅជាសម្បត្តិជាតិទិន៍ជាស្នាដៃរបស់បុព្វបុរស យកទៅបោះពុម្ពលក់ ធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ដោយក្រសួងវិតខំទាញសតិសម្បជញ្ញអ្នកទាំងនោះ ឲ្យបេះមានហិរិឧត្តប្ប ខ្លះ ៗ មកវិញ ។

ទី ៩- បានរៀបចំបោះពុម្ពនូវសៀវភៅ អដ្ឋកថា ជាភាសាបាលី ដែលក្រុមជំនុំព្រះត្រៃបិដកបានរៀបរៀងប្រមូលសព្វគ្រប់ហើយនោះ ដើម្បីបន្ថែមបន្ថែមទៅលើគម្ពីរព្រះត្រៃបិដកទាំង ១១០ ភាគ តាមសេចក្ដីសព្វព្រះរាជហឫទ័យនៃល្អង់ធូលីព្រះបាទ ។

សម្ដេចជាអម្ចាស់ !

លទ្ធផលទាំងប៉ុន្មានដែលវិជ្ជាឋានបានសម្រេចហើយខាងលើនេះ គឺកើតឡើងដោយសារព្រះរាជកិច្ចណែនាំផ្ទាល់របស់ល្អង់ធូលីព្រះបាទ និងរបស់សម្ដេចព្រះសង្ឃនាយកជាម្ចាស់ ។ ខ្ញុំព្រះបង្គំយើងខ្ញុំ សូមសន្យាថានឹងបន្តការងារបម្រើជាតិ សាសនា ព្រះរាជបល្ល័ង្ក និងព្រះត្រៃរតន៍តាមព្រះរាជបណ្ដាំរបស់ល្អង់ធូលីព្រះបាទជានិច្ច ។ ចំពោះវេនានុក្រមខ្មែរ ដែលសម្ដេចជាអម្ចាស់សព្វព្រះរាជហឫទ័យស្នើព្រះនេត្រ ព្រះកាណ៌នោះ ខ្ញុំព្រះបង្គំយើងខ្ញុំនឹងរក្សាទុកនូវគណៈកម្មការដែលធ្លាប់ធ្វើការក្រោមព្រះរាជឧបត្ថម្ភរបស់ល្អង់ធូលី តាំងពីព្រះអង្គគង់ព្រះជន្មនៅនោះ ឲ្យបន្តការងាររហូតដល់បោះពុម្ពជាលើកទី ៦ នាឆ្នាំ ១៩៧០ ខាងមុខនេះ ។

ខ្ញុំព្រះបង្គំយើងខ្ញុំនឹងសម្រេចសូមដាក់នាមវចនានុក្រម ដែលបម្រុងបោះពុម្ពថា "វចនានុក្រម ជួន ណាត" ព្រមទាំងដាក់ព្រះបរមនាមយាល័ក្ខណ៍ព្រះអង្គដើម្បីគោរពតាមព្រះរាជបណ្ដាំថា "កាលណាអាត្មាទៅ វចនានុក្រមដែលអាត្មាបានខំត្រួសត្រាយធ្វើនេះ តាមតែអស់លោកដាក់នាម ដាក់រូបអាត្មាយ៉ាងណាក៏ដោយចុះ ប៉ុន្តែឥឡូវនេះ គឺពេលអាត្មានៅរស់ សុំដាក់ត្រឹម "វចនានុក្រមខ្មែរ" តែប៉ុណ្ណោះចុះ ។

ជាទីបញ្ចប់ ខ្ញុំព្រះបង្គំជាខ្ញុំទាំងអស់សូមលើកបុញ្ញកុសលក្នុងពិធីបង្សុកូលនេះថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃសម្ដេចជាអម្ចាស់ សូមទ្រង់បានគង់នៅជាបរមសុខក្នុងសុគតិភព រហូតដល់សម្រេចនូវសម្បត្តិព្រះនិព្វានជាបរិយោសាន ។

មួយចំណែកទៀត ខ្ញុំព្រះបង្គំជាខ្ញុំទាំងអស់ សូមឧទ្ទិសនូវមគ្គផលដែលសម្រេចឡើងក្នុងពេលនេះ, មួយចំណែកថ្វាយចំពោះសម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះប្រមុខរដ្ឋ សូមព្រះអង្គបានសម្រេចនូវសម្បត្តិសួគ៌ សម្បត្តិព្រះនិព្វាន ហើយមានព្រះជន្មាយុជាងរយព្រះវស្សា ដើម្បីជាម្លប់ដល់ពុទ្ធបរិស័ទ ប្រជាពលរដ្ឋជាកូនចៅក្នុងកម្ពុជរដ្ឋ, និងមួយចំណែកទៀត ប្រគេនចំពោះសម្ដេចព្រះសង្ឃនាយកជាអម្ចាស់ដែលគង់ជាអធិបតីក្នុងទីនេះ ព្រមទាំងសម្ដេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ, សូមសម្ដេចទាំងពីរព្រះអង្គមាន

ព្រះជន្មាយុយឺនយូរ ដើម្បីជាទីពំនឹងនៃពុទ្ធសាសនិកទាំងអស់ ។

សូមក្រាបបង្គំទូលថ្វាយនៅថ្ងៃពុធ ៩ រោច ខែកត្តិក ត្រូវនឹងថ្ងៃទី ៣ ធ្នូ ឆ្នាំ ១៩៥៩ ។

ទូលព្រះបង្គំជាខ្ញុំ ឈាវ ហ័បអាន

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ជាតំណាងនៃបុគ្គលិកទាំងអស់ ។

បន្ទាប់ពីសុន្ទរកថានេះមក សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក មានពុទ្ធដីកាតបវិញ ក្នុងព្រះបរមនាមនៃព្រះសព ព្រមទាំងក្នុងនាមព្រះសង្ឃជាសិស្សគណទាំងអស់នៃសព ដើម្បីថ្លែងអំណរគុណនិងសេចក្ដីសរសើរជាឧឡារិក ចំពោះបុគ្គលិក នៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យដែលបេះសាមគ្គីរួបរួមគ្នា និងមាចិត្តភក្ដីមករៀបចំពិធីថ្វាយព្រះរាជកុសលក្នុងវេលានេះ ។ សម្ដេចមានពុទ្ធដីកាដោយព្រះកន្ត្រស្ដស្ងប់ ថ្លែងបញ្ជាក់ពីទឹកព្រះទ័យនៃព្រះបរមសព ដែលតែងជាប់ជំពាក់នឹងកិច្ចការទាំងអស់របស់ពុទ្ធសាសនបណ្ឌិត្យ មានការតាក់តែងវចនានុក្រមខ្មែរជាដើម រហូតដល់ពេលមានព្រះអាពាធហើយ ក៏នៅតែជាប់ព្រះទ័យនឹងការងារនេះដែរ ។ បន្ទាប់មក សម្ដេចបានប្រសិទ្ធិពរប្រគេននិងជូនចំពោះបុគ្គលិកទាំងព្រះសង្ឃ ទាំងគ្រហស្ថ នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ សូមឲ្យបានប្រកបនឹងជោគជ័យក្នុងការងារបម្រើវប្បធម៌ជាតិនិងព្រះពុទ្ធសាសនា ។

តមក ព្រះសង្ឃ ២០ អង្គក៏ចាប់ចម្រើនព្រះសត្តប្បករណាភិធម្មបង្សុកូល ថ្វាយព្រះបរមសព ។ លុះចប់ព្រះធម៌នេះហើយ បុគ្គលិកទាំងអស់ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ លើកយកទេយ្យទាន ប្រគេនព្រះសង្ឃ ជាកិច្ចបង្ហើយបុណ្យ ។

ពិតមែនតែពិធីនេះ មិនជាធំដុំប៉ុន្មាន ប៉ុន្តែមានអត្ថន័យធំទូលាយវែងឆ្ងាយណាស់ ព្រោះជាការរំលឹកឡើងនូវព្រះកិត្តិគុណដែលមានមកជាច្រើនឆ្នាំហើយ និងជាកំណត់កត់ទុកក្នុងដួងចិត្តនៃជនទាំងអស់ ចំពោះព្រះកិត្តិគុណនេះ តទៅអនាគតពុំអាចរសាយរលុបរលាយបានឡើយ ។



សហជីវិននាយករដ្ឋបាល ថ្លែងវិយោគទុក្ខ តាងនាមបុគ្គលិកទាំងអស់



សហជីវិន ឈាង-ហ័ប-អាន ប្រគេនទេយ្យទាន



សហជីវិន ឈាង-ហ័ប-អានលើកទេយ្យទានប្រគេនព្រះពុទ្ធាចារ្យ ហ៊ី-ជា
សមាជិកក្រុមជំនុំព្រះត្រៃបិដក ដើម្បីប្រគេនព្រះសង្ឃ



សហជីវិន នាយកវិជ្ជាហ៊ានប្រគេនទេយ្យទាន



បុគ្គលិកវិដ្ឋាហាតប្រណាម្យគោរពបរមសព

# បញ្ជីអត្ថបទដែលបានផ្សាយហើយ
# ក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៦៩

## ១- ផ្នែកសាសនា :

| លេខរៀង | នាមអ្នកនិពន្ធ | ចំណងជើង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ១ | ព្រះមហា ប៉ុក សុខ | រឿងសុមនសាមណេរ ភាគ ៨ | ១ |
| ២ | ព្រះសិរីសម្មតិវង្ស ប៉ុណ្ណ សម្មាជ | អង្គការព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា | ២ |
| ៣ | ព្រះមហា ប៉ុក សុខ | រឿងចន្ទាកគោរ | ២ |
| ៤ | ព្រះមហាព្រហ្មមុនី ឡុង ណារ់ និងព្រះធម្មកវីវង្ស គុង ឈួន | បករសូត្រ | ៣ |
| ៥ | សម្ដេចព្រះពោធិវង្ស ហួត តាត | ពិធីសម្ពោធព្រះត្រៃបិដក និងពុទ្ធភាសិតខ្លះ ក្នុងបរិនិព្វានសូត្រ | ៤ |
| ៦ | ពុទ្ធសាសនបណ្ឌិត្យ | ឧប្បត្តិហេតុនៃព្រះត្រៃបិដក | ៤ |
| ៧ | ព្រះមុនីកោសល សូ ហាយ | មហាបរិនិព្វានកថា | ៤ |
| ៨ | លោក ម៉ែង ជ្រីវ | សេចក្ដីក្លាហាន | ៥ |

| លេខរៀង | នាមអ្នកនិពន្ធ | បំណាំងជើង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ៩ | លោកហេង សំអាន | រឿងសតនបណ្ឌិត | ៥ |
| ១០ | -ដ- | អគ្គសាវគ្គជីវប្បវត្តិ | ៦ |
| ១១ | លោក ប៊ូ ប៉ូ | កម្លាំងនៃស្ត្រី | ៦ |
| ១២ | -ដ- | មជ្ឈិមសីល | ៧ |
| ១៣ | លោក ញ៉ុង សឿង | រឿងឧបគត និងមារ | ៧ |
| ១៤ | លោក ប៊ូ ប៉ូ | មហាសីល | ៨ |
| ១៥ | ព្រះមហា ប៉ាង ខាត់ | ទស្សនវិជ្ជាពុទ្ធសាសនា | ៥ដល់១១ |
| ១៦ | ភិក្ខុ លាប សារុន | អដ្ឋង្គិកមគ្គកថា | ៩ |
| ១៧ | លោក ប៊ូ ប៉ូ | រឿងបណ្ឌិតសាមណេរ | ១០ |
| ១៨ | លោក ផល ទិត | រឿងតាមណាំចន្ទ | ១១ |
| ១៩ | - ផេង ជ្រីវ | ប្រជុំជីវិត មច្ចានំ នាមគោត្តំ ន ជីរតិ | ១២ |

## ២- វិជ្ជាអក្សរសាស្ត្រ :

| | | | |
|---|---|---|---|
| ១ | សហ. ផេង-ជ្រីវ | អំពីពន្លឺព្រះអាទិត្យ | ១ |
| ២ | ព្រះភិក្ខុ ប៉ាង ខាត់ | វេចនានុក្រមសំស្ក្រឹត ខ្មែរ | ១ដល់១២ |
| ៣ | ឧកញ៉ា នូ កន | រឿងសាមកុក | ១ដល់១២ |
| ៤ | អ្នកស្រី ពេជ សល់ | រឿងគ្រោះថ្នាក់នារីដោយខ្យល់ព្យុះ | ១ដល់១២ |

| លេខរៀង | នាមអ្នកនិពន្ធ | ចំណងជើង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ៥ | សហ. លាង ហ៊ាប់អាន | ល្បងសិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ | ១ |
| ៦ | សហ. ឌឹក គាម | បិណ្ឌបាតកអង្គដំទឹក | ២ |
| ៧ | សហ. លី ធាមតេង | ការគិតនៃអ្នកនិពន្ធក្នុងការសាងជាតិ | ២ |
| ៨ | សហ. ញ៉ុក ថែម | ជីវប្រវត្តិរបស់លោក ញ៉ុក ថែម | ២ |
| ៩ | សហ. ស្ដើង ធ្បូរ | អ្នកតាពោធិអារក្ស | ២ |
| ១០ | សហ. ព្រួច កុម | រឿងសូត្រសាប់អកកំបោរប្រាក់ | ៣ |
| ១១ | ព្រះមហាព្រហ្មមុនី ឡុង ណារ ទីនព្រះធម្មកវីវង្សត្រុង ឈួន | ជីវប្រវត្តិសម្ដេចមង្គល ទេពាចារ្យ កែវ អ៊ុប | ៣ |
| ១២ | សហ. លី ធាមតេង | ពិធីដង្ហែក្បួនព្រះត្រ័យបិដក | ៤ |
| ១៣ | សហ. ឌឹក គាម | វប្បធម៌មន ខ្មែរ | ៥ |
| ១៤ | - ហែល សុំផា | របៀបរៀបចំខាងតុលាការ | ៦ |
| ១៥ | - ក៉យ ប៊ុក | ការប្រយុទ្ធ នឹង មធ្យោបាយ ដោះស្រាយសេចក្ដីល្ងង់ | ៦ |
| ១៦ | - ឌឹក គាម | បិណ្ឌបាតក្រពះគោ | ៦ |
| ១៧ | - ញ៉ុង សឿង | ពាក្យកាព្យព្រីបតុមុខ | ៧ |
| ១៨ | - ហ៊ុន សារី | ប្រវត្តិភូមិក្បាលអ្នក ឬ ប៊ូអង់ | ៧ |

| លេខរៀង | នាមអ្នកនិពន្ធ | ចំណងជើង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ១៩ | សហ លី ធាមតេង | ល្បើកអក (របស់លោកបម្រើឧទ័យ) | ៣ ដល់ ១១ |
| ២០ | - ឌឹក គាម | កវិទ្រូបណ្ឌិត | ៧ |
| ២១ | - លី ធាមតេង | ចំនុកច្រៀងបុរាណខ្មែរ | ៩ |
| ២២ | ព្រះមហាប៉ាង ខាត | វប្បធម៌សំស្ក្រឹត | ៩ |
| ២៣ | លោក ឋាន តេង | សប្បុរិសធម៌ ៧ ប្រការ (ពាក្យកាព្យ) | ៩ |
| ២៤ | លោក ផេង ជ្រីវ | ការផ្លាស់ប្ដូរប្រពៃណីក្នុងរឿងរកគូស្រករ | ១០ |
| ២៥ | - ញ៉ុង សឿង | ចម្រៀងបញ្ចសីខគន្ធព្វទេវបុត្រ | ១០ |
| ២៦ | - លី ធាមតេង | កម្រងចំនុកចម្រៀងបុរាណខ្មែរ | ១០ |
| ២៧ | - ហាប រិត | អំពីសត្វចិញ្ចឹម ( សត្វគោ ) | ១២ |
| ២៨ | អ្នកស្រី ពេជ សល់ | ប្រវត្តិគ្រូកេង ហៅគ្រូង៉ុយនៅកំពង់ចាម | ១២ |


## ៣-ផ្នែកកំណត់-ប្រវត្តិការណ៍


| | | | |
|---|---|---|---|
| ១ | | ពុតហ្វាយអគ្គនាយកដ្ឋាននៃក្រសួងវាំង ក្នុងព្រះបរមរាជវាំង | ១ |

| លេខរៀង | នាមអ្នកនិពន្ធ | បំណងរឿង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ២ | ការិយាល័យ- ទំនៀមទម្លាប់ | ប្រកាសប្រឡងទំនៀមទម្លាប់ខ្មែរ | ១ |
| ៣ | សហ.លី-ធាមតេង | អនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃលើកទី២៤ | ១ |
| ៤ | ង.ឱ.អ៊ឹងហុងសាធ | សារាចរលេខ ២០ កជ ស្ដីពីសាមគ្គីធម៌ | ២ |
| ៥ | ភិក្ខុ ប៊ុន-ចុល | បុណ្យបូជាសពព្រះតេជព្រះគុណ ជួន ផន អាចារ្យកម្មដ្ឋាន | ៥ |
| ៦ | | វិធីប្រគល់ព្រះត្រៃបិដកខ្មែរ ចំពោះ មជ្ឈមណ្ឌលព្រះពុទ្ធសាសនា នៅ ប្រទេសអាល្លឺមង់ខាងកើត | ៥ |
| ៧ | សហ.លី-ធាមតេង | ពិធីនមស្ការព្រះសក្យមុនីចេតិយ | ៥ |
| ៨ | | សេចក្ដីអំពាវនាវពីវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ | ៥ |
| ៩ | | ប្រកាសប្រឡងប្រជែង ទំនៀមទម្លាប់ខ្មែរ ឆមាសទី ២ ១៩៦៩ | ៦ |

| លេខរៀង | នាមអ្នកនិពន្ធ | ចំណងជើង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ១០ | សហ. ម៉ែន ចន់ | ប្រវត្តិភូមិនិងកោះនានានៅខែត្រ កោះកុង | ៦ដល់៨ |
| ១១ | ទំនៀមទម្លាប់ | ប្រកាសលទ្ធផលប្រឡងទំនៀមទម្លាប់ ឆមាសទី១ | ៧ |
| ១២ | សហ. លី-ធាមតេង | ពិធីបូជាសពព្រះសុមេធាវង្ស ព្រាជ្ញ ប៉ុល | ៨ |
| ១៣ | -ដ- | ពិធីប្រគេនព្រះរាជអំណោយ សម្ដេចនុ | ៨ |
| ១៤ | | ចុតហ្មាយសហ. ឌី ទូចរដ្ឋលេខាធិការធម្មការ | ១០ |
| ១៥ | គណៈកម្មការបុណ្យ | ព្រះរាជជីវប្រវត្តិនៃសម្ដេចព្រះសង្ឃរាជ | ១០ |
| ១៦ | ក្រសួងធម្មការ | ព្រះរាជក្រឹត្យតែងតាំងសម្ដេចព្រះសុមេធាធិបតីសង្ឃនាយក ហួត តាត | ១១ |
| ១៧ | ក្រសួងសង្ឃនាយក | ព្រះសង្ឃដីកា នៃសម្ដេចព្រះសង្ឃនាយកគណៈមហានិកាយស្ដីពីការប្រែប្រសាមគ្គី | ១២ |

| លេខរៀង | នាមអ្នកនិពន្ធ | ចំណងជើង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ១៨ | លោក លី ធាមតេង | បុគ្គលិកវិជ្ជាបាទពុទ្ធសាសន-បណ្ឌិត្យគោរពព្រះបរមសពសម្ដេចព្រះសង្ឃរាជ | ១២ |